# កម្ពុជាលើផ្លូវបំបែក

## ការពង្រឹងគណនេយ្យភាព ដើម្បីកាត់បន្ថយភាពក្រីក្រ



រៀបរៀងដោយធនាគារពិភពលោក សហការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ

សំរាប់កិច្ចប្រជុំក្រុមពិគ្រោះយោបល់

ភ្នំពេញ ថ្ងៃ ទី ៦ ‐ ៧ ខែ ធ្នូ ឆ្នាំ ២០០៤

**របាយការណ៍លេខ** 30636-kh

# កម្ពុជាលើផ្លូវបំបែក
## ការពង្រឹងគណនេយ្យភាព ដើម្បីកាត់បន្ថយភាពក្រីក្រ

**ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០០៤**

**ប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក**

**ឯកសាររបស់ធនាគារពិភពលោក**

# រូបិយវត្ថុ និងអត្រាប្តូរប្រាក់

រូបិយវត្ថុ - កម្ពុជា គឺរៀល

អត្រាប្តូរប្រាក់ ( គិតនៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ) CR/US$ 4,030/1

## ឆ្នាំសារពើពន្ធ

## (ថ្ងៃទី ១ ខែ មករា ដល់ ថ្ងៃទី ៣១ ខែធ្នូ)

| | |
|---|---|
| អនុប្រធានធនាគារពិភពលោកប្រចាំតំបន់: | លោក ជីមីល អ៊ូឌីនកាស៊ុម |
| នាយកធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា: | លោក អៀន ផតធើរ |
| ប្រធានគ្រប់គ្រង និង ប្រធានការងារនេះ : | លោកស្រី នីសា អាក្រាវ៉ាល |

# អក្សរកាត់

| | | |
|---|---|---|
| ADD | : | បង្កើនល្បឿននៃការអភិវឌ្ឍស្រុក |
| ADESS | : | ការគាំទ្រការអភិវឌ្ឍកសិកម្មដល់សិលា |
| ADHOC | : | សមាគមសិទ្ធិមនុស្ស និងការអភិវឌ្ឍកម្ពុជា |
| APR | : | របាយការណ៍រីកចំរើនប្រចាំឆ្នាំ |
| ASEAN | : | សមាគមជាតិអាស៊ីអាគ្នេយ៍ |
| ATC | : | កិច្ចព្រមព្រៀងវាយនភណ្ឌ និងសំលៀកបំពាក់ |
| BMOs | : | អង្គការសមាជិកភាពជំនួញ |
| BOT | : | សាងសង់-អនុវត្ត-ផ្ទេរ |
| C/SC | : | ក្រុមប្រឹក្សាឃុំ /សង្កាត់ |
| C/SF | : | មូលនិធិឃុំ /សង្កាត់ |
| C/SF Board | : | ក្រុមប្រឹក្សាភិបាលឃុំ /សង្កាត់ |
| CAR | : | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| CDC | : | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDRI | : | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា |
| COM | : | ក្រុមប្រឹក្សារដ្ឋមន្ត្រី |
| CPIA | : | ការវាយតំលៃរបស់ធនាគារពិភពលោកចំពោះគោលនយោបាយ និងស្ថាប័នរបស់ប្រទេស |
| DDC | : | គណៈកម្មាការអភិវឌ្ឍន៍ស្រុក |
| DWF | : | នាយកដ្ឋានរុក្ខាប្រមាញ់ និងសត្វព្រៃ |
| DISHA | : | គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សំរាប់សកម្មភាពសង្គម និងធនធានមនុស្ស |
| FBC | : | គណៈកម្មាការហិរញ្ញវត្ថុនិងធនាគាររដ្ឋសភា |
| HIPC | : | ប្រទេសក្រីក្រដែលមានប្រាក់បំណុលខ្ពស់ |
| HRMIS | : | ទិន្នន័យរបស់ CAR |
| IFAPER | : | ការវាយតំលៃលើការប្រើប្រាស់ថវិកាអោយចំគោលដៅរួម និងការពិនិត្យមើលការចំណាយសាធារណៈ |
| MDGs | : | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ |
| MEF | : | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MFA | : | កិច្ចព្រមព្រៀងពហុភាគីលើសសៃអំបោះ |
| MFU | : | អង្គភាពព្រៃឈើក្រុង |
| MoE | : | ក្រសួងបរិស្ថាន |
| MOEYS | : | ក្រសួងអប់រំ យុវជន និងកីឡា |
| MOH | : | ក្រសួងសុខាភិបាល |
| MOI | : | ក្រសួងមហាផ្ទៃ |
| MPTC | : | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| NAA | : | អាជ្ញាធរសវនកម្មជាតិ |
| NCSC | : | គណៈកម្មការជាតិគាំទ្រឃុំ សង្កាត់ |
| NGO | : | អង្គការមិនមែនរដ្ឋាភិបាល |
| NPRS | : | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| NPV | : | តំលៃពិតបច្ចុប្បន្ន |
| NT | : | រតនាគារជាតិ |
| ODA | : | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| OECD | : | អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍ សេដ្ឋកិច្ច |
| PAP | : | កម្មវិធីសកម្មភាពអាទិភាព |
| PBC | : | គណៈកម្មការផែនការ និងថវិកា |
| PCB | : | ស្ថាប័នសំរបសំរួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងតុលាការ |
| PDRD | : | បន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |
| PIF | : | មូលនិធិវិនិយោគខេត្ត |

| | | |
|---|---|---|
| PIP | : | កម្មវិធីវិនិយោគសាធារណៈ |
| PIUs | : | អង្គភាពប្រតិបត្តិការគំរោង |
| PFM | : | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PLUAC | : | គណៈកម្មាការប្រើប្រាស់ និងចែកចាយដី |
| PLUP | : | ការកសាងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម |
| PMATU | : | អង្គភាពតាមដានភាពក្រីក្រ និងវិភាគបច្ចេកទេស |
| PPFM | : | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយមានការចូលរួម |
| PPI | : | ការចូលរួមរបស់វិស័យឯកជនក្នុងហេដ្ឋារចនាសម្ព័ន្ធ |
| PT | : | រតនាគារខេត្ត |
| RS | : | យុទ្ធសាស្ត្រចតុកោណ |
| SARS | : | ជំងឺប្រព័ន្ធដកដង្ហើម |
| SCM | : | ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម |
| SEDP II | : | ផែនការអភិវឌ្ឍន៍ សង្គមសេដ្ឋកិច្ចលើកទី២ |
| SFMPs | : | យុទ្ធសាស្ត្រផែនការគ្រប់គ្រងព្រៃឈើ |
| SWIM | : | ការគ្រប់គ្រងវិស័យចំរុះ |
| TA | : | ជំនួយបច្ចេកទេស |
| TWGs | : | ក្រុមការងារបច្ចេកទេស |
| VAT | : | អាករលើតំលៃបន្ថែម |
| VDCs | : | គណៈកម្មការអភិវឌ្ឍន៍ភូមិ |

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ ទទួលបានការណែនាំ និង វិភាគទានដ៏ឧត្តុងឧត្តមដែលមិនអាចកាត់ថ្លៃបានពី ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ប្រធាន **SNEC** និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ យើងខ្ញុំជាក្រុមការងារ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមចំណែកដ៏ថ្លៃថ្លារបស់បណ្ឌិត **ហង់ ជួនណារ៉ុន** អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **វង្សី វិស្សុត** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **សុន គន្ធរ** អនុប្រធាន **SNEC** ឯកឧត្តម **ច័ន្ទ តុងអ៊ីវ** រដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម សុខ ចិន្តា អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តម **ឈៀង យ៉ាណារ៉ា** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តម **ជូ វិចិត្រ** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **សក់ សេដ្ឋា** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បណ្ឌិត **សុខ សាវ៉ារុធ** អនុប្រធានអង្គភាពគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង លោក **កុយ សារឹម** នាយករងនៃនាយកដ្ឋានរដ្ឋបាលទូទៅនៃក្រសួងមហាផ្ទៃ ។

ទន្ទឹមនឹងនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណដោយស្មោះស្ម័គ្រចំពោះ លោក **Shyam Bajpai** (ធនាគារអភិវឌ្ឍន៍អាស៊ី) លោក **Douglas Gardner** (ប្រធានកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា) និង លោក **Philip Marker** (**UK DFID**) ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យរបាយការណនេះ។ យើងខ្ញុំ ក៏សូមថ្លែងអំណរគុណចំពោះលោកស្រី **Beate Trankmann** (កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ) កញ្ញា **Aissata De** (កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ) លោក **Saku Akmeemana** (**OHCHR**) លោក **Henrik Alffram** (**OHCHR**) លោក **Chris Price** (**DFID**) និងលោក **Mogens Christensen** (**DANIDA**) បានជួយផ្តល់ជាយោបល់ និង វិភាគទានដ៏សំខាន់សំរាប់របាយការណ៍នេះ ។

របាយការណ៍នេះ បានរៀបចំឡើង ដោយមានការសំរបសំរួល និង ការណែនាំរួមពីលោក **Sarwar Lateef** ទីប្រឹក្សាផ្នែកអភិបាលកិច្ចប្រចាំធនាគារពិភពលោកនៅកម្ពុជា ។ របាយការណ៍នេះ ចែកចេញជាច្រើនផ្នែក ក្នុងនោះមាន ទស្សនះរួម រៀបរៀងដោយ លោក **Sarwar Lateef** ជំពូកទី ១ រៀបរៀងដោយ លោក

Robert Hagemann (មូលនិធិរូបិយវត្ថុអន្តរជាតិ) ជំពូកទី ២ រៀបរៀងដោយ លោក Robert Taliercio (PREM) ជំពូកទី ៣ រៀបរៀងដោយ លោកស្រី Louise Scura (ផ្នែកអភិវឌ្ឍន៍ជនបទ) ជំពូកទី ៤ រៀបរៀង ដោយ លោក Steven Schonberger (ផ្នែកអភិវឌ្ឍន៍ជនបទ) ជំពូកទី ៥ រៀបរៀងដោយលោក Magdi Amin (ផ្នែកអភិវឌ្ឍន៍វិស័យឯកជន) ជំពូកទី ៦ រៀបរៀងដោយលោក Tim Conway (PREM) លោកស្រី Mia Hyun (PREM) និង លោក Marcos Van Den Boogard (WBI) ហើយនិង ឧបសម្ព័ន្ធទាក់ទងនឹងទិន្នន័យ ត្រូវបានរៀបរៀងដោយលោក ជា ហួត (PREM) ។

ព័ត៌មាន និង ទិន្នន័យសំរាប់បញ្ចូលក្នុងរបាយការណ៍នេះ ទទួលបានពីបុគ្គលិកដទៃទៀតនៃការិយាល័យធនាគារពិភពលោក ក្នុងនោះរួមមាន លោក Eric Haythorne (ផ្នែកច្បាប់) លោកស្រី Gillian Brown (ផ្នែកអភិវឌ្ឍន៍សង្គម) លោកស្រី **និល វណ្ណា** (ផ្នែកអភិវឌ្ឍន៍សង្គម) លោក **ជា ហួត** (PREM) លោក **បេង ស៊ីម៉េត** (ផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស) លោកស្រី **ចំរើន មុនិតា** (ផ្នែកអភិវឌ្ឍន៍ជនបទ) លោក **ប៊ុន វាសនា** (ផ្នែកហេដ្ឋារចនាសម្ព័ន) និង លោកស្រី **សំអឿន សុភីនិត** (ជំនួយការផ្នែកព័ត៌មានសាធារណៈ) ។ ជាមួយគ្នានេះដែរ លោក Ian Porter (នាយកធនាគារពិភពលោកប្រចាំកម្ពុជា) លោកស្រី Nisha Agrawal (ប្រធានផ្នែកគ្រប់គ្រងធនាគារប្រចាំកម្ពុជា) និង លោក Kazi Mahbub-Al-Matin (អ្នកសេដ្ឋកិច្ចឈានមុខនៅកម្ពុជា) ក៏បានផ្តល់នូវការណែនាំទូទៅសំរាប់ការរៀបចំរបាយការណ៍នេះ ។

លោក David Vannier (JPA) នៅការិយាល័យប្រចាំកម្ពុជា បានសំរបសំរួលដល់ការពិនិត្យកែសំរួល និងរៀបចំរបាយការណ៍ជាភាសា អង់គ្លេស និង លោក **ប៊ូ សារឿន** (អ្នកឯកទេស ខាងទំនាក់ទំនងព័ត៌មាន) ក៏បានសំរបសំរួលដល់ការពិនិត្យកែសំរួលនិងការរៀបចំរបាយការណ៍នេះជាភាសាខ្មែរ ។ លោកស្រី **អ៊ូ ណារីយ៉ា** អ្នកស្រី **ខៀវ អមរា** លោក **សាក់ សម្បត្តិ** លោក **ម៉ក់ ថូល** និង អ្នកស្រី Zelena Jagdeo ក៏បានរួមចំណែកជួយរៀបចំរបាយការណ៍នេះដែរ ។

**មាតិកា** **ទំព័រ**


សេចក្តីដកស្រង់ ........ i

**សេចក្តីសង្ខេប ........ ១**

ក - សារតារ ........ ៣

ខ - ក្របខ័ណ្ឌអភិបាលកិច្ច និងគណនេយ្យភាពរបស់កម្ពុជា ........ ៧

គ - កំណែទំរង់ជាអាទិភាព ........ ១៧

ឃ - ការពង្រឹងការត្រួតមើលនិងតុល្យភាព តាមរយៈកំណែទំរង់វិស័យយុត្តិធម៌ ........ ២០

ង - ការកែលំអគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ ........ ២៥

ច - វិមជ្ឈការៈ ជំរុញអោយរដ្ឋាភិបាលមានភាពជិតស្និទនិងប្រជាពលរដ្ឋ ........ ៣០

ឆ - ការគ្រប់គ្រងធនធានធម្មជាតិសំរាប់ផលប្រយោជន៍សាធារណៈ ........ ៣២

ជ - ការលុបបំបាត់ឧបសគ្គផ្នែកអភិបាលកិច្ចដើម្បីការវិនិយោគនិងកំណើន ........ ៣៦

ឈ - សេចក្តីសន្និដ្ឋាន ........ ៣៩

**ជំពូកទី ១ ........ ៤៧**

ក - ស្ថានភាពកំណើន ........ ៥០

ខ - ស្ថានភាពសារពើពន្ធ ........ ៥២

គ - រចនាសម្ព័ន្ធជាឧបសគ្គដល់កំណើននិងកាត់បន្ថយភាពក្រីក្រ ........ ៥៤

ឃ - ការប្រមើលមើលក្នុងរយៈពេលមធ្យម ........ ៥៥

**ជំពូកទី ២ ........ ៦១**

ក - លើកកំពស់ការគៀងគរធនធាន ........ ៦៣

ខ - ការរៀបចំ ចំណាយសាធាណៈចំពោះការកាត់បន្ថយភាពក្រីក្រ ........ ៦៥

គ - ការកាត់បន្ថយហានិភ័យផ្អែកលើជំនឿទុកចិត្តចំពោះមូលនិធិ ........ ៦៨

ឃ - កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ៧៤

ង - ការកែទំរងមុខងារសាធារណៈរបស់កម្ពុជា ........ ៧៦

ច - សេចក្តីសន្និដ្ឋាន ........ ៨០

**ជំពូកទី ៣** **៨៣**

ក - ការចាប់ផ្ដើម........ ៨៦

ខ - ឆ្ពោះទៅរកយុទ្ធសាស្ត្រ និងទស្សនៈយូរអង្វែង........ ៩១

គ - ពង្រឹងក្របខ័ណ្ឌទទួលខុសត្រូវនៅថ្នាក់អនុជាតិ........ ៩៥

ឃ - បង្កើនកំរិតនិងលទ្ធភាពព្យាករណ៍ធនធានដែលមានសំរាប់ថ្នាក់ អនុជាតិ........ ១០៣

ង - ពង្រីកសមត្ថភាព និងគុណភាពនៃការគាំទ្រនៅថ្នាក់អនុជាតិ........ ១០៩

ច - សេចក្ដីសន្និដ្ឋាន........ ១១០

**ជំពូកទី ៤** **១១៣**

ក - សារៈសំខាន់របស់ធនធានធម្មជាតិ........ ១១៧

ខ - រដ្ឋជាអ្នកគ្រប់គ្រងធនធាន និងបទពិសោធន៍ទទួលបាន........ ១២១

គ - ពង្រឹងមូលដ្ឋានគ្រឹះសំរាប់លើកកំពស់ការគ្រប់គ្រងធនធានធម្មជាតិ........ ១២៨

ឃ - ការពង្រីកតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ន........ ១៣៣

ង - ការសំឡឹងមើលទៅអនាគត់: ផលប្រយោជន៍ដើម្បីការទទួលខុសត្រូវរួម........ ១៣៧

ច - ដោះស្រាយបញ្ហាប្រឈមជាបន្ទាន់ដើម្បីការពារធនធានធម្មជាតិ........ ១៤៤

ឆ - សេចក្ដីសន្និដ្ឋាន........ ១៤៥

**ជំពូកទី ៥** **១៤៩**

ក - មូលហេតុដែលអភិបាលកិច្ចជាបញ្ហាចោទ ........ ១៥២

ខ - ការកែលំអបរិយាកាសខាងបញ្ញត្តិ ........ ១៥៥

គ - ការបង្កើតស្ថាប័នគាំទ្រទីផ្សារដែលអាចជឿជាក់បាន ........ ១៦០

ឃ - តម្លាភាពនិងការប្រកួតប្រជែងក្នុងភាពជាដៃគូរវាងឯកជន-សាធារណៈ ........ ១៦៣

ង - ការអភិវឌ្ឍក្រុម និងស្តង់ដារបទដ្ឋាន ........ ១៦៩

ច - ពីការត្រួតត្រាទៅជាការសំរបសំរួល : ធាតុសំខាន់៧នៃកំណែទំរង់ ........ ១៧១

សេចក្តីសន្និដ្ឋាន ........ ១៧៣

**ជំពូកទី ៦** **១៧៧**

ក - ជំនួយអភិវឌ្ឍន៍ និងបញ្ហាអភិបាលកិច្ចរបស់ប្រទេសកម្ពុជា ........ ១៨៣

ខ - កិច្ចខិតខំប្រឹងប្រែងដើម្បីកែទំរង់ជំនួយក្នុងឆ្នាំ២០០៤ ........ ១៨៧

គ - ចលនាឆ្ពោះទៅរកគណនេយ្យភាពទៅវិញទៅមក : របៀបវារៈ

នៃកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍សំរាប់ឆ្នាំ២០០៥ ........ ១៩២

ឃ - ពង្រឹងក្រុមការងារបច្ចេកទេស ........ ១៩៦

ង - ពិនិត្យតាមដានប្រសិទ្ធិភាពជំនួយ និងការអនុវត្តរបស់សមាគមន៍ ........ ១៩៨

ច - សមាគមផ្តល់ជំនួយ និងអភិបាលកិច្ច ........ ២០២

ឆ - តើដៃគូអភិវឌ្ឍន៍អន្តរជាតិរបស់កម្ពុជា គួរឆ្លើយតបបែបណា ដើម្បីជំរុញអោយមាន

អភិបាលកិច្ចល្អប្រសើរជាងមុននៅកម្ពុជា ........ ២០៣

# សេចក្តីដកស្រង់

១. រាជរដ្ឋាភិបាលកម្ពុជា ទើបតែអនុម័តយុទ្ធសាស្ត្រចតុកោណ ដើម្បីជំរុញអោយមាន កំណើនសេដ្ឋកិច្ច ការងារ សមធម៌ និង ប្រសិទ្ធិភាពនៅកម្ពុជា ។ យុទ្ធសាស្ត្រនេះ បានកំណត់ថា អភិបាលកិច្ច គឺជា ល័ក្ខខ័ណ្ឌ ដំបូងដែលមានសារៈសំខាន់បំផុតចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា ។ របៀបវារៈសំរាប់កិច្ចប្រជុំក្រុម ពិគ្រោះយោបល់ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ៦ ដល់ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ២០០៤ ត្រូវបាន រៀបចំឡើងជុំវិញ យុទ្ធសាស្ត្រចតុកោណនេះ ហើយការពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់នេះ នឹងផ្តោតការយក ចិត្តទុកដាក់ទៅលើគោលនយោបាយសំខាន់ៗ និង ការវិនិយោគដែលមាន គោលដៅសំរេចអោយបាននូវ ចក្ខុវិស័យមួយ ដើម្បីអោយកម្ពុជា កាន់តែសម្បូររុងរឿង និង មានអភិបាលកិច្ចប្រសើរ ដូចមានចែងនៅក្នុង យុទ្ធសាស្ត្រនោះ ។

២. របាយការណ៍សង្ខេបសំរាប់កិច្ចប្រជុំពិគ្រោះយោបល់នេះ ផ្តោតជាសំខាន់ទៅលើភាពប្រឈមខាង អភិបាលកិច្ចជាគន្លឹះមួយចំនួនដែលកម្ពុជាកំពុងជួបប្រទះ ហើយមានបំណងផ្តល់នូវមូលដ្ឋានវិភាគ ដើម្បី សំរួលអោយមានការតស៊ូមតិនិងការពិភាក្សា លើបញ្ហាទាំងនោះ នៅពេលប្រជុំ ។ របាយការណ៍ ដែលមាន ចំណងជើងថា "កម្ពុជាលើផ្លូវបំបែក" បានអះអាងថា ដើម្បីអោយមានការកែប្រែខាងអភិបាលកិច្ច នៅ កម្ពុជា យើងនឹងត្រូវមានការងារយ៉ាងច្រើនលើសពីគោលនយោបាយដែលបានចែងនៅក្នុងយុទ្ធសាស្រ ចតុកោណ ដែលការនោះនឹងជួយគាំទ្រ ហើយមិនមែនបំផ្លាញដល់ដំណើរការអភិវឌ្ឍន៍ ។ អ្វីដែលយើងត្រូវ ការ គឺកិច្ចខិតខំប្រឹងប្រែងរួម ដើម្បីពង្រឹងមូលដ្ឋានគ្រឹះសំរាប់សង្វាក់គណនេយ្យកិច្ច ដែលពេលខ្លះ ទោះជា ត្រូវចាប់ផ្តើមពីចំនុចសូន្យក៏ដោយ ។ ការប្រឹងប្រែងកែទំរង់ទាំងនោះ ត្រូវការពេលវេលាដ៏យូរដើម្បីអនុវត្ត លើសពីអាណត្តិរដ្ឋសភា នីតិកាលទីបីទៅទៀត ។ ក៏ប៉ុន្តែប្រសិនបើមានការកែប្រែត្រលប់និន្នាការ អភិបាលកិច្ចបច្ចុប្បន្ន ហើយប្រសិនបើមូលដ្ឋានគ្រឹះអាចបង្កើតបានលើផ្នែកគន្លឹះមួយ ចំនួនក្នុងការជំរុញ គណនេយ្យភាព នោះមានន័យថា មានការចាប់ផ្តើមល្អហើយ ហើយនឹងផ្តល់ជាសញ្ញា ជាវិជ្ជមានដល់គ្រប់ ភាគីដែលចូលប្រឡូក នៅក្នុងសេដ្ឋកិច្ចមួយ ថាមានការផ្លាស់ប្តូរបៀបលេង ។

៣. របាយការណ៍រួមបញ្ចូលទាំងទស្សនៈរួម និងអមដោយប្រាំមួយជំពូក ។ ទស្សនៈរួម បានផ្តល់នូវការ ពណ៌នាត្រួសៗពីការរីកចំរើនថ្មីៗ ចំពោះការខិតខំប្រឹងប្រែងផ្នែកអភិវឌ្ឍន៍របស់កម្ពុជា ។ ផ្នែកនេះក៏បានបន្ត

ទៅពិពណ៌នាពីប្រពន្ធ័គណនេយ្យភាពសាធារណៈរបស់កម្ពុជា ហើយវិភាគពីហេតុផលនៃការដែលប្រព័ន្ធនេះមិនដំណើរការ ហើយដែលមានអ្នកក្រនិងអ្នកទន់ខ្សោយជាអ្នកខាតបង់ ។ ផ្នែកនេះ ផ្តល់ក្របខ័ណ្ឌមួយដើម្បីតាមដានពីវិធីដែលប្រជាពលរដ្ឋអាចចាប់អ្នកផ្តល់សេវាសាធារណៈ អោយទទួលខុសត្រូវដល់ការធ្វើអោយការផ្តល់សេវានោះកាន់តែប្រសើរឡើង ។ ការនេះមានទាំងផ្លូវវែង ដែលជាគណនេយ្យកិច្ចតាមរយៈអ្នកនយោបាយដែលខ្លួនបោះឆ្នោតអោយ ហើយតាមរូបភាពនោះ ចាប់អ្នកផ្តល់សេវាអោយទទួលខុសត្រូវ ហើយនិងតាមផ្លូវខ្លីដែលក្នុងនោះប្រជាពលរដ្ឋប្រមូលផ្តុំគ្នា ហើយទាមទារអោយមានសេវាកាន់តែប្រសើរពីសំណាក់មន្ត្រីសាធារណៈនិងអ្នកផ្តល់សេវាផ្សេងៗទៀត ។

៤. លើសពីនោះ របាយការណ៍នេះបានរៀបចំដូចតទៅ។ ជំពូក១ ផ្តល់ការវិភាគដែលបុគ្គលិកមូលនិធិរូបិយវត្ថុអន្តរជាតិបានធ្វើឡើង អំពីស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្នរបស់កម្ពុជា និងការរំពឹងទុកក្នុងរយៈពេលមធ្យម ដោយដកស្រង់ពី កិច្ចពិគ្រោះលេខទី៤ដែលចេញនាពេលថ្មីៗនេះរបស់ IMF ។ ជំពូក ២ តាមដានពីមូលហេតុដែលប្រជាពលរដ្ឋក្រីក្ររបស់កម្ពុជាមិនបានទទួលផលពីការចំណាយសាធារណៈ។ ជំពូកនេះផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលដើម្បីរៀបចំកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបនឹងភាពប្រឈមនេះ ហើយជំពូកនេះសង្កត់ធ្ងន់លើតម្រូវការអោយមានការអនុវត្តន៍កម្មវិធីកែទំរង់ដែលបានព្រមព្រៀងអោយបានឆាប់រហ័ស ។ ជំពូកទី ៣ អះអាងថាវិមជ្ឈការនិងសហវិមជ្ឈការ អាចជួយកែលំអជីវិតរបស់ប្រជាពលរដ្ឋទូទៅ ប្រសិនបើយើងផ្តោតលើការផ្តល់សេវាអោយបានកាន់តែប្រសើរ ដោយតាមរយៈការបង្កើនការចូលរួម ការបង្កើនការបញ្ចេញមតិយោបល់ និងជំរុញតម្លាភាព ហើយនិងបំព្រួញខ្សែសង្វាក់គណនេយ្យកិច្ច ចាប់ពីសហគមន៍មូលដ្ឋាន ទៅរដ្ឋាភិបាល ។ ជំពូកនេះ អះអាងថា ក្នុងខណៈដែលមានការរីកចំរើនលើវិមជ្ឈការ និង សហវិមជ្ឈការខាងមុខងាររដ្ឋមានការរីកចំរើនដ៏ស្ទួចស្តើង ។ ចក្ខុវិស័យសំរាប់ជំហានជាបន្តបន្ទាប់ទៅ លើវិមជ្ឈការនិងសហវិមជ្ឈការ គឺកំពុងតែរៀបចំ ។ ជំពូកទី ៤ លើកឡើងពីប្រធានបទដ៏តឹងតែងនៃការគ្រប់គ្រងធនធានធម្មជាតិ ហើយ អះអាងថា ទោះបីជាមានធនធានធម្មជាតិដ៏សម្បូរបែបធនធានកម្ពុជា ទាំងនេះ មិនត្រូវបានគេប្រើប្រាស់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសអ្នកក្រទេ ។ ប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិមួយប្រកបដោយការចូលរួម តម្លាភាពនិងគណនេយ្យភាព កំពុងតែមានតម្រូវការអោយបង្កើត ជាបន្ទាន់នៅកម្ពុជា។ ជំពូកទី ៥ ពិពណ៌នា អំពីភាពប្រឈមខាងអភិបាលកិច្ច ខាងវិស័យឯកជននៅកម្ពុជា ។

ជំពូកនេះទាមទារអោយវិធានការជាបន្ទាន់ ដើម្បីកាត់បន្ថយការចំនាយលើមការធ្វើជំនួញ ធ្វើដូច្នោះនឹងឆ្លើយតបទៅនឹងការចង់បានកំណើនសេដ្ឋកិច្ច ៦-៧ ភាគរយ សំរាប់បង្កើតការងារ និងការ កាត់បន្ថយភាពក្រីក្រ ដែលអាចរក្សាបានក្នុងរយៈពេលជាមធ្យមនៅពេលដែលកូតា (quota) នឹងត្រូវចប់នៅដំណាច់ឆ្នាំ ២០០៤ នេះ ។ ជាចុងបញ្ចប់ ជំពូកទី ៦ ផ្តោតលើបញ្ហាអភិបាលកិច្ចជុំវិញ ប្រសិទ្ធិភាពនិង ការគ្រប់គ្រងជំនួយនៅកម្ពុជា ។ ជំពូកនេះ អះអាងថា ក្នុងខណៈដែលមានការកែលំអនៅឆ្នាំ ២០០៤ ទម្លាប់ការងាររបស់អ្នកផ្តល់ជំនួយនៅកម្ពុជា មានទំហំមួយគួរអោយកត់សំគាល់ដែលតម្រូវអោយមានការកែលំអ ប្រសិនបើអ្នកផ្តល់ជំនួយត្រូវក្លាយជាផ្នែកមួយនៃដំណោះស្រាយជាជាងផ្នែកមួយនៃបញ្ហានោះ ។ ជាពិសេស កំរិតនិងប្រភេទនៃជំនួយ ចាំបាច់ត្រូវសំរបទៅតាមទាំងអទិភាពរបស់រដ្ឋាភិបាល និង ទាំងសមត្ថភាពការអនុវត្តន៍របស់គាត់ ។

# កម្ពុជា: លើផ្លូវបំបែក
# ទស្សនៈរួម

*"អភិបាលកិច្ចល្អ ជាលក្ខខណ្ឌដំបូងដ៏សំខាន់បំផុតមួយ សំរាប់ការការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចិរភាព សមធម៌ និងយុត្តិធម៌សង្គម ។ អភិបាលកិច្ចល្អ តំរូវអោយមាននូវការចូលរួមយ៉ាងទូលំទូលាយ ការចែករំលែកព័ត៌មានតាមបែប ជឿនលឿន គណនេយ្យភាព តម្លាភាព សមភាព ការមិនបោះបង់ចោលនូវបុគ្គលណាម្នាក់ និងនីតិរដ្ឋ ។ អភិបាលកិច្ចល្អ តំរូវអោយអំពើពុករលួយត្រូវបានកាត់បន្ថយដល់កំរិតអប្បបរមា ទស្សនៈរបស់មតិភាគតិច និង សំលេងរបស់អ្នកដែល ងាយទទួលរងគ្រោះបំផុតនៅក្នុងសង្គមត្រូវបានគេស្តាប់ និងយកទៅពិចារណានៅក្នុងដំណើរ ការនៃការធ្វើសេចក្តី សំរេចចិត្ត" ។*

*- យុទ្ធសាស្រ្តចតុកោណ ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជា[១]*

១. ក្រុមពិគ្រោះយោបល់សំរាប់ប្រទេសកម្ពុជា ជួបប្រជុំគ្នាក្នុងខណៈពេលមួយ ដែលជាពេលវេលាដ៏សំខាន់នៅ ក្នុងប្រវត្តិសាស្រ្តរបស់ប្រទេសនេះ ។ រដ្ឋាភិបាលថ្មី បានឈានចូលកាន់អំណាចបន្ទាប់មានភាពជាប់គាំងផ្នែកនយោបាយអូសបន្លាយនៅក្រោយការបោះឆ្នោត នាខែកក្កដា ឆ្នាំ២០០៣ កន្លងមក ។ ការអូសបន្លាយនេះ បានធ្វើអោយខាតបង់នូវកំលាំងជំរុញសំរាប់កំណែទំរង់ដែលត្រូវការចាំបាច់ ។ ប៉ុន្តែ ដំណើរការនេះបានបង្ក អោយមានវត្តមាននៃយុទ្ធសាស្រ្តចតុកោណនេះឡើង (RS) ដើម្បីឆ្លុះបញ្ចាំងអំពីការឯកភាពគ្នារវាងដៃគូនានានៅក្នុងរដ្ឋាភិបាលចំរុះ ហើយដំណើរនេះត្រូវបានកំនត់ថា ជា "ផែនការសកម្មភាពសំរាប់រយៈពេលបួន ឆ្នាំបន្ទាប់[២]" របស់រដ្ឋាភិបាលថ្មី ។ យុទ្ធសាស្រ្ត ថ្មីនេះ មានទិសដៅជាគន្លឹះចំនួនបួន : កំណើនសេដ្ឋកិច្ច ការបង្កើតការងារធ្វើអភិបាលកិច្ចដែលបានធ្វើអោយមានភាពប្រសើរឡើង និងការអនុវត្តការកែទំរង់ដោយ មានល្បឿនលឿននៅក្នុងគ្រប់វិស័យទាំងអស់ដើម្បី "កាត់បន្ថយភាពក្រីក្រ និងសំរេចនូវការអភិវឌ្ឍប្រកបទៅដោយចីរភាព" ។ អភិបាលកិច្ចល្អត្រូវគេចាត់ទុកថា ជាបេះដូងនៃយុទ្ធសាស្រ្តនេះ ។

២. យុទ្ធសាស្ត្រចតុកោណនេះ ត្រូវទទួលបានការស្វាគមន៍ ជាសញ្ញាដំបូងដែលបង្ហាញថា រដ្ឋាភិបាលថ្មីមានការប្តេជ្ញាចិត្តចំពោះដំណើរការកែទំរង់ ។ ក្នុងរយៈពេលមួយជំនាន់មនុស្ស កំណែទំរង់បែបនេះ អាចធ្វើអោយកែប្រែអនាគតរបស់ប្រជាពលរដ្ឋចំនួនពីរភាគបីនៃប្រជាពលរដ្ឋកម្ពុជា ដែលរស់នៅដោយពឹងផ្អែកលើប្រាក់ចំណូលតិច ជាង២ដុល្លារ ក្នុងមួយថ្ងៃ ។ ការបង្កើតបាននូវទ្រព្យសម្បត្តិបន្ថែមដ៏ច្រើនក្រាស់ក្រែលក៏អាចនឹងជួយបំពេញនូវ សេចក្តីរំពឹងទុកដែលកំពុងតែកើនឡើង របស់ប្រជាពលរដ្ឋដែលចង់បានច្រើនឡើងលើសពីសន្តិសុខផ្លូវកាយដែល សន្តិភាពបាននាំមកអោយពួកគេ ។ យុទ្ធសាស្ត្រនេះ គឺត្រឹមត្រូវទាំងស្រុងក្នុងការពន្យល់អភិបាលកិច្ចថា ជា "លក្ខខណ្ឌ ដំបូងដ៏សំខាន់បំផុតមួយសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច" ហើយវាគួរទទួលបានការលើកទឹកចិត្តអោយរដ្ឋាភិបាលយល់ឃើញថា បញ្ហានេះ គឺជាស្នូលនៃយុទ្ធសាស្ត្ររបស់ខ្លួន ។ អាស្រ័យហេតុនេះហើយ ទើបរបាយការណ៍សង្ខេបសំរាប់ក្រុមពិគ្រោះយោបល់ ផ្តោតជាសំខាន់លើបញ្ហាអភិបាលកិច្ចដែលប្រទេសកម្ពុជាកំពុងប្រឈមមុខ ។

៣. ប៉ុន្តែ វាតំរូវឱ្យមានលើសពីការដាក់ចេញជាគោលនយោបាយ នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដើម្បីប្រែក្លាយអភិបាលកិច្ចនៅកម្ពុជា សំរាប់ការជួយទ្រទ្រង់ និងការមិនបង្កឧបសគ្គដល់ដំណើរការអភិវឌ្ឍ ។ អ្វីដែលត្រូវការចាំបាច់នោះ គឺកិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយ ដើម្បីពង្រឹងគ្រឹះគណនេយ្យភាពជាសង្វាក់ទំនើប ហើយនៅក្នុងករណីជាច្រើន ត្រូវកសាងឡើងពីភាពទទេ ។ កំណែទំរង់បែបនេះ នឹងត្រូវការជាចាំបាច់នូវពេលវេលាដ៏វែង ដើម្បីអនុវត្ត គឺវែងជាងអាយុកាលនៃសភានីតិកាលទី៣ របស់កម្ពុជាទៅទៀត ។ ប៉ុន្តែ ប្រសិនបើនិន្នាការបច្ចុប្បន្ននៃអភិបាលកិច្ច អាចផ្លាស់ប្តូរបាន និងប្រសិនបើគ្រឹះជាច្រើនត្រូវបានគេចាក់នៅក្នុងវិស័យជាគន្លឹះមួយចំនួន ដើម្បីពង្រឹងគណនេយ្យភាពនោះ ការចាប់ផ្តើមដ៏ល្អប្រសើរមួយនឹងត្រូវសំរេចបាន និងសញ្ញាដ៏គួរអោយទុកចិត្តបានត្រូវគេបញ្ជូនទៅដល់គ្រប់អ្នកមានតួនាទីនៅក្នុងវិស័យសេដ្ឋកិច្ចពោលគឺអ្វីៗនឹងមានការផ្លាស់ប្តូរ ។ ជំពូកនេះ ផ្តល់នូវទស្សនៈរួមអំពីការវិវឌ្ឍន៍ នាពេលថ្មីៗកន្លងមកនៅក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍរបស់កម្ពុជា ។ បន្ទាប់មកទៀត ជំពូកនេះរៀបរាប់អំពីប្រព័ន្ធគណនេយ្យភាពសាធារណៈរបស់កម្ពុជា និងធ្វើការវិភាគថាតើមូលហេតុអ្វីបានជាប្រព័ន្ធនេះ មិនបានទទួលជោគជ័យក្នុងការជួយដល់ប្រជាជនក្រីក្រ និងប្រជាជនងាយទទួលរងគ្រោះរបស់ប្រទេសនេះ ស្របតាមការចំណាយនេះ ។

៣. ជំពូកនេះ បញ្ចប់ដោយសេចក្ដីសង្ខេបអំពីវិស័យកំណែទំរង់សំខាន់ៗចំនួនប្រាំ ដែលនឹងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើកំណើន និងភាពក្រីក្រ ។ ជំពូកនេះអះអាងថា ការបោះជំហានយ៉ាងស្វាហាប់នៅលើរបៀបវារៈកំណែទំរង់អភិបាលកិច្ចមួយ ដែលមានមូលដ្ឋានយ៉ាងរឹងមាំនៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដ៏ទូលំទូលាយ នឹងបង្កើតបានជាកំលាំង ជំរុញជាវិជ្ជមានដ៏រឹងមាំមួយ សំរាប់ការកាត់បន្ថយភាពក្រីក្រ ។

## ក. សាវតារ

## កម្ពុជាបានធ្វើអោយមានការវិវឌ្ឍន៍គួរអោយចាប់អារម្មណ៍ ប៉ុន្តែនៅតែប្រឈមមុខនឹងបញ្ហាសំខាន់ៗជាច្រើន

៥. របាយការណ៍ក្រោយពេលជម្លោះរបស់ប្រទេសកម្ពុជា មានលក្ខណៈច្របូកច្របល់ ។ ផ្ទុយទៅវិញ គេក៏សង្កេតឃើញមានការរីកចំរើនមួយចំនួន ដ៏គួរអោយចាប់អារម្មណ៍ផងដែរនៅក្នុងវិស័យមួយចំនួន ។ ការរៀបចំការបោះឆ្នោតដែលហាក់ដូចជាប្រកបដោយសន្តិភាព និងត្រឹមត្រូវយុត្តិធម៌ ត្រូវបានរៀបចំឡើងចំនួនបីលើរួចមកហើយ ។ សន្តិភាព ស្ថិរភាព និងអារម្មណ៍ធម្មតា ត្រូវបានបង្កើតអោយមានឡើងវិញ ។ ស្ថាប័នលទ្ធិប្រជាធិបតេយ្យ កំពុងចាប់ផ្តើមតំណើរការ ។ បណ្តាញសង្គមស៊ីវិលកំពុងរីករាលដាល ហើយប្រព័ន្ធសារព័ត៌មានដែលនៅមិនទាន់មានការអភិវឌ្ឍនឡើយ ក៏កំពុងចាប់ផ្តើមប្រើប្រាស់សេរីភាពដែលទើបទទួលបានថ្មីៗរបស់ខ្លួនផងដែរ ។ ជាមួយនឹងការបោះឆ្នោតឃុំ/សង្កាត់នាពេលថ្មីៗកន្លងមកនេះ កិច្ចប្រឹងប្រែងបណ្តោះអាសន្ន តែគួរអោយចាប់អារម្មណ៍ក្នុងការ ផ្សព្វផ្សាយលទ្ធិប្រជាធិបតេយ្យទៅដល់រដ្ឋាភិបាលមូលដ្ឋាន ក៏បានចាប់ផ្តើមឡើង ។

៦. ចំណែកឯផ្នែកសេដ្ឋកិច្ចវិញ ប្រទេសកម្ពុជារហូតមកទល់នឹងពេលថ្មីៗនេះ បានទទួលនូវកំណើនដែលមានសន្ទុះដ៏ខ្លាំងក្លា បើទោះបីជាមិនមានតុល្យភាពក៏ដោយ ។ លទ្ធភាពអនុគ្រោះក្នុងការនាំចូលទៅទីផ្សារសំលៀកបំពាក់កាត់ដេររបស់សហរដ្ឋអាមេរិក បាននាំមកនូវកំណើនដ៏ក្រាស់ក្រែលដល់ការនាំចេញរបស់កម្ពុជា ។ កំណើននៃការនាំចេញផលិតផលសំលៀកបំពាក់កាត់ដេរ ការរស់ឡើងវិញនៃវិស័យទេសចរណ៍ ជំនួយដ៏សំខាន់ដែលកម្ពុជាបានទទួល និងការប្រសើរឡើងវិញពីជំលោះ បានរួមចំណែកធ្វើអោយមានការរីកចំរើននូវអត្រាកំណើនជាមធ្យម ៦,៧ភាគរយ ក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ១៩៩០ និងឆ្នាំ២០០២ ។ ស្ថិរភាព

ម៉ាក្រូសេដ្ឋកិច្ច ត្រូវរក្សាបានតាមរយៈគោលនយោបាយសារពើពន្ធ និងកិច្ចប្រឹងប្រែងរកប្រាក់ចំណូលដែលបានក៏រិតទាប តែកំពុងតែមានភាពប្រសើរឡើង ។ នៅលើឆាកអន្តរជាតិវិញ ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ថ្មីៗនេះរបស់ប្រទេសកម្ពុជា គឺពុំទាន់អាចចាត់ទុកថា ជាសញ្ញាដែលថាប្រទេសនេះបានត្រលប់ចូលទៅលើឆាកអន្តរជាតិវិញឡើយ ។ កំណែទំរង់រចនាសម្ព័ន្ធក្នុងប៉ុន្មានឆ្នាំចុងក្រោយ របស់រដ្ឋាភិបាលមុននេះ បានរួមវិភាគទានយ៉ាងច្រើនដល់ការសំរេចបានលទ្ធផលល្អគួរសមនេះ ។

៧. ការអភិវឌ្ឍន៍ដែលប្រកបដោយភាពអនុគ្រោះទាំងនេះ បានបិទបាំងនូវបញ្ហាសំខាន់ៗចំនួនបីចំពោះរដ្ឋាភិបាលថ្មី។ ទីមួយ ការរីកចំរើនត្រូវគំរាមគំហែងយ៉ាងធ្ងន់ធ្ងរ ក្នុងរយៈពេលខ្លី ទៅមធ្យម ។ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានធ្វើការព៉ានប្រមានថា កំណើននឹងធ្លាក់ចុះយ៉ាងខ្លាំងដល់២ភាគរយ នៅក្នុងឆ្នាំ២០០៥ រួចមានភាពប្រសើរឡើងបន្តិចម្តងៗ រហូតដល់ ៦ ទៅ ៦.៥ ភាគរយមុនឆ្នាំ២០០៩ ហើយដំណើរនេះ នឹងកើតមានលុះណាតែកម្ពុជា ចាប់ដំណើរការកំណែទំរង់ដែលលើកស្ទួយភាពប្រកួតប្រជែង និងបរិយាកាសសំរាប់វិនិយោគទុន ។ ការថយចុះនៃកំណើន ឆ្លុះបញ្ចាំងអំពីការវិវឌ្ឍន៍យ៉ាងយឺតៗ ក្នុងការងារកំណែទំរង់រចនាសម្ព័ន្ធក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហើយការលុបចោលនូវប្រព័ន្ធកូតាក្រោមកិច្ចព្រមព្រៀងវាយភណ្ឌចំរុះ (Multi Fiber Agreement) ដែលនឹងរឹតតែដាក់ក្រុមហ៊ុននាំចេញរបស់កម្ពុជាអោយប្រឈមនឹងការប្រកួតប្រជែងដ៏ខ្លាំងក្លាជាមួយក្រុមហ៊ុនដែលមានលក្ខណៈប្រកួតប្រជែងជាង។ ដូច្នេះវាតំរូវមានការអនុវត្តន៍កំណែទំរង់ជាបន្ទាន់នូវអភិបាលកិច្ច និងរចនាសម្ព័ន្ធ ។

៨. ទីពីរ ភាពក្រីក្រដែលគិតតាមប្រាក់ចំណូលនៅតែខ្ពស់ (ប្រហែល ៤០ ភាគរយ) ហើយគ្មានការថមថយឡើយ ។ ទីផ្សារពលកម្មក៏មិនមានលទ្ធភាពស្រូបយកកំលាំងពលកម្ម ភាគច្រើននៃចំនួនមនុស្ស ២០០.០០០ នាក់ ដែលទើបតែចូលក្នុងទីផ្សារថ្មីៗ ។ សំរាប់ភាពក្រីក្រដែលមិនគិតតាមប្រាក់ចំណូល ប្រវត្តិរបស់វាមានភាពលាយឡំគ្នាច្រើន ។ ប្រទេសកម្ពុជា មើលទៅហាក់ដូចជាងាកចេញពីផ្លូវទៅសំរេចគោលដៅភាគច្រើននៃអភិវឌ្ឍន៍សហសវត្សរ៍ ។ សន្តិសុខស្បៀងមានការខ្វះខាត គឺមានតែ ៣៦ ភាគរយ ចំណែកសមាមាត្រនៃប្រជាជនដែលរងគ្រោះដោយខ្វះ ស្បៀងអាហារ គឺមានលើសពីគោលដៅឆ្នាំ២០០៥ដែលកំណត់ត្រឹម ១៩.៥ ភាគរយ ។ អត្រាមរណៈកុមារមានការកើនឡើងជាងកាលពី១០ឆ្នាំកន្លងមក ជាពិសេសកុមារស្លាប់ក្រោយពេលកើត ។ មូលហេតុចំបងៗ ដែលបណ្តាលអោយកុមារស្លាប់ មានជម្ងឺរាគរូស

រលាកផ្លូវដង្ហើមធ្ងន់ធ្ងរ និងជម្ងឺផ្សេងៗទៀតដែលអាចការពារបានដោយការប្រើប្រាស់វ៉ាក់សាំងជាមុន ជាពិសេសគឺជម្ងឺកញ្ជ្រឹល ដែលអត្រាចាក់ថ្នាំការពារជម្ងឺបានត្រឹមតែ ៥៩ ភាគរយប៉ុណ្ណោះ ដែលអត្រានេះស្ថិតនៅក្រោមអត្រាគោលដៅឆ្នាំ២០១៥ ដែលបានកំណត់រហូតដល់ ៩០ ភាគរយ ។ ទោះមានការវិវឌ្ឍន៍ក៏ដោយ អត្រាមរណៈមាតានៅតែមានកំរិតខ្ពស់ដដែលគឺប្រហែល ៤៣៧ ក្នុងចំណោម ១០០.០០០ នាក់ ។ ស្ថានភាពសុខភាព និងអនាម័យមានសភាពតោកយ៉ាក ពោលគឺមានតែ ៣០ ភាគរយនៃប្រជាពលរដ្ឋទាំងអស់ ប៉ុណ្ណោះ មានលទ្ធភាពប្រើប្រាស់ទឹកបរិភោគដែលមាសុវត្ថភាព និងមានតែ ១៧ ភាគរយមានលទ្ធភាពប្រើប្រាស់សម្ភារៈអនាម័យ ។ ប្រទេសកម្ពុជាគួរសំរេចអោយបានការអប់រំបឋមសិក្សាសំរាប់កុមារទាំងអស់នៅមុនឆ្នាំ២០១៥ ប៉ុន្តែ មិនទំនងជាអាចសំរេចបាននូវគោលដៅ ការអប់រំមធ្យមសិក្សា និងសមភាពយេនឌ័រ ។ [៣]

៩. ទីបី អភិបាលកិច្ច ដូចដែលរដ្ឋាភិបាលទទួលស្គាល់ នៅតែជាបញ្ហាដ៏សំខាន់ដដែល ។ ការយល់ឃើញដែលផ្អែកលើទិន្នន័យ (ក្រាហ្វិកលេខ ១) បង្ហាញអោយឃើញនូវភាពពល្អប្រសើរខ្លះៗ នៅគ្រប់អាំងឌីកាទ័ររបស់អភិបាលកិច្ច នៅចន្លោះឆ្នាំ១៩៩៦ និងឆ្នាំ២០០២ ទោះបីខ្សែបន្ទាត់កំរិតកំហុសខ្ពស់ពេកដែលមិនអាចធ្វើអោយមានគេមានទំនុក ចិត្តលើទិសដៅនៃការផ្លាស់ប្តូរ ។ នៅក្នុងវិស័យចំនួនពីរ គឺការគ្រប់គ្រងអំពើពុករលួយ និងនីតិរដ្ឋ កម្ពុជាជាប់លំដាប់ ថ្នាក់ក្រោមក្នុងចំណោមបណ្តាប្រទេសដែលអនុវត្តមិនល្អ ។ សម្ទង់មតិក្នុងស្រុក អះអាងថា អំពើពុករលួយកំពុងរីរាល ដាល និងមានកំរិតខ្ពស់ ។




១០. ការវាយតំលៃបរិយាកាសវិនិយោគទុនថ្មីៗ( កម្ពុជា: ការឆក់យកឱកាសពិភពលោក ឆ្នាំ២០០៤)នេះ របស់ធនាគារពិភពលោក បានអះអាងថា អំពើពុករលួយ មិនមែនគ្រាន់តែជាទស្សនៈយល់ឃើញមួយនោះទេ ដែលក្រុមហ៊ុននានាបានរាយការណ៍ថា ការបង់ប្រាក់ទៅអោយមន្ត្រីសាធារណៈ កើតមានជាញឹកញាប់ភាគច្រើន បំផុត ឬ ជានិច្ចកាលតែងតែតំរូវអោយធ្វើដូច្នេះ ។ ក្នុងចំណោមក្រុមហ៊ុនអាជីវកម្មចំនួន ៤៤៧ ដែលបានឆ្លើយនឹងសំណួរអំពីការបង់ប្រាក់សំណូក ៨២ ភាគរយ (៣៦៨ក្រុមហ៊ុន នៃក្រុមហ៊ុនទាំងអស់) បានរាយការណ៍អំពីកិរិតវិជ្ជមាននៃការបង់ប្រាក់សំណូក ។ មួយចំណែកនៃប្រាក់ចំណូលដែលប្រើប្រាស់សំរាប់ការបង់ប្រាក់សំណូកនេះ គិតជាមធ្យមស្មើនឹង ៥ភាគរយ ដែលច្រើនជាងពីរដងដែលគេបានរកឃើញនៅក្នុងការស្ទង់មតិដូចគ្នានេះ នៅប្រទេសបង់ក្លាដេស ប៉ាគីស្ថាន និងប្រទេសចិន ។ ក្រុមហ៊ុនអាជីវកម្មក៏បានរាយ ការណ៍ផងដែរថា ជាមធ្យមទឹកប្រាក់ចំនួន ៥ ភាគរយនៃតំលៃកិច្ចសន្យា ត្រូវតំរូវអោយចំណាយដើម្បីទទួលបាន ការធ្វើជំនួញជាមួយទីភ្នាក់ងារសាធារណៈ ។ ក្រុមហ៊ុនដែលបង់សំណូកច្រើន មិនបានទទួលសេវាសាធារណៈល្អ ប្រសើរតបវិញឡើយ ។ ក្រុមហ៊ុនអាជីវកម្មទាំងនោះ បង្ហាញនូវទស្សនៈយល់ឃើញថាឥទ្ធិពល គឺផ្តុំនៅក្នុងចំណោម ក្រុមដែលមានបុព្វសិទ្ធិមួយចំនួនដែលគ្របដណ្តប់វិស័យសំខាន់ៗ និងមានចំណងទាក់ទងជាមួយមេដឹកនាំនយោបាយ ដែលប្រើប្រាស់ឥទ្ធិពលដ៏មានអំណាចទៅលើច្បាប់ និងបទបញ្ញត្តិផ្សេងៗរបស់ប្រទេស ។

១១. អភិបាលកិច្ចទន់ខ្សោយ ព្រមទាំងភាពបរាជ័យក្នុងការគ្រប់គ្រងអំពើពុករលួយ និងការពង្រឹងនីតិរដ្ឋ បង្ហាញ អោយឃើញអំពីសមត្ថភាពស្ថាប័នដែលនៅមានកំរិតរបស់ប្រទេសកម្ពុជា កង្វះការជឿទុកចិត្តគ្នាក្នុង ចំណោមឥស្សរជន និងការប្រឆាំងជំទាស់ទៅនឹងការកែទំរង់ពីសំណាក់ក្រុមដែលការពារផលប្រយោជន៍ ផ្ទាល់ខ្លួន ។ ទាំងនេះ គឺជាពពកខ្មៅសល់ពីអតីតកាលដ៏សោកនាដកម្មរបស់កម្ពុជា ដែលបានជះស្រមោលលើ អ្វីដែលអាចក្លាយជាអនាគតដ៏ត្រចះត្រចង់ ដែលរារាំងស្ថាប័នថ្មីៗ និងមានសមត្ថភាពទន់ខ្សោយមិនអោយ ធ្វើការប្រកបដោយប្រសិទ្ធភាពក្នុងការធានា អោយមានគណនេយ្យភាព និងតម្លាភាព ។ របៀប និងមូល ហេតុដែលគណនេយ្យភាពគាំងដំណើរការ នឹងលើក យកមកពិភាក្សាបន្ទាប់ ។

## ខ. ក្របខ័ណ្ឌអភិបាលកិច្ច និងគណនេយ្យភាពរបស់កម្ពុជា




១២. យុទ្ធសាស្ត្រចតុកោណ បញ្ជាក់យ៉ាងច្បាស់លាស់អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការ បង្កើតនូវលទ្ធិប្រជាធិបតេយ្យសេរី ជាមួយនិងការគោរពសិទ្ធិមនុស្ស ដូចដែលបានដឹកល់នៅក្នុងរដ្ឋធម្មនុញ្ញ លើកទី ៦ របស់ប្រទេស ដែលបានអនុម័តនៅឆ្នាំ១៩៩៣ និងដែលត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៩៩ ។ ដូចគ្នានឹងប្រទេស ប្រកាន់លទ្ធិប្រជាធិបតេយ្យដទៃទៀតដែរ ក្របខ័ណ្ឌគណនេយ្យភាពរបស់កម្ពុជា ដែល កើតចេញពីរដ្ឋធម្មនុញ្ញ គឺឈរលើមូលដ្ឋានទំនាក់ទំនងសំខាន់ៗបីរបស់គណនេយ្យភាព : រវាងប្រជាពលរដ្ឋ

និងរដ្ឋ  រវាងមន្ត្រីជាប់ឆ្នោតរបស់រដ្ឋ  និងអ្នកដែលទទួលខុសត្រូវលើការផ្តល់សេវាសំខាន់ៗដែលរដ្ឋផ្តល់ដល់ប្រជាពលរដ្ឋ និងរវាងអ្នកដែលផ្តល់សេវា និងប្រជាពលរដ្ឋដែលជាអ្នកទទួលនិងប្រើប្រាស់សេវាទាំងនេះ ។

ប្រជាពលរដ្ឋ និងតំណាងរាស្ត្រដែលជាប់ឆ្នោត ឬអ្នកធ្វើគោលនយោបាយ




១៣. គោលការណ៍បែងចែកអំណាច  និងតំរូវការសំរាប់អំណាចនីតិប្រតិបត្តិ  ដែលស្ថិតនៅក្រោមកំហិតនៃច្បាប់ត្រូវបានតំកល់នៅ*រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា* ។ ឧបករណ៍ដ៏សំខាន់សំរាប់ត្រួតពិនិត្យ និងធ្វើអោយមានតុល្យភាពនោះ គឺមានសភាជាតិ និងតុលាការ ។ លើសពីនេះទៅទៀត រដ្ឋមន្ត្រី និងមន្ត្រីរដ្ឋាភិបាល ត្រូវទទួលខុសត្រូវជាបុគ្គល និងជាសមូហភាពចំពោះសភាជាតិ នូវរាល់គោលនយោបាយទូទៅ និងការប្រព្រឹត្តរបស់បុគ្គល ដូចដែលមានចែងនៅក្នុងមាត្រា១២១នៃរដ្ឋធម្មនុញ្ញ ។ ប៉ុន្តែ ដោយសារតែនីតិប្រតិបត្តិដ៏មានអំណាច ដែលមានបំណងគ្រប់គ្រងផ្តាច់មុខនូវដំណើរការធ្វើគោលនយោបាយនានា ទាំងអង្គនីតិបញ្ញត្តិ និងតុលាការរបស់រដ្ឋាភិបាល ត្រូវប្រឈមមុខនឹងឧបសគ្គដ៏ធ្ងន់ធ្ងរ ក្នុងការបំពេញតួនាទីជាស្ថាប័នរបស់ពួកគេ ។

១៤. ដោយសារតែលិទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជានៅវ័យក្មេងនៅឡើយ វាមិនគួរអោយភ្ញាក់ផ្អើលទេ ដែលថា សមាជិករដ្ឋសភាជាតិ ប្រឈមមុខនឹងការលំបាកនានាក្នុងការទាមទារសិទ្ធិក្នុងតួនាទីដើម្បីតទល់នឹងអង្គនីតិប្រតិបត្តិ ។ ឧបសគ្គជាគន្លឹះដែលរដ្ឋសភាជាតិ កំពុងប្រឈមមុខនោះ មានដូចជាបទពិសោធដ៏ស្តួចស្តើងក្នុងការធ្វើសេចក្តីព្រាងច្បាប់ ឬគោលនយោបាយជជែកវែកញែក កង្វះការចូលរួមពីអ្នកធ្វើច្បាប់ក្នុងការវិភាគវែកញែក និងការត្រួតពិនិត្យឡើងវិញនូវសំណើច្បាប់ ឧបសគ្គដែលកើតមាន

ឡើងដោយសារតថភាពនយោបាយ ក្នុងការអនុវត្តការត្រួតពិនិត្យ និងមុខងារអង្កេតការ និងចំណេះដឹងដ៏តិចតួច ព្រមទាំងការប្រឈមនឹងបញ្ហាអភិវឌ្ឍន៍ជាគន្លឹះរបស់សភាជាតិ ។ រដ្ឋលេខាធិការដ្ឋានសភាជាតិមានធនធាន និងសមត្ថភាពស្តួចស្តើងសំរាប់ប្រើប្រាស់ ។ ការណ៍នេះ នាំអោយមានសេវាមិនល្អដល់គណៈកម្មាធិការសភា និងសមាជិកម្នាក់ៗ ព្រមទាំងកង្វះការ សំរបសំរួល រវាងសភា និងព្រឹទ្ធសភា ។ ជាងនេះទៅទៀត ភក្តីភាពចំពោះគណបក្ស ទំនងជាមានច្រើនជាងភក្តីភាពចំពោះ មណ្ឌលបោះឆ្នោត ដែលសមាជិកសភាជាតិតំណាងអោយ ។ ខណៈពេលនេះដែរពុំមានកម្មវិធីនយោបាយរបស់រដ្ឋាភិបាលជជែកជាក់លាក់អំពីតួនាទីសភាជាតិក្នុងការពិនិត្យមើលលើកម្មវិធី និង គោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាល និងថវិកាជាតិ ទោះបីជាមានការប្តេជ្ញាចិត្តដែលធ្វើឡើងដោយលោកនាយករដ្ឋមន្ត្រី និងសមាជិករបស់រាជរដ្ឋាភិបាលមួយចំនួនសន្យាចំពោះសភាជាតិក្តី ( ចំណុចទី ៧) ។

១៥. តុលាការ ដែលជាប្រភពសំខាន់ទីពីរសំរាប់ការទប់អំណាចនីតិប្រតិបត្តិ ត្រូវបានបំផ្លិចបំផ្លាញក្រោមរបបខ្មែរក្រហម ៤ ។ ចៅក្រមក្នុងប្រទេសបានភៀសខ្លួនចេញពីប្រទេស ឬត្រូវគេកាប់សំលាប់ ។ ក្នុងចំណោមអ្នកដែលមានវិជ្ជាជីវៈផ្នែកច្បាប់ពី ៤០០ ទៅ ៦០០ នាក់ មុនឆ្នាំ១៩៧៥ មានតែ ១០ នាក់ប៉ុណ្ណោះដែលមានជីវិតរស់នៅក្នុងប្រទេសនេះ ក្នុងរយៈពេល៥ឆ្នាំក្រោយមក ។ ទសវត្សរ៍ឆ្នាំ១៩៨០ គឺជាទសវត្សរ៍នៃកិច្ចខិតខំប្រឹងប្រែងដើម្បីស្ថាបនាប្រព័ន្ធតុលាការឡើងវិញ ដោយប្រមែប្រមូលគ្រូបង្រៀន និងមនុស្សផ្សេងទៀតយកមកអោយកាន់តំណែងជាចៅក្រម និងព្រះរាជអាជ្ញា ( អេវ៉ាន ហ្គោតិស្វេន ឆ្នាំ ២០០២) ។ ប៉ុន្តែរហូតមកដល់ បច្ចុប្បន្ននេះ នៅតែខ្វះខាតទេពកោសល្យផ្នែកច្បាប់ជាច្រើន ។ ក្នុងចំណោមចៅក្រម ៦នាក់ នៃចៅក្រមកម្ពុជា ចំនួន ១១៧នាក់ មានចៅក្រមតែម្នាក់គត់ដែលមានសញ្ញាបត្រផ្នែកច្បាប់ ហើយមានតែចៅក្រមតុលាការកំពូលម្នាក់គត់ មានសញ្ញាបត្រផ្នែកច្បាប់ ក្នុងចំណោមចៅក្រមតុលាការកំពូលចំនួន ៩នាក់ ។ ក្នុងចំណោមព្រះរាជអជ្ញាសាធារណៈ មានតែ១០ភាគរយប៉ុណ្ណោះ ដែលមានសញ្ញាបត្រផ្នែកច្បាប់ ។ ដូច្នេះ ប្រព័ន្ធតុលាការដែលសល់ពីរបបកម្ពុជាប្រជាធិបតេយ្យមិនមានធនធានគ្រប់គ្រាន់ដើម្បីធ្វើការងាររបស់ខ្លួន ស្ថិតនៅក្នុងលក្ខខណ្ឌមួយជាឧបករណ៍របស់អង្គនីតិប្រតិបត្តិ ទទួលប្រាក់បៀវត្សតិច និងត្រូវគេចោទប្រកាន់ ថាពុករលួយ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាឧបករណ៍មួយរបស់រដ្ឋធម្មនុញ្ញ មានបំណងធានាឯករាជ្យភាព និង សមត្ថកិច្ចរបស់តុលាការ គឺត្រូវធ្វើកំណែទំរង់ជាបន្ទាន់ ។ សមាសធាតុផ្សេងទៀតនៃវិស័យយុត្តិធម៌ ដូចជាប៉ូលិស ក៏មិនទាន់ ដំណើរល្អដូចគ្នាដែរ ។ អ្វីដែលត្រូវ

ការចាំបាច់ដើម្បីអនុវត្តកំណែទំរង់ប្រព័ន្ធតុលាការ ដែលជាបញ្ហាមួយស្ថិតនៅក្នុងបញ្ជីអាទិភាពរបស់យុទ្ធសាស្ត្រចតុកោណ នឹងត្រូវលើកយកមកពិភាក្សានៅផ្នែកខាងក្រោយនៃជំពូកនេះ ។

១៦. ដោយមានរដ្ឋសភា និងប្រព័ន្ធតុលាការទន់ខ្សោយ ពលរដ្ឋកម្ពុជាត្រូវតែពឹងផ្អែកលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និង សង្គមស៊ីវិលដែលមិនទាន់អភិវឌ្ឍនៅឡើយ ដើម្បីជួយបំពងសំលេងនៃការបញ្ចេញមតិរបស់ពួកគេ និងជំរុញអោយអង្គនីតិប្រតិបត្តិ មានការទទួលខុសត្រូវ ។ ច្បាប់ស្តីពី*ប្រព័ន្ធសារព័ត៌មាន* ដែលអនុម័តកាលពីឆ្នាំ១៩៩៥ ធានាដល់សេរីភាពសារព័ត៌មាន ហាមមិនអោយមានការត្រួតពិនិត្យមុនការបោះពុម្ពផ្សាយ និងធានានូវសិទ្ធិដើម្បីការពារការណ៍សំងាត់របស់ប្រភព ។ គ្មានការតំរូវអោយសុំអាជ្ញាប័ណ្ណជាមុន ដើម្បីធ្វើការបោះពុម្ពផ្សាយកាសែតឡើយ ។ ប៉ុន្តែ ច្បាប់នេះហាមឃាត់នូវការផ្សព្វផ្សាយរបាយការណ៍ព័ត៌មាននានាដែលអាចប៉ះពាល់ដល់ "សន្តិសុខជាតិ ឬស្ថិរភាពនយោបាយ" ឬ"បង្ខូចមុខមាត់ស្ថាប័នជាតិ" ។ ហើយអ្នកសារពត៌មាន គឺងាយនឹងរងគ្រោះពីការកាត់ទោសតាមផ្លូវច្បាប់ចំពោះការបរិហារកេរ្តិ៍ និងព័ត៌មានមិនពិត ។ ទោះជា យ៉ាងនេះក្តី អង្គភាពកាសែតប្រហែល ១០ ឬលើសពីនេះ ដែលបោះពុម្ពផ្សាយជាទៀងទាត់ ហាក់ដូចជាមានលក្ខណៈសេរីគ្រាន់បើ ។ ប៉ុន្តែ ចំណែកឯសារព័ត៌មានផ្នែកចាក់ផ្សាយដែលជាមួយ នឹងស្ថានីយវិទ្យុប្រមាណ ២០ និងស្ថានីយទូរទស្សន៍ចំនួន ៧ ផ្សព្វផ្សាយដល់ ប្រជាពលរដ្ឋចំនួនយ៉ាងច្រើននោះ ពុំទាន់មានច្បាប់ដូចគ្នានេះនៅឡើយទេ ។ វិទ្យុមានប្រជាប្រិយភាពយ៉ាងខ្លាំង ហើយមធ្យោបាយ សំរាប់ការសំដែងមតិដោយសេរី ។ ស្របពេលគ្នានេះដែរ សារព័ត៌មានខ្លួនឯងត្រូវតែពង្រឹងការទទួលខុសត្រូវក្នុងការផ្សព្វផ្សាយអោយបានត្រឹមត្រូវ និងមានគោលដៅច្បាស់លាស់ (វត្ថុវិស័យភាព) ។ ប្រព័ន្ធសារព័ត៌មាន គួរទទួលបានផលប្រយោជន៍ពីការបណ្តុះបណ្តាលលើវិជ្ជាជីវៈសារព័ត៌មាន ក្នុងការអង្កេតតាមដានប្រកបដោយការទទួលខុសត្រូវ ។ ការធានានូវច្បាប់ទម្លាប់ដោយអង្គភាពសារព័ត៌មានខ្លួនឯងក៏អាចតំរូវអោយមាន អោយដូចនឹងក្រុមប្រឹក្សាសារព័ត៌មានក្នុងបណ្តាប្រទេសដទៃទៀត ។

១៧. សង្គមស៊ីវិលកំពុងរីកដុះដាលយ៉ាងឆាប់រហ័ស ប៉ុន្តែមិនទាន់មានប្រសិទ្ធភាពក្នុងការបំពងសំលេងរបស់ប្រជាពលរដ្ឋ ជាពិសេសពលរដ្ឋក្រីក្រនៅឡើយទេ ។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកភាគច្រើនបំផុតនៅក្មេងខ្ចី គ្មានបទពិសោធន៍ ហើយប្រឈមមុខនឹងបញ្ហានៃការធ្វើសកម្មភាពរួមគ្នា ។ ប្រពៃណីនៃការពិគ្រោះយោបល់ជាមួយអង្គការក្រៅរដ្ឋាភិបាលនៅមុនការអនុម័តច្បាប់សំខាន់អ្វីមួយ ឬការបង្កើតគោល

នយោបាយថ្មី គឺមានតិចតួចណាស់ លើកលែងតែមានការគាបសង្កត់ពីម្ចាស់ជំនួយអោយធ្វើការពិគ្រោះយោបល់បែបនេះ ។ អង្គការក្រៅរដ្ឋាភិបាល ក្នុងស្រុកពឹងផ្អែកលើអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិក្នុងការលើកបញ្ហាជាមួយរដ្ឋាភិបាល តាមរយៈឥទ្ធិពលរបស់ពួកគេជាមួយម្ចាស់ជំនួយទ្វេភាគី ។ ការពឹងផ្អែកយ៉ាងខ្លាំងលើមូលនិធិបរទេស ធ្វើអោយអង្គការក្រៅរដ្ឋាភិបាលបង្វែរគណនេយ្យភាពរបស់ខ្លួន ទៅអង្គការផ្តល់មូលនិធិបរទេសជាជាងចំពោះពលរដ្ឋក្រីក្រក្នុងប្រទេសកម្ពុជា ។ អង្គការក្រៅរដ្ឋាភិបាលក៏តំរូវអោយ អនុវត្តផងដែរនូវអ្វីដែលពួកគេបានថ្លែង ដោយធានាថាការគ្រប់គ្រង និងហិរញ្ញវត្ថុ របស់អង្គការ ត្រូវមានតម្លាភាព និងគណនេយ្យភាពដូចគ្នា ដូចដែលពួកគេទាមទាររដ្ឋាភិបាលអនុវត្តដែរ ។ ច្បាប់គ្រប់គ្រង ប្រតិបត្តិការរបស់អង្គការក្រៅរដ្ឋាភិបាល ដែលស្នើឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណ អាចនឹងជួយធានាអោយមានគណនេយ្យភាព និងតម្លាភាពគ្រប់គ្រាន់នៅក្នុង វិស័យអង្គការក្រៅរដ្ឋាភិបាល ។ ប៉ុន្តែច្បាប់បែបនេះ នឹងចាំបាច់ត្រូវធ្វើអោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិពេញចិត្តថា ច្បាប់នេះនឹងមិនត្រូវបានប្រើប្រាស់ ដោយរដ្ឋាភិបាលដែលមិនពេញចិត្តនឹងការរិះគន់របស់ពួកគេចំពោះគោលនយោបាយរបស់ខ្លួន ដើម្បីរឹតបន្តឹងសកម្ម ភាពរបស់អង្គការទាំងនោះឡើយ ។

១៨. បច្ចុប្បន្ននេះ ពលរដ្ឋកម្ពុជាភាគច្រើនបំផុតទទួលបានសេរីភាពដែលមិនធ្លាប់មានពីមុនមក ក្នុងការសំដែងមតិរបស់ពួកគេ ។ ការតវ៉ាដោយជនស៊ីវិល បច្ចុប្បន្ននេះ មានលក្ខណៈជាធម្មតា លើបញ្ហាដូចជាប្រាក់ឈ្នួលកម្មករ អំពើពុករលួយ និងច្បាប់បោះឆ្នោត ។ ការធ្វើកូដកម្មបានកើតមានកាន់តែច្រើនឡើង គឺការអត់ឱនចំពោះការគ្រប់គ្រងមិនត្រឹមត្រូវ មិនសូវមានដូចមុនឡើយ ហើយកម្មករ និយោជិត រៀបចំជាសកម្មភាពរួមគ្នា ។ សកម្មភាពទាំងនេះ គឺជាទំនោរល្អមួយ ទោះបីវាមានលក្ខណៈ មិនទាន់ប្រាកដប្រជាក៏ដោយ ។ សេរីភាពក្នុងការនិយាយស្តី និង ជំទាស់ មិនទាន់ត្រូវបានគេមើលឃើញថាជាសិទ្ធិនៅឡើយទេ ប៉ុន្តែជាអ្វីដែលត្រូវបានគេអត់ឱន ជាមួយនឹងកង្វះនូវភាពច្បាស់លាស់អំពីកំរិតនៃការអត់ឱននោះ ។ ប៉ុន្តែសេរីភាពថ្មីទាំងនេះ គឺជាមធ្យោបាយសុវត្ថិភាពដ៏សំខាន់មួយ ដែលបង្កើតអោយមានបរិយាកាសទំនាក់ទំនងរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ហើយបញ្ហានេះ ត្រូវតែទទួលបាននូវការលើកទឹកចិត្ត ។ បទពិសោធន៍អន្តរជាតិ បង្ហាញអោយឃើញថា សារព័ត៌មានសេរី សង្គមស៊ីវិល ដ៏រឹងមាំ និងប្រជាពលរដ្ឋដែលមានឆន្ទៈធ្វើអោយរដ្ឋាភិបាលរបស់ខ្លួនមានការទទួលខុសត្រូវ បង្កើតអោយមានគណនេយ្យភាពសាធារណៈកាន់តែ ខ្លាំង

ឡើង និងសេវាសាធារណៈកាន់តែល្អប្រសើរឡើង ។ ការទទួលស្គាល់បញ្ហានេះនៅក្នុងយុទ្ធសាស្រ្តចតុកោណ អាចត្រូវបានគេមើលឃើញនៅក្នុងការធ្វើអោយសង្គមស៊ីវិល ចូលរួមធ្វើជាដៃគូរបស់រដ្ឋាភិបាល ក្នុងការអភិវឌ្ឍ និង នៅក្នុងការប្តេជ្ញាចិត្តដើម្បីលើកទឹកចិត្តចំពោះសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាល ។

**តំណាងរាស្ត្រដែលជាប់ឆ្នោត ឬអ្នកធ្វើគោលនយោបាយ និងស្ថាប័នផ្តល់សេវានានា**

តំណាងរាស្ត្រជាប់ឆ្នោត និងអ្នកតាក់តែងគោលនយោបាយ

អ្នកផ្តល់សេវាកម្ម

១៩. នៅក្នុងគ្រប់រដ្ឋាភិបាលទាំងអស់ អ្នកនយោបាយគឺជាអ្នកបង្កើតគោលនយោបាយដ៏សំខាន់ ប៉ុន្តែដើម្បីបំពេញមុខងារសំខាន់ៗរបស់រដ្ឋ អនុវត្តគោលនយោបាយ និងផ្តល់សេវា ពួកគេត្រូវតែផ្ទេរមុខងារទាំងនេះទៅអោយមន្ត្រីការិយាធិបតេយ្យ ។ ការណ៍នេះបានធ្វើអោយកើនឡើងនូវបញ្ហា ដែលសេដ្ឋកិច្ចវិទូហៅថា *បញ្ហាចាងហ្វាង-ភ្នាក់ងារ*[៥] បញ្ហាលំបាកក្នុងការធានាថា ភ្នាក់ងារដែលជាស្ថាប័នផ្តល់សេវាអោយអ្នកដែលត្រូវបានផ្ទេរមុខងារទាំងនេះអោយពិតជាអនុវត្តនូវភារកិច្ចទទួលខុសត្រូវរបស់ពួកគេប្រកបដោយប្រសិទ្ធភាពនិងមានលក្ខណៈ សន្សំសំចៃខ្ពស់បំផុត ។ *ចាងហ្វាង* ត្រូវតែបង្កើតអោយមានបទបញ្ញត្តិសំរាប់តំរង់ការិយាធិបតេយ្យតាមរយៈច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ ។ បន្ទាប់មកទៀត ពួកគេត្រូវបង្កើតអោយមាន "កិច្ចព្រមព្រៀង" ផ្លូវការ ឬក្រៅផ្លូវការ ជាមួយមន្ត្រីការិយាធិបតេយ្យ ។ ជាថ្នូរនឹងការលើកទឹកចិត្តមួយកញ្ចប់ដែលផ្តល់អោយ (បៀវត្សប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗទៀត) មន្ត្រីការិយាធិបតេយ្យត្រូវដាក់អោយទទួលខុសត្រូវចំពោះការអនុវត្តន៍នូវកិច្ចការដែលដាក់អោយពួកគេធ្វើ ។ គណនេយ្យភាពត្រូវពង្រឹងតាមរយៈមធ្យោបាយមួយចំនួនៈ ការត្រួតមើលនិងតុល្យភាពផ្ទៃក្នុង (សវនកម្មផ្ទៃក្នុង ការវាយតំលៃកម្មវិធីមុន និងក្រោយការធ្វើរបាយការណ៍) បណ្តាញផ្លូវការសំរាប់ត្រួតពិនិត្យឡើងវិញ នូវសេចក្តីសំរេចចិត្តផ្នែករដ្ឋបាលដែលជះឥទ្ធិពលទៅលើសិទ្ធិរបស់បុគ្គលម្នាក់ៗ និងការដាក់កំហិតពីខាងក្រៅ (ទីភ្នាក់ងារសវនកម្មជាន់ខ្ពស់ គណៈកម្មការប្រឆាំងអំពើពុករលួយដែលស្នើអោយបង្កើតឡើង សេរីភាពលើបញ្ញត្តិព័ត៌មាន និងច្បាប់នានា ដែលតំរូវអោយប្រកាសទ្រព្យសម្បត្តិ) និងវិធានការដាក់ពិន័យ ។ ប្រព័ន្ធ

គណនេយ្យភាព ពឹងផ្អែកលើការបង្កើតព័ត៌មានអោយបានគ្រប់គ្រាន់ស្តីពីការអនុវត្តន៍ការងារ ។ នៅពេលដែលកិច្ចព្រមព្រៀងលែងដំណើរការ វានឹងនាំអោយកើតមានអំពើពុករលួយ និងការផ្តល់សេវាមិនបានល្អ ។ អំពើពុករលួយអាច ជាប្រភេទដែលទាក់ទងនឹងការគ្រប់គ្រងការងាររដ្ឋបាល នៅពេលមន្ត្រីរាជការប្រមូលយកថ្លៃឈ្នួលផ្សេងៗក្នុងអំឡុងពេលនៃការអនុវត្តន៍គោលនយោបាយ ឬអាចពាក់ព័ន្ធនឹងការក្តោបក្តាប់រដ្ឋដោយក្រុមអ្នកមានអំណាចដើម្បីបញ្ច្រាបឥទ្ធិពលលើច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយផ្សេងៗដើម្បីបំរើផលប្រយោជន៍របស់ខ្លួន ។ ការក្តោបក្តាប់រដ្ឋ ជាធម្មតាគឺពាក់ព័ន្ធនឹងការពុករលួយ របស់*ខាងប្រាង*ពោលគឺអ្នកនយោបាយ ប៉ុន្តែជាធម្មតា វាក៏ត្រូវមានការឃុបឃិតគ្នារវាងអ្នកនយោបាយ និងមន្ត្រីការិយាធិបតេយ្យ ដែលត្រូវតែជួយអនុវត្តគោលនយោបាយ ឬកម្មវិធីពុករលួយ ។

២០. នៅប្រទេសកម្ពុជា ដូចដែលយើងបានធ្វើការកត់សំគាល់ខាងលើអំពើពុករលួយ គឺជាជំងឺឆ្លងដែល ឆ្លុះបញ្ចាំងអោយឃើញអំពីការគាំងដំណើរនៃប្រព័ន្ធគណនេយ្យភាព។ កិច្ចព្រមព្រៀង រវាងតំណាងរាស្ត្រជាប់ឆ្នោតឬអ្នកធ្វើគោលនយោបាយ ជាមួយនឹងស្ថាប័នផ្តល់សេវា ត្រូវជាប់គាំងដោយមូលហេតុជាច្រើន ។ ទីមួយ កិច្ចព្រមព្រៀងរវាងអ្នកនយោបាយ និងមន្ត្រីរាជការស៊ីវិល កាន់តែពុំសូវមានប្រសិទ្ធភាពដោយសារគ្មានក្របខណ្ឌច្បាប់គ្រប់គ្រាន់សំរាប់តំរង់អាកប្បកិរិយារបស់មន្ត្រីរាជការស៊ីវិល និងដោយសារតែការបរាជ័យក្នុងការអនុវត្តច្បាប់ ។ គ្មានច្បាប់រដ្ឋប្បវេណីព្រហ្មទណ្ឌ និងច្បាប់ស្តីពីនីតិវិធីពាណិជ្ជកម្ម ព្រមទាំងគ្មានច្បាប់ប្រឆាំងនឹងអំពើពុករលួយផងដែរ សូម្បីតែច្បាប់ទាំងនោះត្រូវបានអនុម័តហើយក្តី ។ ទោះជាយ៉ាងណាក្តី មន្ត្រីទទួលបន្ទុកការអនុវត្តន៍ច្បាប់ និង តុលាការ មិនបានពង្រឹងការអនុវត្តច្បាប់ដែលមានស្រាប់ ។ ទីពីរ រដ្ឋខកខានមិនបានធានាថា មន្ត្រីរាជការ ស៊ីវិលមានសមត្ថភាព ឬមានការលើកទឹកចិត្ត អោយបំពេញការងារដែលគេកំណត់អោយធ្វើ ។ សមត្ថភាព គឺនៅខ្វះខាតទាំងជំនាញ និងធនធានសំរាប់បំពេញការងារ ។ ដោយមានការបំផ្លិចបំផ្លាញទាំងស្រុងនូវបញ្ញាវ័ន្តកម្ពុជា ក្រោមរបបខ្មែរក្រហម ប្រទេសនេះមានមន្ត្រីសាធារណៈដែលមានសមត្ថភាព និង បទពិសោធន៍ល្អៗ យ៉ាងតិចតួចស្តួចស្តើង ។

២១. គ្រឿងលើកចិត្តសំរាប់មន្ត្រីរាជការស៊ីវិល ក៏មានលក្ខណៈមិនសមហេតុផល ។ មន្ត្រីរាជការស៊ីវិលមិនបានទទួលការគ្រប់គ្រងអោយបានត្រឹមត្រូវ ហើយមានប្រាក់បៀវត្សតិចតួច ដូច្នេះធ្វើអោយមានការប៉ះពាល់ដល់ការលើកទឹកចិត្តអោយគោរពនូវកិច្ចព្រមព្រៀងរបស់ខ្លួន ។ ប្រាក់បៀវត្សរបស់មន្ត្រីរាជការ

ស៊ីវិល មានកំរិតទាបមិនសមហេតុផល ។ និយោជិតប្រភេទ ក ដែលមានបរិញ្ញាបត្រ ទទួលបានបៀវត្សចំនួន ៤០ ដុល្លាក្នុងមួយខែ ។ ជាមធ្យម ប្រាក់ឈ្នួលរបស់មន្ត្រីរាជការស៊ីវិល គឺលើសផលិតផលក្នុងស្រុកសរុបសំរាប់ប្រជាពលរដ្ឋម្នាក់បន្តិចប៉ុណ្ណោះ គឺជាប្រាក់ឈ្នួលមួយក្នុងចំណោមប្រាក់ឈ្នួលទាបបំផុតក្នុងបណ្តាប្រទេសក្នុងតំបន់ ។ ផលធៀបនៃប្រាក់ឈ្នួលជាមធ្យម រវាងប្រាក់ឈ្នួលប្រភេទខ្ពស់បំផុត និងប្រភេទទាបបំផុត គឺតិចជាង ២ ដុល្លា ។ ការចំណាយលើសេវាកម្ម និងការថែទាំដោយផ្ទាល់ ក៏មានកំរិតពុំគ្រប់គ្រាន់គួរអោយអាណិតផងដែរ ។

២២. ការទទួលបានប្រាក់ចំណូលដ៏ទាបរបស់កម្ពុជា សំរាប់ឱកាសលើកកំពស់កំរិតជីវភាព វានឹងរួមចំណែកដល់វដ្តដ៏អាក្រក់នៃអំពើពុករលួយ ។ ប្រាក់ចំណូលមានកំរិតទាបដោយផ្នែក ដោយសារការប្រមូលប្រាក់ចំណូល ងាយរងនឹងអំពើពុករលួយ ។ កង្វះតម្លាភាពនៅក្នុងការផ្តល់សេវាឯកជន នូវហេដ្ឋារចនាសម្ព័ន្ធ ដីធ្លី និងការសម្បទានទ្រព្យសម្បត្តិរដ្ឋដទៃទៀតកាត់បន្ថយនូវចំនួនប្រាក់ចំណូល ដែលគួរតែមានកើនឡើងនៅក្នុង*រតនាគារ* ។ ម្យ៉ាងវិញទៀត ប្រាក់ចំណូលទាប មានន័យថា ប្រាក់ឈ្នួលក៏ទាប ហើយចំណាយលើការផ្តល់សេវាកម្មទាប ដែលរួមចំណែកបង្កអោយមានអំពើពុករលួយ ។ សេវាសាធារណៈស៊ីវិលរបស់ប្រទេសកម្ពុជា ចាំបាច់ត្រូវឆ្លងកាត់អន្តរកាលពីប្រព័ន្ធ (ហ្គោតិស្នេហ៍) ផ្អែកតាមការតែងតាំង និងបណ្តាញបច្ចុប្បន្ន ដែលក្នុងនោះ បុគ្គលមានអំណាច ចាត់ចែងបណ្តាញមន្ត្រីរាជការស៊ីវិលដែលមានភក្តីភាពរបស់ពួកគេ តាមទំនាក់ទំនងពឹងផ្អែកគ្នាទៅវិញទៅមក ទៅប្រព័ន្ធមួយទៀតដែលផ្អែកលើគុណសម្បត្តិ និងគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈ ។ យុទ្ធសាស្ត្រចតុកោណ ធ្វើអោយរដ្ឋាភិបាលប្តេជ្ញាចិត្តចំពោះកំណែទំរង់បែបនេះ ។

២៣. ម្យ៉ាងវិញទៀត ប្រព័ន្ធគណនេយ្យភាពទន់ខ្សោយខ្លាំងពេក ដែលមិនអាចអនុញ្ញាតអោយអ្នកធ្វើគោលនយោបាយត្រួតពិនិត្យអំពើពុករលួយកើត ទោះបីជាពួកគេចង់ធ្វើក៏ដោយ ។ ប្រព័ន្ធបើកប្រាក់ដោយផ្អែកលើសាច់ប្រាក់សុទ្ធមិនត្រឹមតែ នាំមកនូវភាពមិនអាចទស្សន៍ទាយបានអំពីការបញ្ចេញថវិកាដែលបែងចែករួច ដោយសារកង្វះនូវសាច់ប្រាក់សុទ្ធ ប៉ុន្តែពេលប្រព័ន្ធ ធ្វើគណនេយ្យនិងរបាយការណ៍មិនគ្រប់គ្រាន់ក៏នឹងនាំមកនូវបរិយាកាសត្រួតពិនិត្យទន់ខ្សោយ និងការកើនឡើងនូវឱកាសសំរាប់អំពើពុករលួយ ។ ស្ថាប័នត្រួតពិនិត្យអំពើពុករលួយដែលមានស្រាប់ ដូចជា ការឃ្លាំមើលរបស់សភា និងប្រព័ន្ធត្រួតពិនិត្យ សាច់ប្រាក់

ផ្ទៃក្នុង និងការគ្រប់គ្រងហិរញ្ញវត្ថុ សុទ្ធតែដំណើរការមិនទាន់មានប្រសិទ្ធភាពនៅឡើយ ។ ប្រព័ន្ធគណនេយ្យភាពខាងក្រៅ ពុំទាន់មានការអភិវឌ្ឍន៍ពេញលេញនៅឡើយ ។ មុខងារសវនកម្មជាតិ គឺនៅថ្មី ហើយគណៈកម្មការប្រឆាំងនឹង អំពើពុករលួយ ដែលបានស្នើឡើងជាយូរមកហើយនោះ ក៏មិនទាន់បង្កើតឡើងនៅឡើយដែរ ។ សូម្បីតែគ្មាន ឧបសគ្គនៃសមត្ថភាពយ៉ាងធ្ងន់ធ្ងរដែលជះឥទ្ធិពលលើគ្រប់ស្ថាប័នទាំងនេះក៏ដោយ ក៏ទីភ្នាក់ងារសំរាប់គណនេយ្យភាពខាងក្រៅទាំងនេះ ទំនងជានឹងធ្វើការនៅក្នុងបរិយាកាសនយោបាយមួយដែលគោរពស្វ័យភាព និងគាំទ្រតែតួនាទីរបស់ខ្លួនប៉ុណ្ណោះ ។

*ប្រជាពលរដ្ឋ និងស្ថាប័នផ្តល់សេវា*




២៤. ប្រជាពលរដ្ឋកម្ពុជាទាក់ទងជាមួយនឹងមន្ត្រីរាជការស៊ីវិល ដែលជាស្ថាប័នផ្តល់សេវាញឹកញាប់ជាងដែលពួកគេទាក់ទងជាមួយតំណាងរាស្ត្រដែលជាប់ឆ្នោតរបស់ពួកគេ ។ តាំងពីការចុះឈ្មោះកូនអោយចូលរៀន ការទទួលការថែទាំសុខភាពជាបឋមនៅមណ្ឌលគាំពារសុខភាព ការស្នើសុំប័ណ្ណបើកបរ ឬការជួបប្រឈមមុខនឹងប៉ូលិស ប្រជាពលរដ្ឋកម្ពុជាឃើញពីការផ្តល់សេវាសាធារណៈជារៀងរាល់ថ្ងៃនៅក្នុងជីវភាពរស់នៅរបស់ពួកគេ ។ ប៉ុន្តែ ខណៈដែលប្រជាពលរដ្ឋគួរតែមានលទ្ធភាពដោយផ្ទាល់ក្នុងការដាក់អោយមន្ត្រីទទួលខុសត្រូវចំពោះពួកគេនូវគុណភាព និងប្រសិទ្ធភាពនៃសេវាដែលមន្ត្រីរាជការផ្តល់អោយពួកគេមានសិទ្ធិអំណាច ឬការត្រួតត្រាលើមន្ត្រីទាំងនេះ នៅតិចតួចបំផុត ។ វប្បធម៌របស់ការិយាធិបតេយ្យ មិនទាន់ក្លាយទៅជាវប្បធម៌មួយ ដែលមន្ត្រីការិយាធិបតេយ្យ ចាត់ទុកប្រជាពលរដ្ឋជាចៅហ្វាយនាយ ហើយពួកគេជាអ្នកបំរើរបស់ប្រជាពលរដ្ឋនៅឡើយទេ ។ ជាងនេះទៅទៀត វប្បធម៌នៃតម្លាភាព គឺត្រូវការជាចាំបាច់ក្នុងចំណោមមន្ត្រីរាជការស៊ីវិលកម្ពុជា ដែលពួកគេជាអ្នកកាន់កាប់ព័ត៌មាន ហើយព័ត៌មានទាំងនេះ គួរតែបាន

ផ្សាយជាសាធារណៈ ប្រសិនបើគ្មានផលប្រយោជន៍ណាមួយមានលើសលុបលើផលប្រយោជន៍សាធារណៈ ដូចមានចែងនៅក្នុងច្បាប់ស្តីអំពីព័ត៌មានសម្ងាត់ ។

២៥. នៅក្នុងបណ្តាប្រទេសប្រជាធិបតេយ្យដែលមានវ័យចំណាស់ ប្រជាពលរដ្ឋអាចបង្កើនឥទ្ធិពលរបស់ ខ្លួនទៅលើកិរិយាធិបតេយ្យ ដោយការរៀបចំខ្លួនពួកគេជាក្រុមតាមរយៈសមាគមមាតាបិតា អង្គការ សាសនា ឬអង្គការ ក្រៅរដ្ឋាភិបាល ។ ទាំងនេះគឺជាមធ្យោបាយដើម្បីដាក់ការគាបសង្កត់ទៅលើកិរិយាធិ-បតេយ្យ ដោយលើកកំពស់ការបញ្ចេញមតិ និងបង្កើនលំហូព័ត៌មានស្តីពីគុណភាព និងប្រសិទ្ធភាព នៃសេវាដែលពួកគេបានទទួល ។ នៅកម្ពុជា ដូចដែលយើងបានឃើញរួចមកហើយនៅផ្នែកខាងលើ អង្គការមិនមែនរដ្ឋាភិបាលនៅមិនទាន់មានបទពិសោធន៍ និង មានលក្ខណៈទន់ខ្សោយនៅឡើយ ។ ការរៀបចំបង្កើតជាក្រុមដើម្បីការពារផលប្រយោជន៍រួម អាចអស់ថ្លៃចំណាយខ្ពស់ ។ នៅក្នុងសង្គមដែលរៀបចំតាមឋានានុក្រម កិច្ចប្រឹងប្រែងដើម្បីរៀបចំបង្កើតជាក្រុម អាចនឹងត្រូវគេសំលឹងមើលដោយភាពមន្ទិលសង្ស័យ ហើយពលរដ្ឋក្រីក្រអាចនឹងមិនហានសំដែងមតិដោយខ្លាចមានការគុំកួន ។ ហើយព័ត៌មានដែលត្រូវការសំរាប់ត្រួតពិនិត្យតាមដានមន្ត្រីរាជការសាធារណៈ ក៏នៅខ្វះខាតនៅឡើយ ។ ប៉ុន្តែប្រសិន បើរដ្ឋាភិបាលមានការប្តេជ្ញាចិត្តពិតប្រាកដក្នុងការធ្វើការជាដៃគូជាមួយសង្គមស៊ីវិល រដ្ឋាភិបាលចាំបាច់ត្រូវលើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាលអោយរៀបចំសហគមន៍ និងពលរដ្ឋក្រីក្រ ព្រមទាំងតាមដានការអនុវត្តន៍របស់មន្ត្រី កិរិយាធិបតេយ្យ និងស្ថាប័នផ្តល់សេវា ។ ឱកាសគឺមានច្រើនគួរសមសំរាប់កិច្ចពិភាក្សាជាលក្ខណៈប្រព័ន្ធច្រើនឡើងរវាងប្រជាពលរដ្ឋ និង ស្ថាប័នផ្តល់សេវា ដែលការណ៍នេះត្រូវបានសំរបសំរួលដោយអង្គការមិនមែនរដ្ឋាភិបាល ដែលបង្កើនការតំរង់ទិសទៅរកសេវារបស់ស្ថាប័នផ្តល់សេវា ។ លទ្ធភាពក្នុងការទទួលបានព័ត៌មានដែលគ្រប់គ្រងដោយអាជ្ញាធរសាធារណៈ ត្រូវតែគេមើលថាជាមូលដ្ឋានគ្រឹះរបស់ប្រជាពលរដ្ឋ ក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាព នៅក្នុងការបង្កើត និង ការអនុវត្តគោលនយោបាយរដ្ឋាភិបាល និងជាមូលដ្ឋានគ្រឹះសំរាប់ការជជែកវែកញែកជាសាធារណៈ ដែលមានព័ត៌មានគ្រប់គ្រាន់ស្តីអំពីសកម្មភាពរបស់រដ្ឋាភិបាល ។ សេរីភាពនៃច្បាប់ព័ត៌មាន អាចជួយនាំមកនូវការផ្លាស់ប្តូរនៅក្នុងវប្បធម៌ ។

## ភាពក្រីក្រ និងអភិបាលកិច្ច

២៦. ការបរាជ័យនៃគណនេយ្យភាពនិងតម្លាភាព ដែលបានកត់សំគាល់ខាងលើ និងការរីកចំរើនយ៉ាងយឺតផ្នែកនីតិរដ្ឋ ឆ្លុះបញ្ចាំងអោយពីបរាជ័យយ៉ាងខ្លាំងលើផ្នែកអភិបាលកិច្ច ដែលប្រជាពលរដ្ឋក្រីក្រកម្ពុជាត្រូវទទួលបន្ទុកនេះយ៉ាងធ្ងន់ធ្ងរ ។ ប្រជាពលរដ្ឋក្រីក្រទទួលរងការលំបាកខ្លាំងបំផុតពីអសន្តិសុខផ្នែករាងកាយ និងកង្វះលទ្ធភាព ក្នុងការទទួលបានភាពយុត្តិធម៌ ។ អភិបាលកិច្ចមិនល្អ ធ្វើអោយថយចុះនូវលទ្ធភាពរបស់រដ្ឋាភិបាលក្នុងការផ្តល់សេវាសាធារណៈជាមូលដ្ឋាន ពោលគឺសេវាសំខាន់ៗ ដែលចាំបាច់សំរាប់ការវិនិយោគទុនលើធនធានមនុស្សក្នុងចំណោមប្រជាពលរដ្ឋក្រីក្រ ។ ជាពិសេស ប្រជាពលរដ្ឋក្រីក្រ គឺពុំមានទីពុំនឹងនៅពេលមានការប្រឈមមុខនឹងអំពើពុករលួយ ។ ពួកគេពឹងផ្អែកលើសេវាសាធារណៈដោយមិនស្របតាមសមាមាត្រ ហើយជាញឹកញាប់ ពួកគេមិនបានស្វែង យល់អំពីអ្វីដែលពួកគេតំរូវអោយបង់ថ្លៃសេវាសាធារណៈឡើយ ដោយអនុញ្ញាតអោយជនពុករលួយធ្វើអាជីវកម្ម លើភាពអវិជ្ជារបស់ពួកគេ ។ អភិបាលកិច្ចមិនល្អ ក៏ធ្វើអោយមានវិសមភាពនៅក្នុងការកាន់កាប់ដីធ្លី ដែលការណ៍នេះ ធ្វើអោយកំណើនសេដ្ឋកិច្ចនៅអនាគតមានការចុះថយ ។ អភិបាលកិច្ចមិនល្អ ក៏ជាចំណែកមួយនៃការកាប់បំផ្លាញព្រៃឈើ និង ការប្រើប្រាស់មិនត្រឹមត្រូវនូវធនធានធម្មជាតិរបស់ប្រទេសនេះ ។ ប៉ុន្តែសរុបមក អំពើពុករលួយ អប្រសិទ្ធភាព និង អសមត្ថភាពក្នុងការពង្រឹងការអនុវត្តកិច្ចសន្យា និងច្បាប់កម្មសិទ្ធិទ្រព្យសម្បត្តិ ចូលរួមគ្នាបន្តិចម្តងៗ បង្កើតអោយមានចំណាយខ្ពស់ដល់អ្នកវិនិយោគក្នុងស្រុក និងបរទេស ។ ជាងនេះទៅទៀត ប្រជាពលរដ្ឋកម្ពុជាទូទៅដែលមានបំណងប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើកសិកម្ម នេសាទត្រី ឬការធ្វើជំនួញ ក៏ទទួលរងនូវបន្ទុកនេះដែរ ។ ជាលទ្ធផល ការវិនិយោគទុនឯកជនក៏ត្រូវបានរារាំង ហើយកំណើនសេដ្ឋកិច្ច ក៏មានល្បឿនយឺតជាងធម្មតា ។ ដោយនឹងមានការធ្លាក់ចុះនូវការនាំចេញវាយនភណ្ឌ ដូចបានកត់សំគាល់ខាងលើ កំណើននឹងថយចុះ ព្រមទាំងនឹងមានការធ្លាក់ចុះនូវសមត្ថភាពរបស់ប្រទេសនេះ ក្នុងការកាត់បន្ថយភាពក្រីក្រអោយបានខ្លាំងក្លា លើកលែងតែរដ្ឋាភិបាល ធ្វើការដោះស្រាយបញ្ហាអភិបាលកិច្ចនេះជាបន្ទាន់ ។ ដូច្នេះដូចដែលរដ្ឋាភិបាលបានកត់សំគាល់នៅក្នុងយុទ្ធសាស្ត្រ ចតុកោណថា ការធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ចគឺជាបេះដូងនៃរបៀបវារៈក្នុងការកាត់បន្ថយភាពក្រីក្រ ។

## គ. កំណែទំរង់ជាអាទិភាព

២៧. ការបរាជ័យនៃគណនេយ្យភាព និងអភិបាលកិច្ចដែលបានរៀបរាប់ខាងលើ គឺពុំមែនជារឿងចំឡែកនៅបណ្តាប្រទេសដែលបានឆ្លងកាត់អន្តរកាលនៅពេលទន្ទឹមគ្នា និងដ៏ស្មុគស្មាញ ។ ប្រទេសកម្ពុជា កំពុងឆ្លង

កាត់អន្តរកាល ៖

- ពីអភិបាលកិច្ចតាមបែបមជ្ឈការនិងឋានានុក្រមយ៉ាងខ្លាំង ដែលចាំបាច់ដើម្បីស្តារឡើងវិញនូវសណ្តាប់ធ្នាប់និងស្ថិរភាពក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយជំលោះ ទៅអភិបាលកិច្ចមួយដែលអំណាចត្រូវគេបែងចែកតាមប្រព័ន្ធវិមជ្ឈការ ទាំងតាមបណ្តាញខ្សែបណ្តោយ និងទទឹង ។
- ពីសង្គមគ្របបណ្តប់ដោយបណ្តាញការងារនិងច្បាប់ទម្លាប់មិនផ្លូវការ ទៅសង្គមមួយដែលផ្អែកជាសំខាន់លើច្បាប់ទម្លាប់ជាផ្លូវការ ។
- ពីសេដ្ឋកិច្ចផ្អែកលើកសិកម្មដែលគ្រប់គ្រងដោយរដ្ឋ ដែលប្រជាពលរដ្ឋភាគច្រើនជាកសិករ ទៅសេដ្ឋកិច្ចមួយដែលផ្អែកលើទីផ្សារចំរុះ ។

២៨. ការឆ្លងអន្តរកាលបែបនេះ ទាមទារយ៉ាងខ្លាំងអោយមានភាពជាអ្នកដឹកនាំផ្នែកនយោបាយរបស់ប្រទេសជាតិមួយ ពីព្រោះអន្តរកាលបែបនេះតំរូវអោយមានក្រុមទទួលអត្ថប្រយោជន៍ផ្ទាល់ខ្លួនដែលមានអំណាចដែលក្រុមទាំងនេះត្រូវបានបញ្ចូលយ៉ាងជិត ស្និទ្ធទៅក្នុងរចនាសម្ព័ន្ធអំណាចរបស់ប្រទេស និង ទាមទារអោយមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវច្បាប់ទម្លាប់ និងការលើកទឹកចិត្ត ដែលប្រទេសនេះកំពុងប្រតិបត្តិ ។ អន្តរកាលគឺកាន់តែមានភាពស្មុគស្មាញ ថែមទៀត ដោយសារតែការិយាធិតេយ្យទន់ខ្សោយ និង មានប្រាក់បៀវត្សទាប និងស្ថាប័នទន់ខ្សោយ និងពុករលួយ ដែលឆ្លុះបញ្ចាំងអោយឃើញពីកំរិតចំណូលដ៏ទាបរបស់ប្រទេសកម្ពុជា និងស្ថានភាពរបស់ប្រទេសដែលមានការអភិវឌ្ឍ ដ៏តិចតួចបំផុត ។ ម្យ៉ាងវិញទៀត ថ្នាក់ដឹកនាំមានជំរើសតិចតួច ។ និរន្តរភាពនៃស្ថានភាពបច្ចុប្បន្ន គឺមិនមែនជាជំរើសផ្សេងទេ ពីព្រោះបើល្អ វាធ្វើអោយមានភាពក្រីក្រកាន់តែធ្ងន់ធ្ងរទៅហើយបើមិនល្អ វាអាចវិលត្រឡប់ទៅក្នុង កណ្តាប់ដៃជនផ្តាច់ការ និងរដ្ឋដែលងាយនឹងមានជម្លោះ ។

២៩. ដោយពិចារណាទៅលើបរិយាកាសកំណែទំរង់ខុសៗគ្នា វាជាការសំខាន់ណាស់ដែលថា រដ្ឋាភិបាលត្រូវចេះជ្រើសរើស និង មានយុទ្ធសាស្រ្តខ្ពស់ ដោយសង្កត់ធ្ងន់លើវិស័យទាំងឡាយណាដែលអភិបាលកិច្ចមិនល្អនឹងរារាំងយ៉ាងខ្លាំងដល់ទស្សនវិស័យលើការអភិវឌ្ឍរបស់ប្រទេស ។ របាយការណ៍នេះ ពិនិត្យមើលទៅលើ

វិស័យបែបនេះមួយចំនួន។ ការពង្រឹងសង្វាក់គណនេយ្យភាព នៅក្នុងប្រទេសកម្ពុជា នឹងតំរូវអោយមានការពង្រឹងលើផ្នែកត្រួតពិនិត្យ និងតុល្យភាព ជាពិសេសតាមរយៈប្រព័ន្ធតុលាការដែលមានសមត្ថកិច្ច ស្មោះត្រង់ និងឯករាជ្យ ។ កំណែទំរង់ប្រព័ន្ធ តុលាការ ក៏ចាំបាច់ផងដែរ ក្នុងការស្តារឡើងវិញនូវទំនុកចិត្តរបស់អ្នកវិនិយោគទុន ដោយការពង្រឹងការអនុវត្ត ច្បាប់ស្តីពីសិទ្ធិលើកម្មសិទ្ធិទ្រព្យសម្បត្តិ និងកិច្ចសន្យា ។ វិធានការជាបន្ទាន់ ក៏ជាតំរូវការចាំបាច់ផងដែរ ក្នុងការបញ្ឈប់កេងប្រវ័ញ្ចលើធនធានហិរញ្ញវត្ថុ និងធម្មជាតិរបស់ប្រទេសជាតិ ។ ការណើនេះនឹងតំរូវអោយមានការពង្រឹង គណនេយ្យភាពផ្នែកហិរញ្ញវត្ថុ និងការធ្វើអោយប្រសើរឡើងនូវគណនេយ្យភាព និងតម្លាភាព នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងតាមរយៈវិមជ្ឈការនាំអោយរដ្ឋាភិបាលមានភាពជិតស្និទ្ធឡើងជាមួយប្រជាពលរដ្ឋ ដើម្បីអោយពួកគេអាចត្រួតពិនិត្យតាមដានការអនុវត្តន៍របស់រដ្ឋាភិបាលអោយបានប្រសើរឡើង ។ ចុងបញ្ចប់ អាទិភាពដ៏ខ្ពស់មួយ គឺលុបបំបាត់នូវរាល់ឧបសគ្គអភិបាលកិច្ច ដើម្បីការរីកចំរើនវិស័យឯកជន និងភាពប្រកួតប្រជែង ព្រមទាំងដើម្បីអោយមានភាពចំរុះដែលត្រូវការជាចាំបាច់ ដោយពិចារណាទៅលើការគំរាមកំហែងចំពោះការនាំចេញផ្នែកវាយនភណ្ឌរបស់ប្រទេសនេះ ។ វិស័យរបស់អភិបាលកិច្ចទាំងនេះ ត្រូវបានដាក់ចូលយ៉ាងរឹងមាំនៅក្នុងយុទ្ធសាស្ត្រចតុកោណ ។ នៅក្នុងករណីនៃគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ រដ្ឋាភិបានចាប់ផ្តើមរួចរាល់ហើយក្នុងការអនុវត្តកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ ។ សំរាប់វិស័យឯកជន រដ្ឋាភិបាលបានបង្កើតផែនការសកម្មភាពមួយ ដើម្បីកាត់បន្ថយការចំណាយក្នុងការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា ។ ដូចគ្នាដែររដ្ឋាភិបាល បានធ្វើកិច្ចការជាច្រើនលើផ្នែកកំណែទំរង់ប្រព័ន្ធតុលាការ និងបានរៀបចំផែនការសកម្មភាពសំរាប់រយៈពេលខ្លី និងមធ្យម ។ ដំណើរការអភិវឌ្ឍន៏យុទ្ធសាស្ត្រស្រដៀងៗគ្នា គឺកំពុងចាប់ផ្តើមនៅក្នុងផ្នែកវិមជ្ឈការ និងការគ្រប់គ្រងធនធានធម្មជាតិ ។

៣០. ជំរើសនៃវិស័យទាំង៥នេះ គឺមិនមានបំណងថា វិស័យនៃអភិបាលកិច្ចផ្សេងៗទៀត មានសារៈសំខាន់តិចជាងនោះទេ ។ មានបញ្ហាជាច្រើន ដូចជា ការពង្រឹងរដ្ឋសភាជាតិ ឬសង្គមស៊ីវិល ដែលបញ្ហាទាំងនេះ ហួសពីជំនាញរបស់ធនាគារ ហើយបញ្ហាទាំងនេះ ពិតជាមានសារៈសំខាន់ ។ របាយការណ៍នេះ ក៏មិនផ្តល់ជាយោបល់ថា អភិបាលកិច្ច គឺជាបញ្ហាប្រឈមមុខតែមួយគត់ក្នុងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាដែរ ។ ប៉ុន្តែ ដូចបានវិភាគយ៉ាងច្បាស់លាស់ពីខាងលើ វាកាន់តែក្លាយជាលក្ខខណ្ឌដ៏ សំខាន់ដំបូងសំរាប់ការរីកចំរើន និងការកាត់បន្ថយភាពក្រីក្រប្រកបដោយ និរន្តរភាព ។ ជាពិតណាស់ការកើនឡើងនៃការគំរាម កំហែងចំពោះ

ទស្សនវិស័យនៃការរីកចំរើនរបស់ប្រទេសកម្ពុជាក្នុងរយៈពេលពីខ្លីទៅមធ្យម ដែលបានលេចឡើងចេញពីការថយចុះនូវការនាំចេញផ្នែកវាយភណ្ឌដែលគេរំពឹងទុក ដែលការនាំចេញផ្នែកនេះ បានជំរុញអោយមានកំណើនសេដ្ឋកិច្ចនាពេលថ្មីៗរបស់ប្រទេសនេះ និងទំនាក់ទំនងដ៏ជិតស្និទ្ធរវាងកត្តាអភិបាលកិច្ច និងបរិយាកាសវិនិយោគទុនទន់ខ្សោយ បង្ហាញថាកំណែទំរង់អភិបាលកិច្ច ត្រូវតែស្ថិតនៅលើរបៀបវារៈយ៉ាងចាំបាច់របស់រដ្ឋាភិបាល ។

## ឃ. ការពង្រឹងការត្រួតពិនិត្យនិងតុល្យភាពតាមរយៈកំណែទំរង់វិស័យយុត្តិធម៌

៣១. ដូចដែលបានកត់សំគាល់ខាងលើ រដ្ឋសភាជាតិដែលគ្មានប្រសិទ្ធភាព និងវិស័យយុត្តិធម៌ដែលមិនបានបំពេញមុខងារត្រឹមត្រូវ ធ្វើអោយប៉ះពាល់ការចែករំលែកអំណាចរវាងអង្គទាំងបីរបស់រដ្ឋាភិបាល ដែលបានចែងយ៉ាងច្បាស់ នៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ។ ផ្នែកនេះផ្តោតទៅលើកំណែទំរង់វិស័យយុត្តិធម៌ដែលវិស័យនេះមានសារៈ សំខាន់ក្នុងការធានានូវគណនេយ្យភាពរបស់អង្គនីតិប្រតិបត្តិព្រមទាំងការពង្រឹងការអនុវត្តច្បាប់របស់ប្រទេស ពោលគឺការពង្រឹងការអនុវត្តន៍កិច្ចសន្យា និងការដោះស្រាយទំនាស់ ។ យុទ្ធសាស្ត្រកំណែទំរង់ច្បាប់ និងតុលាការដ៏ទូលំទូលាយមួយ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី កាលពីខែមិថុនា ឆ្នាំ ២០០៣ ។ បន្ទាប់ពីការអនុម័តនេះ រាជរដ្ឋាភិបាលក្រោមការដឹកនាំ*ស្ថាប័នសំរបសំរួលអចិន្ត្រៃយ៍* (PCB) នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងតុលាការ បានធ្វើការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ជាមួយទីភ្នាក់ងាររដ្ឋាភិបាល សង្គមស៊ីវិល និងម្ចាស់ជំនួយ ។ បន្ទាប់ពីនេះមក គេឃើញមាននូវផែនការសកម្មភាពសំរាប់រយៈពេលខ្លី (២០០៤-២០០៦) និងសំរាប់រយៈពេលមធ្យម (២០០៤-២០០៨) ។ ផែនការទាំងនេះ ទាមទារអោយមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំង ។ ប៉ុន្តែពួកវាក៏បង្ហាញអោយឃើញពី ការរីកចំរើនយ៉ាងសំខាន់នៅក្នុងការគិតគូររបស់រដ្ឋាភិបាលនៅក្នុងវិស័យនេះ ។ បច្ចុប្បន្ន រដ្ឋាភិបាលថ្មី ចាំបាច់ត្រូវធ្វើការសំរេចចិត្តអោយបានច្បាស់ ដើម្បីចាប់ផ្តើមដំណើរការកំណែទំរង់ រៀបចំថវិកា និងធនធានមនុស្សគ្រប់គ្រាន់ដើម្បីអនុវត្តការងារនេះ និងបង្ហាញអោយឃើញនូវវឌ្ឍនភាពជាក់ស្តែងនៅក្នុងវិស័យជាយុទ្ធសាស្ត្រមួយចំនួន ។ ជាពិសេស :

៣២. *ភាពជាអ្នកដឹកនាំដ៏រឹងមាំ គឺជាតំរូវការចាំបាច់សំរាប់ដំណើរការកំណែទំរង់ ។* ការខិតខំប្រឹងប្រែងលើកំណែទំរង់ច្បាប់ និងតុលាការ ចាំបាច់ត្រូវផ្ទេរទៅអោយស្ថាប័នអន្តរក្រសួងមួយ ដែលតំណាងអោយ

ទីភ្នាក់ងារសំខាន់ៗ និងដឹកនាំដោយអ្នកជំនាញ កំណែទំរង់ពិតប្រាកដ និងប្រកបដោយថាមវន្ត និងមានកេរ្តិ៍ឈ្មោះទាំងផ្នែកវិជ្ជាជីវៈច្បាប់ និងកិច្ចការសាធារណៈទូទៅផង និងមានការគាំទ្រយ៉ាងខ្លាំងពីខាងផ្នែកនយោបាយ នៅក្នុងកំរិតដ៏ខ្ពស់បំផុតមួយ ។ ស្ថាប័ននេះ ចាំបាច់ត្រូវមានអំណាច ដើម្បីធ្វើសនិទានកម្មលើអ្វីមួយដែលធ្វើអោយច្របូកច្របល់ និងដែលជាន់គ្នានូវការទទួលខុសត្រូវរបស់ទីភ្នាក់ងារតាមផ្នែកសំខាន់ៗ ដូចជា ក្រសួងយុត្តិធម៌ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (SCM) ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងតុលាការ ព្រមទាំងតុលាការកំពូល ទាក់ទងនឹងយុត្តិធម៌ផ្នែករដ្ឋបាល និង និយ័តកម្មច្បាប់ ការដោះស្រាយបណ្តឹងអធិការកិច្ចតុលាការនិងការដាក់ទណ្ឌកម្មពិន័យ និងកំណត់អ្នកដើរតួនាទី *ទាំងអស់* ដែលពាក់ព័ន្ធនៅក្នុងដំណើរការ និងគណនេយ្យភាពដោយឡែកៗរបស់ពួកគេ ។ ស្ថាប័ននេះ ចាំបាច់ត្រូវទទួល យកសេចក្តីព្រាងនៃផែនការសកម្មភាពថ្មីនេះ និងផ្តល់អាទិភាពអោយវា ព្រមទាំងផ្តោតការយកចិត្តដាក់ទៅ លើសកម្មភាពជាយុទ្ធសាស្ត្រ[៦] ។ ផែនការបែបនេះតំរូវអោយមានហិរញ្ញវត្ថុគ្រប់គ្រាន់ និងគ្មានភាពមិនប្រាកដប្រជា ដែលសំគាល់នូវដំណើរគំរោងថវិកាកម្ពុជា ។

**៣៣.កំណែទំរង់ចាំបាច់ត្រូវចាប់ផ្តើមជាមួយ SCM :** សមាជិកភាព[៧] បច្ចុប្បន្នរបស់ SCM (ក្រៅពីអតីតព្រះមហាក្សត្រដែលបច្ចុប្បន្នព្រះអង្គចូលនិវត្ត ដែលជាព្រះប្រធាននៃ SCM ប៉ុន្តែព្រះអង្គកំរនឹងយាងចូលក្នុងកិច្ចប្រជុំណាស់) ទទួលឥទ្ធិពលពីគណៈបក្សនយោបាយកាន់អំណាចណាមួយ ។ រដ្ឋាភិបាល ត្រូវពិចារណាអំពីការតែងតាំងបុរស ឬស្ត្រីដែលសុចរិត និងមានសមត្ថភាពខ្ពស់ ដែលមិនពាក់ព័ន្ធនឹងគណៈបក្សនយោបាយ ឬទំនាស់លើផលប្រយោជន៍នៅថ្ងៃអនាគត ។ ដំណើរការតែងតាំង ចាំបាច់ត្រូវធ្វើអោយឃើញថាមានលក្ខណៈមិនលំអៀង និងមានឯករាជ្យពីឥទ្ធិពលរបស់អង្គនីតិប្រតិបត្តិ ហើយមានទំរង់គំរូជាលក្ខណៈអន្តរជាតិជាច្រើន ដែលគេអាចយកមកប្រើប្រាស់បាន ។ SCM ដែលបានធ្វើកំណែទំរង់រួចហើយ គួរតែទទួលបានហិរញ្ញប្បទាន និងការគាំទ្រគ្រប់គ្រាន់ពីក្រសួងយុត្តិធម៌ ដើម្បីបំពេញនូវការទទួលខុស ត្រូវរបស់ខ្លួនក្នុងការឃ្លាំមើលសេចក្តីព្រាងច្បាប់ដែលទាក់ទងទៅនឹងប្រព័ន្ធតុលាការ និងសេចក្តីសំរេចចិត្តនានា ដែលពាក់ព័ន្ធនឹងការតែងតាំង ការផ្ទេរ ការតំលើងឋានៈ និងវិធានការផ្នែកវិន័យ នៅក្នុងប្រព័ន្ធតុលាការ ។

**៣៤. SCM ដែលបានធ្វើកំណែទំរង់រួចហើយ ចាំបាច់ត្រូវចាប់ផ្តើមដោយការការផ្លាស់ប្តូររចនាសម្ព័ន្ធនៅក្នុងតុលាការជាន់ខ្ពស់នានា ។** វានឹងត្រូវការពេលវេលា ដើម្បីធ្វើអោយតុលាការកម្ពុជាមានលក្ខណៈប្រកប

វិជ្ជាជីវៈ ។ ប៉ុន្តែកំណែទំរង់ចាំបាច់ត្រូវចាប់ផ្តើមជាមួយតុលាការកំពូល តុលាការឧទ្ធរណ៍ ហើយអាចចាប់ផ្តើមជាមួយតុលាការខេត្តមួយ ឬពីរផងដែរ ។ កំណែទំរង់លើប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងការផ្តល់ផលប្រយោជន៍ផ្សេងៗទៀតដល់តុលាការទាំងនេះ ចាំបាច់ត្រូវចង់ភ្ជាប់ជាមួយនឹងការជ្រើសរើសបុគ្គលិកថ្មីៗ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាក់លាក់ជាងមុន និងត្រូវមានក្រមចរិយាធម៌ច្បាស់លាស់ ។ ការអនុម័តច្បាប់ស្តីពីស្ថានភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា ដែលអូសបន្លាយពេលយ៉ាងយូរ ចាំបាច់ត្រូវធ្វើអោយស្របច្បាប់ឡើងនូវការជ្រើសរើស បុគ្គលិក ការបណ្តុះបណ្តាល ការផ្តល់ប្រាក់បៀវត្ស និងការចូលនិវត្តន៍របស់ចៅក្រម ព្រមទាំងបញ្ជាក់អោយបានច្បាស់លាស់អំពីការ ចាត់វិធានការ ផ្នែកវិន័យអោយសមស្រប ។

៣៥. ជំហានទាំងបីនេះ ចាំបាច់ត្រូវអមដោយវិធានការផ្សេងៗមួយចំនួន ។ ការអនុម័តច្បាប់ទំនើបៗស្តីពីនីតិវិធីរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ដែលឆ្លុះបញ្ចាំងអោយឃើញពីតំរូវការរបស់ប្រជាពលរដ្ឋកម្ពុជាសព្វថ្ងៃនេះ និងដែលផ្អែកលើការពិគ្រោះយោបល់គ្រប់គ្រាន់ ព្រមទាំងមានការផ្សព្វផ្សាយច្បាប់ទាំងនេះអោយបានទូលំទូលាយ តាមរយៈការបណ្តុះបណ្តាល និងមធ្យោបាយផ្សេងៗទៀត នឹងជួយដល់ការបំពេញមុខងាររបស់ប្រព័ន្ធច្បាប់ ។ ច្បាប់ចាំបាច់ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយអោយបានទូលំទូលាយ ហើយសាលក្រមតុលាការចាំបាច់ត្រូវផ្តល់ហេតុផលត្រឹមត្រូវ និងផ្សព្វផ្សាយជាសាធារណៈ ។ កំណែទំរង់លើសមាគមគណៈមេធាវីកម្ពុជា ដើម្បីពង្រឹងការអនុវត្តន៍ក្រមចរិយាធម៌អោយបានត្រឹមត្រូវដល់សមាជិករបស់ខ្លួនក៏មានប្រយោជន៍ផងដែរ ។ កំណែទំរង់លើប្រព័ន្ធនរគបាល និងការជំនុំជំរះក្តី ក៏នឹងត្រូវការជាចាំបាច់ ប្រសិនបើការធ្វើអោយប្រសើរឡើងនៅក្នុងតុលាការព្រហ្មទណ្ឌមិនត្រូវបានគេធ្វើវិទ្ធង្សនា ដោយករណីស៊ើបអង្កេតដែលគ្មានសមត្ថកិច្ច និងពុករលួយ ។

៣៦. ខណៈពេលដែលប្រព័ន្ធច្បាប់ជាផ្លូវការមួយ កំពុងត្រូវបានគេធ្វើកំណែទំរង់ សេចក្តីព្រាងផែនការសកម្មភាពនានា កំពុងផ្តោតយ៉ាងសមស្របលើរបៀបដោះស្រាយទំនាស់ផ្សេងទៀត ។ អ្នកវិនិយោគទុនបរទេស ពឹងផ្អែកទៅលើអាជ្ញាកណ្តាលពាណិជ្ជកម្មអន្តរជាតិ ប៉ុន្តែអ្នកវិនិយោគទុនក្នុងស្រុក គួរទទួលបានផលប្រយោជន៍ពីមជ្ឈមណ្ឌលដោះស្រាយទំនាស់មួយផ្សេងទៀត ដែលគួរទទួលបានការសំរបសំរួលពីច្បាប់ស្តីអំពីអាជ្ញាកណ្តាលពាណិជ្ជកម្ម ។ ទំនាស់ក្នុងស្រុកភាគច្រើនត្រូវបានដោះស្រាយនៅខាងក្រៅប្រព័ន្ធច្បាប់ជា ផ្លូវការ និងប្រព័ន្ធតុលាការ (សូមមើលជំពូក៤) តាមរយៈគណៈកម្មការសុរិយោដី និងគណៈកម្មាធិការ

ដោះស្រាយទំនាស់ថ្នាក់ឃុំ និងភូមិ ។ វាមានសារៈសំខាន់ណាស់ ក្នុងការស្វែងយល់អោយបានប្រសើរឡើង ពីដំណើរនៃការងារទាំងនេះ និងពីរបៀបដែលគេអាចពង្រឹងកិច្ចការទាំង នេះបន្ថែមទៀត ។

៣៧. គោលដៅដ៏ប្រសើរក្នុងការបង្កើត "នីតិរដ្ឋ" នៅតែមានភាពស្រពិចស្រពិល រហូតដល់មន្ត្រីរដ្ឋាភិបាលកម្ពុជា យល់ឃើញថា ពួកគេត្រូវភ្ជាប់កាតព្វកិច្ចដោយច្បាប់ និងរហូតដល់បុគ្គលទាំងអស់ មានសិទ្ធិស្មើគ្នា និងភាពថ្លៃថ្នូរ ចំពោះមុខច្បាប់ ហើយថាយុត្តិធម៌កើតមានដល់មនុស្សគ្រប់រូប ។ ការណ៍នេះនឹងអាចកើតមានឡើងបាន លុះត្រាតែមានការផ្លាស់ប្តូរចំបងៗលើទំនាក់ទំនងនយោបាយ សង្គម និងសេដ្ឋកិច្ច នៅក្នុងសង្គមកម្ពុជា ដែលការផ្លាស់ប្តូរនឹងងាកទៅរកគ្រឿងលើកទឹកចិត្តដល់មន្ត្រីរដ្ឋាភិបាល (លោក ហ្គារី ហ្គោតប៉ាស្ទ័រ ឆ្នាំ ២០០៣) ។ ដូច្នេះ វាពិតជាមានសារៈសំខាន់ណាស់ ដែលគេត្រូវមានភាពប្រាកដប្រជាលើអ្វីដែលអាចរំពឹងថា នឹងទទួលបានជោគជ័យក្នុងការធ្វើ កំណែទំរង់ប្រព័ន្ធតុលាការ ។ ការបង្កើនថវិកាសំរាប់ក្រសួងយុត្តិធម៌វានឹងអាចជាសញ្ញាដ៏សំខាន់មួយពីរដ្ឋាភិបាលសំរាប់ការប្តេជ្ញាខ្ពស់ក្នុងការកែទំរង់ច្បាប់ និងតុលាការនៅកម្ពុជា។ ម្ចាស់ជំនួយអាចជួយបង្កើនការយល់ដឹងជាសាធារណៈ នៅក្នុងប្រទេសកម្ពុជា អំពីសារៈសំខាន់នៃប្រសិទ្ធភាពរបស់វិស័យយុត្តិធម៌ ក្នុងការស្តារឡើងវិញនូវការរីកចំរើន និងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ។

## តើគណៈកម្មការប្រឆាំងនឹងអំពើពុករលួយ គឺជាចម្លើយមួយ ចំពោះប្រព័ន្ធតុលាការដែលមិនបានបំពេញមុខងារត្រឹមត្រូវឬ?

៣៨. ដោយវិស័យយុត្តិធម៌រឹតតែមិនបានបំពេញមុខងារត្រឹមត្រូវរដ្ឋាភិបាល កំពុងងាកទៅរកគណៈកម្មការប្រឆាំងនឹងអំពើពុករលួយ ដើម្បីដោះស្រាយបញ្ហាពុករលួយនៅក្នុងប្រព័ន្ធតុលាការខ្លួនឯង និងនៅកន្លែងផ្សេងទៀត ។ យុទ្ធសាស្ត្រចតុកោណរបស់ប្រទេសកម្ពុជា ធ្វើអោយរដ្ឋាភិបាលប្តេជ្ញាចិត្ត " លើកកំពស់ការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ និងបង្កើតស្ថាប័នឯករាជ្យមួយ ដើម្បីប្រឆាំងនឹងអំពើពុករលួយ" (រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណឆ្នាំ ២០០៤) ហើយក៏ " ចាត់វិធានការរឹងមាំនានា ដែលជីកឫសគល់នៃអំពើពុករលួយ" (រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណឆ្នាំ ២០០៤) ។ សេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយ មានលក្ខណៈខ្វះខាតនូវរបៀបអនុវត្តអន្តរជាតិល្អៗ ដែលមាន ចែងនៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ (UNCAC) ហើយមានបញ្ហាធ្ងន់ធ្ងរអំពី ភាពស៊ីចង្វាក់ផ្ទៃ

ក្នុងរបស់ខ្លួន ដោយបង្កើននូវបញ្ហាដែលមិនអាចជៀសបានលើការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ ។ ពង្រាងច្បាប់នេះ បានកំណត់អំពើពុករលួយយ៉ាងទូលំទូលាយ ដែលជាមធ្យោបាយដ៏ត្រឹមត្រូវមួយ សំរាប់ចាប់ផ្តើម ប៉ុន្តែវាក៏ខកខានមិនបានកំណត់អោយបានប្រសើរឡើងនូវផ្នែកជាច្រើនទៀតនៃពង្រាងច្បាប់នេះ ។ បក្ខពួកនិយម និងទំនាស់លើផលប្រយោជន៏ ត្រូវបានដោះស្រាយតាមការយល់ឃើញប៉ុណ្ណោះ ។ ចាំបាច់ត្រូវមានតម្លាភាពជាងនេះទៀត លើលក្ខខណ្ឌដែលពាក់ព័ន្ធនឹងការប្រកាសទ្រព្យសម្បត្តិ ពោលគឺ អ្នកអនុវត្តសេចក្តីត្រូវការព័ត៌មានដែលត្រូវផ្សព្វផ្សាយជាសាធារណៈ និងការដាក់ពិន័យដែលទាក់ទងនឹងការខកខានមិនបានប្រកាសទ្រព្យសម្បត្តិ ។ ប្រព័ន្ធប្រកាសទ្រព្យសម្បត្តិដែលបំពេញមុខងារត្រឹមត្រូវ និងឯករាជ្យ គឺជាមធ្យោបាយទប់ស្កាត់អំពើពុករលួយដ៏មានប្រយោជន៏មួយ ។ ច្បាប់នេះ ក៏ខកខានមិនបានហាមឃាត់ដល់ការលាងលុយកខ្វក់ ឬបិទបាំងផលប្រយោជន៏ពីអំពើពុករលួយ ។ ចាំបាច់ត្រូវមានវិធានាការជាបឋម ដើម្បីធ្វើអោយច្បាប់នេះ ស្របទៅតាម UNCAC មុនពេលច្បាប់នេះត្រូវគេអនុម័ត ។ បទបញ្ញត្តិដែលអមជាមួយច្បាប់នេះ គួរប្រើប្រាស់នូវវិធានច្បាស់លាស់មួយសំរាប់ហាមឃាត់មិនអោយ ឬបើកអោយមានការបកស្រាយផ្សេងពីនេះ ។

៣៩. *ឧត្តមក្រុមប្រឹក្សាប្រឆាំងនឹងអំពើពុករលួយ* ដែលបានស្នើឡើង គឺជាយានដ៏ចំបងសំរាប់ការអនុវត្តច្បាប់ថ្មី។ បទពិសោធន៏របស់ស្ថាប័នស្រដៀងគ្នានេះ នៅក្នុងបណ្តាប្រទេសដទៃទៀត មិនមានការជំរុញទឹកចិត្តឡើយ ហើយលក្ខខណ្ឌដែលធ្វើអោយស្ថាប័នទាំងនោះទទួលបានជោគជ័យ គឺត្រូវការចាំបាច់ណាស់សំរាប់ប្រទេសដែលមាន ស្ថាប័ននៅទន់ខ្សោយ (លោក ប៉ាទ្រិក មេហ្គើ ឆ្នាំ ២០០២) ។ ប្រសិនបើក្រុមប្រឹក្សានេះដំណើរការបានយ៉ាងហោចណាស់ក្រុមប្រឹក្សានេះត្រូវការ សមាជិកដែលមានភាពសុចរិត និងមានភាពឯករាជ្យខ្ពស់ ព្រមទាំងត្រូវការនូវថវិកាគ្រប់គ្រាន់សំរាប់ដំណើរការការងាររបស់ខ្លួន ។ រដ្ឋាភិបាល ក៏ចាំបាច់ត្រូវធានាអោយមានបរិយាកាសគាំទ្រដែលក្នុងនោះឯករាជ្យភាព និងអំណាច របស់ក្រុមប្រឹក្សានេះ ត្រូវគេគោរព និងការពារមិនអោយមានការជ្រៀតជ្រែកផ្នែកនយោបាយ ។ នគរបាល និង តុលាការ នឹងត្រូវធ្វើការជាមួយដោយមិនជំទាស់នឹងក្រុមប្រឹក្សានេះ ប្រសិនបើសេចក្តីសំរេចរបស់ក្រុមប្រឹក្សានេះ ត្រូវគេដាក់អោយអនុវត្ត។ ក្រុមប្រឹក្សាថ្មីនេះ ត្រូវមានយុទ្ធសាស្ត្រ និងការជ្រើសរើសនៅក្នុងរបៀបវារៈរបស់ខ្លួន ដែលមិនធ្វើអោយស្ថាប័ននេះចុះឥទ្ធិពល ហើយនេះជាកំហុសធម្មតាមួយដែលស្ថាប័នដទៃទៀតដូចគ្នានេះតែងជួបប្រទះ ។ ជាចុងបញ្ចប់ ច្បាប់បំពេញបន្ថែមមួយចំនួនដទៃទៀត នឹងចាំបាច់ជួយសំរបសំរួលដល់ការរបស់ក្រុមប្រឹក្សានេះ ដូចជា

ច្បាប់ស្តីពីសេរីភាពនៃព័ត៌មាន ច្បាប់ស្តីពីការការពារសាក្សី និងច្បាប់ស្តីពីការបរិហារកេរ្តិ៍ ដែលច្បាប់ទាំងនេះការពារប្រព័ន្ធសារព័ត៌មានពីការជំនុំជំរះក្តីមិនសម ហេតុផលលើការរាយការណ៍អំពីអំពើពុករលួយ ។ ប្រទេសម្ពុជាក៏នឹងទទួលផលប្រយោជន៍ពីបទពិសោធន៍អន្តរជាតិផងដែរ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ប្រទេសកម្ពុជាបានចុះហត្ថលេខារួចមក ហើយនៅលើគំនិតផ្តួចផ្តើមប្រឆាំងអំពើពុករលួយ ប្រចាំតំបន់អាស៊ីរបស់អង្គការ ADB-OECD ។ ឥឡូវប្រទេសកម្ពុជាត្រូវតែក្លាយទៅជាហត្ថលេខីនៃអនុសញ្ញាសហប្រជាជាតិប្រឆាំងអំពើពុករលួយ ដែលបានចុះហត្ថលេខាដោយប្រទេសជាង ១០០ ក្នុងនោះរួមទាំងប្រទេសសមាជិកអាស៊ានជាច្រើនដែលជាដៃគូរបស់កម្ពុជាផងដែរ ។ ការពង្រឹងការអនុវត្តន៍ច្បាប់ គឺមានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយអំពើពុករលួយ ។ ប៉ុន្តែការប្រយុទ្ធប្រឆាំងនិងឫសគល់នៃអំពើពុលរលួយតំរូវអោយដោះស្រាយការបរាជ័យនៃគណនេយ្យភាពដែលបានបរិយាយខាងដើម ។ ដូចនេះហើយបានជាយើងបែទៅរកដោះស្រាយបញ្ហាទាំងនេះ ។

## ខ. ការកែលំអគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ

៤០. បរាជ័យផ្នែកអភិបាលកិច្ចជាលក្ខណៈប្រព័ន្ធ ប៉ះពាល់ទៅដល់តួនាទីរបស់ថវិការាជរដ្ឋាភិបាល ដែលជាឧបករណ៍មួយក្នុងការផ្តល់សេវា និងការកាត់បន្ថយភាពក្រីក្រ ។ ដូចដែលឃើញខាងលើរួចមកហើយ សង្វាក់គណនេយ្យភាពទាំងមូល រួមទាំងសេចក្តីណែនាំលើគោលនយោបាយ និងការឃ្លាំមើលដែលមិនគ្រប់គ្រាន់ដោយសភាជាតិ ព្រមទាំងភាពស្ទើរតែគ្មានគណនេយ្យភាពឯករាជ្យ តាមរយៈសវនកម្មឯករាជ្យ និងការឃ្លាំមើលរបស់សង្គមស៊ីវិល គឺនៅមានកំហុសឆ្គងច្រើន ។ ជាងនេះទៅទៀត ប្រាក់ចំណូលទាបជំរុញអោយមានការខ្វះថវិកាដោយសារ តែការិយាធិបតេយ្យដែលពុករលួយ និងទន់ខ្សោយ មិនអាចមានលទ្ធភាពធ្វើការខំប្រឹងប្រែងរកប្រាក់ចំណូលអោយបានខ្ជាប់ខ្ជួន ។ ម្យ៉ាងវិញទៀត កង្វះខាតហិរញ្ញប្បទានជំរុញអោយមានអំពើពុករលួយ ពីព្រោះវាជាកត្តាមួយធ្វើអោយមន្ត្រីរាជការស៊ីវិលមិនបានទទួលប្រាក់បៀវត្ស និងធនធានគ្រប់គ្រាន់សំរាប់បំពេញការងាររបស់ពួកគេ ។ មានសមាស ធាតុ ៤ សំខាន់ៗ ក្នុងការធ្វើអោយប្រសើរឡើងនូវគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈនេះ

៤១. *កំណែទំរង់ចាំបាច់ត្រូវចាប់ផ្តើមជាមួយនឹងការខិតខំប្រឹងប្រែង ធ្វើអោយប្រាក់ចំណូលមានភាពប្រសើរឡើង:* រដ្ឋាភិបាលថ្មី ធ្វើការប្តេជ្ញាចិត្ត ដើម្បីបង្កើនប្រាក់ចំណូលពីចំនួនដែលមិនគ្រប់គ្រាន់បច្ចុប្បន្ន ពោលគឺ១០ ភាគរយ នៃផលិតផលក្នុងស្រុកសរុប ដែលទាបជាងកំរិតជាមធ្យម របស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលទាប (១៦ ភាគរយ) ទៅចំនួនប្រហែល ១៤ ភាគរយ មុនឆ្នាំ២០០៩ ដែលទស្សនវិស័យលើកំណើនកំពុងថយចុះ នឹងមិនអាចមានលក្ខណៈប្រសើរឡើយ ប្រសិនបើគ្មានការធ្វើអោយប្រសើរឡើងវិញយ៉ាងខ្លាំងក្លាលើរដ្ឋបាលពន្ធដារ ។ កំណែលំអបែបនេះ មិនគួររងចាំរហូតដល់មានការកែទំរង់សេវាស៊ីវិល ដ៏ធំមួយនោះទេ ។ រដ្ឋាភិបាលថ្មី ត្រូវតែពិចារណាលើសាកល្បងកែប្រែដ៏ធំមួយលើការផ្តល់ការលើកទឹកចិត្ត និងការគ្រប់គ្រងការអនុវត្ត នៅក្នុងនាយកដ្ឋានពន្ធដារ និងគយ ។ រដ្ឋាភិបាលគួរតែធ្វើកិច្ចការនេះផងដែរ តាមរយៈអាជ្ញាប្រមូលចំណូលស្វយ័តមួយ ពោលគឺ ជាវិធីសាស្ត្រមួយដែលគេបានសាកល្បងដ៏ជោគជ័យនៅក្នុងបណ្តាប្រទេសជាច្រើន ឬតាមរយៈប្រព័ន្ធមួយដែលផ្អែកលើគុណសម្បត្តិ និងការបំពេញការងារក្នុងនាយកដ្ឋាន ឬអង្គភាពដែលបានជ្រើសរើស ។ ការធ្វើអោយប្រសើរឡើងនូវប្រាក់ចំណូលដែលមិនមែនពន្ធដារ នឹងតំរូវអោយកំណែទំរង់អភិបាលកិច្ចនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងអោយមានតម្លាភាពច្រើនឡើងនៅក្នុងការគ្រប់គ្រងសម្បទាននានារបស់រដ្ឋាភិបាល ដូចជា សម្បទានទាក់ទងនឹង ប្រាសាទអង្គរវត្ត ។

៤២. *ប្រសិទ្ធភាពនៃការចំណាយសាធារណៈទៅលើកម្មវិធីដែលផ្តោតទៅលើភាពក្រីក្រត្រូវតែកែលំអ* ។ ចាប់តាំងពីឆ្នាំ ១៩៩៨ រដ្ឋាភិបាលបានធ្វើការកែលំអជាច្រើនទៅលើការរៀបចំធនធានជាមួយនឹងទិសដៅអភិវឌ្ឍន៍របស់ខ្លួន តាមរយៈការបង្កើនយ៉ាងខ្លាំងចំពោះការចំណាយទៅលើវិស័យអាទិភាពនានា ពី / ភាគរយ ទៅ ៣,២ ភាគរយ នៃផលិតផលក្នុងស្រុកសរុប ។ ហើយប្រទេសកម្ពុជា មានផែនការបន្តបង្កើនចំណាយនៃវិស័យអាទិភាពនានានៅក្នុងឆ្នាំខាងមុខៗ ។ ការណ៍នេះបានធ្វើអោយវិស័យអប់រំចំណាយកាន់តែច្រើន ដោយមានទិសដៅជួយដល់ជនក្រីក្រ ចំណែកឯការចំណាយទៅលើវិស័យសុខាភិបាលមានចំណាត់ថ្នាក់បន្ទាប់បន្សំ ។ ប៉ុន្តែ ការណ៍នេះមិនទាន់បានធ្វើអោយមានផលប៉ះពាល់ធំដុំទៅលើអាំងឌីកាទ័រសង្គម ដែលឆ្លុះបញ្ចាំងអំពីសេចក្តីត្រូវការកែលំអ ប្រសិទ្ធភាពក្នុងការចំណាយតាមរយៈការផ្សារភ្ជាប់ការចំណាយអោយកាន់តែជិតស្និទ្ធទៅនឹងលទ្ធផលជាអាទិភាព និងតាមរយៈការពង្រឹងយន្តការនៃគណនេយ្យភាព ។ ការកែលំអយន្តការគណនេយ្យភាព និងលទ្ធភាពទទួលបានពត៌មានដែលនឹងជួយដល់សង្គមស៊ីវិល និងប្រជា

ពលរដ្ឋ ជំរុញអោយរដ្ឋាភិបាលមានភាពទទួលខុសត្រូវចំពោះការផ្តល់សេវាជួយដល់ជនក្រីក្រ នឹងមានសារៈសំខាន់ ចំពោះការធ្វើអោយប្រសើរឡើងនូវផលប៉ះពាល់នៃការចំណាយសំរាប់កាត់បន្ថយភាពក្រីក្រ ។

៤៣. *ហានិភ័យនៃមូលនិធិសាធារណៈត្រូវកាត់បន្ថយ ។* ហានិភ័យនៃមូលនិធិសាធារណៈ គឺមានកំរិតខ្ពស់ ដោយសារតែភាពទន់ខ្សោយលើផ្នែកទាំងបីនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ : ការរៀបចំគំរោងថវិកា ការអនុវត្ត និងរបាយការណ៍។ ប្រព័ន្ធរបស់ប្រទេសកម្ពុជាត្រូវបានគេចាត់ថ្នាក់ទាបជាងកំរិតមធ្យម បើធៀបនឹងប្រទេសជិតខាងដែលស្ថិត ក្នុងចំណោមប្រទេសដែលមានប្រាក់ចំណូលទាប។ គណនេយ្យភាព គឺមានភាពទន់ខ្សោយតម្លាភាពគឺមានកំរិតទាប ហើយអំពើពុករលួយត្រូវបានគេរាយការណ៍ថាមានកំរិតខ្ពស់ខ្លាំង។ កំណែទំរង់គឺមានភាពចាំបាច់ត្រូវអនុវត្តពីថ្នាក់ លើរហូតដល់ថ្នាក់ក្រោមនៃសង្វាក់គណនេយ្យភាព ។ ការឃ្លាំមើលរបស់សភាចាំបាច់ត្រូវពង្រឹង ។ *គណៈកម្មាធិការទទួលបន្ទុក ហិរញ្ញវត្ថុ និងធនាគារ* (FCB) របស់រដ្ឋសភាជាតិ ត្រូវបើកចំហការពិភាក្សារបស់ខ្លួនដល់សាធារណជន ហើយផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ខ្លួនឯង និងរដ្ឋសភាជាតិ ដើម្បីពិភាក្សាដេញដោលអំពីថវិកា ។ ការពង្រឹងការគាំទ្រ FBC សមាជិករដ្ឋសភាជាតិអោយមានការយល់ដឹង និងរួមចំណែកកាន់តែប្រសើរឡើងចំពោះ ការធ្វើគោលនយោបាយស្តីពីគំរោងថវិកា នឹងមានប្រយោជន៍ផងដែរ ។ បរិយាកាសត្រួតពិនិត្យលើចំណាយសាធារណៈ ក៏ចាំបាច់ត្រូវកែលំអផងដែរ ។ ការផ្លាស់ប្តូរពីប្រព័ន្ធទូទាត់ដោយប្រើសាច់ប្រាក់ ទៅជាការផ្ទេរតាមប្រព័ន្ធធនាគារ នឹង ជួយកាត់បន្ថយដល់ការរំលោភបំពានយ៉ាងច្រើន និងការអនុវត្តន៍ការទូទាត់បែបសំរបសំរួលដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ ពីបណ្តាទីភ្នាក់ងាររដ្ឋាភិបាល ។ ការត្រួតពិនិត្យហិរញ្ញវត្ថុផ្ទៃក្នុង ចាំបាច់ត្រូវពង្រឹង ហើយអាជ្ញាធរសវនកម្មជាតិដែលនៅថ្មីថ្មោងនៅឡើយ ត្រូវការពង្រឹងបន្ថែមទៀត ហើយរបាយការណ៍របស់អាជ្ញាធរនេះ ត្រូវតែផ្សព្វផ្សាយជាសាធារណៈ ។ ការបញ្ចេញថវិកាយឺតយ៉ាវ ពោលគឺស្ទើរតែមួយភាគបីនៃការចំណាយជាប្រចាំលើផ្នែកស៊ីវិលទាំងអស់ ក្នុងឆ្នាំ២០០១ ត្រូវបានគេបើកជូននៅខែចុងក្រោយនៃឆ្នាំនោះ ដែលកត្តានេះក៏រួមចំណែកបង្កអោយការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ មិនបានល្អប្រសើរនេះ ។ កង្វះតម្លាភាពលើដំណើរការធ្វើគំរោងថវិកា ក៏រួមចំណែកបង្កអោយគណនេយ្យភាពទន់ខ្សោយដែរ ។ គំរោងថវិកា ចាំបាច់ត្រូវធ្វើអោយសាធារណៈជន មានការយល់ដឹងច្រើន ហើយចាំបាច់ត្រូវតែពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលនៅគ្រប់ដំណាក់កាលនៃវដ្តរបស់គំរោងថវិកា ។ ការណ៍នេះ នឹងតំរូវអោយមាន

ការខិតខំប្រឹងប្រែង ក្នុងការបណ្តុះបណ្តាលបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល អោយស្វែងយល់កាន់តែប្រសើរឡើងលើបញ្ហាថវិកា និងការអនុវត្តថវិកា ។

៤៤. លទ្ធកម្មសាធារណៈ នៅតែជាប្រភពដ៏សំខាន់មួយនៃអំពើពុករលួយ ។ ក្នុងខណៈដែលមានការដាក់អោយមានការប្រកួតប្រជែងក្នុងការធ្វើលទ្ធកម្ម ដែលបានដាក់អោយអនុវត្តកាលពីរឆ្នាំមុន វានៅតែមានការគ្រប់គ្រង ដោយមិនមានតម្លាភាព ច្រើននៅឡើយ ។ វិស័យឯកជន ត្អូញត្អែរថាភាគីដែលមានឈ្មោះនៅក្នុងបញ្ជីសង្ខេប សុទ្ធតែត្រូវបង់ថ្លៃឈ្នួលមិនផ្លូវការ សំរាប់ទទួលបានបុព្វសិទ្ធិ ។ ការពឹងផ្អែកទៅលើសម្បទាន ពីប្រភពតែមួយសំរាប់ គំរោង BOT ( គំរោងសាងសង់ ប្រតិបត្តិការ និងផ្ទេរ Build-operate-transfer project) បានបង្កើតនូវបរិយាកាសបិទជិតមួយក្នុងការផ្តល់សម្បទានបែបនេះ និងបានលើកទឹកចិត្តអោយមានការចរចាដោយផ្ទាល់ ដែលមានពបញ្ហោបញ្ហាចោទលើលទ្ធផល ។ កំណែទំរង់ត្រូវតែបញ្ចូលនូវច្បាប់ឯករាជ្យ ដែលមានសុពលភាពលើក្រិត្យជាច្រើន ដែលមានភាពចំរូងចំរាស់ ការត្រួតពិនិត្យតាមដានលើលទ្ធកម្មពីសង្គមស៊ីវិល និងវិស័យឯកជនដោយឯករាជ្យ ព្រមទាំងការបង្កើន តម្លាភាពលើដំណើរការរួមមានទាំងការផ្សព្វផ្សាយពាណិជ្ជកម្មអោយបានទូលំទូលាយ និងការបោះពុម្ពផ្សាយលទ្ធផល ។

៤៥. ដោយទទួលស្គាល់នូវបញ្ហាទាំងនេះ គណៈកម្មាធិការកំណែទំរង់ដែលទើបត្រូវបានតែងតាំងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំនូវកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ ដែលអនុម័តដោយនាយករដ្ឋមន្ត្រី ជាមួយនឹងសេចក្តីថ្លែងការអំពីយុទ្ធសាស្ត្រមួយ និងផែនការសកម្មភាពរំកិលដែលមានអាទិភាព ក្របខ័ណ្ឌគ្រប់គ្រងការបំពេញការងារមួយ និងសមាសភាពកំណែទំរង់ការគ្រប់គ្រងនិងចាត់តាំងបន្ថែមផងដែរ ។ អាទិភាពខ្ពស់បំផុតជាច្រើនក្នុងផែនការសកម្មភាពរបស់រដ្ឋាភិបាល ត្រូវបានកំណត់ចំពោះការអនុវត្តន៏ ដោយយោងទៅតាមកាលវិភាគមួយដែលបានឯកភាពគ្នា ជាមួយដៃគូ PFM ។ ការប្តេជ្ញាផ្នែកនយោបាយពិតប្រាកដចំពោះកម្មវិធីកំណែទំរង់មួយដោយរដ្ឋាភិបាលថ្មី នឹងចាំបាច់ត្រូវស៊ីសង្វាក់គ្នាជាមួយនឹងការគាំទ្រពីម្ចាស់ជំនួយអោយបានគ្រប់គ្រាន់ចំពោះកម្មវិធីនោះផងដែរ ។ ដៃគូនានាបានទទួលស្គាល់ថា ពួកគេអាចកែលំអការផ្តល់ជំនួយបច្ចេកទេស របស់គេដល់រដ្ឋាភិបាលផ្អែកទៅលើបទពិសោធន៏ថ្មីៗនេះ ។ បញ្ហាពិបាកបំផុតពោល គឺការផ្តល់យោបល់ដោយឡែកៗ និងផ្ទុយគ្នាពីដៃគូ កង្វះនូវភាពមិនស៊ីសង្វាក់គ្នានូវជំនួយទៅនឹងផែនការរបស់រដ្ឋាភិបាល កង្វះនូវគណនេយ្យភាពនៃជំនួយចំពោះ

រដ្ឋាភិបាល និងកង្វះនូវភាពជាអ្នកដឹកនាំរបស់រដ្ឋាភិបាល ពោលគឺ ត្រូវបានដោះស្រាយដោយបង្កើតអោយមានវិធីសាស្ត្រទូទាំងវិស័យ PFM ។ ចំណុចនេះ បើកចំហផ្លូវអោយមានភាពជឿនលឿនដំបូងនៅក្នុងវិស័យនេះ ។

*៤៦. ការកាត់បន្ថយហានិភ័យហិរញ្ញវត្ថុ នឹងត្រូវការជាមូលដ្ឋានកំណែទំរង់សេវាសាធារណៈ ។* សេវាស៊ីវិលដែលប្រាក់ឈ្នួលតិច និងផ្អែកលើការគាំទ្រ គឺជារូបមន្តមួយនៃអំពើពុករលួយកំរិតខ្ពស់ ។ យុទ្ធសាស្ត្រចតុកោណ អំពាវនាវអោយមានកំណើនប្រចាំឆ្នាំពី១០ ភាគរយ ទៅ ១៥ ភាគរយ លើប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល ទន្ទឹមនឹងមាន"ការយកចិត្តទុកដាក់ជាពិសេស" ចំពោះការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល(រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណឆ្នាំ ២០០៤)។ ការយកចិត្តទុកដាក់ជាពិសេសបែបនេះ គួរធ្វើតាមប្រព័ន្ធគ្រប់គ្រងដែលផ្អែកលើគុណសម្បត្តិ ព្រមជាមួយនឹងប្រាក់បៀវត្សខ្ពស់ជាងមុន និងមិនមានការគាបសង្កត់ ដែលស្របគ្នានឹងនិរន្តរភាពសារពើពន្ធ ។ ដោយពិចារណាលើឧបសគ្គសារពើពន្ធ សកម្មភាពនេះមិនអាចចៀសផុតពីរយៈពេលវែងទេ។ ក្នុងរយៈពេលខ្លី មធ្យោបាយកំណែទំរង់សេវាស៊ីវិល ទំនងជា តាមរយៈការដាក់អោយអនុវត្ត តាមជំហានស្របគ្នានូវការគ្រប់គ្រងផ្អែកលើគុណសម្បត្តិ និងប្រាក់បៀវត្សខ្ពស់ និងពុំមានការគាបសង្កត់សំរាប់វិស័យមុខងារ និងជំនាញ ដែលបានជ្រើសរើស ជាអាទិភាពខ្ពស់ ។ ការផ្តល់ប្រាក់បៀវត្សខ្ពស់ នឹងមានលក្ខណៈងាយស្រួលជាងក្នុងការសំរេចអោយក្នុងរយៈពេលមធ្យម ប្រសិនបើការត្រួតពិនិត្យសារឡើងវិញនូវមុខងារ ត្រូវបានគេអនុវត្តបន្តិចម្តងៗដោយរើកញែករកហេតុ និងពង្រាយបុគ្គលិកជាថ្មីនៅគ្រប់វិស័យ និងតំបន់ដើម្បីដោះស្រាយកង្វះនូវជំនាញ និងបុគ្គលិក ក្នុងវិស័យណាមួយ និងដោះស្រាយលើវិស័យផ្សេងៗទៀត ដែលមានជំនាញ និងបុគ្គលិកលើស ពីសេចក្តីត្រូវការ ។ ជាបញ្ចប់ ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនៅក្នុងយុទ្ធសាស្ត្រចតុកោណ ចំពោះការធ្វើអោយសេវាស៊ីវិល មានលក្ខណៈអព្យាក្រិតលើផ្នែកនយោបាយត្រូវទទួលបានការស្វាគមន៍ ។ អព្យាក្រិតបែបនេះ ចាំបាច់ត្រូវដាក់បញ្ចូលយ៉ាងរឹងមាំនៅក្នុងមធ្យោបាយក្នុងការជ្រើសរើស ការតំលើងឋានៈ និងការផ្ទេររបស់មន្ត្រីរាជការស៊ីវិល ។ ការណ៍នេះត្រូវភ្ជាប់ជាមួយច្បាប់ចរិយាធម៌ច្បាស់លាស់មួយ សំរាប់ហាមប្រាមមន្ត្រីរាជការស៊ីវិលមិនអោយប្រព្រឹត្តសកម្មភាព ឬចាត់ វិធានការបែបបក្ខពួកនិយម ឬហាមសកម្មភាពទាំងឡាយណា ដែលផ្ទុយនឹងការទទួលខុសត្រូវរបស់ពួកគេក្នុងការការពារផលប្រយោជន៍សាធារណៈ ។ ទោះបីជាមានការវិវឌ្ឍន៍ការងារយ៉ាងច្រើនលើសេវាស៊ីវិលក៏ដោយ ក៏រហូតមកដល់ពេលនេះ កំណែទំរង់ ក៏មិនមានលទ្ធផលគួរជាទីពេញចិត្តដែរ ។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពអាទិភាពជាបន្តបន្ទាប់ សំរាប់ការដាក់អោយអនុវត្តនូវលក្ខណៈពិសេសនៃសេវាស៊ីវិលដែលផ្អែកលើគុណសម្បត្តិជាធំ ដោយកាំប្រាក់បៀវត្សខ្ពស់នៅក្នុងវិស័យ អង្គភាព និង មុខងារបច្ចុប្បន្ន ដែលជាអាទិភាពខ្ពស់មួយចំនួនចាំបាច់ត្រូវបង្កើតឡើង ដើម្បីទទួលបានការអនុម័តពីដៃគូរបស់កម្ពុជា ។

## ច. វិមជ្ឈការៈ ជំរុញអោយរដ្ឋាភិបាលមានភាពជិតស្និទនឹងប្រជាពលរដ្ឋច្រើនឡើង

៤៧. ប្រទេសកម្ពុជា បានចាប់ផ្តើមដំណើរការប្រព័ន្ធវិមជ្ឈការគួរអោយចាប់អារម្មណ៍ ដែលប្រឈមមុខនឹងហានិយភ័យផង និងឱកាសផង ។ សមត្ថភាពទន់ខ្សោយរបស់រដ្ឋាភិបាលថ្នាក់ក្រោម និងហានិភ័យខ្ពស់នៅក្នុងបន្ទុកហិរញ្ញវត្ថុ អាចបង្កើនឱកាសបង្កអោយមានអំពើពុករលួយ ។ នៅពេលជាមួយគ្នានេះ ប្រព័ន្ធវិមជ្ឈការអាចធ្វើអោយដំណើរឆ្ពោះទៅរកគណនេយ្យភាពខ្លី ឡើងនៅពេលខាងមុខ ដោយធ្វើអោយរដ្ឋាភិបាលកាន់តែមានភាពជិតស្និទ្ធឡើងជាមួយប្រជាពលរដ្ឋ ។ យុទ្ធសាស្ត្រចតុកោណរបស់កម្ពុជាកត់សំគាល់យ៉ាងត្រឹមត្រូវថា ការអនុវត្តន៍ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ "គឺមានសារៈសំខាន់ក្នុងការពង្រឹងលទ្ធិប្រជាធិតេយ្យនៅតាមមូលដ្ឋាន ដោយធ្វើអោយប្រសើរឡើងនូវសេវាសាធារណៈ និងលើកកំពស់វប្បធម៌នៃការចូលរួម និងការអភិវឌ្ឍតាមមូលដ្ឋាន ដោយមានការចូល រួមពីប្រជាពលរដ្ឋលើក្នុងគ្រប់វិស័យទាំងអស់ (រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណឆ្នាំ ២០០៤) ។ ពីរឆ្នាំដំបូង ក្នុងការអនុវត្តប្រព័ន្ធវិមជ្ឈការ គេសង្កេតឃើញមានការរីកចំរើនគួរអោយពិចារណា ។ ប្រព័ន្ធ និងដំណើរការជាមូលដ្ឋាន ត្រូវបានគេបង្កើតឡើងពាសពេញផ្ទៃប្រទេស ដូច្នេះពួកវាបានជួយសំរួលដល់ក្រុមប្រឹក្សាឃុំ និងសង្កាត់ ដែលបានជាប់ឆ្នោតក្នុងការចាប់ផ្តើមបំពេញតួនាទី ។ មានបញ្ហាលើដំណើររៀបចំ ដែលមិនអាចជៀសវាងបាន និងដែលត្រូវធ្វើការកែតំរូវ ។ ផ្នែកខ្លះឆ្លុះបញ្ចាំងនូវភាព ស្ទាក់ស្ទើរនិងកំណត់នូវជំហានមិនច្បាស់លាស់ឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោម ។ ដោយពិចារណាលើប្រវត្តិដ៏មានចំរូងចំរាស់របស់កម្ពុជា គេអាចយលនូវការប្រុងប្រយ័ត្នមួយចំនួន និងការមិនហានប្រថុយនឹងគ្រោះថ្នាក់ ។ នៅពេលជាមួយគ្នានេះដែរការពិសោធន៍បានកំពុងឆ្លុះបញ្ចាំងអោយឃើញពីសញ្ញាវិជ្ជមានយ៉ាងខ្លាំង ហើយប្រការសំខាន់ថាវានឹងមិនបរាជ័យទេ ។ គេចាំបាច់ត្រូវមានបីដំណាក់កាលក្នុងការដាក់បញ្ចូលគំនិតផ្តួចផ្តើមនេះ នៅក្នុងជំហារដ៏រឹងមាំមួយ ។

៤៨. **បង្កើតទស្សនវិស័យរយៈពេលវែងយ៉ាងទូលំទូលាយ សំរាប់អភិបាលកិច្ចនៅថ្នាក់អនុជាតិៈ** ការបកស្រាយអោយច្បាស់លាស់អំពីទស្សនវិស័យលើលក្ខណៈអភិបាលកិច្ចដែលបានអនុវត្តតាមប្រព័ន្ធវិមជ្ឈការក្នុងរយៈពេលវែង នឹងផ្តល់អោយនូវទិសដៅ និងយកចិត្តទុកដាក់លើគោលនយោបាយ និងកម្មវិធីដែលជំរុញគំនិតផ្តួចផ្តើមនេះ ។ ទស្សនវិស័យនេះ ត្រូវគ្របដណ្តប់គ្រប់ថ្នាក់នៃរដ្ឋាភិបាលទាំងអស់ : ថ្នាក់ខេត្ត ស្រុក និងឃុំ និងក្នុងគោលបំណងកែតំរូវអំណាចបែបមជ្ឈការនាពេលបច្ចុប្បន្នប្រៀបធៀបទៅកំរិតថ្នាក់អនុជាតិ។ ផែនទីបង្ហាញអំពីដំណើរទៅរកគោលដៅរយៈពេលវែង នឹងជួយតំរែតំរង់ផ្លូវ និង ពង្រឹងដល់ដំណើរការដែលមានសារៈសំខាន់ក្នុងការទទួលបានជោគជ័យ ដូចជា ការធ្វើផែនការតាមបែបចូលរួមការផ្ទេរសារពើពន្ធ និងការផ្តល់សេវា ។ ការអនុវត្ត ពិគ្រោះយោបល់មួយដែលផ្អែក លើមេរៀនដំបូងៗអំពីវិមជ្ឈការរយៈពេលពីរឆ្នាំ នឹងមិនត្រឹមតែជួយបង្កើតអោយមានការឯកភាពជាតិរួមគ្នាមួយ លើទិសដៅសំរាប់ការផ្លាស់ប្តូរ ប៉ុន្តែថែមទាំងអនុញ្ញាតអោយមានការកែតំរូវខ្លះៗ នៅពាក់កណ្តាលផ្លូវដែលបញ្ជាក់ច្បាស់អំពីការទទួលខុសត្រូវ និងមុខងារ និងកំណត់នូវក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែលត្រូវការចាំបាច់ដើម្បីធានាភាពជឿនលឿនឆ្ពោះទៅរកគោលដៅរយៈពេលវែង ។ គំនិតផ្តួចផ្តើមថ្មី មួយក្នុងការបង្កើតអោយមានក្រុមការងារបច្ចេកទេសរួមគ្នារវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ (TWG) ដែលទទួលបន្ទុកកិច្ចការវិមជ្ឈការ និងវិសហមជ្ឈការ ដែលគួរតែបង្កើតអោយមានក្របខ័ណ្ឌជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៅក្នុងវិស័យនេះ ផ្តល់ឱកាសក្នុងការជំរុញការងារ អោយឆ្ពោះទៅមុខ ។

៤៩. *បញ្ជាក់អោយច្បាស់និងពង្រឹងគណនេយ្យភាពផ្ទៃក្នុង និងក្រៅរបស់ឃុំ និងសង្កាត់។* បច្ចុប្បន្ននេះ សមាជិកក្រុមប្រឹក្សាឃុំ ជាអ្នកទទួលខុសត្រូវចំពោះអ្នកបោះឆ្នោតអោយខ្លួន មេដឹកនាំគណបក្សនយោបាយដែលខ្លួនពាក់ព័ន្ធ និងចំពោះរដ្ឋាភិបាលថ្នាក់ខេត្ត និងថ្នាក់កណ្តាល ។ ដោយមានទិសដៅផ្សេងៗគ្នានោះ ពួកគេងាយនឹងទោរទន់ទៅរកអ្នកដែលមានអំណាចបំផុត ពោលគឺមេដឹកនាំគណបក្សនយោបាយដែលកំពុងកាន់អំណាច ។ គណនេយ្យភាព គឺត្រូវមានកត្តាដទៃៗទៀតមួយចំនួន ។ ថវិកាឃុំ ស្ថិតនៅក្រោមការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទន់ខ្សោយ ដូចនៅថ្នាក់កណ្តាលដែរ ។ ឃុំគ្មានបុគ្គលិកផ្ទាល់ខ្លួន ហើយសមាជិកក្រុមប្រឹក្សាឃុំខ្វះអំណាចគ្រប់គ្រងលើមន្ត្រីសាធារណៈ ដែលទទួលខុសត្រូវចំពោះការផ្តល់សេវា ពីព្រោះពួកគេជាផ្នែកមួយនៃរដ្ឋាភិបាលថ្នាក់ខេត្ត ដែលស្ថិតនៅក្រោមរដ្ឋាភិបាលថ្នាក់កណ្តាលទាំងស្រុង ។ លើសពីនេះ

ទៀត សង្គមស៊ីវិលមិនមានលទ្ធភាពដើរតួនាទីអោយមានប្រសិទ្ធភាព ដើម្បីជះឥទ្ធិពលលើលទ្ធផលនៃថវិកាឃុំទេ ពីព្រោះតែកង្វះតម្លាភាព និងការចូលរួមក្នុងដំណើរការរបស់ឃុំ និងសង្កាត់ ។ ការជំរុញសំលេងរបស់ប្រជាពលរដ្ឋនិងឥទ្ធិពលរបស់សង្គមស៊ីវិល និងការបញ្ជាក់ច្បាស់ និងពង្រឹងគណនេយ្យភាពផ្នែកហិរញ្ញវត្ថុ ជាអាទិភាពដ៏ខ្ពស់មួយ ប្រសិនបើឃុំនិងសង្កាត់ មិនឆាប់អនុវត្តផ្នែកហិរញ្ញវត្ថុ និងអំពើពុករលួយដូចគ្នានឹងរដ្ឋាភិបាលថ្នាក់កណ្តាល ។ រដ្ឋាភិបាលថ្នាក់កណ្តាល ក៏គួរពិនិត្យអោយបានកាន់តែប្រសើរលើការ បំពេញការងាររបស់រដ្ឋាភិបាលមូលដ្ឋានក្នុងការផ្តល់សេវាផងដែរ ដើម្បីលើកទឹកចិត្តអោយមានការប្រកួតប្រជែងល្អរវាងឃុំ/សង្កាត់ ។ ជាប្រការសំខាន់ផងដែរដែលឃុំ/សង្កាត់ ត្រូវបានអនុញ្ញាតអោយបង្កើនការខិតខំប្រឹងប្រែង ប្រមែប្រមូលចំណូលរបស់ខ្លួនគេផ្ទាល់ គឺមិនត្រឹមតែដើម្បីបំពេញបន្ថែមទៅលើថវិកាផ្ទេរពីថ្នាក់កណ្តាលប៉ុណ្ណោះទេ គឺថែមទាំងកែលំអគណនេយ្យភាពចំពោះអ្នកបង់ពន្ធតាមមូលដ្ឋានផងដែរ ។

*៥០. បង្កើនភាពដែលអាចប៉ាន់ស្មានបាន ភាពដែលអាចទុកចិត្តបាន និងកំរិតនៃមូលនិធិ ដែលត្រូវផ្ទេរទៅអោយឃុំ* និងជួយឃុំអោយពង្រឹងការខិតខំប្រឹងប្រែងប្រមូលប្រាក់ចំណូលផ្ទាល់របស់ខ្លួន ។ ការផ្ទេរសាច់ប្រាក់យឺតយ៉ាវ និងមិនពេញលេញ បានធ្វើអោយមានការលំបាកក្នុងការផ្តល់មូលនិធិទៅអោយកម្មវិធីការងាររបស់ឃុំនិងសង្កាត់ ។ ការបង្កើតជាដំបូងនូវគណៈកម្មាធិការមូលនិធិឃុំនិងសង្កាត់ ដែលពិនិត្យមើលនិងទទួលខុសត្រូវចំពោះការគ្រប់គ្រងមូលនិធិសំរាប់ឃុំនិងសង្កាត់នោះ (ដែលសំខាន់បានមកពីជំនួយខាងក្រៅដល់ប្រទេសកម្ពុជា) គឺជាអាទិភាពខ្ពស់មួយ ។ ជាងនេះទៅទៀត មានតំរូវការពិតប្រាកដដ៏ធំធេងអោយមានកម្មវិធីដែលទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ ដែលមិនទាន់បានឆ្លើយតបតាមរយៈថវិកាដ៏តិចតួចសំរាប់ឃុំនិងសង្កាត់ ដែលមានទំហំជាមធ្យម ៦.០០០ ដុល្លាអាមេរិកក្នុងមួយឆ្នាំ ហើយចំនួនដ៏តិចតួចនេះស្មើនឹង ៧៥ សេនដុល្លាអាមេរិកក្នុងម្នាក់ៗ ។ រដ្ឋាភិបាលត្រូវ តែបន្តតាមដាននូវការទទួលស្គាល់របស់ខ្លួននៅក្នុងយុទ្ធសាស្រ្តចតុកោណ អំពីតំរូវការអោយមាន"ធនធានហិរញ្ញវត្ថុ ក្នុងកំរិតសមហេតុផលដល់ថ្នាក់ឃុំ (រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្រ្តចតុកោណឆ្នាំ ២០០៤) ដោយបង្កើនការបែងចែកថវិកាជាបណ្តើរៗសំរាប់គោលបំណងនេះ ។

## ឆ. គ្រប់គ្រងធនធានធម្មជាតិសំរាប់ផលប្រយោជន៍សាធារណៈ

៥១. រាល់សិទ្ធិលើកម្មសិទ្ធិទ្រព្យសម្បត្តិជាផ្លូវការទាំងអស់ ត្រូវបានបំផ្លាញដោយខ្មែរក្រហម និងការបំលាស់ទីលំនៅរបស់ប្រជាជនជាច្រើន បានធ្វើអោយប៉ះពាល់ដល់កម្មសិទ្ធិធនធានធម្មជាតិ ដែលធ្លាប់បានទទួលពីជំនាន់មុនមក។ ជាងនេះទៅទៀត បន្ទាប់ពីការបញ្ចប់សង្គ្រាមស៊ីវិល អសន្តិសុខផ្នែករាងកាយដែលដក់ជាប់ក្នុងអារម្មណ៍ និងភាពទន់ខ្សោយក្នុងការការពង្រឹងការអនុវត្តន៍សិទ្ធិលើកម្មសិទ្ធិទ្រព្យសម្បត្តិ បាននាំអោយមានការធ្វើអាជីវកម្មលើធនធានធម្មជាតិយ៉ាងឆាប់រហ័ស ដែលប៉ះពាល់ដល់និរន្តរភាព ។ តំរូវការខ្លាំងនូវលើប្រាក់ចំណូលមិនផ្លូវការ ដើម្បីឧបត្ថម្ភយោធា និងសេវាស៊ីវិលដែលពឹងផ្អែកលើការគាំទ្រនិងទទួលបានប្រាក់បៀវត្សតិចតួច និងដើម្បីផ្តល់មូលនិធិដោយយុទ្ធនាការនយោបាយ កាន់តែលើកទឹកចិត្តបន្ថែមក្នុងអាជីវកម្មលើធនធានធម្មជាតិដោយគ្មាននិរន្តរភាព ដើម្បីទទួលបានផលចំណេញហិរញ្ញវត្ថុក្នុងរយៈពេលខ្លី ។

៥២. ផ្ទៃដីរបស់ប្រទេសកម្ពុជា ប្រហែលជា ៧៥% ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ក្នុងនោះរួមទាំងតំបន់ព្រៃឈើ ទាំងអស់ធនធានទឹកសាបទឹកប្រៃជាច្រើន តំបន់មរតកវប្បធម៌ និងទ្រព្យសម្បត្តិកសិកម្មដែលមានទ្រង់ទ្រាយធំ ។ យន្តការជាបឋមរបស់រដ្ឋាភិបាល សំរាប់ការគ្រប់គ្រងធនធានធម្មជាតិ បានចុះកិច្ចសន្យាលើតំបន់ធំៗ ទៅអោយអ្នកវិនិយោគទុនកម្ពុជា និងបរទេស ។ សម្បទានទាំងនេះ ជាទូទៅត្រូវបានផ្តល់អោយតាមរយៈដំណើរការមួយដែល មើលទៅហាក់ដូចជាក្នុងគោលបំណងពិសេស និងគ្មានតម្លាភាព ។ ការចាត់ចែងធនធានធម្មជាតិ គឺមិនបានផ្អែកលើការវាយតំលៃលើលទ្ធភាពឡើយ ។ អ្នកវិនិយោគទុន មិនត្រូវបានជ្រើសរើសអោយបានគ្រប់ជ្រុងជ្រោយ ដើម្បីធានានូវសមត្ថភាពផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការបំពេញកាតព្វកិច្ចដែលមាននៅក្នុងកិច្ចសន្យា ហើយស្ថាប័នរដ្ឋាភិបាល មិនមានលទ្ធភាពពង្រឹងការអនុវត្តបទបញ្ញត្តិនានាដែលមាននៅក្នុងកិច្ចសន្យា ។ ចំណូលផ្ទាល់ពីសម្បទានទាំងនេះ មានចំនួនតិចជាងការរំពឹងទុកឆ្ងាយណាស់ ខណៈដែលសម្បទានទាំងនេះ បានរួមចំណែកធ្វើអោយមានកំណើន និងការងារបានតិចតួច ។ ផលវិបាកផ្នែកបរិស្ថាន មានលក្ខណៈជាអវិជ្ជមានយ៉ាងខ្លាំង ។ ជា លទ្ធផលសហគមន៍តាមមូលដ្ឋាន បានទទួលផលប្រយោជន៍តិចតួចពីសម្បទានទាំងនេះ ។ ឥឡូវនេះ ភាពគ្មានដីធ្លី ត្រូវបានគេប៉ាន់ស្មានពី ១២ ភាគរយ ទៅ ១៥ ភាគរយ នៅពេលដែលទំហំកសិដ្ឋានជាមធ្យម ត្រូវបានគេរាយការណ៍មកថា កំពុងធ្លាក់ចុះ ។

៩៣. រដ្ឋាភិបាល បានផ្តល់ជាសញ្ញាអោយដឹងពីកំរិតដ៏ខ្ពស់បំផុតនៃការខ្វះខាននៅក្នុងគោលនយោបាយទាំងនេះ ហើយបានលុបចោលប្រហែល ៤០ ភាគរយ នៃសម្បទានទាំងនេះ ដែលស្មើនឹងពាក់កណ្តាលនៃតំបន់សម្បទានពីមុន ។ ជាងនេះទៅទៀត ការផ្អាកសកម្មភាពកាប់ព្រៃឈើនៅក្នុងតំបន់សម្បទាន បានចូលជាធរមានអស់រយៈពេលជាង ១៨ ខែ ។ បច្ចុប្បន្ននេះ រដ្ឋាភិបាលប្តេជ្ញាចិត្ត តំរង់ទិសគោលនយោបាយធនធានធម្មជាតិអោយស្របគ្នាជាមួយនឹងវត្ថុបំណងនៃយុទ្ធសាស្ត្រចតុកោណ ហើយកំពុងតែបង្កើនការស្វែងរកវិធីសាស្ត្របែងចែកផលប្រយោជន៍ដែលផ្អែកលើសហគមន៍ ដើម្បីតំរង់ទិសឡើងវិញ នឹងតំរូវអោយឆ្លងកាត់ដំណាក់កាលមួយចំនួន ។

៩៤. **កំណែទំរង់ ចាំបាច់ត្រូវដាក់ចេញនូវគោលនយោបាយត្រឹមត្រូវ និងមូលដ្ឋានច្បាប់សំរាប់ការគ្រប់គ្រងធនធានធម្មជាតិ** ។ ដំណើរការគោលនយោបាយផ្អែកតាមពិគ្រោះយោបល់ទូលំទូលាយ គឺចាំបាច់ដើម្បីបង្កើតអោយមានទស្សនវិស័យមួយសំរាប់ការគ្រប់គ្រងធនធានធម្មជាតិដោយរដ្ឋ ។ ដំណើរការនេះ ចាំបាច់ត្រូវសិក្សាស្រាវជ្រាវអំពីតំលៃតុល្យភាពចំបងៗរួមទាំងតម្លៃឱកាសដែលលះបង់រវាងការថែទាំបន្ត និងការពង្រីកតំបន់ព្រៃឈើ និងនេសាទ ជាមួយនឹងសម្ពាធនានាដែលជំរុញអោយពង្រីកផ្ទៃដីកសិកម្ម និងតម្លៃឱកាសដែលលះបង់រវាងវិធីសាស្ត្រគ្រប់គ្រងដោយម្ចាស់កម្មសិទ្ធិតូចតាច និងសហគមន៍ ជាមួយនឹងវិធីសាស្ត្រតាមបែបពាណិជ្ជកម្ម ។ តម្លៃទូទាត់ទាំងនេះ ត្រូវការព័ត៌មានពីការវាយតំលៃធនធានធម្មជាតិ និងការធ្វើផែនទីដីធ្លីរបស់រដ្ឋ ។ ច្បាប់ជាច្រើន ដែលគ្របដណ្តប់លើធនធានធម្មជាតិ ត្រូវបានអនុម័តនាពេលថ្មីៗនេះ ឬស្ថិតនៅក្នុងការពិចារណា ។ ច្បាប់ទាំងនេះ ចាំបាច់ត្រូវថែងអោយបានប្រសើរឡើងអំពីឋានានុក្រមនៃកម្មសិទ្ធិធនធានរបស់រដ្ឋ យន្តការសំរាប់ដោះស្រាយចំណុចមិនស្របគ្នារវាងច្បាប់ទាំងនេះ និងច្បាប់ទាំងឡាយដែលដោះស្រាយទំនាស់លើការទាមទារកម្មសិទ្ធិធនធាន ។ សិទ្ធិលើកម្មសិទ្ធិទ្រព្យសម្បត្តិ ជាធនធានធម្មជាតិ ចាំបាច់ត្រូវតំរូវអោយមានការពន្យល់បំភ្លឺបន្ថែម ។

៩៥. **ស្ថាប័នទទួលបន្ទុកការគ្រប់គ្រងធនធានធម្មជាតិ ចាំបាច់ត្រូវធ្វើអោយរឹតតែមានគណនេយ្យភាព និងតម្លាភាព** ។ ការទទួលខុសត្រូវរបស់ស្ថាប័ន មានលក្ខណៈជាសហមជ្ឈការផង និងមជ្ឈការផង នៅក្នុងប្រទេសកម្ពុជា ។ ការអនុវត្តន៍ប្រព័ន្ធសហមជ្ឈការលើមុខងាររបស់ទីភ្នាក់ងារមួយនៅក្នុងកំរិតជាតិ មានការចាប់អារម្មណ៍តិចតួចចំពោះតម្លៃឱកាសដែលលះបង់សំរាប់គោលនយោបាយ និងបានកាត់បន្ថយការត្រួត

ពិនិត្យ និងតុល្យភាព ។ គោលនយោបាយត្រូវបានធ្វើឡើងដោយគ្មានការពិគ្រោះយោបល់គ្រប់គ្រាន់ជាមួយនឹងអ្នកដែលនឹងទទួល រងឥទ្ធពលដោយផ្ទាល់ពីគោលនយោបាយ ។ នៅពេលមានការពិគ្រោះយោបល់ ដូចជាក្នុងករណីច្បាប់ភូមិបាល ជាដើម វាផ្តល់ប្រយោជន៍ជាដំកំភួន ។ កំណែទំរង់ ចាំបាច់ត្រូវរួមបញ្ចូលការដោះស្រាយលើការលើកទឹកចិត្តមិនសមស្រប ដែលស្ថាប័នទាំងនេះកំពុងប្រឈមមុខ ហើយដែលធ្វើអោយពួកគេច្បាមយកប្រយោជន៍ផ្ទាល់ខ្លួន ។ ប្រការទាំងនេះ រួមមានបញ្ហាជាប្រចាំគឺប្រាក់បៀវត្សមន្ត្រីរាជការ និងការគ្រប់គ្រងទន់ខ្សោយ និងផ្អែកលើការគាំទ្រ ។ ការត្រួតពិនិត្យ និងការធ្វើអោយមានតុល្យភាពដោយឯករាជ្យ ចាំបាច់ត្រូវពង្រឹងឡើងដោយរួមទាំងការឃ្លាំមើលរបស់សភា និងគណនេយ្យភាពឯករាជ្យ ព្រមទាំងតាមរយៈអាជ្ញាធរសវនកម្មជាតិ ។ ការពិគ្រោះយោបល់ ដែលចាំបាច់ ជាមួយនឹងសហគមន៍តាមមូលដ្ឋាន និងការផ្សព្វផ្សាយជាសាធារណៈ ដូចដែលមានចែងនៅក្នុងអនុក្រិត្យ ស្តីពីការគ្រប់គ្រងសម្បទានព្រៃឈើ គួរត្រូវពង្រីកទៅលើធនធានធម្មជាតិទាំងអស់ ។ ការត្រួតពិនិត្យតាមដានការអនុវត្តការងាររបស់ ទីភ្នាក់ងាររដ្ឋដោយសង្គមស៊ីវិល គួរក្លាយជាបទដ្ឋានមួយ ។

**៥៦. ដោយ ៨៥%នៃប្រជាពលរដ្ឋកម្ពុជារស់នៅទីជនបទ ដែលជាសមាមាត្រមួយមានប្រជាពលរដ្ឋក្រីក្រច្រើន វិធីសាស្ត្រក្នុងការគ្រប់គ្រងធនធាន ចាំបាច់ត្រូវផ្តល់អាទិភាពដល់សហគមន៍តាមមូលដ្ឋាន នូវលទ្ធភាពផ្ទាល់ក្នុងការទទួលបានផលប្រយោជន៍។** ការធ្វើឯកជននីយកម្មលើដីធ្លី ដែលអនុគ្រោះដល់បុគ្គលតាមរយៈការទទួលស្គាល់សិទ្ធិកាន់កាប់របស់ពួកគេ ដោយយោងតាមច្បាប់ភូមិបាល គឺទំនងជាត្រូវបានគេពិចារណា ហើយសម្បទានសង្គមនានា ក៏នឹងផ្ទេរចេញពីដីធ្លីសាធារណៈផងដែរ ។ ការអនុវត្តន៍ពន្ធលើដីធ្លីដែលមិនធ្វើអាជីវកម្ម នឹងជួយការពារការកាន់កាប់ដីធ្លីទុកសំរាប់លក់ពេលដីមានតំលៃ និងជួយផ្តល់ដីបន្ថែមដល់ទីផ្សារ ។ ទោះជាយ៉ាងណាក៏ដោយ ធនធានធម្មជាតិជាច្រើន ទំនងជាស្ថិតនៅក្នុងដៃរបស់រដ្ឋ ។ ការរៀបចំតំបន់សម្បទាន អាចនៅតែជាវិធីសាស្ត្រគ្រប់គ្រងដ៏ល្អមួយ ប្រសិនបើការគ្រប់គ្រងទាំងនេះ មានតម្លាភាពនិងគណនេយ្យភាព និងតំរូវអោយមានការពិគ្រោះយោបល់ការបែងចែកផលប្រយោជន៍ជាមួយសហគមន៍តាមមូលដ្ឋាន ។ ការបែងចែកផលប្រយោជន៍ដែលបានកើនឡើង ក៏គួរតែតំរូវអោយមានការគ្រប់គ្រងតំបន់សម្បទានបច្ចុប្បន្ន និងជីវរដ្ឋទាំងអស់ ។ សហគមន៍តាមមូលដ្ឋាន អាចចែករំលែកគ្នានូវលទ្ធភាពក្នុងការប្រើប្រាស់ធនធានធម្មជាតិ និងផលប្រយោជន៍ជាប្រាក់កាសផ្ទាល់ ។ វិធីសាស្ត្រជាដៃគូតាមមូលដ្ឋាន នឹងបង្វែរការទទួលខុសត្រូវលើការបង្កើតសេវា សាធារណៈទៅអ្នកដើរតួនាទីនានាតាមមូលដ្ឋាន

ដែលមានភាពចំរុះយ៉ាងទូលំទូលាយ ពោលគឺរួមទាំងសហគមន៍ និងក្រុមប្រឹក្សាឃុំ ព្រមទាំងបុគ្គលិកស្រុក និងខេត្ត ។ ឧបសគ្គដែលកំពុងប្រឈមមុខ ក្នុងការធ្វើអោយមានការបែកចែងផលប្រយោជន៍តាមមូលដ្ឋាន មិនគួរត្រូវគេអោយតំលៃយ៉ាងទាបឡើយ ។ ចាំបាច់ត្រូវមានការយកចិត្តទុកដាក់ជាពិសេស ដើម្បីរារាំងមិនអោយមានការកាន់កាប់ធនធានធម្មជាតិដោយពួកឥស្សរជន និងការធ្វើអោយបាត់បង់នូវ សិទ្ធិរបស់ប្រជាពលរដ្ឋក្រីក្រលើធនធានធម្មជាតិ ។

៥៧. **អាទិភាពចំបងគឺការកាត់បន្ថយហានិយភ័យនៃការចាប់យកដីធ្លី ដោយឥតគិតក្រែង** ដូចដែលគេរៀបចំអោយមានជាស្ថាប័ន និងការគ្រប់គ្រងថ្មីៗ នៅពេលដែលដីធ្លីជាច្រើនស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ ដោយសារការលុបចោលនូវសម្បទានានា ដោយមិនបានបង្កើនសមត្ថភាពរបស់រដ្ឋក្នុងការគ្រប់គ្រងដីធ្លីទាំងនេះ ។ សេចក្តីសង្ឃឹមដ៏ធំបំផុត គឺត្រូវបង្កើតអោយមានការរៀបចំដែលមានការសហការរៀបចំជាមួយនឹងសហគមន៍មូលដ្ឋាន និងពង្រីកសមត្ថភាពក្នុង ទីភ្នាក់ងាររបស់រដ្ឋាភិបាល ។ អង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា មានបទពិសោធន៍រួចស្រេចហើយជាមួយនឹងការត្រួតពិនិត្យតាមដាន និងការពង្រឹងការអនុវត្តតាមបែបសហការ ។ ប្រព័ន្ធដែលមាន អ្នកពាក់ព័ន្ធច្រើនដែលឧបត្ថម្ភគាំទ្រដោយអ្នកត្រួតពិនិត្យតាមដានឯករាជ្យ នឹងតំរូវអោយមានការប្រមូលធនធាន របស់រដ្ឋាភិបាល និងម្ចាស់ជំនួយឱ្យមានរួចជាស្រេច ។

## ៥. ការលុបបំបាត់ឧបសគ្គលើផ្នែកអភិបាលកិច្ច ដើម្បីការវិនិយោគ និងកំណើន

៥៨. ដោយពិចារណាលើស្ថានភាពដ៏គួរអោយគ្រោះថ្នាក់នៃហិរញ្ញវត្ថុសាធារណៈរបស់ខ្លួន ប្រទេសកម្ពុជាមានជំរើសតិចតួចណាស់ក្រៅពីពឹងផ្អែកលើអ្នកវិនិយោគឯកជនក្នុងស្រុក និង បរទេស ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគរបស់ប្រទេសនេះដើម្បីផ្តល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងដើម្បីធ្វើជាម៉ាស៊ីនដ៏សំខាន់សំរាប់ជំរុញកំណើន។ ប៉ុន្តែឧបសគ្គលើផ្នែកអភិបាលកិច្ច ជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើលទ្ធភាពរបស់ផ្នែកឯកជនក្នុងការឆ្លើយតបជាវិជ្ជមានចំពោះបញ្ហាប្រឈមនេះ ។ វិស័យយុត្តិធម៌ដែលមិនបំពេញមុខងារបានត្រឹមត្រូវបង្កើននូវភាពមិនច្បាស់លាស់ និង គ្រោះថ្នាក់យ៉ាងខ្លាំង ជាពិសេសពីសកម្មភាពរបស់រដ្ឋដែលប្រព្រឹត្តតាមទំនើងចិត្ត ។ អំពើពុករលួយបង្កើនការចំណាយនៃការចាប់ផ្តើម និងប្រកបអាជីវកម្មនៅប្រទេសកម្ពុជា ដល់ចំណុចដែលគំរាមកំហែងដល់ការប្រកួតប្រជែងធៀបរបស់ប្រទេស ហើយការខ្វះតម្លាភាពក្នុងការប្រាស្រ័យទាក់ទងគ្នារវាងរដ្ឋាភិបាល និងផ្នែកឯកជន ជាពិសេសក្នុងវិស័យ សម្បទាន និងការរៀបចំ

គំរោងតាមបែប BOT លើកទឹកចិត្តដល់អាជីវកម្មដែលមិនគោរពសីលធម៌ អោយប៉ុនប៉ងក្តាប់លើរដ្ឋ ហើយការរៀបចំបែបនេះបន្ថយប្រាក់ចំណូលជាសក្តានុពលចូលនាយកដ្ឋានពន្ធដារ ។ យុទ្ធសាស្ត្រចតុកោណ ទទួលស្គាល់បញ្ហានេះ ដោយតំរូវអោយមានការពង្រឹងទាំងផ្នែកអភិបាលកិច្ចសាធារណៈ និងសាជីវកម្ម ព្រមទាំងកែលំអ បរិយាកាសវិនិយោគ (រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណឆ្នាំ ២០០៤) ។

៥៩. **បន្ទុកលើបទបញ្ញត្តិផ្នែកឯកជន ចាំបាច់ត្រូវសំរួល ។** ផ្នែកឯកជនផ្លូវការជួបប្រទះនឹងចំណាយ រត់ការមួយចំនួនធំ និងរបាំងឧបសគ្គចំពោះការបង្កើត និងការដំណើរការអាជីវកម្ម ។ វាត្រូវការពេលវេលា ៩៤ ថ្ងៃ ដើម្បីបើកអាជីវកម្មមួយនៅប្រទេសកម្ពុជា គឺយូរជាងក្នុងប្រទេសវៀតណាមចំនួន ៣០ ថ្ងៃ និងយូរជាងប្រទេសថៃ ចំនួន ៥២ ថ្ងៃ ។ ការអនុវត្តនីការសំរបសំរួលពាណិជ្ជកម្ម ត្រូវស្ថិតនៅក្រោមការចំណាយផ្លូវការ និងក្រៅផ្លូវការខ្ពស់ ការពន្យារពេល ភាពមិនប្រាកដប្រជា និងការសំរេចតាមទំនើងចិត្ត ។ ប្រទេសកម្ពុជាក៏ស្ថិតនៅក្នុងចំណោមកន្លែង ដែលមានការយឺតយ៉ាវបំផុតក្នុងការរត់ការទំនិញនាំចូល ដែលមានសារៈសំខាន់ជាអាយុជីវិតរបស់ឧស្សាហកម្មនាំចេញ ដែលកំពុងតែដុះពន្លកឡើងនៅក្នុងប្រទេសនេះ ដោយមានទីភ្នាក់ងារមួយចំនួនធំ ដែលប្រជែងគ្នាដើម្បីត្រួតត្រាលើការនាំចូលនេះ ។ ដូចដែលបានកត់សំគាល់ខាងលើរួចមកហើយ អំពើពុករលួយត្រូវបានគេមើលឃើញថា មានកំរិតធ្ងន់ធ្ងរដល់ថ្នាក់សហគ្រាសឯកជនចាត់ថ្នាក់លើសពីការលំបាកដទៃទៀតទាំងអស់ ដែលសហគ្រាសបានជួបប្រទះក្នុង ការប្រតិបត្តិការនៅប្រទេសកម្ពុជា ។ ការភ័យខ្លាចនូវបទបញ្ញត្តិ ជំរុញអោយក្រុមហ៊ុនជាច្រើនស្ថិតនៅក្រៅផ្លូវការ និងនៅក្រៅសំណាញ់របស់រដ្ឋាភិបាល ដែលជាការអនុវត្តន៍មួយមានការខាតបង់ ។ កំណែទំរង់ នឹងទាមទារអោយ មានការលុបបំបាត់នូវការឆក់យកផលចំណេញពីចំណុចខ្វះខាតនៃបទបញ្ញត្តិ ដោះស្រាយនូវដែនសមត្ថកិច្ចជាន់គ្នារបស់ទីភ្នាក់ងាររដ្ឋាភិបាល និងអនុវត្តតាមយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះថ្នាក់ចំពោះការត្រួតត្រានានា ។

៦០. **ស្ថាប័នគាំទ្រទីផ្សារចាំបាច់ត្រូវពង្រឹងឡើង ។** ក្នុងពេលអវត្តមានស្ថាប័នគាំទ្រទីផ្សារដូចជាប្រព័ន្ធច្បាប់និងតុលាការមួយ ដែលមានប្រសិទ្ធភាព ដូចនេះពុំមានយន្តការណាមួយដើម្បីធានាអោយមានបរិយាកាសប្រកួតប្រជែងស្មើៗគ្នា ដើម្បីដោះស្រាយទំនាស់រវាងរដ្ឋាភិបាល និងផ្នែកឯកជន និងដើម្បីជួយពង្រឹងការអនុវត្តកិច្ចសន្យានោះទេ ។ ការកែទំរង់វិស័យយុត្តិធម៌ដូចបានកត់សំគាល់ខាងលើ នឹងត្រូវការពេលវេលាច្រើន ។ ទន្ទឹមនឹងនោះ រដ្ឋាភិបាលចាំបាច់ត្រូវដោះស្រាយនូវគោលគំនិតយល់ជាទូទៅថា សាជីវកម្មធំៗ និង

ក្រុមហ៊ុនមួយក្តាប់តូច ដែលមានសម្ព័ន្ធភាពយ៉ាងជិតស្និទ្ធជាមួយថ្នាក់ដឹកនាំនយោបាយនោះ ប្រើប្រាស់ឥទ្ធិពលមិនសមស្របទៅលើគោលនយោបាយ ។ ការពង្រីកការជជែកពិភាក្សាជាមួយនឹងវិស័យឯកជននៅក្នុងលក្ខណៈមួយដែលផ្តល់សំលេងដែលមានប្រសិទ្ធភាពដល់ដៃគូប្រកួតដទៃទៀត និងត្រូវគេមើលឃើញថានាំអោយមានគោលនយោបាយ និងការអនុវត្តន៍ដែលធានាអោយទីផ្សារ មានការប្រកួតប្រជែង និងយុត្តិធម៌នោះ នឹងមានសារៈសំខាន់ក្នុងការកសាងទំនុកចិត្ត រហូតដល់ពេលមានស្ថាប័ន គាំទ្រទីផ្សារចាប់ផ្តើមដើរតួនាទីដ៏មានប្រសិទ្ធភាព ។

**៦១. ការប្រកួតប្រជែង និងតម្លាភាពត្រូវការចាំបាច់ក្នុងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដោយវិស័យឯកជន ។** កង្វះនូវការប្រកួតប្រជែង ក៏ជាឧបសគ្គគន្លឹះមួយដែរនៅក្នុងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដោយវិស័យឯកជនក្នុងប្រទេសកម្ពុជា ។ ដូចក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនដែរ រដ្ឋនៅប្រទេសកម្ពុជាមានលទ្ធភាពតិចតួចក្នុងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ដោយមានធនធានរដ្ឋបាល និងថវិកាមានកំរិត ។ ប៉ុន្តែនិន្នាការនៃការចរចាកិច្ចសន្យាដោយផ្ទាល់ជាមួយអ្នកម៉ៅការឯកជន ដោយគ្មានការដេញថ្លៃបែបប្រកួតប្រជែងបានបណ្តាលអោយគំរោងនានា មិនអាចធ្វើបានក្នុងតំលៃទាបបំផុត និងមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យបច្ចេកទេសនានាដែលទំនងនឹងកំរិតភាព បរាជ័យក្នុងការផ្តល់សេវានោះទេ ។ ក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិបច្ចុប្បន្ន ដែលគ្រប់គ្រងទៅលើ*ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធឯកជនដោយមានការចូលរួម* (PPI) គឺមិនគ្រប់គ្រាន់ ។ ក៏មិនមានការងារធ្វើផែនការ និងគោលនយោបាយគ្រប់គ្រាន់ សំរាប់ដឹកនាំការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែរ ។ មាននីតិវិធីដែលបានកំណត់ច្បាស់លាស់មួយចំនួនតូច សំរាប់ត្រួតពិនិត្យមើលពាក្យស្នើសុំដែលមិនបានចរចាសំរាប់ PPI ហើយការណ៍នេះធ្វើអោយមានការខ្វះតម្លាភាពទាំងស្រុងនៅគ្រប់ដំណាក់កាលទាំងអស់នៃការអនុវត្តន៍គំរោងបែបនេះ ។ គំរោងទាំងនេះជាញឹកញាប់ ត្រូវបានផ្តល់ហិរញ្ញប្បទានទាំងស្រុងដោយសមធម៌ មួយផ្នែកគឺដើម្បីជៀសវាងនូវការពិនិត្យពិច័យពីសំណាក់ស្ថាប័នហិរញ្ញវត្ថុណាមួយ ។ ការណ៍នេះទំនងជាបង្កើនអត្រានៃប្រាក់ចំណេញដែលរំពឹងទុក ។ កង្វះព័ត៌មានអំពីគំរោងទាំងនេះ ធ្វើ អោយមានការលំបាកក្នុងការវាយតំលៃថាតើសាធារណជន កំពុងទទួលបាននូវគុណតំលៃគ្រប់គ្រាន់ដែលជាផលប្រយោជន៍បានមកពីសម្បទាននៃទ្រព្យសម្បត្តិសាធារណៈ ដូចជាដីធ្លី និងកម្មសិទ្ធិសាធារណៈជាដើម ។ ដោយខ្វះនូវច្បាប់សមស្រប មានន័យថាការសំរេចចិត្តតាមទំនើងចិត្ត មិនអាចត្រូវបានគេត្រួតពិនិត្យដោយងាយឡើយហើយ ផលប្រយោជន៍សាធារណៈ ក៏មិនអាចការពារបានដោយងាយដែរ ។

៦២. គំរោងដែលមិនមានការចរចា ឬបានចរចាដោយផ្ទាល់ បង្កើតនូវឱកាសសំរាប់អំពើពុករលួយខ្នាតធំ និងកាត់បន្ថយនូវជំនឿរបស់សាធារណជនលើរដ្ឋាភិបាល ។ កំណែទំរង់ត្រូវតែចាប់ផ្តើមជាមួយតម្លាភាពកាន់តែច្បាស់ឡើងនៅលើរាល់កិច្ចសន្យាបែបនេះទាំងអស់ ។ កិច្ចសន្យាទាំងអស់គួរត្រូវតែផ្សព្វផ្សាយជាសាធារណៈ ដូចការអនុវត្តក្នុងប្រទេសម៉ិកស៊ិក ដែលកិច្ចសន្យាទាំងនេះត្រូវតែចុះផ្សាយនៅលើវ៉ិបសាយរបស់រដ្ឋាភិបាល ។ ក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់មួយ គឺត្រូវការចាំបាច់ ដែលរួមបញ្ចូលទាំងការអនុម័តច្បាប់ និងបទបញ្ញត្តិដែលបង្កើតអោយមានដំណើរការប្រកបដោយតម្លាភាព និងគណនេយ្យភាពសំរាប់ PPI ។ ហើយកិច្ចសន្យាដែលមានស្រាប់ទាំងអស់ ចាំបាច់ត្រូវធ្វើសវនកម្ម ដើម្បីបញ្ជាក់អោយច្បាស់ថាតើគេកំពុងបំរើផលប្រយោជន៍សាធារណៈឬទេ ។ ក្រសួងពាណិជ្ជកម្ម ក្រសួងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានចាប់ផ្តើមធ្វើការងារក្នុងទិសដៅនេះហើយ ។

## ឈ. សេចក្តីសន្និដ្ឋាន

*"...ការដោះស្រាយដោយជោគជ័យនូវភាពជាប់គាំងខាងនយោបាយក្នុងបរិយាកាសមួយមានសន្តិភាព និងស្ថិរភាព និងក្នុងស្មារតីជាថ្មីនៃការបង្រួបបង្រួមផ្សះផ្សាជាតិ ហើយលទ្ធិប្រជាធិបតេយ្យ បានផ្តល់អោយយើងនូវឱកាសជាថ្មី និងពោរពេញដោយក្តីសង្ឃឹម ដើម្បីចាប់ប្រតិបត្តិកំណែទំរង់ដែលមានល្បឿនកាន់តែលឿន កាន់តែមានភាពចំរុះ និងកាន់តែស៊ីជំរៅថែមទៀត ក្នុងគ្រប់វិស័យទាំងអស់ដែលយើងបានចាប់ផ្តើមក្នុងអណត្តិមុនៗ ...។ ប្រទេសកម្ពុជា គ្មានជំរើសណាល្អ ជាងការបោះជំហានទៅមុខជាមួយកំណែទំរង់យ៉ាងមោះមុតទាំងអស់នេះទេ ។ ជាមួយនឹងការប្តេជ្ញាចិត្តចំពោះកំណែទំរង់បន្តទៅទៀត ឱកាសរបស់យើងដើម្បីរស់រានមានជីវិតគឺមាន ៩០% រីឯការចុះចាញ់ឈប់ធ្វើកំណែទំរង់វិញ ឱកាសនោះនឹងធ្លាក់មកនៅត្រឹមតែ ១០% ប៉ុណ្ណោះ ។"*

***សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា*

៦៣. រាជរដ្ឋាភិបាលទទួលស្គាល់យ៉ាងច្បាស់លាស់ ដូចបានបង្ហាញនៅក្នុងសេចក្តីថ្លែងការណ៍ខាងលើរបស់ **នាយករដ្ឋមន្ត្រី ហ៊ុន សែន** ថា ប្រទេសកម្ពុជាស្ថិតនៅចំណុចរបត់ប្រវត្តិសាស្ត្រដ៏សំខាន់មួយរបស់ខ្លួន ។ កិច្ចការជាច្រើនត្រូវបានសំរេចនៅក្នុងទសវត្សរ៍កន្លងទៅនេះ ប៉ុន្តែនៅមានកិច្ចការច្រើនទៀតដែលត្រូវធ្វើ ដើម្បីបំបែកគំនាបនៃភាពក្រីក្រដែលជាគំនាបលើប្រជាជនជាច្រើន ។ ការបរាជ័យបច្ចុប្បន្នក្នុងការបង្កើន

ល្បឿនកំណែទំរង់ នឹងបង្ហាញអោយឃើញការខាតបង់យ៉ាងខ្លាំងចំពោះអ្នកក្រីក្រនៅប្រទេសកម្ពុជា និងចំពោះអនាគតរបស់កម្ពុជាក្នុងនាមជាប្រទេសមួយ ។ បើគ្មានការខិតខំប្រឹងប្រែងជាបន្ទាន់ ដើម្បីលុបបំបាត់នូវឧបសគ្គលើផ្នែកអភិបាលកិច្ចចំពោះភាពចំរុះផ្នែកវិនិយោគ និងសេដ្ឋកិច្ចទេ កំណើន នឹងត្រូវធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេលមធ្យម ។ បើគ្មានការខិតខំប្រឹងប្រែងហ្មត់ ចត់ដើម្បីកែលំអគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈទេនោះ ឬដើម្បីគ្រប់គ្រងឱ្យប្រសើរឡើងនូវធនធានធម្មជាតិ របស់ប្រទេសនេះទេ ប្រជាពលរដ្ឋក្រីក្រនឹងទទួលបន្ទុកយ៉ាងធ្ងន់ធ្ងរ ទាំងទុនលើធនធានមនុស្ស និងទុនរូបវន្ត ។

៦៤. នេះមិនមែនចង់បង្ហាញថាកិច្ចការចំពោះមុខនោះវាងាយស្រួលនោះទេ ។ កំណែទំរង់រចនាសម្ព័ន្ធ និងស្ថាប័នដ៏ធំមួយ នឹងត្រូវការជាចាំបាច់ ។ កំណែទំរង់បែបនេះ នឹងគំរាមកំហែងដល់ផលប្រយោជន៍របស់អ្នកមានអំណាច ទាំងនៅក្នុង និងក្រៅរដ្ឋាភិបាល ហើយនឹងត្រូវមានការរារាំងពីអ្នកទាំងនោះ ។ ការណ៍នេះនឹងជំរុញអោយមានការជំនួសនូវដំណើរការសំរាប់កំណែទំរង់ដ៏ពិតប្រាកដ ។ ដំណើរការនេះ គឺមានសារៈសំខាន់ណាស់ ប៉ុន្តែជាញឹកញាប់ វាត្រូវបញ្ចប់ដោយខ្លួនឯង នៅពេលដែលការប្តេជ្ញាចិត្តចំពោះកំណែទំរង់មានភាពទន់ខ្សោយ រុញច្រានដោយបំណងប្រាថ្នាមួយ ដែលគ្រាន់តែធ្វើឡើងដើម្បីបំពេញតាមតំរូវការ របស់ម្ចាស់ជំនួយ និងធ្វើអោយម្ចាស់ជំនួយ មើលឃើញមានការរីកចំរើនខ្លះៗប៉ុណ្ណោះ ជាជាងរុញច្រានដោយគោលជំហរ និងការឯកភាពយ៉ាងរឹងមាំ ។ ដូច្នេះតាមពិតទៅ ប្រទេសកម្ពុជាគឺ កំពុងស្ថិតនៅលើផ្លូវបំបែកមួយ ។ ប្រទេសកម្ពុជា អាចជ្រើសរើសបន្តការកែទំរង់អោយបានខ្លាំងក្លាដែលផ្តល់អំណាចតាមរយៈការពង្រឹងភាពជាម្ចាស់សំដៅទៅផ្លាស់ប្តូរជាមូលដ្ឋានគ្រឹះនូវការលើកទឹកចិត្តដែលបច្ចុប្បន្នប៉ះ ពាល់ដល់ការអភិវឌ្ឍប្រកបដោយចីរភាពរយៈវែង ។ ឬប្រទេសកម្ពុជាអាចបន្តធ្វើអោយច្រលំបល់ជាមួយនឹងផល វិបាកអាក្រក់ធ្ងន់ធ្ងរសំរាប់អ្នកក្រីក្រ ។ ជំរើសដែលនាយករដ្ឋមន្ត្រីទទួលស្គាល់នោះ គឺពិតជាអាចឃើញយ៉ាងច្បាស់ក្រឡែត ។

៦៥. ដោយពិចារណាទៅលើឧបសគ្គខាងធនធានមនុស្ស និងស្ថាប័ន ដែលប្រទេសកម្ពុជាកំពុងប្រឈមមុខមាត់ សំរាប់កំណែទំរង់ ទំនងជាមិនមានភាពរលូន ហើយត្រូវប្រើពេលវេលាយូរដើម្បីធ្វើអោយផលប្រយោជន៍នឹងលេចចេញជារូបរាងឡើង ។ ប៉ុន្តែប្រការសំខាន់គឺត្រូវបោះជំហានជាយុទ្ធសាស្ត្រក្នុងទិសដៅជាគន្លឹះមួយចំនួន និងព្យាយាម បង្ហាញការរីកចំរើនជាក់ស្តែងក្នុងរយៈពេល ១២ខែខាងមុខ ។ ការរីកចំរើន និងជោគជ័យឆាប់រហ័សក្នុងវិស័យ យុទ្ធសាស្ត្រមួយចំនួនអាចកសាងនូវការគាំទ្រ និងកំលាំងចលករផ្នែក

នយោបាយ និងបង្កើននូវទំនុកចិត្តរបស់អ្នកកែទំរង់អោយបន្តកិច្ចការដដែលតទៅទៀត ។ ការងារជាច្រើនដែលរដ្ឋាភិបាល បានអនុវត្តនៅក្នុងការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ និងបរិយាកាសវិនិយោគឯកជន បានផ្តល់ជាគំនិតថានៅក្នុងវិស័យទាំងពីរនេះ មានភាពច្បាស់លាស់នៅលើអ្វីដែលត្រូវតែបំពេញ ហើយក៏ជាសក្តានុពលក្នុងការបង្ហាញឱ្យឃើញពីលទ្ធផលដំបូង ។ ការរីកចំរើនលើគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ មានសារៈសំខាន់យ៉ាងពិសេស ប្រសិនបើដៃគូអភិវឌ្ឍន៍អន្តរជាតិរបស់កម្ពុជា បង្កើនទំនុកចិត្តដោយជឿជាក់ថាជំនួយអភិវឌ្ឍន៍ដែលពួកគេផ្តល់ធ្លាក់ទៅដល់ក្រុមគោលដៅដែលពួកគេចង់ជួយ ។ អាទិភាពផ្សេងៗទៀតនឹងកើតមានឡើងនៅពេលដែលការងារវិភាគដ៏សំខាន់ៗត្រូវបានបញ្ចប់រួចរាល់ ។

## តើដៃគូអភិវឌ្ឍន៍របស់ប្រទេសកម្ពុជាជាផ្នែកមួយនៃបញ្ហាឬទេ?

៦៦. ដៃគូអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសកម្ពុជា មានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ហើយមានបំណងចូលរួមជាផ្នែកមួយនៃដំណោះស្រាយ ។ ប៉ុន្តែពួកគេក៏អាចក្លាយជាផ្នែកមួយនៃបញ្ហាផងដែរ ។ ការខកខានមិនបាននិយាយជំនួសអោយប្រជាជនក្រីក្រនៅក្នុងប្រទេសកម្ពុជា ដោយមានសំលេងជាធ្លុងមួយ ឬខក ខានមិនបានផ្សាភ្ជាប់ការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសទៅនឹងការបំពេញការងារ និងលទ្ធផល បានបញ្ជូននូវសញ្ញាដ៏ច្រ បូកច្របល់ដល់ថ្នាក់ដឹកនាំរបស់ប្រទេសដែលបានបង្ហាញពីភាពប៉ិនប្រសប់ល្មមគ្រប់គ្រាន់ សំរាប់ទាក់ទាញការគាំទ្រ ពីម្ចាស់ជំនួយប៉ុណ្ណោះ ។

៦៧. កិច្ចប្រជុំក្រុមពិគ្រោះយោបល់នៅពេលខាងមុខ គឺជាឱកាសមួយដើម្បីធ្វើការចាប់ផ្តើមដ៏ស្រស់បំព្រងមួយ ។ ការខិតខំប្រឹងប្រែងរិតបន្តឹងកិច្ចសំរបសំរួលរបស់ម្ចាស់ជំនួយដែលបានធ្វើឡើងមុនកិច្ចប្រជុំនេះ ផ្តល់ជាឱកាសសំរាប់ធ្វើអោយការឧបត្ថម្ភគាំទ្ររបស់ម្ចាស់ជំនួយ ស្របទៅនឹងសាររួម និងច្បាស់លាស់មួយ ។ ទំហំនៃការគាំទ្ររបស់ម្ចាស់ជំនួយទ្វេភាគី និងពហុភាគី ចាំបាច់ត្រូវដាក់ល័ក្ខខ័ណ្ឌអោយបានច្បាស់លាស់អំពីភាពគ្រប់គ្រាន់នៃការខិតខំប្រឹងប្រែង ធ្វើកំណែទំរង់របស់ប្រទេសកម្ពុជា ។ បើសិនជាកំណែទំរង់នេះមានជារូបរាងឡើង ម្ចាស់ជំនួយចាំបាច់ត្រូវស្វែងរកមធ្យោបាយក្នុងការផ្តល់ហិរញ្ញប្បទានលើចំណុចដែលទំនងជាមានការខ្វះខាតនៃចំណូលរបស់រដ្ឋាភិបាល ប្រសិនបើកំណើនមានការយឺតយ៉ាវយ៉ាងខ្លាំងនៅក្នុងឆ្នាំ២០០៥ និងឆ្នាំ បន្ទាប់ ។

៦៨. ដូចដែលបានកត់សំគាល់នៅក្នុងជំពូក១រួចហើយ កំណើនទំនងជាធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងឆ្នាំ២០០៤-២០០៥ ហើយក៏ទំនងជា មិនអាចធ្វើអោយប្រសើរឡើងវិញនូវគោលដៅនៃ*យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ* (NPRS) អោយបានពី ៦ ទៅ ៦,៥ ភាគរយ ត្រឹមឆ្នាំ២០០៩ ។ ដោយពិចារណាលើសេនារីយ៉ូនេះ ប្រទេសកម្ពុជាមានឆន្ទៈអនុវត្តកំណែទំរង់អភិបាលកិច្ចដ៏ចាំបាច់ ដើម្បីធ្វើអោយប្រសើរឡើងវិញ បរិយាកាសវិនិយោគទុនរបស់ខ្លួន វាចាំបាច់ដែលម្ចាស់ ជំនួយត្រូវមានលទ្ធភាពឆ្លើយតបទៅនឹងតំរូវការរបស់ប្រទេសកម្ពុជា ក្នុងការស្តារឡើងវិញនូវកំណើនអោយបាន ច្រើនតាមដែលធ្វើទៅបានក្នុងរយៈពេលអន្តរកាលនេះ ។ នៅក្នុងចន្លោះឆ្នាំ១៩៩៩-២០០៣ ការហូរចូលនូវជំនួយដ៏ច្រើន ដែលគិតជាមធ្យមស្មើនឹង ១២ ភាគរយភាគរយនៃផលិតផលក្នុងស្រុកសរុប បានជួយផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគទុនក្នុងស្រុក និងជួយជំរុញដោយសកម្មភាពសាងសង់ (IMFឆ្នាំ២០០៤) ។ ប្រហែលជាពាក់កណ្តាលនៃ ជំនួយដែលបានហូរចូលទាំងនេះ គឺជាជំនួយឥតសំណងក្នុងរូបភាពជាគំរោងដែលផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ និងជាជំនួយបច្ចេកទេស ដែលជំនួយទាំងអស់នេះ ស្ថិតនៅក្រៅគំរោងថវិកា ។ ជំនួយដែលបានហូរចូលទាំងនេះ ត្រូវបានគេប្រើប្រាស់ដើម្បីធ្វើអោយប្រសើរឡើងនូវវិស័យសុខាភិបាល និងអប់រំ (២៤ ភាគរយ) ស្តាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (២៣ ភាគរយ) និងដើម្បីពង្រឹងស្ថាប័នសេដ្ឋកិច្ច និងសង្គម (១៥ ភាគរយ) ។ វិស័យកសិកម្ម និង រុក្ខាប្រមាញ់ ទទួលបានត្រឹមតែ ៨ ភាគរយនៃជំនួយទាំងអស់ប៉ុណ្ណោះ ។

៦៨. ឥឡូវនេះ គឺជាពេលត្រូវត្រួតពិនិត្យសារឡើងវិញ នូវការបែងចែកថ្មីៗនៃជំនួយបរទេសដោយពិចារណាបន្ថែមលើការផ្តោតការយកចិត្តដាក់លើរបៀបវារៈកំណើន ។ ទោះបីជាសមត្ថភាពទន់ខ្សោយផ្នែករដ្ឋបាល អាចតំរូវអោយជំនួយប្រហែល៥០%នៃជំនួយទាំងអស់ ក្នុងកំឡុងឆ្នាំ ១៩៩៩ - ២០០៣ ត្រូវបានប្រើប្រាស់សំរាប់កិច្ចសហប្រតិបត្តិការ ផ្នែកបច្ចេកទេសក៏ដោយ ក៏ការបែងចែកជំនួយទាំងនេះ អាចតំរូវអោយមានការដោះស្រាយផ្ទាល់លើភាពក្រីក្រ និងធ្វើអោយមានកំណើនក្នុងរយៈពេលវែង ។ តំរូវការដ៏ធំធេងដើម្បីលើកកំពស់ប្រាក់ចំណូលតាមជនបទ ទាមទារអោយមានការវិនិយោគទុនច្រើនថែមទៀតនៅក្នុងវិស័យកសិកម្ម និងនៅក្នុងហេដ្ឋារចនាសម្ព័ន្ធនៅតាមជនបទ ដើម្បីផ្សាភ្ជាប់កសិដ្ឋានទៅនឹងទីផ្សារ ។ ជាការពិតណាស់ ការវិនិយោគទុនទាំងនេះប្រាកដជាអាចត្រូវបានគេប៉ាន់ប្រមាណ ជាមុន លើរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រវិនិយោគទុន អោយបានគ្រប់គ្រាន់សំរាប់វិស័យទាំងនេះ ។

៧០. ម្ចាស់ជំនួយចាំបាច់ត្រូវស្វែងរកមធ្យោបាយដែលមានប្រសិទ្ធភាពជាងនេះ ក្នុងការផ្តល់ជំនួយបច្ចេកទេស ដើម្បីកសាងសមត្ថភាពផ្ទាល់ខ្លួនរបស់កម្ពុជា ជាជាងអនុវត្តជំនួសគេ។ ការពឹងអាស្រ័យទៅលើទីប្រឹក្សាបរទេស គឺជារឿងមួយច្រើនហួសហេតុៈ ចំនួនទីប្រឹក្សាបរទេសមាន ៨០០នាក់ និង ទំហំនៃការចំណាយដោយម្ចាស់ជំនួយមានកំរិតខ្ពស់ ការចំណាយប្រាក់បៀវត្សសរុបរបស់រដ្ឋាភិបាលទៅទៀត ។ ការទុកចិត្តទៅលើទីប្រឹក្សាសំរាប់ដំណើរការកំណែទំរង់ ឬការគ្រប់គ្រងគំរោង ធ្វើអោយមានការលំបាកដល់ភាពជាម្ចាស់របស់ជាតិ និងការកសាងសមត្ថភាពស្ថាប័ន ជាពិសេសនៅពេលដែលទីប្រឹក្សាទាំងនេះ មានភាពទន់ខ្សោយចំពោះការបញ្ចូលទៅក្នុងដំណើរការផ្ទៃក្នុងរបស់រដ្ឋាភិបាល (ហ្គោដព្រី ឆ្នាំ ២០០៣ និង មីស្លីវិក ឆ្នាំ ២០០៤) ។ កម្មវិធីដែលត្រូវសំរេចតាម ពេលកំណត់សំរាប់ការកាត់បន្ថយ និងការលុបបំបាត់ទីប្រឹក្សាបរទេស និងជំនួសពួកគេដោយអ្នកឯកទេសកម្ពុជា សំរាប់រយៈពេលមធ្យម និងវែងចាំបាច់ត្រូវចាប់ផ្តើមអនុវត្តជាបន្ទាន់ ។ គំរូវការនេះត្រូវតែអមដោយកម្មវិធីមួយដើម្បីជំនួសការអនុវត្តនាពេលបច្ចុប្បន្ននៃការបន្ថែមប្រាក់បៀវត្សរ៍ពិសេសដល់មន្ត្រីរដ្ឋាភិបាលដែលធ្វើការលើគំរោងដែលគាំទ្រដោយម្ចាស់ជំនួយ ជាមួយនឹងប្រព័ន្ធចំណាយប្រកបដោយតម្លាភាពមួយ ដើម្បីជ្រើសរើសយ៉ាងប្រយ័ត្នប្រយ៉ែងក្រុមអាទិភាពសំខាន់ដើម្បីលើកកំពស់ការផ្គត់ផ្គង់សេវាដល់អ្នកក្រ។ ដូចជាគំរោងមួយដែលនឹងគំរូវអោយមានការភ្ជាប់គ្នាទៅវិញទៅមកដើម្បីលើកកំពស់ការគ្រប់គ្រងការអនុវត្តរបស់មន្ត្រីរាជការនៅតាមក្រសួង (ជំពូកទី៣)។ ប្រព័ន្ធប្រភេទនេះ នឹងចាំបាច់ត្រូវបង្កើតឡើង និងអនុវត្តសំរាប់រយៈពេលពី ១០ ទៅ ១៥ឆ្នាំ ខាងមុខ រហូតដល់ចំណូលកម្ពុជា មានភាពប្រសើរឡើងគ្រប់គ្រាន់ល្មមនឹងផ្តល់ប្រាក់បៀវត្សដែលអាចផ្គត់ផ្គង់ដល់សេវាកម្មស៊ីវិលមានប្រាក់ឈ្នួលមួយដែលអាចរស់បាន។

៧១. ម្ចាស់ជំនួយ ក៏ចាំបាច់ត្រូវកាត់បន្ថយនូវចំណាយសំរាប់កម្ពុជាពីការបរាជ័យក្នុងកិច្ចសំរបសំរួលរបស់ម្ចាស់ជំនួយ។ ការផ្សារភ្ជាប់កម្មវិធីម្ចាស់ជំនួយ និងកម្មវិធីអភិវឌ្ឍន៍របស់រដ្ឋាភិបាល ការធានាថារាល់ជំនួយរបស់ម្ចាស់ជំនួយទាំងអស់ត្រូវបានកត់ត្រានៅក្នុងគំរោងថវិកា ការអនុវត្តការងារវិភាគរួមគ្នា ការពឹងផ្អែកច្រើនឡើង លើកម្មវិធីជំនួយតាមវិស័យ ការធ្វើអោយនីតិវិធីរបស់ម្ចាស់ជំនួយមានភាពស្របគ្នា ដើម្បីកាត់បន្ថយបន្ទុកគោលនយោបាយ និង អនុវត្តរបស់ម្ចាស់ជំនួយជាច្រើនដែលបច្ចុប្បន្នរដ្ឋាភិបាល ត្រូវអនុវត្តតាមដើម្បីបំពេញលក្ខណៈសម្បត្តិសំរាប់ទទួលជំនួយ ។ ផែនការសកម្មភាពស្តីពីការធ្វើអោយស៊ីសង្វាក់គ្នាដែលបានស្នើឡើង នឹងត្រូវលើកយកទៅពិចារណា នៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់នេះ ហើយចាប់ផ្តើម

ដំណើរការកំណែទំរង់ខាងផ្នែកម្ចាស់ជំនួយ ។ ជំហានដ៏សំខាន់ដំបូង គឺនឹងត្រូវផ្តល់ជំនួយសហប្រតិបត្តិការទៅដល់ផែនការ៥ឆ្នាំបន្ទាប់របស់រដ្ឋាភិបាល គឺចាប់ពីឆ្នាំ ២០០៦ - ២០១០ ដែលនឹងព្យាយាមបង្កើតគោលនយោបាយ និងការវិនិយោគទុន ដែលនឹងធ្វើអោយទស្សនវិស័យយុទ្ធសាស្ត្រចតុកោណក្លាយជាការពិតសំរាប់ប្រទេសកម្ពុជា ។

៧២. រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍អន្តរជាតិរបស់ខ្លួន ជួបប្រទះនឹងឱកាសពិសេសមួយ ដើម្បីពន្លឿនយ៉ាងខ្លាំងនូវដំណើរការកំណែទំរង់ នាពេលមួយដែលហាក់ដូចជាអំណោយផលក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសនេះ ។ ថ្នាក់ដឹកនាំសំរាប់កិច្ចការនេះត្រូវតែមកពីប្រទេសកម្ពុជា ? តើអ្នកដឹកនាំប្រទេសកម្ពុជានឹងចាប់យកឱកាសនេះឬទេ ?

---

1

[១] រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណ សំរាប់កំណើន ការងារ សមភាព ប្រសិទ្ធិភាពនៅក្នុងប្រទេសកម្ពុជា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងនីតិកាលទី៣របស់រដ្ឋសភា នៅឯទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤

[២] Ibid. p.2

[៣] អង្គការ UNDP និង SIDA, របាយការណ៍ស្តីពីគោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជាឆ្នាំ២០០៣ មាននៅគ្រប់ឯកសារ

[៤] វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍកម្ពុជា (CDRI) ឧបត្ថម្ភ និងត្រួតពិនិត្យដោយធនាគារអភិវឌ្ឍន៍អាស៊ី *កម្ពុជា : ការលើកស្ទួយអភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព* ខែមេសា ឆ្នាំ២០០០ កថាខណ្ឌ ៣៨

[៥] *ចៅហ្វាយ* អាចជាអ្នកនយោបាយ ហើយភ្នាក់ងារអាចជាការិយាលេខានុការ ។ ឬ *ចៅហ្វាយ* អាចជាប្រធានទីភ្នាក់ងារ ឬមន្ត្រីរាជការ ស៊ីវិល ហើយ*ភ្នាក់ងារ* អាចជាអ្នកផ្តល់សេវាជួរមុខ (ដូចជា ប្រធាននាយកដ្ឋានប្រៃសណីយ៍ និងបុរសប្រៃសណីយ៍)។ បញ្ហា របស់ចៅហ្វាយ-ភ្នាក់ងារកើតមានឡើង ពីព្រោះផលប្រយោជន៍របស់*ចៅហ្វាយ* និង*ភ្នាក់ងារ* មានការខ្វែងគ្នា ។ ចៅហ្វាយខ្វះពតិមានគ្រប់គ្រាន់អំពីអាកប្បកិរិយារបស់ភ្នាក់ងារ (ភាពមិនស៊ីមេទ្រីនៃពតិមាន) ហើយភ្នាក់ងារមានគ្រឿងលើកទឹកចិត្តក្នុងការលាក់ពតិមាន ។ ភ្នាក់ងារអាចប្រព្រឹត្តអំពើពុករលួយ ប្រសិនបើនៅក្នុងការវិនិច្ឆ័យរបស់គាត់ ឃើញថា ផលប្រយោជន៍នៃការធ្វើដូច្នោះ លើសពីការខាតបង់ ។ ការខាតបង់នៅទីនេះសំដៅដល់ហានិយផ័យនៃការរកឃើញ និងការដាក់ទណ្ឌកម្ម ឬការបាត់បង់កេរ្តិ៍ឈ្មោះ និងការគោរពខ្លួនឯង ។ លោក Robert Klitgaard’s បានបង្កើតសមីការ : **អំពើពុករលួយ = សិទ្ធិផ្តាច់មុខ + សិទ្ធិសំរេច - គណនេយ្យភាព** ដែលបង្កប់ន័យថា អំពើពុករលួយគឺជាបញ្ហានៃការលុបចោល ឬដាក់កំហិតចំពោះសិទ្ធផ្តាច់មុខ ទៅលើការផ្តល់សេវា ដោយកាត់បន្ថយសិទ្ធិសំរេចនៅក្នុងដៃរបស់ភ្នាក់ងារ ហើយបង្កើននូវគណនេយ្យភាព

សំរាប់ទង្វើរបស់ខ្លួន ( លោក Robert Klitgaard, *ការគ្រប់គ្រងអំពើពុករលួយ* Berkeley: University of Carlifornia Press, ១៩៩៨ ទំព័រ ៦៩-៧៥) ។ គំរូនេះសន្មតថា *ចៅហ្វាយ* ពុំប្រព្រឹត្តអំពើពុករលួយទេ ។ ជាញឹលញាប់នេះមិនមែនជាបញ្ហាទេ ហើយ *ចៅហ្វាយ* និង *ភ្នាក់ងារ* អាចឃុបឃិតគ្នាប្រឆាំងទៅនឹង *ចៅហ្វាយ*ធំ គឺប្រជាជន ។

[៦] បញ្ហានេះភានលើកឡើងនៅក្នុងការទំនាក់ទំនងមួយពីរដ្ឋាភិបាលទៅក្រុមការងាររបស់ម្ចាស់ជំនួយលើកំណែទំរង់ច្បាប់ និងតុលាការ ថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០០៤ ដែលធ្វើជូនឯកឧត្តម ស៊ុំ មានិត ប្រធានស្ថាប័នសំរប់សំរួលអចិន្ត្រៃនៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងតុលាការ

[៧] ក្រុមប្រឹក្សានេះមានសមាជិក ជាអាទិ៍ ព្រះមហាក្សត្រ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានតុលាការកំពូល អគព្រះរាជ អាជ្ញាតុលាការកំពូល និងប្រធានសាលាឧទរណ៍ អគព្រះរាជអាជ្ញាសាលាឧទរណ៍ និងចៅក្រមបីនាក់ទៀតដែលបោះ ឆ្នោតជ្រើសរើសដោយប្រព័ន្ធតុលាការសំរាប់រយៈពេល៥ឆ្នាំ។

[៨] សុន្ទរកថានៅក្នុងវេទិការវាងផ្នែកឯកជន និងរាជរដ្ឋាភិបាល លើកទី៧ វិមានរដ្ឋាភិបាល ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៤

[៩] លោក ហ្គោដព្រី ឆ្នាំ ២០០៣ និង លោក មីស្លីវិក ២០០៤

# សេចក្ដីសង្ខេប

## ជំពូកទី ១

## ស្ថានភាពសេដ្ឋកិច្ចនាពេលកន្លងមក និង សេចក្ដីរំពឹងទុកសំរាប់ពេលខាងមុខ

១. ជំពូកនេះដោយផ្អែកលើការពិគ្រោះលើមាត្រាទី៤នាពេលថ្មីៗនេះរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ **(IMF)** ផ្ដល់ការវិភាគលើស្ថានភាពសេដ្ឋកិច្ចរបស់កម្ពុជានាពេលថ្មីៗ និង សេចក្ដីរំពឹងទុកសំរាប់ពេលខាងមុខ។ សេដ្ឋកិច្ច មានការប្រែប្រួលរីកចំរើនយ៉ាងខ្លាំង ចាប់តាំងពីឆ្នាំ១៩៩៩ ។ ដោយមានការទទួលបាននូវស្ថិរភាពនយោបាយបន្ទាប់ពីការបោះឆ្នោតឆ្នាំ ១៩៩៨ មក និងដោយមានគោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្ន ផ្នែកឯកជនបានរីកចំរើននៅតាមទីប្រជុំជន។ ផលិតផលសរុបក្នុងស្រុក **(GDP)** បានពង្រីកក្នុងអត្រាពី ៦ ទៅ ៧ ភាគរយ ក្នុងអំឡុងឆ្នាំ ១៩៩៩-២០០៣ មួយផ្នែកធំដោយសារ កំណើនខាងការនាំចេញសំលៀកបំពាក់ដែលចាប់ចេញពីសូន្យទៅដល់ ១ ពាន់លាន់ដុល្លារ តាមរយៈការ ផ្ដល់ទីផ្សារអនុគ្រោះរបស់សហរដ្ឋអាមេរិក ហើយនិង ដោយសារការរីកចំរើនខាងទេសចរណ៍ និង ការហូរចូលនូវជំនួយបរទេស ដែលមានជាមធ្យម ១២ ភាគរយនៃផលិតផលសរុបក្នុងស្រុក ។ ទោះបីជា យ៉ាងណាមានការរំពឹងទុកថាកំណើនសេដ្ឋកិច្ចនឹងថយចុះនៅឆ្នាំ ២០០៤ មួយផ្នែកធំដោយមកពីផ្នែក កសិកម្មដែលមានការរំពឹងទុកថាចុះខ្សោយ ។ ការកើនឡើងនូវតំលៃប្រេងក៏រំពឹងថា នឹងដាក់សំពាធ ទៅ លើអតិផរណា និងតុល្យភាពនៃចំណាយ ។

២. គោលនយោបាយសារពើពន្ធមានការគាំទ្រដល់កំណើនសេដ្ឋកិច្ច ដោយបានធានាអោយមានលំនឹងម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ចំណូលថវិការបស់រដ្ឋ បានកើនពី៨ភាគរយនៃផលិតផលសរុបក្នុងស្រុកនៅឆ្នាំ ១៩៩៨ ទៅ ១១,២ ភាគរយនៅឆ្នាំ ២០០២ ដែលជាការឆ្លុះបញ្ចាំងនូវការពង្រឹងរដ្ឋបាលគយ និងពន្ធដារ ។ តែទោះជាយ៉ាងណាក៏ដោយ ការប្រឹងប្រែងប្រមូលចំណូលរដ្ឋនៅមិនគ្រប់គ្រាន់ ហើយការរីកចំរើន បានចុះដុនដាបទៅវិញនៅឆ្នាំ២០០៣។ ចំណូលថវិការជាតិរបស់កម្ពុជានៅតែ ទាបជាងអត្រាជាមធ្យម ១៦ ភាគរយនៃផលិតផលសរុបក្នុងស្រុកនៃបណ្ដាប្រទេសជិតខាងដែលមានប្រាក់ចំណូលទាប ។ ការសងការប្រាក់លើបំណុលជាប់ជំពាក់ សហព័ន្ធរុស្ស៊ី និង សហរដ្ឋអាមេរិក នឹងយកមួយផ្នែកធំនៃ

កំណើនចំណូលថវិការជាតិណាមួយដែលអាចមាន ។

៣. សេចក្តីសង្ឃឹមសំរាប់រយៈពេលមធ្យម អាស្រ័យទៅលើថា តើកម្ពុជានឹងទទួលបានជោគជ័យទេលើការ បង្កើនល្បឿនកំនែទំរង់រចនាសម្ព័ន្ធ និង ការកែត្រលប់ពីស្ថានភាពដែលដុនដានខាងការ ប្រកួតប្រជែង ដោយសារបញ្ហាអភិបាលកិច្ចខ្សោយ។ ការលុបបំបាត់ប្រព័ន្ធកូតា (Quota) នៅខែមករា ២០០៥ នឹងធ្វើអោយអ្នកនាំចេញសំលៀកបំពាក់របស់កម្ពុជាជួបនឹងការប្រកួតប្រជែងជាខ្លាំង ពីសំណាក់អ្នកនាំសំលៀកបំពាក់ចេញដូចជាពីប្រទេសចិនដែលមានការចំណាយទាបជាងកម្ពុជា ។ ការនេះតម្រូវអោយកម្ពុជាឈានទៅរកពិពិធកម្មខាងកំណើនសេដ្ឋកិច្ចអោយពេញទំហឹង ។ ការលើកស្ទួយកសិកម្មជាយុទ្ធសាស្ត្រដ៏ប្រសើរបំផុត ដើម្បីធានាប្រភពកំណើនជាគន្លឹះមួយ ដែលអាចជួយស្រូបយកកំលាំងពលកម្ម ដែលរំពឹងថាមានការកើនឡើង ដោះស្រាយភាពក្រីក្រដោយផ្ទាល់ និង ដែលអាចអោយមានការពង្រីក ទីផ្សារក្នុងស្រុកបានកាន់តែលឿនសំរាប់ផលិតផលកែច្នៃ ។ ការចូលជាសមាជិកពាណិជ្ជកម្មពិភពលោក ក៏ផ្តល់ឱកាសដល់កំណើនសេដ្ឋកិច្ច ដែលពុំនោះទេកម្ពុជានឹងពុំអាចទទួលបាន ក៏ប៉ុន្តែការទទួលផល ទាំងនោះបាន កម្ពុជាត្រូវការកែទំរង់អោយបានកាន់តែលឿននិងគ្រប់ជ្រុងជ្រោយ ។ ការខិតខំប្រឹងប្រែងគួរតែផ្តោតលើការពង្រឹងការប្រកួតប្រជែង ដើម្បីកាត់បន្ថយឥទ្ធិពលពីការនាំចេញសំលៀកបំពាក់ដែលរំពឹង ទុកថាមានការចុះថយ ហើយឆ្ពោះទៅលើកទឹកចិត្តអោយមានពិពិធកម្មលើការនាំចេញ ។

៤. តំលៃនៃការនាំចេញសំលៀកបំពាក់អាចថយចុះដល់ ១២ ភាគរយ នៅឆ្នាំ ២០០៥ ដែលអាចនាំដល់ការថយចុះខាងកំណើនផលិតផលក្នុងស្រុកសរុប មកត្រឹម ២ ភាគរយ នៅឆ្នាំដដែលនោះ ។ ប្រសិនបើមានការអនុវត្តដ៏ស្រួចស្រាល់លើការកែទំរង់ នោះកំណើនសេដ្ឋកិច្ចនឹងកើនដល់កំរិត ដែលរដ្ឋាភិបាលកំណត់ គឺ៦ ទៅ៦.៥ ភាគរយ ត្រឹមឆ្នាំ២០០៩។ ការបរាជ័យមិនបានសំរេចការកែទំរង់ នឹងកំរិតកំណើនសេដ្ឋកិច្ចមកត្រឹម ២ ទៅ ៤ភាគរយ ក្នុងរយៈពេលជាមធ្យម។

# ជំពូក១: ស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងការរំពឹងទុកក្នុងរយៈពេលមធ្យម

៥ កំណើនសេដ្ឋកិច្ចមូលដ្ឋានគ្រឹះទូទៅ និងការគ្រប់គ្រងសារពើពន្ធ គឺជាស្នូលដើម្បីទទួលបានជោគជ័យលើ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ ដូចដែលបានបញ្ជាក់ នៅក្នុងទស្សនះរួមថា ប្រទេសកម្ពុជាបានធ្វើអោយមានផលចំណេញដ៏គួរអោយចាប់អារម្មណ៍ ចាប់តាំងពីសង្គ្រាមនៅក្នុងប្រទេសនេះបានបញ្ចប់ ។ នៅក្នុងជំពូកនេះបានផ្តល់នូវការវាយតំលៃមួយរបស់ IMF លើសមិទ្ធិផលសេដ្ឋកិច្ចបច្ចុប្បន្នរបស់កម្ពុជា និងការរំពឹងមើលពាក់កណ្តាលអាណត្តិ ដែលយោងទៅតាមកិច្ចពិភាក្សាលើកទី៤ នៃការពិគ្រោះយោបល់របស់ IMF ។

ក្រាហ្វិកទី ១.១ **ចីរភាពលំហូរជំនួយ**

**(ជាភាគរយនៃ GDP)**




៦ ចាប់តាំងពីដើមឆ្នាំ១៩៩៩ សមិទ្ធិផលសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាបានប្រសើរឡើង ។ ជាមួយនិងអំណោយផលខាងស្ថេរភាពនយោបាយ រួមនឹងការ បោះឆ្នោតឆ្នាំ១៩៩៨ សកម្មភាពវិស័យឯកជនបានចាប់ផ្តើមរីកស្ទុះស្ទាយនៅទីប្រជុំជន។ កំណើនផលិតក្នុងស្រុកបានពង្រីកក្នុងរង្វង់ពី ៦ ទៅ ៧ ភាគរយ ចន្លោះឆ្នាំ ១៩៩៩ ដល់ ២០០៣ ដែលបានមកពីកត្តាខាងក្រៅដ៏សំបើម ដូចជាការស្ទុះឡើងនៃការនាំចេញវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ក៏ដូច ជាសំហូរប្រាក់ជំនួយជាច្រើន (ក្រាហ្វិកទី ១.១)។ លើសពីនេះ កម្ពុជាបានទទួលផលប្រយោជន៍ពីការទទួលយកនូវចំនួនដ៏ច្រើននៃជំនួយអភិវឌ្ឍន៍ផ្លូវការទាំងក្នុងទំរង់ដោយផ្ទាល់ និង ទាំងក្នុងទំរង់ប្រយោល។ កំណើនក៏បានគាំទ្រដោយគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្នជាទូទៅផងដែរ។ ទោះបីជាមានការអភិវឌ្ឍគួរសមក៏ដោយ ក៏នៅតែមានការលំបាកខ្លះៗ ដែលបានគិតទុកសំរាប់ការអនុវត្តកំណើនរបស់កម្ពុជា។ ទី១ ទោះបីជាមានកំណើនរឹងមាំ តែការកាត់បន្ថយភាពក្រីក្របាននៅទ្រឹង ហើយសូចនករវាស់ការអភិវឌ្ឍធនធានមនុស្ស ជាច្រើនដូចបានចែងក្នុងទស្សនៈរួម បានបង្ហាញថា ពុំមានលក្ខណៈប្រសើរច្រើន ដូចដែលយើងសង្ឃឹមទុកនោះទេ។ ទី២: ដូចដែល

បានបង្ហាញនៅក្នុងជំពូកនេះ កំណើនក្នុងរយៈពេលមធ្យម គឺសង្ឃឹមថា នៅតែមានអត្រាទាបជាងអ្វីដែលជាតំរូវការសំរាប់កាត់បន្ថយភាពក្រីក្រ ទោះបីជានៅក្រោមរូបភាពក្នុងកាលៈទេសៈដែលអាចរំពឹងទុកដ៏ប្រសើរក៏ដោយ។ ទស្សនៈនេះឆ្លុះបញ្ចាំងជាចំបងពីដំណើរការដែលពុំគ្រប់គ្រាន់ នៅក្នុងការកែទំរង់រចនាសម្ព័ន្ធក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ដូច្នេះត្រូវមានការងារជាបន្ទាន់ ដើម្បីអនុវត្តការកែទំរង់ប្រកបដោយអត្ថន័យ ជាពិសេសការកែលំអ អភិបាលកិច្ច ដើម្បីពន្លឿនកំណើនអោយបាន ខ្លាំងខ្លា និង ទូលំទូលាយ។ វាក៏មានតំរូវការបន្ទាប់ដែរ ដើម្បីផ្តោតការយកចិត្តទុកដាក់ ដោយផ្ទាល់លើគោលគំនិត ដើម្បីកាត់បន្ថយភាពក្រីក្រ។

## ក ~ ស្ថានភាពកំណើន

៧ កំណើនសេដ្ឋកិច្ចដ៏រឹងមាំនេះ សូម្បីមានមូលដ្ឋានគ្រឹះចង្អៀតក៏ដោយ ក៏អាចងើបចេញបានដែរ ដោយសំអាងទៅលើកត្តាខាងក្រៅបីសំខាន់ៗៈ សន្ទុះនៃការនាំចេញផ្នែកកាត់ដេរ ការហូរចូលទេសចរ និង ជំនួយពីខាងក្រៅ។

៨ នៅឆ្នាំ១៩៩៦ កម្ពុជាត្រូវបានគេផ្តល់អោយនូវលក្ខខណ្ឌពិសេសសំរាប់ការនាំចូលសំលៀកបំពាក់ចូលទីផ្សាររបស់អាមេរិកក្រោមកិច្ចព្រមព្រៀងវាយនភណ្ឌ និង សំលៀកបំពាក់ (ATC)។ នៅក្រោមកិច្ចព្រមព្រៀងទ្វេភាគីនេះ ពន្ធអាករជាមធ្យមរបស់អាមេរិកសំរាប់សំលៀកបំពាក់ដែលផលិតនៅកម្ពុជាបានបញ្ចុះថ្លៃពី ៥០ ទៅ ៧០ ភាគរយ មកនូវពី ១០-២០ ភាគរយ វិញ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មឆ្នាំ១៩៩៦ បានទាក់ទាញអ្នកវិនិយោគទុនបរទេសមួយចំនួនធំរួមចំណែកធ្វើអោយមានកំណើនបំពេញតំរូវការស្ថេភាពមួយ នៅក្នុងការនាំចេញវិស័យកាត់ដេរទៅកាន់អាមេរិកពីចំនួន 0 នៅឆ្នាំ១៩៩៥ មកដល់ ៥00 លានដុល្លាក្នុង ឆ្នាំ១៩៩៩ ហើយកើនរហូតដល់ទៅជាង ១000លានដុល្លានៅក្នុងឆ្នាំ ២00៣ ដែលវាស្មើនឹង ៧0ភាគរយ នៃការនាំចេញវិស័យកាត់ដេរទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ ផលប្រយោជន៏សំរាប់សេដ្ឋកិច្ចនៅក្នុងស្រុកនៅមានកំរិត ហើយស្ទើតែទាំងស្រុងនៃវត្ថុធាតុដើមសុទ្ធតែត្រូវបាន នាំចូលពីបរទេសទាំងអស់។

៩. ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ សកម្មភាពទាក់ទងនឹងទេសចរក៏បានបំពេញទៅដល់កំណើនផលិតផលក្នុងស្រុកសរុបដែរ។ អ្នកទេសចរដែលមកទស្សនាកម្ពុជាមានការកើនឡើងជាងពាក់កណ្តាល

ក្នុងអំឡុងពេលពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ២០០២ ដែលចំនួននេះ កើនដល់ ៥៤០ពាន់នាក់ក្នុងឆ្នាំ២០០២។ ប៉ុន្តែកំណើន ទេសចរនេះបានបន្ទុចបង្អាក់រយៈពេលខ្លីនៅក្នុងឆ្នាំ២០០៣ ដោយសារជំងឺសារ។

១០. កត្តាពីខាងក្រៅទី៣ដែលបំពេញសំរាប់កំណើននៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះមាន ស្ថេរភាពលំហូរនៃជំនួយអភិវឌ្ឍន៍ផ្លូវការ(ODA) (ក្រាហ្វិក ១.២)។ គិតជាមធ្យមក្នុងទសវត្សរ៍កន្លងមកផ្អែកលើមូលដ្ឋាននៃចំណូលម្នាក់ៗ កម្ពុជាបានទទួល ODA ច្រើនជាងប្រទេសដែលមានប្រាក់ចំណូលទាប។ លំហូរជំនួយប្រមាណ ១២ ភាគរយ នៃ GDP ហើយប្រហែលជាងពាក់កណ្តាលនៃលំហូរនេះ គឺជាជំនួយឥតសំណងសំរាប់គំរោង និងជំនួយបច្ចេកទេស ដែលត្រូវបានប្រើប្រាស់ស្ទើរតែទាំងស្រុងដើម្បីលើកកំពស់វិស័យសុខភាព និងការអប់រំ កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ពង្រឹងស្ថាប័នសេដ្ឋកិច្ច និងសង្គម ហើយនិងជួយដើម្បីធ្វើការវិនិយោគក្នុងស្រុក និងបង្កើនសកម្មភាពសាងសង់។

១១. នាពេលថ្មីៗនេះ កំណើនដែលមិនមែនកសិកម្មបានថយចុះដល់ ៣.២ ភាគរយ ក្នុងឆ្នាំ២០០៣ ដោយមានបញ្ហា ទាក់ទងទៅនឹងជំងឺសារ ដែលបានធ្វើអោយភ្ញៀវទេសចរធ្លាក់ និងភាពមិននឹងនំ ទាក់ទងទៅនឹងការបោះឆ្នោត។ ទោះជាយ៉ាងណា ក៏ដោយជាទូទៅ GDP បន្តកើនឡើង ៥.២ភាគរយ ហើយដោយសារតែលទ្ធផល នៃលក្ខខណ្ឌបរិយាកាស មានអំណោយផលល្អក្នុងវិស័យបង្កបង្កើតផល លើតំបន់ ដែលអាចដាំដុះបាន ដែលជាហេតុធ្វើអោយមានកំណើនខ្លាំង ក្នុងផលិតផលកសិកម្ម ។ ឱនភាពគណនីចរន្តខាងក្រៅ (មិនរួមបញ្ចូលការផ្ទេរសាច់ប្រាក់ជាផ្លូវការ) បានកើនឡើងពី ១ ¼ ភាគរយ ទៅ ១០¼ ភាគរយ នៃ GDP ដោយសារតែកំណើនការនាំចូលទំនិញ ចំណូលវិស័យ ទេសចរណ៍ថយចុះ និងអត្រាតំលៃប្រេងឡើងថ្លៃ។ ទុនបំរុងដុលនៅតែបន្តកើនឡើង ៧៣៧ លានដុល្លាអាមេរិក (ជិតស្មើនិង៣ខែនៃតំលៃនាំចូលទំនិញ និងសេវាកម្ម) នាចុងឆ្នាំ២០០៣។



អតិផលរណារក្សាបាន ហើយតំលៃនៃការប្តូរប្រាក់រៀលជាមួយ នឹងដុល្លានៅតែមានស្ថេរភាព លើកលែងតែរយៈ ពេលខ្លីមួយកាល ពីដើមឆ្នាំ នៅពេលដែលប្រាក់រៀលធ្លាក់ថោកបន្តិចដោយសារការធ្លាក់ចុះទុនបំរុងទុករបស់រដ្ឋាភិបាល ។

១២. ការប្រមើលមើលសំរាប់កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០០៤ មានលក្ខណៈមិនច្បាស់លាស់ដោយសារភាពទន់ខ្សោយនៃការរំពឹងទុកសំរាប់ផលិតកម្មកសិកម្ម ។ ជំងឺគ្រុនផ្តាសាយបក្សីកាលពីដើមឆ្នាំនេះ រួមនិងការនេសាទត្រីបានតិចតួចដោយសារតែកំរិតទឹកនៅទន្លេមេគង្គខាងក្រោមទាប និងផលិតកម្មកសិកម្មដែលមើលទៅមិនអាចច្រើនជាងផលដែលទទួលកាលពីឆ្នាំកន្លងទៅ បានបង្ហាញអោយឃើញថា កំណើនផលិតផលនៅទន់ខ្សោយ ។ កំណើនមិនមែនកសិកម្មត្រូវបានរំពឹងថា នឹងងើបឡើងវិញដោយសារកំណើនទេសចរណ៍កើនឡើងវិញ ដូចនេះជាទូទៅ GDP និងអាចកើនឡើងចន្លោះ ៤ ទៅ ៤¼ ភាគរយ ។ ផលប៉ះពាល់នៃការកើនតំលៃប្រេងសាំង ត្រូវបានគេរំពឹងថា នឹងធ្វើអោយរីកធំឡើងនៃឱនភាពគណនីចរន្តប្រហែលជា ¼ ភាគរយ ទៀតនៃ GDP ។ អតិផលរណា គឺប្រហែលជាកើន ឡើងបន្តិចបន្តួចដោយសារការកើនឡើងតំលៃ នៃប្រទេសជាដៃគូពាណិជ្ជកម្ម ។

## ខ ~ ស្ថានភាពសារពើពន្ធ




១៣. ដូចដែលបានរៀបរាប់ពីខាងដើម យើងអាចនិយាយបានថា គោលនយោបាយសារពើពន្ធ មានការគាំទ្រយ៉ាងធំធេងចំពោះកំណើន ដោយធានាថាវាបានបំពេញទៅនឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណូលរដ្ឋាភិបាល ជាទូទៅបានកើនឡើង ៨ ភាគរយ នៃ GDP នៅក្នុងឆ្នាំ១៩៩៨ ទៅដល់ ១១,២ ភាគរយ ក្នុងឆ្នាំ២០០២ ។ ការកែលំអ គឺផ្តោតយ៉ាងខ្លាំងទៅលើការពង្រឹងផ្នែកគ្រប់គ្រងពន្ធ និងគយ ជួយដោយកម្មវិធីជំនួយបច្ចេកទេសដ៏សំខាន់មួយ ក្រោមផែនការសកម្មភាពសហប្រតិបត្តិការ បច្ចេកទេសពីម្ចាស់ជំនួយពហុភាគី (TCAP) និងជំនួយបច្ចេកទេស (TA) ពីម្ចាស់ជំនួយទ្វេភាគីផ្សេងៗ ដោយរួម

ទាំងប្រទេស បារាំងនិងជប៉ុន [១] ។ ទោះជាយ៉ាងណាក៏ដោយ ការកែលំអនៅក្នុងការប្រមូលប្រាក់ចំណូលនៅមានភាពស្រអាប់នៅឡើយ ប្រសិនបើសង្កេតជាទូទៅ រំយោលចំណូលនេះបានធ្លាក់ចុះនៅក្នុងឆ្នាំ ២០០៣ បន្ទាប់ពីមានការរីកចំរើនជាបន្តបន្ទាប់កាលពី ពីរឬបីឆ្នាំកន្លងទៅ(ក្រាភិច១.៣) ។ ប្រាក់ចំណូលកម្ពុជា សរុបនៅតែទាបជាង ចំណូលជាមធ្យមរបស់ប្រទេសក្រីក្រជិតខាងដែលមានជាមធ្យមមាន ១៦ភាគរយ នៃ GDP ។

១៤. ជាធម្មត្តាចំណូលទាបបានជះឥទ្ធពលដល់ការចំណាយសារធារណៈ ។ ការលំបាកនៃការខ្វះខាតសាច់ប្រាក់បានស្តែងអោយឃើញនៅក្នុងផ្នែកមួយនៃការលំបាក សំរាប់ការប្រមូល និងក្នុងផ្នែកមួយដែលមានភាពផុយ ស្រួយនៃគណនីចំណូលរបស់រដ្ឋាភិបាល និងការចែករំលែកមិនស្មើភាពគ្នានៃការចំណាយអោយសមរម្យ ដែលបន្តសន្សានៅបញ្ចប់ឆ្នាំសារពើពន្ធ ។ នេះវាមិនត្រឹមតែប៉ះពាល់លើកម្មវិធីដែលអនុវត្តជារៀងរាល់ឆ្នាំប៉ុណ្ណោះទេ ប៉ុន្តែវាបានប៉ះពាល់យ៉ាងខ្លាំងចំពោះឆ្នាំសារពើពន្ធបន្តបន្ទាប់ទៀត ពីព្រោះការបិទបញ្ជីការចំណាយបញ្ចប់ឆ្នាំបានគិតទូទាត់យកមកវិញលើលំហូរប្រាក់ចំណូលឆ្នាំសារពើពន្ធថ្មីបន្តទៀត ឬក៏ក្លាយជាចំណាយដែលត្រូវសងថ្មី ។ កិច្ចខិតខំប្រឹងប្រែង មួយរបស់រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមក្នុងអំឡុងឆ្នាំ ២០០៣ ដើម្បីដោះស្រាយបញ្ហាបញ្ចេញលុយក្នុងរយៈ ពេលខ្លីដែលមានឥទ្ធពលខ្លាំងក្លាលើការចំណាយផ្នែកសុខភាព និងការអប់រំ ជាមួយនិងកំរិតនៃការទទួលបានជោគជ័យមួយ ។ ទោះជាយ៉ាងណាក៏ដោយ ការកែលំអដ៏ត្រឹមត្រូវ និងឋិតថេរនេះកំពុងរង់ចាំការអនុវត្តរបស់រដ្ឋាភិបាល លើកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលអនុម័តថ្មីៗនេះ វានឹងផ្តល់ឱកាស និងកំណែទំរង់ជាបន្តបន្ទាប់មួយសំរាប់ទទួលការគាំទ្រពីដៃគូអភិវឌ្ឍន៍របស់រដ្ឋាភិបាល ( រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រ ចតុកោណ) ។

១៥. ប្រសិទ្ធភាពនៃហិរញ្ញវត្ថុសាធារណៈដែលវាជាឧបករណ៍មួយសំរាប់កែលំអការផ្តល់ធនធានចំណាយ ឬក៏សំរាប់ការបរិចាកបំពេញដោយផ្ទាល់ដើម្បីកាត់បន្ថយភាពក្រីក្រនោះនៅមានកំរិត ។ ប៉ុន្តែគោលនយោបាយ សារពើពន្ធបានជួយរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដោយជៀសវាងការឧបាស្រ័យលើហិរញ្ញវត្ថុធនាគារក្នុងស្រុក ។ ក្នុងពេលជាមួយគ្នានេះ ភាពមិនស៊ីសង្វាក់គ្នារវាងចំណូល និងកិច្ចសន្យាចំណាយបានលេចចេញជាលទ្ធផលក្នុងកំណើនស្ថេរភាពមួយនៅក្នុងការសងថ្មីវិញទៅដល់អ្នកផ្គត់ផ្គង់ក្នុងស្រុក ការសង់ត្រឡប់នេះ អាចទស្សទាយបានថានិងមានការប្រសើរច្រើនលើថវិកាសំរាប់ប៉ុន្មានឆ្នាំខាងមុខនេះ ។ នៅពេលដែលមានការចរចារលើរចទាសម្ព័ន្ធសេវាជាយថាហេតុនៃបំណុលរបស់សហព័ន្ធរុស្សី និងសហរដ្ឋអាមេរិក

ត្រូវបានបញ្ចប់នោះ សេវាបំណុលទូទៅ អាចរំពឹងទុកថានិងអាច ធ្វើអោយមានកំណើតលើប្រាក់ចំណូល ក្នុងរយៈពេលមធ្យមមួយមុនពេលសាកស្រានទៅវិញ។

## គ ~ រចនាសម្ព័ន្ធជាឧបសគ្គដល់កំណើននិងកាត់បន្ថយភាពក្រីក្រ

១៦. មានតែដំណើរការលើការកែទំរង់រចនាសម្ព័ន្ធតែមួយប៉ុណ្ណោះ ដែលត្រូវបានធ្វើឡើងចាប់តាំងពីឆ្នាំ ១៩៩៩ ហើយ ជំហាននៃកំណែទំរង់នៅក្នុងផ្នែកខ្លះទៀត មានភាពយឺតយ៉ាវនៅក្នុងឆ្នាំ២០០៣ និង២០០៤ នេះ ដោយសារតែមានការបោះឆ្នោត និងការជាប់គាំងនយោបាយរយៈពេលយូរបន្ទាប់ពីពេលបោះឆ្នោត មក។ ការខ្វះខាតលើដំណើរ ការវិវត្តន៍នេះនិងមានលទ្ធផលត្រឡប់វិញសំរាប់ការប្រមើលមើលរយៈពេល មធ្យមមួយ។ ស្ថាប័នគ្រឹះនានា បានបង្កើតឡើង និងច្បាប់ផ្សេងៗ ចាប់ពីច្បាប់កិច្ចសន្យាពាណិជ្ជកម្មរហូត ដល់ច្បាប់គណនេយ្យត្រូវបានអនុម័ត។ ច្បាប់ស្ថាប័នហិរញ្ញវត្ថុមួយត្រូវបានអនុម័ត ដែលអាចផ្តល់មូលដ្ឋាន គតិយុត្តសំរាប់ការទទួលជោគជ័យនៃផ្នែកធានាគារ។ ប៉ុន្តែដំណើរការនេះមានការយឺតយ៉ាវ ជាពិសេសលើ សេវាកម្មស៊ីវិល និងកែទំរង់ប្រព័ន្ធច្បាប់ ដែលវិស័យទាំងពីរនេះ ត្រូវបានប្រមើលមើលថាជាការឆ្លុះបញ្ចាំង នូវការប្រទាំងប្រទើសនយោបាយ ដើម្បីកំណែទំរង់នានា។ ដូចលទ្ធផលនៃការបរាជ័យក្នុងការប្រមូលផ្តុំ លើឱកាសសំរាប់កំណែទំរង់ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ ជាពិសេសប្រឆាំងទៅនឹងទំនាក់ទំនង ដ៏ខ្លាំងមួយ( កំណើនអាស្រ័យទៅលើធាតុខាងក្រៅ) ដែលវាជាមូលដ្ឋានរឹងមាំសំរាប់ចិរភាព កំណើននោះមិន ទាន់បង្កើតទេ មិនសូម្បីតែតំបន់ទីក្រុង។

១៧. ភាពកំសោយនៃរចនាសម្ព័ន្ធដែលមានអន្តរអំពើទៅវិញទៅមកមួយចំនួនមានការលំបាកស្មុគ្រស្មាញ ដោយសារបញ្ហាអភិបាលកិច្ច នៅតែជាឧបសគ្គរាំងចំពោះការឈានទៅមុខរបស់កម្ពុជា ដើម្បីកាត់បន្ថយ ភាពក្រីក្រ។ ទី១ : ភាពយ៉ាប់យ៉ឺនដែលបង្កប់នៅខាងក្រោមនៃការប្រកួតប្រជែងត្រូវបានបិទបាំងដោយ ការអភិវឌ្ឍដ៏ខ្លាំងក្លារបស់ប្រទេសជិតខាងក្រៅ ដែលបានរៀបរាប់ខាងដើម។ ដូចដែលបានពិភាក្សានៅក្នុង ជំពូកទី៥ ដែលនិយាយអំពីភាពខ្វះខាតខាងគ្រប់គ្រងរដ្ឋបាលសាធារណៈ និងភាពទន់ខ្សោយអភិបាលកិច្ច ដោយសារតែមានភាពយឺតយ៉ាវនៃការកែទំរង់នៃប្រព័ន្ធច្បាប់និងតុលាការ ដែលវាបានរាំងដល់បរិស្ថាន ជំនួញ ហើយអនុញ្ញាតអោយអ្នកមានបង្កើតច្បាប់ (បទបញ្ញាតិ) ដោយខ្លួនគេ។ បន្ថែមពីនេះ ហេដ្ឋារចនា

សម្ព័ន្ធដែលទើបនឹងកកើត ជាមួយនិងខ្វះខាតការថែរក្សាជួសជុល ហើយមានកំរៃខ្ពស់នោះ បានធ្វើអោយតំលៃប្រតិបត្តិមានតំលៃខ្ពស់។[២]

១៨. បញ្ហាទី២ : មានហេតុផលមួយចំនួន ដែលថាហេតុអ្វីបានជាភាពក្រីក្រពុំមានការកាត់បន្ថយនោះ គឺថាការ អភិវឌ្ឍកសិកម្មនៅតែមានភាពស្ងប់ស្ងៀមដដែល។ ការទទួលបានដីធ្លី និងទីផ្សារនៅមានកំរិត ហើយមានតែមួយភាគតូចនៃ ODA បានផ្តល់ជូនទៅដល់កម្មវិធីអភិវឌ្ឍកសិកម្ម។ កំណើនយឺតៗនៅក្នុងផ្នែកកសិកម្ម បានរុញកម្ពុជាអោយនៅឆ្ងាយពីគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ និងបន្ថយសមត្ថភាពរបស់ខ្លួនដើម្បីចាប់យកការកើនឡើងក្នុងការ ចូលប្រកួតប្រជែងនៅក្នុងទីផ្សារការងារនារយៈពេលមធ្យម។

១៩. ជាចុងក្រោយ សមត្ថភាពរបស់រដ្ឋាភិបាល នៅតែមានការលំបាកធ្ងន់ធ្ងរដដែលដោយការខ្វះខាតទុនមនុស្ស និងការចាក់ឬសជាប់នៃបញ្ហាអភិបាលកិច្ច ហើយនេះទោះបីជាមានជំនួយសហប្រតិបត្តិការបច្ចេកទេសពីខាងក្រៅក៏ដោយ។ គុណភាពនៃសេវាកម្មស៊ីវិលនៅតែមានភាពទន់ខ្សោយ ហើយចំណូលសារពើពន្ធបច្ចុប្បន្នមាន ១០,៤ ភាគរយ នៃ GDP គឺវាមានការលំបាកគ្រប់គ្រាន់ហើយដើម្បីបំពេញតំរូវការអាទិភាពនៃការចំណាយ។

## ឃ ~ ការប្រមើលមើលក្នុងរយៈពេលមធ្យម

២០. ក្តីរំពឹងក្នុងរយៈពេលមធ្យមនោះអាស្រ័យទៅលើថាតើកម្ពុជាទទួលបានជោគជ័យយ៉ាងណា ពីកំណើនគ្រប់ច្រកល្ហក និងលើលទ្ធភាពរបស់រដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាភាពក្រីក្រដោយផ្ទាល់អោយបានច្រើនជាងឆ្នាំកន្លងមក។ នៅក្នុងក្តីសង្ឃឹមនេះ ការកែទំរង់ជាបន្ទាន់នៅក្នុងវិស័យកសិកម្ម គឺមានសារៈសំខាន់ណាស់។ ដូចជា ការបើកសេដ្ឋកិច្ចតូចៗនៅលើដីដែលមិនបានប្រើប្រាស់ និងប្រើប្រាស់កំលាំងពលកម្មដ៏ច្រើនដែលគ្មានជំនាញ ធ្វើដូចនេះ កសិកម្ម គឺត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាឱកាសដ៏មានអត្ថប្រយោជន៍មួយរបស់ប្រទេសកម្ពុជា។ ការលើកកំពស់កសិកម្ម គឺជាយុទ្ធសាស្ត្រដ៏វិសេសវិសាល ដើម្បីធានាសុវត្ថិភាពធនធានគន្លឹះមួយនៃកំណើន ដែលអាចជួយស្រូបយកមួយផ្នែកនៃការកើនឡើងកំលាំងពលកម្ម ហើយដោះស្រាយបញ្ហាក្រីក្រដោយផ្ទាល់ និងផ្តល់ការពង្រីងយ៉ាងឆាប់រហ័សនៃសកម្មភាព ទីផ្សារក្នុងស្រុកសំរាប់ផលិតផលផលិតកម្មនានា។ កំលាំងបន្ថែមនៃវិស័យកសិកម្ម ប្រហែលជាអាចលើកទឹកចិត្ត

អោយមានវិនិយោគទុនពីបរទេស ដែលពេលនេះប្រទេសកម្ពុជានៅ ខ្វះខាតនៅឡើយ ហើយមួយវិញទៀត វាជាផ្នែកមួយដោយសារថាប្រជាជនជាង ១៣ លាននាក់ មិនបានផ្តល់អោយមានប្រសិទ្ធភាព ទីផ្សារក្នុងស្រុកធំធេងបានទេ។

២១. ការចូលជាសមាជិកអង្គការ WTO ផ្តល់ឱកាសសំរាប់ កំណើនទោះបីវាមិនទាន់សមស្របសំរាប់កម្ពុជាក៏ដោយ ប៉ុន្តែការទទួលបាននេះវានឹងទាមទារអោយមានការកែទំរង់ជាច្រើន និងឈានទៅរកការកែទំរង់។ កម្ពុជាមិនអាស្រ័យតែលើវិស័យកាត់ដេរដែលជាក្បាលម៉ាស៊ីននៃ កំណើនដ៏សំខាន់ដោយអវត្តមាននៃការកែលំអសំរាប់ការប្រកួតប្រជែងនោះទេ។ កិច្ចខិតខំប្រឹងប្រែងគួរផ្តោត ទៅលើការលើកកំពស់ការប្រកួតប្រជែង ដើម្បីរារាំងការប៉ះពាល់ពីការធ្លាក់ចុះនៃការរំពឹងក្នុងវិស័យកាត់ដេរ និង លើកទឹកចិត្តអោយមានលក្ខណៈចំរុះ នៃមូលដ្ឋានសំរាប់ការនាំចេញរបស់ខ្លួន។ មានការងារបន្ទាន់មួយដោយសារ តែការលុបចោលប្រព័ន្ធកូតាក្នុង ខែមករា ឆ្នាំ២០០៥ វានឹងបង្ហាញអោយឃើញថាអ្នកនាំចេញនានាពីកម្ពុជា ប្រឈមនឹងការប្រកួតប្រជែង ដោយផ្ទាល់ពីប្រទេសចិន ដែលជាប្រទេសមានតំលៃផលិតដែលគេប៉ាន់ស្មានពី ១៥% ទៅ ៣០ ភាគរយ ទាបជាងកម្ពុជា។ វានឹងត្រូវការពេលវេលាខ្លះមុនពេលការនាំចេញរបស់កម្ពុជាអាចសង្គ្រោះមកវិញ បានទោះបីជាកំណែទំរង់ទាំងអស់ដែលកំណត់បានធ្វើហើយយ៉ាងណាក៏ដោយ។ តំលៃនៃការនាំចេញវិស័យកាត់ដេរ អាចធ្លាក់ចុះ ១២ ភាគរយ នៅឆ្នាំ ២០០៥ ដែលវាប្រហែលជាអាចធ្លាក់ចុះកំណើន GDP នៅក្រោម ២ ភាគរយ។ ទាក់ទង ទៅនឹងអត្រាប្តូរប្រាក់ គឺហាក់ដូចជាមានការប៉ះពាល់តិចតួចទៅលើការប្រកួតប្រជែងនេះដោយសារតំលៃចំណាយចំណូលជាច្រើនរួមទាំងប្រាក់ឈ្នួល គឺអាចទូទាត់ជាដុល្លាអាមេរិកបាន។ ទោះជាយ៉ាងណាក៏ដោយការប៉ះពាល់ជាទូ ទៅលើការកាត់ចេញនៃកូតា លើតារាងតុល្យភាពនៃការចំណាយ អាចតិចតួចដោយសារវត្ថុធាតុដើមនៃវិស័យនេះ ភាគច្រើនគឺនាំចូលពីប្រទេសក្រៅ ហើយផលចំណេញការផ្ទេរប្រាក់ប្រហែលជាធ្លាក់ចុះ។ ប្រទេសកម្ពុជាអាចទទួលផលចំណេញខ្លះប្រសិនបើសហរដ្ឋអាមេរិកជួយផ្តល់សំរាប់ដោះស្រាយបញ្ហានេះ ដូចជាលើការការពារផលិតផលខ្លះ ដែលនាំចូលពីប្រទេសចិន ដែលអាចមានរហូតដល់ឆ្នាំ២០១៣ ឬការការពារពិសេសលើវាយនភ័ណ្ឌ ដែលនឹងផុតអាណត្តិឆ្នាំ ២០០៨។ ទោះជាយ៉ាងណាក៏ដោយវាហាក់ដូចជាមានហានិភ័យខ្ពស់សំរាប់រដ្ឋាភិបាល បើសិនបង្កើតយុទ្ធសាស្ត្រសេដ្ឋកិច្ចរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានមិនច្បាស់លាស់របស់អាមេរិកក្នុងជំរើសទាំងពីរនេះ។ លើសពីនេះការកាត់បន្ថយពន្ធបន្ថែមដោយអាមេរិក ឬក៏ការបន្ធូរបន្ថយនៃច្បាប់ដែលទាមទារដោយ

សហគមន៍អឺរ៉ុប និងកាណាដា អាចធ្វើអោយមានឥទ្ធពលប្រសើរ។

២២. សេនារិយោដ៏ប្រសើរដែលបានរៀបរាប់ខាងលើ គឺអាស្រ័យដោយសន្មតថានឹងមានការអនុវត្តកំណែទំរង់មួយ ដែលមានប្រសិទ្ធភាពលើការកាត់បន្ថយចំណាយ និងលើកកំពស់និរន្តភាពអភិបាលកិច្ច។ ទោះបីជានៅក្រោមទស្សនៈសុទិដ្ឋិនិយមក៏ដោយ កំណើនអាចឈានត្រឹមតែកំរិតគោលដៅយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រប្រចាំឆ្នាំប៉ុណ្ណោះ ដែលមានពី ៦ ទៅ ៧½ ភាគរយ ដល់ឆ្នាំ២០០៩។ នៅក្រោមសេនារិយោនេះ បំណុលសាធារណៈមាន ដល់ទៅ ៧៥ ភាគរយនៃ GDP នាបញ្ចប់ឆ្នាំ ២០០៣ ដែលគេរំពឹងថាអាចមានស្ថេរភាព។ ដោយយើងគិតថា កម្ពុជាអាចទទួលបានការយល់ព្រមអោយមានពេលវេលា ថ្មីក្នុងការសងបំណុលវិញដល់រុស្សី និងអាមេរិកក្នុងលក្ខខណ្ឌ នៃការប្រៀបធៀបទៅលើកិច្ចព្រមព្រៀងក្លិបប៉ារីស នាឆ្នាំ ១៩៩៥ នោះ តំលៃដុលរបស់កម្ពុជា (NPV) នៃ បំណុលសាធារណៈ សំរាប់ចុងបញ្ចប់ឆ្នាំ២០០៤ នេះ និងកាត់បន្ថយ ៣៣ ភាគរយនៃ GDP។ ទោះជាយ៉ាងណាក៏ដោយ NPV នៃបំណុលសាធារណៈ នៅតែមានក្នុងទំហំប្រមាណជា ២៣៥ ភាគរយ នៃចំណូលទាំងអស់ (២៨០ ភាគរយ មិនរាប់បញ្ចូល ជំនួយឥត

កម្ពុជា: សេនារីយោទិន្នន័យ និងមិនប្រែប្រួល

| គិតជាភាគរយនៃ GDP | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|---|---|
| **សេនារីយោទិន្នន័យ** | | | | | | | | |
| កំណើន GDP សរុប(%នៃបំរែបំរួល) | 5.5 | 5.2 | 4.3 | 1.9 | 4.3 | 5.5 | 5.9 | 6.1 |
| មានវិស័យកាត់ដេរ (ជាលានដុល្លា) | 21.0 | 15.0 | 12.0 | -12.0 | -1.0 | 5.8 | 7.2 | 7.2 |
| មានវិស័យកសិកម្ម (ជាលានដុល្លា) | -2.7 | 9.2 | 0.4 | 3.2 | 3.7 | 3.8 | 3.9 | 4.2 |
| ផ្សេងៗ (ជាលានដុល្លា) | 7.9 | 0.4 | 4.9 | 4.9 | 6.0 | 6.4 | 6.8 | 6.9 |
| ចំណូលរដ្ឋាភិបាល | 11.2 | 10.4 | 11.9 | 12.3 | 12.9 | 13.3 | 13.6 | 14.0 |
| ចំណាយចរន្ត មាន | 10.1 | 11.0 | 10.7 | 11.2 | 11.9 | 11.9 | 12.2 | 12.2 |
| ប្រាក់កំរៃ | 3.7 | 3.7 | 3.7 | 3.8 | 4.0 | 4.2 | 4.5 | 4.7 |
| ផ្សេងៗ | 6.3 | 7.3 | 7.0 | 7.4 | 7.9 | 7.7 | 7.7 | 7.5 |
| មានជាអាទិ៍ ចំណាយសង្គម (មិនមែនប្រាក់កំរៃ) | 2.0 | 1.8 | 2.1 | 2.2 | 2.3 | 2.4 | 2.5 | 2.7 |
| ឱនភាពបឋម | 3.6 | 4.3 | 3.2 | 3.1 | 3.1 | 2.7 | 2.5 | 2.1 |
| នាំចេញវិស័យកាត់ដេរ (ជាលានដុល្លា) | 1,338 | 1,607 | 1,794 | 1,587 | 1,590 | 1,699 | 1,839 | 1,991 |
| តុល្យភាពគណនីចរន្ត មិនមែនផ្ទេរសាច់ប្រាក់ផ្លូវការ (ជាលានដុល្លា) | -359 | -429 | -489 | -545 | -565 | -567 | -566 | -567 |
| មូលធនបំរុងទុកអន្តរជាតិ (ជាលានដុល្លា) | 663 | 737 | 782 | 804 | 838 | 886 | 935 | 1,021 |
| **សេនារីយោមិនកែប្រ** | | | | | | | | |
| កំណើន GDP សរុប(%នៃបំរែបំរួល) | 5.5 | 5.2 | 4.3 | 0.9 | 2.7 | 3.1 | 3.4 | 3.7 |
| មានវិស័យកាត់ដេរ (ជាលានដុល្លា) | 21.0 | 15.0 | 12.0 | -15.0 | -5.0 | -2.0 | 0.0 | 3.0 |
| មានវិស័យកសិកម្ម (ជាលានដុល្លា) | -2.7 | 9.2 | 0.4 | 3.2 | 3.3 | 3.1 | 2.7 | 2.7 |
| ផ្សេងៗ (ជាលានដុល្លា) | 7.9 | 0.4 | 4.9 | 4.0 | 4.0 | 4.2 | 4.5 | 4.5 |
| ចំណូលរដ្ឋាភិបាល | 11.2 | 10.4 | 11.1 | 10.9 | 10.9 | 10.9 | 11.0 | 11.0 |
| ចំណាយចរន្ត មាន | 10.1 | 11.0 | 10.3 | 10.0 | 9.9 | 9.9 | 9.9 | 9.9 |
| ប្រាក់កំរៃ | 3.7 | 3.7 | 3.6 | 3.5 | 3.5 | 3.5 | 3.5 | 3.5 |
| ផ្សេងៗ | 6.3 | 7.3 | 6.7 | 6.5 | 6.4 | 6.4 | 6.4 | 6.4 |
| មានជាអាទិ៍ ចំណាយសង្គម (មិនមែនប្រាក់កំរៃ) | 2.0 | 1.8 | 1.9 | 1.9 | 1.9 | 1.9 | 1.9 | 1.9 |
| នភាពបឋម | 3.6 | 4.3 | 3.7 | 3.3 | 3.1 | 3.1 | 2.8 | 2.8 |
| នាំចេញវិស័យកាត់ដេរ (ជាលានដុល្លា) | 1,338 | 1,607 | 1,794 | 1,579 | 1,516 | 1,490 | 1,495 | 1,545 |
| តុល្យភាពគណនីចរន្ត មិនមែនផ្ទេរសាច់ប្រាក់ផ្លូវការ (ជាលានដុល្លា) | -359 | -429 | -489 | -621 | -639 | -647 | -599 | -575 |
| មូលធនបំរុងទុកអន្តរជាតិ (ជាលានដុល្លា) | 663 | 737 | 782 | 728 | 688 | 656 | 672 | 749 |

ប្រភព:Fund staff estimates.

សំណង)។ ការពង្រឹងដ៏សំខាន់បំផុត នោះគឺការខិតខំប្រមូលចំណូល និងធ្វើអោយមានកាកាត់បន្ថយអោយនៅទាបជាង ២០០ ភាគរយ បន្ទាប់ពីឆ្នាំ២០១៣។

២៣. បរាជ័យក្នុងការជំរុញអោយមានការកំណែទំរង់នោះវានឹងកំហិតកំណើនចន្លោះពី ២ - ៤ ភាគរយជារៀងរាល់ឆ្នាំ ក្នុងរយៈពេលមធ្យមនេះ។ ការខ្វះខាតការប្តេជ្ញាខ្ពស់ដើម្បីកែលំអអភិបាលកិច្ច វានឹងរារាំងការលើកកំពស់បរិយាកាសជំនួញ នឹងធ្វើអោយការងើបឡើងវិញពីចំណុចអវិជ្ជមាននៃការលុបចោលកូតាមិនអាចទៅរួច។ ខ្វះការកែលំអជាដុំកំភួនក្នុងការប្រមូលចំណូលរដ្ឋាភិបាល និងពុំមានលទ្ធភាពដើម្បីបំពេញតំរូវការចំណាយអាទិភាពទេ នេះមិននិយាយដល់ការចំណាយ ដើម្បីទទួលគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ផង។ លើសពីនេះ កំណើនរយៈពេល វែងនឹងទទួលរង់គ្រោះប្រសិនបើការកែទំរង់វិស័យកសិកម្មមិនបានបង្កើតឡើង ហើយនឹងមិនអនុវត្តទេនោះ។ នៅក្នុងនេះសេនារិយោ មិនកែប្រែនេះ NPV នៃបំណុលសាធារណៈ និងកើនដល់ប្រមាណ ២៣០ ទៅ ២៥០ ភាគរយ នៃចំណូលសារពើពន្ធ ដែលវានឹងគំរាមកំហែងស្ថេរភាពនៃសារពើពន្ធ។ នៅពេលដែលសេដ្ឋកិច្ចហាក់ដូចមិនមាន វិបត្តិហិរញ្ញវត្ថុ ឬវិបត្តិតារាងតុល្យភាព ប៉ុន្តែខ្វះខាតការកែទំរង់ និងធ្វើអោយយឺតយ៉ាវនៃដំណើរការឈានទៅរកការកាត់បន្ថយភាពក្រីក្រ ពេលនោះអាចនឹងនាំទៅរក ចលាចលសង្គម ។

២៤. ជំពូកបន្ទាប់ នឹងពិនិត្យមើលថាតើអ្វីនឹងអាចយកធ្វើជាមធ្យោបាយនៃការកែលំអនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីនាំយកការកែលំអលើការប្រមើលមើលថវិកាសំរាប់កម្ពុជា ដោយផ្តោតជាពិសេស ផលវិបាកលើអភិបាលកិច្ច ដែលត្រូវដោះស្រាយ។

---

[1] TCAP គឺជាកម្មវិធីជំនួយបច្ចេកទេសរយៈពេលមធ្យមមួយ (២០០១-២០០៤) ដែលមានគោលបំណងសំខាន់លើការពង្រឹងស្ថាប័នម៉ាក្រូសេដ្ឋកិច្ច ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាយកដ្ឋានគយ និងរដ្ឋាករ នាយកដ្ឋានពន្ធរតនាគារជាតិ និង ធនាគារជាតិនៃកម្ពុជា។ ម្ចាស់ជំនួយដែលចូលរួមក្នុង TCAP មានជា អាទិ : IMF ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រសួងអភិវឌ្ឍន៍អន្តរជាតិរបស់ចក្រភពអង់គ្លេស UNDP អង្គការសុខភាពពិភពលោក និងរដ្ឋាភិបាលប្រទេសហូឡង់។

[២] កម្ពុជាជាប្រទេសមួយងាយរងគ្រោះក្នុងចំណោម ប្រទេសដែលមានប្រាក់ចំណូលតិចនៅក្នុងអាស៊ាន ចំពោះការលប់ពេញនូវកូតាកាត់ដេរ ។ សូមមើលជំពូក ២"ស្តីអំពីលទ្ធផលនៃការបញ្ចប់កូតាក្នុងឆ្នាំ២០០៥" ដែលបង្ហាញពីបញ្ហាមួយចំនួន។

# ជំពូកទី ២

## ការបង្កើនគណនេយ្យកិច្ចលើហិរញ្ញវត្ថុសាធារណៈ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ផ្តល់នូវប្រព័ន្ធមួយដែលនាំឱ្យអ្នកធ្វើគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង អ្នកគ្រប់គ្រង មានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ដោយមានខ្ទង់ថវិការដ្ឋជាឧបករណ៍គោល សំរាប់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការប្រមូលធនធាន និងគោលនយោបាយចំណាយ ព្រមទាំងតាមរយៈការគ្រប់គ្រងចំណាយ ។ តែទោះជាយ៉ាងណាក៏ដោយ ពេលអនុវត្តជាក់ស្តែង ខ្ទង់ថវិកា មិនបានបំពេញតាមតួនាទីជាគន្លឹះនោះទេ ។ ធនធានមិនបានទៅដល់អ្នកដែលត្រូវទទួលទេ។ ភាពទន់ខ្សោយនៃសង្វាក់នៃការទទួលខុសត្រូវ (គណនេយ្យភាព) ធ្វើអោយទន់ខ្សោយខាងផ្នែកអភិបាលកិច្ច ដែលបន្ទុចបង្អាក់ដល់លទ្ធភាពរបស់ខ្ទង់ថវិការសំរាប់ការកាត់បន្ថយភាពក្រីក្រ ។ សភាជាតិ មិនបានធ្វើការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាពទៅលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនោះទេ ក្នុងខណៈដែលប្រជាពលរដ្ឋខ្វះយន្តការប្រកបដោយប្រសិទ្ធិភាពដើម្បីទាមទារអោយមានតួនាទីនេះ ។ ធនធានមិនគ្រប់គ្រាន់នាំអោយសេវាសាធារណៈប្រឈមនឹងសមត្ថភាពទាបក្នុងការបំរើការងារ ហើយខ្លាំងខាងការលើកទឹកចិត្តដល់ការបង្វែរថវិការទៅធ្វើអ្វីផ្សេងៗទៀត ។ ភាពខ្សោយនៃការគ្រប់គ្រងខាងក្នុង និង ខាងក្រៅនេះ នាំទៅដល់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ ដែលអាចមាន និង កំពុងតែមានការរំលោភ បំពាន ។

២. កម្ពុជាមានការរីកចំរើនមួយចំនួនក្នុងការកែទំរង់ប្រពន្ធ័គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ក៏ប៉ុន្តែការនាំមុខលើគោលការណ៍ទាំងបួនរបស់សារពើពន្ធ ការជឿទុកចិត្តថាថវិកាចាយវាយចំគោលដៅ **(fiduciary)** និង ភាពប្រឈមខាងស្ថាប័ន ត្រូវតែជំនះអោយបាន ដើម្បីអនុវត្តរបៀបវារៈអភិវឌ្ឍន៍ ។ ទី១ កម្ពុជាចាំបាច់ត្រូវពង្រឹងការប្រមូលធនធាន ដើម្បីធានានិរន្តរភាពសារពើពន្ធ។ រដ្ឋាភិបាល មានផែនការ ប្រមូលប្រាក់ចំណូលអោយបានដល់ប្រមាណ ១៤ ភាគរយ នៃផលិតផលសរុបក្នុងស្រុក ត្រឹមឆ្នាំ ២០០៩ ។ ការនេះតម្រូវអោយមានរដ្ឋបាលពន្ធដារ រឹងមាំក្នុងពេលដ៏ខ្លីនិងមធ្យម និងគោលនយោបាយពន្ធដាររឹងមាំ ក្នុងរយៈពេលមធ្យមនិងយូរអង្វែង។ ការរីកចំរើននឹងអាស្រ័យលើការបង្កើតប្រព័ន្ធផ្តល់រង្វាន់ អនុលោមតាមស្នាដៃនិងគុណសម្បត្តិ នៅតាមភ្នាក់ងារប្រមូលថវិការចំណូលរដ្ឋទាំងឡាយ ហើយនឹង ដោះស្រាយ វប្បធម៌នៃការមិនអនុវត្តតាមតាមរយៈការពង្រឹងតម្លាភាពលើរដ្ឋបាលពន្ធដារ។ ទីពីរ ដើម្បីកាត់បន្ថយភាពប្រថុយប្រថាន

ទាំងឡាយនៃការជឿទុកចិត្តថាថវិកាចាយវាយចំគោលដៅ លើមូលនិធិសាធារណៈ រដ្ឋាភិបាលត្រូវ ប្រឡូកនឹងការកែទំរង់ដ៏ពេញលេញលើផ្នែកអនុវត្តថវិកា ការគ្រប់គ្រងសាច់ប្រាក់ និង ប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុសាធារណៈ ។ រដ្ឋាភិបាលបានប្តេជ្ញាធ្វើការកែទំរង់ទាំងនេះ ជាផ្នែកមួយនៃកម្មវិធីកែទំរង់ការគ្រង់គ្រងហិរញ្ញវត្ថុរបស់ខ្លួន ដូចដែលបានគាំទ្រដោយនាយករដ្ឋមន្ត្រី ។ លើសពីនេះទៀត ការខិតខំនឹងត្រូវធ្វើឡើងដើម្បីពង្រឹងតួនាទីរបស់រដ្ឋសភាក្នុងការត្រួតពិនិត្យថវិការ ដើម្បីជំរុញអោយមានតម្លាភាពក្នុងដំណើរការថវិកា និងពង្រឹងភ្នាក់ងារត្រួតពិនិត្យជាតិដែលទើបតែបង្កើតថ្មី ។ ទីបី ទោះបីជាមានការរីកចំរើនគួរអោយកត់សំគាល់ក្នុងការចំណាយលើវិស័យសង្គមកិច្ចសំខាន់ៗសំរាប់អ្នកក្រក៏ដោយ ក៏ការបរាជ័យខាងអភិបាលកិច្ចរារាំង មិនអោយអ្នកក្រទទួលផលប្រយោជពេញលេញ ពីការធ្វើសនិទានកម្មលើការចំណាយនេះនៅឡើយ ។ ទំនាក់ទនងនឹង គណនេយ្យកិច្ច នឹងត្រូវតែពង្រឹងរវាង អ្នកផ្តល់សេវានិងអ្នកទទួលផល។ នៅចំនុចចុងក្រោយ កម្ពុជានឹងត្រូវចាប់ធ្វើការកែទំរង់មន្ត្រីរាជការ ដោយផ្តោតបែបជំរើសលើស្ថាប័នភាវូបនីយកម្ម ប្រពន្ធ័ការងារ និងការផ្តល់បៀវត្សតាមគុណសម្បត្តិ ដើម្បីផ្តល់សេវា កាត់បន្ថយភាពក្រីក្រ ។

៣. កម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរដ្ឋាភិបាលបានរៀបចំឡើង ហើយមានដៃគូអភិវឌ្ឍន៍របស់កម្ពុជាចំនួន ១០ បានគាំទ្រ អាចចាប់ផ្តើមដោះស្រាយបញ្ហាទាំងនោះ ។ ដោយមានការប្តេជ្ញាខ្ពស់ពីម្ចាស់ជំនួយ ដើម្បីជួយដល់កម្មវិធីនេះ ការផ្តល់នូវជោគជ័យដ៏ឆាប់រហ័យមួយចំនួន អាចជួយផ្តល់នូវថាមពល ក្នុងការធ្វើការកែទំរង់លើផ្នែកគ្រប់គ្រងធំៗខាងដំណើរការថវិការរបស់រដ្ឋាភិបាល ។

# ជំពូក 2 : *ការបង្កើនការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុសាធារណៈ*[១]

៤. ការពង្រឹងការទទួលខុសត្រូវហិរញ្ញវត្ថុសាធារណៈ គឺជាស្នូលនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។ ប្រព័ន្ធបំពេញមុខងារដ៏ល្អមួយសំរាប់ការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ជាតិគឺបង្កើនបែងចែក និង ចំណាយធនធានគ្រប់គ្រាន់ សំរាប់កម្មវិធីដែលពង្រឹងមូលធនមនុស្សនៃពលរដ្ឋក្រីក្រ សំរាប់ការពារសុវត្ថិភាពរាងកាយ របស់ពួកគេនិងធានាអោយមានហេដ្ឋារចនាសម្ព័ន្ធសាធារណៈគ្រប់គ្រាន់ ដើម្បីលើកស្ទួយកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ការទទួលខុសត្រូវចំពោះធនធាន ការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ គឺស្ថិតនៅក្នុងកណ្តាប់ដៃរបស់ពលរដ្ឋកម្ពុជាផ្ទាល់។ តាមទ្រឹស្តី ក្របខ័ណ្ឌច្បាប់ចែងអំពីប្រព័ន្ធមួយដែលតំរូវអោយអ្នកបង្កើតគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងអ្នកគ្រប់គ្រង ទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ។ រដ្ឋធម្មនុញ្ញឆ្នាំ 1993/1999 (មាត្រា 90 និង 113 ) ចែងថា អ្នកតំណាងអោយប្រជាជនកម្ពុជាដែលត្រូវបានបោះឆ្នោតជ្រើសតាំង និងតែងតាំងមានតំណែងនៅក្នុងព្រឹទ្ធសភា និងរដ្ឋសភា មានសិទ្ធិ "អនុម័តថវិកាជាតិ" ។ រដ្ឋធម្មនុញ្ញ (មាត្រា 57) ក៏បានចែងផងដែរថា "ការប្រមូលពន្ធត្រូវអនុលោមតាមច្បាប់" ហើយ "ថវិកាជាតិត្រូវកំនត់ដោយច្បាប់ " (ច្បាប់ហិរញ្ញវត្ថុសាធារណៈកម្ពុជា ការិយាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ឆ្នាំ ២០០០)។ រដ្ឋាភិបាល "កំណត់អាទិភាពជាតិ" ដែលត្រូវការ ថវិកាសំរាប់ដោះស្រាយ។ បន្ទាប់មកក្រុមប្រឹក្សារដ្ឋមន្ត្រីអនុម័តសារាចរលើការចំណាយសំរាប់អោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុប្រើប្រាស់ដើម្បីរៀបចំថវិកា (ច្បាប់ថវិកា ឆ្នាំ ១៩៩៣) ។ រាជរដ្ឋាភិបាលផ្តល់សមត្ថកិច្ច និងផ្តល់ធនធានដល់ក្រសួងពាក់ព័ន្ធមួយចំនួន ដែលនៅក្រោមការណែនាំរបស់ក្រសួងនានានៅថ្នាក់កណ្តាលក្នុងការផ្តល់ទំនិញ និងសេវាតាមការកំណត់នៅក្នុងថវិកា ។ ដូចនេះ ថវិកាគឺជាមធ្យោបាយសំខាន់ សំរាប់ការកាត់បន្ថយភាពក្រីក្រតាមរយៈការកៀងគរធនធាន និងតាមរយៈគោល នយោបាយលើការចំណាយ ហើយនិងតាមរយៈការគ្រប់គ្រង។

៥. ប៉ុន្តែភស្តុតាងមួយចំនួនបានបញ្ជាក់ថា ថវិកានេះមិនបានបំពេញតាមតួនាទីសំខាន់របស់ខ្លួនទេ។ ធនធាន មិនត្រូវបានបញ្ជូនទៅដល់អ្នកដែលគួរទទួលផលប្រយោជន៍ឡើយ។ មូលហេតុសំខាន់នោះ គឺការកាត់ផ្តាច់ខ្សែសង្វាក់នៃការទទួលខុសត្រូវ បង្កើតអោយមាន "ភាពបរាជ័យនៅក្នុងអភិបាលកិច្ច" ដែលធ្វើអោយប៉ះពាល់ដល់លទ្ធភាពនៃថវិកាក្នុងការកាត់បន្ថយភាពក្រីក្រ។ ជំពូកនេះពិនិត្យឡើងវិញនូវព្រឹត្តិការណ៍ថ្មីៗ

របស់ប្រទេសកម្ពុជា ក្នុងការបង្កើនបែងចែក និង ការប្រើប្រាស់ធនធានសំរាប់ការកាត់បន្ថយភាពក្រីក្រ ដោយគិតដល់ក្របខ័ណ្ឌទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ-អ្នកបង្កើត គោលនយោបាយ-និងមន្ត្រីរាជការ។ ក្របខ័ណ្ឌនេះ ត្រូវបានអនុវត្តចំពោះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) និងកំណែទំរង់មុខងារសាធារណៈ បង្ហាញអោយឃើញច្បាស់នូវចំណុចខ្សោយធ្ងន់ធ្ងរមួយចំនួននៅក្នុងការអនុវត្ត។ រដ្ឋសភាជាតិមិនបានត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទេ ហើយប្រជាពលរដ្ឋគ្មានយន្តការដែលមានប្រសិទ្ធភាពណាមួយដើម្បីទាមទារការត្រួតពិនិត្យបែបនោះឡើយ។ អ្នកបង្កើតគោលនយោបាយផ្តល់នូវកំរិតនៃធនធានមិនគ្រប់គ្រាន់ រួមមានការផ្តល់ប្រាក់ខែមិនសមស្របអោយអ្នកផ្តល់សេវាតាមរយៈថវិកា។ មូលហេតុមួយផ្នែក គឺបណ្តាលមកពីចំណូលទាប។ អាស្រ័យហេតុនេះ ចំណូលមានកំរិតទាប ដោយសារមូលហេតុមួយផ្នែក គឺអ្នកបង់ពន្ធ មិនចង់បង់ពន្ធសំរាប់សេវាដែលខ្វះគុណភាព ហើយអ្នកបង់ពន្ធបានជួបប្រទះផលវិបាកតិចតួចដែលបណ្តាលមកពីការមិនបង់ពន្ធ។ ធនធានមិនគ្រប់គ្រាន់ធ្វើអោយមន្ត្រីរាជការខ្វះសមត្ថភាពក្នុងការផ្តល់សេវា និងជាកត្តាជំរុញអោយបង្វែរទិសមូលនិធិសំរាប់ការប្រើប្រាស់លើកិច្ចការដទៃ ដែលបង្កការលំបាកដល់ខ្សែសង្វាក់រវាងផ្នែកសាធារណៈ និងផ្នែកឯកជន។ ការត្រួតពិនិត្យផ្ទៃក្នុង និងផ្ទៃក្រៅដែលមានលក្ខណៈទន់ខ្សោយ នាំអោយមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដែលអាចនិងពិតជាមានការរំលោភបំពាន។ ទាំងអស់នេះមានន័យថា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្ថិតនៅឆ្ងាយ ពីគោលបំណងរំពឹងទុកនៅក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។

៦. ក្នុងពេលដែលមានការរីកចំរើនខ្លះៗកាលពីពេលថ្មីៗកន្លងទៅលើកំណែទំរង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រទេសកម្ពុជាត្រូវបង្កើតអោយមានការរីកចំរើនជាច្រើនបន្ថែមទៀតលើបញ្ហាប្រឈមចំបងបួនលើផ្នែកសារពើពន្ធ ជំនឿទុកចិត្ត និងផ្នែកស្ថាប័ន ដើម្បីអនុវត្តគំរោងអភិវឌ្ឍន៍របស់ខ្លួន។ ទីមួយ ប្រទេសកម្ពុជាចាំបាច់ត្រូវកែលំអលើការកៀងគរធនធាន ដើម្បីធានាអោយបាននូវនិរន្តរភាពនៃសារពើពន្ធជារួម។ ទីពីរ ដើម្បីកាត់បន្ថយហានិភ័យនូវភាព មិនទុកចិត្តចំពោះមូលនិធិសាធារណៈ។ រដ្ឋាភិបាលចាំបាច់ត្រូវចូលរួមនៅក្នុងកំណែទំរង់ពេញលេញនៃការអនុវត្តន៍ថវិកា ការគ្រប់គ្រងសាច់ប្រាក់ និងប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុសាធារណៈ។ ទីបី រដ្ឋាភិបាលចាំបាច់ត្រូវធ្វើសនិទានកម្មលើ គោលនយោបាយចំណាយសាធារណៈ ដើម្បីសំរេចតាមគោលដៅដែលរដ្ឋាភិបាលបានកំនត់នៅក្នុងយុទ្ធសាស្ត្រកំរិតជាតិ

ផ្សេងៗ[២] ។ រដ្ឋាភិបាលបានប្តេជ្ញាធ្វើកំណែទំរង់ទាំងនេះ ធ្វើជាផ្នែកមួយនៃកម្មវិធីកំណែទំរង់ PFM របស់ខ្លួន ដែល នាយករដ្ឋមន្ត្រីបានឯកភាព ។

៧. ចុងក្រោយប្រទេសកម្ពុជាចាំបាច់ត្រូវធ្វើកំណែទំរង់មុខងារសាធារណៈ ដោយផ្តោតទៅលើការបង្កើតប្រព័ន្ធផ្តល់លាភការ និងផ្តល់ការងារដែលផ្អែកលើគុណសម្បត្តិការងារមួយចំនួន ដើម្បីផ្តល់សេវាកាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែ ទោះជា យ៉ាងនេះក្តី ផែនការនិងយុទ្ធសាស្ត្រដែលអាចជឿទុកចិត្តបានក្នុងការដោះស្រាយបញ្ហាទាំងនោះ នៅមិនទាន់បានចាប់ដំណើរការនៅឡើយទេ។ ផ្នែកខាងក្រោមនេះ អធិប្បាយពិស្តារអំពីបញ្ហាប្រឈមសំខាន់ទាំងបួន និងផ្តល់នូវសំណើ នៃសេចក្តីព្រាងដំណោះស្រាយ ។

## ក. ការលើកកំពស់ការកៀងគរធនធាន

៨. ទោះបីមានតំរូវការអោយមានប្រាក់ចំណូលខ្ពស់សំរាប់ផ្តល់ហិរញ្ញប្បទានកំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់ហិរញ្ញវត្ថុអោយបានគ្រប់គ្រាន់សំរាប់សេវារបស់រដ្ឋាភិបាលធៀបនឹងបណ្តាប្រទេសកសិកម្មដែលមានប្រាក់ចំណូលទាបក្តី អត្រាប្រាក់ចំណូលសារពើពន្ធរបស់កម្ពុជា ពិសេសប្រាក់ចំណូលពន្ធនៅតែមានកំរិតទាបជាងគេបំផុតនៅក្នុងពិភពលោក។ ជាការពិត ប្រសិនបើគ្មានកំណើនច្រើនចំពោះប្រាក់ចំណូលទេ នោះនឹងមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ចំពោះកម្មវិធីកាត់បន្ថយភាពក្រីក្រ រយៈពេលមធ្យមរបស់កម្ពុជា។

៩. ផ្អែកលើមរតកនៃកិច្ចប្រឹងប្រែងរកចំណូលដែលមានកង្វះខាតយ៉ាងធ្ងន់ធ្ងរ ដើម្បីអោយមានភាពប្រាកដប្រជា រាជរដ្ឋាភិបាលបានធ្វើអោយមានការរីកចំរើននៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ជាលទ្ធផលនៃកិច្ចប្រឹងប្រែងកំណែទំរង់ និងឥណទានរបស់រដ្ឋាភិបាល ប្រាក់ចំណូលបានកើន ពី 10.2 ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅក្នុងឆ្នាំ 1999 ទៅ 11.2 ភាគរយ នៅក្នុងឆ្នាំ 2002 ប៉ុន្តែធ្លាក់ចុះមកត្រឹម 10.4 ភាគរយ នៅឆ្នាំ 2003 ។ ការធ្លាក់ចុះនេះគឺបណ្តាលមក ពីកត្តាខាងក្រៅ (ការរីករាលដាលនៃជំងឺរលាកផ្លូវដង្ហើមដ៏ធ្ងន់ធ្ងរ (SARS) និងកុបកម្មប្រឆាំងនឹងជនជាតិថៃ និង ការបោះឆ្នោត) រួមជាមួយនឹងផលប៉ះពាល់បន្តបន្ទាប់នៃភាពខ្វះចន្លោះនៅក្នុងប្រព័ន្ធ។ ជារួម ស្ថិតក្នុងភាពបន្ទាន់នៃការបង្កើនប្រាក់ចំណូល

រដ្ឋាភិបាលបានឆ្លើយតបដោយបង្កើតកម្មវិធីកំណែទំរង់ដែលបង្កើតលទ្ធផល ទោះបីជាមិនបានសំរេចទាំងស្រុងក៏ដោយ ក៏បានផ្តល់នូវមូលដ្ឋានគ្រឹះសំរាប់កំណែទំរង់បង្កើតប្រាក់ចំណូលថ្មីៗទៀតដែរ ។

១០. ជាការពិតណាស់ថា ការកែលំអជាបន្តបន្ទាប់នឹងជួបការលំបាកកាន់តែច្រើន ដោយសារតែក្តីរំពឹងអំពីការរីកចំរើនថយចុះ ។ រដ្ឋាភិបាលមានផែនការបង្កើនប្រាក់ចំណូលដល់ 14 ភាគរយ នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2009[៣] ។ ការលើកកំពស់ការកៀរគរធនធានក្នុងស្រុក ចាំបាច់ត្រូវពឹងផ្អែកលើរដ្ឋបាលពន្ធដែលបានកែលំអក្នុងរយៈពេលខ្លីទៅរយៈពេលមធ្យម និងការកែលំអគោលនយោបាយពន្ធដារសំរាប់រយៈពេលមធ្យមទៅរយៈពេលវែង ។ តាមបទពិសោធន៍ថ្មីៗនេះបានអោយដឹងថា ដើម្បីអោយការកែលំអរដ្ឋបាលពន្ធមាននិរន្តភាព ចាំបាច់ត្រូវចាប់ផ្តើមពីឫសគល់នៃបញ្ហា ។ ផ្លូវដែលរដ្ឋាភិបាលបានជ្រើសរើសនៅក្នុងកម្មវិធី PFM គឺដើម្បីបង្កើតប្រព័ន្ធលាភការលើសមត្ថភាព លើលទ្ធផលអនុវត្តន៍នៅតាមនាយកដ្ឋានមួយចំនួន ។ ចាំបាច់ត្រូវមានការកែលំអរដ្ឋបាលពន្ធដែលប្រឈមមុខជាមួយវប្បធម៌របស់កម្ពុជាស្តីពីការមិនគោរពតាម ដែលវដ្តអវិជ្ជមាននៃភាពមិនគោរពរបស់អ្នកបង់ពន្ធផ្តល់ឱកាសអោយមានរដ្ឋបាលមិនល្អ និងមានអំពើពុករលួយ ព្រមទាំងមានការផ្តល់សេវាមិនគ្រប់គ្រាន់ ។ ដូចនេះ ការរីកចំរើនអាស្រ័យលើការដោះស្រាយបញ្ហាប្រឈមស្តីពីអភិបាលកិច្ច ក្នុងនោះរួមមានការបង្កើនតម្លាភាពផងដែរ ។ ការកែលំអនៅក្នុងការទទួលខុសត្រូវ ក៏មានប្រភពមកពីការកាត់បន្ថយការពឹងផ្អែកលើជំនួយបរទេស និងបង្កើនការពឹងផ្អែកលើប្រជាពលរដ្ឋកម្ពុជា ក៏ដូចជាពឹងផ្អែកលើបណ្តាក្រុមហ៊ុនដែលកំពុងដំណើរការនៅក្នុងប្រទេសកម្ពុជាផងដែរ ។

១១. ជាមួយគ្នានេះដែរ ការប្រមូលប្រាក់ចំណូលមិនមែនពន្ធ ក៏ជាផ្នែកមួយដែលមានបញ្ហាប្រឈមយ៉ាងច្រើនចំពោះអភិបាលកិច្ចផងដែរ ។ ជាពិសេសចំពោះការជួលទ្រព្យសម្បត្តិរដ្ឋទៅអោយផ្នែកឯកជន និងការងារលទ្ធកម្មពាក់ព័ន្ធនឹងការផ្តល់កិច្ចសន្យា ។ វិធានការដើម្បីកែលំអតម្លាភាព អាចជួយកាត់បន្ថយការធ្លាក់ចុះក្នុងពេលអនាគត លើមុខចំណូលមិនមែនពន្ធមួយចំនួន ។ ក្រៅពីនេះ ប្រាក់ចំណូលពីកិច្ចសន្យាជួលនានាអាចកើនឡើងតាមរយៈការកែលំអការតាមដានការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងតាមរយៈសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋដែលកំពុងដំណើរការ ។

## ខ. ការរៀបចំចំណាយសាធារណៈចំពោះការកាត់បន្ថយភាពក្រីក្រ

១២. ចាប់តាំងពីឆ្នាំ ១៩៩៨ មក រដ្ឋាភិបាលបានធ្វើការកែលំអយ៉ាងច្រើនលើការរៀបចំធនធាន ជាមួយនឹងគោលដៅអភិវឌ្ឍន៍ ដោយការបង្កើនវិភាជន៍សំរាប់វិស័យអាទិភាព ដូចជា វិស័យអប់រំ និង សុខាភិបាល។ ចំណាយរបស់រដ្ឋាភិបាលលើវិស័យអាទិភាពបានកើនពី ១.៤ ភាគរយ នៃផលិតផលក្នុងស្រុក សរុបនៅឆ្នាំ ១៩៩៨ ទៅ ៣.២ ភាគរយ នៅឆ្នាំ ២០០១។ ជាងនេះទៅទៀត យុទ្ធសាស្ត្រជាតិកាត់បន្ថយ ភាពក្រីក្រ (NPRS) បញ្ជាក់ថា រាជរដ្ឋាភិបាលមានគោលបំណងបន្តយុទ្ធសាស្ត្រ ដោយបង្ហាញគោលដៅ ប៉ងប្រាថ្នាជាខ្លាំងក្នុងការបង្កើនចំណាយចំពោះវិស័យអាទិភាពដល់ឆ្នាំ ២០០៥ ។

១៣. ប៉ុន្តែតាមរយៈកំណើនបច្ចុប្បន្ន លទ្ធភាពក្នុងការបែងចែកឡើងវិញបន្តទៀតនឹងមានកំរិត លទ្ធភាព នេះ អាស្រ័យលើកំណើនប្រាក់ចំណូល។ តាមពិត ការបែងចែកឡើងវិញក្នុងកំឡុងឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៣ កើតឡើងក្នុងន័យធៀប ដែលជាទូទៅមានន័យថា ថវិការបស់ក្រសួងភាគច្រើនបានកើនឡើង តាមន័យនាមនាម។ មានតែស្ថាប័ន ប្រាំប៉ុណ្ណោះ ដែលត្រូវបានកាត់បន្ថយថវិកាក្នុងកំឡុងឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០១។ ដើម្បីអនុវត្តផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ចសង្គមកិច្ចលើកទីពីរ (SEDP II) /NPRS និង ដើម្បីសំរេចបានតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) រដ្ឋាភិបាលចាំបាច់ត្រូវបែងចែក ធនធានចេញពីកម្មវិធី និងវិស័យមិនមែនអាទិភាព។

១៤. លើសពីនេះទៅទៀត សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចបង្ហាញថា ផលប៉ះពាល់នៃការបែងចែក ទាំងនេះ ចំពោះវិស័យសង្គមកិច្ចមិនត្រូវបានបង្ហាញឱ្យឃើញឡើយ។ គោលនយោបាយចំណាយអាចចូលរួម ក្នុងការកាត់បន្ថយភាពក្រីក្រកន្លងមក អាស្រ័យលើស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងចំណាយ របស់ប្រទេសកម្ពុជា។ ដើម្បីឈានដល់គោលដៅការកាត់បន្ថយភាពក្រីក្រដែលបានកំណត់ ចាំបាច់ត្រូវធ្វើ អោយប្រសើរឡើងនូវប្រសិទ្ធភាពនៃការចំណាយ ដោយផ្សាភ្ជាប់វាយ៉ាងជិតស្និទ្ធទៅនឹងលទ្ធផលជា អាទិភាព និងដោយពង្រឹងយន្តការនៃការទទួលខុសត្រូវ ។ ការបង្កើនប្រសិទ្ធភាពអាចសំរេចបាន ដោយធ្វើ អោយប្រសើរឡើងនូវការកំណត់គោលដៅធនធានដែលជួយគាំទ្រដល់ជនក្រីក្រ តាមរយៈ ផែនការនិង ថវិកានៃផ្នែកដែលជាប់ទាក់ទងគ្នាយ៉ាងស្អិតរមួត ។ នៅក្នុងដំណើរការធ្វើផែនការនៅក្នុងលើវិស័យអប់រំ និងសុខាភិបាលបានមានភាពល្អប្រសើរ ហើយមានទំនាក់ទំនងជិតស្និទ្ធជាមួយការកសាងផែនការ និងការ

រៀបចំថវិកា ដែលធ្វើអោយមានការកែលំអចំពោះការផ្តល់អាទិភាពលើការចំណាយ។ កសិកម្ម និងការដឹកជញ្ជូនជើងគោកនៅមិនទាន់រីកចំរើនបែបនេះនៅឡើយទេ ទោះបីជាកិច្ចការនេះមានសារៈសំខាន់ក្នុងការផ្តល់មូលដ្ឋានគ្រឹះប្រសិទ្ធភាពបែងចែកតាមរយៈការដឹកនាំធនធានបន្ថែមទៀតទៅកាន់វិស័យសេដ្ឋកិច្ចក្តី ។

១៥. ការចំណាយត្រូវបានផ្តោតទៅលើពលរដ្ឋក្រីក្រនៅក្នុងវិស័យអប់រំ និងចំណាយតិចតួចនៅក្នុងវិស័យសុខាភិបាល និងកាន់តែតិចសំរាប់វិស័យកសិកម្ម។ ចំណាយសាធារណៈដែលពាក់ព័ន្ធនឹងការអប់រំត្រូវបានរំពឹងថានឹងផ្តល់អត្ថប្រយោជន៍ កាន់តែច្រើនចំពោះពលរដ្ឋក្រីក្រនៅឆ្នាំ ២០០២ ប្រៀបធៀបនឹងឆ្នាំ ១៩៩៧ (មើលតារាង ២.១)។ នៅឆ្នាំ ២០០២ គេបានប៉ាន់ស្មានថា ពលរដ្ឋក្រីក្របំផុតចំនួន ៤០ ភាគរយ នៃចំនួនប្រជាជនសរុប ទទួលបាន ៣៩ ភាគរយ នៃចំណាយអប់រំសរុប ហើយទទួលបាន ៥០ ភាគរយ នៅកំរិតបឋមសិក្សា។

**តារាង 2.1៖ ភាគនៃឧបត្ថម្ភកធនផ្នែកអប់រំដែលទទួលបានតាម ចំណែកប្រាក់ចំណូល** (ចំណាយរបស់រដ្ឋាភិបាល)

| *ចំណែក* | *I* | *II* | *III* | *IV* | *V* | |
|---|---|---|---|---|---|---|
| **%នៃឧបត្ថម្ភកធនសាធារណៈដោយប្រើចំណែកនៃការចុះឈ្មោះ** | | | | | | |
| បឋមសិក្សា | 21% | 21% | 21% | 20% | 17% | 100% |
| មធ្យមសិក្សាបឋមភូមិ | 8% | 12% | 19% | 23% | 38% | 100% |
| មធ្យមសិក្សាទុតិយភូមិ | 4% | 4% | 14% | 21% | 56% | 100% |
| ក្រោយមធ្យមសិក្សា | 2% | 0% | 6% | 15% | 76% | 100% |
| *ភាគរយនៃឧបត្ថម្ភកធនរបស់រដ្ឋាភិបាលដែលបានទទួល ការប៉ាន់ស្មានឆ្នាំ* 2002 | | | | | | |
| សរុប | 19% | 20% | 19% | 19% | 23% | 100% |
| បឋមសិក្សា | 25% | 25% | 21% | 17% | 12% | 100% |
| មធ្យមសិក្សាបឋមភូមិ | 11% | 14% | 19% | 22% | 34% | 100% |
| មធ្យមសិក្សាទុតិយភូមិ | 7% | 7% | 13% | 26% | 46% | 100% |
| ក្រោយមធ្យមសិក្សា | 1% | 0% | 12% | 22% | 65% | 100% |

***ប្រភព៖*** ***IFAPER***, 2003.

១៦. ម្យ៉ាងវិញទៀត នៅក្នុងវិស័យសុខាភិបាល ក្រុមដែលមានប្រាក់ចំណូលទាបបំផុតប្រើប្រាស់ត្រឹមចំនួន ១៣ ភាគរយនៃធនធាន ផ្ទុយទៅវិញក្រុមដែលមានប្រាក់ចំណូលច្រើនជាងគេប្រើប្រាស់ធនធានចំនួន ២០ ភាគរយ (រូបទី ២.១)។ វិសមភាព នៃរបាយធនធានអាចមើលឃើញយ៉ាងជាក់ច្បាស់ចំពោះការប្រើប្រាស់មធ្យោបាយរូបវិន្តរបស់ជាតិ ។ ផ្ទុយទៅវិញមន្ទីរពេទ្យស្រុកទំនងជាផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដំផុតដល់ក្រុមពលរដ្ឋក្រីក្របំផុត។ ដំណើរនៃការរៀបចំថវិកា (និងការអនុវត្ត) ចាំបាច់ត្រូវបែងចែកឡើងវិញដល់ឫសគល់នូវធនធានសុខាភិបាលឆ្ពោះទៅរកការផ្តល់លាភការមិនស្ថិតនៅក្រុងភ្នំពេញ និងសំដៅបែងចែកដល់សេវាខេត្ត-ស្រុក ដើម្បីអោយមានឥទ្ធិពលជាក់ស្តែងលើគោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សរ៍ (MDGs) ចំពោះសុខភាពកុមារ និងសុខភាពមាតា។

១៧. អាស្រ័យហេតុនេះភាពក្រខ្សត់នៃធនធាន តំរូវអោយមានការធ្វើសនិទានកម្មលើការចំណាយជាអាទិភាពមួយខ្ពស់។ មានលទ្ធភាពមួយចំនួនស្តីពីការធ្វើសនិទានកម្មនៃការចំណាយ: (ក) ការកាត់បន្ថយចំណាយនៅក្នុងវិស័យមិនសូវមាន អាទិភាព (ខ) ការបង្កើតប្រាក់សន្សំបន្ថែមពីការកែសំរួលចំណាយស្ថាប័នរួមទាំងការពង្រឹងរចនាសម្ព័ន្ធ រដ្ឋបាល និង (គ) ការកែសំរួលចំណាយប្រតិបត្តិការដោយការបន្ថយចំណាយរដ្ឋបាលផ្សេងៗ ដោយបង្កើនចំណាយលើ ការថែទាំ និងបញ្ជី ប្រាក់បៀវត្សរ៍។

*រូបទី 2.1 ការទទួលអត្ថប្រយោជន៍ផ្នែកសុខភាពពីក្រុមប្រជាពលរដ្ឋដែលមានប្រាក់ចំណូលខុសៗគ្នា*




*ប្រភព: IFAPER, 2003*

១៨. ដៃគូអភិវឌ្ឍន៍ក៏រួមចំណែកទទួលខុសត្រូវផងដែរចំពោះការបែងចែកធនធាន។ គេឃើញមានការប្តូរបន្តិចម្តងៗ នូវសមាសភាពផ្នែកមុខងាររបស់ជំនួយបរទេស ទោះបីជាគ្មាននិន្នាការកត់សំគាល់ឆ្ពោះទៅកាន់វិស័យអាទិភាពរបស់រដ្ឋាភិបាលក្តី ។ ទន្ទឹមជាមួយគ្នានេះ កញ្ចប់ជំនួយបរទេសរបស់កម្ពុជាផ្តោតយ៉ាងធ្ងន់ទៅលើជំនួយបច្ចេកទេស ។ ការចំណាយលើជំនួយបច្ចេកទេស គិតទាំងចំណាយបុគ្គលិក និង ចំណាយបណ្តុះបណ្តាល និងចំណាយប្រតិបត្តិការពាក់ព័ន្ធមានកំរិត ប្រមាណជា ៤៥ ភាគរយ នៃកញ្ចប់ទឹកប្រាក់នៃគំរោងជំនួយបទេស ដោយរួមមានជំនួយផ្នែកមនុស្សធម៌ផងដែរ ។ លើមូលដ្ឋាននេះ ការចំណាយលើជំនួយបច្ចេកទេសមានចំនួនពីពីរទៅបីដងនៃចំណាយរបស់រដ្ឋាភិបាលលើបញ្ជីប្រាក់ខែមន្ត្រីរាជការស៊ីវិល។ នៅខណៈដែលវិភាគទានជំនួយបច្ចេកទេសរួមចំណែកយ៉ាងសំខាន់ចំពោះការកសាងសមត្ថភាព និងចំពោះកំណែទំរង់ស្ថាប័ន នៅពេលក្រោយៗមកតំរូវអោយមានការបង្វែរធនធានកាន់តែច្រើនទៅរកការវិនិយោគ និងស្ថិតនៅក្នុងល័ក្ខខ័ណ្ឌត្រឹមត្រូវៗផ្តល់ហិរញ្ញប្បទានចំពោះចំណាយប្រតិបត្តិការតាមរយៈការទ្រទ្រង់ថវិកា ។ ទោះជាយ៉ាងនេះក្តី នៅក្នុងរយៈពេលខ្លី មានករណីមួយដែលត្រូវធ្វើ ដើម្បីបង្កើតអោយមានគំនិតច្នៃប្រឌិតអំពីលទ្ធភាពនៃការបញ្ជូនសារជាថ្មី នូវមូលនិធិជំនួយបច្ចេកទេស រួមមានប្រាក់ឧបត្ថម្ភលើប្រាក់ខែ ទៅកាន់ចំណាយប្រាក់បៀវត្សរ៍[៤] ។

១៩. ការបរាជ័យខាងផ្នែកអភិបាលកិច្ចទំនងជាចោទជាសំណួរថា ហេតុអ្វីបានជាពលរដ្ឋក្រីក្រនៅក្នុងកម្ពុជា មិនបានទទួលអត្ថប្រយោជន៍ច្រើនបន្ថែមទៀតពីចំណាយសាធារណៈ ។ ចំណងទាក់ទងមិនល្អរវាងថវិកា និងគោលនយោបាយ សំខាន់គឺបណ្តាលមកពីភាពកំសោយនៅក្នុងទំនាក់ទំនងការទទួលខុសត្រូវរវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវា ។ លទ្ធផលអាចប្រសើរឡើង នៅពេលមានព័ត៌មានកាន់តែប្រសើរ និងការបញ្ចេញយោបល់ ដែលជួយក្នុងការដាក់សម្ពាធអោយអ្នកនយោបាយ និង មន្ត្រីរាជការទទួលខុសត្រូវ។

## គ. ការកាត់បន្ថយហានិភ័យផ្នែកជំនឿទុកចិត្តចំពោះមូលនិធិ

២០. ចំណុចខ្សោយនៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមិនត្រឹមតែធ្វើអោយខាតបង់យ៉ាងច្រើននូវប្រសិទ្ធភាពនៃការបែងចែក និងប្រតិបត្តិការប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្កើតកំរិតហានិភ័យខ្ពស់ ដែលមិនអាចទទួលយកបាន នូវជំនឿទុកចិត្តចំពោះមូលនិធិសាធារណៈផងដែរ ។ ប្រព័ន្ធបង់ប្រាក់ផ្អែកលើសាច់ប្រាក់ដែលឆ្លុះបញ្ចាំងនូវការលំបាកក្នុងពេលកន្លងមក ក៏ដូចជាការលំបាកក្នុងពេលបច្ចុប្បន្ន នៅតែជាឧបសគ្គចំបង

មួយ ។ ការអនុវត្តនីតិវិធីថវិកាកាន់តែជួបបញ្ហាដោយសារការអូសបន្លាយពេលវេលា និងការបញ្ចេញមូលនិធិ ដែលមិនអាចប៉ាន់ស្មានបាន (សូម្បីតែសំរាប់ការបើកប្រាក់បៀវត្សរ៍ក្តី សូមមើលគំនូសតាង ២.២) ដែលធ្វើ អោយប៉ះពាល់ដល់ការធ្វើផែនការប្រតិបត្តិការ និងនាំទៅដល់បំណុលកកស្ទះ ។ ប្រព័ន្ធគណនេយ្យនិងប្រព័ន្ធ របាយការណ៍មិនគ្រប់គ្រាន់ធ្វើអោយមានបរិយាកាសត្រួតពិនិត្យចុះខ្សោយ និងបង្កើនឱកាស សំរាប់អំពើពុក រលួយ។ ជាការពិត តាមន័យប្រៀបធៀប ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសកម្ពុជា មានកំរិតទាបជាងមធ្យម ដែលបង្ហាញនូវតំរូវការអោយមានការកែលំអយ៉ាងច្រើនលើប្រព័ន្ធទាំងនោះ។

***គំនូសតាង ២.២ : ប្រាក់បៀវត្សរ៍ប្រចាំខែនៅក្រសួងសុខាភិបាល ឆ្នាំ ២០០១***




ប្រភព : ***IFAPER,*** 2003.

២១. ផលប៉ះពាល់នៃការព្យាយាមដោះស្រាយបញ្ហាទាំងនេះ តាមរយៈការអនុវត្តនីគំនិតផ្តួចផ្តើមសាក ល្បង ជាពិសេស កម្មវិធីសកម្មភាពជាអាទិភាព (PAP) មិនត្រូវបានបង្ហាញដោយសារមានកត្តាកំហិត ផ្នែកសាច់ប្រាក់ និងកង្វល់អំពីលទ្ធភាពគ្រប់គ្រាន់នៃការចាត់ចែងត្រួតពិនិត្យ។ គួរកត់សំគាល់ផងដែរថា អត្រាអនុវត្តសំរាប់ផ្នែកជាអាទិភាព បានបន្ថយអត្រាសំរាប់រដ្ឋបាលស៊ីវិលទាំងមូល ទោះបីជាមានការបែង ចែកចំណាយតាមវិស័យមួយភាគធំតាមរយៈការ លើកកំពស់យន្តការបែងចែកក៏ដោយ (សូមមើលតារាង ២.២)។ ស្ថានភាពក្នុងឆ្នាំ ២០០២ ពុំមានការផ្លាស់ប្តូរច្រើនឡើយ។ ក្នុងការកសាងផែនការ និងធ្វើលទ្ធកម្ម ទំនិញនិងសេវាកម្មតាមបែបមួយដែលល្អប្រសើរនិងមានប្រសិទ្ធភាព គេត្រូវចំណាយយ៉ាងច្រើន ។ ប៉ុន្តែ គំនិតផ្តួចផ្តើមអំពី PAP បានលើកកំពស់ការរៀបចំធនធានជាមួយគោលដៅគោលនយោបាយ និងជួយបែង ចែកមូលនិធិទៅកាន់ស្ថាប័នប្រតិបត្តិ ។

២២.	បញ្ហាប្រឈមចំពោះរដ្ឋាភិបាលគឺការពង្រឹងគំនិតផ្តួចផ្តើមបច្ចុប្បន្ន ក្នុងពេលដោះស្រាយជាបណ្តើរៗ នូវឧបសគ្គផ្នែករចនាសម្ព័ន្ធ ដែលកើតឡើងដោយសារស្ថាប័នហិរញ្ញវត្ថុទន់ខ្សោយ និងសមត្ថភាពមានកំរិត។ រដ្ឋាភិបាលទទួលស្គាល់ តំរូវការក្នុងការផ្តោតទៅលើការកែលំអការអនុវត្តន៍ថវិកា ការគ្រប់គ្រងសាច់ប្រាក់ និងបរិយាកាសត្រួតពិនិត្យ ដែលទាំងអស់នេះត្រូវបានលើកឡើងនៅក្នុងកម្មវិធីកំណែទំរង់ PFM ។ ជាងនេះទៅទៀតទោះបីជាមានក្របខ័ណ្ឌច្បាប់ មួយពេញលេញ និងមានការត្រួតពិនិត្យច្រើនសន្ទឹកសន្ធាប់ក្តី កំណែទំរង់ក៏ចាំបាច់ត្រូវដោះស្រាយកិច្ចប្រតិបត្តិលើការ គ្រប់គ្រងហិរញ្ញវត្ថុដែលមានភាពកំសោយ ដែលបច្ចុប្បន្ននេះធ្វើអោយប៉ះពាល់ជាអវិជ្ជមានដល់តម្លាភាព និង គណនេយ្យភាព ដែលធ្វើធ្វើមានហានិភ័យផ្នែកជំនឿទុកចិត្ត។ ឧទាហរណ៍ ភស្តុតាងជាក់ស្តែងមួយបញ្ជាក់ថា "ការរត់ការ" នៃប្រតិបត្តិការរតនាគារ ជាពិសេសការបញ្ចេញមូលនិធិថវិកា កើតមាននិងត្រូវបានគេទទួលស្គាល់ជាទូទៅ។

**តារាង ២.២ : បញ្ហាគនដល់ចុងគ្រា : ភាគរយចំណាយក្នុងខែ ធ្នូ ឆ្នាំ ២០០០ និង ២០០១**

| សេដ្ឋកិច្ច/វិស័យ | ២០០០ | | ២០០១ | |
|---|---|---|---|---|
| | ថ្នាក់កណ្តាល | ថ្នាក់ខេត្ត | ថ្នាក់កណ្តាល | ថ្នាក់ខេត្ត |
| ចំណាយចរន្តផ្នែកស៊ីវិល | ៤៣.៤ | ២២.៨ | ៣១.៦ | ២៩.៩ |
| ជំពូក ១០: ប្រាក់បៀវត្សរ៍ | ១១.៦ | ១៩.៤ | ១៤.១ | ២៣.៧ |
| ជំពូក ១១: ចំណាយប្រតិបត្តិការ | ៣៨.២ | ២៥.០ | ៤២.២ | ៣៤.៩ |
| ជំពូក ១៣: សកម្មភាពកម្មវិធីជាក់លាក់ | ៤៧.៧ | ១០០.០ | ៤៧.៣ | ៧០.០ |
| ចំណាយមូលធនដោយមូលនិធិក្នុងស្រុក | ១០.៨ | | ១៨.២ | |
| ការការពារ និងសន្តិសុខ | ១៧.២ | | ១៨.៥ | |
| ការអប់រំ | ៦៣.២ | ២១.១ | ៣៤.៧ | ៣០.២ |
| សុខាភិបាល | ៥៩.៧ | ៣១.៧ | ៧១.៤ | ៤៣.៦ |
| កសិកម្ម | ៤១.២ | ១៨.៦ | ៣០.៧ | ២៨.០ |
| អភិវឌ្ឍន៍ជនបទ | ៣១.៥ | ២២.១ | ១៣.២ | ២៧.៤ |

*ប្រភព : **IFAPER**, 2003*

២៣. ទោះបីជាមានការរីកចំរើនខ្លះក្នុងការកែលំអមុខងារសវនកម្មក៏ដោយ ក៏ការត្រួតពិនិត្យជាសាធារណៈ លើការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលនៅមានកំរិតខ្សោយជាខ្លាំង។ ច្បាប់ស្តីពីការបង្កើតអាជ្ញាធរសវនកម្មជាតិ (NAA) ត្រូវបានអនុម័តនៅខែ មីនា ឆ្នាំ 2000 ចែងអំពីក្របខ័ណ្ឌស្ថាប័ន ការទទួលខុសត្រូវ និងសមត្ថកិច្ច ដែលស្របតាមស្តង់ដារអន្តរជាតិ។ អាជ្ញាធរសវនកម្មជាតិមានលក្ខណៈឯករាជ្យ មិនចំណុះអំណាចប្រតិបត្តិ និងរាយការណ៍ទៅរដ្ឋសភាជាតិ ដោយមានស្វ័យភាពខាងផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ និងមានសិទ្ធិកំណត់វិសាលភាព និងវិធីសាស្ត្រសវនកម្ម។ NAA បានធ្វើសវនកម្មលើការអនុវត្តន៍ថវិកាឆ្នាំ ២០០១ ជាកិច្ចការសវនកម្មដំបូងរបស់ខ្លួន។ សវនកម្មនេះត្រូវបាន បញ្ចប់នៅខែ កញ្ញា ឆ្នាំ ២០០២ និងត្រូវបានបញ្ជូនទៅកាន់រដ្ឋសភាជាតិ។ ប៉ុន្តែ របាយការណ៍នោះនៅមិនទាន់បានបញ្ចេញជាសាធារណៈទេ មានន័យថា ផលប៉ះពាល់ដែលអាចកើតមានរបស់របាយការណ៍នោះ ស្តីពីការកែលំអការទទួលខុសត្រូវ នៅមិនទាន់អនុវត្តនៅឡើយទេ ។

២៤. ស្របជាមួយនឹងការបង្កើតសវនករផ្ទៃក្រៅ រាជរដ្ឋាភិបាលកម្ពុជាកំពុងស្វះស្វែងក្នុងការកសាងសមត្ថភាពសវនកម្មផ្ទៃក្នុង ។ អគាធិការដ្ឋានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើសវនកម្មស្តីពីកិច្ចប្រតិបត្តិនៅតាមស្ថាប័ន ទោះបីជាប្រសិទ្ធភាពរបស់អគាធិការដ្ឋាននោះមានតិចតួច ដោយសារមូលហេតុមួយផ្នែក គឺគ្មានកម្មវិធីសវនកម្មជាយុទ្ធសាស្ត្រ ឬគ្មានកម្មវិធីសវនកម្មដែលផ្អែកលើហានិភ័យ។ ជាងនេះទៅទៀត អង្គភាពសវនកម្មផ្ទៃក្នុងរបស់ ក្រសួងពាក់ព័ន្ធក៏ទំនងជាមិនដំណើរការបានគ្រប់គ្រាន់ឡើយ ។

២៥. ចំណោងទាក់ទងដ៏សំខាន់មួយទៀតនៅក្នុងខ្សែសង្វាក់គ្រប់គ្រងចំណាយគឺលទ្ធកម្មសាធារណៈ។ ហានិភ័យអំពីជំនឿទុកចិត្តនៅក្នុងលទ្ធកម្មបានចុះថយ ដោយសារមានការដាក់ឱ្យដេញថ្លៃក្នុងលក្ខណៈប្រកួតប្រជែងទៅតាមដំណាក់ៗ ក្នុងរយៈពេលដប់ប្រាំបីខែកន្លងមកនេះ[៥] ។ ប៉ុន្តែហានិភ័យលើជំនឿទុកចិត្ត នៅតែមានកំរិតខ្ពស់ ដោយសារមានចំណុចខ្សោយនានានៅក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិបច្ចុប្បន្ន ដោយសារកង្វះច្បាប់ស្តីពីលទ្ធកម្មឯករាជ្យដែលជាបង្គោលសំរាប់ត្រួតពិនិត្យនិងអនុវត្ត ដោយសារកង្វះសមត្ថភាពនៅតាមក្រសួងពាក់ព័ន្ធ ដោយសារមន្ត្រីរាជការមានទំលាប់ចរចាកិច្ចសន្យា ដោយផ្ទាល់ជាមួយនឹងអ្នកម៉ៅការនិងជាមួយអ្នកផ្គត់ផ្គង់ ជំរុញអោយមាន "កិច្ចព្រមព្រៀង" ក្រៅផ្លូវការ និងមានចន្លោះប្រហោងនៅក្នុងអនុក្រិត្យស្តីពី

សាងសង់-អនុវត្ត-ផ្ទេរ (BOT) ឆ្នាំ ១៩៩៨ ដែលបានលើកទឹកចិត្ត អោយមានការផ្តល់ កិច្ចសន្យាសម្បទានមួយចំនួនតាមរយៈការចរចា ដោយផ្ទាល់លើអ្វីដែលទំនងជាមានបញ្ហា។

២៦. បើប្រៀបធៀបទៅនឹងបណ្តាប្រទេសដែលត្រូវបានទទួលស្គាល់ថា មានមូលដ្ឋានសមស្របសំរាប់សកម្មភាពលទ្ធកម្មនោះ នៅមានភាពខ្វះចន្លោះ និងចំណុចខ្សោយនៅក្នុងក្របខ័ណ្ឌច្បាប់បច្ចុប្បន្ន ពាក់ព័ន្ធទៅនឹងផ្នែកសំខាន់ៗ ដូចជាច្បាប់ក្រុមហ៊ុន ច្បាប់ធនក្ស័យ ច្បាប់កិច្ចសន្យាច្បាស់លាស់ និងច្បាប់មជ្ឈត្តវិនិច្ឆ័យពាណិជ្ជកម្ម។ ចំណុចខ្សោយមួយ ទៀតគឺ មានអនុក្រិត្យជាច្រើនស្តីពីលទ្ធកម្ម ដែលអនុក្រឹត្យទាំងនោះបញ្ជាក់អំពីនីតិវិធីខុសៗគ្នាចំពោះសកម្មភាពលទ្ធកម្មជាក់លាក់ ជាជាងមានច្បាប់មួយដែលមានអំណាចពេញលេញ ។ អ្នកផ្គត់ផ្គង់ និងអ្នកម៉ៅការ ក៏ដូចជាអង្គភាពលទ្ធកម្មរបស់ រដ្ឋាភិបាលតែងបានទទួលស្គាល់ជារឿយៗនូវការយល់ច្រលំចំពោះវិធានដែលត្រូវអនុវត្តចំពោះការដេញថ្លៃណាមួយ ។ បន្ថែមលើតំរូវការអោយមានការបង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិល្អ និងសំរាប់អនុវត្តចំពោះវិស័យអាជីវកម្ម និងពាណិជ្ជកម្មជាការសំខាន់ណាស់ដែលរាជរដ្ឋាភិបាលកម្ពុជាកែលំអការផ្សព្វផ្សាយពតិមានទាក់ទងនឹងលទ្ធកម្ម ។ ច្បាប់ អនុក្រឹត្យ និង ប្រកាសថ្មីៗទាំងអស់ដែលមិនបានដាក់បញ្ចូលទៅក្នុង *រាជកិច្ច* ប្រចាំសប្តាហ៍ គប្បីលៃយ៉ាងណាបង្កលក្ខណៈងាយស្រួល ក្នុងការផ្តល់ពតិមានដល់សាធារណជន។

២៧. លទ្ធកម្មសាធារណៈដែលមានប្រសិទ្ធភាព និងប្រកបដោយតម្លាភាព គឺជាផ្នែកសំខាន់នៃកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសមួយ ហើយក៏ជាបញ្ហាដែលគួរប្រតិបត្តិតាមគោលការណ៍ចែងច្បាស់លាស់នៅគ្រប់ករណី ដើម្បីបន្ថយឱកាស ប្រព្រឹត្តអំពើពុករលួយ ។ ក្នុងន័យនេះ កំណែទំរង់លទ្ធកម្មក៏ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកម្មវិធីកំណែទំរង់ PFM របស់រដ្ឋាភិបាលផងដែរ ។

២៨. ការត្រួតពិនិត្យច្បាប់លើចំណាយសាធារណៈ រួមមានលទ្ធកម្មធ្វើឡើងដោយគណៈកម្មការហិរញ្ញវត្ថុ និង ធនាគារ (FBC) របស់រដ្ឋសភាជាតិ និងដោយរដ្ឋសភាទាំងមូល ទោះបីចំណងទាក់ទងរវាងការត្រួតពិនិត្យច្បាប់ និងការទទួលខុសត្រូវមានភាពទន់ខ្សោយក៏ដោយ។ FBC ពិនិត្យមើលនូវសំណើថវិកា និងរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល មុននឹងបញ្ជូនទៅកាន់កិច្ចប្រជុំពេញអង្គ។ ក្នុងខណៈពេលដែលមានការពិភាក្សាយ៉ាងសកម្មអំពីបញ្ហាថវិកា កិច្ចពិភាក្សា របស់ FBC មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ ឬពុំត្រូវបានបោះផ្សាយឡើយ។ ទោះបីជាតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាមានសិទ្ធិលើកសំណើអំពីការ

បែងចែកឡើងវិញចំពោះច្បាប់ថវិកាក្តី ពួកគេកម្រធ្វើបែបនេះណាស់។ សេចក្តីព្រាងច្បាប់ថវិកាត្រូវបានបោះឆ្នោតនៅក្នុងសម័យប្រជុំពេញអង្គ បន្ទាប់ពីការបង្ហាញរបស់រដ្ឋាភិបាល និងបន្ទាប់ពី មានការពិភាក្សាត្រួសៗ។ ការពិភាក្សានេះមានផ្សាយក្នុងសារពត៌មានក្នុងស្រុក ទោះបីជាសារព័ត៌មានភាគច្រើន មានអត្ថបទដែលមានទំនោរផ្តោតទៅលើការស៊ើបអង្កេតអំពើពុករលួយនៅក្នុងផ្នែកសាធារណៈ ជាជាងផ្តោតលើបញ្ហាគោលនយោបាយចំណាយក្តី ។ ជាងនេះទៅទៀត ប៉ុន្មានឆ្នាំកន្លងមក រដ្ឋសភាមានពេលតិចតួចណាស់សំរាប់ពិនិត្យមើលថវិកាលំអិត ។

២៩. ការកែលំអការទទួលខុសត្រូវក៏ជួបឧសគ្គផងដែរ ដោយសារកង្វះតម្លាភាពជាទូទៅនៅក្នុងវិស័យសាធារណៈ។ ឧទាហរណ៍ គេមិនអាចងាយទទួលបានថវិកានៅក្នុងទំរង់បច្ចុប្បន្ន ហើយថវិកាក៏មិនត្រូវបានផ្សព្វផ្សាយអោយបានទូលំទូលាយដែរ។ ទិន្នន័យស្តីពីការអនុវត្តន៍ថវិកាមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ ។ ព័ត៌មានជាមូលដ្ឋានស្តីពីមុខងារសាធារណៈត្រូវបានគេការពារយ៉ាងម៉ត់ចត់។ រដ្ឋសភាជាតិមិនបានពិគ្រោះជាមួយសង្គមស៊ីវិលលើបញ្ហាថវិកាឡើយ។

៣០. ក្នុងខណៈពេលការរៀបចំការត្រួតពិនិត្យទាំងអស់មានលក្ខណៈសមស្របក្តី ក៏ការរៀបចំទាំងនោះមិនសូវមានប្រសិទ្ធភាពដែរ មួយផ្នែកគឺដោយសារសមត្ថភាពនៅមានកំរិត។ គេត្រូវដោះស្រាយបញ្ហាទាំងនេះក្នុងរយៈពេលមធ្យម ទៅរយៈពេលវែង ដោយបង្កើនចំនួន និងការបណ្តុះបណ្តាលបុគ្គលិកគ្រប់គ្រងហិរញ្ញវត្ថុដែលកំពុងបំរើការ ។ ទទ្ទឹមនឹងនេះ ឧបសគ្គផ្នែកសមត្ថភាព មិនមែនជាលេសដែលធ្វើអោយការត្រួតពិនិត្យមានលក្ខណៈទន់ខ្សោយនោះទេ ជាពិសេស ប្រសិនបើសមត្ថភាពក្នុងការរាយការណ៍ និងក្នុងការប្រឆាំងនឹងការកេងរំលោភបំពាន ជួបការលំបាកដោយសារ បរិយាកាសអភិបាលកិច្ចមិនល្អ។ ចំពោះមុខគេអាចកែលំអយ៉ាងច្រើនចំពោះប្រសិទ្ធភាពនៃរៀបចំការត្រួតពិនិត្យ ដែលមានក្នុងពេលបច្ចុប្បន្ន ដោយលៃយ៉ាងណាអោយរបាយការណ៍សវនកម្មត្រូវបានផ្សព្វផ្សាយដល់សាធារណជន។ ជាងនេះទៅទៀត គួរចាប់អារម្មណ៍លើការបង្កើតការរៀបចំការត្រួតពិនិត្យ "ពីក្រោមទៅលើ" ដើម្បីបំពេញបន្ថែមទៅ លើការត្រួតពិនិត្យជាផ្លូវការពីសំណាក់ NAA និងពីរដ្ឋសភា តាមរយៈការចូលរួមរបស់អ្នកទទួលផលប្រយោជន៍នៅក្នុងការតាមដានការផ្តល់សេវា និងការបញ្ចេញថវិកាដល់តំបន់នានា។

## ឃ. កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៣១. រដ្ឋាភិបាលបានដឹងអំពីបញ្ហាប្រឈមនឹងការលំបាកទាំងនេះ ហើយប្ដេជ្ញាដោះស្រាយតាមបែបដែលអាចឆ្លើយតបអោយបានទូលំទូលាយ ។ គណៈកម្មការកំណែទំរង់ដែលបានតែងតាំងថ្មីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើត "កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" ដែលទទួលការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍ទាំងដប់របស់ខ្លួន ដោយមានសមាសភាគស្នូលដូចតទៅ: (ក) ខ្លឹមសារយុទ្ធសាស្ត្រច្បាស់លាស់ និងកម្មវិធីការងារប្រចាំឆ្នាំដែលមានលក្ខណៈរំកិល ផ្ដល់អាទិភាព រៀបចំតាមលំដាប់លំដោយ និងគណនាចំណាយ (ខ) ក្របខ័ណ្ឌគ្រប់គ្រងសកម្មភាពអនុវត្តន៍ ដើម្បីជួយក្នុងការបង្កើតកម្មវិធី ការលើកកំពស់តម្លាភាព និងការទទួលខុសត្រូវ ការតាមដានវឌ្ឍនភាព និងបង្កលក្ខណៈ អំណោយផលក្នុងការប្រៀបធៀបជាអន្តរជាតិ (គ) កំណែទំរង់រចនាសម្ព័ន្ធបំពេញបន្ថែម និងយុទ្ធសាស្ត្រកសាងសមត្ថភាព ដោយផ្ដោតទៅលើការលើកទឹកចិត្តសមស្រប។ កម្មវិធីរបស់រដ្ឋាភិបាលនឹងផ្អែកលើសមិទ្ធិផលក្នុងពេលកន្លងមកដោយ ថ្មីៗនេះមានរាប់បញ្ចូលនូវការកាត់បន្ថយបំណុលចំពោះអ្នកផ្គត់ផ្គង់ ការកែសំរួលបូងគណនី និងការបង្កើនការប្រមូលបំណុលពន្ធ។

៣២. នៅក្នុងដំណាក់កាលដំបូង ("ដំណាក់កាលទីមួយ") កម្មវិធីកំណែទំរង់ PFM របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្ដោតទៅលើការសំរេចគោលដៅដូចតទៅ: "...ដើម្បីសំរេចគោលដៅមួយដែលថវិកាក្លាយទៅជាឧបករណ៍ដែលកាន់តែបង្កើតភាពជឿជាក់នៃការគ្រប់គ្រងជាយុទ្ធសាស្ត្រ ឬការគ្រប់គ្រងប្រចាំថ្ងៃនៃធនធានសាធារណៈ ពីព្រោះការគ្រប់គ្រង នោះបានផ្ដល់ធនធានដែលអាចទុកចិត្ត និងអាចប៉ាន់ស្មានបានចំពោះអ្នកគ្រប់គ្រងថវិកា ។ ប្រការនេះបញ្ជាក់ថា ថវិកា ឆ្លុះបញ្ចាំងនូវរាល់ធនធានសាធារណៈសំខាន់ៗ និងការប្រើប្រាស់ថវិកា។ ដូច្នេះ ធ្វើអោយមានជំហានជាបន្តបន្ទាប់តាមដំណាក់កាល ដើម្បីធ្វើអោយអ្នកគ្រប់គ្រងមានការទទួលខុសត្រូវលើការប្រើប្រាស់ធនធាន អោយបានចំទិសដៅ និងមានប្រសិទ្ធភាព" (រាជរដ្ឋាភិបាលកម្ពុជា កម្មវិធីកំណែទំរង PFM ឆ្នាំ ២០០៤) ។ ដើម្បីសំរេចកិច្ចការនេះ រដ្ឋាភិបាលមានបំណង : លើកកំពស់ភាពពេញលេញ និងសមាហរណកម្មថវិកា (នៅក្នុងការកសាង និងក្នុងការអនុវត្តន៍) ពង្រីកវិសាលភាពអនុវត្តប្រតិបត្តិការរតនាគារ តាមរយៈប្រព័ន្ធធនាគារ ដោយប្រើមលប្បទានប័ត្រ ឬការបង្វែរការច្របាច់បញ្ចូលនូវគណនីនានារបស់រដ្ឋាភិបាលអោយទៅជាគណនីរតនាគារ តែមួយបង្កើតបែបបទដើម្បី

បង្ការការសន្យានានាដែលលើសពីធនធានថវិកាដែលមាន លើកកំពស់ស្ថានការណ៍ថវិកាពិត តាមរយៈការព្យាករណ៍និងការគ្រប់គ្រងបំណុលពង្រឹងការប្រមូលចំណូលពន្ធ និងចំណូលមិនមែនពន្ធ កំណត់ដែនសមត្ថកិច្ចរបស់អ្នកគ្រប់គ្រងធនធាននៅក្នុងក្រសួងពាក់ព័ន្ធ អោយចំណាយស្របតាមថវិកាវិភាជន៍របស់ខ្លួន ដាក់កំហិតការចំណាយថវិកាបន្ថែម ពង្រឹងនីតិវិធីលទ្ធកម្ម បង្កើនការសំរបសំរួលនិងការសំរេចចិត្តនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយផ្នែក តាមរយៈការដាក់ឱ្យអនុវត្តវិធានការលើកទឹកចិត្ត និងអភិវឌ្ឍសមត្ថភាព។

៣៣. ដំណាក់កាលបន្ទាប់ដែលមានបំណងលើកកំពស់ការត្រួតពិនិត្យផ្ទៃក្នុង និងដើម្បីធ្វើអោយអ្នកគ្រប់គ្រងមានការទទួលខុសត្រូវៈ (i) លើកកំពស់ដែនទទួលខុសត្រូវដោយបញ្ជាក់ច្បាស់លាស់អំពីមុខងាររបស់រដ្ឋាភិបាល និងភារកិច្ចនានា ។ (ii) កែលំអទិន្នន័យគណនេយ្យនិងការគ្រប់គ្រង (iii) លើកកំពស់ការរាយការណ៍ សំរាប់គោលបំណងគ្រប់គ្រងសកម្មភាពអនុវត្ត និង (iv) លើកកំពស់សវនកម្មទាំងផ្ទៃក្នុងនិងផ្ទៃក្រៅ ។

៣៤. លក្ខខណ្ឌអាទិភាពខ្ពស់បំផុតជាច្រើននៅក្នុងផែនការសកម្មភាពរបស់រដ្ឋាភិបាល ត្រូវបានបង្កើតឡើងសំរាប់អនុវត្ត ស្របតាមកាលវិភាគដែលបានព្រមព្រៀងជាមួយដៃគូ PFM (បេសកម្មរួមគ្នាលើកទី៣របស់PFM ឆ្នាំ ២០០៤) ។ កិច្ចការនេះរួមមាន : ការរៀបចំប្រព័ន្ធដំណើរការ ប្រតិបត្តិការថ្មីពីការប្តេជ្ញាទៅជាការអនុវត្ត អនុវត្តវិធានការនានាដើម្បីប្រមូលចំណូលពន្ធ និងពន្ធគយតាមរយៈ មូលប្បទានប័ត្រ និងតាមរយៈការផ្ញើទៅធនាគារជាតិកម្ពុជាដោយផ្ទាល់ និងបង្កើនល្បឿនការបង់ប្រាក់របស់អ្នកផ្គត់ផ្គង់ដោយមូលប្បទានប័ត្រ ឬដោយការបង្វែរ បង្កើតផែនការបញ្ចេញសាច់ប្រាក់ដែលមានតម្លាភាពសំរាប់ឆ្នាំ ២០០៥ និង ប្រព័ន្ធប៉ាន់ស្មានចរន្តសាច់ប្រាក់រយៈពេល ៣ ខែម្តង អនុវត្តការផ្ទេរប្រាក់របស់អង្គភាពគ្រប់គ្រងរូបិយប័ណ្ណបរទេស ទៅកាន់រតនាគារ និងរៀបចំដំណើរការឡើងវិញដើម្បីរួមបញ្ចូលការគ្រប់គ្រងសាច់កសាងផែនការនិងដំណើរការបន្ថែម ដោយការលុបបំបាត់បំណុលចាស់ៗដែលកកស្ទះ និងបង្កើតប្រព័ន្ធដែលត្រូវបានពង្រឹងសំរាប់ធានាអោយបាននូវការគ្រប់គ្រង អោយមានប្រសិទ្ធភាពចំពោះថវិកាបន្ថែម ។ ការអនុវត្តវិធានការដំណាក់កាលទីមួយអាចនឹងស្តារការជឿជាក់ចំពោះ ថវិកាជាតិរបស់ប្រទេសកម្ពុជា និងអាចបង្កើតជាមូលដ្ឋានដែលញុំាងអោយអ្នកគ្រប់គ្រងមានការទទួលខុសត្រូវក្នុងការ ប្រតិបត្តិតាមការគ្រប់គ្រងហិរញ្ញវត្ថុដែលតំរូវដោយច្បាប់។

៣៥. សហគមន៍ម្ចាស់ជំនួយបានបញ្ជាក់ពីឆន្ទៈរបស់ខ្លួនក្នុងការខិតខំប្រឹងប្រែងរួមគ្នា ដើម្បីផ្តល់ការគាំទ្រចាំបាច់សំរាប់គំនិតផ្តួចផ្តើមកំណែទំរង់បន្ទាន់នេះ ។ ដើម្បីឆ្ពោះទៅរកគោលដៅនេះ បេសកកម្មចំរុះដែលរួមមានដៃគូអភិវឌ្ឍន៍ចំនួនដប់ ពោលគឺ ធនាគារអភិវឌ្ឍន៍អាស៊ី អូសអេដ (AusAID) ឌីហ្វិដ (DFID) គណៈកម្មការអឺរ៉ុប (EC) កិច្ចសហប្រតិបត្តិការបារាំង មូលនិធិរូបិយវត្ថុអន្តរជាត (IMF) អង្គការចៃកា (JICA) ស៊ីដា (SIDA) កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ធនាគារពិភពលោក (WB) បានធ្វើទស្សនកិច្ចនៅកម្ពុជាក្នុងកំឡុង ខែ មករា ដល់ កក្កដា ឆ្នាំ 2004 ដើម្បីរៀបចំកម្មវិធីជួយដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបង្កើតយន្តការមួយសំរាប់សំរបសំរួលអ្នកផ្តល់ជំនួយ។ ដៃគូបានទទួលស្គាល់ថា ពួកគេអាចលើកកំពស់ការផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាល ដោយផ្អែកលើបទពិសោធន៍បច្ចុប្បន្ន។ បញ្ហាលំបាកបំផុត ដែលជាប់ប្តូន្ទានដ៏ចំរូងចំរាស់ និងដាច់ដោយឡែកពីគ្នាពីដៃគូ) គឺកង្វះការរៀបចំជំនួយជាមួយនឹងផែនការរបស់រដ្ឋាភិបាល កង្វះការទទួលខុសត្រូវនៃជំនួយចំពោះរដ្ឋាភិបាល និងកង្វះភាពជាអ្នកដឹកនាំរបស់រដ្ឋាភិបាល ត្រូវបានដោះស្រាយដោយការបង្កើតវិធីសាស្ត្រទូលាយ លើវិស័យគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដូច្នេះ ផ្អែកលើផែនការរបស់រដ្ឋាភិបាល និងដៃគូ បច្ចុប្បន្ននេះយន្តការស្ថាប័នត្រូវបានបង្កើតឡើង ដើម្បីគាំទ្រ កំណែទំរង់អោយមាននិរន្តរភាព។ ឥលូវនេះគឺជាពេលសំរាប់ការអនុវត្ត ។

## ខ. ការកែទំរង់មុខងារសាធារណៈរបស់កម្ពុជា

៣៦. មូលហេតុដ៏សំខាន់មួយទៀតដែលនាំអោយមានសេវាសាធារណៈខ្វះគុណភាព គឺបណ្តាលមកពីកង្វះប្រព័ន្ធសំរាប់លើកទឹកចិត្តដែលមានប្រសិទ្ធភាព និងកង្វះយន្តការទទួលខុសត្រូវនៅក្នុងផ្នែកមុខងារសាធារណៈកម្ពុជា ។ ការគ្រប់គ្រងមុខងារសាធារណៈផ្អែកតិចតួចលើគុណសម្បត្តិការងារ ការបើកប្រាក់បៀវត្សរ៍តិច និងអំពើពុករលួយគ្រប់ទីកន្លែង គឺជាមូលហេតុចំបង ដែលធ្វើឱ្យលទ្ធផលអនុវត្តនៃវិស័យសាធារណៈរបស់កម្ពុជាប្រព្រឹត្តទៅមិនបានល្អ ។ ការវាយតំលៃរបស់ធនាគារពិភពលោកចំពោះគោលនយោបាយនិងស្ថាប័នរបស់ប្រទេស (CPIA) បានចាត់ប្រទេសកម្ពុជាក្នុងបណ្តាប្រទេស ដែលមានចំណាត់ថ្នាក់លេខបួន ក្នុងចំណោមបណ្តាប្រទេសដែលមានចំណូលទាប លើបញ្ហាដែលពាក់ព័ន្ធនឹងស្ថាប័ន និងការគ្រប់គ្រងផ្នែកសាធារណៈដែលបញ្ជាក់អំពីតំរូវការចំបាច់ក្នុងការអភិវឌ្ឍន៍យ៉ាងច្រើន ។ ដោយមានបញ្ហាដ៏ធ្ងន់ធ្ងរនេះ កំណែទំរង់មុខងារសាធារណៈ នៅក្នុងរយៈពេលខ្លី ចាំបាច់ត្រូវរៀបចំតាមលំដាប់លំដោយដែលមានលក្ខណៈ

ជាយុទ្ធសាស្ត្រ និងអនុវត្តក្នុងរយៈពេលមធ្យម ប្រសិនបើទស្សនៈវិស័យរបស់រដ្ឋាភិបាលអំពីការកាត់បន្ថយភាពក្រីក្រក្លាយជាការពិតមែននោះ ។ កម្មវិធីកំណែទំរង់ចាំបាច់ត្រូវមានយុទ្ធសាស្ត្រទូលាយមួយដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីរាជការតាមរយៈ ការអនុវត្តប្រព័ន្ធផ្អែកលើគុណសម្បត្តិ ដែលធានាថា ការចំណាយលើធនធានមនុស្សជាចំណុចដែលត្រូវត្រួតពិនិត្យ (ដូចជា ការជួល និងការតំលើងឋានៈ ជាដើម) និងរួមបញ្ចូលទាំងស្រុងជាមួយនឹងដំណើរការរៀបចំថវិកា ការលើកកំពស់ប្រាក់បៀវត្សរ៍មន្ត្រីរាជការ ដើម្បីទាក់ទាញនិងរក្សាបុគ្គលិកជំនាញ ជាពិសេសសំរាប់ថ្នាក់គ្រប់គ្រងកំរិតខ្ពស់ និងបុគ្គលិកនៃវិស័យអាទិភាព និងធ្វើសនិទានកម្មនិយោជន៍មុខងារសាធារណៈលៃយ៉ាងណាអោយធនធានមនុស្ស ត្រូវបានដាក់ពង្រាយបានស្របនៅក្នុងវិស័យដែលមានអាទិភាពខ្ពស់ ។ ជាការពិតណាស់ ហានិភ័យចំបងនានាចំពោះ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាលគឺសមត្ថភាពរបស់មន្ត្រីរាជការក្នុងការផ្តល់សេវាកម្ម។

៣៧. ទោះបីជារដ្ឋាភិបាលបានធ្វើអោយមានការរីកចំរើនសមរម្យមួយចំនួន ដូចជាការធ្វើជំរឿនមន្ត្រីរាជការ និងការបង្កើតប្រព័ន្ធបើកប្រាក់ខែដោយស្វ័យប្រវត្តិជាដើមក្តី នៅមានកិច្ចការជាច្រើនបន្ថែមទៀតដែលត្រូវធ្វើ ។ នៅក្នុងផ្នែកនេះ មួយចំនួន ដូចជាការបង្កើតអោយមានការត្រួតពិនិត្យ វិធានការសំខាន់ៗ ដូចជាការចុះបញ្ជីស្ថាប័ន នឹងអនុញ្ញាតអោយរដ្ឋាភិបាលកសាងលើភាពជោគជ័យពីអតីតកាលប្រកបដោយផលិតភាព រីឯនៅក្នុងផ្នែកខ្លះទៀត ដូចជាការបង្កើតប្រព័ន្ធ ផ្អែកលើគុណសម្បត្តិការងារ ដែលជំរុញដោយការផ្តល់ប្រាក់បៀវត្សរ៍ខ្ពស់ រដ្ឋាភិបាលនឹងត្រូវប្រឈមក្នុងការជំរុញខ្លួន អោយបានឆ្ងាយ និងអោយបានរហ័សជាងការរំពឹងក្នុងពេលបច្ចុប្បន្ន។

៣៨. ទោះបីជាបញ្ហាបន្ទាន់បំផុតប្រឈមមុខនឹងមុខងារសាធារណៈកម្ពុជា គឺបណ្តាលមកពីកង្វះប្រព័ន្ធផ្អែកលើគុណសម្បត្តិការងារសំរាប់ការគ្រប់គ្រង ការជ្រើសរើស និងការតំលើងឋានៈមន្ត្រីរាជការក្តី បញ្ហាបន្ទាន់បំផុតដែលប្រឈមមុខចំពោះមន្ត្រីរាជការខ្លួនឯងគឺប្រាក់បៀវត្សរ៍មានកំរិតទាប ដែលមិនត្រឹមតែធៀបនឹងកំរិតប្រាក់ឈ្នួលខាងក្រៅសេវាប៉ុណ្ណោះទេ ប៉ុន្តែធៀបនឹងចំណាយជីវភាពផងដែរ (សូមមើលតារាង ២.៣) ។ បើប្រៀបធៀបអនុបាតប្រាក់ខែ មធ្យមនៃមន្ត្រីរាជការធៀបនឹងផលិតផលក្នុងស្រុកសរុប (GDP) សំរាប់ពលរដ្ឋម្នាក់ៗ ផលធៀបនេះមានកំរិតទាប ជាងគេក្នុងចំណោមផលធៀបដែលទាបជាងគេបំផុតនៅក្នុងតំបន់។

*តារាង ២.៣: មធ្យមនៃលាភការប្រចាំខែ ឆ្នាំ ២០០២ (គិតជាដុល្លារអាមេរិក)*

| ប្រភេទ | កំរិតនៃការអប់រំ | ដុល្លារអាមេរិក/ខែ | អនុបាតរវាងលាភការមធ្យមនៃប្រភេទខ្ពស់បំផុតនិងទាបបំផុត |
|---|---|---|---|
| A | មធ្យមសិក្សា+ ៤ ឆ្នាំ | ៤០ | ១.៩ |
| B | មធ្យមសិក្សា +២ ឆ្នាំ | ៣២ | ១.៥ |
| C | មធ្យមសិក្សា | ២៦ | ១.២ |
| D | ក្រៅពីនេះ | ២១ | -- |

*ប្រភព : ក្រុមប្រឹក្សាសំរាប់កំណែទំរង់រដ្ឋបាល*

៣៩. ដោយមិនរាប់បញ្ចូលបុគ្គលិកកំរិតខ្ពស់ដែលចំនួនតិច (ប្រហែល ៧០០ នាក់ក្នុងចំណោមជិត ១៦៨ ពាន់នាក់ នៅឆ្នាំ ២០០៣) មន្ត្រីរាជការភាគច្រើនមានប្រាក់ចំណូលតិចណាស់ ទោះជាក្នុងប្រាក់ចំណូលដាច់ខាត ឬប្រាក់ចំណូលធៀបក្តី ។ ម្យ៉ាងវិញទៀត អនុបាតរវាងលាភការមធ្យមនៃប្រភេទដែលមានលាភការខ្ពស់បំផុតនិងទាបបំផុតមានកំរិតទាបជាង ២ ដែលជាអនុបាតទាបណាស់ធៀបនឹងស្តង់ដារអន្តរជាតិ ។ ការយកចិត្តទុកដាក់បង្កើនប្រាក់ខែពី ១០-១៥ ភាគរយ ក្នុងមួយឆ្នាំ ពីសំណាក់រដ្ឋាភិបាល គ្មានផលប៉ះពាល់ធ្ងន់ធ្ងរលើការជ្រើសរើស ឬការរក្សាទុកមន្ត្រីរាជការដែលមានជំនាញឡើយនៅក្នុង ទសវត្សរ៍ខាងមុខនេះ ។

៤០. រចនាសម្ព័ន្ធប្រាក់បៀវត្សរ៍នេះ រួមជាមួយនឹងកង្វះការអនុវត្តន៍ផ្អែកលើគុណសម្បត្តិការងារ ពុំមានលក្ខណៈគ្រប់គ្រាន់សំរាប់ជំរុញមន្ត្រីរាជការដែលកំពុងបំរើការនៅក្នុងប្រព័ន្ធនេះ ឬទាក់ទាញបេក្ខជនដែលមានសមត្ថភាពចាំបាច់គ្រប់ចំនួន អោយនៅបំរើក្នុងវិស័យមុខងារសាធារណៈឡើយ ។ ជាការពិតណាស់ កំរិតប្រាក់បៀវត្សរ៍ដ៏ទាប នាំអោយមានអំពើពុករលួយ ដោយការធ្វើអោយព្រំដែនរវាងផ្នែកសាធារណៈនិងផ្នែកឯកជនមានលក្ខណៈមិនច្បាស់លាស់ ។ ជាក់ស្តែង មន្ត្រីរាជការអាចរស់រានមានជីវិត ហើយមួយចំនួនថ្កុំថ្កើងបានដោយសារតែមានបណ្តាញចៅហ្វាយនាយ ដែលពួកគេបញ្ជូនធនធានទៅអោយចៅហ្វាយនិងបញ្ជូនអោយអតិថិជនរបស់ពួកគេ ។ មានរបាយការណ៍ជាច្រើនស្តីពីការសូកសំណូក ជាថ្នូរនឹងការងារ ។

ក្នុងករណីខ្លះ មានរបាយការណ៍និយាយថា គេទិញការងារក្នុងតំលៃមួយម៉ឺនដុល្លារអាមេរិក ។ រីឯពលរដ្ឋក្រីក្រក៏ចាំបាច់ត្រូវទិញការងារផងដែរ ។ វដ្តបែបនេះបន្តកើតមានជាលំដាប់ ។

៤១. កំណើនមន្ត្រីរាជការទាំងមូលកើតឡើងចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ ១៩៩០ ដែលបញ្ជាក់ថា សម្ពាធនយោបាយគ្របសង្កត់ដោយការមិនសូវយកចិត្តទុកដាក់លើគុណសម្បត្តិការងារ និងមិនសូវយកចិត្តទុកដាក់លើការតំលើងឋានៈក៏ដូចជាបង្កើតអោយមានការត្រួតពិនិត្យ ។ យោងតាមច្បាប់ថវិកា ចំនួនការងារផ្នែកសាធារណៈបានកើនឡើង ១៣ ភាគរយ ចាប់ពីឆ្នាំ ១៩៩៤ គឺពី ១៤៨,៣៩៣ ទៅ ១៦៧,៧៧៨ នៅឆ្នាំ ២០០៣ ។ ការវិភាគក៏បានបង្ហាញថាផងដែរថា គួរមានការលើកកំពស់នៅក្នុងការ ពង្រាយមន្ត្រីរាជការនៅតាមភូមិសាស្ត្រ និងតាមវិស័យអាទិភាព (ការពង្រាយបុគ្គលិកឡើងវិញពីថ្នាក់ កណ្តាលដល់ថ្នាក់ខេត្តជាការចាំបាច់សំរាប់វិស័យមួយចំនួន ដូចជាវិស័យកសិកម្ម និងសុខាភិបាល) ។ ការពិនិត្យសារឡើងវិញនូវមុខងារ ដែលគ្របដណ្តប់លើការរៀបចំតាមស្ថាប័នអោយបានសមស្រប ការរៀបចំការចាត់តាំងដំណើរការ និងការរៀបចំបុគ្គលិកតាមមុខងាររបស់រដ្ឋាភិបាល ដើម្បីលើកកំពស់ប្រសិទ្ធភាព នៅក្នុងការផ្តល់សេវានឹងមានភាពចាំបាច់ក្នុងការរកអោយឃើញនូវកំរិតនិយោជន៏ជារួម រកមើលកង្វះខាត ពិតប្រាកដតាមវិស័យ និងពិនិត្យរកសមាសភាពនិយោជន៏នៃវិស័យសាធារណៈសមស្របបំផុតសំរាប់ ប្រទេសកម្ពុជា ។

៤២. ដូច្នេះប្រព័ន្ធផ្អែកលើគុណសម្បត្តិការងារប្រកបដោយតម្លាភាព ដែលជំរុញដោយប្រាក់បៀវត្សរ៍ខ្ពស់តាមរយៈកំណើនប្រាក់បៀវត្សរ៍តាមលំដាប់លំដោយនិងតាមគោលដៅ នឹងក្លាយជាផ្នែកដ៏សំខាន់នៃកម្មវិធីកំណែទំរង់របស់រដ្ឋាភិបាល ។ ការណ៍នេះពិតជាមិនអាចសំរេចបានទេ ក្នុងការបង្កើនប្រាក់បៀវត្សរ៍ចំពោះមន្ត្រីរាជការកម្ពុជា ដោយសារតែបញ្ហាដូចបានពោលខាងលើ និង ការកំហិតផ្នែកសារពើពន្ធ ជាពិសេសគឺបណ្តាលមកពីកង្វះការគ្រប់គ្រងល្អប្រសើរ ។ មាគ៌ាសំរាប់លទ្ធភាពកំណែទំរង់មុខងារសាធារណៈ គឺតាមរយៈការដាក់អោយអនុវត្តស្របជាមួយនឹងតាមដំណាក់កាល នូវការគ្រប់គ្រងដែលផ្អែកលើគុណសម្បត្តិការងារ ហើយប្រសើរជាងនេះគឺបំបែកបៀវត្សរ៍សំរាប់វិស័យអាទិភាពខ្ពស់មួយចំនួន តាមមុខងារ និងតាមជំនាញ ។ ជាចុងក្រោយ ការធ្វើសនិទានកម្មរយៈពេលវែងនៃចំនួនបុគ្គលិក នឹងដើរទន្ទឹមគ្នាជាមួយសនិទានកម្មលាភការ ។ ជាងនេះទៅទៀត ការបើប្រាក់ខែអោយមន្ត្រីរាជការតាមប្រព័ន្ធធនាគារអាចនឹងកាត់បន្ថយអំពើពុករលួយ ជាងការបើកប្រាក់ខែដោយប្រើសាច់ប្រាក់ ។

៤៣.	ក៏ដូចជានៅកន្លែងផ្សេងក្នុងប្រទេសកម្ពុជាទៀតផងដែរ ការមានតម្លាភាពកាន់តែច្រើនលើផ្នែកព័ត៌មាន ជាមូលដ្ឋាន អាចជួយលើកកំពស់ការទទួលខុសត្រូវ ហើយក្នុងករណីនេះ អាចធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងធនធានមនុស្ស ។ នៅប្រទេសភាគច្រើន ព័ត៌មានស្តីពីចំនួន និងកំរិតនៃមន្ត្រីរាជការនៅតាមក្រសួងមន្ទីរគឺជាព័ត៌មានសាធារណៈ ផ្ទុយទៅវិញ នៅកម្ពុជាគេចាត់ទុកព័ត៌មាននេះថា ជាព័ត៌មានសម្ងាត់ ។ កត្តាដែលរដ្ឋាភិបាលមិនប្រើប្រាស់តួលេខផ្លូវការ នៅពេលរាប់មន្ត្រីរាជការរបស់ខ្លួន បង្កអោយមានការច្របូកច្របល់ និងប៉ះពាល់ដល់ការវិភាគដ៏ច្បាស់លាស់ ។ បញ្ហាសំខាន់ គឺទិន្នន័យមូលដ្ឋាន (HRMIS) របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល (CAR) មិនត្រូវបានគេប្រើក្រៅពី CAR ឡើយ ។ ជាការចាំបាច់ រដ្ឋាភិបាលត្រូវប្រើទិន្នន័យមូលដ្ឋានរួមតែមួយសំរាប់ថវិកា ដើម្បីត្រួតពិនិត្យទំហំ និងរបាយការណ៍ស្ថាប័ន។ ដើម្បីសំរេចតាមគោលដៅនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ យ៉ាងហោចណាស់ត្រូវមានលទ្ធភាពទទួលទិន្នន័យមូលដ្ឋានរបស់ CAR សំរាប់រៀបចំថវិកា។ ការផ្តល់លទ្ធភាពអោយទទួលបាននូវទិន្នន័យមូលដ្ឋាននឹងកែលំអគុណភាពវិភាគទិន្នន័យនិងវិភាគគោលនយោបាយ ហើយមានលក្ខណៈចាំបាច់សំរាប់លើកកំពស់អោយមានតម្លាភាព។ ការមានតម្លាភាពកាន់តែច្រើនគឺជាការចាំបាច់សំរាប់កែលំអការគ្រប់គ្រងកំលាំងពលកម្ម ។

## ច. សេចក្តីសន្និដ្ឋាន

៤៤.	សំណួរដែលថាតើហេតុអ្វីបានជាពលរដ្ឋក្រីក្ររបស់ប្រទេសកម្ពុជាមិនបានទទួលផលប្រយោជន៍បន្ថែមទៀតពីចំណាយសាធារណៈ បានចោទជាបញ្ហាត្រង់ៗធ្ងន់ធ្ងរលើបញ្ហាអភិបាលកិច្ចល្អ ។ កំហុសឆ្គងក្នុងការងារផ្តល់សេវា បង្ហាញច្បាស់តាមរយៈចំណងទាក់ទងអប្រសិទ្ធភាពរវាងគោលនយោបាយ និងលទ្ធផលអនុវត្តន៏ និងអប្រសិទ្ធភាពនៅក្នុងចំណាយ ដែលភាគច្រើនបណ្តាលមកពីកង្វះយន្តការទទួលខុសត្រូវដែលមានប្រសិទ្ធភាព។ ជាពិសេស លទ្ធផលអនុវត្តន៏ សំរាប់ពលរដ្ឋក្រីក្រ អាចធ្វើអោយប្រសើរឡើងនៅពេលមានព័ត៌មានល្អប្រសើរ និងមានប្រមូលមតិយោបល់ ដែលជាជំនួយសំរាប់អោយអ្នកនយោបាយ និងមន្ត្រីរាជការទទួលខុសត្រូវ ។ ប្រការនេះបង្ហាញថា ទាក់ទងនឹងការរៀបចំលំដាប់លំដោយ ក្នុងការលើកកំពស់តម្លាភាពនៃវិស័យសាធារណៈ ជាពិសេសតាមរយៈការបង្កើនផ្សព្វផ្សាយព័ត៌មានអំពីទិន្នន័យ ការធ្វើសេចក្តីសំរេចចិត្ត គឺជាជំហានដំបូងឆ្ពោះទៅរកមាគ៌ាទទួលខុសកាន់តែប្រសើរ ។

គេត្រូវការពេលវេលាសំរាប់កសាង និងដាក់អោយមានយន្តការគណនេយ្យភាព ហើយជាចុងក្រោយនឹងមានការចូលរួមស៊ីជំរៅរវាងពលរដ្ឋនិងរដ្ឋាភិបាល ។ រដ្ឋាភិបាលទំនងជាទទួលស្គាល់បញ្ហាប្រឈម ដែលត្រូវដោះស្រាយនៅក្នុងផ្នែកសំខាន់ៗ ដើម្បីលើកកំពស់គុណភាព និងបរិមាណនៃការផ្តល់សេវាដែលផ្តោតទៅលើពលរដ្ឋក្រីក្រ ។ ចំណុចដែលអាច អនុវត្តនិងដែលមានអាទិភាពខ្ពស់សំរាប់កាត់បន្ថយភាពក្រីក្រគឺការបង្កើតកម្មវិធីអាទិភាព និងរៀបចំតាមលំដាប់លំដោយ នូវ*កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ កម្មវិធីកំណែទំរង់ PFM សមនឹង ទទួលបាននូវការគាំទ្រយ៉ាងពេញលេញ និងដោយក្តីសប្បុរសពីដៃគូអភិវឌ្ឍន៍របស់កម្ពុជា ។

៤៦. ផ្នែកដែលសំខាន់គឺកំណែទំរង់មុខងារសាធារណៈ ប៉ុន្តែជាអកុសលផ្នែកនេះមានការរីកចំរើនតិចតួច។ គេពុំឃើញមានយុទ្ធសាស្រ្តតាមអាទិភាពតាមលំដាប់លំដោយសំរាប់ បង្ហាញលក្ខណៈមុខងារសាធារណៈដែលលើកតំកើងឋានៈ តាមរយៈគុណសម្បត្តិការងារនៅក្នុងវិស័យដែលមានអាទិភាពខ្ពស់ និងការគាំទ្រកំណែទំរង់ទាំងនេះ តាមរយៈការតម្លើងប្រាក់បៀវត្សរ៍ឡើយ ។ វឌ្ឍនភាពលើកំណែទំរង់មុខងារសាធារណៈមានសារៈសំខាន់ខ្លាំងណាស់ សំរាប់កំណត់ជោគវាសនា ក្នុងការអនុវត្តន៍យុទ្ធសាស្រ្តចតុកោណ។

---

[1] ជំពូកនេះភាគច្រើនមានមូលដ្ឋានលើឯកសារពិនិត្យឡើងវិញអំពី ការវាយតំលៃជំនឿទុកចិត្តរូបិយវត្ថុ រួមជាមួយនឹងការពិនិត្យចំណាយសាធារណៈ (IFAPER) របស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ ២០០៣

[2] ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទី 2 និងយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍កម្ពុជាប្រចាំសហស្សវត្សរ៍

[3] ចំណូលមិនមែនពន្ធពីវិស័យប្រៃសណីយ៍-ទូរគមនាគមន៍ ការដេញថ្លៃកូតា និងអាជ្ញាប័ណ្ណផ្នែកសំល្បែកបំពាក់ អាកាសចរណ៍ស៊ីវិល ពន្ធសួយសារ លើឈើហ៊ុប និងពន្ធផ្សេងៗ មានសារសំខាន់ជាពិសេសសំរាប់ប្រទេសកម្ពុជា ដែលបង្កើតបានជាចំណែកប្រមាណជា 29% នៃប្រាក់ចំណូលសរុប នៅឆ្នាំ 2002។ សម្ពាធចុះថយលើការប្រមូលចំណូលនឹងកើតមានក្នុងរយៈពេលខ្លី។ ឧទាហរណ៍ ប្រាក់ចំណូលពីការដេញថ្លៃកូតាសំល្បែកបំពាក់ នឹងត្រូវបញ្ចប់ ប្រសិនបើប្រព័ន្ធកូតាត្រូវបានកាត់ផ្តាច់នៅឆ្នាំ 2005 តាមការគ្រោងទុក ហើយការផ្តល់អាជ្ញាប័ណ្ណនាំចេញអាចនឹងត្រូវលុបបំបាត់។

[4] ចំពោះការពិនិត្យរកមើលគ្និតល្អន់នូវបញ្ហាចំណាយដែលផ្តល់ហិរញ្ញប្បទានពីបរទេស សូមអានជំពូក ២ នៃឯកសារ IFAPER

[5] ចាប់តាំងពីខែមករា ឆ្នាំ 2004 រាជរដ្ឋាភិបាលបានតំរូវអោយក្រសួងទាំងអស់អនុវត្តការដេញថ្លៃដោយ "ចំហ "(ការដេញថ្លៃដែលមានលក្ខណៈ ប្រកួតប្រជែង) ធៀបនឹងការធ្វើកិច្ចសន្យាដោយផ្ទាល់ (លើកលែងតែព្រះបរមរាជវាំងចេញ)

# ជំពូកទី ៣

## វិមជ្ឍការ : ជំរុញការផ្តល់សេវាប្រកបដោយគណនេយ្យកិច្ចសំរាប់អ្នកក្រ

១. វិមជ្ឍការនិងសហវិមជ្ឈការ ត្រូវបានរាជរដ្ឋាភិបាលមើលឃើញថា ជាសសរទ្រទ្រង់ ដល់ប្រជាធិប្បតេយ្យ និងការផ្តល់សេវាដ៏មាំទាំសំរាប់កាត់បន្ថយភាពក្រីក្រ ដូចដែលមានចែងក្នុងយុទ្ធសាស្ត្រចំបង៧របស់ខ្លួនដូចជាយុទ្ធសាស្ត្រចតុកោណ ។ វិមជ្ឍការសំដៅដល់ការប្រគល់អំណាច នយោបាយនិងរដ្ឋបាល ពីថ្នាក់កណ្តាលទៅឃុំ ។ សហវិមជ្ឈការសំដៅលើការប្រគល់ ការទទួលខុសត្រូវ ការធ្វើការសំរេចចិត្ត និងអំណាច ពីក្រសួងទៅមន្ទីរខេត្ត និង ការិយាល័យតាមស្រុក។

២. វិមជ្ឍការនិងសហវិមជ្ឈការ អាចកែលំអជីវិតប្រជាពលរដ្ឋទូទៅ ប្រសិនបើគេផ្តោតលើការផ្តល់សេវាអោយបានប្រសើរ ដោយជំរុញអោយមានការចូលរួម បំពងសំលេង និង បង្កើនតម្លាភាព ហើយជួយជំរុញអោយសង្វាក់គណនេយ្យកិច្ចកាន់តែខិតជិតគ្នា ពីសហគមន៍មូលដ្ឋាន ដល់រដ្ឋាភិបាល ។ ក៏ប៉ុន្តែ ការទទួលទាំងអស់ ពុំត្រូវបានគេធានានៅឡើយទេ ។ រដ្ឋអំណាចមូលដ្ឋាន អាចមិនត្រូវបានគេផ្តល់អំណាច អោយគ្រប់គ្រាន់មានការប្រឈមនឹងសមត្ថភាពទាប និង អាចទទួលឥទ្ធិពលពីក្រុមអភិជន ។

៣. រហូតមកដល់ពេលនេះ សហវិមជ្ឈការនៃមុខងាររដ្ឋមានការរីកចំរើនដ៏តិចតួចប៉ុណ្ណោះ ។ ក៏ប៉ុន្តែការបោះឆ្នោតនាខែកុម្ភៈ ឆ្នាំ២០០២ ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ១៦២១ សំគាល់នូវការចាប់ផ្តើមនៃដំណើរការឆ្ពោះទៅរកការងាកចេញពីទំរង់អភិបាលកិច្ចដែលកណ្តាលពេក ។ ការនេះមានការទទួលស្គាល់ ពីសហគមន៍ផ្តល់ជំនួយ ហើយការនេះ មានការទទួលឧបត្ថម្ភធន ដ៏សន្ធឹកសន្ធាប់ក្នុងរូបភាពជាជំនួយ និង កម្ចីបរទេស ។ ក៏ប៉ុន្តែ លទ្ធផលជាវិជ្ជមាននាពេលដំបូង និងចលនាការដែលបានបង្កើតឡើងនេះ នឹងត្រូវអស់ប្រសិទ្ធិភាពល្អិកណារដ្ឋាភិបាល មិនបញ្ជាក់អោយបានច្បាស់លាស់ពីទិសដៅទូលំទូលាយដែលខ្លួនកំពុងតែប្រកាន់យក ហើយនិង មិនបង្ហាញពីការប្តេជ្ញចិត្តអោយបានកាន់តែធំធេង ដើម្បីដោះស្រាយឧបសគ្គមួយចំនួនដែលបានកើតឡើងទេនោះ ។

៤. មុខនាទីនិងការទទួលខុសត្រូវរបស់ឃុំសង្កាត់ និង តួនាទីគាំទ្ររបស់អភិបាល និង រដ្ឋបាលខេត្ត ចាំបាច់ត្រូវបញ្ជាក់អោយបានច្បាស់ ។ តួនាទីខុសគ្នារវាងសង្កាត់និងឃុំ ចាំបាច់ត្រូវទទួលស្គាល់ ។

៥. ក្របខ័ណ្ឌគណនេយ្យកិច្ចចាំបាច់ត្រូវពង្រឹង ។ ផ្នែកបន្ទាប់ពីក្រសួង មានភាពខ្សោយជាងថ្នាក់ក្រសួងដែលស្ទាក់ស្ទើរនឹងអោយអំណាចរបស់ខ្លួនទៅថ្នាក់ក្រោមឆ្ងាយណាស់ ។ ប្រព័ន្ធផ្សេងៗ ដែលពាក់ពន្ធ័ ដូចជាផែនការដែលមានការចូលរួម ការផ្ទេរសារពើពន្ធ ការផ្តល់សេវា ហើយនិង គណនេយ្យកិច្ចទាំងក្នុង និង ក្រៅដោយរួមទាំងការធ្វើសវនកម្ម គឺនៅខ្សោយ ។ នៅផ្នែកសុខាភិបាល ជាឧទាហរណ៍ ការធ្វើសុខុដុម នីយកម្មរវាងផែនការ និង គំរោងថវិកា នៅខ្សោយ ការផ្តល់ថវិកា មិនអាចទាយទុកជាមុនបាន និង ការគ្រប់គ្រងហិរញ្ញវត្ថុកណ្តាលពេក នាំអោយមានការបាត់បង់ទឹកចិត្តដល់អ្នកនៅតាមខេត្តក្នុងការប្រឡូក នឹងការធ្វើផែនការពីថ្នាក់ក្រោម ។ មន្ត្រីឃុំសង្កាត់ត្រូវបាន បោះឆ្នោតសមាមាត្រ មានបញ្ជីគណបក្សជាមូលដ្ឋាន ដែលធ្វើអោយពួកគាត់ទទួលខុសត្រូវចំពោះមុខគណបក្សនយោបាយ ដែលជ្រើសរើសគាត់ ជាជាងប្រជាពលរដ្ឋដែលបោះឆ្នោតអោយ ។

៦. វិធានការ ក៏ចាំបាច់ដែរដើម្បីពង្រីកមូលដ្ឋានពន្ធដារដល់ឃុំ ដែលមានតិចតួច ។ ការនេះនឹងជួយបង្កើនគណនេយ្យភាព នៅពេលដែលអ្នកបង់ពន្ធនៅមូលដ្ឋាន នឹងអាចទាមទារសេវាកម្ម ពីអ្នកដែលដាក់ពន្ធលើពួកគាត់ ។

# ជំពូក៣: វិមជ្ឈការ: ជំរុញសេវាប្រកបដោយគណនេយ្យភាពសំរាប់អ្នកក្រីក្រ

៧. ប្រទេសកម្ពុជាកំពុងឈានទៅរកការពង្រឹងលទ្ធិប្រជាធិបតេយ្យដ៏ក្មេងខ្ចីរបស់ខ្លួនតាមរយៈការនាំមកនូវរដ្ឋាភិបាលដែលខិតទៅជិតជាមួយនឹងប្រជាជន ។ វិមជ្ឈការ និងសហវិមជ្ឈការត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍យុទ្ធសាស្ត្រចំបងរបស់រាជរដ្ឋាភិបាល រួមទាំងយុទ្ធសាស្ត្រចតុកោណ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងផែនការសកម្មភាពអភិបាលកិច្ច ដែលជាមធ្យោបាយធ្វើអោយប្រទេសប្រកាន់យកលទ្ធិប្រជាធិប-តេយ្យ និងកែលំអការផ្តត់ផ្គង់សេវានៅក្នុងតំបន់ ។ យុទ្ធសាស្ត្រ នេះត្រូវបានគេចាត់ទុកថាជាមូលដ្ឋានសំខាន់សំរាប់កាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍ជនបទ ហើយនិងផ្តល់អំណាចដល់ប្រ ជាជនសាមញ្ញក្នុងការសំរេចចិត្តលើអនាគតផ្ទាល់ខ្លួនរបស់ពួកគេ ។ ជំពូកនេះសិក្សាអំពីបទពិសោធន៍នៃវិមជ្ឈការរយៈពេល ២ឆ្នាំ ដំបូង វិភាគលើហានិភ័យ សក្តានុពល និងឱកាស ហើយគូសបញ្ជាក់អំពីសកម្មភាពសំខាន់ៗដែលត្រូវការចាំបាច់នាពេលបច្ចុប្បន្នដើម្បីធានា ថាវិមជ្ឈការបង្កើនការទទួលខុសត្រូវនិងសំលេងសំរាប់អ្នកក្រីក្រនៅក្នុងប្រទេសកម្ពុជា ។

៨. នៅក្នុងវចនានុក្រមអភិវឌ្ឍន៍របស់កម្ពុជា ពាក្យ "វិមជ្ឈការ" ត្រូវបានគេប្រើប្រាស់សំដៅលើការបែងចែកអំណាចរដ្ឋបាល និងនយោបាយទៅអោយថ្នាក់ឃុំ និងពាក្យ "សហវិមជ្ឈការ" សំដៅលើការបែងចែកការទទួលខុសត្រូវផ្នែករដ្ឋបាល ការធ្វើសេចក្តីសំរេចចិត្ត និងអំណាចពីក្រសួងសំខាន់ៗទៅអោយនាយកដ្ឋានខេត្តនិង/ឬការិយាល័យស្រុកថ្នាក់អនុជាតិ ។ មកដល់បច្ចុប្បន្ននេះ សហវិមជ្ឈការនៃមុខងាររដ្ឋផ្តល់ទៅអភិបាលខេត្តនិងកំណែទំរង់ពាក់ព័ន្ធ ផ្តោតសំខាន់ទៅលើខេត្តនិងស្រុក ដែលចាត់ទុកថាជាថ្នាក់អនុជាតិសំរាប់រៀបចំថវិកាផែនការហិរញ្ញវត្ថុ និងរដ្ឋបាល នៅមានការរីកចំរើនតិចតួចណាស់ ។ ក៏ប៉ុន្តែតាមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់កាលពីខែ កុម្ភៈ ឆ្នាំ២០០២ កម្ពុជាបានចាប់ផ្តើម ដំណើរការកែប្រែទំរង់អភិបាលកិច្ចកណ្តាលរបស់ខ្លួន ដោយផ្តល់អំណាចអោយមន្ត្រីមូលដ្ឋានដែលជាប់ឆ្នោតថ្មីចំនួន ១១.២៦១នាក់ អោយទទួលខុសត្រូវតួនាទីសំខាន់ៗមួយចំនួន រួមមានការធ្វើផែនការអភិវឌ្ឍន៍ឃុំ បង្កើតនិងអនុវត្ត គំរោងអភិវឌ្ឍន៍មូលដ្ឋានទ្រង់ទ្រាយតូចដែល ផ្តោតជាដំបូងលើការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈទ្រង់ទ្រាយតូច ដូចជាផ្លូវក្នុងភូមិ និងការចុះបញ្ជីអត្រានុកូលដ្ឋាន ។ ជាជំហានដំបូងនៅក្នុងទិសដៅថ្មីដែលឈានទៅរកវិមជ្ឈការ

មានលក្ខណៈទូលំទូលាយនេះ ត្រូវបានគាំទ្រយ៉ាងខ្លាំងក្លាពីសហគមន៍ផ្តល់ជំនួយ និងទទួលបានការឧបត្ថម្ភយ៉ាងច្រើន តាមរយៈជំនួយបរទេស និង ហិរញ្ញប្បទាន។ រហូតដល់បច្ចុប្បន្ននេះ មានការរីកចំរើនគួរអោយកត់សំគាល់មួយចំនួន តែក៏នៅមានទិដ្ឋភាពសំខាន់មួយចំនួនដែលមានសភាពរីកចំរើនយឺតយ៉ាវយ៉ាងធ្ងន់ធ្ងរ ។ ក៏ប៉ុន្តែ ការធ្វើសហវិមជ្ឈការ និង វិមជ្ឈការត្រូវការរយៈពេលវែង។ នៅមានជំរើសគោលនយោបាយពិបាកៗជាច្រើនទៀតរង់ចាំ ។ បទពិសោធន៍ជាសកល បានបង្ហាញថាការយល់ដឹងអំពីអត្ថប្រយោជន៍សក្តានុពលនៃវិមជ្ឈការនឹងពឹងផ្អែកយ៉ាងច្រើនថាតើគេជ្រើសរើសជំរើស សំរាប់អនាគតបានល្អយ៉ាងដូចម្តេច។

៩. រាជរដ្ឋាភិបាលយល់ដឹងអំពីតំរូវការបន្ទាន់ក្នុងការបង្កើតនូវការស្រុះស្រួលមតិគ្នាជាទូទៅមួយជុំវិញចក្ខុវិស័យនៃវិមជ្ឈការ និងសហវិមជ្ឈការ និងការអនុវត្តនៃចក្ខុវិស័យនេះបានចាប់ផ្តើមនាពេលថ្មីៗ ដែលដឹកនាំដោយក្រុមការងារអន្តរក្រសួង មួយដែលតែងតាំងដោយនាយករដ្ឋមន្ត្រី ។ ក្នុងការដែលគ្មានចក្ខុវិស័យរួមនេះក៏គ្មានយុទ្ធសាស្ត្រដើម្បីប្រែក្លាយចក្ខុវិស័យនេះអោយទៅជាសកម្មភាព និងលទ្ធផលនៅថ្នាក់មូលដ្ឋាន។ ដូចគ្នានេះដែរ ការសំរបសំរួល ពីម្ចាស់ជំនួយនៅក្នុងផ្នែកនេះពុំសូវមានការពេញចិត្តប៉ុន្មានទេ ហើយការណែនាំរបស់ម្ចាស់ជំនួយ ចំពោះដំណើរការជូនកាល មានលក្ខណៈផ្ទុយ។

## ក ការចាប់ផ្តើម

១០. សហវិមជ្ឈការនិងវិមជ្ឈការនៅក្នុងប្រទេសកម្ពុជាមានសក្តានុពលធ្វើអោយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសាមញ្ញមានភាពប្រសើរជាងមុន ប្រសិនបើគេផ្តោតការយកចិត្តទុកដាក់ក្នុងការសំរេចអោយបាននូវការផ្គង់ផ្គង់សេវាដែលមានប្រសិទ្ធិភាពខ្ពស់បំផុត និងកាត់បន្ថយអំពើពុករលួយនិងការខាតបង់ ។ ជាក់លាក់ជាងនេះទៀត ដោយមើលឃើញការគ្រប់គ្រងដំណើរការដ៏ល្អ គេមើលឃើញសក្តានុពលក្នុងការកែលំអអភិបាលកិច្ច និងការផ្គត់ផ្គង់សេវាតាមរយៈការបង្កើនកំរិតនៃការចូលរួមសំខាន់ៗ ហើយនិងពង្រឹងសំលេងរបស់ប្រជាជនក្នុងសហគមន៍មូលដ្ឋាននៅក្នុងការសំរេចចិត្តដែលប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ តាមរយៈការបង្កើនតម្លាភាពលើគ្រប់ទិដ្ឋភាពនៃសកម្មភាពរបស់រដ្ឋាភិបាល តាមរយៈការធ្វើអោយប្រជាជនក្នុងសហគមន៍ មូលដ្ឋានមានលទ្ធភាពអាចពិនិត្យតាមដានកាន់តែប្រសើរលើការប្រតិបត្តិរបស់រដ្ឋាភិបាល និងតាមរយៈការកាត់បំព្រួញចង្វាក់

នៃការទទួលខុសត្រូវពីសហគមន៍មូលដ្ឋានដល់រដ្ឋាភិបាល ដើម្បីធ្វើអោយការបោះឆ្នោតនៅមូលដ្ឋានមានសារៈសំខាន់ និងផ្តល់នូវការលើកទឹកចិត្តដ៏ខ្លាំងក្លាសំរាប់អាជ្ញាធរមូលដ្ឋានអោយប្រតិបត្តិការងារបានល្អប្រសើរ។

១១. អត្ថប្រយោជន៍សក្តានុពលដែលបានពីវិមជ្ឈការពិតជាមិនត្រូវបានធានា។ មានការលំបាកដែលអាចកើតឡើងជាច្រើន ។ អាជ្ញាធរមូលដ្ឋានប្រហែលជាគ្មានអំណាចពេញលេញមានសមត្ថភាព ឬមូលនិធិពុំគ្រប់គ្រាន់ដើម្បីប្រើប្រាស់នូវឯករាជ្យ ភាពដែលពួកគេសង្ឃឹមថាត្រូវមានតាមរយៈការបោះឆ្នោត ។ អាជ្ញាធរមូលដ្ឋានក៏អាចទំនងជា "មិនអើពើ" ឬក៏ទំនងជាឋិតនៅក្រោម អំណាចរបស់ក្រុមដែលមានអត្ថប្រយោជន៍ពិសេសនៅក្នុងមូលដ្ឋាន ដូចជាអត្ថប្រយោជន៍ពាណិជ្ជកម្ម ។ ដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តដែលមិនអនុញ្ញាតអោយមានការចូលរួមសំខាន់ៗ អាចពង្រីង និន្នាការទាំងនេះបាន ។ ចុងបញ្ចប់ព័ត៌មាន ដែលអាចទុកចិត្តបានស្តីអំពីការប្រតិបត្តិរបស់អាជ្ញាធរមូលដ្ឋាន អាចមានការខ្វះខាត ធ្វើអោយរាំងស្ទះដល់អ្នកបោះឆ្នោត នៅក្នុងការពិនិត្យតាមដានអាជ្ញាធរមូលដ្ឋានរបស់ពួកគេ ។ ហើយបើទោះជាមានពត៌មានក៏ដោយ ក៏អ្នកបោះឆ្នោតនៅមូលដ្ឋាន ប្រហែលគ្មានមធ្យោបាយផ្លូវច្បាប់ឬនយោបាយ ដើម្បីដាក់ទោសមន្ត្រីអាជ្ញាធរមូលដ្ឋានទាំងនោះពីបទអំពើពុករលួយឬការប្រតិបត្តិមិនល្អនោះទេ។

## *ការចាប់ផ្តើមក្នុងការពិសោធនៅមូលដ្ឋាន*

១២. នៅពេលដែលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់កាលពីខែ កុម្ភៈ ឆ្នាំ២០០២ បានបង្កើតនូវអាជ្ញាធរមូលដ្ឋានដោយការបោះឆ្នោតលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រថ្មីរបស់ប្រទេសកម្ពុជា ។ ទាំងនៅខេត្ត/ក្រុង និងឃុំ/សង្កាត់ គឺជាកំរិតរដ្ឋបាលនៅក្នុងប្រទេសជាយូរមកហើយ ។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ របស់ព្រះរាជាណាចក្រកម្ពុជាបានចែងខេត្តនិងក្រុងថា ជាអនុតំបន់លំដាប់ទីមួយរបស់ប្រទេស ។ ក្រុងគឺជាដែនដី មានកំរិតស្មើនឹងខេត្តនៅក្នុងតំបន់ទីក្រុងដែលបាន ជ្រើសរើស ។ បច្ចុប្បន្នកម្ពុជាមានខេត្តចំនួន២០ និងក្រុងចំនួន៤ (ក្រុងភ្នំពេញ កែប ប៉ៃលិន និងព្រះសីហនុ)។ ខេត្តចែកចេញជាស្រុក និងឃុំបន្តទៀត ហើយក្រុងចែកចេញជាខ័ណ្ឌនិងសង្កាត់ ។ នៅទូទាំង ប្រទេសមានឃុំ ចំនួន១៥១០ និង១១១សង្កាត់ ។ នៅក្នុងតំបន់ជនបទនិងក្នុងទីក្រុងមានភូមិដូចគ្នា។

១៣. នៅទូទាំងខេត្ត/ក្រុងមានបរិមាណខុសគ្នាច្រើនទាំងលើប្រជាជន និងផ្ទៃដីរបស់អនុតំបន់រដ្ឋបាលកំរិតទីពីរនិងកំរិតទីបី ។ ចំនួនស្រុកមានពី ៥ នៅក្នុង ខេត្តមណ្ឌលគីរី ទៅ ១៦ នៅក្នុងខេត្តកំពង់ចាម ។ ចំនួនឃុំមានពី ២១ នៅក្នុងខេត្តមណ្ឌលគីរី ទៅ១៧៣ នៅក្នុងខេត្តកំពង់ចាម។ ចំនួនប្រជាជនគិតជាមធ្យមនៅក្នុងឃុំ/សង្កាត់មានចំនួនប្រហែល ៨.០០០ នាក់ ។ ក៏ប៉ុន្តែ ចំនួននេះប្រែប្រួលគួរអោយកត់សំគាល់។ ក្រៅពីនេះ នៅក្នុងខេត្តដាច់ស្រយាល និងមានប្រជាជនរស់នៅតិច ដូចជាខេត្តរតនៈគីរី ផ្ទៃដីភូមិសាស្ត្ររបស់ខេត្តអាចមានទំហំធំគួរសម ។ ដោយសារតែលទ្ធផលនៃបំរែបំរួលដ៏ច្រើននេះ និងបញ្ហាប្រឈមដែលទាក់ទងដែលបង្ហាញអោយឃើញអំពីប្រតិបត្តិការដែលមានប្រសិទ្ធិភាពរបស់ឃុំ ព្រំដែនរបស់ឃុំនឹងត្រូវបានគេពិនិត្យសើរើឡើងវិញ ហើយអាចត្រូវបានគេកែសំរួល ឡើងវិញមុនការបោះឆ្នោតជ្រើសរើសអាជ្ញាធរមូលដ្ឋានលើកទីពីរសំរាប់ឆ្នាំ២០០៧។

១៤. នៅក្នុងកំឡុងពេលនៃការកសាងប្រទេសក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ដែលបន្តពីសង្គ្រាមស៊ីវិលអស់រយៈពេលជាច្រើនទសវត្សរ៍ រាជរដ្ឋាភិបាលបានគ្រប់គ្រងខេត្តទាំងអស់ ដោយបង្ហាញហេតុផលថាធ្វើ ដើម្បីហេតុផលសន្តិសុខជាតិ ដោយដាក់កំហិតនូវកំរិតនៃឯករាជ្យភាពដល់ខេត្តនានា ដែលធ្លាប់មានក្នុងកំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ និងទសវត្សរ៍ឆ្នាំ១៩៨០ ។ ពីដំបូងអភិបាលខេត្តក្រុងត្រូវរាយការណ៍ ដោយផ្ទាល់ទៅនាយករដ្ឋមន្ត្រី និង មានអំណាចសំរេចចិត្តសំខាន់ៗនៅថ្នាក់ខេត្តក្រុង ប៉ុន្តែបន្ទាប់ពីឆ្នាំ ១៩៩៣ មានការកែទំរង់នយោបាយ និងសាពើព័ន្ធ មានការគ្រប់គ្រងនៅថ្នាក់មជ្ឈឹមឡើងវិញ និងកាត់បន្ថយអំណាច របស់អភិបាលខេត្តក្រុង ដោយដាក់នៅក្រោមក្រសួងមហាផ្ទៃវិញ ។ ក៏ប៉ុន្តែ នៅពេលដែលមានស្ថេរភាពជាតិ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ ឡើងវិញពីសន្តិសុខផ្ទៃក្នុងទៅការអភិវឌ្ឍ ហើយមេដឹកនាំរបស់ ប្រទេសបានទទួលស្គាល់យ៉ាងឆាប់រហ័សនូវតួនាទីសំខាន់ ដែលប្រកបដោយសក្តានុពលរបស់ខេត្តនិងឃុំក្នុងការផ្គត់ផ្គង់សេវា ព្រមទាំងបានបង្កើនអំណាចនិងការទទួលខុសត្រូវ បន្តិចម្តងៗនៅថ្នាក់អនុជាតិ។

១៥. រាជរដ្ឋាភិបាលបានផ្តល់អំណាចដល់ក្រសួងអភិវឌ្ឍន៍ជនបទ[១] ដើម្បីបង្កើតរចនាសម្ព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ជនបទ សំរាប់ប្រទេសដែលមានអង្គភាពមួយនៅគ្រប់លំដាប់ថ្នាក់អនុតំបន់ៈ គណៈកម្មាធិការ

អភិវឌ្ឍន៍ជនបទខេត្ត (PRDC) គណៈកម្មាធិការអភិវឌ្ឍន៍ស្រុក (DDC) គណៈកម្មាធិការអភិវឌ្ឍន៍ឃុំ (CDC) និងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (VDCs)។ កម្មវិធីនិងគំរោងអភិវឌ្ឍន៍ជនបទដែលគាំទ្រ ដោយម្ចាស់ជំនួយនិងអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានធ្វើការ នៅក្នុងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទទាំងនេះ ចាប់តាំងពីបានបង្កើតគណៈកម្មាធិការទាំងនេះមក ។ ក្រសួងអភិវឌ្ឍន៍ជនបទ បានផ្តោតការយកចិត្តទុកដាក់ជាបឋមលើថ្នាក់ភូមិដែល VDCs ត្រូវបានបង្កើតឡើងនៅក្នុងភូមិចំនួនប្រហែល ៨០០០ តាមរយៈការបោះឆ្នោតដោយចំហ។ ផែនការនិងសកម្មភាពអភិវឌ្ឍន៍នានារបស់ VDCsទាំងនេះ ត្រូវបានគាំទ្រដោយគំរោងដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយនិងអង្គការក្រៅរដ្ឋាភិបាលជាច្រើន ដោយរួមសហការជាមួយក្រសួង និងនាយកដ្ឋានអភិវឌ្ឍន៍ជនបទខេត្ត (PDRD)។

១៦. នៅថ្នាក់ឃុំ សកម្មភាពដែលផ្តល់មូលនិធិច្រើនបំផុតដោយម្ចាស់ជំនួយនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនិងអភិវឌ្ឍន៍ជនបទគឺជាកម្មវិធីសិលា ។ ដំបូង ភូមិគឺជាគោលដៅសំខាន់សំរាប់ផែនការអនុឃុំក្រោមកម្មវិធីសិលា ក៏ប៉ុន្តែក្រោយមកត្រូវបានគេបោះបង់ចោលទៅគាំទ្រថ្នាក់ឃុំ ពីព្រោះគេគិតថាផែនការថ្នាក់ភូមិមិនអាចចំលងតាមបានទូទាំងប្រទេសទេ ហើយដោយសារតែឃុំវាតំណាងអោយលំដាប់ថ្នាក់រដ្ឋបាលទាបបំផុត ។ ដំណាក់កាលទីមួយរបស់កម្មវិធីសិលា (១៩៩៦-២០០១)បានធ្វើការជាមួយ PRDC និង CDC (ដែលបង្កើតឡើងដោយតំណាងរបស់ VDCs)នៅក្នុងខេត្ត[២] តូចៗមួយចំនួន និងបានបង្ហាញអំពីគំរូសំរាប់ធ្វើផែនការវិមជ្ឈការហិរញ្ញប្បទាន និងការគ្រប់គ្រងសកម្មភាពអភិវឌ្ឍន៍នៅថ្នាក់ឃុំនិងខេត្ត។ មេរៀនដែលទទួលបានពីបទពិសោធន៍របស់កម្មវិធីសិលាបានធ្វើអោយមានកំណែទំរង់វិមជ្ឈការយ៉ាងច្រើន ដែលបង្ហាញអោយឃើញថា "គ្រាប់ពូជនៃវិមជ្ឈការអាចដុះនៅលើទឹកដីកម្ពុជាហើយ" ។

១៧. តាមការពិត វិមជ្ឈការមានការរីកចំរើនលឿនជាងវិសហមជ្ឈការ ដោយប្រើវិធីសាស្ត្របន្ថែមមួយ ។ រហូតមក ដល់បច្ចុប្បន្ននេះ កត្តាសំខាន់នៃកំណែទំរង់វិមជ្ឈការបានផ្តោតការយកចិត្តទុកដាក់លើការបែងចែកអំណាចនយោបាយទៅអោយអាជ្ញាធរមូលដ្ឋានដែលបានជាប់ឆ្នោតថ្មីពាក់កណ្តាលស្វ័យប្រវត្តិ គឺក្រុមប្រឹក្សាឃុំ/សង្កាត់ (C/SC) ដែលជា ក្រុមប្រឹក្សាបង្កើតឡើងដំបូងមានការទទួលខុសត្រូវចំពោះរដ្ឋបាលនិងការអភិវឌ្ឍ

មូលដ្ឋានទៅតាមសមត្ថភាពដែលបច្ចុប្បន្ននៅមានកំរិតរបស់ពួកគេ ក៏ដូចជាការបង្កើតឡើងនូវប្រព័ន្ធផ្ទេរហិរញ្ញវត្ថុរបស់អន្តររដ្ឋាភិបាលនៅថ្នាក់ជាតិ ដូចជាមូលនិធិឃុំ/សង្កាត់ (C/SF) ដើម្បីគាំទ្រដល់ការអនុវត្តការងារទទួលខុសត្រូវដំបូងទាំងនេះ ។

១៨. ក៏ប៉ុន្តែ នៅថ្នាក់ខេត្ត រហូតមកដល់បច្ចុប្បន្នមានការរីកចំរើនពិតប្រាកដតិចតួចលើសហាវិមជ្ឈការនៃអំណាចរដ្ឋបាល និងមុខងាររបស់អភិបាលខេត្ត និងរដ្ឋបាលស្រុកនិងខេត្ត ។ មានការពិសោធច្រើននៅថ្នាក់ខេត្តទាំងក្នុងគំរោងថវិកា (បង្កើនល្បឿននៃការអភិវឌ្ឍស្រុក (ADD) និងកម្មវិធីសកម្មភាពអាទិភាព (APP)) និងទាំងក្រៅគំរោងថវិកា (មូលនិធិវិនិយោគខេត្ត (PIF) និងការគាំទ្រការអភិវឌ្ឍកសិកម្មដល់សិលា (ADESS)) ។ ក៏ប៉ុន្តែ ការសាកល្បង ទាំងនេះមិនទាន់បានឈានដល់វិធីសាស្ត្ររួមមួយសំរាប់ការធ្វើសហាវិមជ្ឈការទេ ។

១៩. ទំរង់នៃវិសហាមជ្ឈការដែលមានលក្ខណៈ "ទន់ខ្សោយ" ដូចជាការផ្ទេរការទទួលខុសត្រូវនិងមុខងារពីក្រសួង សំខាន់ៗទៅអោយ ការិយាល័យថ្នាក់អនុជាតិរបស់ខ្លួន កំពុងត្រូវបានសាកល្បងដោយក្រសួងជាច្រើនដោយប្រើប្រាស់ គំរូមួយចំនួនដែលមានលក្ខណៈផ្សេងៗគ្នា និងមិនស៊ីសង្វាក់គ្នាទាំងស្រុង (ឧទាហរណ៍ ADD PAP ADESS) ។ ក៏ប៉ុន្តែ ការវិភាគទៅលើគុណសម្បត្តិ និងគុណវិបត្តិ របស់វិធីសាស្ត្រផ្សេងៗនៅមិនទាន់បានធ្វើនៅឡើយ ហើយវា នឹងជាធនធានដ៏សំខាន់មួយសំរាប់ក្របខ័ណ្ឌវិសហាមជ្ឈការ ។ ទំរង់សហាវិមជ្ឈការដែលមានលក្ខណៈ "រឹងមាំ" ផ្តល់អោយរដ្ឋបាលខេត្ត/ក្រុងនូវជំរើសក្នុងការបែងចែកធនធានថវិកាខេត្តទៅអោយនាយកដ្ឋានផ្សេងៗតាមវិស័យ ដើរតួនាទីអោយបានទូលាយនៅក្នុងការគ្រប់គ្រងបុគ្គលិក និងប្រើប្រាស់បែបនៃការផ្គត់ផ្គង់សេវាផ្សេងៗគ្នាមួយចំនួនសមស្របតាមលក្ខ័ណ្ឌនៅមូលដ្ឋាន និងបង្កើនប្រាក់ចំណូលពីប្រភពរបស់ខ្លួន ក៏ត្រូវបានសាកល្បងផងដែរក្នុងកំរិតមួយ តាមវិធីសាស្ត្រប្រើប្រាស់ថវិកាក្រៅគំរោងក្រោមកម្មវិធីសិលា តាមរយៈមូលនិធិវិនិយោគខេត្ត ។

## ខ ឆ្ពោះទៅរកយុទ្ធសាស្ត្រ និងទស្សនៈវិស័យយូរអង្វែង

២០. វិធីសាស្ត្របន្ថែមដែលកម្ពុជាបានកំណត់យកសំរាប់ការធ្វើវិមជ្ឈការបានអនុញ្ញាតិអោយគេទាញយកនូវមេរៀននៃបទពិសោធន៍ ចាប់យកឱកាសនយោបាយ និងសំរេចបាននូវសមិទ្ធិផលសំខាន់ៗនៅក្នុងវិស័យមួយចំនួន ។ ក៏ប៉ុន្តែ ភាពការិតកំណត់នៃវិធីសាស្ត្របន្ថែមដែលមានសារៈសំខាន់នេះ គឺកំពុងតែខិតយ៉ាងលឿនមកជិតហើយ ។ ជំហានបណ្តោះអាសន្នដំបូងឆ្ពោះទៅរកការធ្វើវិមជ្ឈការ រហូតមកដល់ពេលនេះ ត្រូវអនុវត្តតាមកំណែទំរង់ហិរញ្ញវត្ថុរដ្ឋបាល និង នយោបាយដែលនឹងពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោម និងលើកកំពស់សមត្ថភាពរបស់ឃុំដើម្បី កាត់បន្ថយភាពក្រីក្រ និងផ្គត់ផ្គង់សេវាអោយបានល្អប្រសើរ ។ គេមើលឃើញថាគ្មានភាពច្បាស់លាស់ផងដែរលើការិតនៃសហវិមជ្ឈការ ។ ការផ្លាស់ប្តូរនៅក្នុងក្របខ័ណ្ឌនយោបាយ និងច្បាប់មានភាពចាំបាច់ដើម្បីដាក់ទិសដៅបំពេញការងារអោយបានល្អប្រសើរ និងផ្តល់អំណាចពេញលេញដល់សហគមន៍មូលដ្ឋាន ។

២១. ដើម្បីផ្លាស់ប្តូរគោលនយោបាយ និងនិយ័តកម្មដែលចាំបាច់ កម្ពុជាចាំបាច់ត្រូវអភិវឌ្ឍចក្ខុវិស័យរយៈពេលវែងមួយសំរាប់អភិបាលកិច្ចនៅថ្នាក់អនុជាតិ ដោយផ្អែកលើដំណើរការពិគ្រោះយោបល់ជាន់ខ្ពស់មួយ ដែលមានរបៀបវារៈទូលំទូលាយ ពីគោលនយោបាយ ហិរញ្ញវត្ថុ និងការធ្វើវិមជ្ឈការនិងវិសហមជ្ឈការរដ្ឋបាល ។ ការពង្រឹងអភិបាលកិច្ចនៅថ្នាក់ខេត្ត ស្រុក និងអ្នកផ្តល់សេវាគឺមានភាពសំខាន់ជាក់លាក់ ណាស់សំរាប់ការផ្តល់សេវាសុខាភិបាល អប់រំ និងអាហារូបត្ថម្ភ ។ លំហាត់ ប្រឹក្សាយោបល់ដែលទាញចេញពីមេរៀនដំបូងរយៈពេលពីរឆ្នាំ និងពីគំនិតផ្តួចផ្តើមសាកល្បងលើវិសហមជ្ឈការនឹងមិនត្រឹមតែជួយដល់ការអភិវឌ្ឍទិសដៅយូរអង្វែងប៉ុណ្ណោះទេ តែបានអនុញ្ញាតអោយមានការកែសំរួលនៅពាក់កណ្តាលពេលនៃការអនុវត្ត ការបញ្ជាក់ឡើងវិញពីការទទួលខុសត្រូវនិងមុខងារ ហើយស្វែងរកនូវក្របខ័ណ្ឌច្បាប់និងគោលនយោបាយ ដែលត្រូវការដើម្បីធានានូវការរីកចំរើនឆ្ពោះទៅរកទិសដៅយូរអង្វែង ។ យោលលើលក្ខណៈវិនិច្ឆ័យនៃគំនិតផ្តួចផ្តើម ដែលបានបញ្ជាក់ក្នុងវិស័យនេះ គឺត្រូវការរបៀបវារៈមួយដែលមានរយៈពេលវែង ។ ក៏ប៉ុន្តែ វាមានសារៈសំខាន់ដើម្បី

ធានាថា ការផ្លាស់ប្តូរក្របខ័ណ្ឌនយោបាយនិងច្បាប់ពីរយៈ ពេលខ្លីទៅមធ្យមត្រូវបានកំណត់ដោយចក្ខុវិស័យរួមសំរាប់ទិសដៅ អនាគតដែលកម្ពុជាត្រូវការក្នុងរយៈពេលវែង ។

២២. ដើម្បីបញ្ជាក់អោយបានច្បាស់លើចក្ខុវិស័យរយៈពេលវែងនិងយុទ្ធសាស្ត្រពាក់ព័ន្ធ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារ អន្តរក្រសួងមួយដើម្បីបង្កើតក្របខ័ណ្ឌយុទ្ធសាស្ត្រផែនការសកម្មភាព និងកម្មវិធីជំនួយឧបត្ថម្ភរបស់ម្ចាស់ជំនួយដែលពាក់ព័ន្ធសំរាប់វិមជ្ឈការនិងវិសហមជ្ឈការអោយបានមុនខែ មេសា ឆ្នាំ២០០៥ ។ ប្រធានក្រុមការងាររួមរវាង រដ្ឋាភិបាល និងម្ចាស់ជំនួយ និង អគ្គលេខាធិកាក្រុមការងាររបស់សិលាធ្វើជាប្រធានក្រុមការងារនេះ ហើយជាអគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយមានតំណាងសមាជិកមួយចំនួនមកពីក្រសួងមហាផ្ទៃ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផែនការ កិច្ចការនារី និងអតីតយុទ្ធជន ព្រមទាំងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។ ក្រុមការងារនេះ គាំទ្រដោយ ក្រុមពិគ្រោះយោបល់របស់ម្ចាស់ជំនួយជាច្រើន ក៏ដូចជាគាំទ្រដោយក្រុមគាំទ្របច្ចេកទេសដែល មានទីប្រឹក្សា បច្ចេកទេសនៅក្នុងប្រទេស ។ ចក្ខុវិស័យរយៈពេលវែង ចាំបាច់ត្រូវតែបញ្ជាក់អោយបានច្បាស់លើបញ្ហាសំខាន់ៗ ដូចជាការបែងចែកមុខងាររវាងមជ្ឈឹម និងតំបន់ រួមទាំងតួនាទីរបស់ខេត្តនិងស្រុក ការតែងតាំងមុខងារសមស្រប សំរាប់ឃុំ/សង្កាត់ ទាំងអណត្តិរបស់ខ្លួននិងមុខងាររបស់ទីភ្នាក់ងារ ដោយការទទួលស្គាល់ភាពខុសគ្នារវាងតំបន់ជនបទ និង ទីក្រុង ។

## *ការចាត់តាំងមុខងារនៅថ្នាក់អនុជាតិខាងទារអោយមានភាពច្បាស់លាស់*

២៣. *ច្បាប់ស្តីអំពីការគ្រប់គ្រងនិងរដ្ឋបាលឃុំ/សង្កាត់* (ច្បាប់វិមជ្ឈការ) និង *ច្បាប់ស្តីអំពីការបោះឆ្នោតឃុំ/សង្កាត់* ដែលជាក្របខ័ណ្ឌច្បាប់មូលដ្ឋានសំរាប់ធ្វើកំណែទំរង់វិមជ្ឈការ ត្រូវបានអនុម័តទាំងពីនៅក្នុងឆ្នាំ ២០០១ ។ ច្បាប់ទាំងពីរនេះកំណត់ អំពីរចនាសម្ព័ន្ធមូលដ្ឋានរបស់ប្រព័ន្ធៈ រចនាសម្ព័ន្ធនិងការទទួលខុសត្រូវរួមរបស់ក្រុមប្រឹក្សាឃុំនិងសង្កាត់ លក្ខន្តិកៈចំពោះការឈរឈ្មោះបោះឆ្នោតឃុំ/សង្កាត់ និងនិតិវិធីចំពោះការបោះឆ្នោតឃុំនិងសង្កាត់ ។ ក៏ប៉ុន្តែ ច្បាប់និងនិយ័តកម្មវិមជ្ឈការ រហូតមកដល់ពេលនេះ ពុំទាន់បានផ្តល់នូវសេចក្តីលំអិតគ្រប់គ្រាន់សំរាប់ការអនុវត្តប្រព័ន្ធនេះអោយបានពេញលេញនៅឡើយនោះទេ ។

២៤. គណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ (NCSC) ដែលជាគណៈកម្មាធិការអន្តរក្រសួងមួយដែលមានក្រសួងមហាផ្ទៃធ្វើជាប្រធាន កំពុងពិនិត្យមើលភាពពេញលេញនៃក្របខ័ណ្ឌនិយ័តកម្ម និងការអនុវត្តដំបូងនៃកំណែទំរង់វិមជ្ឈការ មុនការបោះឆ្នោតឃុំ/សង្កាត់លើកទីពីរដែលគ្រោងធ្វើនៅឆ្នាំ២០០៧ ។ NCSC សំរេចបានសមិទ្ធិផលគួរអោយកត់សំគាល់មុនការបោះឆ្នោត ក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២០០២ ក្នុងការបង្កើតនិងកែលំអអនុក្រិត្យ សេចក្តីប្រកាស និងបានពិភាក្សាលំអិតអំពីគោល ការណ៍ណែនាំសំរាប់ធ្វើផែនការ ហិរញ្ញវត្ថុ និងការគ្រប់គ្រងសំរាប់ C/SC និង C/SF ។ ក៏ប៉ុន្តែ ចាប់តាំងពីពេលនោះមក ការរីកចំរើនមានកំរិត ។ ក្របខ័ណ្ឌច្បាប់សំរាប់វិមជ្ឈការ និងនិយ័តកម្មគាំទ្រ និងគោលការណ៍ណែនាំដែលកំពុងប្រតិបត្តិ នៅមិនទាន់បានបញ្ចប់នៅឡើយ ឬក៏ទាមទារអោយពិនិត្យសើរើឡើងវិញ និងកែតំរូវក្នុងពេលឥឡូវនេះ ដោយយោងលើបទពិសោធន៍ក្នុងការអនុវត្តលើកដំបូង ។

២៥. ច្បាប់វិមជ្ឈការមិនបានផ្តល់អំណាចដល់ C/SCs ទេ។ វាគ្រាន់តែផ្តល់នូវក្របខ័ណ្ឌរួមមួយអាស្រ័យលើការត្រួតពិនិត្យ និងការគាំទ្រយ៉ាងច្រើនពីថ្នាក់លើ ហើយដែល C/SCs ត្រូវបានគេផ្តល់អំណាចអោយដើម្បីរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គ្រប់គ្រងសេវាសាធារណៈតាមចំនួនកំរិត "លើកកំពស់សុខមាលភាពសាធារណៈ" "ជំរុញការអភិវឌ្ឍ" និងបំពេញកាតព្វកិច្ចដ៏ទៃផ្សេងទៀត។ មកទល់បច្ចុប្បន្ននេះ C/SCs បានផ្តល់នូវ គំរោងហេដ្ឋានរចនាសម្ព័ន្ធទ្រង់ទ្រាយតូចយ៉ាងច្រើន ដូចជា ផ្លូវនៅតាមមូលដ្ឋាន លូទឹកក្រោមដីនិងស្ពាន ប្រលាយទឹក និងការផ្គត់ផ្គង់ទឹក ។ ក្រៅពីនេះ ច្បាប់នេះផ្តល់មុខងារដែល ឃុំ/សង្កាត់ អាចប្រតិបត្តិជួសមុខអោយក្រសួង និងនាយកដ្ឋានខេត្ត/ក្រុងទាំងអស់តាមសំណើ ប្រសិនបើ កំរិតនៃមូលនិធិសមរម្យមួយត្រូវបានផ្តល់អោយ C/SC ដើម្បីបំពេញតួនាទីនេះ ។ បច្ចុប្បន្ន មុខងារដែលបានតែងតាំងនេះនៅមានកំរិត ហើយទំនងជាបន្តនៅបែបនេះសំរាប់រយៈពេលពីខ្លីទៅមធ្យម ។ ក៏ប៉ុន្តែ មានសំណើពិសេសមួយចំនួនកំពុងត្រូវបានដាក់ស្នើឡើងសំរាប់មុខងារបន្ថែមនៅក្នុង C/SC ។ សំណើទាំងនេះចាំបាច់ត្រូវពិចារណាអោយបានហ្មត់ចត់នៅក្នុងបរិបទទូលំទូលាយ លើតួនាទីសមរម្យ សំរាប់ C/SC និងសមត្ថភាពរបស់ពួកគេ ។

២៦. មានទិដ្ឋភាពពីរផ្សេងគ្នា ប៉ុន្តែទាក់ទងគ្នា ចំពោះសហវិមជ្ឈការនៃមុខងារ និង អំណាចរដ្ឋបាល។ ទិដ្ឋភាពទាំងពីរនេះ ទីមួយពាក់ព័ន្ធទៅនឹងតួនាទីរបស់អភិបាល និងរដ្ឋបាលខេត្តនិងស្រុក ក្នុងការផ្តល់នូវការគាំទ្រដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងទីពីរ ក្នុងការចែកចាយសេវាកម្មតាមវិស័យនៅថ្នាក់ខេត្តនិងថ្នាក់ក្រោម តាមរយៈមន្ទីរខេត្ត និងការិយាល័យស្រុករបស់ក្រសួង។

២៧. តួនាទីគាំទ្ររបស់អភិបាលចំពោះ C/SC ត្រូវបានកំណត់ច្បាស់ដោយ NCSC ក្នុងក្របខ័ណ្ឌ[៣] និយ័តកម្មវិមជ្ឈការ ។ ការណែនាំរបស់ក្រុមការងារសិលាក៏ផ្តល់នូវការរៀបចំបណ្តោះអាសន្នផងដែរសំរាប់រចនាសម្ព័ន្ធគាំទ្រថ្នាក់ខេត្តពី PRDC ទៅ C/SC[៤] ។ ប៉ុន្តែ ការរៀបចំបណ្តោះអាសន្ននេះមិនទាន់បានដាក់បញ្ចូលពេញលេញទៅក្នុងស្ថាប័ននោះទេ និងត្រូវពឹងផ្អែកយ៉ាងខ្លាំងលើប្រាក់បៀវត្សរ៍បន្ថែមដែលផ្តល់អោយដោយម្ចាស់ជំនួយ និងជំនួយបច្ចេកទេសដែលពាក់ព័ន្ធ ។ ក្នុងកំឡុងពេលបីឆ្នាំដំបូងនៃការអនុវត្ត គុណភាពនៃការសំរបសំរួល ការឧបត្ថម្ភផ្នែកបច្ចេកទេស និងការឧបត្ថម្ភផ្នែកគណនេយ្យត្រូវបានដាក់លាយឡំបញ្ចូលគ្នា ក៏ប៉ុន្តែជាទូទៅ មានការរីកចំរើនដោយទទួលបាននូវបទពិសោធន៍ ។ ការរៀបចំ បណ្តោះអាសន្ននៅ ក្នុងស្ថាប័ននឹងទាមទារអោយមានការធ្វើសមាហរណកម្មនៃមុខងារគាំទ្រទៅក្នុងមុខងារទូទៅរបស់មន្ទីថ្នាក់ខេត្តរបស់ ក្រសួងពាក់ព័ន្ធ ឬនៅក្នុងការិយាល័យអភិបាលឬសាលាខេត្តដែលបានពង្រីក ។

២៨. ច្បាប់រៀបចំស្ថាប័នក្នុងសំរាប់ខេត្ត ដែលអាចជំនួសអោយច្បាប់និងនិយ័តកម្មដទៃទៀត ហើយផ្តល់នូវមូលដ្ឋានស្របច្បាប់ សំរាប់កំណែទំរង់វិមជ្ឈការ គឺស្ថិតនៅក្នុងដំណាក់ការដំបូងសំរាប់ពិភាក្សា ហើយមិនទាន់មានការឯកភាពលើគោលការណ៍ មូលដ្ឋាននៅឡើយទេ ។ អាណត្តិ សំរាប់ការដឹកនាំកំណែទំរង់សហវិមជ្ឈការឋិតនៅលើក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល (CAR) ក្រោមក្រុមប្រឹក្សារដ្ឋមន្ត្រីជាន់ខ្ពស់ ។ ដោយសារតែសហវិមជ្ឈការនិងវិមជ្ឈការមានទំនាក់ទំនងជិតស្និទ ជាមួយគ្នានិងត្រូវសំរបសំរួលជាមួយគ្នាចាំបាច់ NCSC ចាំបាច់ត្រូវចូលរួមយ៉ាងសំខាន់ក្នុងការបង្កើតគោលគំនិត និងការបង្កើតកំណែទំរង់វិសហមជ្ឈការ ។ លើសពីនេះទៀត ការចូលរួមពីក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និងកីឡា គឺមានសារៈសំខាន់ ដោយសារថ្នាក់អនុជាតិនៃក្រសួងនេះមានការទទួលខុសត្រូវគ្រប់គ្រង និងប្រាស្រ័យទាក់ទងផ្ទាល់ជាមួយប្រជាពលរដ្ឋ

និងអតិថិជន។ សំរាប់វិស័យទាំងនេះ ក្របខ័ណ្ឌផ្លូវច្បាប់នៃការរៀបចំស្ថាប័ន ត្រូវមានការបញ្ជាក់ពីតួនាទី ការទទួលខុសត្រូវនៃមុខងារ និងហិរញ្ញវត្ថុ និង ការទទួលខុសត្រូវនៅថ្នាក់កណ្តាល ខេត្ត ស្រុក និងអ្នកផ្តល់សេវា ឬក៏រិតផ្តល់សេវា។

### *ទទួលស្គាល់អំពីភាពខុសគ្នារវាងសង្កាត់និងក្រុង*

២៩. ប្រព័ន្ធបច្ចុប្បន្នមិនបានបញ្ជាក់អំពីភាពខុសគ្នារវាងសង្កាត់ក្នុងទីក្រុងនិងឃុំក្នុងជនបទទេនៅក្នុងច្បាប់ ឬក៏នៅក្នុងការអនុវត្ត។ ករណីនេះ ចោទចេញជាបញ្ហាពីរធំៗ។ ទីមួយ សកម្មភាពនានាដែលសមស្របសំរាប់សង្កាត់អាចខុសគ្នាពី សកម្មភាពដែលសមស្របសំរាប់ឃុំ ឬវិធីសាស្ត្រខុសគ្នាសំរាប់សេវាកម្មដូចគ្នាអាចត្រូវការចាំបាច់។ ទីពីរ ការធ្វើផែនការទៅតាមស្ថានភាពតំបន់និងការផ្គត់ផ្គង់សេវា គឺមានសារៈសំខាន់ជាពិសេសនៅក្នុងតំបន់ទីក្រុង ដោយសារតែមាត្រដ្ឋានសេដ្ឋកិច្ច និងផលប៉ះពាល់ពីខាងក្រៅ ។ រហូតមកទល់ពេលនេះ ក្រុមប្រឹក្សាសង្កាត់តូចៗដែលបានជាប់ឆ្នោតនៅក្នុងក្រុងទទួលបានការផ្ទេរប្រាក់ជាច្រើនដោយឥតមានលក្ខណ្ឌដែលក្រុងពុំមានឱកាសដូច ។ មានតំរូវការចាំបាច់បន្ទាន់ដើម្បីពិចារណាលើវិធីសាស្ត្រសមរម្យមួយ សំរាប់ការធ្វើផែនការគ្របដណ្តប់ក្រុងនិងផ្គត់ផ្គង់សេវាទូទាំងក្រុង និងការកំណត់តួនាទីរបស់សង្កាត់ដែលត្រូវអនុវត្តក្នុងដំណើរការនេះ ។ បញ្ហានេះ ទាមទារនូវការត្រិះរិះឡើងវិញ ជាមូលដ្ឋានខ្លះអំពីច្បាប់វិមជ្ឈការបច្ចុប្បន្ន និងការអនុម័តច្បាប់ថ្មីសំរាប់គ្រប់គ្រងក្រុង និង តំបន់ទីក្រុងដែលបានជ្រើសរើសដទៃៗទៀត រួមបញ្ចូលទាំងប្រព័ន្ធរដ្ឋបាលនិងអភិបាលកិច្ចទីក្រុងដែលបានកែតំរូវយ៉ាង ត្រឹមត្រូវ។

## គ ពង្រឹងក្របខ័ណ្ឌទទួលខុសត្រូវនៅថ្នាក់អនុជាតិ

៣០. សមត្ថភាពរបស់សហគមន៍មូលដ្ឋានត្រូវការការពង្រឹងដើម្បីអាចមានឥទ្ធិពលលើការប្រើប្រាស់ធនធានដែលអាចប៉ះពាល់ដល់ជីវភាពនិងការរស់នៅរបស់ពួកគេ: គំនិតមួយចំនួនមានរួចជាស្រេចដូចជា "វេទិកាខេត្ត" ការពង្រឹងសិក្ខាសាលា ស្តីអំពីសមាហរណកម្មស្រុក ដែលត្រូវការច្រើននូវការសំរបសំរួលពីខាងក្រៅ ដូចជាតាមរយៈសង្គមស៊ីវិលជួយដល់មន្ត្រីឃុំ ។ ភាពចាំបាច់ក្នុងការជួយសហគមន៍មូលដ្ឋានអោយផ្តោតការយកចិត្តទុក

ដាក់លើអាទិភាពអភិវឌ្ឍន៍នានាដែល សំខាន់បំផុតចំពោះឃុំរបស់ពួកគេ និង ការទទួលខុសត្រូវរបស់មន្ត្រីថ្នាក់អនុជាតិលើការផ្តត់ផ្គង់សេវាដែលឆ្លើយតបទៅ នឹងគោលដៅទាំងនេះ គឺជាការសំខាន់ ។

## *រចនាសម្ព័ន្ធរដ្ឋបាលនិងនយោបាយត្រូវការរៀបចំឡើងវិញដើម្បីពង្រឹងការទទួលខុសត្រូវ*

៣១. ជាទូទៅរចនាសម្ព័ន្ធអន្តររដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជាមានភាពអោនថយដោយជាប់ទាក់ទងនឹងទិដ្ឋភាពសំខាន់ៗពីរ: (១) អំណាចនិងធនធាន របស់ថ្នាក់អនុជាតិខ្សោយឬតិចជាងច្រើនប្រៀបនឹងអំណាចនិងធនធានដែលកាន់កាប់ ឬគ្រប់គ្រងដោយថ្នាក់មជ្ឈឹម និង (២) ប្រព័ន្ធដែលទាក់ទង (ការធ្វើផែនការដែលមានការចូលរួមការផ្ទេរហិរញ្ញវត្ថុ ការផ្តត់ផ្គង់សេវា និងការទទួលខុសត្រូវខាងក្នុងនិងខាងក្រៅ) មានលក្ខណៈទន់ខ្សោយ ហើយកន្លងមក ប្រតិបត្តិមិនបានទៀងទាត់ ។ ក្រសួងសុខាភិបាលបានប្រឹងប្រែងយ៉ាងខ្លាំងក្នុងការធ្វើផែនការពីថ្នាក់ក្រោមឡើងលើសំរាប់ឆ្នាំ២០០៥ ប៉ុន្តែលុះត្រាតែផែនការមានភាពស៊ីគ្នានឹងផែនការថវិកាហើយថវិកាត្រូវបានផ្ទេរតាមការរំពឹងទុក និងវិមជ្ឈការមានភាពទូលាយលើការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុ បើពុំនោះទេទឹកចិត្តរបស់អ្នកចូលរួមក្នុងការធ្វើផែនការនឹងនៅតែមានកំរិតកំណត់ដដែល ។ ការចូលរួមសំរាប់ការប្រឹក្សាយោបល់ពីប្រជាពលរដ្ឋនិងអតិថិជនក្នុងដំណើរនៃការធ្វើផែនការនៅមិនទាន់បានមានការព្យាយាមខ្លាំងក្លានៅឡើយ ។

៣២. អភិបាលខេត្តមិនត្រូវបានបោះឆ្នោតជ្រើសរើសទេ គឺត្រូវបានតែតាំងដោយនាយករដ្ឋមន្ត្រី និងត្រូវជាបុគ្គលិករបស់ក្រសួងមហាផ្ទៃ ។ ដូច្នេះ អភិបាលខេត្តទាំងនេះចាត់ទុកខ្លួនឯងថាមានការទទួលខុសត្រូវចំពោះថ្នាក់មជ្ឈឹម។ ផុតពីសាលាខេត្ត "រដ្ឋបាលខេត្ត" មានអំណាចខ្សោយ និងត្រូវបានគេចាត់ទុកថាជាការប្រមូលផ្តុំមន្ទីររបស់ក្រសួង ដែលប្រតិបត្តិការនៅថ្នាក់ខេត្ត ហើយនឹងតភ្ជាប់ដោយយន្តការសំរបសំរួលដែលមានលក្ខណៈទន់ខ្សោយ ។ "ការផ្តត់ផ្គង់សេវាថ្នាក់ខេត្ត" គឺជាផ្នែកមួយ ("នៅក្នុងខេត្ត") ជាជាងគោលគំនិតរដ្ឋបាលតែមួយ ("តាមរយៈរដ្ឋបាលខេត្ត")។ ការផ្តត់ផ្គង់សេវានៅក្នុងខេត្តលើវិស័យសំខាន់ៗដូចជា សុខាភិបាល អប់រំ ផ្លូវថ្នល់ ។ល។ ត្រូវបានគ្រប់គ្រង និងរៀបចំថវិកាដោយក្រសួងសំខាន់ៗតាមលក្ខណៈជាខ្សែបណ្តោយរួម។ ការិយាល័យខេត្តរបស់ក្រសួងទាំងនេះ ដើរតួនាទីសំខាន់ជាសាខានៃរដ្ឋបាលកណ្តាលរបស់ក្រសួង ។ ទំនាក់ទំនងនៃការទទួល

ខុសត្រូវ និងខ្សែរយៈនៃរចនាសម្ព័ន្ធទៅថ្នាក់លើមានលក្ខណៈខ្លាំងក្លា ការទទួលខុសជាខ្សែទទឹងជាមួយការិយាល័យរបស់អភិបាលខេត្ត មានលក្ខណៈទន់ខ្សោយឬក៏គ្មាន ។ ទីបី ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងមួយចំនួន (ឧទាហរណ៍ ក្រសួងសុខាភិបាល និងក្រសួងអប់រំ) ដើម្បីផ្ទេរការទទួលខុសត្រូវនានាទៅអោយទីភ្នាក់ងារខេត្ត នៅក្នុងវិស័យទាំងនេះក៏ដោយ ក៏ការរីកចំរើនពិតប្រាកដនៅមានកំរិតនៅឡើយ។ ការអភិវឌ្ឍ និង ការដកពិសោធន៍ ជាមួយនឹងវិធីផ្សេងៗដោយការផ្តល់អោយអ្នកផ្តល់សេវា ឬអង្គភាពផ្តល់សេវានូវកាទទួលខុសត្រូវផ្ទាល់ចំពោះប្រជាពលរដ្ឋ និងអតិថិជនជាទិដ្ឋភាពមួយមានសារៈសំខាន់នៃរបៀបវារៈដែលមិនចេះចប់ ឧទាហរណ៍ ផ្សព្វផ្សាយយ៉ាងទូលាយ ពីទិន្នន័យនៃការអនុវត្តសេវាក្នុង"កាតរបាយការណ៍ពលរដ្ឋ" ឬវេទិកាសំរាប់ផ្តល់ពត៌មានត្រឡប់ដល់ប្រជាពលរដ្ឋ ពីការផ្គត់ផ្គង់សេវា ។

៣៣. ច្បាប់ស្តីអំពីការបោះឆ្នោតឃុំ/សង្កាត់តំរូវអោយមានបេក្ខជនពី ៥រូប ទៅ ១១រូប នៅក្នុង C/SC អាស្រ័យលើចំនួន ប្រជាជននៅក្នុងឃុំ ដើម្បីឈរឈ្មោះបោះឆ្នោតសំរាប់រយៈពេល៥ឆ្នាំ តាមរយៈការបោះឆ្នោតប្រព័ន្ធសមាមាត្រនិងផ្អែកលើឈ្មោះគណបក្ស ។ ទំនាក់ទំនងរបស់គណបក្សគឺជាការចាប់ផ្តើមដ៏សំខាន់មួយពីប្រព័ន្ធបោះឆ្នោតដោយចំហដែលអនុវត្តសាកល្បងក្រោមកម្មវិធីសិលា ។ ដូច្នេះ មានគ្រោះថ្នាក់មួយដែលមន្ត្រីឃុំដែលបានជាប់ឆ្នោតអាចទទួលខុសត្រូវចំពោះគណបក្សនយោបាយច្រើនជាងចំពោះសហគមន៍មូលដ្ឋាន ដែលនាំអោយមានការលំបាកដល់ប្រជាពលរដ្ឋសាមញ្ញ ដែលគិតថាឃុំមានមុខងារបំរើផលប្រយោជន៏ដល់សហគមន៍មូលដ្ឋាន។

៣៤. ក្រសួងមហាផ្ទៃក៏បានធ្វើការត្រួតពិនិត្យផងដែរ ។ ជាពិសេស ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់អាចត្រូវបានបដិសេធដោយក្រសួងមហាផ្ទៃ ដែលមានអំណាចបញ្ឈប់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ណាមួយបានដោយផ្អែក លើហេតុផលផ្សេងៗ។ C/SC និមួយៗមានសមាជិកមួយរូប ស្មៀនឃុំដែលជាបុគ្គលិករបស់ក្រសួងមហាផ្ទៃ និងទទួលខុសត្រូវជួយការងាររដ្ឋបាលដល់ C/SC ។ ហើយប្រធានឃុំតែងតាំងអាជ្ញាធរភូមិដែលទទួលប្រាក់បៀវត្សរ៍ពី C/SC ពីមូលនិធិឃុំសង្កាត់ ។

## *តួនាទីរបស់ភូមិនៅតែទាមទារអោយមានការបញ្ជាក់ច្បាស់លាស់*

៣៥. ភូមិទាំងអស់គ្មានតំណាងផ្ទាល់នៅក្នុង C/SC ទេ ក៏ប៉ុន្តែ ច្បាប់វិមជ្ឈការអនុញ្ញាតិអោយមានប្រកជាច្រើន សំរាប់តំណាង និងការចូលរួមរបស់ ថ្នាក់ភូមិនៅក្នុងដំណើរការធ្វើផែនការអភិវឌ្ឍឃុំ។ ច្រកសំខាន់បំផុតសំរាប់គឺ តាមរយៈការបង្កើតគណៈកម្មាធិការធ្វើផែនការនិងរៀបចំថវិកា (PBC) ដែលទទួលខុសត្រូវក្នុងការជួយដល់ប្រធានឃុំ អនុវត្តដំណើរការធ្វើផែនការអភិវឌ្ឍន៍ឃុំ និងធ្វើពង្រាងកម្មវិធីវិនិយោគនិងអភិវឌ្ឍន៍ឃុំ/សង្កាត់ និងថវិកាឃុំ ។ ប្រកាសស្តីអំពីផែនការឃុំ/សង្កាត់កំណត់អំពីសមាសធាតុរបស់ PBC ដែលមានប្រធានឃុំធ្វើជាប្រធាន ហើយស្មៀនឃុំធ្វើជាលេខាព្រមទាំងមានសមាជិកជាច្រើនអ្នកទៀតៈ តំណាងបីនាក់មកពី C/SC ដែលបានជ្រើសរើសដោយប្រធាន អ្នកភូមិទាំងពីរភេទពី២-៤នាក់ដែលត្រូវបានជ្រើសរើសដោយប្រធាន និង តំណាងពីររូបមានបុរសនិងស្ត្រីដែលត្រូវបានជ្រើសរើសដោយ C/SC ចេញពីអាជ្ញាធរភូមិ ឬសំរាប់ភូមិដែលមាន VDCs តំណាងម្នាក់មកពីអាជ្ញាធរភូមិនិមួយៗ ហើយ VDC[៥] មានបុរសម្នាក់និងស្ត្រីម្នាក់។

៣៦. ក៏ប៉ុន្តែ ការរៀបចំរយៈពេលវែងសំរាប់ការជ្រើសរើសតំណាងភូមិដែលត្រូវការសំរាប់ចូលរួមក្នុងដំណើរការធ្វើផែនការអភិវឌ្ឍឃុំ/ សង្កាត់នៅមិនទាន់មានភាពច្បាស់លាស់ ។ តួនាទីសក្តានុពលសំរាប់តំណាង VDC លើ PBC ដែលហួសពីអាណត្តិ៥ឆ្នាំដំបូងរបស់ C/SC និងទំនាក់ទំនងរវាង VDC និងអាជ្ញាធរភូមិ ចាំបាច់ត្រូវបញ្ជាក់អោយបានច្បាស់ ។ និយ័តកម្មវិមជ្ឈការអនុញ្ញាតិអោយ C/SC តែងតាំងប្រធានភូមិមួយរូប ហើយប្រធានភូមិ តែងតាំងអនុប្រធាន ។ មានការអោយយោបល់មួយចំនួនថាត្រូវអោយមានការបោះឆ្នោតភូមិ ក៏ប៉ុន្តែការពិភាក្សាផ្ទៃក្នុងនាបច្ចុប្បន្ន មិនទាន់បានចប់សព្វគ្រប់នៅឡើយ។ ដោយមើលឃើញសារៈសំខាន់នៃតំណាងរបស់ភូមិស្តីអំពី PBC ការអនុម័តយន្តការសមស្របជាអចិន្ត្រៃយ៍សំរាប់ជ្រើសរើសតំណាងភូមិអោយបានឆាប់តាមលទ្ធភាពដែលអាចធ្វើទៅបាននោះ គឺជារឿងសំខាន់។

## **ការចូលរួម និងតម្លាភាពនៃដំណើរការអភិវឌ្ឍន៍ឃុំ/សង្កាត់ត្រូវតែពង្រឹង**

៣៧. តួនាទីរបស់សង្គមស៊ីវិលនៅក្នុងការបង្ហាញអំពីសេចក្តីត្រូវការសំរាប់អភិបាលកិច្ចល្អនៅថ្នាក់អនុជាតិ ចាំបាច់ត្រូវតែពង្រឹង ។ ទិដ្ឋភាពគន្លឹះពីរសំខាន់លើបញ្ហានេះគឺការចូលរួមនិងតម្លាភាព ទិដ្ឋភាពទាំងពីរនេះចាំបាច់ត្រូវតែបង្កើនតាមរយៈការអនុវត្តច្បាប់និងនិយ័តកម្មដែលមានស្រាប់អោយបានល្អប្រសើរ ព្រមទាំងកែសំរួលដំណើរការបច្ចុប្បន្នដើម្បីអនុញ្ញាតិអោយមានលទ្ធភាពកាន់តែច្រើនឡើងសំរាប់ការចូលរួមសំខាន់ៗ និងការទទួលព័តិមាន។

៣៨. ឧទាហរណ៍ គោលការណ៍ណែនាំស្តីអំពីដំណើរការធ្វើផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ ដែលបានកំណត់ពិស្តារនិងលទ្ធភាព សំរាប់ការចូលរួមនៅក្នុងដំណាក់កាលនិមួយៗក្នុងដំណើរការធ្វើផែនការ មិនបានគូសបញ្ជាក់ស្របតាមខចែងរបស់ប្រកាសស្តីអំពីការធ្វើផែនការឃុំ/សង្កាត់ ដែល PBC ដែលថាការប្រជុំត្រូវបើកចំហជាសាធារណៈជន ឬក៏មិនបានផ្តល់យោបល់អំពីដំណើរការនេះទេ ដូចជាការបិទប័ណ្ណប្រកាសជាសាធារណៈ អំពីថ្ងៃខែនិងពេលវេលានៃការប្រជុំ ដែលនឹងសំរួលដល់ការចូលរួមអោយបានច្រើននៅក្នុងអង្គប្រជុំ ។ ការពិនិត្យសើរើឡើងវិញអំពីការអនុវត្តដំបូង ក៏បានចោទជាការព្រួយបារម្ភទាក់ទងទៅនឹងការ ការចូលរួមនិងតម្លាភាពរបស់ដំណើរការនៃការធ្វើផែនការឃុំ/សង្កាត់ ។ ខ ចែងនៅក្នុងប្រកាសរបស់អន្តរក្រសួងសំរាប់ការចូលរួមជាសាធារណៈអោយបានច្រើននៅក្នុងដំណើរការធ្វើផែនការនេះ ជាទូទៅអ្នកភូមិ អង្គការសង្គមស៊ីវិល ឬក៏សូម្បីតែក្នុងករណីខ្លះក្រុមប្រឹក្សាឃុំ/សង្កាត់មិនបានដឹងឮទេ ហើយមិនត្រូវបានអនុវត្តអោយស៊ីសង្វាក់គ្នា ។ ក្រសួងមហាផ្ទៃគួរ តែចាត់វិធានការបន្ទាន់ដើម្បីធានាថា វិធានការនានា ត្រូវបានអនុម័តដើម្បីលើកទឹកចិត្តជុំរុញអោយមានការពិភាក្សា ការចូលរួម និងតម្លាភាពមានលក្ខណៈទូលំទូលាយ។ ស្ពាន់ដាអនុវត្តសំរាប់ការផ្សព្វផ្សាយជាសាធារណៈអំពីអង្គប្រជុំរបស់ PBC ដែលបើកចំហចំពោះសាធារណៈជន ព្រមទាំងការអភិវឌ្ឍនិងអនុវត្តយុទ្ធនាការយល់ដឹងជាសាធារណៈដើម្បីពន្យល់សាធារណៈជនអំពីឱកាសសំរាប់ការចូលរួម នៅក្នុងដំណើរការធ្វើផែនការអភិវឌ្ឍឃុំ/សង្កាត់ នឹងជួយសំរួលអោយមានការ ចូលរួមកាន់តែប្រសើរឡើង។

ការផ្តោតការយកចិត្តទុកដាក់បន្ថែមលើតម្លាភាពនិងលទ្ធភាពក្នុងការទទួលយកព័តិមាន រួមទាំងការចែករំលែកព័តិមាន ដែលមានលក្ខណៈទូលំទូលាយដោយអជ្ញាធរមូលដ្ឋាននិងសង្គមស៊ីវិល ក៏ត្រូវការចាំបាច់ផងដែរដើម្បី

ជួយសំរួលដល់សង្គមស៊ីវិលក្នុងការពិនិត្យតាមដានការប្រតិបត្តិរបសអាជ្ញាធរមូលដ្ឋាន។ រដ្ឋាភិបាលកណ្តាលអាចដើរតួនាទីសំខាន់ផង ដែរក្នុងការធានានូវទំនាក់ទំនងរឹងមាំរវាងវិមជ្ឈការនិងអភិបាលកិច្ចដែលបានកែលំអតាមរយៈការពិនិត្យតាមដានការ ប្រតិបត្តិរបស់ថ្នាក់ឃុំ និងផ្សព្វផ្សាយពត៌មាននេះជាសាធារណៈ។ ការដាក់លក្ខ័ណ្ឌលើការបែងចែកមូលនិធិបន្ថែមទៅ អោយអាំងឌីកាទ័រប្រតិបត្តិនឹងបង្កើតអោយមានការប្រកួតប្រជែងដ៏ល្អនៅក្នុងចំណោមឃុំ និងពង្រឹងនូវការផ្សារភ្ជាប់គ្នា នៃអភិបាលកិច្ច ។

## តួនាទីរបស់អភិបាល និង PDRC តំរូវអោយមានការបញ្ជាក់ច្បាស់លាស់

៤០. ការរៀបចំស្ថាប័នដែលមាននៅតាមខេត្តដើម្បីគាំទ្រដល់សកម្មភាពអភិវឌ្ឍន៏ឃុំ/សង្កាត់ ទាមទារអោយពិនិត្យសើរើឡើងវិញ ហើយយន្តការអចិន្ត្រៃយ៏មួយត្រូវបានរៀបចំឡើងដោយទាញចេញពីមេរៀននៃការរៀបចំបច្ចុប្បន្ន ។ មានកត្តាពីរ សំខាន់។ ទីមួយ អភិបាលខេត្ត តាមរយៈគណៈកម្មាធិការអភិវឌ្ឍន៏ជនបទខេត្ត (PRDC) សំរបសំរួលការកសាង សមត្ថភាពរបស់ឃុំ/សង្កាត់ សំរួលដល់ការធ្វើផែនការ ជំនួយបច្ចេកទេសក្នុងការដេញថ្លៃ ការអនុវត្តគំរោងអភិវឌ្ឍន៏ សេវាទូទាត់ប្រាក់និងគណនី[៦] ។ ដោយសារតែការរៀបចំនេះត្រូវបានគ្រប់គ្រងដោយប្រកាសមួយពីក្រុមការងាររបស់សិលា តួនាទីរយៈពេលវែងរបស់ PRDC មានភាពមិនច្បាស់លាស់ ។ អ្នកខ្លះចង់អោយ PRDC ឬរចនាសម្ព័ន្ធស្រដៀងគ្នានេះបន្តសំរបសំរួលដល់សកម្មភាពគាំទ្រនានាដល់ឃុំ ចំណែកឯអ្នកខ្លះទៀតចង់ឃើញជំរើសដទៃផ្សេងទៀត ។

៤១. ទីពីរ សេវាគាំទ្រដែលផ្តល់អោយឃុំ តាមរយៈនាយកដ្ឋានខេត្ត ត្រូវបានផ្តល់មូលនិធិក្រៅគំរោងថវិកាតាមរយៈកម្មវិធីសិលា[៧] ។ ភាពទន់ខ្សោយធ្ងន់ធ្ងររបស់ប្រព័ន្ធនេះ ដែលទាក់ទិនទៅនឹងខ្សែបន្ទាត់នៃការ ទទួលខុសត្រូវ គឺថា C/SC ត្រូវពឹងផ្អែកលើភ្នាក់ងារផ្គត់ផ្គង់សេវា ដែលមិនបានរាយការណ៏ផ្ទាល់ទៅអោយពួកគេ ។ ហើយប្រាក់ខែបន្ថែមរបស់ពួកគេ និងចំណាយប្រតិបត្តិការ ត្រូវបានបើកអោយដាច់ដោយឡែកទាំងស្រុងតាមរយៈមូលនិធិរបស់ម្ចាស់ជំនួយ។ ក៏ប៉ុន្តែ តំរូវការសំរាប់បន្តការសំរបសំរួល និងការគាំទ្របច្ចេកទេសសំរាប់រយៈពេលពីខ្លី ទៅមធ្យមត្រូវបានកំណត់ ជាក់លាក់ដោយសារសមត្ថភាពមានកំរិត នៅថ្នាក់ឃុំ

និងមន្ទីរខេត្ត ហើយជំរើសសំរាប់យន្តការផ្សេងៗ ដើម្បីផ្តល់ការគាំទ្រអោយបានគ្រប់គ្រាន់ ចាំបាច់ត្រូវវាយតំលៃអោយបានហ្មតចត់មុននឹងបញ្ចប់អាណត្តិបច្ចុប្បន្នរបស់សិលានៅចុងឆ្នាំ២០០៥ ។

៤២. បញ្ហាទូលំទូលាយមួយ ប៉ុន្តែមានទំនាក់ទំនងគ្នា គឺរចនាសម្ព័ន្ធរដ្ឋបាលរបស់អជ្ញាធរខេត្ត រួមទាំងតួនាទីរបស់ អភិបាលខេត្តនិងសាលាខេត្ត និងជំរើសសំរាប់ PRDC និងគណៈកម្មាធិការប្រតិបត្តិរបស់ខ្លួនធ្វើការ សំរបសំរួលរាល់សកម្មភាពអភិវឌ្ឍន៍ទាំងអស់នៅថ្នាក់ខេត្ត។ ក្នុងករណីដែលក្រុមប្រឹក្សាខេត្តអវត្តមាន វិធីធានាការទទួលខុសត្រូវពីលើចុះក្រោម ក៏ដូចជាពីក្រោមឡើងលើ ចាំបាច់ត្រូវរៀបចំអោយបានជាក់លាក់ និងចែងនៅក្នុងច្បាប់ ដូចជាការបង្កើតវេទិកាខេត្ត ដើម្បីបង្ហាញអំពីការទទួលខុសត្រូវលើការសំរេចចិត្តរៀបចំថវិកា និងការប្រគល់អំណាច អោយបានច្រើនពីក្រសួងមួយចំនួនទៅអោយ នាយកដ្ឋាននៅខេត្ត ។

## *ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ/សង្កាត់ចាំបាច់ត្រូវពង្រឹង*

៤៣. អនុក្រិត្យស្តីអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ/សង្កាត់ បានកំណត់អំពីប្រព័ន្ធសំរាប់រៀបចំថវិកាឃុំ គណនេយ្យ ការគ្រប់គ្រង ចំណាយ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការធ្វើរបាយការណ៍ហិរញ្ញវត្ថុនិងសវនកម្ម។ ការអនុវត្តដំបូងបានបង្ហាញអំពីភាពទន់ខ្សោយមួយចំនួននៅក្នុងប្រព័ន្ធនេះ ព្រមទាំងបានបង្ហាញអំពីការអនុវត្តផ្ទុយពីនីតិវិធីដែលបានយល់ព្រមចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់មូលនិធិឃុំ/សង្កាត់ដោយបុគ្គលិករបស់រតនាគារខេត្ត ។ ឧទាហរណ៍ ការកត់ត្រាគណនីពីការបែងចែកថវិកាគ្រោងសំរាប់ឃុំ ជាសាច់ប្រាក់ដែលបានទទួល ានបង្វែងកំណត់ត្រាពីសាច់ប្រាក់ដែលបានទទួល និងសាច់ប្រាក់ដែលមានសំរាប់ឃុំនីមួយៗ ។ ទាំងនេះត្រូវបានបង្កើតឡើងដោយរតនាគារខេត្តដែលការផ្ទេរសាច់ប្រាក់របស់មូលនិធិឃុំ/សង្កាត់ត្រូវបានរក្សាទុកនៅក្នុងគណនីសាច់ប្រាក់រួមមួយរបស់រតនាគារខេត្ត ហើយបានចុះឥណទានក្នុងគណនីរងរបស់មូលនិធិឃុំ/សង្កាត់រួមមួយ ប៉ុន្តែមិនមែនចុះឥណទានក្នុងគណនីរបស់ឃុំ/សង្កាត់ នីមួយៗនោះទេ ។ ជាលទ្ធផល ក្រុមប្រឹក្សាឃុំ/សង្កាត់មិនបានដឹងអំពីមូលនិធិដែលមាននៅពេលណាមួយជាក់លាក់ ដូចនេះហើយគ្មានលទ្ធភាពអាចគ្រប់គ្រងគណនីនិងកម្មវិធីការងាររបស់ពួកគេទេ ។ ការអនុវត្តនេះ រួមជាមួយទាំងការផ្ទេរប្រាក់យឺត និងមិនគ្រប់គ្រាន់ទៅអោយមូលនិធិឃុំ/សង្កាត់តាមបទពិសោធន៍ឆ្នាំ ២០០៣ បានអនុញ្ញាតអោយរតនាគារខេត្តអនុវត្តនូវ

ច្បាប់ពិសេស (ឧទាហរណ៍ អ្នកមកមុនបំរើមុនលៃលកតាមចំនួន) សំរាប់ការកំណត់អាទិភាពចំណាយក្នុងចំណោមលំដាប់ចំណាយដែលបានទទួល ដែលបើកចំហអោយមានការរំលោភបំពាន ។ កង្វះខាតតម្លាភាពនៅក្នុងនិតិវិធីក៏ធ្វើអោយមានការការពារមិនបានជិតដល់ប្រឆាំង នឹងការបង្វែរសាច់ប្រាក់របស់មូលនិធិឃុំ/សង្កាត់ទៅអោយគោលដៅផ្សេង សូម្បីតែជាការផ្ទេរបណ្ដោះអាសន្នក៏ដោយ ។ ភាពទន់ខ្សោយទាំងនេះចាំបាច់ត្រូវដោះស្រាយជាបន្ទាន់ ។

## *ផ្ទេរគណនីរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ពីរតនាគារខេត្តទៅធនាគារពាណិជ្ជកម្ម*

៤៤. អនុក្រិត្យស្ដីអំពីការបង្កើតមូលនិធិឃុំ/សង្កាត់អនុញ្ញាតិអោយឃុំផ្ទេរមូលនិធិទៅកាន់គណនីរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ នៅក្នុងធនាគារពាណិជ្ជកម្មប្រសិនបើក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអនុម័តយល់ព្រម ។ ប៉ុន្តែក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF) រហូតមកដល់បច្ចុប្បន្ននេះ នៅស្ទាក់ស្ទើរក្នុងការអនុម័តអោយប្រើប្រាស់គណនីរបស់ធនាគារពាណិជ្ជកម្ម ។ ការប្រើប្រាស់រតនាគារខេត្តក្នុងការផ្ដល់នូវសេវាទូទាត់ប្រាក់និងគណនេយ្យឃុំក៏បានបង្ហាញអោយឃើញថាមានបញ្ហាដែរ ។ ដើម្បីពង្រឹងការទទួលខុសត្រូវដែលមានលក្ខណៈសមស្របតាមរយៈការត្រួតពិនិត្យអោយបានល្អប្រសើរលើការប្រើប្រាស់ប្រាក់របស់ក្រុមប្រឹក្សាឃុំ កែលំអការគ្រប់គ្រងសាច់ប្រាក់នៅថ្នាក់ឃុំ និងធានាការប្រើប្រាស់មូលនិធិឃុំ/សង្កាត់តាមគោលដៅដែលបានគ្រោង ការប្រើប្រាស់គណនីរបស់ធនាគារពាណិជ្ជកម្មសំរាប់ឃុំ-សង្កាត់គួរតែត្រូវសាកល្បងនិងប្រើប្រាស់ ។ បញ្ហាមួយដែលការសាកល្បងនេះត្រូវការចាំបាច់ដើម្បីដោះស្រាយ គឺការរៀបចំសេវាគណនេយ្យក្នុងពេលឥឡូវនេះ ដែលប្រតិបត្តិដោយរតនាគារខេត្តជួសមុខអោយ C/SCs ។

## *សវនកម្មប្រចាំឆ្នាំលើមូលនិធិឃុំ/សង្កាត់ដោយអាជ្ញាធរសវនកម្មជាតិ*

៤៥. ទោះបីជាមូលនិធិឃុំ/សង្កាត់បានបង្កើតឡើងតាំងពីឆ្នាំ២០០២ក៏ដោយ ក៏មូលនិធិនេះមិនបានទទួលការធ្វើសវនកម្មខាងក្រៅ នៅក្នុងប្រតិបត្តិការឆ្នាំទីមួយរបស់ខ្លួនដែរ ។ ក៏ប៉ុន្តែ មូលនិធិឃុំ/សង្កាត់ឆ្នាំ២០០៣បច្ចុប្បន្នកំពុងត្រូវបានធ្វើសវនកម្ម ដោយទីភ្នាក់ងារសវនកម្មជាតិក្រោមការរៀបចំដែលផ្ដល់មូលនិធិដោយម្ចាស់

ជំនួយ ។ សវនកម្មនេះ នឹងរាយការណ៍អំពីគំរូប្រតិបត្តិការសំរាប់ឃុំទាំងអស់នៅរតនាគារខេត្ត និងការត្រួតពិនិត្យរូបវ័ន្ត១០ ភាគរយ នៅថ្នាក់ឃុំ ។ របាយការណ៍សវនកម្មព្រៀងនេះនឹងត្រូវរៀបចំ ហើយលទ្ធផលនៃសវនកម្មនឹងត្រូវលើកយកទៅពិភាក្សា ជាមួយឃុំមុនធ្វើការសំរេច ។ គេមើលឃើញថា សេចក្តីសង្ខេបនៃរបាយការណ៍សវនកម្មនេះនឹងត្រូវបានផ្សព្វផ្សាយ ជាឯកសារសាធារណៈបន្ទាប់ពីរបាយការណ៍ សវនកម្មនេះត្រូវបានអនុម័តដោយសភាជាតិ ។ វាមានសារៈសំខាន់ណាស់ក្នុងការធ្វើសវនកម្មប្រចាំឆ្នាំលើមូលនិធិឃុំ/សង្កាត់ ហើយវាមានសារៈសំខាន់ណាស់ដែលចំណាយប្រតិបត្តិការសំរាប់អនុវត្ត សវនកម្មលើមូលនិធិឃុំ/សង្កាត់សំរាប់ឆ្នាំ ២០០៤ និងឆ្នាំខាងមុខបន្តទៀតត្រូវបានគេរៀបចំថវិកាយ៉ាងត្រឹមត្រូវ នៅក្នុងថវិការដ្ឋ។

## ឃ បង្កើនកំរិត និងលទ្ធភាពព្យាករណ៍ធនធានដែលមានសំរាប់ថ្នាក់អនុជាតិ

៤៦. ឃុំត្រូវច្រើនជាងបច្ចុប្បន្ននូវធនធាន និងលទ្ធភាពព្យាករណ៍ធនធាន រួមទាំងប្រាក់ចំណូលផ្ទាល់ខ្លួនរបស់ឃុំ ហើយវិធាន ការខាងក្រោមនេះត្រូវបានគេផ្តល់អនុសាសន៍ ។

### បង្កើនលទ្ធភាពព្យាករណ៍ ទំនុកចិត្ត និងភាពត្រឹមត្រូវក្នុងការបញ្ចេញមូលនិធិឃុំ/សង្កាត់

៤៧. មូលនិធិឃុំ/សង្កាត់គឺជាយន្តការហិរញ្ញវត្ថុ ដែលតាមរយៈយន្តការនេះក្រុមប្រឹក្សាឃុំ/សង្កាត់មានលទ្ធភាពទទួលធនធានដែលផ្តល់អោយពីថវិកាជាតិ សំរាប់ការអភិវឌ្ឍនិងរដ្ឋបាលមូលដ្ឋាន ។ ការអនុវត្តវិមជ្ឈការគ្មានស្ថេរភាពដោយសារតែការបញ្ចេញសាច់ប្រាក់ទៅអោយមូលនិធិឃុំ/សង្កាត់ក្នុងឆ្នាំ២០០៣ និង ២០០៤ មានលក្ខណៈយឺតយ៉ាវនិងមិនគ្រប់គ្រាន់ ។ គោលការណ៍សំខាន់មួយនៃការផ្ទេរហិរញ្ញវត្ថុអន្តររដ្ឋាភិបាលពីថ្នាក់ជាតិទៅថ្នាក់មូលដ្ឋាន គឺជាទំនុកចិត្ត និងលទ្ធភាពព្យាករណ៍នៃការបញ្ចេញសាច់ប្រាក់ដែលទាក់ទង។ ដើម្បីធានាដល់លទ្ធភាពព្យាករណ៍លំហូមូលនិធិ និងអនុញ្ញាតអោយក្រុមប្រឹក្សាឃុំ/សង្កាត់អនុវត្តផែនការ ការងារប្រចាំរបស់ខ្លួនអោយមានប្រសិទ្ធិភាព និងមានការទទួលខុសត្រូវចំពោះ អ្នកបោះឆ្នោតរបស់ខ្លួននិងរដ្ឋាភិបាលថ្នាក់ជាតិដូចគ្នា វាមានសារៈសំខាន់ដែលទាំងពេលវេលានិងចំនួននៃការផ្ទេរសាច់ប្រាក់របស់មូលនិធិឃុំ/សង្កាត់មិនមែនជាជំរើស ហើយដំណើរការទៅដោយស្វ័យប្រវត្តិដោយឈរលើមូលដ្ឋានទៀងទាត់មួយនៅ

ក្នុងសមាមាត្រនៃការបែងចែកសរុបដែលបានកំណត់ទុកជាមុន ។ វាមានសារៈសំខាន់សំរាប់រដ្ឋាភិបាលក្នុងការអនុវត្តប្រព័ន្ធផ្ទេរសាច់ប្រាក់ដែលមិនមែនជាជំរើស អាចព្យាករណ៍បាននិងអាចទុកចិត្តបាន ដើម្បីអោយភាគីទាំងអស់ដែល ពាក់ព័ន្ធអាចធ្វើផែនការបានត្រឹមត្រូវ ។ គេបានផ្តល់អនុសាសន៍ថា ប្រព័ន្ធបញ្ចេញសាច់ប្រាក់របស់មូលនិធិឃុំ/សង្កាត់ស្របគ្នាជាមួយនិងប្រព័ន្ធគ្រប់គ្រងថវិកាទូទៅ តាមរយៈការបញ្ចេញប្រចាំខែ ដោយផ្អែកលើមូលដ្ឋានមិនមែនជំរើសស្របគ្នាជា មួយនិងឥណទានថវិកាដែលបានអនុម័ត ។

## បង្កើតក្រុមប្រឹក្សាភិបាលមូលនិធិឃុំ/សង្កាត់

ក្រោមច្បាប់វិមជ្ឈការ[៨] មូលនិធិឃុំ/សង្កាត់ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមូលនិធិឃុំ/សង្កាត់ ដែលមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ប្រធាន) ក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ព្រមទាំង តំណាងបីរូបរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ដែលត្រូវបានជ្រើសរើសចេញពីក្នុងចំណោមប្រធានឃុំ/សង្កាត់ ។ រដ្ឋលេខាធិការ ដ្ឋានមួយនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវគាំទ្រដល់ក្រុមប្រឹក្សាភិបាលមូលនិធិនេះ ។ ទោះបីជាអនុក្រិត្យស្តីអំពី មូលនិធិឃុំ/សង្កាត់តំរូវអោយបង្កើតក្រុមប្រឹក្សាភិបាលមូលនិធិឃុំ/សង្កាត់នៅក្នុងឆ្នាំ២០០២ ហើយមូលនិធិឃុំសង្កាត់បានដំណើរការអស់រយៈពេលជាងពីរឆ្នាំហើយក៏ដោយ ក៏ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ/សង្កាត់មិនទាន់បានបង្កើតឡើងនៅឡើយទេ ។ ការពន្យាក្នុងការបង្កើតក្រុមប្រឹក្សាភិបាលឃុំ/សង្កាត់ថ្មីៗនេះ មានការមិនឯកភាពគ្នាលើវិធីសាស្រ្តដែល ត្រូវយកមកប្រើប្រាស់ដើម្បីជ្រើសរើសតំណាងក្រុមប្រឹក្សាឃុំ/សង្កាត់ ទោះបីជាមាននិតិវិធីបណ្តោះអាសន្នមួយបានចែង នៅក្នុងអនុក្រិត្យនេះក៏ដោយ ។ រហូតមកដល់ពាក់កណ្តាលឆ្នាំ២០០៤ហាក់ដូចជាគ្មានការផ្លាស់ប្តូរណាមួយលើបញ្ហានេះទេ ទោះបីជារដ្ឋាភិបាលបានធានាអះអាងម្តងហើយម្តងទៀតថា ការបង្កើតក្រុមប្រឹក្សាភិបាលមូលនិធិឃុំ/សង្កាត់ ត្រូវធ្វើអោយបានឆាប់ក៏ដោយ ។ បញ្ហាដែលកើតមានឡើងនៅក្នុងប្រតិបត្តិការរបស់មូលនិធិឃុំ/សង្កាត់ក្នុងឆ្នាំ២០០៣ និង២០០៤ គឺជាបញ្ហាដែលត្រូវដោះស្រាយដោយក្រុមប្រឹក្សាភិបាលមូលនិធិឃុំ/សង្កាត់ ហើយការគ្មានក្រុមប្រឹក្សាភិបាលមូលនិធិ ឃុំ/សង្កាត់បានធ្វើអោយមានការគ្រប់គ្រងមិនល្អដល់មូលនិធិឃុំ/សង្កាត់ក្នុងកំឡុងឆ្នាំ ២០០៣ និង ២០០៤ ។ គេបានផ្តល់អនុសាសន៍ថាក្រុមប្រឹក្សាភិបាលមូលនិធិឃុំ/សង្កាត់ត្រូវតែបង្កើតជាបន្ទាន់ ។

## *បង្កើនការបែងចែកមូលនិធិឃុំ/សង្កាត់*

៤៩. ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ/សង្កាត់[៩] បែងចែកធនធានរបស់មូលនិធិឃុំ/សង្កាត់ប្រចាំឆ្នាំតាមរូបមន្ត ដែលបានឯកភាពគ្នាទៅអោយឃុំ មានសមាសភាគថវិកាពីររបស់មូលនិធិឃុំ/សង្កាត់ ។ ការបែងចែកទៅអោយ ឃុំនូវសមាសភាគមូលនិធិ ឃុំ/សង្កាត់សំរាប់អភិវឌ្ឍន៏មូលដ្ឋានផ្អែកលើរូបមន្តមួយដែលរួមបញ្ចូលទាំងកត្តានានា សំរាប់ប្រជាជននិងភាពក្រីក្រ ។ ក៏ប៉ុន្តែ ការបែងចែកទាំងនេះមិនទទួលរងផលប៉ះពាល់ពីការប្រតិបត្តិរបស់ឃុំ ទាក់ទងទៅនឹងអភិបាលកិច្ចឬការផ្គត់ផ្គង់សេវានោះទេ ។ ដើម្បីអាចទទួលនូវមូលនិធិឃុំ/សង្កាត់បាន ក្រុម ប្រឹក្សាឃុំ/សង្កាត់គ្រាន់តែចង់បង្ហាញថាពួកគេ បានអនុវត្តផែនការដែលមានការចូលរួម ដំណើរការអនុវត្ត និងរៀបចំថវិកា បានបញ្ចប់របាយការណ៏ហិរញ្ញវត្ថុទាំងអស់ តាមការអនុវត្តផែនការអភិវឌ្ឍន៏ និងផែនការ ថវិការបស់ខ្លួន ហើយបានប្រមូលផ្តុំវិភាគទានរបស់អ្នកទទួលផល និងធនធានក្នុង ស្រុកដទៃៗទៀតដើម្បីបំពេញ បន្ថែមដល់ការផ្ទេរសមាសភាគសំរាប់អភិវឌ្ឍន៏មូលដ្ឋាន។

៥០. នៅក្នុងឆ្នាំ២០០២មានឃុំតែចំនួន ៥០៦ ប៉ុណ្ណោះ បានទទួលមូលនិធិពីផ្នែកអភិវឌ្ឍន៏របស់មូល និធិឃុំ/ សង្កាត់ ។ នៅក្នុងឆ្នាំ២០០៣ និង២០០៤ ឃុំ/សង្កាត់ទាំង ១.៦២១ បានទទួលមូលនិធិផ្នែកអភិវឌ្ឍន៏ ទោះបីជា ឃុំមួយចំនួន (ឃុំដែលគ្មានបទពិសោធន៏ពីមុនក្រោមកម្មវិធីសិលា) បានទទួលចំនួនមូល និធិផ្នែកអភិវឌ្ឍន៏ក្នុង ឆ្នាំ២០០៣ ដែលមានតែនាមក៏ដោយ ។ នៅពេលដែលមូលនិធិនេះបានបើកឱកាសទូលាយ គេក៏បានកំរិតចំនួន ដែលមានសំរាប់ឃុំនីមួយៗ ដោយសារតែមូលនិធិ ឃុំ/សង្កាត់សរុប មិនត្រូវបានគេបង្កើន ។

៥១. ចំនួនជាមធ្យមដែលផ្តល់ទៅអោយឃុំតាមរយៈមូលនិធិឃុំសង្កាត់ចាំបាច់ត្រូវបង្កើនអោយបានច្រើន ប្រ សិនបើវិមជ្ឈការកាន់តែមានសារៈសំខាន់ខ្លាំងឡើង គឺ ៦.០០០ ដុល្លា ក្នុងមួយឆ្នាំសំរាប់ឃុំនីមួយៗមិនគ្រប់ គ្រាន់ទេ ក្នុងការទ្រទ្រង់ឃុំដែលមានសកម្មភាពល្អនៅក្នុងរយៈពេលវែង ឬក្នុងការផ្តល់នូវការលើកទឹកចិត្តយូរ អង្វែង ដើម្បីកែលំអការផ្គត់ផ្គង់សេវាមូលដ្ឋាន ។

៥២. កំរិតមធ្យមនៃវិភាគទានពីប្រាក់ចំណូលក្នុងស្រុករបស់រាជរដ្ឋាភិបាលទៅអោយគណនីរបស់មូលនិធិ ត្រូវបង្កើតទុកជាមុនសំរាប់យ៉ាងហោចណាស់រយៈពេលបីឆ្នាំសារពើពន្ធ[១០] ។ អនុក្រិត្យស្តីអំពីមូលនិធិឃុំ/សង្កាត់

ដែលបានប្រកាសកាលពីខែកុម្ភៈ ឆ្នាំ២០០២ បានបែងចែកមូលនិធិឃុំ/សង្កាត់សំរាប់ឆ្នាំ ២០០២ ដល់ឆ្នាំ ២០០៤។ ថ្មីៗនេះ រដ្ឋាភិបាលបានកំណត់ ភាគរយនៃប្រាក់ចំណូលក្នុងស្រុកដែលនឹងត្រូវបែងចែកទៅអោយមូលនិធិឃុំ/សង្កាត់សំរាប់រយៈពេលបីឆ្នាំបន្តបន្ទាប់គឺ ២០០៥ ដល់ ២០០៧ ។ ការបែងចែកទាំងនេះ នឹងកើនឡើងបន្តិចបន្តួចលើការបែងចែកឆ្នាំ ២០០៤ ចំនួន ២,៥ ភាគរយ គឺ ២,៥២ ភាគរយ សំរាប់ ឆ្នាំ២០០៥ ២,៥៤ ភាគរយ សំរាប់ឆ្នាំ២០០៦ និង២,៥៦ ភាគរយ សំរាប់ឆ្នាំ២០០៧ ។ គេផ្តល់អនុសាសន៍ថា សំរាប់បី ឆ្នាំបន្តបន្ទាប់ កំរិតទាំងនេះគួរតែត្រូវបានបង្កើនឡើងអោយច្រើនជាងក្នុងឆ្នាំ២០០២-២០០៤ និង ២០០៥-២០០៧ ដើម្បីឈានទៅរកបរិមាណមធ្យមយ៉ាងហោចណាស់អោយបាន ២០.០០០០ដុល្លារ សំរាប់ឃុំនីមួយៗ ។

## *បង្កើនធនធានពីប្រភពផ្ទាល់ខ្លួនសំរាប់ថ្នាក់អនុជាតិ*

៥៣. ក្រុមប្រឹក្សាឃុំ/សង្កាត់មានសិទ្ធិតំឡើងពន្ធនិងចំណូលមិនមែនពន្ធ និងមានសិទ្ធិកំណត់តំលៃសេវាកម្ម ។ ច្បាប់វិមជ្ឈការ ប្រគល់ដី អចលនវត្ថុ (បច្ចុប្បន្នមានត្រឹមតែពន្ធលើការផ្ទេរដី) និងពន្ធលើថ្លៃឈ្នួលទៅអោយឃុំ/សង្កាត់ ក៏ប៉ុន្តែច្បាប់នេះ មិនបានចែងលំអិតថា តើពួកគេត្រូវធ្វើរចនាសម្ព័ន្ធដូចម្តេចនោះទេ ។ ច្បាប់នេះតំរូវអោយមានការបកស្រាយលំអិតបន្ថែម អំពីប្រភពចំណូលរបស់ឃុំ/សង្កាត់ រួមទាំងប្រភេទ អត្រានិងដំណើរការនៃការប្រមូល ។ ច្បាប់នេះ ក៏អនុញ្ញាតអោយមានការផ្ទេរប្រាក់ចំណូលជាផ្នែក ឬទាំងមូលពីប្រភពពន្ធជាតិឬប្រភពមិនមែនពន្ធ ហើយទាមទារអោយឃុំនិងសង្កាត់បង្កើត មុខងារសំរាប់ខ្លួនឯងជំនួសអោយទីភ្នាក់ងាររបស់រដ្ឋ ។

៥៤. តាមការពិត ប្រភពចំណូលផ្ទាល់ខ្លួនរបស់ឃុំ/សង្កាត់មានកំរិត។ ឃុំ/សង្កាត់ត្រូវបានគេអនុញ្ញាតអោយយកថ្លៃសំរាប់ការចុះបញ្ជីរដ្ឋបាល ដែលកាលពីមុនអាជ្ញាធរថ្នាក់កណ្តាល/ខេត្តជាអ្នកយក ដូចជា ការចុះបញ្ជីកំណើត អាពាហ៍ពិពាហ៍ មរណភាព និងអោយចែកថ្លៃដែលបានពីការផ្ទេរដី ។ ប្រភពទាំងនេះវាសាមញ្ញបំផុត ទោះបីជាមានភស្តុតាង មិនអាចទុកចិត្តបាន បង្ហាញថាឃុំ/សង្កាត់បានកំណត់តំលៃឈ្នួលរដ្ឋបាលក្រៅច្បាប់ខ្ពស់ ហើយក្នុងករណីខ្លះប្រើប្រាស់ធនធានទាំងនេះដើម្បីជួលពលកម្មក៏ដោយ ។ ឃុំ/សង្កាត់ ក៏ត្រូវបានគេតំរូវអោយប្រមូលវិភាគទានមូលដ្ឋានផងដែរ សំរាប់ថ្លៃ ចំណាយ ១០ ភាគរយ របស់គំរោងអភិវឌ្ឍន៍ដែលផ្តល់មូល

និធិដោយឃុំ/សង្កាត់ ។ ឃុំ/សង្កាត់មួយចំនួនអោយអ្នកប្រើប្រាស់បង់ថ្លៃផ្គត់ផ្គង់សេវា ទោះបីជាប្រព័ន្ធនេះត្រូវបានគេកំរិតក៏ដោយ ។ ការសិក្សាអំពីជំរើសដើម្បីពង្រីក និងធ្វើអោយទៅជាផ្លូវការនូវប្រភពចំណូលផ្ទាល់ខ្លួនរបស់ឃុំ/សង្កាត់កំពុងតែដំណើរការ ។

៥៥. ច្បាប់ថវិកាខេត្ត ឆ្នាំ ១៩៩៧ ផ្តល់អោយខេត្តនូវមូលដ្ឋានមួយ ដើម្បីទទួល និង/ឬរក្សាប្រាក់ចំណូលសំរាប់ការអភិវឌ្ឍ។ ក៏ប៉ុន្តែ តាមការពិត មានធនធានជំរើសតិចតួចណាស់សំរាប់អភិវឌ្ឍន៍ ត្រូវបានបែងចែកទៅអោយខេត្តនានាពីថវិកាជាតិ ហើយនាយកដ្ឋានខេត្តរបស់ក្រសួងពាក់ព័ន្ធសំខាន់ៗនានាគ្មានអំណាចដើម្បីបង្កើតនិងអនុវត្តគំនិតផ្តួចផ្តើមអភិវឌ្ឍន៍នៅក្នុងខេត្តរបស់ខ្លួនទេ លើកលែងតែនៅក្នុងករណីពិសេសនៃសកម្មភាពសាកល្បង ។

៥៦. ប្រភពចំណូលផ្ទាល់ខ្លួនបច្ចុប្បន្នមានប្រាក់ចំណូលតូចៗនៅថ្នាក់ឃុំនិងខេត្ត ក៏ប៉ុន្តែ វាហាក់ដូចជាមានលទ្ធភាពអាចពង្រីកបរិមាណបាន ។ ក៏ប៉ុន្តែ បញ្ហានេះមិនអាចត្រូវដោះស្រាយបានដោយឡែកពីគ្នាទេសំរាប់ថ្នាក់ឃុំនិងខេត្ត ពីព្រោះថ្នាក់ទាំងពីរ នេះនឹងអាស្រ័យលើប្រភពចំណូលសក្តានុពលដូចគ្នា ។ មានកត្តាពីរដែលចាំបាច់ត្រូវដោះស្រាយ។ កត្តាទីមួយ ទាក់ទងទៅ នឹងបញ្ហាច្បាប់និងគោលនយោបាយ ។ ក្នុងរយៈពេលខ្លីការប្រកាសអោយប្រើនិយ័តកម្មមួយចំនួន ដើម្បីសំរបសំរួលដល់ការប្រមូលចំណូលដែលបានពីប្រភពចំណូលផ្ទាល់ខ្លួននៅថ្នាក់អនុជាតិគឺជាការចាំបាច់ក្នុងរយៈពេលវែង ការបែងចែកប្រភព ចំណូលអោយបានច្បាស់លាស់រវាងឃុំនិងខេត្ត ការលុបបំបាត់ចោលការត្រួតពិនិត្យចំណូលជាន់គ្នា និងការបញ្ជាក់អោយ បានច្បាស់អំពីការកំណត់អំណាចតំរូវអោយមាន (ដោយមើលឃើញអំពីទំនាក់ទំនងសំខាន់រវាងបញ្ហាចំណូលផ្ទាល់នៅមូលដ្ឋាន និងខេត្ត កិច្ចប្រឹងប្រែងនេះនឹងត្រូវដោះស្រាយជាមួយចំណូលខេត្តនិងឃុំស្របពេលជាមួយគ្នា) ។ កត្តាទីពីរ ទាក់ទងទៅនឹងការអភិវឌ្ឍប្រព័ន្ធ និងនិតិវិធីមូលដ្ឋានសំរាប់ថ្នាក់អនុជាតិ ដើម្បីគ្រប់គ្រងកិច្ចប្រឹងប្រែងប្រមូលចំណូល ។

## *សន្និធានកម្មផែនការនិងថវិកាថ្នាក់ខេត្ត*

៥៧. ពាក្យថាថវិកាខេត្តប្រើនៅទីនេះសំដៅទៅលើយន្តការពីរដាច់ដោយឡែកពីគ្នាប៉ុន្តែវាមានទំនាក់ទំនងគ្នាគឺផ្នែកថវិកាខេត្ត ក្រុង និងថវិកាសាលាខេត្ត ឬអភិបាលខេត្ត/ក្រុង ។ កន្លងមក គឺស្ថិតនៅក្រោមថវិកាជាតិ

និងគ្រប់គ្រងដោយថ្នាក់ក្រសួង ។ សាលាខេត្ត គឺប្រើប្រាស់ថវិកាក្រោមក្រសួងមហាផ្ទៃដែលមានអភិបាលខេត្ត ជាតំណាងនៅខេត្ត ដោយបូកប្រាក់ចំណូលរួម ទាំងចំណូលពីពន្ធ និងមិនមែនពន្ធ ដែលបានផ្តល់អោយទៅខេត្ត/ក្រុង ក្រោមច្បាប់ថវិកាខេត្ត/ក្រុងឆ្នាំ១៩៩៧ ។

៩៨. មានការសាកល្បងការប្រើប្រាស់ថវិកាមួយចំនួនដែលនៅក្រៅប្រពន្ធ័ថវិកាខេត្តដែលបានអនុម័ត ដោយរួមទាំងការបើក ប្រាក់ADD និង PAP ។ ADD គឺប្រើប្រាស់ ដោយរំលងនិតិវិធីបញ្ចេញលុយដែលមានបញ្ហានៅឯថ្នាក់ខេត្ត ហើយចាប់យកធនធានដោយផ្ទាល់ផ្តល់ទៅដល់អ្នកផ្តល់សេវាជួរមុខនៅឯថ្នាក់ស្រុក ។ អ្នកដែលប្រើប្រាស់ ADD សំខាន់ជាងគេគឺក្រសួងសុខាភិបាល ។ ចំណែកឯ PAP គឺជាការចំណាយមួយផ្នែកទៀត និងកាន់តែស្តែងចេញអោយឃើយច្បាស់ពីខិតខំប្រឹងប្រែងដើម្បីធ្វើអោយងាយស្រួលដល់ការគ្រប់គ្រង និងការបញ្ចេញលុយសំរាប់សេវាមូលដ្ឋាន ។ PAP គឺគ្របដណ្តប់លើវិស័យ ៤ (កសិកម្ម អប់រំ សុខាភិបាល និងអភិវឌ្ឍន៍ជនបទ) ហើយអាចប្រើប្រាស់បានសំរាប់តែការចំណាយប្រតិបត្តិការមិនមែនប្រាក់បៀវត្ស។ រហូតមកដល់ពេលនេះ មានតែក្រសួងអប់រំនិងសុខាភិបាលទេបានប្រើប្រាស់ ។ ក្រសួងអប់រំប្រើទូទៅ ចំណែកឯក្រសួងសុខាភិបាល ប្រើប្រាស់លើខេត្តមួយចំនួនតូចប៉ុណ្ណោះសំរាប់ជំនួស ADD ។ PAP ធ្លាប់មានការលំបាកដោយបញ្ហានៃការលំហូរសាច់ប្រាក់ ហើយការបញ្ចេញសាច់ប្រាក់ យឺតយ៉ាវយ៉ាងខ្លាំងមានន័យថាបញ្ចេញក្រោយពេលកំណត់រហូត ។

៩៩. គោលការណ៍សាកល្បងសហវិមជ្ឈការដែលមិនមែនថវិកា គឺជាមូលនិធិវិនិយោគថ្នាក់ខេត្តរបស់សិលា និងការអភិវឌ្ឍ កសិកម្មគាំទ្រកម្មវិធីសិលា(ADESS)។ ផែនការអភិវឌ្ឍន៍ថ្នាក់ខេត្ត៥ឆ្នាំ (PDP) គឺជាគ្រឹះសំរាប់កម្មវិធីវិនិយោគថ្នាក់ខេត្ត (PIP) ប្រចាំឆ្នាំមួយ ដែលផ្តល់ថវិកាជំនួយរបស់មូលនិធី PIF របស់សិលា ។ មូលនិធិ IFAD និង ADESS ប្រើប្រាស់យន្តការសិលា សំរាប់តែវិស័យកសិកម្ម។ គំរោងសាកល្បងទាំងពីនេះមិនទាន់យកជាគំរូបានទេសំរាប់គោលគំនិតរួម ដើម្បីធ្វើសហវិមជ្ឈការផែនការ និងថវិកា ។

៦០. មានតំរូវការជាបន្ទាន់មួយ ដើម្បីកំណត់ជាគោលគំនិតឡើងវិញលើថវិកាខេត្ត ជាថវិកាសំរាប់គ្រប់គ្រង និងថវិកា សំរាប់អភិវឌ្ឍន៍ ភូមិសាស្ត្ររបស់ខេត្ត និងកែលំអរស្ថាប័នពាក់ព័ន្ធនៅក្នុងប្រពន្ធ័ផែនការ និងថវិកាខេត្ត។ បច្ចុប្បន្ន ការសំរេចផ្តល់ធនធានថវិកាទៅអោយខេត្ត នោះគឺនៅត្រឹមសាលាខេត្តដែលផ្តោតការប្រើប្រាស់ជាដំបូងនៅលើការចំណាយដដែលៗ ។ ធនធានសាលាខេត្ត និងធនធានមូលនិធិវិនិយោគខេត្ត ស្ថិតក្រោមការគ្រប់គ្រងរបស់អភិបាលខេត្ត ហើយរបៀបប្រើប្រាស់ធនធាន ទាំងពីរនេះ ទាំងការធ្វើផែនការទាំងកម្មវិធី និងការគ្រប់គ្រង មានលក្ខណៈខុសៗគ្នា ។ លើសពីនេះ វាមានភាពមិនប្រាកដប្រជាជាមួយនឹងដំណើរការផែនការ និងថវិការបស់ថ្នាក់ជាតិ ក៏ដូចជាបណ្តាញនៅខ្សោយរវាងដំណើរការផែនការ និងថវិកាថ្នាក់ជាតិ និងថ្នាក់ខេត្ត ។

៦១. ច្បាប់គួរតែបញ្ជាក់អោយបានច្បាស់ និងពង្រីកអាណត្តិរបស់អភិបាលខេត្ត និងការងារគ្រប់គ្រងរបស់សាលាខេត្ត ក៏ដូចជា ប្រកខ័ណ្ឌគណនេយ្យភាព សំរាប់រដ្ឋបាលថ្នាក់ខេត្ត ។ លើកពីនេះ មានការបង្កើតសមាហរណកម្មថវិកាខេត្ត និងការភ្ជាប់ផែនការអភិវឌ្ឍន៍ខេត្តទៅនឹងប្រតិបត្តិការរបស់រដ្ឋាភិបាលមជ្ឈឹម និងផែនការអភិវឌ្ឍន៍ឃុំ គឺជាធាតុសំខាន់ណាស់នៃប្រព័ន្ធសហវិមជ្ឈការ ។ ប្រព័ន្ធនៃការកែទំរង់នៅក្នុងផ្នែកទាំងនេះ គួផ្តោតទៅលើការពង្រីកការប្រុងប្រយត្ត័ថ្នាក់ខេត្តលើការចំណាយនៃវិស័យនានានៅថ្នាក់ខេត្ត កែលំអតម្លាភាពនៃការ ផ្តល់ថវិកា និងធ្វើអោយប្រសើរលើការគ្រប់គ្រងហិរញ្ញវត្ថុខេត្ត ។

## ខ ពង្រីកសមត្ថភាពនិងគុណភាពនៃការគាំទ្រនៅថ្នាក់អនុជាតិ

### *បង្កើតប្រសិទ្ធភាពនៃការកសាងសមត្ថភាព*

៦២. សមត្ថភាពរបស់ថ្នាក់ឃុំ/សង្កាត់បច្ចុប្បន្ន នៅមានកំរិត ក៏ដូចជានៅឯផ្នែកគន្លឹះៗនៃរចនាសម្ព័ន្ធគាំទ្រថ្នាក់ខេត្ត ។ ក្រសួងមហាផ្ទៃបានរៀបចំការវាយតំលៃតំរូវការវគ្គបណ្តុះបណ្តាលមួយនាឆ្នាំ២០០៣ ដែលកំណត់នូវតំរូវការបណ្តុះបណ្តាលសំរាប់ក្រុមគោលដៅទាំងនោះ ហើយកម្មវិធីបណ្តុះបណ្តាលរបស់ក្រសួងមហាផ្ទៃឆ្នាំ ២០០៤ គឺជាការខិតខំប្រឹងប្រែងមួយដើម្បីដោះស្រាយតំរូវការទាំងនេះ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ

នៅមានច្រើនទៀតដែលយើងត្រូវការ ។ ដោយសារនេះជាចំណុចចាប់ផ្តើមមួយ ដូចនេះការវាយតំលៃស៊ីជំរៅថ្មីៗនេះលើប្រសិទ្ធភាពនៃការបណ្តុះបណ្តាល មកទល់ពេលបច្ចុប្បន្នគប្បីត្រូវយកមកប្រើសំរាប់ការបណ្តុះបណ្តាលនាពេលអនាគត ។ ដូចគ្នាដែរ វិធានការទាក់ទង ទៅនឹងការកសាងសមត្ថភាពដែលមិនមែនជាការបណ្តុះបណ្តាលគួរធ្វើអោយបានច្រើន ។ ឧទាហរណ៍: ការបង្កើតសមាគមមេឃុំ អាចជួយអោយមានការផ្លាស់ប្តូរបទពិសោធន៍រវាងឃុំនានា ។

## *កែលំអគុណភាពនៃការគាំទ្រដោយការសំរបសំរួលនិងបច្ចេកទេស*

៦៣. ការសំរបសំរួលដែលបានផ្តល់ដោយខេត្តពុំមានន័យគ្រប់គ្រាន់សំរាប់ពង្រឹងសមត្ថភាពសហគមន៍មូលដ្ឋានទេ ដោយសារវាមានភាពជាការត្រួតពិនិត្យដោយផ្ទាល់ជាច្រើនលើដំណើរការនេះ។ សំលេងរបស់ប្រជាជនអាចពង្រីកអោយបានប្រសើរ ដោយមានការ សំរបសំរួលអោយបានច្រើនចំពោះការចូលរួមដោយផ្ទាល់ពីសង្គមស៊ីវិល និងNGOs ។ ក៏ដូចគ្នានេះដែរ ការពិនិត្យដំបូង លើអនុគំរោងបានលើកឡើងការព្រួយបារម្ភខ្លះៗទាក់ទងទៅនឹងគុណភាពនៃការគាំទ្របច្ចេកទេស ដែលត្រូវបានផ្តល់ដោយអង្គភាពគាំទ្របច្ចេកទេសថ្នាក់ខេត្ត និងគុណភាពបច្ចេកទេសដែលទាក់ទងនានា របស់អនុគំរោងខ្លះៗ ។ ដូច្នេះវាមានតំរូវការសំខាន់សំរាប់ផ្តោតលើការកសាងសមត្ថភាព ជាពិសេសសំរាប់មន្ត្រីគាំទ្របច្ចេកទេស ដែលជាអ្នក ដើរតួដ៏សំខាន់នៅក្នុងការធានាលើការរចនារៀបចំនិងអនុវត្តអោយស្របទៅនឹងគំរោងរបស់ឃុំ និងសំរាប់បណ្តុះបណ្តាលមន្ត្រីដែលត្រូវការជំនាញសំរបសំរួល និងគោលការណ៍អភិបាលបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ។ បន្ថែមពីនេះ ការផ្តោតសំខាន់គួរត្រូវបានផ្តល់ ដើម្បីបង្កើនការយល់ដឹងសំរាប់មន្ត្រីសាធារណៈ និងរដ្ឋាភិបាលនៅគ្រប់កំរិត អំពីកំណែទំរង់វិម្សការរបស់រដ្ឋាភិបាល និងតួនាទីរបស់ពួកគេនៅក្នុងការងារនេះ ។

## ច សេចក្តីសន្និដ្ឋាន

៦៤. ភាពស្ទាក់ស្ទើរបស់រាជរដ្ឋាភិបាលចំពោះសហវិមជ្ឈការ និងវិមជ្ឈការ គឺអាចយល់បាន ដោយសារហេតុនៃប្រវត្តិសាស្ត្រនិងការលំបាកដែលប្រទេសកម្ពុជាបានជួបប្រទះ ។ ប៉ុន្តែការធ្វើអោយមានវិមជ្ឈការ បាននាំមក

នូវលទ្ធផល ដែលបានបង្ហាញពីការសន្យាដ៏ធំធេងនៅក្នុងការផ្តល់អំណាចទៅអោយប្រជាជនក្រីក្រនៅសហគមន៍ ដើម្បីពង្រឹងសំលេងរបស់គេនៅក្នុងការងារអភិវឌ្ឍន៍ និងដើម្បីបង្កើតការទទួលខុសត្រូវរបស់អាជ្ញាធរថ្នាក់ក្រោម។ ប៉ុន្តែភិមសា (ចលនា) ខាងលើ និងអាចអស់ទៅវិញប្រសិនបើគ្មានការប្តេជ្ញាចិត្តពីរដ្ឋាភិបាល ដើម្បីដោះស្រាយផលលំបាកខ្លះដែលកើតមានឡើង ។ ក្រុមការងារអនត្តរក្រសួងអភិវឌ្ឍយុទ្ធសាស្ត្រ និងផែនការសកម្មភាពផ្តល់នូវឱកាសនៅក្នុងរយៈរយៈប៉ុន្មានខែខាងមុខ ដើម្បីចាប់ផ្តើមរៀបចំនូវទស្សនៈចែករំលែកទូលំទូលាយរយៈពេលយូរអង្វែងមួយសំរាប់ វិមជ្ឈការ និងសហវិម្ឋការ និងបញ្ជាក់អំពីការទទួលខុសត្រូវទាំងខាងក្នុង និងខាងក្រៅនៅថ្នាក់អនុជាតិ ជាមួយនឹងទស្សនៈ ដើម្បីពង្រីកនូវការទួលខុសត្រូវចំពោះអ្នកក្រជាជាងចំពោះរដ្ឋាភិបាលថ្នាក់មជ្ឈឹម ឬចំពោះគណបក្សនយោបាយតាមខ្សែទឹង ហើយបន្សីគ្នានូវការទទួលខុសត្រូវជាមួយនឹងការកើនឡើង និង ការព្យាករកាន់តែប្រាកដចំពោះលំហូរធនធាន ដោយរួមទាំងចំណូលធនធានរបស់ខ្លួន ។ វិធានការទាំងនេះ និងជួយដល់សហគមន៍មូលដ្ឋានទទួលយកនូវ ការទទួលខុសត្រូវខ្ពស់សំរាប់ការគ្រប់គ្រងធនធានធម្មជាតិរបស់ប្រទេស ដែលជាប្រធានបទមួយទៀតនៅក្នុងជំពូកបន្ទាប់ ។

---

[១] សេចក្តីសំរេចលេខ១៣៦ ចុះខែ ធ្នូ ឆ្នាំ១៩៩៤ បន្ទាប់មកទទួលស្គាល់ដោយសេចក្តីសំរេចរបស់រដ្ឋាភិបាលលេខ០២ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩

[២] មានដូចជាខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ សៀមរាប ឧត្តរមានជ័យ រតនះគីរី និងក្រុងប៉ៃលិន

[៣] តាមរយៈប្រកាសស្តីអំពីការបែងចែកអំណាចទៅអោយអភិបាលខេត្ត/ក្រុងដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ (លេខ១៨៨៤ MOI ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០២)

[៤] ប្រកាសស្តីអំពីការបង្កើតរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការអភិវឌ្ឍន៍ខេត្ត/ក្រុងរបស់កម្មវិធីសិលា (លេខ២៩២ FTS ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០២)

[៥] VDCs ត្រូវបានបង្កើតឡើងតាមរយៈដំណើរការបោះឆ្នោតក្រៅផ្លូវការនៅថ្នាក់ភូមិដែលបានធ្វើឡើងតាមនិតិវិធីដែលបានកំណត់ដោយក្រសួងអភិវឌ្ឍន៍ជនបទដែលអនុញ្ញាតិអោយនរណាក៏បាននៅក្នុងភូមិឈរឈ្មោះបោះឆ្នោត និងធានាថាសមាជិក VDC ដែលបានជាប់ឆ្នោតមួយចំនួនត្រូវតែជាស្ត្រី ។

[៦] ផ្តល់អោយដោយគណនេយ្យករខេត្តក្រោមរតនាគារខេត្ត

[៧] បច្ចុប្បន្នសិលាផ្តល់នូវប្រាក់ខែបន្ថែមដល់ PRDC និងអង្គភាពគាំទ្រពាក់ព័ន្ធនានា ព្រមទាំងចំណាយប្រតិបត្តិការសំរាប់បែងចែកទៅអោយឃុំ និងជំនួយបច្ចេកទេសបន្ថែម

[៨] ដូចដែលបានរៀបរាប់លំអិតបន្ថែមនៅក្នុងអនុក្រិត្យស្តីអំពីការបង្កើតមូលនិធិឃុំ/សង្កាត់។

[៩] ដោយសារតែគ្មានក្រុមប្រឹក្សាភិបាលមូលនិធិឃុំ/សង្កាត់ អនុគណៈកម្មាធិការ NCSC ទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន ត្រូវដើរតួនាទីជំនួស។

[១០] តាមការស្នើសុំក្រោមមាត្រា៧៧នៃច្បាប់ឃុំ

# ជំពូកទី ៤

## ការគ្រប់គ្រងធនធានធម្មជាតិដើម្បីផលប្រយោជន៍សាធារណៈ

១. ទុនមនុស្ស សង្គម និង ហេដ្ឋារចនាសម្ព័ន្ធ នៅកម្ពុជា ត្រូវបំផ្លាញខ្ទេចខ្ទីរ ក្នុងអំឡុងសង្គ្រាមស៊ីវិល ។ ធនធានធម្មជាតិ បានសល់ជាទ្រព្យតែមួយគត់ដែលមានតំលៃខ្ពស់ និងអាចរកបាន សំរាប់បែងចែក ដើម្បីផ្គាប់ចិត្តភាគីច្បាំងគ្នា ក្នុងការប្តូរយកមកវិញនូវសន្តិភាព និងការបង្រួបបង្រួម ដើម្បីគ្រប់គ្រងលើទឹកដី និងប្រជាជនទាំងមូល ។ កម្មសិទ្ធិទ្រព្យសម្បត្តិផ្លូវការ ត្រូវបានកំទេចចោលដោយរបបខ្មែរក្រហម និងការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនដ៏លើសលប់ បានធ្វើអោយបាត់បង់សិទ្ធិកាន់កាប់ធនធាន ដែលត្រូវបានទទួលស្គាល់តាំងពីមុនមក ។ អសន្តិសុខលើទ្រព្យធន ដែលអូសបន្លាយជាយូរ និងកម្មសិទ្ធិមិនច្បាស់លាស់ បាននាំអោយមានការកេងប្រវ័ញ្ចដ៏ឆាប់រហ័ស លើធនធានដែលជាប្រភពរកចំណូលក្រៅផ្លូវការដ៏ងាយស្រួល ដើម្បីជួយទ្រទ្រង់សេវាសាធារណៈនិងប្រពន្ធ័កងទ័ព ដែលមានប្រាក់ខែទាប ដែលពឹងលើអ្នកគាំទ្រ ហើយនិងដើម្បីផ្គត់ផ្គង់យុទ្ធនាការនយោបាយ ។ សិទ្ធិប្រមូលផល ត្រូវគេលក់ទៅអោយអ្នកវិនិយោគ តាមរយៈដំណើរការដែលមិនមានតម្លាភាពទាល់តែសោះ និង មានលក្ខខណ្ឌតិចតួចសំរាប់អោយមានការត្រួតពិនិត្យលើការប្រព្រឹត្តិ ដែលមិនមាននិរន្តភាព ហើយមិនអើពើពីឥទ្ធិពលដែលប៉ះលើប្រជាជន មូលដ្ឋាន ។

២. កម្ពុជា ទទួលបានទាយជ្ជទានធនធានធម្មជាតិក្នុងម្នាក់ៗខ្ពស់ជាងគេបំផុតនៅតំបន់អាស៊ីអាគ្នេយ៍ ដោយ មានចំនែកយ៉ាងធំពីព្រៃឈើនិងត្រីទឹកសាបដែលផ្តល់ទិន្នផលខ្ពស់ ។ ប្រជាជនប្រហែល ៨៥ ភាគរយរស់ នៅតាមទីជនបទ ហើយភាគច្រើនពឹងផ្អែកលើកសិកម្ម ។ ក៏ប៉ុន្តែភាគច្រើននៃដីរដ្ឋមានការកាន់កាប់ដោយខុសច្បាប់ ក្នុងខណៈពេលដែលរដ្ឋមិនច្បាស់ថាខ្លួនមានអ្វីខ្លះ ។ វិធីសាស្ត្រជាចំបងរបស់រដ្ឋាភិបាលគឺត្រូវផ្តល់កុងត្រាលើផ្ទៃដីដ៏ធំទៅអោយអ្នកវិនិយោគខ្មែរនិងបរទេស ដែលកន្លងបានបង្ហាញថា ជាយន្តការឥតមានប្រសិទ្ធិភាពសំរាប់ការផ្តល់ធនធានសាធារណៈ ។ សហគមន៍មូលដ្ឋានបានឃើញមានការកែលំអដ៏តិចតួចក្នុងការអោយពួកគេអាចទទួលបាននូវធនធានធម្មជាតិ ក្នុងពេលដែលទំនាស់លើធនធានដី ដែលមានតិចតិចកំពុងតែកើនឡើង ។

៣. មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល បានផ្តល់សញ្ញានៃការទទួលស្គាល់ថា មានចំនុចខ្វះខាតរបស់គោលនយោបាយមុន ហើយបានចាត់វិធានការមួយចំនួនដោយបញ្ឈប់ រឺក៏បន្ថយសកម្មភាពគ្រប់គ្រងដែលគ្មានប្រសិទ្ធិភាព ។ ឡូតិ៍នេសាទធ្វើពាណិជ្ជកម្ម និង ព្រៃសម្បទានចំនួន ៤០ កន្លែង ដែលគ្របដណ្តប់ជាងពាក់

កណ្តាលនៃតំបន់សម្បទាន ត្រូវបានលុបចោល ។ អ្នកដែលបានទទួលសិទ្ធិសម្បទាន តម្រូវអោយដាក់ ផែនការគ្រប់គ្រងព្រៃឈើជាយុទ្ធសាស្ត្រ ។ ការផ្អាកលើការកាប់ឈើ និងដឹកឈើក្នុងតំបន់ ដែលគ្រប់គ្រងដោយសម្បទាន បានចូលជាធរមានរយៈពេល ១៨ ខែ ។ ស្របពេលនេះដែរ របៀបគ្រប់គ្រង តាមសហគមន៍កំពុងត្រូវបានស្ទាបស្ទង់ ។

៤. ការវិភាគធនធានធម្មជាតិ ចាំបាច់ត្រូវធ្វើ ព្រមទាំងច្បាប់បញ្ជាក់ពីកម្មសិទ្ធិ និង ការទទួលខុសត្រូវរបស់ស្ថាប័នចាំបាច់ត្រូវអនុម័ត និងអនុវត្ត ។ លើសពីនេះទៀត សមត្ថភាពបច្ចេកទេសក្នុងការវិភាគ ធ្វើផែនការអនុវត្ត និង រាយការណ៍ ពីការគ្រប់គ្រងធនធាន ត្រូវតែពង្រឹង ។ អង្គការក្រៅរដ្ឋាភិបាល នឹងត្រូវធ្វើការ ដោយមានការសហការជាមួយរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយ ដើម្បីធ្វើសមាហរណកម្មការរៀបចំបែងចែកផលប្រយោជន៍ទៅក្នុងសកម្មភាពគ្រប់គ្រងធនធានធម្មជាតិពេលបច្ចុប្បន្ននិងទៅអនាគត ។ ការគាំទ្រដល់សហគមន៍និងអាជ្ញាធរតាមតំបន់ដែលនឹងមានការទទួលខុសត្រូវថ្មី តាមរយៈការរៀបចំនេះ នឹងត្រូវតាក់តែងឡើង ។ ក្នុងខណៈដែលការផ្លាស់ប្តូរទាំងនេះ លើគោលនយោបាយរបស់រដ្ឋាភិបាល កំពុងតែត្រូវបានអនុវត្ត មានភាពចាំបាច់ជាបន្ទាន់មួយដើម្បីអោយមានការគាំទ្រដល់ការការពារជីវរដ្ឋ តាមរយៈវិធីមានភាគីចូលរួមច្រើន ។ អ្នកផ្តល់ជំនួយចាំបាច់ត្រូវឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ដោយផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីជួយបង្កើតប្រពន្ធ័គ្រប់គ្រង ធនធានធម្មជាតិមួយដែលមានគណនេយ្យកិច្ច តម្លាភាព និង ការចូលរួម ។

# ជំពូក ៤ : ការគ្រប់គ្រងធនធានធម្មជាតិដើម្បីប្រយោជន៍សាធារណៈ

*"បើនិយាយអំពីដីធ្លី និង ធនធានធម្មជាតិកម្ពុជា គឺជា ប្រទេសមួយមាន ធនធានរហូតដល់ ៨០ ភាគរយ ពោលគឺច្រើនជាងប្រទេសដទៃទៀតនៅអាស៊ី ដែលភាគច្រើន មានមិនលើសពី ៥០ ភាគរយឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ធនធានទាំងនេះ មិនទាន់មានប្រសិទ្ធិភាព និង មិនទាន់រួមចំណែកជួយជំរុញកំណើនសេដ្ឋកិច្ច និង កាត់បន្ថយភាពក្រីក្រនៅឡើយ .... ។ រាជរដ្ឋាភិបាល ប្តេជ្ញាយ៉ាងមុតមាំថា នឹងកែប្រែដីធ្លីអោយក្លាយជាក្បាលម៉ាស៊ីនជំរុញអោយមានកំណើនសេដ្ឋកិច្ច និង ជួយ កាត់បន្ថយភាពក្រីក្រ" ។*

*នេះជាប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងនាឱកាសបើកវេទិកាជាតិស្តីពីដីធ្លីដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤។*

៥. ករិតដ៏ខ្ពស់នៃទាយជ្ជទាន(អំណោយផល)ពីធនធានធម្មជាតិ ផ្តល់នូវគុណសម្បត្តិផង និង គុណវិបត្តិផង ។ ក្នុងរយៈពេលជាង ៥០ ឆ្នាំ កន្លងមកនេះ គេសង្កេតឃើញប្រទេសកំពុងអភិវឌ្ឍន៍ដែលមានធនធានធម្មជាតិតិចតួច មានកំណើន សេដ្ឋកិច្ចលឿនជាងប្រទេសដែលមានធនធានធម្មជាតិច្រើនចំនួនពី ២ ទៅ ៣ ដង (អាសើ ឆ្នាំ ២០០២) ។ ករណីនេះ កើតមានឡើងភាគច្រើនដោយសារចំណូល (ទាំងផ្លូវការ និង មិនផ្លូវការ) ពីការធ្វើអាជីវកម្មកេញប្រវញ្ចលើធនធានធម្មជាតិ ។ វាផ្តល់ជាយន្តកា "ងាយស្រួល" មួយសំរាប់គាំទ្រអង្គការនយោបាយរដ្ឋ ច្រើនជាងស្ថាប័នអភិវឌ្ឍន៍ដែលទទួលខុសត្រូវចំពោះប្រជាពលរដ្ឋដ៏ ច្រើននិងគាំទ្រអោយមានការអភិវឌ្ឍ ដែលមានមូលដ្ឋានទូលំទូលាយសំរាប់សេដ្ឋកិច្ចដែលនាំមុខដោយវិស័យឯកជន ។

៦. ពិតណាស់ប្រទេសកម្ពុជាទើបតែងើបចេញផុតពីជំលោះ និងសង្គ្រាមស៊ីវិល ទុនរូបវ័ន្ត ទុនមនុស្ស និងទុនសង្គម ត្រូវបំផ្លិចបំផ្លាញស្ទើរគ្មានសល់ ។ ធនធានព្រៃឈើ ដីកសិកម្ម ធនធានជលផល និង រ៉ែ ដែលជាសម្បត្តិដ៏មានតំលៃបំផុតរបស់ជាតិ ត្រូវបានប្រើប្រាស់សំរាប់តែការផ្សះផ្សារភាគីជំលោះ ដើម្បីស្វែងរកសន្តិភាព និង ពង្រឹងការគ្រប់គ្រងទឹកដី និង ប្រជាជនតែប៉ុណ្ណោះ ។ កម្មសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិជាផ្លូវការទាំងអស់ ត្រូវបានរបបខ្មែរក្រហមបំផ្លាញចោល ហើយការ ជម្លៀសប្រជាជនចេញពីភូមិឃុំជាទ្រង់ទ្រាយធំ បានរំលាយចោលសិទ្ធិកាន់កាប់ធនធានដែលត្រូវបានទទួលស្គាល់តាំងពីមុនមក ហើយដែលសិទ្ធិកាន់កាប់ធនធាននេះ ជួយសំរបសំរួលដល់ការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងសង្គម សូម្បីតែនៅពេល

អវត្តមានប្រព័ន្ធគ្រប់គ្រងសិទ្ធិកាន់កាប់ ឬ សិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិជាផ្លូវការក៏ដោយ ។ លើសពីនេះទៀត ក្រោយពេលដែលសង្គ្រាមស៊ីវិលត្រូវបញ្ចប់ អសន្តិសុខផ្នែករូបវ័ន្ត និង ភាពខ្សោយក្នុងការអនុវត្តសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ បានធ្វើអោយមានការកើនឡើងយ៉ាងឆាប់រហ័សនូវការធ្វើអាជីវកម្មកេងយកផលប្រយោជន៍លើធនធាន តាមមធ្យោបាយមួយដែលមិនមាន និរន្តរភាពយូរអង្វែង ។ តំរូវការដ៏ខ្ពស់ចំពោះចំណូលមិនផ្លូវការ ដើម្បីបន្ថែមទៅលើប្រាក់បៀវត្សរ៍ទាប ប្រព័ន្ធមន្ត្រីរាជការ និងយោធាមានលក្ខណះអំណាចធំជាង និង ឧបត្ថម្ភដល់យុទ្ធនាការឃោសនានយោបាយ បានជំរុញអោយបន្ថែមមានការបោះបង់ចោលនូវការប្រើប្រាស់ធនធានដែលមាននិរន្តរភាព សំរាប់តែបង្កើនហិរញ្ញវត្ថុរយះពេលខ្លី ។ សិទ្ធិប្រើប្រាស់ធនធានត្រូវបានលក់អោយទៅអ្នកវិនិយោគជាតិនិងអន្តរជាតិ តាមរយះដំណើរការដែលគ្មានតម្លាភាព និងក្រោមល័ក្ខខ័ណ្ឌដែលមានការត្រួតពិនិត្យយ៉ាងតិចតួចទៅលើការប្រើប្រាស់ ធនធានដែលគ្មាន និរន្តរភាព និងមិនបានយកចិត្តទុកដាក់លើផលប៉ះពាល់ដែលកើតឡើងពីការវិនិយោគនេះ ទៅលើប្រជាជនក្នុងមូលដ្ឋាន ។

៧. កម្ពុជាកំពុងតែស្ថិតនៅលើផ្លូវបំបែក។ ធនធានធម្មជាតិ ទោះបីជានៅមានច្រើនក្តី ក៏កំពុងតែស្ថិតនៅក្រោមកំណើនសម្ពាធមួយ ។ គោលនយោបាយគ្រប់គ្រងធនធានធម្មជាតិបច្ចុប្បន្ន ដែលបន្ថែមលើបំផ្លាញចោលនូវការលើកទឹកចិត្តដើម្បីជំរុញអោយមានកំណែទំរង់អភិបាលកិច្ចដ៏ទូលំទូលាយ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ទំនងជានាំទៅដល់ការប្រកួតប្រជែងលើការប្រើប្រាស់ធនធាននៅក្នុងចំណោមប្រជាជនដែលចេះតែកើនឡើងឥតឈប់ឈរ។ ការធ្វើកំណែទំរង់អភិបាលកិច្ចលេចិនធានធម្មជាតិ អាចជួយកែលំអការចិញ្ចឹមជីវិតនៅតាមជនបទអោយកាន់តែប្រសើរឡើង ដែលតាមរយះនេះ ក៏អាចកាត់បន្ថយបាននូវជំលោះ និងរួមចំណែកជំរុញអោយមានកំណើនសេដ្ឋកិច្ច និងការនាំចេញ ដោយនិរន្តរភាព ព្រមទាំងផ្តល់នូវសេវាបរិស្ថានល្អប្រសើរ និង បង្កើនចំណូលដល់វិស័យសាធារណះទៀតផង ។ កំណែទំរង់នេះ នឹង ពង្រឹងដល់កំណែទំរង់វិស័យផ្សេងទៀត ដូចជា ការអភិវឌ្ឍន៍វិស័យជនបទជាដើម ។ ទោះបីជាវិធានការជាច្រើនសំរាប់កែ លំអការគ្រប់គ្រងធនធានធម្មជាតិនៅកម្ពុជា អោយបានល្អប្រសើរនេះត្រូវបានអនុវត្តហើយក៏ដោយ ក៏សម្ព័ន្ធភាព ដ៏រឹងមាំរបស់ក្រុមអ្នកមានប្រាក់ មានអំណាចនៅខាងក្នុងនិងក្រៅរាជរដ្ឋាភិបាល នៅតែបន្តទប់ទល់ទៅនឹងកំណែទំរង់នេះ។ បញ្ហាប្រឈម ដែលរាជរដ្ឋាភិបាលត្រូវតែដោះស្រាយ គឺ ការយកឈ្នះទៅលើសម្ព័ន្ធភាពនេះ ដោយធ្វើការផ្លាស់ប្តូរពីយុទ្ធវិធីបែបមជ្ឈការ ខ្ពស់ទៅ

យុទ្ធវិធីដែលជំរុញអោយភាគីពាក់ព័ន្ធនៅថ្នាក់ជាតិនិងមូលដ្ឋានសំរេចទិសដៅកំណើនសេដ្ឋកិច្ច និង ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

## គ.      សារៈសំខាន់របស់ធនធានធម្មជាតិ

៨.      កម្ពុជា មានទាយជ្ជទានធនធានធម្មជាតិសំរាប់មនុស្សម្នាក់ខ្ពស់ជាងគេបំផុតនៅអាស៊ីបូព៌ា (សូមមើលរូប ៤.១) គឺ ១,៥ ហ.ត (ផ្ទៃដីដាំដុះកសិកម្ម) សំរាប់មនុស្សម្នាក់ ហើយប្រហែល ១/៤ (មួយភាគបួន) នៃផ្ទៃដីសរុប គឺជាដីដាំដុះកសិកម្ម ។ ប្រហែល ៦០ ភាគរយនៃផ្ទៃដីសរុបនៅកម្ពុជា ពោលគឺប្រហែល ៣/៤ (បីភាគបួន) ហ.ត សំរាប់មនុស្សម្នាក់ ត្រូវបានចាត់ទុកជាដីព្រៃឈើ ក្នុងនោះ ២៤ ភាគរយ ពោលគឺ ប្រហែល ០,២៥ ហិចតា សំរាប់ មនុស្សម្នាក់ ស្ថិតនៅក្នុងតំបន់ ការពារធម្មជាតិ ឬ តំបន់ព្រៃការពារ ។ កម្ពុជា មានធនធានជលផលទឹកសាបច្រើន ជាងគេបំផុតនៅអាស៊ីបូព៌ា ដោយផលិត បានពី ៣០០ ទៅ ៤០០ ពាន់តោនក្នុងមួយឆ្នាំ ពោលគឺ ប្រហែល ៦០ គីឡូក្រាម សំរាប់មនុស្សម្នាក់ ។ ធនធានទឹកសាប ដែលតាមការប៉ាន់ស្មាន មានជាង ៤០ពាន់ម៉ែតគូបសំរាប់ មនុស្សម្នាក់ ស្ថិតនៅលំដាប់ទីពីរនៅក្នុងតំបន់ បន្ទាប់ពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចំណែកភាគរយនៃការប្រើប្រាស់ទឹកសាបប្រចាំឆ្នាំ មានកំរិតទាបជាងគេ បំផុត នៅក្នុងតំបន់ ។

រូប ៤.១ : ទាយជ្ជទានធនធានធម្មជាតិសំរាប់មនុស្សម្នាក់ (គិតជា ហិចតា)




៩.      នៅក្នុងយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាល បានទទួលស្គាល់ថា កម្ពុជាមានធនធានធម្មជាតិច្រើនសន្ធឹកសន្ធាប់ ហើយ បានចាត់ទុកសារៈសំខាន់នៃកំណើន "កសិកម្ម" ឬ កំណើនសេដ្ឋកិច្ចជនបទដែលមានមូលដ្ឋានទូលំទូលាយ ជា"កំលាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ និង ការកាត់បន្ថយភាពក្រីក្រ" (រាជរដ្ឋាភិបាល

កម្ពុជា យុទ្ធសាស្ត្រចតុកោណឆ្នាំ ២០០៤) ។ យុទ្ធសាស្ត្រ នេះ បានផ្តោតការយកចិត្តទុកដាក់ទៅលើតួនាទីនៃធនធានធម្មជាតិក្នុងការគាំទ្រដល់ការចិញ្ចឹមជីវិតនៅជនបទ តាមរយៈការលើកកំពស់ផលិតភាពកសិកម្ម និង ការបង្កើនការប្រើប្រាស់ដីធ្លី ធនធានទឹក ជលផល និង ធនធានព្រៃឈើ រួមទាំងតំបន់ការពារធម្មជាតិផង ប្រកបដោយសមធម៌ ប្រសិទ្ធភាព និង និរន្តរភាព ។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក៏បានទទួលស្គាល់ពីសារៈសំខាន់នៃធនធាននានា ដើម្បីកំណើនសេដ្ឋកិច្ច ក្រៅពីវិស័យកាត់ដេរ និង ទេសចរណ៍ ដើម្បីកាត់បន្ថយភាពងាយទទួលរងគ្រោះដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក ក៏ដូចជាដាក់បញ្ចូល ប្រជាពលរដ្ឋក្រីក្រទៅក្នុងកំណើនសេដ្ឋកិច្ច ដែលក្នុងនោះ ៩០ ភាគរយ រស់នៅជនបទ។

១០. ការចិញ្ចឹមជីវិតរបស់គ្រួសារកម្ពុជាភាគច្រើន ពឹងផ្អែកលើធនធានកសិកម្ម និង ធនធានធម្មជាតិផ្សេងទៀត ។ ប្រជាជនកម្ពុជា ប្រមាណ ៨៥ ភាគរយ រស់នៅតំបន់ជនបទ ដែលក្នុងនោះ ៧០ ភាគរយពឹងផ្អែកជា សំខាន់ទៅលើការប្រកប របរកសិកម្ម ។ ទោះជាយ៉ាងណាក៏ដោយ គ្រួសារភាគច្រើន ជាពិសេសគ្រួសារក្រីក្រ បានធ្វើយុទ្ធសាស្ត្រការចិញ្ចឹមជីវិត ដោយឡែកៗគ្នា ដែលបំពេញបន្ថែមលើផលិតកម្មកសិកម្ម ដោយធ្វើអាជីវកម្មលើធន ធានសម្បត្តិរួម ដូចជា ត្រី និង អនុផល ព្រៃឈើ រួមទាំងជ័រឈើធម្មជាតិផងដែរ (សូមមើល តារាង ៤.១) ។ កំណើនប្រជាជនដ៏លឿនក្នុងរយៈពេលកន្លងមក (២.៥ ភាគរយក្នុងមួយឆ្នាំ) កំពុងតែបន្ថែមចំនួនមនុស្សប្រមាណ ២០០.០០០ នាក់ ទៅលើចំនួនកំលាំងពលកម្មដែលមានស្រាប់ជារៀងរាល់ឆ្នាំ ដែលប្រហាក់ប្រហែលនឹងកំរិត ការងារបច្ចុប្បន្ននៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ ។ ឱកាសការងារនៅ ក្នុងវិស័យផលិតកម្ម និង សេវាកម្ម តាមមិនទាន់កំណើនកំលាំងពលកម្មនេះទេ ដូច្នេះ ធ្វើអោយកំណើននេះនឹងបែរទៅរកការងារនៅជនបទ និង ការងារអាជីវកម្មលើធនធានធម្មជាតិ ដើម្បីចៀសវាងការធ្លាក់ចូលទៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ ។ អ្នកវិនិយោគក្នុងស្រុក និង បរទេសមួយចំនួន កំពុងតែពិនិត្យមើលកាលានុវត្តភាពនៅក្នុងវិស័យកសិកម្ម ព្រៃឈើ និង ជលផល ហើយ ការស្វែងរកសិទ្ធិអោយបានទូលំទូលាយក្នុងការប្រើប្រាស់ធនធានធម្មជាតិ ជាការវិនិយោគថ្មីទៅលើវិស័យផលិតកម្ម និង សេវាកម្ម ដូចបានលើកឡើងនៅក្នុងជំពូកក្រោយ ត្រូវបានរាំងដោយសារតែតំលៃនៃការចាប់ផ្តើមអាជីវកម្មនៅក្នុងវិស័យទាំងនោះមានកំរិតខ្ពស់ពេក ។ នៅក្នុងប្រទេសជាច្រើន ជំលោះបែបនេះ បានរីកធំឡើងយ៉ាងឆាប់រហ័សបណ្តាលអោយមានអំពើហិង្សា ពោលគឺ ជំលោះរវាងវិស័យឯកជននិងវិស័យឯកជន និង រវាងវិស័យឯកជន និង រដ្ឋ (បាននុន អៀន និង ផូល កូលីយើ ឆ្នាំ ២០០៣) ។ ផ្អែកតាមបទ ពិសោធន៍ដែលទទួលបានពីប្រទេស

ដទៃបានបង្ហាញថា ទោះបីជាមិនមានជំលោះកើតឡើងក៏ដោយ ក៏កង្វះ ការគ្រប់គ្រងល្អលើ ធនធានធម្មជាតិ ដែលធ្វើអោយមានការខ្វះខាតទ្រព្យសម្បត្តិកាន់តែច្រើន ដូចជាករណីកើតឡើងនៅកម្ពុជា ជាដើម អាច បង្កើតអោយមានឧបសគ្គ មិនត្រឹមតែចំពោះគុណភាពនៃកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរារាំង ដល់កំណើនសេដ្ឋកិច្ចនេះទៀតផង ហើយនិងកាត់បន្ថយចំណូលសំរាប់ការវិនិយោគនានា ដូចជា ការវិនិយោគ លើវិស័យអប់រំ ជាដើម (សូមមើល ប្រអប់ ៤.១) ។

តារាង ៤.១ : ភាគរយជាមធ្យមនៃប្រភពចំណូលរបស់គ្រួសារនៅជនបទ

| ប្រភពចំណូល | ប្រភពចំណូលរបស់គ្រួសារនៅជនបទ តាមបញ្ចភាគចំណាយ (ភាគរយ) | | | | | |
|---|---|---|---|---|---|---|
| | ក្រីក្របំផុត | ទី ២ | ទី ៣ | ទី ៤ | មានបំផុត | សរុប |
| កសិកម្ម | ៥០ | ៥៤ | ៥៤ | ៥៥ | ៣៧ | ៥០ |
| ធនធានធម្មជាតិរួម | ២១ | ១៦ | ១៥ | ១២ | ៦ | ១៤ |
| ប្រាក់កំរៃ | ៩ | ៩ | ១១ | ១០ | ២៣ | ១៣ |
| ក្រៅពីកសិកម្ម | ៨ | ១២ | ១០ | ១៤ | ២៥ | ១៤ |
| ការផ្ទេរប្រាក់ វិសជ្ជនា ផ្សេងទៀត | ១២ | ៩ | ១០ | ៩ | ៩ | ៩ |
| ចំណូលប្រចាំគ្រួសារជាមធ្យម (១.០០០ រៀល ក្នុងមួយឆ្នាំ) | ២.៥៥៣ | ៣.០៥៧ | ៣.៣៥១ | ៣.៨៧៥ | ៥.៦១៦ | ៣.៦៨៩ |

**ប្រភព : អង្កេតសេដ្ឋកិច្ចនិងសង្គមកិច្ចកម្ពុជាឆ្នាំ ១៩៩៩**

**ប្រអប់ ៤.១ : សារៈសំខាន់នៃលទ្ធភាពប្រើប្រាស់សម្បត្តិធនធានធម្មជាតិសំរាប់កាត់បន្ថយភាពក្រីក្រឱ្យទទួលបាន ជោគជ័យ**

តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ធនាគារពិភពលោកនាពេលថ្មីៗនេះ លើឥទ្ធិពលនៃកង្វះទ្រព្យសកម្ម បាន បង្ហាញថា កំណើនសេដ្ឋកិច្ច និង ការកាត់បន្ថយភាពក្រីក្រមានទំនាក់ទំនងគ្នា ។ ការសិក្សាស្រាវជ្រាវ ទី ១ លើទិន្នន័យ ស្តីពីទំនាក់ទំនងរវាងកង្វះទ្រព្យសកម្ម កំណើនសេដ្ឋកិច្ច និង ការអប់រំ ដែលទទួលបានពីប្រទេសចំនួន ៦០*១ បាន បង្ហាញថា កង្វះទ្រព្យសកម្មដំបូង ដូចដែលបានវាស់ស្ទង់តាមរយៈការបែងចែកដីធ្លី មានផលប៉ះពាល់ធ្ងន់ធ្ងរ ពោលគឺ រារាំងដល់កំណើនសេដ្ឋកិច្ច ។ លើសពីនេះទៀត លទ្ធផលនៃការវិភាគនេះបានបង្ហាញអោយឃើញថា គោលនយោបាយ

ពង្រីកការអប់រំ មានឥទ្ធិពលតិចតួចនៅក្នុងប្រទេសដែលមានការបែងចែកទ្រព្យសកម្មមិនស្មើគ្នា។ ការសិក្សាស្រាវជ្រាវទី ២ លើកគ្នាដែលពន្យល់ពីអត្រា ខុសៗគ្នានៃកំណើនសេដ្ឋកិច្ចពីឆ្នាំ ១៩៦០ ទៅឆ្នាំ ១៩៩០ នៅក្នុង ៧៣ ប្រទេស បានបង្ហាញអោយឃើញពីទំនាក់ទំនងដ៏រឹង មាំនិងជាវិជ្ជមាន រវាងកំណើនសេដ្ឋកិច្ច និងសមធម៌នៃការបែងចែកដីធ្លីដំបូង*២។ សេដ្ឋកិច្ចរបស់ប្រទេសមួយចំនួន ដូចជា ជប៉ុន ម៉ាឡេស៊ី និង ថៃ ដែលមានការបែងចែក ដីធ្លីដោយសមធម៌នៅឆ្នាំ ១៩៦០ មានការកើនឡើងលឿនជាងសេដ្ឋកិច្ច របស់ប្រទេស ដូចជា វេណេហ្ស៊ុអេឡា ប៉េរូ និង កែនយ៉ា ពី ២ ទៅ ៣ ដង ។ ការសិក្សាស្រាវជ្រាវនេះ ក៏បានរកឃើញថា បើ ពិចារណាទៅលើតួនាទីសំខាន់ នៃការវិនិយោគដើម្បីជំរុញឱ្យមានកំណើនសេដ្ឋកិច្ច កម្មវិធីបែងចែកដីធ្លីគួរតែជួយបង្កើនល្បឿន កំណើនសេដ្ឋកិច្ច ដរាបណាកម្មវិធីទាំងនេះនិងគោលនយោបាយពាក់ព័ន្ធ មិនរារាំងដល់ការវិនិយោគទូទៅ។

នៅកម្ពុជា កំណើនវិសមភាពដីធ្លី អាចជាឧបសគ្គរាំងដល់កំណើនសេដ្ឋកិច្ច និង ធ្វើឱ្យលទ្ធផលនៃការអប់រំធ្លាក់ចុះ ។ ការផ្តោតការយកចិត្តទុកដាក់ទៅលើសម្បត្តិដីធ្លីកាន់កាប់ជាទ្រង់ទ្រាយធំ ជាពិសេស តាមរយៈសម្បទានសេដ្ឋកិច្ច ដោយមានករណីលើកលែងតិចបំផុត បានធ្វើអោយមានកំណើនវិនិយោគតិចតួច ។ ហេតុដូច្នេះ ការបង្វែរទិសដៅគោលនយោបាយដីកសិកម្ម ពីសម្បទានកសិកម្មជាទ្រង់ទ្រាយធំ ទៅការគាំទ្រអោយមានការធ្វើសមាហរណកម្មអ្នកមានដីធ្លីតិចតួចចូលទៅក្នុងប្រព័ន្ធទីផ្សារ មានសក្តានុពលធ្វើអោយមានកំណើនផលិតភាព និង កំណើនសេដ្ឋកិច្ច ។ ផ្អែកតាមបទពិសោធន៍នៅក្នុងតំបន់ បានអោយដឹងថា មានជំរើសមួយចំនួនសំរាប់ផ្សារភ្ជាប់ ផលិតភាពអ្នកមានដីធ្លីតិចតួចជាមួយនឹងបច្ចេកវិទ្យា ដំណើរការកែច្នៃ និង គុណសម្បត្តិទីផ្សារកសិ-ពាណិជ្ជកម្មជា ទ្រង់ទ្រាយធំ តាមរយៈកសិដ្ឋានមានកិច្ចសន្យា សម្បត្តិជាមូលដ្ឋាន និង ជំរើស ដទៃទៀត ដែលទើបតែចាប់ផ្តើមអនុវត្តនៅកម្ពុជា ។ ក្រៅពីការធានាឱ្យមានសិទ្ធិកាន់កាប់ដីធ្លីសំរាប់អ្នកមានដីតិចតួច និង ការបែងចែកដីធ្លីឱ្យអ្នក គ្មានដីធ្លី ការបង្វែរទិសដៅគោលនយោបាយដីកសិកម្ម ធ្វើអោយមានកំណើនវិនិយោគទៅលើការ រៀបចំអ្នកផលិត និង ហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលជួយកាត់បន្ថយចំណាយលើការផ្សារភ្ជាប់ទំនាក់ទំនងអ្នកមានដីធ្លីតិចតួច ជាមួយនឹង កសិ-ពាណិជ្ជកម្ម និង ទីផ្សារ ។

*១ ឌីនិងគើ ក្លោស និង ណេត្រូ អូលិនតូ "ការចែកចាយព្រទ្យសកម្ម មិនគ្រប់គ្រាន់ និងកំណើន" ធនាគារពិភពលោក ឆ្នាំ ២០០៣

*២ ឌីនិងគើ ក្លោស និង លីន ស្គេរ "កំណើនសេដ្ឋកិច្ច និង ចំណូលមិនស្មើភាពគ្នាៈ ការសាកល្បងបណ្តាញសារជាថ្មី" ហិរញ្ញវត្ថុ និងការអភិវឌ្ឍ ឆ្នាំ ២០០១

## ខ. រដ្ឋជាអ្នកគ្រប់គ្រងធនធានធម្មជាតិ ~ បទពិសោធន៍ទទួលបានរហូតមកដល់ពេលនេះ

១១. រដ្ឋ គឺជាកម្មសិទ្ធិករនៃសម្បត្តិធម្មជាតិទាំងឡាយក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ កម្មសិទ្ធិដីរបស់រដ្ឋ ត្រូវធ្វើយុត្តិកម្ម នៅពេលដែលឯកជនភាវូបនីយកម្ម មិនអាចផ្តល់ផលប្រយោជន៏ដល់សង្គម នៅពេលដែលរដ្ឋមាន សមត្ថភាពធានា អោយមានការផ្តល់ផលប្រយោជន៏ទូលំទូលាយដល់សាធារណជន ឬ នៅពេលដែលរដ្ឋមានសមត្ថភាពបង្វែរធនធានធម្មជាតិ ដែលបានចុះកិច្ចសន្យាអោយធ្វើអាជីវកម្ម និង ផលចំណេញរបស់ខ្លួនពីធនធានធម្មជាតិនេះ ទៅអោយប្រជាពលរដ្ឋក្រីក្រ ។ ការត្រួតត្រាផ្ទាល់លើទ្រព្យសម្បត្តិទាំងអស់ ជាភារកិច្ចរបស់រដ្ឋកម្ពុជា ចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៩២ ។ ជាលទ្ធផល ទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ រួមមាន តំបន់ព្រៃឈើទាំងអស់ ក្នុងនោះមាន តំបន់ការពារធម្មជាតិ ព្រៃផលិតកម្ម និង ព្រៃសម្បទាន ។ បន្ថែមពីនេះទៀត នេសាទទឹកប្រៃនិងទឹកសាប ផ្លូវទឹក សំណង់តំបន់ការពារធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈដទៃទៀត និង កេមរតកវប្បធមិ និង សម្បត្តិវប្បធមិ និងសម្បត្តិកសិកម្មទ្រង់ទ្រាយធំ ស្ថិត នៅក្រោមសហគ្រាសរដ្ឋ ឬ កិច្ចសន្យាសម្បទាន ។ ផ្ទៃដីដែលស្ថិតនៅក្រោមកម្មសិទ្ធិឯកជនគ្រប់គ្រងប្រមាណ ២.៥០០.០០០ ហ.ត ត្រូវបានកំរិតត្រឹមតែជាដីលំនៅដ្ឋាន និង ដីដាំដុះកសិកម្ម (ជាពិសេស វាលស្រែ) ដែលអាជ្ញាធរមូលដ្ឋាន បានធ្វើការ បែងចែកជាថ្មីម្តងទៀតនៅឆ្នាំ ១៩៨៩ (រូប ៤.២)[១] ដើម្បីអោយកាន់កាប់ជាលក្ខណៈឯកជន ។ ដីជាច្រើនដែល ប្រគល់អោយ

**រូប ៤.២ : ការបែងចែកប្រភេទដីតាមផលប្រយោជន៍**




ចំណាំ : "ផ្សេងទៀត" សំដៅទៅលើដីដែលស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់ រួមទាំង តំបន់អភិវឌ្ឍន៍ផ្នែកយោធា ផ្លូវទឹក និង តំបន់ទីក្រុង/ទីប្រជុំជន ។

យោធាកាន់កាប់ ជាពិសេស មុនពេលមានបទបញ្ញត្តិពីការគ្រប់គ្រង ទ្រព្យសម្បត្តិរដ្ឋឆ្នាំ ១៩៩៧ មានស្ថានភាព ពុំច្បាស់លាស់ ដោយសារមួយផ្នែក ទំនងជាត្រូវបានចែកអោយទៅអតីតយុទ្ធជន ហើយមួយផ្នែកទៀត ត្រូវបានលក់អោយ ទៅអ្នកវិនិយោគឯកជនទៅហើយ ។ ផ្អែកតាមតួលេខនេះ បានឱ្យដឹងថា ដីប្រមាណ ១៤ លានហិចតា ត្រូវជា ៧៥ ភាគ រយនៃផ្ទៃដីសរុប តាមលក្ខណៈបច្ចេកទេស ស្ថិតនៅក្រោម ការគ្រប់គ្រងរបស់រដ្ឋ ទោះ បីជាមួយផ្នែកធំនៃដីនេះ ស្ថិតនៅ ក្រោមការកាន់កាប់ខុសច្បាប់ក៏ដោយ ។

១២. ការបែងចែកជាផ្លូវការនូវប្រភេទដីជាដីសាធារណៈ ឬ ដីឯកជន ពុំទាន់មានន័យគ្រប់គ្រាន់នៅឡើយ ។ ដីជាច្រើនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ត្រូវអ្នកមានដីធ្លីតិចតួចកាន់កាប់ ឬ ត្រូវអ្នកមានប្រាក់មានអំណាចចាប់យក រួមទាំងដីដែលសមស្របសំរាប់ការប្រើប្រាស់ជាលក្ខណៈឯកជន និង ដីសាធារណៈរបស់រដ្ឋ ដែលទុកសំរាប់តំបន់ការពារធម្មជាតិ ។ លើសពីនេះទៀត គេមិនបានដឹងច្បាស់លាស់អំពីតំបន់ទីតាំង និង ព្រំប្រទល់ដីសាធារណៈរបស់រដ្ឋទេ ហើយការទទួលខុស ត្រូវរបស់ស្ថាប័នក្នុងការកំណត់ទីតាំង ការវាស់វែង និង ការកំណត់ព្រំប្រទល់ដីរបស់រដ្ឋ ពុំសូវមានលក្ខណៈច្បាស់លាស់ទេ ។ ឧទាហរណ៍ : ការធ្វើបរិវត្តន៍ព្រៃឈើ និង ការអភិវឌ្ឍន៍ដី ភាគច្រើនត្រូវធ្វើឡើងដោយមិនមានការធ្វើផែនការ និង មិនមានការគ្រប់គ្រងត្រឹមត្រូវ ។ ការពិនិត្យវាយតំលៃវិស័យដោយឯករាជ្យ (**Independent Sector Review**) បានប៉ាន់ស្មានអំពីអត្រាកាប់ឈើ ប្រចាំឆ្នាំ គឺ ១ ភាគរយ ដោយមានបាត់បង់ជាច្រើននៅក្នុងតំបន់សំខាន់ៗមួយចំនួន ដូចជា តំបន់ភាគពាយព្យក្បែរ ព្រំដែនថៃ ខេត្តរតនគិរី តាមដងផ្លូវជាតិលេខ ៤ និងផ្លូវតាមឆ្នេរសមុទ្រ និង ព្រៃលិចទឹកនៅជុំវិញ បឹងទន្លេសាប ។[២] ព្រៃឈើកម្ពុជាសព្វថ្ងៃ គឺនៅសល់ពីទាយជ្ជទានធនធានធម្មជាតិរបស់ប្រទេសជាតិ ការកាប់ឈើខុសច្បាប់ និង កំណើនដំណោះស្រាយក្នុងវិស័យកសិកម្ម ។ ការទន្ទ្រានយកដីព្រៃឈើជាច្រើនពីសំណាក់កសិករ ដែលបន្ទាប់មក អាចមាន ការកាប់ឈើដោយខុសច្បាប់ផងនោះ គឺជាការគំរាមកំហែងដ៏ខ្លាំងក្លាបំផុតចំពោះធនធានព្រៃឈើ ។ ការធ្វើបរិវត្តន៍ក៏ជារូបភាពមួយនៃ"សម្បទានដីសេដ្ឋកិច្ច" សំរាប់ការអភិវឌ្ឍន៍ការដាំដុះកសិកម្ម ជាទ្រង់ទ្រាយធំ ។ ទោះបីជាតំបន់ដីព្រៃឈើជាច្រើនមានសក្តានុពលភាពក្នុងការប្រើប្រាស់ប្រកបដោយនិរន្តរភាព ក្រោមកម្មវិធីដីកសិកម្ម និងកម្មវិធីដីផ្សេងទៀតក៏ដោយ ក៏ការធ្វើបរិវត្តន៍ក្នុងពេលបច្ចុប្បន្ន នៅតែប្រឈមមុខនឹងបញ្ហាដោយសារមិនមានការវាយតំលៃ ឬ ការកំណត់អំពីតំបន់ដែលអំណោយផលចំពោះការដាំដុះកសិកម្ម ហើយមិនមាននីតិវិធី ឬ ផែនការសំរាប់ធ្វើនិយតកម្មលើបរិវត្តន៍ដីព្រៃឈើទៅជាការ ប្រើប្រាស់ដើម្បីគោល

ដោយផ្សេងៗ និង សំរាប់ធានាថា ការធ្វើបរិវត្តន៍ ត្រូវតែបំរើឱ្យផលប្រយោជន៍សាធារណៈ និង ត្រូវ ធ្វើឡើង ប្រកបដោយតម្លាភាព ដោយប្រើប្រាស់ វិធីសាស្ត្រគ្រប់គ្រងដីធ្លីដែលមានប្រសិទ្ធិភាពខ្ពស់នោះទេ ។

១៣. យន្តការរបស់រាជរដ្ឋាភិបាលសំរាប់គ្រប់គ្រងធនធានធម្មជាតិឱ្យមានប្រសិទ្ធិភាព គឺ ការចុះកិច្ចសន្យាអាជីវកម្មលើដី មួយភាគធំ ជាមួយនឹងអ្នកវិនិយោគកម្ពុជានិងបរទេស ។ កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចចំនួនប្រហែល ៥៧ សំរាប់ការងារ កសិកម្ម លើផ្ទៃដី ៩៤០.០០០ ហ.ត ត្រូវបានផ្តល់ជូនជាផ្លូវការ ចាប់តាំងពីដើម ទសវត្សរ៍ឆ្នាំ ៩០ មក ជាពិសេស សំរាប់ ការដាំដុះដំណាំឈើហូបផ្លែ ដែលក្នុងនោះ កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចនីមួយៗ មានទំហំចាប់ពី ៥០០ ទៅ ជាង ៣០០.០០០ ហ.ត (សូមមើល តារាង ៤.២) ។ កិច្ចសន្យាសម្បទាន សំរាប់តំបន់ព្រៃឈើ ដែលត្រូវបានផ្តល់ជូនជាផ្លូវការ ចាប់តាំងពីដើម ទសវត្សរ៍ឆ្នាំ ៩០ មក គឺមានចំនួន ៣០ លើផ្ទៃ ដីព្រៃឈើជាង ៦ លានហ.ត។ ប្រព័ន្ធសម្បទាននេសាទ ត្រូវបានអនុវត្ត នៅចុងទសវត្សរ៍ឆ្នាំ ៨០ និង នៅត្រឹម ឆ្នាំ ១៩៩៩ ក្នុងនោះ មានឡូត៍នេសាទចំនួន ២៧០ កន្លែងដែលមានផ្ទៃក្រឡាសរុប ៩៥០.០០០ ហ.ត ។ ក្រៅពី កិច្ចសន្យាសម្បទានផ្លូវការទាំងនេះ នៅមាន កិច្ចសន្យាសម្បទានមួយចំនួនទៀត ដែលត្រូវបានផ្តល់ជូនដោយយោធា សំរាប់ការធ្វើអាជីវកម្មលើដីធ្លីដែល ខ្លួនទទួលបានសំរាប់គោលដៅសន្តិសុខ ។ ជាទូទៅ ការផ្តល់កិច្ចសន្យា សម្បទាននេះ ត្រូវបានធ្វើឡើង ដោយ គ្មានដំណើរការសំរបសំរួលជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬ គណៈរដ្ឋមន្ត្រីទេ ។ បន្ទាប់ពីមានការពិនិត្យត្រឹមត្រូវ គេសង្កេតឃើញថា ព្រំប្រទល់នៃតំបន់សម្បទាន ទាំងនេះ ភាគច្រើនជាន់ លើតំបន់សម្បទាន តំបន់ព្រៃឈើ ឬ តំបន់ការពារធម្មជាតិ ដែលមានស្រាប់ ។

**តារាង ៤.២ : ស្ថានភាពគ្រប់គ្រងធនធានធម្មជាតិរបស់រដ្ឋ** (ចំនួនគិតជា ហិចតា)

| ប្រព័ន្ធគ្រប់គ្រង | ដីកសិកម្ម | ព្រៃឈើ | នេសាទ | សរុប |
|---|---|---|---|---|
| កិច្ចសន្យាសម្បទានសរុប | 940.000 (57) | 6.875.498 (29) | 953.812 (270) | 8.769.310 |
| កិច្ចសន្យាសម្បទានដែលត្រូវលុបចោល | 123.680 (16) | 3.501.170 (17) | 538.522 (110) | 4.163.372 |
| កិច្ចសន្យាសម្បទានដែលនៅសល់ | 816.320 (41) | 3.374.328 (12) | 415.290 (160) | 4.605.938 |
| តំបន់អភិរក្ស | | 4.650.000 (29) | | 4.650.000 |
| តំបន់គ្រប់គ្រងដោយសហគមន៍ | 50.000* | 71.724 | 227.785 | 299.509 |

* ផែនការសម្បទានដីសង្គមរហូតដល់ឆ្នាំ ២០០៨

ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ **McKinney** និង តុលា

១៤. ដូចនៅក្នុងវិស័យដទៃទៀតដែរ (សូមមើលជំពូកទី ៥) ប្រព័ន្ធសម្បទាន មិនទាន់ក្លាយជាយន្តការមួយដែលមានប្រសិទ្ធិភាពក្នុងការផ្តល់នូវផលប្រយោជន៍សាធារណៈនៅឡើយទេ ។ តាមធម្មតា កិច្ចសន្យាសម្បទាន ត្រូវបានផ្តល់ជូនតាមរយៈដំណើរការពិសេសដែលគ្មានតម្លាភាព ។ ការជ្រើសរើសធនធានសំរាប់កិច្ចសន្យាសម្បទាន ត្រូវបានធ្វើឡើងដោយមិនមានការវាយតំលៃលទ្ធភាពជាមុន ។ សិទ្ធិកាន់កាប់មុនៗ និងសិទ្ធិកាន់កាប់ដែលមានរឿងវិវាទ មិនទាន់ត្រូវបានកំណត់ និង ដោះស្រាយនៅឡើយ ។ ការជ្រើសរើសអ្នកវិនិយោគ ត្រូវបានធ្វើឡើងដោយគ្មានគោលការណ៍ត្រឹមត្រូវ ដើម្បីធានាអោយ មានសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុគ្រប់គ្រាន់សំរាប់អនុវត្តកិច្ចសន្យា ។ លើសពីនេះទៀត ស្ថាប័នរាជរដ្ឋាភិបាល មិន មានលទ្ធភាពអនុវត្តកិច្ចសន្យាទេ ។ ជាលទ្ធផល ផែនការសម្បទាន អនុវត្តមិនបានល្អ ដោយផ្តល់នូវផលប្រយោជន៍សាធារណៈ តិចតួច ។

១៥. ចំណូលផ្ទាល់ពីកិច្ចសន្យាសម្បទាន មានកំរិតទាបជាងចំណូលដែលបានគ្រោងទុកឆ្ងាយណាស់ ឬមិនមានចំណូលសោះ ដែលបង្ហាញអោយឃើញថា ប្រសិទ្ធិភាពផលិតកម្មដើម្បីទាក់ទាញតំលៃខ្ពស់បំផុតសំរាប់ធនធាននេះ មានកំរិតទាបណាស់។ មិនមានការបង់ចំណូលពន្ធពីកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចទេ ដែលឆ្លុះបញ្ចាំងឱ្យឃើញថា អត្រាប្រើប្រាស់ដីធ្លីដោយអ្នកអនុវត្តសិទ្ធិសម្បទាន នៅមានកំរិតទាបណាស់ (តាមការប៉ាន់ស្មានគឺមានតិចជាង ២ ភាគរយ) ។ ទោះជាយ៉ាងណាក៏ដោយ វាគួតែត្រូវបានគេកត់ចំណាំថា សម្បទានបានបង់ប្រាក់កក់ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ចំណូលផ្លូវការពីវិស័យ ព្រៃឈើដែលតាមការគ្រោងទុក មានពី ៥០ ទៅ ១០០ លានដុល្លាអាមេរិកក្នុងមួយឆ្នាំនោះ ទទួលបានជាមធ្យមគឺតិចជាង ១០ លានដុល្លា អាមេរិក ដោយសារមានការគេចមិនបង់ពន្ធផ្លូវការយ៉ាងច្រើន ។ ការផ្អាកការកាប់ឈើនៅក្នុងកិច្ចសន្យា សម្បទាន និង ការដឹកជញ្ជូនឈើហ៊ុប ត្រូវបានប្រកាសជាផ្លូវការនៅខែ មករា ឆ្នាំ ២០០២ ដោយសារមាន ការកើនឡើងនូវ ការព្រួយបារម្ភលើការកាប់ឈើដោយគ្មាននិរន្តរភាព នៅក្នុងកិច្ចសន្យាសម្បទាន និង កង្វះសមត្ថភាពរបស់អ្នកអនុវត្តសិទ្ធិសម្បទាន ក្នុងការដាក់ជូនពិនិត្យនូវ "ផែនការគ្រប់គ្រងព្រៃឈើជាយុទ្ធសាស្ត្រ" ទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់នៅមុនដំណាច់ឆ្នាំ ២០០១ ។

ចំណូលពីវិស័យ នេសាទជាមធ្យម គឺតិចជាង ៣ លានដុល្លាអាមេរិកក្នុងមួយឆ្នាំ ក្នុងអំឡុងពេលជាងមួយទសវត្សរ៍កន្លងមកនេះ ។

១៦. ផលប្រយោជន៍សាធារណៈពីការគ្រប់គ្រងរបស់រដ្ឋលើដីកសិកម្ម ព្រៃឈើ និង ជលផល មានកំរិតទាបណាស់ ។ ផលិតផលក្នុងស្រុកសរុបពីធនធានធម្មជាតិ (GDP) បានកើនឡើងជាង ២ ភាគរយក្នុងមួយឆ្នាំ ចាប់ពី ឆ្នាំ ១៩៩៧ ដល់ឆ្នាំ ២០០២ ដោយវិស័យព្រៃឈើ និង ការដាំដុះកសិកម្ម រួមចំណែកក្នុងកំរិតមួយដ៏ទាបក្នុងកំណើន សេដ្ឋកិច្ច (សូមមើលរូប ៤.៣) ។ នេះ ឆ្លុះបញ្ចាំងឱ្យឃើញថា ផ្នែកនេះ ផ្តល់នូវការងារតិចតួច និង ធ្វើអោយវិស័យ នាំចេញធ្លាក់ចុះទៀតផង ។ តំបន់ការពារធម្មជាតិដែលមានទំហំជាង ១/៤ (មួយភាគបួន) នៃផ្ទៃដីប្រទេសកម្ពុជា មិនបានការពារអោយមានប្រសិទ្ធិភាពនូវ ជីវចំរុះ អាងរងទឹកភ្លៀង និង បរិស្ថានដែលមានសារៈសំខាន់ចំពោះប្រទេសជាតិ ក៏ដូចជាពិភពលោក (NIS ឆ្នាំ ២០០៣) ។

រូប ៤.៣ : ចំណែកនៃធនធានធម្មជាតិក្នុងផលិតផលក្នុងស្រុកសរុប (គិតជា ពាន់លានរៀល តំលៃថេរក្នុងឆ្នាំ ១៩៩៣)




ប្រភព : មូលនិធិរូបិយវត្ថុអន្តរជាតិ

១៧. សហគមន៍ក្នុងមូលដ្ឋាន ក៏មិនបានមើលឃើញមានការកើនឡើងនូវលទ្ធភាពរបស់ខ្លួនក្នុងការប្រើប្រាស់ធនធានធម្មជាតិដែរ ។ ទោះបីជាមិនមានទិន្នន័យសំរាប់ប្រៀបធៀបក៏ដោយ ក៏គេអាចដឹងបានថាទំហំដីកសិកម្ម ជាមធ្យមកាន់កាប់ ដោយគ្រួសារមួយ ហាក់ដូចជាមានការថយចុះនៅតំបន់ជនបទ ពោលគឺតិចជាងទំហំកំណត់ ដែលអាចផ្គត់ផ្គង់ស្បៀងគ្រប់គ្រាន់ដល់គ្រួសារ ។ តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវខុសៗគ្នាបានអោយដឹងថា អ្នកគ្មានដីធ្លី មានពី ១២ ទៅ ១៥ ភាគរយ នៃប្រជាជនសរុបនៅជនបទ ហើយ

បុព្វហេតុចំបងនៃការគ្មានដីធ្លី ដូចជា គូស្រករទើបរៀបថ្មីចង់បានដីធ្លីផ្ទាល់ខ្លួន គួបផ្សំជា មួយនឹងកំណើនប្រជាជននាពេលបច្ចុប្បន្ន និង ឱកាសការងារ តិចតួចនោះ បានបង្ហាញអោយឃើញថា អ្នកគ្មានដីធ្លីកំពុងតែមានការកើនឡើង ។ ទោះបីជាពិតមានទាក់ទងនឹងការ បែងចែកដីធ្លី នៅមិនទាន់យកជាការបានទាំងស្រុងក៏ដោយ (លោក ចាន់ សុផល ទេព សារាវី និង សន្ទី អាចារិយា ឆ្នាំ ២០០១) ផ្អែកតាមការថយចុះនៃទំហំកសិដ្ឋានជាមធ្យម និង កំណើនអ្នកគ្មានដីធ្លី បានបង្ហាញឃើញថា ការបែងចែកដីធ្លី អាចធ្វើអោយកំណើនសេដ្ឋកិច្ច លើមូលដ្ឋានទូលំទូលាយ ដែលកំពុងស្ថិតក្នុងស្ថានភាពមិនល្អនេះ កាន់តែធ្លាក់ចុះថែមទៀត ។

១៨. ការកាត់បន្ថយលទ្ធភាពប្រើប្រាស់ទ្រព្យសម្បត្តិរួម អាចបង្កអោយមានអស្ថេរភាពសង្គមនៅតាមជនបទ ។ តាមលទ្ធផល នៃការសិក្សាស្រាវជ្រាវខុសៗគ្នានៅមូលដ្ឋាន (លោក គីម សិដារា លោក ចាន់ សុផល និង សន្ទី អាចារិយា) បានបង្ហាញអោយឃើញថា ប្រជាជនកំពុងតែជួបប្រទះនូវការលំបាកកាន់ តែខ្លាំងឡើងក្នុងការប្រមូលអនុផលព្រៃឈើ និង ការនេសាទត្រី ដោយសារការដាក់កំរិតលើលទ្ធភាពប្រើប្រាស់ធនធានដែល ធ្វើឡើងដោយអ្នកអនុវត្តសិទ្ធិសម្បទាន ការបាត់បង់ធនធានបណ្តាលមកពីការធ្វើអាជីវកម្ម ដែលគ្មាននិរន្តរភាព និង សំពាធកំណើនប្រជាជន ។ មិនតែប៉ុណ្ណោះ ជំលោះទាក់ទងនឹងដីធ្លី ធនធានព្រៃឈើ និង នេសាទ ហាក់ដូចជាកាន់តែរីករាលដាលឡើង[៣] ។ ជំលោះទាំងនេះ កើតមានឡើង រវាងអ្នកភូមិ និង អ្នកភូមិ រវាងអ្នកភូមិ និង អ្នកខាងក្រៅដែលដណ្តើមកាន់កាប់ដី ដែលអ្នកភូមិកំពុងប្រើប្រាស់សំរាប់សកម្មភាពកសិកម្ម ឬ សកម្មភាពរួម និង រវាងអ្នកភូមិ និង អ្នកអនុវត្តសិទ្ធិសម្បទាន ជាពិសេសទាហានអភិរក្ស ដោយសារសម្បទានដី ត្រូវបានដាក់បញ្ចូលដីភូមិ ឬ ដោយសារសម្បទានដីនេះ ធ្វើអោយមានការខូចខាត ឬ កាត់បន្ថយលទ្ធភាពប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម ។

១៩. រាជរដ្ឋាភិបាល បានទទួលស្គាល់ចំពោះចំណុចអសកម្មលើការអនុវត្តន៏កិច្ចសន្យាសម្បទានមួយចំនួន ដែលកំពុងដំណើរការ ហើយបានលុបចោលកិច្ចសន្យាសម្បទាននិងឡូត៍នេសាទប្រហែល ៤០ ភាគរយ ដែលគ្របដណ្តប់ ជិតពាក់កណ្តាល នៃតំបន់សម្បទានសរុប (សូមមើលតារាង ៤.២) ។ តាមសេចក្តីរាយការណ៍ បានអោយដឹងថា កិច្ចសន្យាសម្បទានដីកសិកម្មចំនួន ១៦ ត្រូវបានលុបចោលចំនួន ២ កំពុងស្ថិតក្នុងដំណើរការលុបចោល ហើយចំនួន ១១ ទៀត ត្រូវបញ្ឈប់សកម្មភាព ។ លើសពីនេះទៀត សម្បទានដីកសិកម្មសរុប នឹងត្រូវកាត់បន្ថយមកនៅត្រឹមតែ ១០.០០០ ហ.ត ដូចមានចែងនៅក្នុងច្បាប់ ភូមិបាលឆ្នាំ ២០០១ ។

ការព្រួយបារម្ភចំពោះកង្វះការត្រួត ពិនិត្យលើអត្រាកាប់ឈើនៅក្នុងតំបន់ព្រៃសម្បទាន បាននាំទៅដល់ការរៀបចំក្របខ័ណ្ឌនិងដំណើរការ សំរាប់ធ្វើ សនិទានកម្មលើវិស័យនេះ តាមរយៈការលុបចោលទាំងស្រុងនិងល័ក្ខខណ្ឌតំរូវអោយមានការដាក់ជូនពិនិត្យ និង ការពិនិត្យមើលលើផែនការគ្រប់គ្រងព្រៃជាយុទ្ធសាស្ត្រ (SFMP) ។ លើសពីនេះទៀត ការផ្អាកជាបណ្តោះអាសន្នចំពោះ ការកាប់ឈើក្នុងកិច្ចសន្យាសម្បទាន និងការដឹកជញ្ជូនឈើហ៊ុប កំពុងស្ថិតនៅជាធរមានរយៈពេលជាង ១៨ ខែ។ ក្រៅពីកិច្ចសន្យាសម្បទានចំនួន ១២ កិច្ចសន្យាសម្បទានទាំងអស់ដែលគ្រប ដណ្តប់លើផ្ទៃដី ៣.៣ លាន ហ.ត ត្រូវបានលុបចោលរួចហើយ ឬ អ្នកវិនិយោគបានដកថយចេញ ហើយកិច្ចសន្យាសម្បទាន ជាច្រើនទៀត ទំនងជានឹងត្រូវលុបចោលដោយផ្អែកលើលទ្ធផលនៃការវាយតំលៃផែនការគ្រប់គ្រងព្រៃឈើជាយុទ្ធសាស្ត្រ ។ ជំលោះដ៏ ស្រួចស្រាល់រវាងម្ចាស់ឡូត៍នេសាទ និង សហគមន៍ក្នុងមូលដ្ឋាន បាននាំទៅដល់ការធ្វើកំណែទំរង់នៅឆ្នាំ ២០០១ ដែលបានកាត់បន្ថយចំនួនឡូត៍នេសាទ មកនៅត្រឹម ១៦០ នៅឆ្នាំ ២០០៣ ហើយផ្ទៃឡូត៍នេសាទសរុបនៅសល់ត្រឹម តែជាង ៤០០.០០០ ហ.ត ប៉ុណ្ណោះ ។ លទ្ធផលដែលទទួលបានពីការធ្វើសនិទានកម្មលើប្រព័ន្ធសម្បទាន មានជាងពាក់កណ្តាលនៃតំបន់ព្រៃ តំបន់នេសាទ និងតំបន់កសិកម្ម ពីការគ្រប់គ្រងដោយការធ្វើសម្បទាន។

២០. យន្តការសំខាន់ សំរាប់គ្រប់គ្រងធនធានធម្មជាតិដែលទទួលបានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជារហូតដល់សព្វថ្ងៃនេះ គឺ យុទ្ធវិធីផ្តោតលើសហគមន៍ ។ ទោះបីជាយន្តការនេះ នៅមានកំរិត បើប្រៀបធៀបជាមួយនឹងតំបន់សម្បទានក៏ដោយ ក៏ទំហំនៃធនធានធម្មជាតិដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគមន៍ មានការកើនឡើងយ៉ាងឆាប់រហ័ស ។ ទាក់ទងនឹង ធនធានសម្បត្តិរួម វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍកម្ពុជា បានប៉ាន់ស្មានថា គំរោងសហគមន៍ព្រៃឈើ ចំនួន ២៣៧ ដែលគ្របដណ្តប់លើផ្ទៃដីជាង ៧០.០០០ ហ.ត និង សហគមន៍នេសាទចំនួន ១៦២ ដែលមានផ្ទៃឡូត៍នេសាទ ប្រហែល ២២៥.០០០ ហ.ត បានចាប់ដំណើរការនៅ ឆ្នាំ ២០០២ ដោយទទួលបាននូវការឧបត្ថម្ភគាំទ្រជាសំខាន់ពីអង្គការ មិនមែនរដ្ឋាភិបាល (ប្រួស មាយែនី និង ព្រុំ តុលា ឆ្នាំ ២០០២) ។ រាជរដ្ឋាភិបាល បានប្រកាសអោយដឹងថា ខ្លួនគ្រោងនឹងធ្វើការចែកចាយដីរបស់រដ្ឋប្រមាណ ៥០.០០០ ហ.ត អោយទៅគ្រួសារដែលគ្មានដីធ្លី និងគ្រួសារក្រីក្រដែលមានដីធ្លីតិច ចំនួនយ៉ាងតិច ១០.០០០ គ្រួសារ ក្នុងរយៈពេល ជាង ៥ ឆ្នាំខាងមុខក្រោមកម្មវិធីសម្បទានដីសង្គម ដែលនឹងជំរុញអោយមានការធ្វើឯកជនភាវូបនីយកម្មលើដីរបស់រដ្ឋ ។ តាំង

ពីមុនមក ការគ្រប់គ្រងរបស់សហគមន៍ ផ្តោតទៅលើតំបន់ដីគ្មានជីជាតិ ឬ តំបន់ដីមានផលិតភាពទាប ហើយមានការវាយតំលៃតិចតួចទៅលើប្រសិទ្ធិភាពនៃយុទ្ធវិធីផ្តោតលើសហគមន៍ជាមូលដ្ឋាន ដើម្បីធានាអោយមានការគ្រប់គ្រងប្រកប ដោយប្រសិទ្ធី ភាពលើធនធានសំរាប់បំរើឱ្យផលប្រយោជន៍ក្នុងមូលដ្ឋានឬតំបន់ផ្សេងទៀត ។ ទោះជាយ៉ាងណាក៏ដោយទាំងរាជរដ្ឋាភិបាល និង ម្ចាស់ជំនួយមានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងចំពោះបញ្ហានេះ ដោយនាំទៅដល់ការអនុវត្តយុទ្ធវិធី ទាំងនេះជាមួយធនធានមានតំលៃខ្ពស់ៗ ដែលតាមរយៈនេះ ការវាយតំលៃលើការដោះដូរផលប្រយោជន៍ជាមួយនឹងការគ្រប់ គ្រងផ្សេងទៀត អាចធ្វើឡើងបានកាន់តែឆាប់រហ័ស ។

## គ. ពង្រឹងមូលដ្ឋានគ្រឹះសំរាប់លើកកំពស់ការគ្រប់គ្រងធនធានធម្មជាតិ

២១. ផលប្រយោជន៍តិចតួចដែលទទួលបានពីសម្បទានទាំងនេះ ឆ្លុះបញ្ចាំងអោយឃើញពីតំរូវការអោយមានការពង្រឹងមូលដ្ឋានគ្រឹះសំរាប់ការគ្រប់គ្រងធនធានធម្មជាតិនៅកម្ពុជា ពោលគឺ ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ ក៏ដូចជា មូលដ្ឋានព័ត៌មាន ទាក់ទងនឹងធនធានទាំងនេះ ។ ការពង្រឹងមូលដ្ឋានគ្រឹះសំរាប់ការគ្រប់គ្រងធនធាននៅកម្ពុជានេះ ក៏មានសារៈសំខាន់ក្នុងការ ពង្រីកយុទ្ធវិធីផ្តោតលើសហគមន៍ និងយុទ្ធវិធីគ្រប់គ្រងដទៃទៀត ។

២២. គោលនយោបាយរបស់រាជរដ្ឋាភិបាលដូចមានចែងនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច ៥ ឆ្នាំ លើកទី២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និង យុទ្ធសាស្ត្រចតុកោណ បានទទួលស្គាល់ពីតួនាទីសំខាន់របស់ធនធានធម្មជាតិ ។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយទាំងនេះ មិនបានផ្តល់ការណែនាំណាមួយអំពី លំដាប់អាទិភាពទាក់ទងនឹងផល ប្រយោជន៍សាធារណៈ ដែលទទួលបានពីធនធានទាំងនេះនៅឡើយទេ( ឃើត ម៉ៃឃើល ឆ្នាំ ២០០៤) ។ ជាទូទៅ ភារកិច្ចកំណត់អាទិភាពត្រូវផ្ទេរអោយទៅស្ថាប័នគ្រប់គ្រងធនធាន ដែលតាមធម្មតា បំរើអោយតែផលប្រយោជន៍ របស់វិស័យនីមួយៗដែលមានមូលដ្ឋានតូចចង្អៀត មិនធ្វើការវិភាគលើការដោះដូរផលប្រយោជន៍ជាមួយនឹងការប្រើប្រាស់ធនធាន និង បញ្ជាក់ឱ្យច្បាស់អំពីអាទិភាពជាតិទេ ។ មានការដោះដូរផលប្រយោជន៍ រវាងការថែរក្សា ជាប្រចាំ និង ការពង្រីកតំបន់ព្រៃឈើនិងនេសាទ និង សំពាធក្នុងការពង្រីក ដីធ្លីក្រោមកម្មវិធីកសិកម្ម ក៏ដូចជា ការដោះដូរផលប្រយោជន៍រវាងតួនាទីរបស់អ្នកមានដីធ្លីតិច និង ការគ្រប់គ្រងរបស់សហគមន៍ ទាក់ទងនឹងយុទ្ធវិធី

សម្បទាន និង រវាងការបង្កើនលទ្ធភាពផ្ទាល់ដល់សហគមន៍ក្នុងការប្រើប្រាស់ធនធានសម្បត្តិរួម និង ផែនការរបស់រដ្ឋដើម្បីបង្កើនចំណូល ឬ គោលដៅផ្សេងទៀតរបស់ជាតិ ( សូមមើលប្រអប់ ៤.២ ) ។

**ប្រអប់ ៤.២ : តំរូវការអោយមានទស្សនៈវិស័យរួមខាងនយោបាយចំពោះព្រៃឈើ**

"ការពិនិត្យវាយតំលៃវិស័យព្រៃឈើដោយឯករាជ្យ" ដែលទទួលបានការឧបត្ថម្ភពីរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ បានវាយតំលៃលើស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងព្រៃឈើក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការពិនិត្យវាយតំលៃនេះ បានផ្តោតទៅលើតំរូវការអោយមានការបញ្ជាក់ឱ្យបានច្បាស់លាស់អតអំពីទិសដៅនៃការគ្រប់គ្រងព្រៃឈើ ដោយពិចារណាទៅលើការដោះដូរផលប្រយោជន៍ជាមួយនឹងការបែងចែកដីធ្លីសំរាប់តំបន់ការពារធម្មជាតិ ព្រៃ ផលិតកម្ម និង ការធ្វើបរិវត្តន៍ចំពោះកសិកម្ម ។ ដំណើរការពិនិត្យវាយតំលៃនេះ បានធ្វើការសន្និដ្ឋានថា:

"កង្វះទស្សនៈវិស័យរួមខាងផ្នែកនយោបាយសំរាប់ដឹកនាំការចរចារលើវិស័យនេះ បង្កអោយមានផលប៉ះពាល់ ជាចំបងមួយចំនួន ដូចជា បង្កើតអោយមានចន្លោះសំរាប់ការធ្វើសេចក្តីសំរេចនិងបទដ្ឋានគតិយុត្តិនៅខាងក្រៅបរិបទ រួមនៃទស្សនៈវិស័យ និងយុទ្ធសាស្ត្ររួមដែលអាចនាំទៅដល់ការបំបែកដំណើរការនេះ បង្កើតអោយមានឱកាសសំរាប់ការដណ្តើមយកការគ្រប់គ្រងលើ ដំណើរការមួយចំនួននិងការសំរេចលទ្ធផលដោយគ្មានការពិគ្រោះយោបល់អោយបានទូលំទូលាយ និង អនុញ្ញាតអោយមានការធ្វើសេចក្តីសំរេចលើទិសដៅជាយុទ្ធសាស្ត្រ ដែលត្រូវអនុវត្តតាមរយៈការចរចាលើខ្លឹមសារនៃច្បាប់ និងអនុក្រឹត្យនានា ។ ឧទាហរណ៍ : មានដំណើរការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើ មុនពេលមានការយល់ច្បាស់ថាតើសម្បត្តិសាធារណៈ គឺជាអ្វីនោះ ។

អ្នកធ្វើអត្ថាធិប្បាយជាច្រើន បានទាមទារឱ្យមានការអនុវត្តន៍ ជាជាងវិនិយោគបន្តទៅលើការរៀបចំតាក់តែង និងការចរចាលើគោលនយោបាយ ។ ទោះជាយ៉ាងណាក៏ដោយ ដរាបណាវិស័យនេះ នៅតែមិនមាន គោលនយោបាយសំរាប់បំភ្លឺផ្លូវ ពីព្រោះថា ដំណើរការសាធារណៈ មានការបញ្ជាក់ច្បាស់លាស់អំពីជំរើស និង អាទិភាពនានាដែលបានព្រមព្រៀងគ្នានោះ វិស័យនេះ ងាយនឹងទទួលរងគ្រោះ ដោយសារការអនុវត្តន៍ជាបន្ត បន្ទាប់នូវដំណើរការមិនរលូនដែលស្ថិតនៅក្រោមឥទ្ធិពលរបស់អ្នកមានប្រាក់មានអំណាចបំផុត ។ តំរូវការអោយមានដំណើរការពិគ្រោះយោបល់គោលនយោបាយអោយបានពេញ លេញនិងទូលំទូលាយ មានលក្ខណៈច្បាស់លាស់ និង បង្កើតបានជាយន្តការសំខាន់មួយ ដែលតាមរយៈនេះ នឹងប្រមូលផ្តុំនូវ តួអង្គអភិវឌ្ឍន៍នានាអោយមកចូលរួម ដើម្បី ដោះស្រាយបញ្ហាចំបងៗ ដូចខាងក្រោម :

| |
|---|
| ១. តើព្រៃឈើប្រើប្រាស់សំរាប់ធ្វើអ្វី ? |
| ២. តើនរណាជាអ្នកត្រូវការព្រៃឈើ ? |
| ៣. តើព្រៃឈើមាននៅឯណា ? |
| ៤. តើមានតំរូវការព្រៃឈើប៉ុន្មាន សំរាប់បំពេញឱ្យសំណួរទី ១ និងទី ២ ?" |
| ប្រភព: ក្រុមការងារបច្ចេកទេសព្រៃឈើ ការពិនិត្យឡើងវិញលើវិស័យព្រៃឈើដោយឯករាជ្យ ឆ្នាំ ២០០៤ |

២៣. តួនាទីរបស់រាជរដ្ឋាភិបាលជាកម្មសិទ្ធិករនៃធនធានធម្មជាតិដើម្បីផលប្រយោជន៍សាធារណៈ ត្រូវបានកំណត់យ៉ាង ច្បាស់លាស់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយក្របខ័ណ្ឌច្បាប់សំរាប់គ្រប់គ្រងធនធានធម្មជាតិ បានផ្តល់ជាឯកសារច្បាប់កាន់តែច្រើនដល់រាជរដ្ឋាភិបាលសំរាប់យកទៅអនុវត្ត ប៉ុន្តែនៅមានបញ្ហា មិនច្បាស់លាស់មួយចំនួនដែលមិន ទាន់ត្រូវបានដោះស្រាយ ។ ក្នុងចំណោមច្បាប់ស្តីអំពីដីធ្លី ព្រៃឈើ នេសាទ ធនធានទឹក និង តំបន់ការពារធម្មជាតិ មានមួយចំនួនត្រូវបានអនុម័តនាពេលកន្លងទៅថ្មីៗនេះ ហើយមួយចំនួន ទៀត ស្ថិតនៅក្រោមការពិចារណារបស់រដ្ឋសភា ឬ គណៈ រដ្ឋមន្ត្រី (សូមមើលតារាង ៤.៣ ) ។ ច្បាប់ទាំងនេះ បាន បញ្ជាក់យ៉ាងច្បាស់លាស់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់រដ្ឋក្នុងការ គ្រប់គ្រងធនធានធម្មជាតិ ហើយ អនុក្រឹត្យដែលទាក់ទង បានកំណត់អំពីឧបករណ៏គោលនយោបាយ ដូចជា សម្បទានកសិកម្ម និង ការគ្រប់គ្រងដោយសហគមន៏មូលដ្ឋាន សំរាប់រាជរដ្ឋាភិបាល យកទៅអនុវត្តអាទិភាពធនធានធម្មជាតិរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ លំដាប់សិទ្ធិកាន់កាប់ធនធានរបស់រដ្ឋមិនមានចែងនៅក្នុងច្បាប់ទាំងនេះ ហើយក៏មិនមែនជាយន្តការ សំរាប់ដោះស្រាយភាព មិនស៊ីសង្វាក់គ្នារវាងច្បាប់ទាំងនេះ និង សិទ្ធិកាន់កាប់ធនធានដែលអាចបង្កអោយមានវិវាទគ្នានោះទេ ។ ដោយហេតុនេះកិច្ចខិតខំប្រឹងប្រែងរបស់អន្តរស្ថាប័នលើការគ្រប់គ្រងធនធាន សំរបសំរួលអោយមានការធ្វើអាជីវកម្មតាមបែប អនាធិប្បតេយ្យ និង ខុសច្បាប់លើធនធានរបស់រដ្ឋ ។

**តារាង ៤.៣ : ស្ថានភាពទាក់ទងនឹង គោលនយោបាយច្បាប់ និង អនុក្រឹត្យសំខាន់ៗ សំរាប់គ្រប់គ្រងធនធានធម្មជាតិ**

| ឧបករណ៏ច្បាប់ | ដី | ព្រៃឈើ | នេសាទ | ធនធានទឹក | តំបន់ការពារធម្មជាតិ |
|---|---|---|---|---|---|
| ក្របខ័ណ្ឌ | ឯកសារក្របខ័ណ្ឌ | គោលនយោបាយ | គ្មាន | គោលនយោបាយ | គ្មាន |

| គោលនយោបាយ | ដីធ្លី (បណ្តោះអាសន្ន) | វិស័យព្រៃឈើ (អនុម័តឆ្នាំ ២០០២) | | ធនធានទឹក (គណៈរដ្ឋមន្ត្រី) | |
|---|---|---|---|---|---|
| ច្បាប់ | អនុម័តនៅឆ្នាំ ២០០១ | អនុម័តនៅឆ្នាំ ២០០២ | ស្ថិតនៅក្រោមការពិចារណារបស់រដ្ឋសភា | ស្ថិតនៅក្រោមការពិចារណារបស់រដ្ឋសភា | បានដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេច |
| ការគ្រប់គ្រងរបស់សហគមន៍ | អនុក្រឹត្យស្តីពីសម្បទានដីសង្គម អនុម័តនៅឆ្នាំ ២០០៣ | អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសហគមន៍ អនុម័ត នៅឆ្នាំ ២០០៣ | អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ បានដាក់ជូន គណៈរដ្ឋមន្ត្រីពិនិត្យសំរេច | អនុក្រឹត្យស្តីពីសហគមន៍កសិករប្រើប្រាស់ទឹក កំពុងតែរៀបចំ | |
| ការគ្រប់គ្រងកិច្ចសន្យាសម្បទាន | អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច កំពុងតែរៀបចំ | អនុក្រឹត្យស្តីពីការគ្រប់គ្រងសម្បទានព្រៃឈើ អនុម័តនៅឆ្នាំ ២០០០ | ព្រះរាជក្រឹត្យ-ច្បាប់ លេខ ៣៣ ស្តីពីការគ្រប់គ្រងជលផល និង រដ្ឋបាល អនុម័តនៅឆ្នាំ ១៩៨៧ | | |
| ការសំរបសំរួលរបស់ស្ថាប័ន | អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរបស់រដ្ឋ កំពុងតែរៀបចំ | | | | |

២៤. ទោះបីជាមានការរីកចំរើនក៏ដោយ ក៏សិទ្ធិកាន់កាប់សម្បត្តិធនធានធម្មជាតិ នៅតែត្រូវការបញ្ជាក់បន្ថែមអោយបានច្បាស់លាស់ ក្រោមក្របខ័ណ្ឌច្បាប់ថ្មី ។ ច្បាប់ភូមិបាលឆ្នាំ ២០០១ បានបញ្ជាក់អំពីស្ថានភាពដីដែលកាន់កាប់ដោយឯកជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង ផ្តល់នូវមូលដ្ឋានសំរាប់ប្រព័ន្ធចុះបញ្ជីដីធ្លីបែបទំនើប ។ កម្មវិធីចេញលិខិតបញ្ជាក់ កម្មសិទ្ធិដីធ្លី កំពុងតែដំណើរការ ហើយ ព្យាយាមធ្វើអោយបានចប់សព្វគ្រប់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា នៅមុនដំណាច់ឆ្នាំ ២០១៥ ។ សិទ្ធិកាន់កាប់ ឬ ប្រើប្រាស់ដីធ្លីរបស់ឯកជន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ពុំសូវមានលក្ខណៈច្បាស់លាស់ ។ ឧទាះ ដីរបស់រដ្ឋ មានពីរប្រភេទ គឺ "ដី សាធារណៈរបស់រដ្ឋ និង ដីឯកជនរបស់រដ្ឋ" ។ ដីសាធារណៈ របស់រដ្ឋ គឺ

សំរាប់តែអភិរក្ស និង គ្រប់គ្រងប៉ុណ្ណោះ ហើយ រដ្ឋ មិនអាចលក់ដូរឱ្យឯកជនឡើយ ។ ផ្ទុយទៅវិញ រដ្ឋអាចលក់ដូរដីឯកជនរបស់រដ្ឋអោយឯកជនប្រើប្រាស់ ហើយ អាចប្រើប្រាស់ជាសម្បទានដី ។

២៥. ច្បាប់ភូមិបាល ទទួលស្គាល់សិទ្ធិកាន់កាប់ដីឯកជនរបស់រដ្ឋ មុនឆ្នាំ ២០០១ ប៉ុន្តែ មិនបានបញ្ជាក់អោយបានច្បាស់ លាស់អំពីរបៀបដោះស្រាយសិទ្ធិកាន់កាប់របស់អ្នកស្រុកដែលរស់នៅជាយូរយារមកហើយ ដូចជា ប្រជាជនមូលដ្ឋាន និង សិទ្ធិកាន់កាប់ដីសាធារណៈរបស់រដ្ឋ ដូចជា រមណីយដ្ឋានជាតិ ឬព្រៃបំរុងទុក។ លើសពីនេះទៀត ច្បាប់នេះ ក៏មិនបានបញ្ជាក់ អោយបានច្បាស់លាស់អំពីអ្វីដែលជាសិទ្ធិរបស់អ្នករស់នៅពឹងពាក់លើធនធានព្រៃឈើ ក្នុងតំបន់ដ៏ធំ ជាយូរយារណាស់មកហើយនោះផងទេ ។ ជាការចាំបាច់ ត្រូវមានការកំណត់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិអោយបានជាក់លាក់ ដូចជា ការរៀបចំអនុក្រឹត្យស្តីពីដីរបស់ប្រជាជនមូលដ្ឋានដែលផ្តល់នូវសិទ្ធិកាន់កាប់រួម ក៏ដូចជាការចាត់ថ្នាក់ដីរបស់រដ្ឋឡើងវិញដើម្បីធានា អោយមានការទទួលស្គាល់ចំពោះការកាន់កាប់ ឬ ការបែងចែកជាសម្បទានដីសង្គម ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរបស់រដ្ឋដែលនឹងប្រកាសអោយប្រើនៅពេលខាងមុខ នឹងផ្តល់នូវក្របខ័ណ្ឌនិយ័តកម្មសំរាប់ការទទួលខុសត្រូវក្នុងការចាត់ថ្នាក់ ការចាត់ថ្នាក់ឡើងវិញ និង ការគ្រប់គ្រងដីរបស់រដ្ឋ និង កំណត់នូវក្របខ័ណ្ឌច្បាប់សំរាប់ការទទួលខុសត្រូវរបស់ស្ថាប័ន ក្នុងការអនុវត្តកិច្ចការទាំងនេះ ។ រាជរដ្ឋាភិបាល មានភារកិច្ចរៀបចំតាក់តែង និង អនុម័តអនុក្រឹត្យនេះ នៅខែ មិថុនា ឆ្នាំ ២០០៥ ខាងមុខនេះ ។

២៦ ការប៉ាន់ប្រមាណអំពីធនធានធម្មជាតិឱ្យបានចប់សព្វគ្រប់ គឺជាតំរូវការបន្ទាន់មួយ ដើម្បីសំរបសំរួលដល់ការធ្វើផែនការនិងការពិនិត្យតាមដានលើការគ្រប់គ្រងធនធានធម្មជាតិ និង ការវិភាគលើការដោះដូរផលប្រយោជន៏ ។ រាជរដ្ឋាភិបាលកំពុងផ្តួចផ្តើមអោយមានការធ្វើផែនទីដីរបស់រដ្ឋ និងការវាយតំលៃលើភាពសមស្រប គុណភាព និង ការប្រើប្រាស់ដី ដែលត្រូវ ធ្វើឡើងជាបណ្តើរៗអោយបានចប់សព្វគ្រប់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា នៅមុនដំណាច់ឆ្នាំ ២០០៦ ។ ការប៉ាន់ប្រមាណ អំពីតំបន់ព្រៃគ្របដណ្តប់ ត្រូវបានធ្វើឡើងនៅឆ្នាំ ១៩៩៧ និង ឆ្នាំ ២០០៣ ប៉ុន្តែ ការផ្លាស់ប្តូរលើការចាត់ថ្នាក់តំបន់ព្រៃគ្របដណ្តប់ អាចលើសពីទំហំនិងគុណភាពនៃធនធានព្រៃឈើដែលមាននៅក្នុងការប៉ាន់ប្រមាណលើកចុងក្រោយ ។ ផលស្តុកត្រី ទាំងទឹកសាបនិងទឹកប្រៃ មិនទាន់បានធ្វើការប៉ាន់ប្រមាណនៅឡើយ ហើយសូម្បីតែព័ត៌មានទាក់ទងនឹងការចាប់ត្រី ក៏មិនអាចយកជាការបានប៉ុន្មានដែរ (កូត ដាវិត ឆ្នាំ ២០០២) ។ ចរន្តទឹក ត្រូវបានពិនិត្យ

តាមដាន ហើយកម្ពុជាកំពុងតែអនុវត្តការធ្វើផែនទីប្រភពទឹកក្រោម ដីជាលើកដំបូងរបស់ខ្លួន ប៉ុន្តែពុំទាន់មានការពិនិត្យតាមដានអោយម៉ត់ចត់លើបរិមាណទឹកក្រោមដីនិងទឹកលើដីដែលបានប្រើប្រាស់ ឬ គុណភាពទឹកនៅឡើយទេ ។ ពុំទាន់មានការរៀបចំចងក្រងជាឯកសារអោយបានត្រឹមត្រូវនូវស្ថានភាពជីវៈចំរុះ ហើយព័ត៌មានស្តីពីស្ថានភាពពពួករុក្ខជាតិ និង សត្វ មានតិចតួច ។ ដោយសារការពិនិត្យតាមដានធនធានដែលមានគុណភាពខ្ពស់ មានសារៈសំខាន់ចំពោះការរៀបចំតាក់តែងការធ្វើផែនការ និង ការពិនិត្យតាមដានគោលនយោបាយសំរាប់ គ្រប់គ្រងធនធានធម្មជាតិ គេគួរតែអនុវត្តយន្តការអន្តរក្រសួងដែលជំរុញអោយមានការពិគ្រោះយោបល់ជាសាធារណៈ សំដៅពង្រឹងគុណភាព និង ជំនឿទុកចិត្តលើការប៉ាន់ប្រមាណអំពីធនធាន ។ រាជរដ្ឋាភិបាល កំពុងអនុវត្តសាកល្បងនូវយុទ្ធ វិធីមួយ ដែលតាមរយៈនេះ គណៈកម្មាធិការប្រើប្រាស់និងបែងចែកដីធ្លីខេត្ត (**PLUAC**) ដែលមានសមាសភាពអាជ្ញាធរ ខេត្តនិងមន្ទីរពាក់ព័ន្ធដែលធ្វើការជាមួយនឹងបុគ្គលិកស្រុក ក្រុមប្រឹក្សាឃុំនិងសង្កាត់ និងភូមិ អាចរៀបចំធ្វើផែនទីដីធ្លីរបស់រដ្ឋ ព្រមទាំង រៀបចំផែនការគ្រប់គ្រងនិងបែងចែកដីធ្លី ។

## ឃ. ការពង្រឹកតួនាទី និង ការទទួលខុសត្រូវរបស់ស្ថាប័ន

២៧. ការទទួលខុសត្រូវរបស់ស្ថាប័នចំពោះការគ្រប់គ្រងធនធានធម្មជាតិនៅកម្ពុជា ត្រូវបានប្រមូលផ្តុំ និង ធ្វើមជ្ឈការ ។ មុខងារជាច្រើនដែលជាទូទៅត្រូវបែងចែកដល់ស្ថាប័ន និង ភាគីពាក់ព័ន្ធមួយចំនួននោះ ត្រូវប្រមូលផ្តុំ តែនៅក្នុងស្ថាប័ន គ្រប់គ្រងធនធានធម្មជាតិតែមួយប៉ុណ្ណោះ ។ លើសពីនេះទៀត ការទទួលខុសត្រូវលើការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានផ្ទេរតាមផ្លូវច្បាប់ (ដូចនៅក្នុងករណីព្រៃឈើ) ឬ តាមលក្ខណៈជាក់ស្តែង (នៅក្នុងករណីធនធានធម្មជាតិដទៃទៀត) អោយទៅអាជ្ញាធរថ្នាក់ជាតិ ។ ការផ្តល់នូវវិសាលភាពតូចចង្អៀតសំរាប់តុល្យភាពនៃការប្រើប្រាស់ធនធានត្រូវតែដោះស្រាយទោះ បីត្រូវទទួលរងឥទ្ធិពល ឬ ចូលរួមដោយផ្ទាល់ក្តី ។

២៨. សេចក្តីព្រាងគោលនយោបាយជាតិ ច្បាប់ និង អនុក្រឹត្យ ជាទូទៅ ត្រូវបានរៀបចំតាក់តែងឡើងដោយ ស្ថាប័នគ្រប់គ្រងធនធាន ដែលមានភារៈទទួលខុសត្រូវអនុវត្តការគ្រប់គ្រងធនធានធម្មជាតិដោយទទួលបានជំនួយបច្ចេកទេសពីគំរោង ។ ក្នុងករណីជាច្រើន យុទ្ធវិធីដែលផ្តោតតែលើក្រសួងមួយបែបនេះ បាននាំមកនូវកង្វះការយកចិត្តទុកដាក់លើតុល្យភាព ការឃ្លាំមើល និង ដំណោះស្រាយជំលោះ

នៅក្នុងគោលនយោបាយ ច្បាប់ និង បទដ្ឋានគតិយុត្តិ ដោយសារស្ថាប័ននានា ទំនងជា មិនមានការទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនផ្ទាល់ទេ ហើយដូចនៅក្នុងប្រទេសដទៃទៀតដែរ ស្ថាប័នទាំងនេះ ជារឿយៗមាននិន្នាការចំពោះការទទួលបាននូវផលប្រយោជន៍ខាងពាណិជ្ជកម្ម នៅក្នុងវិស័យនេះ ។ អ្វីដែលប្លែកនោះគឺ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដែលមាន សមាជិក ១៧ រូប ត្រូវបានបង្កើតឡើង មុនពេលរៀបចំតាក់តែងច្បាប់ភូមិបាលថ្មី ដោយសង្ឃឹមថា កង្វល់របស់អន្តរក្រសួង ត្រូវបានដោះស្រាយនៅក្នុងដំណាក់កាលរៀបចំតាក់តែងច្បាប់ ។ ក្នុងករណីមួយចំនួន រាជរដ្ឋាភិបាល ពឹងផ្អែកលើការគាំទ្ររបស់ភាគីពាក់ព័ន្ធដោយអញ្ជើញអោយចូលរួមជាសាធារណៈក្នុងការរៀបចំគោល នយោបាយ និងក្របខ័ណ្ឌច្បាប់ ។ ឧទា. ទាក់ទងនឹងបទពិសោធន៍ល្អដែលទទួលបានរហូតមកដល់ពេលនេះ ដូចជា ការរៀបចំតាក់តែងច្បាប់ភូមិបាលឆ្នាំ ២០០១ និង សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ បានបង្ហាញអោយឃើញអំពីផលប្រយោជន៍នៃដំណើរការចូលជាចំហ ។ ក្នុងករណីទាំងពីរ ការរៀបចំតាក់តែងច្បាប់ ត្រូវបានធ្វើឡើងមុន ឬ រៀបចំឡើងជាមួយការពិភាក្សាលើឯកសារគោលនយោបាយ ដែលប្រើប្រាស់ភាសាសាមញ្ញធម្មតាក្រៅពីភាសាច្បាប់ ទិសដៅរបស់រាជរដ្ឋាភិបាល និង បញ្ញត្តិនៃច្បាប់ ។ ក្រសួងពាក់ព័ន្ធ ស្នើសុំយោបល់ ហើយរៀបចំសិក្ខាសាលាពិគ្រោះយោបល់មួយចំនួន ដើម្បីអោយភាគីពាក់ព័ន្ធចូលរួមផ្តល់ជាបទពិសោធន៍ និងយោបល់មុនពេលរៀបចំបង្ហើយសេចក្តីព្រាងច្បាប់ ។ ជាទូទៅ ដំណើរការនេះ ជំរុញអោយមានការពង្រឹងខ្លឹមសារច្បាប់ និង ជំរុញអោយមានការគាំទ្រយ៉ាងទូលំទូលាយចំពោះការអនុវត្ត ច្បាប់នេះ ។

២៩. ស្ថាប័នគ្រប់គ្រងធនធាន កំពុងតែពង្រឹងសមត្ថភាពបច្ចេកទេសរបស់ខ្លួន ដើម្បីអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តិនានា ប៉ុន្តែទទួលបានការលើកទឹកចិត្តតិចតួច ហើយសមត្ថភាពក្នុងការដោះស្រាយបញ្ហានៅក្នុងមូលដ្ឋាននៅមានកំរិត ។ ទោះ បីជាជំនាញបច្ចេកទេសមានការរីកចំរើនគួរអោយកត់សំគាល់ក្នុងរយៈពេលជាង ១០ ឆ្នាំ កន្លងទៅនេះក៏ដោយ ក៏ប្រាក់បៀវត្សរ៍ មន្ត្រីរាជការ និង ថវិកាសំរាប់ប្រតិបត្តិការមិនមានគ្រប់គ្រាន់សំរាប់ជាការលើកទឹកចិត្ត និង ការគាំទ្រអោយបានពេញលេញ ដើម្បីអនុវត្តមុខងារគ្រប់គ្រងធនធានអោយមានប្រសិទ្ធិភាព ។ ច្បាប់ និង អនុក្រឹត្យថ្មី ដែលបង្កើនការទទួលខុសត្រូវដល់ បុគ្គលិកមិនស៊ីគ្នាជាមួយនឹងថវិកា ឬ មូលនិធិជំនួយ ដើម្បីទប់នឹងតំលៃដែលចេះតែកើនឡើង ។ ជាលទ្ធផលបុគ្គលិកស្ថាប័ន គ្រប់គ្រងធនធានភាគច្រើន ត្រូវស្ថិតនៅក្រោមឥទ្ធិពល របស់ក្រុមអ្នកមានប្រាក់មានអំណាចដែលមានបំណងធ្វើអាជីវកម្មលើ ធនធានដោយស្របច្បាប់ ឬ ខុសច្បាប់ ។ លើសពីនេះទៀត កង្វះការផ្ទេរ

សិទ្ធិអំណាចសំរាប់អនុវត្តនីរបៀបចំការគ្រប់គ្រងជា មួយនឹងសហគមន៍ និង អាជ្ញាធរមូលដ្ឋាន រុញច្រាន បុគ្គលិកស្ថាប័នគ្រប់គ្រងធនធានអោយធ្លាក់ចូលទៅក្នុងស្ថានភាពប្រឈមមុខ ជាមួយនឹងសហគមន៍មូលដ្ឋាន ឬ ឃុបឃិតអនុញ្ញាតឱ្យមានសកម្មភាពខុសច្បាប់ ។ ចុងក្រោយបង្អស់ មន្ត្រីជាន់ខ្ពស់ក្នុងជួរ រាជរដ្ឋាភិបាល អនុវត្តរំលងបុគ្គលិកស្ថាប័នគ្រប់គ្រងធនធាន ជាពិសេស នៅក្នុងដំណើរការផ្តល់កិច្ចសន្យាសម្បទាន ។

៣០. ការពង្រឹងយន្តការដោះស្រាយជំលោះទាក់ទងនឹងដីធ្លី និង ធនធានធម្មជាតិ តំរូវឱ្យធ្វើឡើង ជាបន្ទាន់ ។ ជំលោះរវាងបុគ្គល ឬ អង្គការឯកជន និង រដ្ឋ ដែលមិនអាចដោះស្រាយបានតាមរយៈការចរចា ជាទូទៅ ត្រូវបញ្ជូនទៅតុលាការ លើកលែងតែករណីជំលោះដីធ្លីដែលបានកើតមានឡើង នៅពេលដែល គណៈកម្មការសុរិយោដី ត្រូវបានបង្កើតឡើងក្នុងគោលបំណងកាត់បន្ថយចំណាយទៅលើការដោះស្រាយ ជំលោះដីធ្លី ។ ស្ថានភាពជំលោះ នៅក្នុងចំណោមអង្គភាពឯកជន គឺប្រហាក់ប្រហែលគ្នា ចំណែកស្ថានភាព ជំលោះដែលខុសគ្នា គឺថា ជំលោះភាគច្រើន ត្រូវបានដោះស្រាយតាមវិធីសាស្ត្រមជ្ឈត្តការ ដោយប្រធានភូមិ ឬ មេឃុំ/ចៅសង្កាត់ មុនពេលបញ្ជូនទៅតុលាការ ឬ គណៈកម្មការសុរិយោដី ប្រសិនបើចាំបាច់ ។ ដូចនៅ ក្នុងករណីអនុវត្តន៍ច្បាប់ និង ករណីពាក់ព័ន្ធនឹងមន្ត្រីរដ្ឋ ឬ ក្រុមអ្នកមានប្រាក់មានអំណាចដែរ ជាទូទៅ យន្តការដោះស្រាយជំលោះ នៅថ្នាក់ក្រោមថ្នាក់ជាតិ មិនអាច ឬ មិនមានឆន្ទៈក្នុងការដោះស្រាយជំលោះ នោះទេ ដែលជំលោះត្រូវបញ្ជូនទៅថ្នាក់ជាតិ ដែលនៅទីនោះ ដំណើរការដោះស្រាយជំលោះ មិនទាន់កំណត់ ច្បាស់លាស់នៅឡើយ ។ ដោយសារមិនមានបញ្ញត្តិច្បាប់ សំរាប់ទប់ទល់នឹងសកម្មភាពដោះស្រាយជំលោះ អោយមានប្រសិទ្ធិភាព ភាគីមានអំណាច ព្យួរ ឬខកខានមិនបានដោះស្រាយ ជំលោះអោយមានភាព យុត្តិធម៌ ធ្វើអោយបាត់បង់ផលប្រយោជន៍របស់ភាគីដើមចោទ ។ វិសមធម៌ក្នុងការឈានទៅរកយុត្តិធម៌ តាមផ្លូវតុលាការ មានតំលៃខ្ពស់ និង ការពន្យារពេលយូរ ប្រជាជននៅជនបទភាគច្រើនមិនបានចាត់ទុក ប្រព័ន្ធតុលាការថាជាយន្តការ មួយដែលអាចផ្តល់នូវភាពយុត្តិធម៌ និង ពិចារណាបានត្រឹមត្រូវលើជំលោះ របស់ពួកគេ ។ បញ្ហាប្រហាក់ប្រហែលគ្នានេះ ត្រូវបានរកឃើញ នៅក្នុងគណៈកម្មការសុរិយោដី ។

៣១. ការពង្រឹងការទទួលខុសត្រូវ និង ការឃ្លាំមើលរបស់រាជរដ្ឋាភិបាលលើការគ្រប់គ្រងធនធាន ធម្មជាតិ ត្រូវធ្វើឡើងជាបន្ទាន់ ។ ដូចដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ចាប់ ពីអាណត្តិទី ៣ នេះទៅ រាជរដ្ឋាភិបាលកម្ពុជា នឹងជំរុញអោយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ធ្វើការពិនិត្យមើល

និងផ្ទៀងផ្ទាត់កិច្ចសន្យា និង កិច្ចព្រមព្រៀងសម្បទានលើធនធានធម្មជាតិនិងទ្រព្យសម្បត្តិរបស់រដ្ឋ ។ នៅកម្ពុជា ការឃ្លាំមើលត្រូវធ្វើឡើងដោយស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និង សង្គមស៊ីវិល ។ នៅក្នុងស្ថាប័នរដ្ឋសភា គណៈកម្មការទី៣ គឺ គណៈកម្មការសេដ្ឋកិច្ច ផែនការ បណ្តាក់ទុន កសិកម្ម អភិវឌ្ឍន៍ជនបទ និង បរិស្ថាន មានភារកិច្ចទទួលខុសត្រូវចំពោះបញ្ហាទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មការនេះ នៅខ្វះជំនួយបច្ចេកទេស ដែលមានសារៈសំខាន់ សំរាប់គណៈកម្មការធ្វើការបកស្រាយរបាយការណ៍បច្ចេកទេសទាក់ទងនឹងបញ្ហាគ្រប់គ្រងធនធានធម្មជាតិ ។ នៅក្នុងស្ថាប័នប្រតិបត្តិ ការឃ្លាំមើល ត្រូវបានអនុវត្តដោយក្រុមប្រឹក្សាឯកទេសអន្តរក្រសួង (ដីធ្លី) ឬ គណៈកម្មការឯកទេសអន្តរក្រសួង (រុក្ខាប្រមាញ់ និង នេសាទ) ព្រមទាំង គណៈរដ្ឋមន្ត្រី ដែលមិនមានភារៈទទួលខុសត្រូវក្នុងការរាយការណ៍ជូនសាធារណជនទេ ។ លើសពីនេះទៅទៀត ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវក្នុងការវាយតំលៃលើស្ថានភាពទ្រព្យសម្បត្តទាំងអស់របស់រដ្ឋ ហើយ ក្រសួងបរិស្ថានមានភារកិច្ចទទួលខុសត្រូវក្នុងការធានាថា បញ្ញត្តិច្បាប់ការពារបរិស្ថានទាំងអស់ត្រូវបានគោរព ។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចការនេះ មិនត្រូវបានធ្វើឡើងជាទៀងទាត់ ហើយលទ្ធផល ក៏មិនត្រូវបានផ្សព្វផ្សាយជូនសាធារណជនដែរ ។ គេរំពឹងថា បន្ទាប់ពីទទួលបានសមត្ថកិច្ច អាជ្ញាធរសវនកម្មជាតិ នឹងធ្វើសវនកម្មលើការគ្រប់គ្រងធនធានធម្មជាតិជារៀងរាល់ឆ្នាំ ហើយ រាយការណ៍ជូនរដ្ឋសភា និង បន្ទាប់មកផ្សព្វផ្សាយជាសាធារណៈ ។

៣២. ជាទូទៅ សង្គមស៊ីវិល មានតួនាទីកាន់តែសំខាន់ក្នុងការឃ្លាំមើលការគ្រប់គ្រងធនធានធម្មជាតិ ។ អង្គការអន្តរជាតិ និង អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក៏ដូចជា ប្រព័ន្ធផ្សព្វផ្សាយជាភាសាខ្មែរ និងភាសាបរទេសនៅក្នុងស្រុក បានផ្តោតការយកចិត្តទុកដាក់លើការអនុវត្តន៍របស់ស្ថាប័នគ្រប់គ្រងធនធាន ។ ស្ថាប័នគ្រប់គ្រងធនធានមួយចំនួន កំពុងតែធ្វើសមាហរ ណកម្មតួនាទីឃ្លាំមើលនិងការចូលរួមរបស់សង្គមស៊ីវិល ទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់ខ្លួន ។ បញ្ញត្តិទាក់ទងនឹងការទទួលខុស ត្រូវនិងការឃ្លាំមើលដែលមានប្រសិទ្ធិភាពបំផុត ត្រូវដាក់បញ្ចូលទៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ដែលតំរូវអោយមានការពិគ្រោះយោបល់ជាមួយនឹងសហគមន៍មូលដ្ឋាន និង ការផ្សព្វផ្សាយជាសាធារណៈនូវផែនការគ្រប់គ្រងដើម្បីសុំយោបល់កែលំអ ។ លើសពីនេះទៀត ការពិនិត្យ តាមដានដោយឯករាជ្យលើការរាយការណ៍និងការតាមដានឧក្រិដ្ឋកម្មព្រៃឈើ ក៏ត្រូវបានអនុវត្ត ។ ការពិនិត្យតាមដាន បានផ្តោតទៅលើការទប់ទល់

របស់មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល ឬ ក្រុមអាជីវកម្មមានអំណាច[៤] ។ ការលំបាកក្នុងការអនុវត្តន៍បញ្ញត្តិច្បាប់ទាក់ទងនឹងព្រៃឈើ បានបង្ហាញអោយឃើញថា មានបញ្ហាប្រឈមក្នុងការបង្កើតអោយមានវប្បធម៌តម្លាភាព និងការទទួលខុសត្រូវនៅក្នុងស្ថាប័នគ្រប់គ្រងធនធានធម្មជាតិ ដែលអាណត្តិ របស់ស្ថាប័ននេះពង្រីកហួសពីការអនុវត្តន៍ និង គ្មានស្ថាប័នឃ្លាំមើលខាងក្រៅណាដែលមានប្រសិទ្ធិភាពទេ ។

## ខ. ការសំឡឹងមើលទៅអនាគតៈ ផលប្រយោជន៍រួម ដើម្បីការទទួលខុសត្រូវរួម

៣៣. ការបង្កើតអោយមាននិងអនុវត្តន៍ប្រព័ន្ធគ្រប់គ្រង ដែលផ្តល់ផលប្រយោជន៍ច្រើនដល់សហគមន៍មូលដ្ឋាន គឺជាតំរូវការបន្ទាន់មួយ ។ ការធ្វើសនិទានភាពលើប្រព័ន្ធសម្បទាន និង វិសាលភាពនៃយុទ្ធវិធីផ្តោតលើសហគមន៍ដែលនៅមានកំរិតបែបនេះ គំរាមកំហែងអោយមានការទុកចោលធនធានធម្មជាតិរបស់កម្ពុជាមួយចំនួនធំអោយនៅក្រៅការគ្រប់គ្រងដែលមានប្រសិទ្ធិភាព ដោយជំរុញអោយមានការប្រើប្រាស់ជាចំហតាមព្រឹត្តន័យ (សូមមើលប្រអប់ ៤.៣) ។ បើពិចារណាទៅលើសមា មាត្រដ៏ធំនៃចំនួនប្រជាជនកម្ពុជា ជាពិសេសប្រជាជនក្រីក្រ ដែលរស់នៅតំបន់ជនបទ និងពឹងផ្អែកលើធនធានធម្មជាតិ យុទ្ធវិធីគ្រប់គ្រងធនធាន គួរតែកំណត់អាទិភាពទៅលើ លទ្ធភាពផ្ទាល់របស់សហគមន៍នៅជនបទនេះ ក្នុងការទទួលបាននូវផលប្រយោជន៍នានា ។ តាមបទពិសោធន៍ដែលទទួលបានពីប្រព័ន្ធសម្បទាន បានបង្ហាញអោយឃើញថា យន្តការបែបមជ្ឈការ សំរាប់ប្រមូលចំណូលពីធនធានធម្មជាតិនៅកម្ពុជា មិនដំណើរការល្អទេ ហើយទំនងជាមានតួនាទីតិចតួចនៅពេលអនាគត ។ លើសពីនេះទៀត ភាពខ្សោយនៃប្រព័ន្ធចំណាយសាធារណៈ បានកំរិតទៅលើសមត្ថភាពបែងចែកចំណូលក្នុងចំណែកមួយសមស្រប អោយទៅសហគមន៍ពាក់ព័ន្ធ តាមរយៈយន្តការ ផ្តល់សេវាធម្មតា[៥] ។

៣៤. ការផ្ទេរសិទ្ធិអោយឯកជនកាន់កាប់ធនធានធម្មជាតិ គឺជាការផ្ទេរផលប្រយោជន៍នៃធនធាននេះអោយទៅសហគមន៍មូលដ្ឋាន និង/ឬ ប្រជាជនក្រីក្រ ។ ដីសាធារណៈមួយចំនួន នឹងត្រូវប្រគល់អោយឯកជនកាន់កាប់ តាមរយៈការទទួលស្គាល់ សិទ្ធិកាន់កាប់ដីសាធារណៈទាំងនេះ ដោយអនុលោមទៅតាមច្បាប់ភូមិបាល ។ លើសពីនេះទៀត សម្បទានដីសង្គម នឹងផ្ទេរកម្មសិទ្ធិដីចេញពីដីសាធារណៈ ហើយកម្មសិទ្ធិនៃអចលនវត្ថុពេញលេញ នឹងប្រគល់អោយទៅអ្នកកាន់កាប់ដីទាំងនេះ ក្នុងរយៈពេលប្រាំឆ្នាំក្រោយ ។ ការយកពន្ធលើដីធ្លីដែលមិនបានប្រើប្រាស់ មានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយសំពាធលទ្ធកម្ម និង ការ

ដាក់លក់ដីបន្ថែមនៅលើទីផ្សារ ។ ក្នុងករណីកម្មសិទ្ធិនៃអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច មានការ រំពឹងទុកថា ដីលំនៅដ្ឋាន និង ដីកសិកម្ម នឹងត្រូវទទួលស្គាល់ជាកម្មសិទ្ធិសមូហភាព ដោយមាន ការកំរិតមួយចំនួនទៅ លើការផ្ទេរកម្មសិទ្ធិ ។

**ប្រអប់ ៤.៣ : ឥទ្ធិពលនៃការដាក់ឡូត៍នេសាទឱ្យសហគមន៍ប្រើប្រាស់**

ការវាយតំលៃលើឥទ្ធិពលនៃកំណែទំរង់គោលនយោបាយនេសាទឆ្នាំ ២០០២ ត្រូវបានធ្វើឡើង ដោយផ្អែកលើ លទ្ធផលនៃការសំភាសន៍នៅតាមភូមិចំនួន ២៦ ក្នុងខេត្ត ៣ ។ ការសិក្សាស្រាវជ្រាវ បានធ្វើការសន្និដ្ឋានថា :

- ឥទ្ធិពលជាវិជ្ជមានដំបូងពីកំណើនលទ្ធភាពប្រើប្រាស់ឡូត៍នេសាទ ឥឡូវនេះ ត្រូវបានគេមើលឃើញថា កំពុងតែថយចុះ ដោយសារការប្រកួតប្រជែងគ្មានច្បាប់ទំលាប់ត្រឹមត្រូវលើធនធាន និង ការកើនឡើងនូវការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ។
- អ្នកនេសាទជាលក្ខណៈគ្រួសារ និង ពាណិជ្ជករ បានបង្កើនទំនាក់ទំនងជាមួយនឹងអ្នកនេសាទជាទ្រង់ទ្រាយធំ ។
- ស្ត្រី និង កុមារ មានលទ្ធភាពដែលមានការធានាកាន់តែច្រើនក្នុងការនេសាទ ដោយគ្មានការភ័យខ្លាចការរំខានពីអ្នកយាម ឡូត៍នេសាទ ។
- ការប្តូរមុខងារមន្ត្រីជលផលខេត្ត ទៅជាមន្ត្រីសំរបសំរួលសហគមន៍នេសាទ ត្រូវការពេលវេលាច្រើន និង តំរូវអោយមានការពង្រឹងសមត្ថភាពផងដែរ ។
- តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការធ្វើជាតំណាងអោយផលប្រយោជន៍របស់ភាគីពាក់ព័ន្ធមួយក្រុមធំនៅក្នុងដំណើរការនេះ មានសារៈសំខាន់ខ្លាំងណាស់ ហើយចាំបាច់ត្រូវពង្រីកបន្ថែមអោយដល់នាយកដ្ឋានជលផល ។
- កំណើនការព្រួយបារម្ភនៅក្នុងចំណោមអ្នកនេសាទថា អាចនឹងមានទំនាស់រវាងតំរូវការរបស់សហគមន៍នេសាទ និង តួនាទីរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ។

ប្រភព : ការិយាល័យផ្នែកសហគមន៍នេសាទ - ឥទ្ធិពលនៃកំណែទំរង់គោលនយោបាយនេសាទ : IMM ខេត្តកំពង់ចាម ពោធិសាត់ និង តាកែវ ព្រមទាំង DFID ខែ មីនា ឆ្នាំ ២០០៤ ។

៣៥. ការធ្វើឯកជនភាវូបនីយកម្មបន្ថែម ឬ ការធ្វើពាក់កណ្តាល ឯកជនភាវូបនីយកម្ម លើធនធានព្រៃឈើ ឬ ជលផល តាមរយៈយន្តការមួយចំនួន ដូចជា ការផ្ទេរកូតា ជាដើម តំរូវអោយមានការស្វែងយល់អោយបានច្បាស់លាស់លើស្ថានភាពធនធានទាំងនេះ និង ការប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ។ សព្វថ្ងៃនេះ មិនទាន់មានការកំណត់ពីកម្មសិទ្ធិលើធនធានទឹកនៅឡើយ ដូច្នេះ រដ្ឋ ជាកម្មសិទ្ធិករនៃធនធាននេះ ប៉ុន្តែកម្ម

សិទ្ធិលើធនធានទឹកឯកជន ត្រូវតែកំណត់ជាបន្ទាន់ ដោយសារមានការកើនឡើងនូវការប្រកួតប្រជែងលើធនធានទឹកលើដី និង ធនធានទឹកក្រោមដី ។ ទោះជាយ៉ាងណាក៏ ដោយគេរំពឹងថា ដោយផ្អែកលើតំរូវការអោយមានការផ្តល់នូវផលប្រយោជន៍សាធារណៈ ធនធានធម្មជាតិ ភាគច្រើន នឹងនៅតែស្ថិតនៅជាទ្រព្យសម្បត្តិរដ្ឋ ។

៣៦. ការរៀបចំសម្បទាន នឹងនៅតែជាយុទ្ធវិធីគ្រប់គ្រងមួយដ៏ល្អ ក្រោមល័ក្ខខ័ណ្ឌល្អប្រសើរ និង មានបញ្ញត្តិច្បាប់ច្បាស់លាស់ សំរាប់ធានាអោយមានការសំរបសំរួល និង ការចែករំលែកផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាន។ បញ្ហាជាច្រើនដែលកើតមានឡើងចំពោះប្រព័ន្ធសម្បទានក្នុងពេលកន្លងមក គឺបណ្តាលមកពីការផ្តល់តំបន់ដែលមិនសមស្រប ក្នុងគោលបំណងឆ្លើយតបទៅតាមសំណើរបស់អ្នកវិនិយោគ និង កង្វះតម្លាភាពទាំងស្រុងនៅក្នុងដំណើរការចុះកិច្ចសន្យា និង ក្នុងការពិនិត្យតាមដានការអនុវត្តន៍របស់អ្នកវិនិយោគ ។ ផ្អែកតាមបទពិសោធន៍ដែល ទទួលបានពីប្រទេសផ្សេងៗបានបង្ហាញឱ្យឃើញថា ប្រព័ន្ធសម្បទាន គឺជាយន្តការមួយសំរាប់ទាក់ទាញទុនវិនិយោគពីបរទេស បច្ចេកវិទ្យា និងលទ្ធភាពទីផ្សារ ដែលនឹងផ្តល់អោយទាំងផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ឯកជន ។ បើពិចារណាទៅលើភាពខ្សោយរបស់ស្ថាប័នទូទៅនៅកម្ពុជា កិច្ចការនេះ តំរូវអោយមាននីតិវិធីច្បាស់លាស់ និងមានតម្លាភាព សំរាប់កំណត់អំពីធនធានដែលត្រូវដាក់បញ្ចូលទៅក្នុងប្រព័ន្ធ សម្បទាន ដោយធានាថា បញ្ហា សង្គម និង បញ្ហាបរិស្ថាន ត្រូវបានប៉ាន់ប្រមាណ និង ដោះស្រាយអោយបានដាច់ស្រេច មុនពេលផ្ទេរកម្មសិទ្ធអោយទៅអ្នកអនុវត្តន៍សិទ្ធិសម្បទាន តាមរយៈការអនុវត្តន៍ដំណើរការដេញថ្លៃដោយមានតម្លាភាព ការធានាអោយមានការពិនិត្យតាមដាន និង ការរាយការណ៍អំពីសមត្ថភាពបច្ចេកទេសនិងហិរញ្ញវត្ថុរបស់អ្នកអនុវត្តន៍សិទ្ធិសម្បទាន ក៏ដូចជាការអនុវត្ត និង ការផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលនៃការវាយតំលៃការឃ្លាំមើលដោយឯករាជ្យ ។ តាមការពិភាក្សាវែកញែកនាពេលបច្ចុប្បន្នជុំវិញអនាគតព្រៃសម្បទាន គេសង្កេតឃើញថា រាជរដ្ឋាភិបាល ម្ចាស់ជំនួយ និង សង្គមស៊ីវិល មានការខ្វែងគំនិតគ្នាលើលទ្ធភាពរបស់អាជ្ញាធរ ក្នុងការធានាអោយមានការអនុវត្តអោយបានត្រឹមត្រូវនូវនីតិវិធីទាំងនេះ បើពិចារណាទៅលើបញ្ហាស្ថាប័ននិងអភិបាលកិច្ច ។

៣៧. ការចែករំលែកកំណើនផលប្រយោជន៍ពីធនធានធម្មជាតិ ភាគច្រើនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ រួមទាំងធនធានធម្មជាតិនៅក្នុងប្រព័ន្ធសម្បទានផង គឺជាតំរូវការចាំបាច់ ។ ផ្អែកតាមបទពិសោធន៍ដែលទទួលបានពីប្រទេសមួយចំនួន បានបង្ហាញអោយឃើញថា យន្តការចែករំលែកផលប្រយោជន៍អាចជំរុញអោយមានតម្លាភាព និង ការទទួលខុសត្រូវក្នុងកំរិត មួយខ្ពស់ ទន្ទឹមនឹងនេះ ការអនុវត្តន៍ច្បាប់ និង ប្រព័ន្ធចំណូល-ចំណាយសាធារណៈ ក៏ត្រូវបានពង្រឹងផងដែរ ។ សហគមន៍មូលដ្ឋាន អាចចែករំលែកទាំងលទ្ធភាពប្រើប្រាស់ធនធាន និង ផលប្រយោជន៍ ជារូបិយវត្ថុផ្ទាល់ពីការគ្រប់គ្រងធនធានធម្មជាតិ។ យន្តការដែលធានាអោយសហគមន៍មូលដ្ឋានមានលទ្ធភាពប្រើប្រាស់ ធនធានព្រៃឈើនិងជលផលជាបន្តបន្ទាប់ បានបង្ហាញអោយឃើញពីការសន្យាផ្តល់ការលើកទឹកចិត្តដល់ប្រជាជន អោយគាំទ្រដល់បទដ្ឋានគតិយុត្តិសំរាប់ការគ្រប់គ្រងធនធានធម្មជាតិ ។ កំណែទំរង់វិមជ្ឈការ ជាពិសេស ការបង្កើតក្រុមប្រឹក្សាឃុំ/សង្កាត់ ក៏ដូចជា យន្តការធ្វើផែនការស្រុក/ខ័ណ្ឌ ផ្តល់នូវមូលដ្ឋានដ៏រឹងមាំសំរាប់គាំទ្រដល់ការជំរុញអោយមានកិច្ចសហការ និង ការទទួលខុសត្រូវ នៅក្នុង ចំណោមសហគមន៍ និង រវាងសហគមន៍ និង ស្ថាប័នគ្រប់គ្រង ធនធាន (សូមមើលប្រអប់រ ៤.៤) ។

**ប្រអប់ ៤.៤ : ព្រៃឈើក្រុងនៅ Bolivia**

នៅ **Bolivia** ច្បាប់ព្រៃឈើឆ្នាំ ១៩៩៦ បានបញ្ជាក់ឡើងវិញពីការផ្ទេរសិទ្ធិ និង អំណាចថ្មីលើការគ្រប់គ្រងដីធ្លី ពីថ្នាក់ជាតិ អោយទៅសាលាក្រុង ។ សិទ្ធិទាំងនេះ រួមមាន :

- សិទ្ធិទទួលបាន ២៥ ភាគរយនៃថ្លៃឈ្នួលអាជីវកម្មសម្បទាន សំរាប់ប្រើប្រាស់លើការអភិវឌ្ឍន៍ព្រៃឈើ និង ហេដ្ឋារចនា សម្ព័ន្ធសង្គម ។
- សិទ្ធិអំណាចក្នុងការគ្រប់គ្រងព្រៃឈើសាធារណៈរហូតដល់ ២០ ភាគរយ ដែលត្រូវចែកអោយទៅសហគមន៍មូលដ្ឋាន (ដូចជាព្រៃបំរុងរបស់សាលាក្រុង) ។

នៅពេលទទួលបានសិទ្ធិថ្មីៗទាំងនេះ ការទទួលខុសត្រូវក៏មានទៅតាមនោះដែរ ។ ដើម្បីទទួលបានចំណូល ជាបន្តបន្ទាប់ពីព្រៃឈើ និង សិទ្ធិអំណាចលើព្រៃបំរុងរបស់សាលាក្រុង រដ្ឋអំណាចមូលដ្ឋាន ត្រូវតែបង្កើតអោយមានអង្គភាពព្រៃឈើក្រុង (**MFU**) ក្នុងរយៈពេល ៦ ខែ បន្ទាប់ពីទទួលបានថ្លៃអាជីវកម្មសម្បទានជាលើកដំបូង ។ អង្គភាពព្រៃឈើក្រុង មានភារកិច្ចទទួលខុសត្រូវក្នុង ការកំណត់អំពីតំបន់ព្រៃបំរុងរបស់សាលាក្រុង ការគាំទ្រដល់

សហគមន៍មូលដ្ឋានក្នុងការរៀបចំផែនការគ្រប់គ្រងព្រៃឈើដើម្បីទទួលបានសម្បទាន និង ការជួយពិនិត្យតាមដានលើការគោរពច្បាប់ព្រៃឈើ ។ ការគោរពច្បាប់ព្រៃឈើ និង សមត្ថភាពរបស់អង្គភាពព្រៃឈើក្រុងក្នុងការអនុវត្តន៍ការទទួលខុសត្រូវរបស់ខ្លួន ស្ថិតនៅក្រោមការ គ្រប់គ្រងរបស់មន្ត្រីជាន់ខ្ពស់ផ្នែកគ្រប់គ្រងព្រៃឈើស្វយ័ត ។

មេរៀនបទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍រហូតមកដល់ពេលនេះ រួមមាន :

- កង្វះសមត្ថភាពរបស់សាលាក្រុង គឺជាឧបសគ្គរាំងដល់ការអនុវត្តន៍នៅក្នុងតំបន់ជាច្រើន ។ កំរិតជំនាញទាបប្រាក់ បៀវត្សរ៍ទាប និង ការជ្រៀតជ្រែកផ្នែកនយោបាយ បានកំរិតទៅលើសមត្ថភាពរបស់សាលាក្រុងក្នុងការបង្កើតអង្គភាពព្រៃឈើក្រុង។
- សាលាក្រុង មានសក្តានុពលក្នុងការបង្កើនប្រសិទ្ធិភាពការងារគ្រប់គ្រងព្រៃឈើនៅតាមតំបន់មួយចំនួន ។ នៅកន្លែងដែលសាលាក្រុងបានខិតខំប្រឹងប្រែងបង្កើតអោយមានអង្គភាពព្រៃឈើក្រុង ទោះបីជាខ្វះការគាំទ្រពីថ្នាក់ជាតិក្តី ក៏សាលាក្រុងបាន បង្ហាញអោយឃើញពីការប្តេជ្ញាចិត្ត ដែលស្ថាប័នចាស់នៅថ្នាក់ជាតិ មិនធ្លាប់ដែលមាន ។
- កំណែទំរង់វិមជ្ឈការ បានផ្តល់នូវឳកាសដល់ក្រុមដែលមានឋានៈទាបនៅក្នុងសង្គម (ឧទាហរណ៍ : ជនជាតិភាគតិច និង កសិករដែលមានដីធ្លីតិចតួច) ចូលរួមក្នុងការគ្រប់គ្រងព្រៃឈើ និង ជាពិសេស ទទួលបានលទ្ធភាពប្រើប្រាស់ព្រៃឈើនៅក្នុងតំបន់ព្រៃបំរុងរបស់សាលាក្រុង ។ ប្រជាពលរដ្ឋក្រីក្រនៅក្នុងសហគមន៍ មានលទ្ធភាពខុសៗគ្នា ក្នុងការទាញយកផល ប្រយោជន៍ពីអោយកាសថ្មីនេះ ។

មានតំរូវការច្បាស់លាស់អោយរដ្ឋាភិបាល បន្តដើរតួនាទីជាអ្នកផ្តល់ជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ និងជាអ្នករៀបចំគោលនយោបាយព្រៃឈើអោយបានច្បាស់លាស់ ដែលបង្ហាញពីការបែងចែកការទទួលខុសត្រូវថ្មីដល់អាជ្ញាធរនៅគ្រប់លំដាប់ថ្នាក់ ទាំងអស់ ។

ប្រភព : **Landell-Mills** - ការផ្តល់ហិរញ្ញប្បទានដល់ព្រៃឈើដែលសមស្រប : ការពិនិត្យមើលបទពិសោធន៍ របស់ប្រទេសផ្សេងទៀត - កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ឆ្នាំ ២០០១ ។

៣៨. ការចែករំលែកផលប្រយោជន៍នៅក្នុងមូលដ្ឋាន ត្រូវដោះស្រាយបញ្ហាប្រាក់ឧបត្ថម្ភដល់បុគ្គលិកស្ថាប័នគ្រប់គ្រងធនធាន និង សហគមន៍មូលដ្ឋាន ។ ទោះបីជារដ្ឋបាលសាធារណៈដ៏ទូលំទូលាយ និងកំណែទំរង់បៀវត្សរ៍កំពុងតែដំណើរ ការហើយក៏ដោយ ក៏គួរតែមានការលើកទឹកចិត្តជាប្រាក់ឧបត្ថម្ភដល់បុគ្គលិក និងសហគមន៍ទាំងនេះ ដោយផ្អែកលើវិធានការអនុវត្តន៍ការងារច្បាស់លាស់និងប្រកបដោយតម្លាភាព ដែលមានការទទួលស្គាល់ពីសំណាក់ភាគីពាក់ព័ន្ធនៅក្នុងមូលដ្ឋាន និង ថ្នាក់គ្រប់គ្រងស្ថាប័ននៅ

ថ្នាក់ជាតិ ។ គំរោងមួយចំនួន របស់អង្គការមិនមែនរដ្ឋាភិបាល បានបង្កើតអោយមានយន្តការផ្តល់ការលើកទឹកចិត្តដល់បុគ្គលិករដ្ឋាភិបាល ដែលជាទូទៅ ជួយជំរុញអោយការអនុវត្តន៍ច្បាប់កាន់តែមានប្រសិទ្ធិភាព (សូមមើលប្រអប់ ៤.៥) ។

**ប្រអប់ ៤.៥ : កិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងធនធាននៅមូលដ្ឋាន រវាង រាជរដ្ឋាភិបាល និង សង្គមស៊ីវិល**

នៅខេត្តមណ្ឌលគិរី អង្គការមិនមែនរដ្ឋាភិបាល កំពុងតែសហការជាមួយនឹងប្រជាជនមូលដ្ឋាន ពោលគឺ ជនជាតិដើមភាគតិចភ្នង និង រដ្ឋបាលព្រៃឈើ ក្នុងការអនុវត្តការកសាងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ។ ការឧបត្ថម្ភគាំទ្រ រួមមានការបណ្តុះបណ្តាលអ្នកសំរបសំរួលភូមិ ទស្សនកិច្ចសិក្សារបស់អ្នកភូមិទៅកាន់ខេត្តរតនគិរីដែលនៅទីនោះមានការ អនុវត្តន៍ការកសាងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម (PLUP) អស់រយៈពេលជាច្រើនឆ្នាំមកហើយ ការផ្តល់ប្រាក់លើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលព្រៃឈើដែលបានជួយដល់ប្រជាជន ព្រមទាំងជំនួយសំរាប់ការធ្វើផែនទី និងសំរាប់ធ្វើ ការងារជាមួយនឹងប្រជាជន និង អាជ្ញាធរឃុំ/សង្កាត់និងភូមិ ។ PLUP កំពុងតែជួយដល់សហគមន៍ទាំងនេះ ក្នុងការបង្ហាញពីទំនាក់ទំនងរបស់គេជាមួយនឹងមូលដ្ឋានធនធានធម្មជាតិ រួមទាំងតំបន់សំរាប់កសិកម្មពនេចរ ឈើដងជ័រទឹក និង ព្រៃសំរាប់ សក្ការៈ និងព្រៃកប់ខ្មោចផងដែរ ។ ប្រជាជន បានបង្ហាញនូវក្តីសង្ឃឹមថា តាមរយៈការធ្វើការងារជាមួយមន្ត្រីខេត្ត ពួកគេនឹងទទួលបាននូវការគាំទ្រពី សេចក្តីសំរេចលើការបែងចែកនិងប្រើប្រាស់ដីធ្លីនាពេលអនាគត ហើយអាចរក្សាបាននូវលទ្ធភាពរបស់ពួកគេក្នុងការប្រើប្រាស់មូលដ្ឋានធនធាន តាមរយៈកម្មសិទ្ធិសមូហភាព កិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ និង ការការពារឈើផលិតជ័រជាលក្ខណៈផ្លូវការទៀតផង ។ ទោះបីជាដំណើរការធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម មិនអាចធានាអោយមានការរក្សាលទ្ធភាពប្រើប្រាស់ធនធានក៏ដោយ ក៏ការគាំទ្ររបស់សង្គមស៊ីវិល ត្រូវបានចាត់ទុកថា មានសារៈសំខាន់ ដោយផ្តល់ដល់សហគមន៍នូវឧបករណ៍សំរាប់ធ្វើការទំនាក់ទំនងជាមួយនឹងមន្ត្រីខេត្ត ប្រកបដោយន័យស្ថាបនាផងដែរ ។

ប្រភព : ទស្សនកិច្ចនៅសមាគមអភិរក្សសត្វព្រៃ និង អង្គការស៊ីដសេនៅក្នុងខេត្តមណ្ឌលគិរី

៣៩. ការរៀបចំអោយមានយុទ្ធវិធីចែករំលែកផលប្រយោជន៍នៅក្នុងមូលដ្ឋាននេះ គួរតែចាប់ផ្តើមពីការធ្វើផែនការ ធនធាននៅមូលដ្ឋានទៅ ។ តួនាទីនិងភារកិច្ចក្នុងការកំណត់ពីការបែងចែកធនធានធម្មជាតិ ទៅតាមផលប្រយោជន៍ គួរតែផ្ទេរអោយទៅស្ថាប័នខេត្តដែលធ្វើការងារជាមួយនឹងសហគមន៍មូលដ្ឋាន រួមទាំងក្រុមប្រឹក្សាឃុំ/សង្កាត់ផង ។ ផ្អែកតាមបទ ពិសោធន៍ដែលទទួលបានពីដំណើរការធ្វើផែនការប្រើប្រាស់

ដីធ្លីដោយមានការចូលរួម (PLUP) និង ការងារផ្សេងទៀត បានបង្ហាញអោយឃើញថា អាទិភាពជាតិ និងខេត្ត ត្រូវបានគោរពនៅក្នុងក្របខ័ណ្ឌដំណើរការធ្វើផែនការធនធាននៅមូលដ្ឋាន ប្រសិនបើអាទិភាពជាតិ មានលក្ខណៈច្បាស់លាស់ ដែលធ្វើអោយភាគីពាក់ព័ន្ធទាំងអស់ បានយល់ច្បាស់ (សូមមើលប្រអប់ ៤.៥) ។ គណៈកម្មាធិការបែងចែកដីធ្លីខេត្ត (Provincial Land Use Allocation Committee) ដែលត្រូវបានបង្កើតឡើងជាលក្ខណៈសាកល្បង ដោយអនុក្រឹតស្តីពីសម្បទានសង្គម គឺជាគំរូមួយនៃកិច្ចសហការអន្តរស្ថាប័ន ក្នុងការវាយតំលៃលើជំរើសសំរាប់ការគ្រប់គ្រងធនធាន ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីសង្គម ដែលកំពុងរង់ចាំការអនុម័ត នឹងផ្តល់នូវអោយកាស សំរាប់រៀបចំអោយមានយុទ្ធវិធីបែបសហវិមជ្ឈការ ដើម្បីគាំទ្រដល់ការធ្វើផែនការគ្រប់គ្រងធនធានរបស់រដ្ឋនៅថ្នាក់ខេត្ត ។

៤០. យុទ្ធវិធីចែករំលែកផលប្រយោជន៍ក្នុងមូលដ្ឋាន នឹងផ្លាស់ប្តូរខ្សែសង្វាក់ការទទួលខុសត្រូវ និង កំណត់មុខងារសមស្របអោយរដ្ឋាភិបាល ជានិយតករនៃទ្រព្យសម្បត្តិសាធារណៈ ជាជាងអ្នកផ្តល់ ។ ប្រព័ន្ធគ្រប់គ្រងបច្ចុប្បន្ន ប្រគល់ការទទួលខុសត្រូវស្ទើរតែទាំងអស់អោយទៅស្ថាប័នគ្រប់គ្រងធនធានថ្នាក់កណ្តាល ដើម្បីធានាអោយមានការបង្កើនទ្រព្យសម្បត្តិអោយគ្រប់គ្រាន់ ។ យុទ្ធវិធីភាពជាដៃគូក្នុងមូលដ្ឋាន បានផ្ទេរការទទួលខុសត្រូវ ក្នុងការបង្កើនទ្រព្យសម្បត្តិសាធារណៈអោយ ទៅតួអង្គនៅក្នុងមូលដ្ឋានដែលមានវិសាលភាពទូលំទូលាយជាង ក្នុងនោះរួមមានសហគមន៍ ក្រុមប្រឹក្សាឃុំ/សង្កាត់ បុគ្គលិក ស្ថាប័នគ្រប់គ្រងធនធានស្រុកនិងខេត្ត និង វិស័យឯកជន ។ បុគ្គលិកថ្នាក់ជាតិ មានភារកិច្ចទទួលខុសត្រូវក្នុងការឃ្លាំមើលជាមួយនឹងភាគីពាក់ព័ន្ធនៅថ្នាក់ខេត្ត និង ភាគីពាក់ព័ន្ធដទៃទៀត ដោយរៀបចំអោយមានលក្ខណៈស៊ីសង្វាក់គ្នារវាងក្រសួង និង អ្នកពិនិត្យតាមដានរបស់សង្គមស៊ីវិល សំដៅកាត់បន្ថយចំណាយទៅលើការឃ្លាំមើល និង ការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងលទ្ធផលនៃការគ្រប់គ្រង ដល់សាធារណជន ។

៤១. ការចែករំលែកផលប្រយោជន៍ មិនមែនជា"ឱសថទិព្វ" សំរាប់ដោះស្រាយបញ្ហាអភិបាលកិច្ចធនធានធម្មជាតិនោះទេ ។ ប្រសិនបើប្រជាជនក្រីក្រ មិនចូលរួមជាមួយនឹងសហគមន៍ ដែលមានលទ្ធភាពកំណត់ពីសិទ្ធិមួយចំនួនក្នុងការកាន់កាប់ធនធានធម្មជាតិនោះទេ កំណើនការចែករំលែកផលប្រយោជន៍នៅក្នុងមូលដ្ឋាន នឹងកាត់បន្ថយសក្តានុពលភាពសំរាប់ការបែងចែកផលប្រយោជន៍ជាថ្មីដល់ប្រជាជនក្រីក្រ ។ ការប្រើប្រាស់ឥទ្ធិពលគាបសង្កត់ពីសំណាក់អ្នកមានអំណាចនៅក្នុងមូលដ្ឋាន ទំនងជាកើតមាននៅក្នុង

សហគមន៍ជាច្រើន ជាពិសេស នៅក្នុងសហគមន៍ ដែលមិនមានយន្តការតម្លាភាពនិងទទួលខុសត្រូវ រួមទាំងសង្គមស៊ីវិលផង ។ សេដ្ឋកិច្ចមាត្រដ្ឋាននៃការគ្រប់គ្រងធនធានធម្មជាតិ អាចបង្កើនបន្ទុកទៅលើបុគ្គលិកថ្នាក់ស្រុក ឬខេត្ត ដែលត្រូវធ្វើការសំរបសំរួលអោយមានការចូលរួមពីភូមិឃុំនៅក្នុងការគ្រប់គ្រងធនធាន ។ ដំណោះស្រាយជំលោះ ក៏អាចមានលក្ខណៈស្មុគស្មាញផងដែរ ដោយសារពាក្យបណ្តឹង ត្រូវបញ្ជូនពីថ្នាក់មូលដ្ឋានទៅថ្នាក់លើ ដើម្បីដោះស្រាយអោយមានប្រសិទ្ធិភាព ។ ផ្អែកតាមបទពិសោធន៍ដែលទទួលបានរហូតមកដល់ពេលនេះបានបង្ហាញអោយឃើញថា រចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់គ្រង គួបផ្សំជាមួយនឹងការគាំទ្រពីសង្គមស៊ីវិលក្នុងការពង្រឹងយន្តការទទួលខុសត្រូវនិងដោះ ស្រាយជំលោះនៅមូលដ្ឋាន អាចដើរតួនាទីសំខាន់ ក្នុងការកាត់បន្ថយលទ្ធភាពនៃការប្រើឥទ្ធិពលគាបសង្កត់ពីសំណាក់អ្នកមានអំណាច និង ក្នុងការពង្រឹងសមត្ថភាពសំរាប់ដោះស្រាយជំលោះនៅមូលដ្ឋាន ។ ទោះជាយ៉ាងណាក៏ដោយ គេមិនត្រូវមើលស្រាលលើបញ្ហាប្រឈមទាក់ទងនឹងការបង្កើតអោយមានយុទ្ធវិធីចែករំលែកផលប្រយោជន៍នៅក្នុងមូលដ្ឋានឡើយ[៦] ។

## ច. ដោះស្រាយបញ្ហាប្រឈមជាបន្ទាន់ដើម្បីការពារធនធានធម្មជាតិ

៤២. ផ្អែកតាមបទពិសោធន៍របស់កម្ពុជា និង បទពិសោធន៍ដែលទទួលបានពីប្រទេសដទៃទៀត បានបង្ហាញអោយឃើញយ៉ាងច្បាស់ថា នៅពេលផ្ទេរអោយទៅទទួលខុសត្រូវលើការគ្រប់គ្រងធនធានធម្មជាតិ បុគ្គលិករដ្ឋាភិបាល និង សហគមន៍មូលដ្ឋាន ត្រូវទទួលការបណ្តុះបណ្តាលពង្រឹងសមត្ថភាពរយៈពេលជាច្រើនឆ្នាំ ។ កត្តានេះ នាំអោយចោទឡើងជាសំណួរថាតើរដ្ឋាភិបាលនិងដៃគូរបស់ខ្លួនគួរធ្វើយ៉ាងណា នៅពេលដែលយុទ្ធវិធីថ្មីទាក់ទងនឹងការចែករំលែកផលប្រយោជន៍នៅក្នុងមូលដ្ឋាន ត្រូវបានបង្កើតឡើងសាកល្បង និង ពង្រីកបន្ថែម ។ ដើម្បីគ្រប់គ្រងធនធានធម្មជាតិដ៏ច្រើនសន្ធឹកសន្ធាប់ដែលបញ្ចេញមកពីសម្បទាន ស្ថាប័នគ្រប់គ្រងធនធានដែលមានសមត្ថភាពទាបនេះ ត្រូវពង្រឹងសមត្ថភាពរបស់ខ្លួន តាមរយៈកិច្ចសហការជាមួយនឹងសហគមន៍មូលដ្ឋាន ពីព្រោះថាវាអាចពង្រឹង សមត្ថភាពដល់ស្ថាប័នរដ្ឋាភិបាល និង តាមរយៈយន្តការលើកកំពស់តម្លាភាព ។ យុទ្ធវិធីពហុភាគី មានលក្ខណៈ សមស្របទៅនឹងការពង្រឹងសមត្ថភាព និងបទពិសោធន៍សំរាប់រៀបចំការចែករំលែកផលប្រយោជន៍អោយមានលក្ខណៈជាផ្លូវការ ក្នុង

រយៈពេលវែង ។ បទពិសោធន៍របស់អង្គការអន្តរជាតិ ដូចជា អង្គការអភិរក្សអន្តរជាតិ (Conservation International) អង្គការជំនួយសត្វព្រៃ (Wild Aide) និង សមាគម អភិរក្សសត្វព្រៃ (Wildlife Conservation Society) ផ្តល់នូវឧទាហរណ៍មួយទាក់ទងនឹងយុទ្ធវិធីដែលអង្គការមិនមែនរដ្ឋាភិបាល ប្រើប្រាស់ ដើម្បីគាំទ្រដល់ការពិនិត្យតាមដានដោយមានការសហការ និង ការអនុវត្តន៍ច្បាប់ ។ ក្រោមប្រព័ន្ធពហុភាគី តួនាទីរបស់អ្នកពិនិត្យតាមដានដោយឯករាជ្យ កាន់តែមានសារៈសំខាន់ក្នុងការជួយដល់រាជរដ្ឋាភិបាល និងដៃគូ ដើម្បីកំណត់ពីចំណុចខ្សោយរបស់ប្រព័ន្ធនេះ ដែលតំរូវអោយចាត់វិធានការកែលំអជាបន្ទាន់ ។ ការបង្កើតប្រព័ន្ធពហុភាគី តំរូវអោយមានការគៀងគរធន ធាន ជាបន្ទាន់ពី រាជរដ្ឋាភិបាល និងម្ចាស់ជំនួយ សំរាប់ឧបត្ថម្ភជំនួយ បច្ចេកទេស ការបណ្តុះបណ្តាល ឧបករណ៍ ការលើកទឹកចិត្ត និង ចំណាយលើការពិនិត្យតាមដាន ។

## ឆ. សេចក្តីសន្និដ្ឋាន

៤៣. ជារួម ក្នុងខណៈដែលការគ្រប់គ្រងធនធានធម្មជាតិរបស់រដ្ឋផ្តល់នូវផលប្រយោជន៍សាធារណៈតិចតួចដល់ប្រជាជនកម្ពុជា ហើយក្របខ័ណ្ឌអភិបាលកិច្ចសំរាប់ធនធានធម្មជាតិនៅទន់ខ្សោយនោះ គេសង្កេតឃើញមានឱកាសល្អជាច្រើនសំរាប់ដោះស្រាយបញ្ហាទាំងនេះ និង បង្កើនផលប្រយោជន៍ពីការគ្រប់គ្រងធនធានធម្មជាតិ ។ រាជរដ្ឋាភិបាល បានទទួល ស្គាល់ចំពោះគុណវិបត្តិរបស់ខ្លួនក្នុងការអនុវត្តន៍យុទ្ធវិធីគ្រប់គ្រងធនធានធម្មជាតិ ហើយបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីបញ្ឈប់ជាបណ្តោះអាសន្ន ឬ កាត់បន្ថយសកម្មភាពគ្រប់គ្រងដែលគ្មានប្រសិទ្ធិភាព ។ រាជរដ្ឋាភិបាល ក៏បានបង្ហាញយ៉ាង ច្បាស់ពីគោលបំណងរបស់ខ្លួនក្នុងការបង្វែរទិសដៅគោលនយោបាយធនធានធម្មជាតិ អោយស្របទៅតាមទិសដៅនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

៤៤. ការបង្កើតអោយមានជំរើសចំពោះយុទ្ធវិធីគ្រប់គ្រងសម្បទានទ្រង់ទ្រាយធំបែបមជ្ឈការ តំរូវអោយមានកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាពីសំណាក់ រាជរដ្ឋាភិបាល ម្ចាស់ជំនួយ និង សង្គមស៊ីវិល ។ ម្ចាស់ជំនួយ ត្រូវឆ្លើយតបទៅនឹងការប្តេជ្ញារបស់រាជរដ្ឋាភិបាល ដោយផ្តល់នូវជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសសំរាប់បង្កើតប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិ ដែលមានលក្ខណៈទូលំទូលាយ មានតម្លាភាព និង មានការទទួលខុសត្រូវតាមរយៈការរៀបចំអោយមានក្របខ័ណ្ឌច្បាប់ និង ការពង្រឹងសមត្ថភាពបច្ចេកទេស សំរាប់

វាយតំលៃ ធ្វើផែនការអនុវត្ត/ប្រតិបត្តិ និង រាយការណ៍អំពីការគ្រប់គ្រងធនធាន ។ ការឃ្លាំមើលការគ្រប់គ្រងធនធានធម្មជាតិ គឺជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល និង សង្គមស៊ីវិល ហើយការពង្រឹងសមត្ថភាព ត្រូវធ្វើឡើងនៅគ្រប់ថ្នាក់ទាំងអស់ ក្នុងនោះរួមមាន រដ្ឋសភា ប្រព័ន្ធតុលាការ ស្ថាប័នអន្តរក្រសួង ភូមិ ឃុំ និង ប្រព័ន្ធផ្សព្វផ្សាយ ។ អង្គការអន្តរជាតិ និង សង្គមស៊ីវិល ត្រូវសហការជាមួយរាជរដ្ឋាភិបាល និង ម្ចាស់ជំនួយ ដើម្បីធ្វើសមា ហរណកម្មយន្តការចែករំលែកផលប្រយោជន៍នៅក្នុងមូលដ្ឋានទៅក្នុងប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិនាពេលបច្ចុប្បន្ន និង អនាគត តាមរយៈការគាំទ្រដល់សហគមន៍ឃុំ/សង្កាត់ ស្រុក/ខ័ណ្ឌ និង ខេត្ត/ក្រុង ដែលត្រូវអនុវត្តភារកិច្ចនិងការទទួល ខុសត្រូវថ្មី ក្រោមគំរោងទាំងនះ ។ ទោះបីជាកិច្ចការទាំងនេះកំពុងតែអនុវត្តក៏ដោយ ក៏មានតំរូវការជាបន្ទាន់មួយអោយបង្កើន ការគាំទ្រដល់សកម្មភាពការពារធនធានធម្មជាតិ តាមរយៈយុទ្ធវិធីពហុភាគីដែលប្រគល់ការទទួលខុសត្រូវសំខាន់ៗអោយ ទៅតួអង្គ អភិវឌ្ឍន៏នៅមូលដ្ឋាន ក្រោមការឃ្លាំមើលរបស់ស្ថាប័ននៅថ្នាក់ជាតិ ។

---

[១] អាស្រ័យទៅលើសេចក្តីណែនាំទី ៣ និងអនុក្រិត្យ លេខ ២៥ របស់រាជរដ្ឋាភិបាលកម្ពុជា

[២] នៅឆ្នាំ ២00៣ សមាគមក្រៅផ្លូវការនៃរាជរដ្ឋាភិបាល ស្ថាប័នផ្តល់ជំនួយ និង អង្គការមិនមែនរដ្ឋាភិបាល បានប្រគល់សិទ្ធិអំណាចឱ្យអ្នកជំនាញការឯករាជ្យមួយក្រុម ធ្វើការត្រួតពិនិត្យបទពិសោធន៍នៅក្នុងវិស័យព្រៃឈើកម្ពុជា និង វិវាទកម្មក្នុងពេលកន្លងទៅថ្មីៗនេះលើតួនាទីរបស់ធនាគារពិភពលោកក្នុងការគាំទ្រកំណែទំរង់ព្រៃសម្បទាន និង ការអនុវត្តន៏ច្បាប់ព្រៃឈើ ។ "ការពិនិត្យវាយតំលៃវិស័យព្រៃឈើដោយឯករាជ្យ" នេះ មានគោលបំណងផ្តល់នូវទស្សនៈវិស័យមួយលើបញ្ហាប្រឈមជាចំបង នៅក្នុងវិស័យនេះ និង ភាពពេញលេញនៃតុល្យភាព និង លំដាប់នៃកម្មវិធីកំណែទំរង់ ដែលត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាល ។ លទ្ធផលនៃការពិនិត្យវាយតំលៃនេះ នឹងយកមកផ្សព្វផ្សាយនៅត្រីមាសទីពីរ ឆ្នាំ ២00៤ កិច្ចសន្យាសម្បទានខ្លះ បានបង់ប្រាក់តំកល់ទុកនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

[៣] ទោះបីជាពុំមានទិន្នន័យដែលប្រកដប្រជាស្តីអំពីជំលោះ លើដីធ្លី ព្រៃឈើ និងនេសាទ នៅមានក្តី ហើយដោយសារតែជំលោះទាំងនោះមិនបានដោះស្រាយតាមផ្លូវការ ការសិក្សាដែលធ្វើទៅលើតែភូមិនានា និងការធ្វើសំភាសន៏របស់បុគ្គលិកអង្គការមិនមែនរដ្ឋា-ភិបាល បានបង្ហាញអោយឃើញថា បញ្ហាជំលោះមានការកើនឡើង ដោយយោងទៅតាមការសិក្សាមួយរបស់ USAID កាលពីខែមិថុនា ស្តីអំពី កម្ពុជា ការសិក្សាវាយតំលៃលើជំលោះព្រៃឈើនៅក៏រិតសហគមន៏ ។

[៤] របាយការណ៍ស្តីពីការតាមដានបទល្មើសព្រៃឈើត្រីមាសទី ២

[៥] ការវាយតំលៃការប្រើប្រាស់ថវិកាឱ្យចំគោលដៅនិងចំណាយសាធារណៈចំរុះ ដោយធនាគារពិភពលោក ឆ្នាំ ២០០៤

[៦] ដើម្បីពិភាក្សាលើបញ្ហានេះឱ្យបានកាន់តែធំទូលាយ **c.f:** លោក Van Acker និង លោក Frank - ការចូលរួមរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាននៅកម្ពុជា ដោយ ក្រសួងមហាផ្ទៃ និងអង្គការ GTZ នៅខែកក្កដា ឆ្នាំ ២០០៤

# ជំពូកទី ៥

## អភិបាលកិច្ចសំរាប់អភិវឌ្ឍន៍វិស័យឯកជន

១. សហគ្រាសឯកជនដែលធ្វើការនៅកម្ពុជាយល់ថាចាំបាច់ត្រូវមានការកែលំអខាងអភិបាលកិច្ច ។ ឧបសគ្គ ចំបងទាំងដប់ដែលពួកគេលើកឡើង ពាក់ពន្ធ័ជាប្រយោល និងផ្ទាល់លើអភិបាលកិច្ច ។ បញ្ហាដែល អ្នកសង្កេតការណ៏ដោយមិនមានភាពលំអៀងនឹងទទួលស្គាល់ថាមានភាពជាបន្ទាន់នោះ មានដូចជា តំលៃ និងការមានប្រាក់កំចី ថ្លៃថាមពល គុណភាពវត្ថុធាតុដើម (quality of inputs) មានផ្លូវគមនាគមន៍។ ជំនាញនិងក៏រិតវប្បធម៌របស់កម្មករមិនមាននៅក្នុងបញ្ជីចំណុចសំខាន់ទាំងដប់នោះទេ ។ ការនេះដោយសារ តែអភិបាលកិច្ចនៅតែខ្សោយ អាជីវកម្មខ្វះភាពជាក់លាក់ដែលគេត្រូវការដើម្បីទទួលភាពប្រថុយប្រថានក្នុង រយៈពេលយូរ (long term risks) ។ នៅពេលអ្នកខ្លះអាចចាត់ទុកថា ការស៊ីសំណូកជាការចំណាយក្នុង ការរកស៊ី ការនេះធ្វើអោយការចំណាយកើនឡើង ហើយធ្វើអោយពិបាកដល់ក្រុមហ៊ុន ក្នុងការទប់ទល់ នឹងស្ថិតនៅក្នុងទីផ្សារបាន ជាពិសេស នៅក្នុងឧស្សាហកម្មដែលមានការប្រកួតប្រជែងខាងថ្លៃ ។ ភាពពុក រលួយ ក៏យកពីរដ្ឋាភិបាលនូវថវិកាចំណូលដែលត្រូវការចាំបាច់ ដែលធ្លាក់ទៅដល់ការរកស៊ីវិញ តាមរយៈ ថ្លៃដឹកជញ្ជូនខ្ពស់ និង ការប្រើប្រាស់ម៉ាស៊ីនភ្លើងដោយខ្លួនឯង ។

២. ពិធីការនៃការបញ្ចូលកម្ពុជា ជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាមទារការកែទំរង់លើ គោលនយោបាយ និង ច្បាប់ចំនួន ៩៨ ផ្សេងៗគ្នា តាមតារាងពេលមួយដែលមានពេលខ្លី ការកែលំអទៅ លើក្របខ័ណ្ឌច្បាប់សំរាប់ការវិនិយោគបរទេសផ្ទាល់និងពន្ធដារ ហើយនឹងក្របខ័ណ្ឌសំរាប់ការពិភាក្សាជា ចំហជាមួយផ្នែកឯកជន លើបញ្ហាបរិយាកាសវិនិយោគ ។ ផ្នែកទាំងឡាយដែលត្រូវការការយកចិត្តទុក ដាក់មានដូចជា ៖

- ការកែលំអបរិយាកាសបទបញ្ជា (regulatory environment) ការត្រួតពិនិត្យរដ្ឋបាល ជា បន្ទុកដ៏ធ្ងន់ដល់វិសយ័ឯកជនរបស់កម្ពុជា ។ មានអធិការកិច្ចប្រចាំឆ្នាំជាច្រើន មានការចំណាយ ខ្ពស់បំផុតពេលចុះបញ្ជី ធ្វើអាជីវកម្ម ហើយមានការចំណាយពេលច្រើនបំផុតលំដាប់ទីពីរដើម្បី ជួប ជាមួយមន្រ្តី ។ ការជាន់លើពីអណត្តិរដ្ឋបាល បង្កើតភាពមិនប្រាកដប្រជា មន្ទិលសង្ស័យ

ហើយចំណាយខ្ពស់ ដើម្បីធ្វើពាណិជកម្ម ។ លើសពីនេះទៀត បទបញ្ជាច្រើនហួសហេតុ និង អំពើពុករលួយ បង្ខំអោយក្រុមហ៊ុននៅក្រៅផ្លូវការ ។

- ការបង្កើតអោយមានស្ថាប័នគាំទ្រទីផ្សារដែលមានទទុកចិត្ត, ការខ្វះខាតកម្មសិទ្ធិ សិទ្ធិកុងត្រា បទដ្ឋាន ធ្វើអោយបរិយាកាសវិនិយោគរបស់កម្ពុជាមិនទាក់ទាញអារម្មណ៍។ ការកែទំរង់ច្បាប់និង តុលាការ និងស្ថាប័នក្រៅផ្លូវការ គឺត្រូវការចាំបាច់ ។ ផ្នែកឯកក៏ត្រូវការរៀបចំអោយបាន ប្រសើរ ឡើងដើម្បីជួយ ក្នុងការអភិវឌ្ឍន៍ស្ថាប័នទាំងនោះ និងពិភាក្សាជាមួយរដ្ឋាភិបាល ។
- តម្លាភាពនិងការប្រកួតប្រជែងក្នុងដៃគូសាធារណៈនិងឯកជន ច្បាប់និងបទបញ្ជាមិនបានផ្តល់ជា ដំណើរការមួយដែលមានការសហការទេ រីក៏មិនបង្កើតអោយមានបែបបទច្បាស់លាស់និងមាន តម្លាភាពដែរ ។ ជាលទ្ធផលដំណើរនេះខ្វះតម្លាភាពនិងភាពប្រកួតប្រជែង ហើយផលប្រយោជន៍ ជាតិមិនអាចសំរេចបានទេ ។

៣. ផែនកាកំណែទំរង់ដែលផ្តើមដោយរដ្ឋាភិបាលដើម្បីកាត់បន្ថយចំណាយក្នុងធ្វើជំនួញ នឹងពង្រឹងដំណើរការសំរបសំរួលពាណិជ្ជកម្ម បង្ហាញពីយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យដើម្បីសំរួលដល់តម្រូវការអធិការ-កិច្ច កំរៃ ពង្រឹង ការចុះបញ្ជី ការអោយអាជ្ញាប័ណ្ណ និង ការដាក់ពន្ធលើក្រុមហ៊ុន ។ ផ្នែកឯកជន នឹងត្រូវលើកទឹកចិត្តអោយអនុវត្តក្រមសីលធម៌ និងកែលំអអភិបាលកិច្ចក្រុមហ៊ុន ។ ផ្នែកនេះនឹងចូលរួមជាមួយរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យការរីកចំរើនលើការកែទំរង់ ដូចដែលបានលើកឡើងផ្នែកលើវិធានការអនុវត្តមានតម្លាភាពមួយចំនួន ។

# ជំពូក ៥ : អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍វិស័យឯកជន

៤. យុទ្ធសាស្ត្រចតុកោណបានថែងថា "គោលដៅសំខាន់បំផុតនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចិរភាពផ្អែកលើមូលដ្ឋានទូលំទូលាយមានសមធម៌ ដោយមានផ្អែកឯកជនជាអ្នកដើរតួនាទីនាំមុខគេ" (រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណឆ្នាំ២០០៤) ។ អភិបាលកិច្ច គឺស្ថិតនៅជាចំណុចស្នូលនៃយុទ្ធសាស្ត្រនេះ ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការកសាងសមត្ថភាព និងការវិនិយោគផ្អែកស្ថាប័នដែលត្រូវការចាំបាច់សំរាប់ឱ្យមាន "កំណើនប្រកបដោយចិរភាពផ្អែកលើមូលដ្ឋានទូលំទូលាយមានសមធម៌"នោះ គឺជារបៀបវារៈមួយដែលវែង និងពិបាក ។ កំណើនផ្អែកលើមូលដ្ឋានទូលំទូលាយបែបនេះ គឺសំខាន់បំផុតចំពោះការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា ។ ប៉ុន្តែបើគ្មានការកែលំអមូលដ្ឋានគ្រឹះខាងអភិបាលកិច្ចទេ របៀបវារៈបែបនេះមានឱកាសទទួលជោគជ័យតិចតួចណាស់ ។

៥. សហគ្រាសឯកជនដែលដំណើរការនៅប្រទេសកម្ពុជា ទាំងសហគ្រាសបរទេស ទាំងសហគ្រាសក្នុងស្រុក យល់ពីចំណុចនេះដោយគ្មានស្រពិចស្រពិល ។ នៅពេលសួរពីឧបសគ្គដែលពួកគេប្រឈមមុខ បញ្ហាចំបងបំផុតចំនួនដប់ ដែលគេលើកឡើងសុទ្ធតែទាក់ទងនឹងអភិបាលកិច្ចដោយផ្ទាល់ឬប្រយោល (រូបភាព ៥.១)[១] ។ តំលៃ និងភាពលទ្ធភាពរក និងផ្តល់ឥណទាន តំលៃភ្លើង គុណភាពនៃការដាក់ទុន កង្វះខាត

**ប្រទេសកម្ពុជា : ឧបសគ្គធ្ងន់ធ្ងរបំផុតចំនួន ១០ ចំពោះ**
**ការប្រតិបត្តិ និងកំណើនរបស់សហគ្រាសឯកជន**



នៃផ្លូវថ្នល់ ជំនាញ និងកិរិតអប់រំរបស់បុគ្គលិក សុទ្ធតែជាបញ្ហាដែលអ្នកសង្កេតអំពីបរិយាកាសជំនួញនៅប្រទេសកម្ពុជា ទទួលស្គាល់ថាបន្ទាន់នោះមិនស្ថិតនៅក្នុង ចំណោមបញ្ហាចំបងបំផុតទាំងនោះទេ។ អ្វីដែលចោទជាបញ្ហាចំពោះវិស័យឯកជននោះ គឺការកែលំអអភិបាលកិច្ច។

## ក ~ មូលហេតុដែលអភិបាលកិច្ចជាបញ្ហាចោទ

៦. អភិបាលកិច្ចជាបញ្ហាចោទ ដោយសារមូលហេតុស្នូលពីរដែលមានសារៈសំខាន់ចំពោះអាជីវកម្មទាំងឡាយគឺៈ ការប្រថុយប្រថាន និងការផ្តល់រង្វាន់ ។ ដរាបណាអភិបាលកិច្ចនៅតែទន់ខ្សោយ មន្ត្រីនានាអាចត្រូវបានគេសូកប៉ាន់មិនអោយអនុវត្តន៍ច្បាប់ ឬបញ្ញត្តិនានា ហើយអាជីវកម្មនានាមិនអាចមានភាពច្បាស់លាស់ដូចមានចែងក្នុងច្បាប់ដែលចាំបាច់ចំពោះការប្រថុយប្រថានរយៈពេលវែងឡើយ ។ ដរាបណា "វិធាន" នៅមិនច្បាស់លាស់នោះ គ្មានការវិនិយោគរយៈពេលវែងណាអាចមានភាពច្បាស់លាស់ឡើយ ហើយការវិនិយោគតែមួយគត់ដែលអាចធ្វើទៅបាន គឺការវិនិយោគរយៈពេលខ្លី មិនប្រាកដ ឬអាស្រ័យលើសម្បត្តិពិសេស ឬការផ្តាច់មុខ ។ បើគ្មានការវិនិយោគ រយៈពេលវែង ជាពិសេសក្នុងការកសាងជំនាញ និងសមត្ថភាព នោះក៏គ្មានភាពប្រកួតប្រជែងរយៈពេលវែងដែរ ។ ដរាបណាអភិបាលកិច្ចនៅតែទន់ខ្សោយ ការសូកប៉ាន់ និងអំពើពុករលួយក្លាយទៅជាវិធាន ជាជាងការប្រកួតប្រជែង ដោយយុត្តិធម៌ ។ ទាក់ទងនឹងការអោយរង្វាន់ និងលើកទឹកចិត្តក្នុងការអនុវត្តន៍វិញបរិយាកាសវិនិយោគដែលកំណត់លក្ខណៈដោយអំពើពុករលួយ ដាក់ទោសចំពោះអ្នកដែលចង់វិនិយោគទុនផ្តោតលើការកែលំអផលិតផល និងសេវារបស់គេជាជាងការបង់សំណូក ហើយបែរជាផ្តល់រង្វាន់ដល់អ្នកដែលចំណាយពេលវេលា និងធនធានដែលមានទៅលើការរុករកភាពអនុគ្រោះពីរដ្ឋទេវិញ ។

៧. ចំពោះអ្នកខ្លះដែលគិតថាខ្លួនអាចចំរុងចំរើនក្នុងបរិយាកាសមួយបែបនេះ សំណូកគឺគ្រាន់តែជាមុខចំណាយបន្ថែមមួយទៀតនៃការធ្វើអាជីវកម្មដូចពន្ធដារដែរ ។ ប៉ុន្តែទោះជាយ៉ាងណាក្តី សំណូកគឺត្រូវបង់ពីប្រាក់ចំណូល "ជួរលើ" ដែលធ្វើអោយទំនិញរបស់គេមិនអាចចុះបាន និងធ្វើអោយមានការលំបាកដល់ក្រុមហ៊ុនក្នុងការអោយរួចថ្លៃដើម និងរស់រានមានជីវិត ។ វាធ្វើអោយប៉ះពាល់ដល់សមត្ថភាពក្នុងការប្រកួតប្រជែងនៅក្នុងឧស្សាហកម្ម ដែលមានការប្រកួតប្រជែងខាងចំណាយខុសពីពន្ធ ហើយសំណូកត្រូវបង់ទៅអោយអន្តរការី ឬបុគ្គល ។ ប្រការនេះ ធ្វើអោយរដ្ឋខាតបង់នូវប្រាក់ចំណូលជាផ្លូវការ ដែលត្រូវការចាំបាច់

សំរាប់យកទៅផ្តល់សេវាសាធារណៈនានា ដូចជា ភ្លើងអគ្គិសនី ផ្លូវថ្នល់ ទូរគមនាគមន៍ សុខាភិបាល អប់រំ ដែលត្រូវការចាំបាច់សំរាប់ភាពប្រកួតប្រជែងរយៈពេលវែង ។ ការចំណាយបែបនេះ បន្ទាប់មក ត្រូវបញ្ជូនទៅក្រុមហ៊ុនក្នុងទ្រង់ទ្រាយដូចជាផលិតអគ្គិសនីដោយកំរៃខ្ពស់ ឬការចំណាយដឹកជញ្ជូនខ្ពស់ជាដើម។ ក្រុមហ៊ុនដែលត្រូវរ៉ាប់រងលើចំណាយទាំងនេះធ្វើអោយខ្លួនឯងមានឱកាសតិចតួចក្នុងការប្រកួតប្រជែង បើតំលៃពលកម្មមិនត្រូវបានរឹតបន្តឹងអោយខ្លាំងទេនោះ។ ការចំណេញរយៈពេលខ្លីពីការ បង់សំណូក ឬទទួលសំណូកជានិច្ចកាលបានមកដោយខាតបង់ទៅវិញនូវទីផ្សារមួយដែលលូតលាស់ប្រកបដោយការប្រកួតប្រជែង ដែលកំណត់លក្ខណៈដោយសេវាសាធារណៈដ៏មានប្រសិទ្ធិភាព គោលនយោបាយអាចទុកចិត្តបាន និងប្រាក់ឈ្នួលសមរម្យ ។

៨. សហគ្រាសឯកជនទាមទារអោយមានវិធានការមួយច្បាស់លាស់ និងភាពដែលអាចប៉ាន់ស្មានបានដើម្បីធ្វើ ការវិនិយោគរយៈពេលវែង ។ ដូចគ្នាដែរ អាជីវកម្មបច្ចុប្បន្នដំណើរការទៅក្នុងទីផ្សារពិភពលោកការប្រគល់ការងារ ផ្អែកទៅលើការប្រកួតប្រជែងគ្នា។ ជាលទ្ធផល ប្រទេសកម្ពុជាមានជំរើសតិចតួចក្រៅពីពង្រឹងអភិបាលកិច្ច និងកាត់បន្ថយអំពើពុករលួយ ។ អ្នកមានចំណែកពាក់ព័ន្ធទាំងអស់សុទ្ធតែមានប្រយោជន៍ក្នុងជោគជ័យនៃទិសដៅដ៏មោះមុតនេះៈ ទាំងអ្នកធ្វើគោលនយោបាយដែលបានប្រថុយដាក់ភាពជឿទុកចិត្តរបស់ខ្លួនលើយុទ្ធសាស្ត្រនេះ ទាំងមន្ត្រីសាធារណៈដែលសមនឹងទទួលបានភាពថ្លៃថ្នូរនៃប្រាក់បៀវត្សរ៍មួយដែលអាចឧបត្ថម្ភដល់គ្រួសាររបស់គេ ទាំងអ្នកបំរើការងារដែលសមនឹងទទួលបាននូវឱកាសក្នុងការដាក់ទុនលើការអប់រំរបស់ខ្លួនចំពោះការងារ និងសំខាន់បំផុត ទាំងសហគ្រិន ដែលមិនត្រូវការភាពអនុគ្រោះពិសេសអ្វីក្រៅពីឱកាសក្នុងការប្រកួតប្រជែងនៅលើលានដែលរាបស្មើ និងលំហគ្រប់គ្រាន់ដើម្បីផ្តោតការយកចិត្តទុកដាក់លើការកែលំអអាជីវកម្មរបស់ខ្លួន ។ បើប្រទេសកម្ពុជាមិនអាចផ្តល់នូវបរិយាកាសបែបនេះបានទេនោះ ពួកគេនឹងរើទៅរកទីកន្លែង និងបរិយាកាសដែលគេអាចរីកចំរើនបាន។

៨. ការកែប្រែត្រូវតែចាប់ផ្តើមជាមួយនឹងទស្សនៈវិស័យគន្លឹះផ្សេងមួយអំពីតួនាទីរបស់រដ្ឋ ពីស្ថាប័នមួយដែលត្រួតត្រាសកម្មភាពឯកជន ទៅជាស្ថាប័នមួយដែលសំរបសំរួលដល់កំណើនរបស់ឯកជនតាមរយៈទីផ្សារដែលមានការប្រកួតប្រជែង ។ ស្របពេលដែលប្រទេសទុកជំលោះផ្ទៃក្នុងជាអតីតកាលរបស់ខ្លួនបន្ទុកដ៏ធ្ងន់ធ្ងរនៃការត្រួតពិនិត្យ និងធ្វើបញ្ញត្តិដែលអាចមានន័យកាលពីមុននោះ ក៏ត្រូវតែឈប់គិតពីវាដែរ

ដោយងាកទៅរកការគិតគូដល់កិច្ចខ្នះខ្នែងគាំទ្រទីផ្សារ ដើម្បីសំរេចគោលបំណងដូចគ្នានេះ ។ វាជាការជាការប្រសើរណាស់ថា រដ្ឋាភិបាលយល់ថា ផ្នែកឯកជនដ៏រស់រវើកមួយ គឺជាផលប្រយោជន៍របស់ខ្លួន តាមពិតវាជាផ្នែកសំខាន់បំផុតមួយនៃយុទ្ធសាស្ត្ររបស់ខ្លួនរួចជាស្រេចទៅហើយ ។ ការប្តេជ្ញានេះចាំបាច់ត្រូវបង្ហាញខ្លួននៅក្នុងការផ្លាស់ប្តូរមួយខាងវប្បធម៌អភិបាលកិច្ចពីវប្បធម៌ មួយដែលដាក់ចេញនូវការចុះបញ្ជី លិខិតអនុញ្ញាត អធិការកិច្ច និងថ្លៃឈ្នួលនៅដំណាក់កាលនីមួយៗ ទៅជាវប្បធម៌ មួយដែលលើកទឹកចិត្តទីផ្សារអោយធ្វើការដោយផ្តោតគោលដៅអន្តរាគមន៍សាធារណៈ តែនៅកន្លែងណាដែលមានការប្រថុយប្រថានធំបំផុត ។

១០. វាមានសារៈសំខាន់ក្នុងការទទួលស្គាល់នូវជំហានជាប្រវត្តិសាស្ត្រ ដែលប្រទេសកម្ពុជាបានប្រកាន់យកឆ្ពោះទៅរកគោលបំណងនេះ ដោយការចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោកនោះ ។ ដូចឯកឧត្តម ចម ប្រសិទ្ធ បានថ្លែង ក្នុងសុន្ទរកថាពេលថ្មីៗនេះ ពិធីសារនៃការចូលអង្គការនេះទាមទារអោយរដ្ឋាភិបាលត្រូវធ្វើកំណែទំរង់ច្បាប់ និង គោលនយោបាយដាច់ដោយឡែកពីគ្នាចំនួន ៩៨ តាមពេលកំណត់ដ៏លឿនមួយធ្វើការកែលំអខាងក្របខ័ណ្ឌបញ្ញត្តិ សំរាប់ការវិនិយោគផ្ទាល់ពីបរទេស និងការដកពន្ធ និងក្របខ័ណ្ឌសំរាប់ការពិគ្រោះយោបល់ចំហជាមួយផ្នែកឯកជន លើបញ្ហាបរិយាកាសវិនិយោគ ។ អង្គការពាណិជ្ជកម្មពិភពលោក គឺជាស្ថាប័នមួយ ដែលទទួលបាននូវចំណុចខ្លាំងរបស់ខ្លួនពីការប្តេជ្ញារបស់សមាជិករបស់ខ្លួន ក្នុងការគ្រប់គ្រងពាណិជ្ជកម្ម ជាមួយនឹងគុណតំលៃរួមមួយចំនួន គឺ : ភាពបើកចំហ តម្លាភាព ភាពដែលអាចប៉ាន់ស្មានបានការមិនរើសអើង/ពហុភាគីនិយម និងការដោះស្រាយទំនាស់ ផ្អែកលើវិធានច្បាប់ ។ គុណតំលៃទាំងនេះដូចគ្នានឹងគុណតំលៃដែលប្រទេសកម្ពុជាកំពុងព្យាយាមអោយមានក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់ខ្លួនកន្លងមកដែរ ។ ការចូលរួមក្នុងអង្គការពាណិជ្ជកម្មពិភពលោកធ្វើអោយ មានការកែលំអលទ្ធភាពចូលទីផ្សារ ហើយក៏បញ្ជូននូវសញ្ញាដ៏ខ្លាំងមួយដល់ដៃគូពាណិជ្ជកម្ម និងវិនិយោគអំពីទិសដៅអនាគតរបស់ប្រទេសកម្ពុជាផងដែរ ។ ក៏ប៉ុន្តែអង្គការពាណិជ្ជកម្មពិភពលោកមិនមែនជាឱសថទិព្វដោះស្រាយគ្រប់បញ្ហានោះទេ ។ ការទាញយកផលប្រយោជន៍ពីលទ្ធភាពចូលទីផ្សារ នឹងទាមទារអោយមានការកែទំរង់យ៉ាងច្រើនដែលពាក់ព័ន្ធដល់ការប្តូរពីវប្បធម៌នៃការត្រួតត្រា ទៅជាវប្បធម៌នៃការសំរបសំរួលវិញ ។ ផ្តើមចេញពីការសន្មតជាមូលដ្ឋាននេះ មានយុទ្ធសាស្ត្រសំខាន់ៗបួនចំណុច ដែលគួរអោយមានការយកចិត្តទុកដាក់ ។

(ក) កែលំអបរិយាកាសខាងបទបញ្ញត្តិសំរាប់អាជីវកម្ម ដែលរួមទាំងការសំរបសំរួលពាណិជ្ជកម្មផង

(ខ) បង្កើតស្ថាប័នគាំទ្រទីផ្សារ ដើម្បីសំរបសំរួលដល់ការប្រកួតប្រជែងគ្នា

(គ) តម្លាភាព និងគណនេយ្យភាពនៅក្នុងភាពជាដៃគូរវាងឯកជន-សាធារណៈ ហើយនិង

(ឃ) ការអភិវឌ្ឍន៍នូវស្ថាប័នសំខាន់ៗ ដែលរួមបញ្ចូលទាំងក្រមសីលធម៌ និងបទដ្ឋាននៃអភិបាលកិច្ច ផ្នែកឯកជនផងដែរ ។

## ខ ~ ការកែលំអបរិយាកាសខាងបទបញ្ញត្តិ

១១. ការដាក់បញ្ញត្តិច្រើនហួសហេតុលើក្រុមហ៊ុន និងទីផ្សារ គឺជាការរួមចំណែកដល់ភាពក្រៅផ្លូវការ អំពើពុករលួយ និងប៉ះពាល់ដល់មូលដ្ឋានពន្ធដារ ។ ឥទ្ធិពលនៃការបរាជ័យខាងអភិបាលកិច្ចបញ្ញត្តិ គឺកាត់បន្ថយនូវទំហំ និង វិសាលភាពនៃផ្នែកឯកជនផ្លូវការដាក់កំរិតលើលទ្ធភាពផលិត និងជាហេតុកាត់បន្ថយនូវឥទ្ធិពលដែលផ្នែកឯកជនមានលើភាពក្រីក្រ ។ យុទ្ធសាស្ត្រកែទំរង់មួយដែលអាចជឿជាក់បាន គឺត្រូវតែផ្អែកលើការជំនួសការត្រួតត្រាខាងរដ្ឋបាលដែលជាន់គ្នា និងពេលខ្លះមានលក្ខណៈសំរេចតាមចិត្តនោះ ដោយកម្មវិធីមួយដែលធ្វើអន្តរាគមន៍ផ្អែកលើការប្រថុយប្រថាន លុបបំបាត់តួនាទីត្រួតគ្នា និងផ្តល់អំណាចទីផ្សារតាមរយៈវិធានដែលថែងច្បាស់លាស់។

១២. ការដាក់បញ្ញត្តិក្នុងករណីនេះសំដៅទៅលើការប្រើប្រាស់អំណាចរដ្ឋ ដើម្បីត្រួតត្រាលើការប្រព្រឹត្តិទៅរបស់ទីផ្សារ ។ ទីផ្សារជារឿយៗទាមទារអោយមានបទបញ្ញត្តិ ដើម្បីការពារដល់អ្នកប្រើប្រាស់ អ្នកបំរើការងារ និង បរិយាកាសបណ្តាក់ទុន ដើម្បីធានាអោយមានទីផ្សារដែលមានប្រសិទ្ធិភាព និងធ្វើអោយមានតុល្យភាពរវាងផលប្រយោជន៍សាធារណៈ ជាមួយនឹងផលប្រយោជន៍របស់ក្រុមហ៊ុនដែលស្វែងរកផលចំណេញ ។ បញ្ហាប្រឈមរបស់អ្នកធ្វើគោលនយោបាយ គឺមិនមែននៅត្រង់ថាតើត្រូវដាក់បញ្ញត្តិ ឬមិនដាក់នោះទេ ប៉ុន្តែផ្ទុយទៅវិញគឺនៅត្រង់ថា តើត្រូវរៀបចំបទបញ្ញត្តិយ៉ាងណាដែលសំរេចគោលបំណងផ្នែកសង្គម ក្នុងបរិយាកាសអំណោយផលសំរាប់ការវិនិយោគមានស្រាប់។

**បទបញ្ញត្តិកាន់តែធ្ងន់ គឺទាក់ទិនជាមួយនឹងអំពើក្រៅផ្លូវការ និងអំពើពុករលួយ**




***សំគាល់ :*** ទំនាក់ទំនងទៅវិញទៅមកដែលបង្ហាញក្នុងតួលេខទាំងនេះផ្អែកលើប្រាក់ចំណូល ។ ទំនាក់ទំនងយកជាការបាននៅក៏រិត ១ ភាគរយ ។

***ប្រភព :*** ទិន្នន័យ *ការធ្វើអាជីវកម្ម* , Schneider 2002; Kaufmann, Kraay, និង Mastruzzi 2003 ។

*ប្រភព : ធនាគារពិភពលោក, **PICS** កម្ពុជា ឆ្នាំ ២០០៣*

១៣. បទបញ្ញត្តិដែលរៀបចំមិនបានល្អ អាចប៉ះពាល់ដល់ផលប្រយោជន៍នៃពាណិជ្ជកម្មសេរី ។ មានភស្តុតាងកាន់តច្រើនឡើងបញ្ជាក់ថា ភាពបើកចំហ និងពាណិជ្ជកម្ម មិនបានបង្កើតនូវកំណើនលូតលាស់ នៅក្នុងបរិយាកាសពាណិជ្ជកម្ម ដែលមានការដាក់បទបញ្ញត្តិខ្លាំងនោះឡើយ (ប៊ីនេស្វារី បូលាគី និង ការ៉ូលីន ហ្វ្រើន ឆ្នាំ ២០០៤) ។ ការដាក់បញ្ញត្តិខ្លាំង ដាក់កំរិតលើភាពអាចបន់បែន បាននៃទីផ្សារ និងតាមរយៈនោះបង្ការមិនអោយមានការប្រើប្រាស់កត្តាផ្សេងៗ ពោលគឺបុគ្គលិកជំនាញ និងមិនជំនាញ ឧបករណ៍ មូលធន ជាដើម ក្នុងមធ្យោបាយនានាដែលនឹងបង្កើតនូវផលចំណេញខាងផលិតភាពដែលជាធម្មតា ពាក់ព័ន្ធជាមួយពាណិជ្ជកម្ម ។ ក៏មានភស្តុតាងយ៉ាងច្រើនផងដែរបញ្ជាក់ថា បទបញ្ញត្តិដែលរៀបចំមិនបានល្អ ឬជ្រុលហួសហេតុ គឺមានទាក់ទិន យ៉ាងជិតដិត ជាមួយអំពើក្រៅផ្លូវការ និងពុករលួយ ។

១៤. ការត្រួតត្រាផ្នែករដ្ឋបាល គឺជាបន្ទុកមួយដ៏ធ្ងន់ និងមានតំលៃខ្ពស់ចំពោះផ្នែកឯកជនរបស់ប្រទេសកម្ពុជា ។ ការអង្កេតអំពីបរិយាកាសវិនិយោគឆ្នាំ ២០០៣ បានបង្ហាញថា ប្រទេសកម្ពុជាប្រៀបធៀបមិនសូវជាល្អទេជាមួយនឹងប្រទេសនានាដែលខ្លួនប្រកួតប្រជែងខាងចំនួនបញ្ហាខាងបទបញ្ញត្តិ ។ កម្ពុជាមានអធិការកិច្ចប្រចាំឆ្នាំច្រើនបំផុត (អត្រាឥណទានតំលៃក្នុងម្នាក់ៗ) ខ្ពស់បំផុតដើម្បីចុះបញ្ជីអាជីវកម្មផ្លូវការ និងមាន "ការចំណាយពេលវេលា" ដើម្បីចាត់ចែងគ្រប់គ្រងដោះស្រាយការងារជាមួយមន្ត្រីច្រើនបំផុត លំដាប់ទីពីរ(បន្ទាប់ពីប្រទេសចិន) ។ ការអនុវត្តន៍លើ ការសំរបសំរួលពាណិជ្ជកម្ម គឺមានឧបសគ្គជាពិសេស

ដោយមានការចំណាយពេលជិះរះបញ្ជីយូរបំផុតលំដាប់ទីពីរ បន្ទាប់ពីប្រទេសប៉ាគីស្ថាន ។ ផ្ទុយពីកេរ្តិ៍ឈ្មោះរបស់ប្រទេសកម្ពុជាក្នុងនាមជាប្រទេសមួយមានបរិយាកាសសេរីនោះ ក្នុងទិដ្ឋភាពមួយចំនួន ប្រទេសកម្ពុជាហាក់ដូចជាមានទីផ្សារមួយដែលមានលក្ខណៈតឹងរឹង ដោយសារឥទ្ធិពលគួប ផ្សំគ្នានៃទីភ្នាក់ងារមួយចំនួនដែលបំពេញការងារក្នុងលក្ខណៈមិនមានការសំរបសំរួលគ្នា។ យោងតាមទិន្នន័យអំពីការប្រកបអាជីវកម្ម (ការប្រកបអាជីវកម្ម : ការយល់ដឹងអំពីបទញ្ញត្តិ។ ធនាគារពិភពលោក) គេត្រូវការពេលវេលា ៩៤ ថ្ងៃ ដើម្បីចាប់ផ្តើមអាជីវកម្មមួយ នៅក្នុងប្រទេសកម្ពុជា ពោលគឺយូរជាងនៅប្រទេសវៀតណាមចំនួន ៣០ ថ្ងៃ និងយូរជាងនៅប្រទេសថៃចំនួន ៥២ ថ្ងៃ ។ ប្រទេសកម្ពុជាមានប្រព័ន្ធសំរាប់ការសុំធ្វើអាជីវកម្មមួយយឺតបំផុត និងថ្លៃបំផុតក្នុងតំបន់អាស៊ីបូពា (ផ្អែកលើមូលដ្ឋានក្នុងម្នាក់ៗ) ។

១៥. វិធានការណ៍រដ្ឋបាលទាំងនេះ បង្កើតនូវការប្រាស្រ័យទាក់ទងញឹកញាប់រវាងមន្ត្រីសាធារណៈ និងក្រុមហ៊ុន ជាហេតុផ្តល់លទ្ធភាពអោយមានអំពើពុករលួយកើតឡើង។ ក្រុមហ៊ុនភាគច្រើនទទួលស្គាល់ថាការបង់ប្រាក់ទៅអោយមន្ត្រីសាធារណៈ ជាញឹកញាប់ ភាគច្រើន ឬជានិច្ចកាល គឺតំរូវ "ធ្វើអ្វីមួយអោយបានសំរេច"។ ការអង្កេតរបស់ យើងលើក្រុមហ៊ុនក្នុងក្រុងចំនួន ៥០០ បានបង្ហាញអោយឃើញថាការបង់សំណូកគឺមានញឹកញាប់ណាស់។ ក្នុង ចំណោមក្រុមហ៊ុនចំនួន ៤៤៧ ដែលបានឆ្លើយសំណួរនេះ មាន ៨២% បានរាយការណ៍ថា ពួកគេបានបង់សំណូក និង ៧១ ភាគរយនៃក្រុមហ៊ុនធំៗផ្តល់មតិថា ការបង់ប្រាក់បែបនេះមានភាពញឹកញាប់ ។ ការបង់ប្រាក់ទាំងនេះ តាមការ រាយការណ៍មានចំនួន ជាមធ្យមស្មើនឹង ៥ ភាគរយ នៃការលក់របស់ក្រុមហ៊ុន ប៉ុន្តែកើនឡើងថែមទៀតទៅតាមទំហំក្រុមហ៊ុន និងភាពផ្លូវការដែលលើសពី ៦ ភាគរយនៃការលក់សរុបរបស់ក្រុមហ៊ុនធំៗ ។




ប្រភព: ធនាគារពិភពលោក នៅកម្ពុជា ឆ្នាំ ២០០៣

១៦. តួនាទីរដ្ឋបាលត្រួតលើគ្នាទាំងនេះ បន្ថែមនូវភាពមិនច្បាស់លាស់ ការសំរេចតាមចិត្ត និងថ្លៃឈ្នួលខ្ពស់ថែមទៀតទៅលើដំណើរការនៃការជួញដូរទំនិញ ។ ក្នុងចំណោមឧបសគ្គចំបង៧ដែលបានរាយការណ៍ដោយក្រុមហ៊ុនពាណិជ្ជកម្ម គឺមានការជំរះបញ្ជីពន្ធគយ ការអនុញ្ញាតច្បាប់របស់ក្រសួងគមនាគមន៍ ឬប៉ូលីសព្រំដែន ការធ្វើអធិការកិច្ចផ្នែកពេទ្យសត្វ និងអនាម័យម្ហូបអាហារ និងកាំកុងត្រូល ។ ឧបសគ្គនីមួយៗសុទ្ធតែពាក់ព័ន្ធការពន្យារ ពេលការចំណាយពេលវេលាគ្រប់គ្រងការចំណាយផ្លូវការ និងការបង់ប្រាក់ក្រៅផ្លូវការ ។ ការជំរះបញ្ជីពន្ធគយតែ មួយមុខទាមទារអោយមានការពន្យារពេលយ៉ាងយូរ និងភាពប្រែប្រួលយ៉ាងសំបើម ជាហេតុមិនអាចប៉ាន់ស្មានបាន នូវកិច្ចដំណើរការទីផ្សារ ។ ជាមធ្យម ក្រុមហ៊ុននានារាយការណ៍ថា ការនាំចូលត្រូវស៊ីពេល ៦.៥ ថ្ងៃ ដើម្បីជំរះ បញ្ជីគយរួច រីឯការនាំចេញត្រូវការពេល ៤.៥ ថ្ងៃ ។ ប៉ុន្តែទោះជាយ៉ាងនោះក្តី ពេលវេលាទាំងនោះបានប្រែប្រួល ក្រុមហ៊ុននានារាយការណ៍ថា ក្នុងឆ្នាំកន្លងទៅ ពួកគេបានត្រូវរង់ចាំជាមធ្យមជាង ១១ ថ្ងៃយ៉ាងតិច សំរាប់ការដឹក ជញ្ជូនមួយលើក និង ១៦ ថ្ងៃដើម្បីជំរះបញ្ជីគយសំរាប់ការដឹកទំនិញនាំចេញម្តង ។ តំលៃសរុបនៃការជំរះបញ្ជី គយសំរាប់ទំនិញនានាក៏មានភាពប្រែប្រួលផ្សេងៗពីគ្នាដែរ ។

១៧. ជាលទ្ធផលបទបញ្ញត្តិប្រើហួស និងមិនអាចប៉ាន់ស្មាន និងភាពញឹកញាប់នៃការបង់សំណូកដែលទាក់ទិន នឹងបទបញ្ញត្តិ ធ្វើអោយក្រុមហ៊ុននានាប្រតិកម្មតបវិញដោយការបង់ប្រាក់ក្រៅផ្លូវការ ។ យោងតាមធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងចំណោមក្រុមហ៊ុនចំនួន ២៧,០០០ ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា មានតែ ៩,០០០ ប៉ុណ្ណោះបានចុះបញ្ជីរួច ។ យុទ្ធសាស្ត្រនៃការស្ថិតនៅក្រៅផ្លូវការ ហាក់ដូចជាមានប្រយោជន៍ក្នុងរយៈពេលខ្លីៈ ក្រុមហ៊ុនក្រៅផ្លូវការ ក៏ដូចជាក្រុមហ៊ុននៅជនបទគឺមិនសូវជួបឧបសគ្គទេ ។ ក្នុងរយៈពេលវែងយុទ្ធសាស្ត្រ បែបនេះ គឺមានតំលៃខ្ពស់ នៅពេលដែលផ្នែកក្រៅផ្លូវការនោះមានសមត្ថភាពចុះថយ ហើយធ្វើពាណិជ្ជកម្មជាមួយផ្នែកផ្លូវការ ដើម្បីរកកេរ្តិ៍ឈ្មោះ និងរីកលូតលាស់ឡើង ។ ជារួមលទ្ធផលទំនងដូចជារង្វង់អវិជ្ជមានមួយដែលក្រុម ហ៊ុនទាំងនោះ នៅតែតូច និង ក្រៅផ្លូវការ ដែលនាំអោយខាតបង់ចំណូលរបស់រដ្ឋាភិបាល ដែលត្រូវការចាំបាច់ ដើម្បីកែលំអការអនុវត្តការងារសាធារណៈ ដែលការខាតបង់ទាំងនោះ ឈានទៅ រួមចំណែកធ្វើអោយមានភាពអន់ខ្សោយក្នុងបរិយាកាសវិនិយោគ ។

១៨. ករណីលើកលែងដ៏សំខាន់មួយចំពោះភាពស្ថិតនៅក្រៅផ្លូវការនោះ គឺវិស័យកាត់ដេរ ដែលបានលូតលាស់ក្នុងបរិយាកាសមួយពិសេស ដែលមិនមានភាពប្រកួតប្រជែង ពោលគឺៈ កូតា ។ វិស័យកាត់ដេរ បានបញ្ជាក់ច្បាស់ពីសមត្ថភាពរបស់ខ្លួនក្នុងនាំចេញ និងរីកលូតលាស់ ប៉ុន្តែឥឡូវនេះវាត្រូវប្រឈមមុខនឹងការបញ្ចុះតំលៃ ជាហេតុនាំអោយមានតំរូវការចាំបាច់ក្នុងការបង្កើនប្រសិទ្ធិភាពរបស់ខ្លួន ។ ដូចអ្នកនាំចេញសំលៀកបំពាក់នានាទូទាំងពិភពលោកដែរ ក្រុមហ៊ុនកម្ពុជាត្រូវតែប្រកួតជាមួយនឹងភាពសេរីនៃពាណិជ្ជកម្ម កាត់ដេរនៅដំណាច់ឆ្នាំ ២០០៤ នេះ តាមរយៈកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោកស្តីពីទំនិញក្រណាត់ និងសំលៀកបំពាក់ សហរដ្ឋអាមេរិកបានផ្តល់ដល់ប្រទេសកម្ពុជានូវកូតាមួយក្នុងទីផ្សារការពាររបស់ខ្លួន ដែលទំហំនៃកូតានោះអាស្រ័យលើស្ថាន ភាពពលកម្មនៅកម្ពុជា ។ កិច្ចព្រមព្រៀងនេះនឹងត្រូវជំនួសដោយការប្រកួតប្រជែងវិញនៅឆ្នាំ ២០០៥ ។ មានលទ្ធភាពដែលថា ការអនុវត្តនូវការទទួលខុសត្រូវចំពោះសង្គមរបស់ក្រុមហ៊ុនសាជីវកម្ម នឹងក្លាយទៅជាប្រភព មួយដែលមានប្រយោជន៍



ដល់ការប្រកួតប្រជែង ប៉ុន្តែប្រទេសកម្ពុជាត្រូវប្រកួត ប្រជែងក្នុងផ្នែកដែលមានទំហំធំ ដែលតំរូវការទំនងជាអាចនឹងប្រែប្រួលទៅតាមតំលៃការវិវត្តប្រែប្រួលនៃចរិកលក្ខណៈរបស់តំលៃក្នុងការនាំចេញ ទំនិញមិនមែនជាគូតារបស់ប្រទេសកម្ពុជាទៅកាន់សហរដ្ឋអាមេរិកបង្ហាញនូវកំរិតធ្លាក់ចុះ ។ នៅពេលដែលឧស្សាហកម្មពិភពលោករួបរួមគ្នាដើម្បីទាញយកប្រយោជន៍ពីសេដ្ឋកិច្ចមានកំរិត ឧស្សាហកម្មរបស់ប្រទេសកម្ពុជាគឺត្រូវប្រឈមនឹងគ្រោះថ្នាក់ ។ ការផ្តោតការយកចិត្តទុកដាក់លើការកែលំអបទបញ្ញត្តិ ប្រហែលជារឹតតែបន្ទាន់ថែមទៀត ក្នុងវិស័យកាត់ដេរ ដើម្បីអនុញ្ញាតអោយមានបុគ្គលិកកម្មករប្រហែល ២៤០,០០០ នាក់នៅមានការងារធ្វើ ។

## គ ~ ការបង្កើតស្ថាប័នគាំទ្រទីផ្សារដែលអាចជឿជាក់បាន

១៩. បញ្ហាខាងបរិយាកាសវិនិយោគជាច្រើន ជាពិសេសក្រៅពីវិស័យកាត់ដេរ និងទេសចរណ៍ បណ្តាលមកពីកង្វះនូវស្ថាប័នសំខាន់ៗ ដែលរាប់បញ្ចូលទាំងខាងសិទ្ធលើទ្រព្យសម្បត្តិ សិទ្ធិកិច្ចសន្យា និងបទដ្ឋានដែលមានការព្រមព្រៀងគ្នា ។ គុណតំលៃនៃសិទ្ធិទាំងនេះអាស្រ័យទៅលើវត្តមាននៃប្រព័ន្ធតុលាការមួយដែលមានប្រសិទ្ធិភាព ។ ដំណើរការរបស់ទីផ្សារ ដូចជាការប្រកួតប្រជែងណាមួយដែរ វាអាស្រ័យទៅលើវិធានច្បាស់លាស់ដែលត្រូវបាន អនុវត្តន៏ យ៉ាងមានប្រសិទ្ធិភាព និងដោយយុត្តិធម៌ ។ នេះទាមទារអោយអំណាចរដ្ឋបាលរបស់រដ្ឋត្រូវប្រើប្រាស់ មិនមែនដើម្បីតែអន្តរាគមនៅគ្រប់ដំណាក់កាលទាំងអស់នៃការប្រកួតប្រជែងទេ ប៉ុន្តែគឺដើម្បីដោះស្រាយទំនាស់ និងអនុវត្តន៏ទោសចំពោះការរំលោភលើវិធាននានា ដែលអ្នកប្រកួតប្រជែងទាំងឡាយត្រូវគោរពតាម ។ នៅទីណា ដែលវិធានទាំងនោះមានភាពច្បាស់លាស់ ហើយការអនុវត្តអាចជឿទុកចិត្តបានទីផ្សារនឹងអនុវត្តមុខងារជាច្រើន ដែលជាគោលដៅចង់បានរបស់ផ្នែកត្រួតពិនិត្យរដ្ឋបាល ។ នេះពាក់ព័ន្ធដល់ការប្តូរពីអំណាច និងគណនេយ្យភាព ពី អ្នករដ្ឋបាល ទៅអោយអ្នកចូលរួមប្រឡូកក្នុងទីផ្សារវិញ ។

២០. ផ្នែកមួយនៃជោគជ័យក្នុងការបង្កើតវិធានច្បាស់លាស់ គឺត្រូវដាក់"អាជ្ញាកណ្តាល"អោយឆ្ងាយពីឥទ្ធិពលរបស់អ្នកចូលរួមប្រឡូកក្នុងទីផ្សារ តាមរយៈប្រព័ន្ធតុលាការឯករាជ្យមួយ ។ ប៉ុន្តែមានមនុស្សតិចណាស់ដែលមានជំនឿទុកចិត្តលើប្រព័ន្ធតុលាការ (សូមមើលសេចក្តីសង្ខេបរួមសំរាប់ការពិភាក្សាពេញលេញជាងនេះ) ។ និយាយអោយសាមញ្ញទៅប្រព័ន្ធតុលាការ នឹងត្រូវការកំណែទំរង់ជាច្រើនដើម្បីកសាង

នូវប្រវត្តិស្នាដៃនៃការកាត់សេចក្ដីដោយមិនលំអៀង និងមានប្រសិទ្ធិភាពមុនពេលដែលការយល់ឃើញបែបនេះត្រូវបានផ្លាស់ប្ដូរ ។ ទន្ទឹមនឹងនោះ មានតួនាទីសំខាន់ៗដែលអាចធ្វើទៅបានដោយផ្នែកឯកជន និងសង្គមស៊ីវិល។

*ក្រាហ្វិក ៥.១ : ឥទ្ធិពលដែលគេមើលឃើញទៅលើរដ្ឋបាល*




២១. ប្រទេសកម្ពុជាបានធ្វើអោយមានភាពជឿនលឿនយ៉ាងច្រើនក្នុងការធ្វើពង្រាងច្បាប់ថ្មី ជាពិសេសទាក់ទិនជាមួយនឹងការចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោក ហើយក៏ចាំបាច់ត្រូវធ្វើអោយមានភាពជឿនលឿនយ៉ាងឆាប់រហ័សដូចគ្នាដែរក្នុងការកសាងសមត្ថភាពដើម្បីអនុវត្តបទបញ្ញត្តិទាំងនេះ ។ ក្រុមស៊ីវិល និងពាណិជ្ជកម្មមួយដែលមានប្រសិទ្ធិភាព គឺមានសារៈសំខាន់ជាពិសេសពីព្រោះវាលើកទឹកចិត្តអោយមានការធ្វើកិច្ចការពេញដៃពេញជើង ។

២២. របៀបវារៈអភិវឌ្ឍន៍ស្ថាប័ន ធ្វើដំណើរទៅមុខបានល្អជាងកំណែទំរង់ច្បាប់ ។ ស្ថាប័នក្រៅផ្លូវការដូចជា បទដ្ឋានផលិតកម្ម វិធានពាណិជ្ជកម្ម ប្រព័ន្ធពតិមាន និងយន្តការក្រៅប្រព័ន្ធតុលាការសំរាប់ដោះស្រាយទំនាស់សុទ្ធ តែដើរតួនាទីមួយក្នុងការបង្កើតនូវបរិយាកាសទីផ្សារមួយដែលគាំទ្រដល់ការប្រកួតប្រជែងដោយយុត្តិធម៌ ។ សូម្បីតែនៅពេលដែលសភារបស់ប្រទេសកម្ពុជាអនុវត្តរបៀបវារៈនីតិបញ្ញត្តិក្ដី ក៏នឹងមានការងារយ៉ាងច្រើនសំរាប់ផ្នែក ឯកជនក្នុងការផ្លាស់ប្ដូរអាកប្បកិរិយារបស់ខ្លួនឆ្លើយតបនឹងច្បាប់ថ្មីៗ

ផងនិងកសាងប្រព័ន្ធមិនផ្លូវការដ៏ទៃទៀតផង។ ដូចលោក ឌូក្លាស ណរត៌ (Douglas North) បានពន្យល់ក្នុងឧទ្ទេសនាមពានរង្វាន់ណូបែលរបស់គាត់ "គឺបន្សំនៃវិធានផ្លូវការ បទដ្ឋានក្រៅផ្លូវការ និងចរិតលក្ខណៈនៃការអនុវត្តន៍ច្បាប់ ដែលជាអ្នកកំណត់រូបរាងនៃការអនុវត្តផ្នែកសេដ្ឋកិច្ច ។ ក្នុងខណៈពេលដែលវិធានអាចត្រូវផ្លាស់ប្តូរពេលរំលងមួយយប់ បទដ្ឋានក្រៅផ្លូវការជាធម្មតាផ្លាស់ ប្តូរតែសន្សឹមៗប៉ុណ្ណោះ។"

២៣. ក្នុងករណីជាច្រើនផ្នែកឯកជនអាចធ្វើការកែទំរង់ ដោយមិនមានអន្តរាគមន៍ពីសាធារណៈ ។ នេះរាប់បញ្ចូលទាំងឧស្សាហកម្មដែលស្វ័យបញ្ញត្តិ ដូចជាសេវាកម្មជាលក្ខណៈអាជីព និងឧស្សាហកម្មដែលស្វ័យបញ្ញត្តិ ភាគខ្លះ ដូចជា សំណង់ជាដើម ។ ផ្នែកឯកជន ជាពិសេសផ្នែកឯកជនក្នុងស្រុក និងនៅជនបទដែលជាអ្នកផ្តល់ការងារធ្វើភាគច្រើននៅប្រទេសកម្ពុជា ចាំបាច់ត្រូវដើរតួនាទីមួយកាន់តែសកម្មក្នុងការបង្កើតស្ថាប័ន ដោយសារប្រទេសកម្ពុជាស្ថិតនៅដំណាក់កាលដំបូងនៃការធ្វើអោយទៅជាផ្លូវការ និងការធ្វើអោយទៅជាជំនាញនោះ ការពិចារណាសំខាន់បំផុត ប្រហែលជាផ្តោលតទៅលើសមត្ថភាពរបស់ស្ថាប័នមូលដ្ឋានក្នុងការរៀនសូត្រ ពោលគឺអោយទទួលបាននូវព័ត៌មាន និងបទពិសោធន៍ដែលជាផ្នែកមួយ សំខាន់នៃដំណើរការសំរបខ្លួនតាមបច្ចេកវិជ្ជា ។ ផ្នែកឯកជនរបស់ប្រទេសកម្ពុជា មានស្ថាប័ន តិចតួចដែលអាចសំរបសំរួលការជជែកពិភាក្សាអំពី"វិធានប្រកួតប្រជែង" ក្រៅពីសមាគមរោងចក្រ កាត់ដេរសំលៀកបំពាក់ដែលជោគជ័យនោះ ។ ផ្នែកឯកជនចាំបាច់ត្រូវតែបានរៀបចំអោយកាន់តែប្រសើរឡើងដើម្បីជួយក្នុងការងារអភិវឌ្ឍន៍ស្ថាប័នបែបនេះ ដើម្បីលើកកំពស់ការយល់ដឹងក្នុងចំណោមអ្នកចូលរួមក្នុងទីផ្សារអំពីសិទ្ធិទាំងឡាយ និងដើម្បីតំរូវអោយរដ្ឋជាអ្នកទទួលខុសត្រូវចំពោះការពង្រឹងសិទ្ធិទាំងនោះដោយយុត្តិធម៌។

២៤. វេទិការដ្ឋាភិបាល-ផ្នែកឯកជន ដែលត្រូវបានរៀបចំឡើងជាកិច្ចប្រជុំពីរលើកក្នុងមួយឆ្នាំរវាងខុទ្ទកាល័យនៃរាជរដ្ឋាភិបាលកម្ពុជា និងតំណាងមកពីផ្នែកឯកជន គឺជាការចាប់ផ្តើមមួយដ៏មានសារៈប្រយោជន៍ ប៉ុន្តែកិច្ចការជាច្រើនទៀតក៏ចាំបាច់ត្រូវធ្វើដែរដើម្បីកសាងនូវ"សំលេង"របស់ផ្នែកឯកជន-ជាពិសេសក្នុងតំបន់ជនបទកម្ពុជា ។ ទុនសង្គម ការបង្កើតបណ្តាញ និងការចែករំលែកព័ត៌មានក្នុងចំណោមផ្នែកឯកជន អាចត្រូវបានសំរបសំរួលដោយសមាគមអាជីវកម្ម ឬអង្គការសមាជិកភាពអាជីវកម្ម ។ អង្គការសមាជិកភាពអាជីវកម្ម ជាអង្គការអន្តរការី ប្រទាក់ក្រឡាគ្នា និងស្វ័យបញ្ញត្តិ ។[២] ដូច្នេះ ពួកគេតំណាងអោយទំរង់នៃការអភិវឌ្ឍន៍បែបចូលរួមមួយដែលកាន់តែមាន សារៈសំខាន់ឡើងនៅក្នុងប្រទេសនានា ដូចជា

ប្រទេសកម្ពុជា ជាដើម ។ ដោយសារទំហំរបស់ខ្លួន អង្គការសមាជិក ភាពអាជីវកម្មមានសមត្ថភាពទទួលយកទូលំទូលាយ និងរួមចំណែកដល់ការកែលំអស្ថានភាពក្របខ័ណ្ឌសំរាប់ផ្នែកឯកជន តាមរយៈការសំរបសំរួលអោយមានការយល់រួមគ្នាអំពីវិធានផ្លូវការនៃពាណិជ្ជកម្មការចាត់វិធានការណ៍ សមូហភាព ការផ្តល់សេវាសំខាន់ៗ និងការបង្កើតបណ្តាញក្នុងចំណោមសមាជិក និងអ្នកមានចំណែកពាក់ព័ន្ធដទៃទៀត ។ គឺបណ្តុំចំណុចខ្លាំងដ៏ពិសេសនេះហើយដែលធ្វើអោយពួកគេក្លាយជាផ្នែកដ៏មានប្រសិទ្ធិភាពក្នុងការ បង្កើនកំណើនលូតលាស់របស់ក្រុមហ៊ុន ក្នុងប្រទេសណាមួយក៏បាន ។ សមាគមអាជីវកម្ម អាចសំរបសំរួលអោយមានការផ្លាស់ប្តូរ ដោយការកែលំអលំហូរព័ត៌មាន និងដោយការសំរបសំរួលលើការរៀនសូត្រតាមរយៈការតស៊ូ មតិលើគោលនយោបាយ តាមរយៈការសំរបសំរួល ឬការផ្តល់ដោយផ្ទាល់នូវសេវាតាមតំរូវការ និងតាមរយៈការ តស៊ូមតិដែលសំដៅបង្កើតបរិយាកាសអាជីវកម្មមួយកាន់តែប្រសើរឡើង ។

២៥. កិច្ចការនេះនឹងទាមទារអោយមានការវិនិយោគក្នុងការលើកកំពស់ការយល់ដឹង និងសមត្ថភាពត្រួតពិនិត្យ និងតស៊ូមតិលើគោលនយោបាយ ។ គ្មានភាគីណាមួយមានចំណែកធំជាងផ្នែកឯកជនក្នុងការកែទំរង់មួយដែលជោគជ័យនោះទេ ដែលផ្នែកនេះជាអ្នកទទួលឥទ្ធិពលដោយផ្ទាល់ពីគុណភាពនៃបរិយាកាសវិនិយោគ ។ ដូច្នេះ ការកសាងសមត្ថភាពក្នុងស្រុកដើម្បីត្រួតពិនិត្យការកែទំរង់ គឺទំនងជាកាន់តែមានចីរភាព និងកាន់តែស៊ីសង្វាក់ជាមួយនឹងយុទ្ធសាស្ត្រ មួយដែលអំពាវនាវអោយមានការប្រើប្រាស់ជាអតិបរមានូវធនធានឯកជនដែលមិនមែនជារបស់រដ្ឋ។

## ឃ ~ តម្លាភាព និងការប្រកួតប្រជែងក្នុងភាពជាដៃគូរវាងឯកជន~សាធារណៈ

២៦. យុទ្ធសាស្ត្រចតុកោណរបស់ប្រទេសកម្ពុជា ដាក់អាទិភាពសំខាន់មួយលើការកែលំអការផ្តល់សេវាសាធារណៈ ដែលត្រូវបានចុះទន់ខ្សោយជាពិសេសដោយសារជំលោះ និងការមិនអើពើជាច្រើនឆ្នាំ ពីព្រោះតែសេចក្តីត្រូវការមានលក្ខណៈស្រួចស្រាល់ ហើយធនធានមានកំរិត រដ្ឋនឹងត្រូវដើរតួនាទីយ៉ាងច្រើន ដោយជៀសមិនរួច សំរាប់ការផ្តល់សេវាសាធារណៈដល់ផ្នែកឯកជន ដោយសារឧបសគ្គ និងកង្វះធនធានប្រទេសកម្ពុជាតាមពិត បានក្លាយជាមជ្ឈមណ្ឌលមួយនៃការច្នៃប្រឌិតថ្មីខាងភាពជាដៃគូរវាងឯកជន-សាធារណៈ សំរាប់ការផ្តល់នូវសេវាសាធារណៈ ដែលរួមបញ្ចូលទាំងសុខាភិបាល ទឹក ការផ្គត់ផ្គង់ភ្លើងអគ្គិសនីជនបទ និងរហូតដល់ការដាក់ចេញនូវបទដ្ឋានការពារពលកម្ម ដែលផ្សារភ្ជាប់នឹងពាណិជ្ជកម្ម (តារាង ៥.១)។

ក្នុងវិស័យទឹកស្អាត រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការផ្តួចផ្តើមគំនិតអោយឯកជនចូលរួម ដែលប្រើប្រាស់កិច្ចសន្យាផ្អែកលើទិន្នផល ដែលមានលក្ខណៈប្រកួតប្រជែង នៃការតបណ្តាញភ្ជាប់ទៅនឹងប្រព័ន្ធទឹកសាធារណៈ ដែលឈានទៅសំចៃបាន ៣០ ភាគរយ ធៀបនឹងការផ្តល់ដោយសេវា សាធារណៈ ។

***តារាង ៥.១ កិច្ចការ PPI នៅប្រទេសកម្ពុជា និងទំរង់នៃជំលោះ***

| *វិស័យ* | | | តំលៃ |
|---|---|---|---|
| គំរោង | អង្គភាពសាធារណៈ | ទំរង់នៃកិច្ចសន្យា PPI | លាន US$ |
| *សេវារបស់សាលាក្រុង* | | | |
| ការគ្រប់គ្រងកាកសំណល់ | អាជ្ញាធរ អប្សរា | សម្បទានសំរាប់ការប្រមូលសំរាមនៅអង្គរវត្ត ជាមួយក្រុមហ៊ុនផ្អែកឯកជនមួយ | គ្មានទិន្នន័យ |
| | សាលាក្រុង ភ.ព | សម្បទានសំរាប់ការប្រមូលសំរាមជាមួយក្រុមហ៊ុន ស៊ីនទ្រី | គ្មានទិន្នន័យ |
| *ទឹក* | ទីភ្នាក់ងារផ្សេងៗ | | |
| ជនបទ | MIME, MRD, MOWRAM, MPWT | ប្រព័ន្ធជនបទដប់ ត្រូវបានចរចាជាឯកជនជាមួយ MIME<br>ប្រព័ន្ធជនបទប្រាំមួយ ត្រូវបានចរចាដោយផ្ទាល់ជាមួយ MRD-MIME-PGs | < 0.25<br>< 0.1 |
| *ការដឹកជញ្ជូន* | MPWT, PGs | | |
| ផ្លូវថ្នល់ | MPWT | ផ្លូវជាតិលេខ ៤ ត្រូវបានចរចាជាមួយ CoM | គ្មានទិន្នន័យ |
| | Provinces | សម្បទានជនបទត្រូវបានចរចាជាមួយអភិបាលខេត្ត | គ្មានទិន្នន័យ |
| ផែ | MPWT | ចំណតប្រេង និងផែស្ងួត ត្រូវបានចរចាជាមួយ CoM | គ្មានទិន្នន័យ |
| អាកាសយានដ្ឋាន | CoM, SSCA | សម្បទានជាមួយ Vinci ដែលឧបត្ថម្ភដោយ SCA សំរាប់ការអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ភ្នំពេញ (PNH) ត្រូវបានចរចាជាមួយ CoM | 30.0 |
| | CoM, SSCA, MPWT | សម្បទានជាមួយ Vinci ដែលឧបត្ថម្ភដោយ SCA ត្រូវបានពង្រីកទៅបញ្ចូលទាំងអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប ផ្អែកលើខបញ្ញត្តិអំពីសិទ្ធិផ្តាច់មុខអន្តរជាតិ ក្នុងសម្បទាន PNH | គ្មានទិន្នន័យ |
| | SSCA | សេវាតំរង់ទិសអាកាសចរណ៍ ត្រូវបានចរចាជាមួយ CoM | 23.0 |

| *វិស័យ*<br>គំរោង | អង្គភាពសាធារណៈ | ទំរង់នៃកិច្ចសន្យា PPI | តំលៃ<br>លាន US$ |
|---|---|---|---|
| *អគ្គិសនី* | MIME, CoM, EDC, EAC | | |
| ទីក្រុង | MIME | កិច្ចព្រមព្រៀងទិញអគ្គិសនីសំរាប់ IPPs ត្រូវបានចរចាជាមួយ MIME ក្នុងកិច្ចសហប្រតិបត្តិការជាមួយ CoM ក្រោមវត្តមានរបស់ EdC | គ្មានទិន្នន័យ |
| ជនបទ | MIME, EDC<br>EAC (និយ័តករ) | ខេត្ត បាត់ដំបង និងខេត្តសៀមរាប បានចរចាជាមួយ MIME-EdC<br>ការផ្តល់លិខិតអនុញ្ញាតដល់អ្នកផ្គតផ្គង់អគ្គិសនីជនបទតូចៗដែលមានស្រាប់ >50kW | គ្មានទិន្នន័យ<br>12.0 |
| *ទូរគមនាគមន៍* | MPTC | | |
| ច្រកផ្លូវអន្តរជាតិ | MPTC | កិច្ចព្រមព្រៀងធ្វើសម្ព័ន្ធអាជីវកម្មជាមួយ RTI | គ្មានទិន្នន័យ |
| បណ្តាញខ្សែទូរស័ព្ទលើតុទីពីរ | MPTC | កិច្ចព្រមព្រៀងធ្វើសម្ព័ន្ធអាជីវកម្មជាមួយ ឥណ្ឌូសាត Indosat សំរាប់ កាំមីនតែល Camintel | គ្មានទិន្នន័យ |
| សេវាចល័ត | MPTC | កិច្ចព្រមព្រៀងធ្វើសម្ព័ន្ធអាជីវកម្មជាមួយឧបការី ៤ : ម៉ូប៊ីថែល Mobitel, សាម៉ាត Samart, កាំតែល Camtel, ស៊ីណាវ៉ាត់ត្រា Shiniwatra ត្រូវបានចរចាជាមួយ MPTC/CoM | គ្មានទិន្នន័យ |
| VOIP | CoM, MPTC | លិខិតអនុញ្ញាតមួយសំរាប់ពិធិសារសំលេងលើអ៊ីនធើណែត (VOIP) ត្រូវបានផ្តល់ដល់ BCC, ចរចាជាមួយ CoM | គ្មានទិន្នន័យ |
| *អ៊ីនធើណែត* | MPTC | លិខិតអនុញ្ញាតដល់អ្នកផ្តល់សេវាអ៊ីនធើណែត | គ្មានទិន្នន័យ |

២៧. ការចូលរួមរបស់ផ្នែកឯកជនបានកើនឡើងក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (PPI) នៅក្នុងប្រទេសកម្ពុជា ក្រោមក្របខ័ណ្ឌស្ថាប័ន និងបញ្ញត្តិសមស្របមួយ គឺទំនងជាផ្តល់នូវឱកាសសំរាប់បង្កើនធនធានថវិកា និងសំរាប់កែ លំអប្រសិទ្ធិភាព ។ ផលប្រយោជន៍នៃការកែលំអប្រសិទ្ធិភាពអាចមានច្រើន ជាពិសេសនៅពេលវាគួបផ្សំនឹងកំណែទំរង់ដែលអំណោយផលដល់ការប្រកួតប្រជែង (ឬសូម្បីសកម្មភាពផ្តាច់មុខដែល

ដំណើរការក្រោមក្របខ័ណ្ឌបញ្ញត្តិ សមស្រប) ។ ភាពជាដៃគូរវាងសាធារណៈ-ឯកជន ចាំបាច់ត្រូវមើលឃើញជាផ្នែកនៃយុទ្ធសាស្ត្រមួយដើម្បីបង្កើន ប្រសិទ្ធិភាពនៃការផ្តល់សេវា ។ ដើម្បីធានានូវលទ្ធផលល្អបំផុតសំរាប់ប្រជាពលរដ្ឋកម្ពុជា និងដើម្បីគាំទ្រដល់គោល ដៅផ្តល់សេវានៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររដ្ឋាភិបាលនឹងចាំបាច់ត្រូវដាក់ចេញនូវគោលការណ៍នៃតម្លាភាព ការប្រកួតប្រជែង គណនេយ្យភាព និងការរៀបចំសមហេតុផលក្នុងគ្រប់កិច្ចការទាំងអស់ជាមួយផ្នែកឯកជន ។

២៨. ប៉ុន្តែការអនុវត្តន៍នៃការចូលរួមរបស់ឯកជនក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៅប្រទេសកម្ពុជា ជាញឹកញាប់ ត្រូវកំណត់លក្ខណៈដោយកង្វះការប្រកួតប្រជែង និងតម្លាភាព ដែលនាំអោយប្រទេសខាតបង់នូវផលប្រយោជន៍ពី ប្រសិទ្ធិភាពដែលជាមូលហេតុសំខាន់បំផុតដើម្បីពាក់ព័ន្ធផ្នែកឯកជន ។ ដោយសារលក្ខណៈនៃសេវាសាធារណៈ ផលចំណេញខាងប្រសិទ្ធិភាពទាំងនេះភាគច្រើនបំផុតអាចចាប់យកបាននៅពេលប្រតិបត្តិការប៉ុណ្ណោះ ។ ដំណើរការនេះ ត្រូវបាន"បំបែក"យ៉ាងលំអិតដើម្បីតំរូវអោយក្រុមហ៊ុនចៀសវាងសំរាប់ធានាបានកិច្ចនូវប្រតិបត្តិការផ្សេង១ ពោល គឺវាជាដំណើរការមួយដែលនាំអោយប្រទេសកម្ពុជាខាតបង់ផលប្រយោជន៍ភាគច្រើននៃការចូលរួមរបស់ឯកជន ។ ក្នុងពេលអវត្តមាននៃក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងបញ្ញត្តិសមស្របនោះ ផលប្រយោជន៍ជាច្រើនដែលទាក់ទិន ជាមួយនឹងការចូលរួមរបស់ឯកជនក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ មិនត្រូវបានធានាទេ ។ នេះក៏មានផលវិបាកអាក្រក់ ធ្ងន់ធ្ងរ ចំពោះប្រាក់ចំណូលថវិកាផងដែរ ។

២៩. ក្នុងវិស័យទូរគមនាគមន៍ លិខិតអនុញ្ញាតឯកជននីមួយ១ ឬកិច្ចព្រមព្រៀងសហប្រតិបត្តិការ គឺជាសម្ព័ន្ធ អាជីវកម្មរវាងឧបការី និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។ ហេតុនេះ ក្រសួងចែករំលែកនូវកម្មសិទ្ធិលើ សេវាចល័តទាំងអស់ បណ្តាញទូរស័ព្ទមានខ្សែ និងច្រកហៅអន្តរជាតិ ។ ក្រសួងក៏ជាអ្នកកំណត់គោលនយោបាយ ខាងទូរគមនាគមន៍ និងដើរតួនាទីជាភ្នាក់ងារដាក់បញ្ញត្តិ ។ វិស័យនេះត្រូវបានកំណត់លក្ខណៈដោយកង្វះនូវតម្លាភាព ក្នុងដំណើរការសំរាប់ផ្តល់លិខិតអនុញ្ញាត ការចែករំលែកប្រាក់ចំណូលទ្រង់ទ្រាយធំដោយបង្ខំរវាងឧបការីឯកជន និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងការប្រកួតប្រជែងដ៏តិចតួចបំផុតខាងតំលៃរវាងអ្នកផ្តល់សេវា ។ ក្នុងវិស័យ ដឹកជញ្ជូនក៏ដូចគ្នាដែរ វាមានលំបាកក្នុងការកំណត់ថាតើរាជរដ្ឋាភិបាលកម្ពុជា និង/ឬអ្នកប្រើប្រាស់ជាអ្នកកំពុងទទួល បាននូវតំលៃពិតពីអាកាស

យានដ្ឋាន ផ្លូវថ្នល់យកប្រាក់ និងសម្បទានត្រួតត្រាចរាចរផ្លូវអាកាស ពីព្រោះកិច្ចសន្យា ទាំងអស់ត្រូវបានចរចាដោយផ្ទាល់ ហើយសេចក្ដីពិស្ដារអំពីកាតព្វកិច្ចអនុវត្តន៍ និងការបែងចែកការប្រថុយប្រថាន មិនត្រូវបានអោយដឹងជាសាធារណៈទេ ។

ខ្សែចង្វាក់នៃគណនេយ្យភាព ត្រូវកាត់ផ្ដាច់ជាច្រើនថ្នាក់ ។ ការធ្វើគោលនយោបាយ ការធ្វើផែនការ និងការកំណត់គំរោង មិនត្រូវបានតំរង់ទិសជិតដល់អោយបានស្របជាមួយនឹងថវិកាដែលមាន ឬជាមួយយុទ្ធសាស្ត្រ របស់វិស័យទាំងនោះឡើយ ។ ច្បាប់ និងបទបញ្ញត្តិបច្ចុប្បន្ន មិនមានចែងអំពីដំណើរការមួយដែលមានការសំរប សំរួលអោយមានប្រសិទ្ធិភាពសំរាប់ការព្រមព្រៀងលើគោលនយោបាយអំពីការអភិវឌ្ឍ PPI ឬសំរាប់កំណត់អាទិភាពរវាងគំរោង ឬវិស័យនានាឡើយ ។ មានភាពច្របូកច្របូលខាងស្ថាប័នគួរអោយកត់សំគាល់ រាប់បញ្ចូលទាំងករណីដែលការបែងចែកតួនាទី និងការទទួលខុសត្រូវរវាងស្ថាប័ននានាមានភាពមិនច្បាស់លាស់។ ច្បាប់ដែលមានស្រាប់មិនបានកំណត់អោយបាន ច្បាស់លាស់ថាតើទីភ្នាក់ងារមួយណាមានអំណាចចូលធ្វើការចរចា និងធ្វើការសំរេចចិត្តលើគំរោងហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ ជាពិសេសឃើញមានភាពច្របូកច្របល់រវាងអំណាចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក្រសួងពាក់ព័ន្ធនានា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈរដ្ឋមន្ត្រី និងរវាងស្ថាប័ន កណ្ដាលទាំងនេះរបស់រដ្ឋាភិបាលជាមួយ ខេត្ត-ក្រុង និងឃុំ-សង្កាត់ ។[៣]

៣១. ច្បាប់ទាក់ទងនឹងវិស័យនានា ក៏មិនបានចែងពីនីតិវិធីច្បាស់លាស់សំរាប់ផ្ដល់ និងចរចាគំរោង PPI ដែរ ។ ក្នុងវិស័យមួយចំនួន មានទីភ្នាក់ងារយ៉ាងច្រើនដែលផ្ដល់ការត្រួតពិនិត្យ លិខិតអនុញ្ញាត និងការអនុញ្ញាតអោយបើកដំណើរការ ប៉ុន្ដែពុំមានការសំរបសំរួល ឬមានតិចតួចប៉ុណ្ណោះរវាងទីភ្នាក់ងារទាំងនេះ ។ ទីភ្នាក់ងាររដ្ឋាភិបាលជាច្រើន ប្រកួតប្រជែងជាមួយគ្នាដើម្បីចូលក្នុងការចរចាសម្បទានជាមួយអ្នកវិនិយោគផ្នែកឯកជន ។ ក្នុងករណីខ្លះ តួនាទី និងការទទួលខុសត្រូវដែលបានកំណត់ជាផ្លូវការនោះ ត្រូវបានបំភ្លេចឬទាត់ចោលដោយបុគ្គលថ្នាក់លើ នាយកដ្ឋាន-មន្ទីរ និងក្រសួង ក្នុងជួររដ្ឋាភិបាល ។

៣២. អ្នកប្រើប្រាស់ទីបំផុតត្រូវបង់ខាត ប៉ុន្ដែមិនមានផ្លូវសំរាប់ដោះស្រាយទេ ។ ផលវិបាកនៃបញ្ហាទាំងនេះ រួមមាន :

- *គំរោងដែលមិនអាចផ្តល់ហិរញ្ញប្បទាន* ជាមួយនឹងអ្នកវិនិយោគសព្វថ្ងៃនេះគ្មានលទ្ធភាពទាំងស្រុងក្នុងការធានារកហិរញ្ញប្បទានគំរោងជាជំនួយមានកំរិត ឬមិនមែនជាជំនួយ សំរាប់គំរោងហេដ្ឋារចនាសម្ព័ន្ធនៅប្រទេសកម្ពុជា - ការវិនិយោគទាំងអស់ត្រូវបានផ្តល់ហិរញ្ញប្បទានពីដើមទុនទាំងស្រុង ដែលបង្កើនការទាមទារអោយមានផលចំណេញតាមតំរូវការ និងជាហេតុនាំអោយនាំតំលៃឡើងខ្ពស់សំរាប់អ្នកប្រើប្រាស់ ។
- *កង្វះនូវព័តិមាន* អំពីតំលៃសំរាប់ប្រាក់ ដែលសាធារណជនទទួលបានពីគំរោងហេដ្ឋារចនាសម្ព័ន្ធដោយសារតែការគ្មានលទ្ធភាពរបស់សាធារណជន ឬភាគីទីបី ដូចជាធនាគារ និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ជាដើម ក្នុងការវាយតំលៃលើតំលៃពេញលេញនៃការប្រថុយប្រថាន និងការបែងចែកនូវប្រាក់ចំណូល និងផលកំរៃក្នុងសម្បទាន ។
- *ការការពារតិចតួចនូវផលប្រយោជន៍សាធារណៈ* កង្វះនូវច្បាប់ដែលមានតម្លាភាព ដែលអាចប៉ាន់ស្មានបាន និងអាចពង្រឹងបាន ហើយនិងនីតិវិធីរដ្ឋបាល រួមចំណែកអោយមានបរិយាកាសមួយដែលការសំរេចចិត្តនានា អាចត្រូវធ្វើឡើងក្នុងលក្ខណៈកណ្តាល ឬមិនសមស្រប ដោយមិនបានគិតគូរអោយបានត្រឹមត្រូវដល់សេដ្ឋកិច្ច ប្រសិទ្ធិភាព ចិរភាពរយៈពេលវែងរបស់គំរោង ឬផលប្រយោជន៍របស់អ្នកប្រើប្រាស់និងសាធារណជនទូទៅ ។

៣៣. ប្រជាពលរដ្ឋ អ្នកផ្តល់សេវា និងរដ្ឋាភិបាល នឹងទទួលផលចំណេញទាំងអស់គ្នាពីប្រសិទ្ធិភាព និងតម្លាភាព ដែលកើនឡើង ។ ជាមួយលទ្ធភាពងាយស្រួលក្នុងការរកមើលកិច្ចសន្យាសម្បទានដែលបោះពុម្ពផ្សាយប្រជាពលរដ្ឋ នឹងមានលទ្ធភាពកាន់តែប្រសើរ ក្នុងការកំណត់ថាតើភាគីណាមួយដែលមានការទទួលខុសត្រូវចំពោះផ្នែកណាមួយ របស់គំរោង ដូចជាផ្នែករក្សាគុណភាពសេវា កែលំអហេដ្ឋារចនាសម្ព័ន្ធ ប្រមូលថ្លៃឈ្នួលភ្ជាប់ និងផ្តាច់សេវា និងប្រតិបត្តិការប្រចាំថ្ងៃដទៃទៀតគ្រប់បែបយ៉ាង ។ ធ្វើដូចនេះនឹងកែលំអដល់គណនេយ្យភាពរបស់អ្នកផ្តល់សេវាផង និងរដ្ឋាភិបាលផង ក្នុងការឆ្លើយតបនឹងបញ្ហា និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ ។ ក្នុងករណីនៃគំរោងដែល មានបញ្ហាចោទជាច្រើន រដ្ឋាភិបាល និងសម្បទានិ បានត្រឹមតែចោទគ្នាទៅវិញទៅមកតាមរយៈសារព័តិមាន ដោយមិនបានអនុញ្ញាតអោយប្រជាពលរដ្ឋជាកំណត់ភាពទទួលខុសត្រូវដោយផ្ទាល់ឡើយ ។

៣៤. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា កំពុងអនុវត្តកម្មវិធីកំណែទំរង់មួយ ដែលនឹងបង្កើតក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់មួយ ដែលជាច្បាប់បង្កលទ្ធភាពមួយដើម្បីលប់ អនុក្រឹត្យ លេខ ៦០ និងកសាងសមត្ថភាពស្ថាប័នដោយមានការឧបត្ថម្ភពីធនាគារពិភពលោក, UNDP និង PPIAF ។ សេចក្តីព្រាងច្បាប់ស្តីអំពីសម្បទាន និងសេចក្តីព្រាងបទដ្ឋានច្បាប់អនុវត្តន៏នានា ត្រូវតែធ្វើ ឱ្យឆាប់រួចរាល់និងអនុម័តជាបន្ទាន់ ។

## ខ ~ ការអភិវឌ្ឍន៍ក្រុម និងស្តង់ដារបទដ្ឋាន

៣៥. ការកែលំអអភិបាលកិច្ច មិនអាចផ្អែកលើសកម្មភាពសាធារណៈមួយមុខទេ ។ យុទ្ធសាស្ត្រណាមួយ ដើម្បីប្រយុទ្ធនឹងអំពើពុករលួយ កសាងស្ថាប័នអោយបានល្អប្រសើរឡើង ការផ្តើមអោយមានតម្លាភាព ក្នុងកិច្ចសន្យាសាធារណៈ ក៏ត្រូវតែផ្អែកលើការខិតខំប្រឹងប្រែងនានាដើម្បីពង្រឹងក្រមសីលធម៌ និងបទដ្ឋាន នៃអភិបាលកិច្ច ដែលត្រូវបានអភិវឌ្ឍ និងពង្រឹងដោយផ្អែកឯកជនខ្លួនឯងផ្ទាល់ដែរ ។ វប្បធម៌នៃការសំរប សំរួលនៅក្នុងផ្នែកសាធារណៈ ត្រូវតែមានការលើកទឹកចិត្តដោយវប្បធម៌នៃការគោរពចំពោះ"វិធាន"ស្រប ច្បាប់ និងបទបញ្ញត្តិនានាដែលការពារ ដល់ផលប្រយោជន៏សាធារណៈនៅពេលដែលវិធានទាំង នោះត្រូវ បានអនុវត្តដោយយុត្តិធម៌។ សំរាប់អ្នកវិនិយោគបរទេសជាច្រើន ការបង់ប្រាក់សំណូកក្នុងប្រទេសក្រៅ ជា បទល្មើសដែលត្រូវដាក់ទោស ។[៤]

៣៦. ទំរង់នានានៃអភិបាលកិច្ចដែលផ្អែកឯកជនអាចដឹកនាំបាន រួមមានអភិបាលកិច្ចសាជីវកម្ម ក្រម សីលធម៌ និងករណីជំរើសនៃការដាក់បញ្ញត្តិខ្លួនឯង និងការប្រើប្រាស់ខ្សែចង្វាក់ផ្គត់ផ្គង់ ដើម្បីលើកកំពស់ ដំណើរការល្អនៃ អាកប្បកិរិយាសាជីវកម្ម ។ អភិបាលកិច្ចសាជីវកម្មនៅប្រទេសកម្ពុជា គឺស្ថិតក្នុងដំណាក់ កាលក្មេងខ្ចីនៅឡើយ ជាមួយនឹងការយកចិត្តជាចំបងទៅលើការបង្កើតបទដ្ឋានគណនេយ្យ ដែលជាមូលដ្ឋាន នៃតម្លាភាព ។ ដរាបណាទី ផ្សារហិរញ្ញវត្ថុនៅតែស្ថិតនៅក្នុង ដំណាក់កាលក្មេងខ្ចី តួនាទីរបស់ធនាគារ ក្នុងការដាក់វិន័យទៅលើផ្នែកឯកជន ក៏នឹងនៅមានកំរិតដែរ ។ ប៉ុន្តែទោះជា យ៉ាងណាក្តី ការអភិវឌ្ឍក្រម សីលធម៌ស៊ីវិល និងពាណិជ្ជកម្មមួយ នឹងធ្វើអោយមានស្ថេរភាពដល់បញ្ហាគន្លឹះខ្លះៗ ដូចជារចនាសម្ព័ន្ធ សាជីវកម្ម តួនាទីរបស់ក្រុមប្រឹក្សានាយក និងកិច្ចការសាជីវកម្មសំខាន់ៗ ។ ម្ចាស់ភាគហ៊ុន និងបញ្ញត្តិករនៃ

ទីផ្សារ នឹងស្ថិតក្នុងជំហរមួយក្នុងការអនុវត្តន៍បទដ្ឋាននៃសីលធម៌ ដែលជាមុខងារមួយនៃតួនាទីរបស់ខ្លួនក្នុងនាមជាអ្នកមានភាគហ៊ុនរបស់សហគ្រាស ។

៣៧. ការស្វ័យបញ្ញត្តិ ជាការមានន័យ នៅពេលដែលប្រយោជន៍សមូហភាពនៃរបរផ្នែកឯកជនមួយ ត្រូវបានតំរង់ទិសបានគ្រប់គ្រាន់អោយស្របជាមួយនឹងផលប្រយោជន៍សាធារណៈ គឺកំលាំងអនុវត្តន៍នៃអ្នកមានរបរដូចគ្នា ធ្វើអោយការអនុវត្តន៍ច្បាប់របស់ផ្នែកសាធារណៈមិនជាការចាំបាច់ ។ ការអភិវឌ្ឍន៍បទដ្ឋានក្នុងឧស្សាហកម្មភាគច្រើន គឺជាតួនាទីដំបូងរបស់ផ្នែកឯកជន ។ ការអនុវត្តន៍ច្បាប់របស់ផ្នែកសាធារណៈមិនចាំបាច់ទេ ពីព្រោះការធ្វើបទដ្ឋានកម្មនៃផ្នែកនានាក្នុងឧស្សាហកម្មមួយ គឺបំរើអោយប្រយោជន៍របស់ផ្នែកឯកជន : វាកែលំអប្រសិទ្ធិភាព កាត់បន្ថយចំណាយ កែលំអលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការសហការគ្នា និងបន្ថយនូវឧបសគ្គចំពោះការចូលហ៊ុន ។ នៅដំណាក់កាលនេះក្នុងការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា វាទំនងថាឧស្សាហកម្មកាត់ដេរ វិស័យកសិកម្មស្រូវ និង វិស័យសំណង់ខ្លះ គឺជាវិស័យតែមួយគត់ដែលបានជឿនលឿនគួរអោយកត់សំគាល់ក្នុងការអភិវឌ្ឍន៍ក្រមសីលធម៌ និងបទដ្ឋាន ដោយសារវិស័យទាំងនេះបានប្រលូកក្នុងពាណិជ្ជកម្មអន្តរជាតិ ។ វាមានវិសាលភាពធំទូលាយសំរាប់ការសហការអន្តរជាតិជាសក្តានុពលបន្ថែមទៀត ក្នុងការបង្កើតបទដ្ឋាន ។ ក្នុងវិស័យសំណង់ អង្គការបទដ្ឋានដូចជា ISO និងវិទ្យាស្ថានបទដ្ឋានរបស់ចក្រភពអង់គ្លេស សន្និសីទអន្តរជាតិរបស់មន្ត្រីសំណង់ ក្រុមប្រឹក្សាក្រមសីលធម៌ អន្តរជាតិ និងគណៈកម្មាធិការបទដ្ឋានក្រមសីលធម៌សំណង់អូស្ត្រាលី អាចជួយជ្រោមជ្រែងក្នុងការអភិវឌ្ឍន៍ក្រមសីលធម៌នៅប្រទេសកម្ពុជាដែលមានលក្ខណៈស្របនឹងអន្តរជាតិ ។ ការខិតខំប្រឹងប្រែងដូចគ្នានេះ អាចត្រូវធ្វើឡើង ក្នុងឧស្សាហកម្មរត់ការគយផងដែរ ។

៣៨. ក្រៅពីម្ចាស់កម្មសិទ្ធិដែលជាអ្នកមានភាគហ៊ុននោះ អ្នកទិញ និងអ្នកលក់ដែលជាដៃគូក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ អាចទទូចទាមទារអោយមានការប្រកាន់ខ្ជាប់នូវក្រមសីលធម៌ជាល័ក្ខខ័ណ្ឌមួយនៃការធ្វើអាជីវកម្ម ។ ចលនាទាមទារ អោយសាជីវកម្មទទួលខុសត្រូវចំពោះសង្គម បានបង្ហាញអោយឃើញថាពាណិជ្ជកម្មអាចត្រូវបានប្រើប្រាស់ ដើម្បីធានាអោយមានការគោរពតាមបទដ្ឋានពលកម្មស្នូល និងបរិដ្ឋានក្នុងចំណោមគោលដៅសាធារណៈសំខាន់ៗ ដទៃទៀត ។ ខ្សែចង្វាក់ផ្គត់ផ្គង់ មានប្រសិទ្ធិភាពក្នុងការពង្រឹងអភិបាលកិច្ចសាជីវកម្ម ដោយសារឥទ្ធិពលនៃ បណ្តាញ និងលទ្ធភាពផ្តល់មតិត្រឡប់ជាប្រចាំរបស់វា ។

## ច ~ ពីការត្រួតត្រាទៅជាការសំរបសំរួល : ធាតុសំខាន់ៗនៃកំណែទំរង់

៣៩. ជោគជ័យនៃអន្តរកាលនេះ អាស្រ័យជាខ្លាំងលើធាតុគន្លឹះបី : ភាពជឿទុកចិត្តបាន តម្លាភាព និង គណនេយ្យភាព ។ កំណែទំរង់ជាក់លាក់នានាដូចបានលើកឡើងខាងលើ ដូចជាការសំរួលបទបញ្ញត្តិ ការកសាង ស្ថាប័នទីផ្សារ និងការណែនាំអោយមានការប្រកួតប្រជែងនៅក្នុងកិច្ចសន្យាសាធារណៈ-ឯកជន សុទ្ធតែមានសារៈ សំខាន់ដើម្បីកាត់បន្ថយឱកាសប្រព្រឹត្តិអំពើពុករលួយ និងបង្កើតបាននូវបរិយាកាសអាជីវកម្មមួយដែលមានប្រសិទ្ធិភាពជាងមុន ។ ប៉ុន្តែ គ្មានកំណែទំរង់ណាអាចធ្វើទៅបានដោយគ្រាន់តែធ្វើមួយឃ្មៀកដូច"គូសប៊ិច" ហើយរំពឹងអោយមានឥទ្ធិពលនោះឡើយ ។

៤០. ភាពអាចជឿទុកចិត្តបាន ជាកត្តាចាំបាច់សំរាប់អ្នកមានចំណែកទាំងអស់ចាប់ផ្តើមបោះបង់ចោលនូវគំរោងបណ្តាក់ទុនរយៈពេលខ្លី ហើយចាប់ផ្តើមវិនិយោគលើភាពប្រកួតប្រជែងរយៈពេលវែង ។ តាមរយៈ យុទ្ធសាស្ត្រចតុកោណ យុទ្ធសាស្ត្រកំណែទំរង់វិស័យសាធារណៈ និងអង្គការពាណិជ្ជកម្មពិភពលោក រដ្ឋាភិបាលបានបង្កើតឡើង នូវទស្សនៈវិស័យច្បាស់លាស់មួយ ។[៥] ប៉ុន្តែ ដើម្បីអោយទស្សនៈវិស័យនេះ អាចជឿទុកចិត្តបាន វាជាការសំខាន់ ចាំបាច់ដែលត្រូវបង្កើតនូវប្រវត្តិស្នាដៃនៃការអនុវត្តន៍ដោយជោគជ័យ ដែលអាចអោយអ្នកមានចំណែកទាំងអស់ មើលឃើញ ដោយទាមទារអោយមានវិធីសាស្ត្រនានាដែលពិចារណាលើការលើកទឹកចិត្តអោយប្រកាន់ខ្ជាប់ ចំពោះកំណែទំរង់ ទាំងក្នុងផ្នែកសាធារណៈ ទាំងផ្នែកឯកជន ។ នេះរួមបញ្ចូលនូវគោលនយោបាយដែលផ្តល់រង្វាន់ចំពោះ ការគោរពតាម និងដាក់ទោសចំពោះការមិនគោរពតាម ក៏ដូចជាវិធាន សសើរលើកទឹកចិត្តសំរាប់បុគ្គលិកផ្នែកសាធារណៈ ដែលផ្តល់ប្រាក់បៀវត្សរ៍អាចអោយរស់បាន ជាថ្នូរនឹងការអនុវត្តន៍គោលនយោបាយបានជោគជ័យ ។

៤១. តម្លាភាព កាត់បន្ថយឱកាស និងអារម្មណ៍គិតពីអំពើពុករលួយ ។ នៅប្រទេសកម្ពុជា គំរោងជាច្រើនដែលត្រូវបានចរចាតាមរយៈសម្បទានលាក់បាំងគ្មានតម្លាភាព ដែលជាប្រធានបទនៃការចោទប្រកាន់គ្នាញឹកញាប់អំពីអំពើពុករលួយ ហើយជារឿយៗក៏ជាប្រធានបទនៃការអំពាវនាវអោយមានការចរចាឡើងវិញអំពីពន្ធអាករដែលអ្នកប្រើប្រាស់ត្រូវបង់ផងដែរ ។ ទំលាប់នៃការបោះពុម្ពផ្សាយ អាចកាត់បន្ថយការមន្ទិលសង្ស័យដែលពេលខ្លះកើត ឡើងជុំវិញការផ្តល់កិច្ចសន្យា ។ ទំលាប់នេះនឹងមានតំលៃយ៉ាងខ្លាំងនៅពេលដែលគំរោងមិនមានការស្នើសុំ និង/ឬ កិច្ចសន្យាត្រូវបានចរចាដោយផ្ទាល់ ។ ដោយយល់ឃើញដូច្នេះ

រដ្ឋាភិបាលប្រទេសម៉ិកស៊ិក ពេលថ្មីៗនេះ បានឆ្លងច្បាប់ស្តីពីតម្លាភាព និងលទ្ធភាពទទួលព័ត៌មានអំពីរដ្ឋាភិបាលសាធារណៈ ដែលធ្វើអោយកិច្ចសន្យារបស់រដ្ឋាភិបាល អាចប្រគល់ដល់ប្រជាពលរដ្ឋដែលស្នើសុំបាននៅក្នុងរយៈពេល ២០ ថ្ងៃ ។ ច្បាប់ថ្មីនេះរបស់ប្រទេសម៉ិកស៊ិក ក៏មានចែងដែរថា ទីភ្នាក់ងាររបស់រដ្ឋសហព័ន្ធ ត្រូវបានចេញផ្សាយកិច្ចសន្យាលើវិបសៃត៍របស់រដ្ឋាភិបាលត្រឹមពាក់ កណ្តាលឆ្នាំ ២០០៣ ។ ទោះបីជាច្បាប់តម្លាភាព ដូចច្បាប់របស់ប្រទេសម៉ិកស៊ិកនេះ នឹងមិនបង្ការអំពើពុករលួយ ទាំងអស់ក្តី ក៏ទាំងមន្ត្រីរដ្ឋាភិបាល ទាំងបុគ្គលិកក្រុមហ៊ុន នឹងមិនសូវចូលខ្លួនពាក់ព័ន្ធនឹងអាកប្បកិរិយាអសីលធម៌ ក្នុងកំឡុងដំណាក់កាលប្រគល់កិច្ចសន្យាដែរ បើសិនជាពួកគេដឹងថា កិច្ចសន្យារបស់ពួកគេទីបំផុតនឹងត្រូវផ្សាយជាសាធារណៈនោះ ។

៤២. ម្ចាស់ជំនួយ ដែលផ្តល់ថវិកាដល់គំរោងហេដ្ឋារចនាសម្ព័ន្ធ និងគំរោងអភិវឌ្ឍន៍វិស័យឯកជន (PSD) ដទៃទៀត អាចទទូចទាមទារអោយមានតម្លាភាព និងការប្រកួតប្រជែងក្នុងគ្រប់វិស័យទាំងឡាយណាដែលប្រើប្រាស់ថវិការបស់ពួកគេ ព្រោះថវិការបស់ម្ចាស់ជំនួយជាការរួមមួយចំណែកសំរាប់ការគ្មានប្រសិទ្ធិភាព។ ការបោះពុម្ពផ្សាយអំពីកិច្ចសន្យា អាចសំរបសំរួល ដល់ការវិវត្តន៍នៃបទដ្ឋានក្នុងកិច្ចការខាងហេដ្ឋារចនា-សម្ព័ន្ធ ។ រដ្ឋាភិបាលនានា ច្បាស់ជាអាចបានផលប្រយោជន៍ពី លទ្ធភាពដឹងឮ និងរកបាននូវកិច្ចសន្យាឯកជនភាវូបនីយកម្ម ពីទីក្រុង ទីភ្នាក់ងារ និងប្រទេសដទៃ ។ ភាពដែលអាចរកបានកាន់តែច្រើននៃកិច្ចសន្យានឹងធ្វើអោយមានភាពកាន់តែងាយស្រួល សំរាប់អ្នកប្រើប្រាស់ក្នុងការកំណត់ថ្លៃពន្ធអាករ និងកាតព្វកិច្ចបង់សេវាដទៃទៀត ជាមួយប្រព័ន្ធប្រហាក់ប្រហែលគ្នា នៅក្នុងដែនសមត្ថកិច្ចផ្សេងៗទៀត ។

៤៣. ទីបំផុត គឺប្រជាពលរដ្ឋ និងអាជីវកម្មទាំងឡាយ ដែលត្រូវតែទាមទារអោយមានការបំពេញការងារ ពីសំណាក់រដ្ឋាភិបាល ក្នុងនាមខ្លួនជាអ្នកបោះឆ្នោត និងអ្នកបង់ពន្ធ ។ រដ្ឋាភិបាលទាំងឡាយដែលបំពេញការងារតាមការប្តេជ្ញារបស់ខ្លួន ដើម្បីសំរេចបាននូវកំណើន និងអនុវត្តន៍ដោយជោគជ័យនូវកំណែទំរង់នានាគួរត្រូវបានផ្តល់រង្វាន់តាមរយៈការផ្តល់អណត្តិរបស់ប្រជាពលរដ្ឋ និងដោយការផ្តល់ការទុកចិត្តជាមួយចំណូលពន្ធរបស់ពួកគេ ។ ប៉ុន្តែ រង្វង់ប្រជាធិបតេយ្យជាទូទៅ មានលក្ខណៈទូលំទូលាយពេក និងមិនសូវបានផ្តោតគោលដៅអោយចំបញ្ហាជាក់លាក់ទេ ។ ប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ ត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាពក្នុងប្រទេសឥណ្ឌា និងប្រទេសដទៃទៀតក្នុងការត្រួតពិនិត្យមើលកំណែទំរង់ស្ថាប័ន និង

គោលនយោបាយជាក់លាក់ណាមួយ ហើយអាចដើរតួនាទីមួយនៅក្នុងប្រទេសកម្ពុជា ។ ប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ អាចប្រើប្រាស់ដើម្បីធានាថា សេវាសាធារណៈ នានាត្រូវបានគេផ្តល់ ។ ដើម្បីធានាអោយមានការបំពេញការងារក្នុងវិស័យទាក់ទងនឹងការអភិវឌ្ឍន៏ផ្នែកឯកជន ប្រការនេះអាស្រ័យយ៉ាងសំខាន់ទៅលើការកំណត់នូវកត្តាចង្អុលបង្ហាញអំពីការបំពេញការងាររបស់រដ្ឋាភិបាល ដែលច្បាស់លាស់ និងអាចត្រួតពិនិត្យបាន សំរាប់ការប្រែប្រួលខាងស្ថាប័ន ឬបទបញ្ញត្តិនីមួយៗ ។ កត្តាទាំងនេះភាគច្រើន ត្រូវបានកំណត់នៅក្នុងគំរោងរបស់រដ្ឋាភិបាល និងក្នុងឯកសាររបស់ម្ចាស់ជំនួយ ប៉ុន្តែចាំបាច់ត្រូវប្រែក្លាយវាទៅជាការប្រើប្រាស់កាន់តែមានប្រសិទ្ធិភាពដោយប្រជាពលរដ្ឋ និងសមាគមអាជីវកម្ម ។ ជាការសំខាន់ដែលប្រជាពលរដ្ឋយល់អំពីកត្តាចង្អុលបង្ហាញទាំងនេះ រួមទាំងអ្នកមានចំណែកដទៃទៀត ជាពិសេសក្នុងប្រព័ន្ធឃោសនា ដែលត្រូវ ផ្សព្វផ្សាយវាជាសាធារណៈ ។

## សេចក្តីសន្និដ្ឋាន

៤៤. ដោយទទួលស្គាល់នូវកត្តាទាំងនេះខ្លះៗ រដ្ឋាភិបាលបានធ្វើការចាប់ផ្តើម និងបានរៀបចំផែនការសកម្មភាព មួយដែលនឹងសំដៅកាត់បន្ថយតំលៃនៃការបើកអាជីវកម្មនៅក្នុងប្រទេសកម្ពុជា និងកែលំអអភិបាលកិច្ចសាជីវកម្ម ។ ក្រោមផែនការនេះ រដ្ឋាភិបាលមានបំណងមួយក្នុងចំណោមបំណងដទៃទៀតដើម្បីបង្កើតនូវប្រព័ន្ធវាស់ស្ទង់តម្លាភាព ការងារមួយដែលនឹងត្រូវត្រួតពិនិត្យដោយផ្នែកឯកជន និងផ្នែកដទៃទៀត ។ ប្រព័ន្ធនេះក៏នឹងបង្កើនប្រសិទ្ធិភាព និង ត្រួតពិនិត្យលើដំណើរការសំរបសំរួលពាណិជ្ជកម្ម ដែលរួមបញ្ចូលទាំងការចេញលិខិតអនុញ្ញាតការចុះឯកសារ និង ការអនុម័តជាន់លើគ្នា និងមិនចាំបាច់ ដែលនាំទៅរកឯកសាររដ្ឋបាលទោលតែមួយ ។ ច្រកទោលស្វ័យប្រវត្តិមួយ សំរាប់ការសំរបសំរួលពាណិជ្ជកម្មនៅកំពង់ផែក្រុងព្រះសីហនុ នឹងត្រូវតំឡើង ។ រដ្ឋាភិបាលក៏នឹងដាក់ចេញនូវ យុទ្ធសាស្ត្រគ្រប់គ្រងភាពប្រថុយប្រថានជារួមមួយដើម្បីពង្រួញ និងធ្វើអោយមានលក្ខណៈសមហេតុផលនូវតំរូវការ អធិការកិច្ចទាំងអស់របស់ទីភ្នាក់ងារត្រួតពិនិត្យផ្សេងៗគ្នា ធ្វើអោយថ្លៃឈ្នួល និងតំលៃមានលក្ខណៈសមហេតុផល បង្កើនប្រសិទ្ធិភាព និងធ្វើអោយការចុះបញ្ជី ការចេញលិខិតអនុញ្ញាត និងការយកពន្ធពីក្រុមហ៊ុន មានលក្ខណៈសមហេតុផល ។ ចំណែកផ្នែកឯកជនវិញ នឹងត្រូវបានលើកទឹកចិត្តអោយអនុម័តក្រមសីលធម៌ និងកែលំអ

អភិបាល កិច្ចសាជីវកម្ម ។ ផ្នែកឯកជននឹងចូលរួមជាមួយរដ្ឋាភិបាលក្នុងការត្រួតពិនិត្យតាមដានភាពជឿនលឿនលើកំណែ ទំរង់ដែលបានស្នើឡើង ។

៤៥. មានការអភិវឌ្ឍន៍គួរអោយស្វាគមន៍ជាច្រើន ។ ឥឡូវនេះ ដំណើរការកំណែទំរង់ដែលស្វាហាប់ និងមានថាមភាពមួយ នឹងចាំបាច់ត្រូវរៀបចំឡើងយ៉ាងឆាប់រហ័ស ដែលអាចបង្ហាញលទ្ធផលក្នុងរយៈវេលាមួយសមហេតុផល ។ នេះជាវិស័យមួយទៀតដែលមានជោគជ័យឆាប់រហ័សជាច្រើនដែល រដ្ឋាភិបាលអាចសំរេចបាន ។ រដ្ឋាភិបាល ចាំបាច់ត្រូវធ្វើចលនាយ៉ាងស្វាហាប់ ដើម្បីអោយជំនឿទុកចិត្តរបស់អ្នកវិនិយោគបានប្រសើរឡើងឆាប់រហ័ស និងផ្តល់ការជំរុញឆ្ពោះទៅរកវិសាលភាពគួរអោយកត់សំគាល់មួយ សំរាប់ការធ្វើពិពិធកម្មចេញពីការពឹងផ្អែកនាពេលបច្ចុប្បន្នដ៏ខ្លាំង និងគួរអោយគ្រោះថ្នាក់លើកូនវិស័យមួយ នោះគឺការនាំចេញសំលៀកបំពាក់ ។ ក្នុងរយៈពេលមធ្យម ដូចបានរៀបរាប់ក្នុង ទស្សនៈរួមនេះ ការរក្សាអោយមានភាពជឿនលឿននឹងអាស្រ័យទៅលើការអភិវឌ្ឍន៍នូវប្រព័ន្ធច្បាប់ និងតុលាការលើកំណែទំរង់នៃសេវាកម្មស៊ីវិល ។ វាក៏នឹងអាស្រ័យលើការអភិវឌ្ឍន៍ផ្នែកលើមូលដ្ឋានកាន់តែ ទូលំទូលាយក្នុងជួរផ្នែកឯកជននូវលទ្ធភាពរបស់ពួកគេក្នុងការចូលរួម និងតំរូវអោយរដ្ឋាភិបាលទទួលខុសត្រូវចំពោះ កំណែទំរង់ខាងបរិយាកាសវិនិយោគ ។ សក្តានុពលសំរាប់កំណើន ដែលនាំអោយមានការបង្កើតការងារធ្វើ និងការកាត់បន្ថយភាពក្រីក្រ គឺមានគួរអោយកត់សំគាល់នៅទីនេះ ។

---

១ សូមមើល *ឆ្ពោះទៅរកយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឯកជនមួយសំរាប់ប្រទេសកម្ពុជា : ការវាយតំលៃបរិយាកាសវិនិយោគ*, ធនាគារពិភពលោក (២០០៤) ។ ទិន្នន័យស្វែងយល់នេះ គឺផ្អែកលើអង្កេតស្តីពីផលិតភាព និងបរិយាកាសវិនិយោគនៅប្រទេសកម្ពុជា ដែលត្រូវបានធ្វើនៅក្នុងខែ កុម្ភៈ រហូតដល់ខែ សីហា ឆ្នាំ ២០០៣

២ អង្គការសមាជិកភាពអាជីវកម្ម ត្រូវកំណត់និយមន័យថាជាអង្គការសមាជិកភាពមិនស្វែងរកផលកំរៃ និងដឹកនាំបែបប្រជាធិបតេយ្យ ដែលទ្រទ្រង់ថវិកាខ្លួនឯងដោយការគួបផ្សំនៃថ្លៃសមាជិកភាព ថ្លៃឈ្នួលសេវា ក៏ដូចជាប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាល ឬអ្នកផ្តល់ជំនួយដែរ ។ គ្មានច្បាប់ណាមួយដែលចែងអំពីការដាក់បញ្ញត្តិលើសមាគមសហគ្រាសជំនួញនៅក្នុងប្រទេសកម្ពុជាទេ ។ ដោយលើកលែងតែអង្គការសមាជិកភាពអាជីវកម្មពីរបី ដូចជាសភាពាណិជ្ជកម្ម ដែលត្រូវបានបង្កើតឡើងដោយច្បាប់ អង្គការសមាជិកភាពអាជីវកម្មភាគច្រើនតាមធម្មតាគ្រាន់តែប្រកាសអំពីអត្ថិភាពរបស់ខ្លួនជាមួយក្រសួងមហាផ្ទៃប៉ុណ្ណោះ ។

៣ ច្បាប់ស្តីពីការវិនិយោគ (LOI ១៩៩៤) បានបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ជាអង្គការសេវា "ចំណុចមួយ" សំរាប់អ្នកវិនិយោគ និងជាអង្គការទទួលខុសត្រូវផ្តាច់មុខសំរាប់ការវាយតំលៃ និងធ្វើសេចក្តីសំរេចលើគំរោងវិនិយោគទាំងអស់ ទាំងគំរោងស្តារ ទាំងគំរោងថ្មី ។ ទោះជាយ៉ាងណាក្តី កិច្ចសន្យាជាច្រើន រួមទាំងផ្លូវជាតិលេខ ៤ ចំណតប្រេង និងផែស្ងួត និងសម្បទាន

ព្រលានយន្តហោះផង ត្រូវបានចរចាដោយផ្ទាល់ជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ។ ដូចគ្នានេះដែរ កិច្ចព្រមព្រៀងទិញភ្លើងអគ្គិសនីជាមួយអ្នកផលិតភ្លើងអគ្គិសនីឯករាជ្យនៅភ្នំពេញ និងគំរោងអគ្គិសនីនៅខេត្តបាត់ដំបង និងសៀមរាប ត្រូវបានចរចាជាមួយក្រសួងរ៉ែ និងថាមពល និងទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមវត្តមានរបស់អគ្គិសនីសកម្ពុជា (EdC) ។

[៤] ការទទួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះការបង់ប្រាក់សំណូក គឺជាការនិន្នាការកើនឡើងមួយក្នុងបណ្តាប្រទេសជាសមាជិក អង្គការ OECD ដែលគាំពារដោយក្រម និងច្បាប់នានា ដូចជាច្បាប់ប្រឆាំងនឹងការអនុវត្តន៍អំពើពុករលួយនៅបរទេសរបស់សហរដ្ឋអាមេរិកជាដើម ។

[៥] ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ *ទស្សនៈវិស័យនៃកំណើន និងអភិបាលកិច្ច* និងឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម *ការប្រែក្លាយការចូល WTO ទៅជាការកាត់បន្ថយភាពក្រីក្រ* ។ សុន្ទរកថាថ្លែងនៅឯសិក្ខាសាលាស្តីពីរដ្ឋាភិបាល-ធនាគារ ដែលបង្ហាញអំពី "ការចាប់យកឱកាសពិភពលោក : ការវាយតំលៃបរិយាកាសវិនិយោគ" ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៤ ។

# ជំពូកទី ៦

## ការលើកកំពស់ប្រសិទ្ធិភាពជំនួយ

១. មានការមួយចំនួនដែលអ្នកផ្តល់ជំនួយនិងរដ្ឋាភិបាលអាចធ្វើខុសពីមុនដើម្បីកែលំអប្រសិទ្ធិភាពជំនួយនៅកម្ពុជា ។ ក្នុងកំឡុងទសវត្សកន្លងទៅ ការគ្រប់គ្រងជំនួយដ៏ខ្សោយ មិនត្រឹមតែបាននាំមកនូវភាពគ្មានប្រសិទ្ធិភាពខាងបច្ចេកទេសប៉ុណ្ណោះទេ ថែមទាំងនាំអោយមានបញ្ហាអភិបាលកិច្ចមួយចំនែក ដែលកំពុងប្រឈមមុខរបស់រដ្ឋ ។ បទពិសោធស្រដៀងគ្នានេះពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍បាននាំអោយមាន សេចក្តីអំពាវនាវជាសកល អោយមានសុខុដុមនីយកម្ម (harmonisation) ដូចជាការសហការអោយបានកាន់តែប្រសើរឡើងរវាងអ្នកផ្តល់ជំនួយតាមរយៈប្រពន្ធ័គ្រប់គ្រងរួម រឺក៏កម្មវិធីរួមគ្នា ហើយនិងការ តំរែតំរឹមអោយស្របគ្នា (alignment) ដែលជាការដែលអ្នកផ្តល់ជំនួយរៀបចំរចនា សម្ព័ន្ធជំនួយ របស់ខ្លួនអោយស្របតាមក្របខ័ណ្ឌ គោលនយោបាយរបស់រដ្ឋាភិបាល ហើយនៅពេលដែលមានលក្ខណៈគ្រប់គ្រាន់ចាត់ចែងការផ្តល់ជំនួយតាមរយៈប្រពន្ធ័រដ្ឋាភិបាលតែម្តង ។ អ្នកផ្តល់ជំនួយ បានស្ថិតនៅលើកំរិត មួយ ប្តេជ្ញាអោយមានសុខដុមនីយកម្ម និង ការរៀបចំអោយស្របគ្នា នៅថ្នាក់អន្តរជាតិ នៅសម័យប្រជុំ សហប្រជាជាតិ សន្និសីទទីក្រុងម៉ុងតឺរ៉េ (Monterrey) និង កិច្ចព្រមព្រៀងទីក្រុងរ៉ូម ។ ឥឡូវនេះ ពួកគេត្រូវធ្វើអោយការសន្យាទាំងនោះទៅជាការអនុវត្តន៏ជាក់ស្តែងនៅតាមប្រទេស ។

២. មានការរីកចំរើនគួរកត់សំគាល់លើការកែទំរង់ជំនួយក្នុងរយៈពេលកន្លងទៅនេះ ដោយមានការបញ្ចូលនូវដំណើរការរួមមួយ ប្រមូលពីបណ្តាញផ្សេងៗមកក្នុងផែនការសកម្មភាពការបញ្ជៀគ្នានិងការតំរង់តាមគ្នា ។ មានអ្នកផ្តល់ជំនួយមួយចំនួន បានធ្វើការរួមគ្នាលើដំណើរការយុទ្ធសាស្ត្រតាមផ្នែក រឺ យុទ្ធសាស្ត្រប្រចាំប្រទេស ដើម្បីកាត់បន្ថយការចំណាយរបស់រដ្ឋាភិបាល ។ រដ្ឋាភិបាលបានដឹកនាំការអំពាវនាវអោយស្ថាប័នសំរបសំរួលដែលមានស្រាប់ កែតម្រូវអោយមានទំរង់បទដ្ឋានទៅជាក្រុមការងារបច្ចេកទេស (TWG) ហើយឈានទៅបង្កើតក្រុមការងារនេះនៅលើវិស័យណាមួយដែលពុំដែលមាននាពេលកន្លងមក ។ ផ្នែកចុងក្រោយបំផុតដែលត្រូវប្រកាស គឺក្រុមការងារបច្ចេកទេសដើម្បីទ្រទ្រង់ការធ្វើផែនការ ជួយដល់អ្នកក្រ (Pro-poor planning) ដោយមានការផ្សារភ្ជាប់អោយបានរឹងមាំជាមួយការចាត់ចែងថវិការ ។ ក្រុមនេះនឹងផ្តោតការងារនាឆ្នាំទីមួយរបស់ខ្លួនលើការសំរបសំរួលការគាំទ្ររបស់អ្នកផ្តល់ជំនួយ ក្រោមការដឹកនាំ

របស់រដ្ឋាភិបាល ឆ្ពោះទៅការបង្កើតផែនការយុទ្ធសាស្ត្រប្រាំឆ្នាំ ២០០៦-២០១០សំរាប់ការអភិវឌ្ឍ និង ការកាត់បន្ថយភាពក្រីក្រ និង កម្មវិធី ។

៣. ទាំងរដ្ឋាភិបាល ទាំងអ្នកផ្តល់ជំនួយចាំបាច់ត្រូវរក្សាការរីកចំរើនដែលទទួលបានកន្លងមក ។ មាន តម្រូវការមួយទៀត ដែលរដ្ឋាភិបាលត្រូវរៀបចំ ហើយអ្នកផ្តល់ជំនួយជួយគាំទ្រ គឺ គោលការណ៍រួមសំរាប់ ការប្រើប្រាស់ជាយុទ្ធសាស្ត្រនូវជំនួយបច្ចេកទេស ។ ប្រព័ន្ធប្រាក់ឧបត្ថម្ភបន្ថែមដែលមាន ត្រូវតែធ្វើអោយ សមស្រប ហើយឈប់បន្តទៅទៀត ។ ក្រុមការងារបច្ចេកទេសត្រូវតែបានទទួលការគាំទ្រ ហើយពង្រឹង ។ ជាចុង ក្រោយអ្នកផ្តល់ជំនួយចាំបាច់ត្រូវចូលរួមក្នុងការតស៊ូមតិជាក្រុម ជាមួយរដ្ឋាភិបាល ទៅលើអភិវឌ្ឍន៍ ជាអាទិភាព ហើយនិងជំនួយពីខាងក្រៅដែលជួយដល់ចំនុចអាទិភាពទាំងនោះ ។

៤. នៅពេលដែលអ្នកផ្តល់ជំនួយអាចធ្វើបានច្រើនដើម្បីកាត់បន្ថយការចំណាយក្នុងពេលផ្តល់ជំនួយ (តាមរយៈប្រព័ន្ធសុខុដុមនីយកម្ម ការបង្កើតដៃគូ និង ការកាត់បន្ថយចំនួនបេសកកម្ម និង របាយការណ៍) ការធ្វើ អោយជំនួយមានតំលៃជាអតិបរមា តម្រូវអោយមានភាពជាអ្នកដឹកនាំរបស់រដ្ឋាភិបាល លើបញ្ហា គោលនយោបាយជាគន្លឹះ និង ការកែទំរង់អភិបាលកិច្ច ។ អ្នកផ្តល់ជំនួយជាច្រើន បានសង្កត់ធ្ងន់ទៅលើ ការរីកចំរើនខាងអភិបាលកិច្ច ដែលជាលក្ខណៈវិនិច្ឆ័យសំខាន់ៗ ក្នុងការផ្តល់ជំនួយដល់កម្ពុជា ។ ហើយ អ្នកផ្តល់ជំនួយខ្លះបានកាត់បន្ថយជំនួយដោយមានការចុះខ្សោយខាងអភិបាលកិច្ច ។ ការអនុវត្តរបៀបវារៈ អភិបាលកិច្ចដែលបានចែងក្នុងយុទ្ធសាស្ត្រចតុកោណ អាចនាំអោយមានការកើនឡើងនូវជំនួយក្នុងប៉ុន្មាន ឆ្នាំទៅមុខនេះ ។

# ជំពូក ៦: លើកកំពស់ប្រសិទ្ធិភាពជំនួយ

៥. នៅក្នុងសហគមន៍អភិវឌ្ឍន៍ មានការទទួលស្គាល់កាន់តែច្រើនឡើងថា ការគ្រប់គ្រងជំនួយនៅក្នុងប្រទេស កំពុងអភិវឌ្ឍន៍ ត្រូវតែធ្វើឡើងដោយមានប្រសិទ្ធិភាព ដើម្បីចៀសវាង ការរារាំងដល់កិច្ចអភិវឌ្ឍន៍របស់ស្ថាប័ន រដ្ឋាភិបាល និង ការបន្ថយបង្អាក់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ តំរូវការអោយអ្នកផ្តល់ជំនួយ មានការទទួលខុសត្រូវខ្ពស់ គឺ ជាតំរូវការបន្ទាន់បំផុតនៅក្នុងប្រទេសដែលទើបតែងើបចេញពីសង្គ្រាម ក្នុងនោះស្ថាប័នរដ្ឋ ទីផ្សារ និង សង្គមស៊ីវិលភាគច្រើន នៅមានលក្ខណៈទន់ខ្សោយ ឬមិនទាន់មានសមត្ថភាពបំរើអោយផលប្រយោជន៍រួមរយៈពេលវែងបាន (សូមមើលប្រអប់ ៦.១) ។ កង្វះការគ្រប់គ្រងល្អលើការផ្តល់ជំនួយ ក្នុងកាលៈទេសៈទាំងនេះ អាចធ្វើឱ្យរាំងស្ទះ ច្រើនជាងជំរុញការអភិវឌ្ឍផ្នែកសំខាន់ៗ ទាំងនោះ ដែលបើគ្មានវាទេ កិច្ចអភិវឌ្ឍន៍រយៈពេលវែង នឹងមិនអាចសំរេចបានឡើយ ពោលគឺ ចក្ខុវិស័យនិងការប្តេជ្ញាចិត្តខាងនយោបាយ ស្ថាប័នរដ្ឋដែលមាន តម្លាភាព ការទទួលខុសត្រូវ និង សមត្ថភាពក្នុងការផ្តល់សេវាសេដ្ឋកិច្ចនិងសង្គមកិច្ច ដែលជួយប្រជាពលរដ្ឋក្រីក្រ និង អភិបាលកិច្ច សេដ្ឋកិច្ចដែលជំរុញអោយ

**ប្រអប់ ៦.១ កត្តាអសកម្មទាំងប្រាំពីរនៅក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍**

តាមលទ្ធិសាសនាគ្រីស្ត មានអំពើបាបប្រាំពីរយ៉ាង ដែលមានលក្ខណៈដ៏ធ្ងន់ធ្ងរ ឬ "មានគ្រោះថ្នាក់ដល់ជីវិត" ។ ណាន់ស៊ី បឺដសូល (Nancy Birdsall) ធ្វើការនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ពិភពលោក បានយកគោលគំនិតទាក់ទងនឹងការបែងចែកកំហុសឆ្គងរបស់មនុស្សមកប្រើប្រាស់ ដើម្បីកំណត់និងធ្វើគំរោងពិភាក្សាលើកំហុសដូចគ្នាដែលប្រព្រឹត្តិឡើងដោយម្ចាស់ជំនួយ នៅក្នុងការរៀបចំនិងការគ្រប់គ្រងកម្មវិធីជំនួយ ។

១. ការគ្មានភាពអត់ធ្មត់ (ជាមួយនឹងការកសាងស្ថាប័ន)
២. មោទនៈភាព (មិនមាន នៅពេលដែលជំនួយមិនដំណើរការ)
៣. ភាពល្ងង់ខ្លៅ (មិនបានវាយតម្លៃ)
៤. ភាពខ្ជិលច្រអូស (ធ្វើពុតចូលរួមដូចជាម្ចាស់)
៥. ច្រណែន (មិនបានសហការ)
៦. លោភៈ (កំណាញ់ស្វិត និង ការធ្វើហិរញ្ញប្បទានដែលមិនអាចទុកចិត្តបាន)
៧. ភាពចោលម្សៀត (ផ្តល់មូលនិធិមិនគ្រប់គ្រាន់សំរាប់ទំនិញសាធារណៈនៅក្នុងពិភពលោកនិងតំបន់)

កំហុសឆ្គងទាំងនេះ កើតមានឡើងជាទូទៅ និង មានលក្ខណៈធ្ងន់ធ្ងរណាស់ នៅក្នុងប្រទេសក្រីក្របំផុត និង ប្រទេសទើបតែងើបចេញពីភ្នក់ភ្លើងសង្គ្រាម ដែលស្ថាប័នផ្លូវការនៅទន់ខ្សោយនៅឡើយ ពតិមានពុំសូវមាន សំពាធជំរុញឱ្យមានលទ្ធផលលឿនរហ័សគឺមានខ្លាំងក្លា ហើយរដ្ឋាភិបាលដែលពឹងផ្អែកតែលើជំនួយ ខ្វះលទ្ធភាព ឬ ទំនុកចិត្ត ក្នុងការអប់រំម្ចាស់ជំនួយ ។

*ប្រភព: Birdsal ឆ្នាំ ២០០៤*

មានកំណើនសេដ្ឋកិច្ច ដែលមូលដ្ឋានធំទូលាយ មាននិរន្តរភាព និង ជួយកាត់បន្ថយភាពក្រីក្រ ។

៦.	ការពិភាក្សាវែកញែកទាំងនេះ មាន លក្ខណៈសមស្របណាស់ចំពោះកម្ពុជា ។ គេ សង្កេតឃើញថា ម្ចាស់ជំនួយមានលទ្ធភាពច្រើន និង មានកិច្ចការជាច្រើនដែលត្រូវធ្វើ ដើម្បីធ្វើអោយជំនួយរបស់ខ្លួនចំពោះ កម្ពុជាកាន់តែមានប្រសិទ្ធិភាព ។ មានឧទាហរណ៍ជាច្រើនដែលបញ្ជាក់អំពីការអនុវត្តន៍ក្នុងរយៈពេលកន្លង មករបស់អ្នកផ្តល់ជំនួយ ជាបុគ្គលក្តី និង ជាសហគមន៍ក្តី ដែលធ្វើអោយជំនួយមិនទទួលបានផលល្អនិងគ្មាន ប្រសិទ្ធិភាព ឬ អាចធ្វើអោយស្ថានភាពកាន់តែអាក្រក់ថែមទៀត ដោយរួមចំណែកជំរុញអោយមាន (ឬ លើកកំពស់) វប្បធម៌ពុករលួយ និង បរិបាលកិច្ច ក្នុងការប្រើប្រាស់ធនធានសាធារណៈ ។ ការគ្រប់គ្រង ជំនួយមិនបានល្អ អាចធ្វើអោយរាំងស្ទះដល់ការ បង្កើតចក្ខុវិស័យសមស្របសំរាប់កិច្ចអភិវឌ្ឍន៍រយៈពេលវែង របស់រាជរដ្ឋាភិបាល ឬ អាចធ្វើអោយចុះអន់ថយដល់ សមត្ថភាពស្ថាប័នរដ្ឋ និង ធ្វើអោយអង្គការសង្គម ស៊ីវិលមានលក្ខណៈមិនស្របច្បាប់ ។

៧.	ដើម្បីងាយយល់ ការពិភាក្សាលើរបៀបរៀបចំជំនួយអភិវឌ្ឍន៍យ៉ាងណាអោយបានល្អប្រសើរបំផុត ដើម្បីរួមចំណែកសំរេចគោលដៅអភិវឌ្ឍន៍នៅថ្នាក់ជាតិ ត្រូវបានរៀបចំជារចនាសម្ព័ន្ធ ក្រោមចំណង ជើងមួយចំនួនដាច់ពីគ្នា (សូមមើលរូប ៦.១) ។ កិច្ចសហប្រតិបត្តិការល្អក្នុងការអភិវឌ្ឍន៍ ពឹងផ្អែកលើសូច នាករដែលគួរអោយទុកចិត្តបាន ស្តីពីភាពជាម្ចាស់លើរបៀបវារៈអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ។ គោល គំនិតស្តីពីភាពជាម្ចាស់នៅត្រង់ចំណុចនេះ មានន័យថា រាជរដ្ឋាភិបាល ដឹងនិងទទួលស្គាល់បញ្ហាដែលខ្លួន កំពុងតែប្រឈមមុខ បានរៀបចំយុទ្ធសាស្ត្រសំរាប់ដោះស្រាយបញ្ហានេះ (យុទ្ធសាស្ត្រដែលសហគមន៍ផ្តល់ ជំនួយបានវាយតំលៃថា ឆ្លើយតបទៅនឹងស្តង់ដារ បច្ចេកទេសត្រឹមត្រូវលើគុណភាព និង លទ្ធភាព) និង បង្ហាញអោយឃើញពីការប្តេជ្ញាចិត្តផ្នែកនយោបាយពិតប្រាកដ ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រនេះ ។

៨.	ប្រសិនបើសហគមន៍ផ្តល់ជំនួយមានជំនឿថា យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាមាន លក្ខណៈពេញលេញគ្រប់គ្រាន់ និងមានតម្លាភាពនោះ គេគួរតែស្ម័គ្រចិត្តរៀបចំតំរូវកម្មវិធីសហប្រតិបត្តិការ របស់ប្រទេសខ្លួន អោយត្រូវជាមួយនឹងទិសដៅគោលនយោបាយ និង អាទិភាពថវិការបស់រាជរដ្ឋាភិបាល ។ (ប្រសិនបើភាពជាម្ចាស់ នេះ មិនមានទេជាការសំខាន់ ត្រូវរៀបចំការគ្រប់គ្រងជំនួយ ទៅតាមមធ្យោបាយ មួយដែលជំរុញអោយមានភាពជា ម្ចាស់នេះ ឬយ៉ាងហោចណាស់ ក៏មិនចាំបាច់បង្កើតភាពជាម្ចាស់នេះសារ

ឡើងវិញទៀតដែរ) ។ ការរៀបចំតំរូវ ប្រភេទខុសគ្នា ដែលអាចត្រូវបានធ្វើឡើង ក្នុងករណីដែលសហគមន៍ផ្តល់ជំនួយមិនសុខចិត្តរៀបចំតំរូវតាម គោលនយោបាយ ឬ អាទិភាពរបស់រាជរដ្ឋាភិបាលទាំងស្រុង តំរូវអោយមានការប្តេជ្ញាចិត្តពីសំណាក់សហគមន៍ផ្តល់ ជំនួយក្នុងការប្រើប្រាស់ប្រព័ន្ធរដ្ឋបាលនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងការផ្ទេរជំនួយនិងសកម្មភាព (ដែលតាមធម្មតា ស្ថិតក្នុងករណីនេះ) ជាជាង តំរូវអោយរាជរដ្ឋាភិបាល កែសំរួលដំណើរការរបស់ខ្លួនទៅតាម ពហុលភាពនៃប្រព័ន្ធជំនួយខុសៗគ្នានោះ ។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំតំរូវប្រព័ន្ធនេះ តំរូវអោយសហគមន៍ផ្តល់ជំនួយ (និង អ្នកជាប់ពន្ធ ឬសមាជិកក្រុមរបស់ខ្លួន) មានការស្ម័គ្រចិត្តដោយខ្លួនឯង និង តំរូវអោយប្រព័ន្ធនិង នីតិវិធីរបស់រាជរដ្ឋាភិបាល ឆ្លើយតបទៅនឹងស្តង់ដារបច្ចេកទេសត្រឹមត្រូវលើប្រសិទ្ធិភាព និង ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ។

៩. ជាចុងក្រោយ ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន មានវិសាលភាពធំធេងក្នុងការរៀបចំសុខដុមនីយកម្ម សហគមន៍ផ្តល់ជំនួយលើនីតិវិធីរបស់ខ្លួន តាមរយៈ ១) អនុម័តកិច្ចព្រមព្រៀងរួមសំរាប់ធ្វើផែនការនិងផ្តល់ជំនួយ (ឧទាហរណ៍ : តាមរយៈការមានភាពច្បាស់លាស់និង ជំហរដូចគ្នាទាក់ទិននឹងល័ក្ខខ័ណ្ឌដែលនឹងបណ្តាលអោយមានជំនួយបន្ថែមឬបន្ថយ ឬ តាមរយៈការជួយទ្រទ្រង់ដល់ក្របខ័ណ្ឌជំនួយលើវិស័យទាំងមូលដែលបានឯកភាព) ២) ប្រសិនបើអាចធ្វើបាន បញ្ច្រាបនិងធ្វើសនិទានកម្មលើនីតិវិធីរបស់ខ្លួន (ឧទាហរណ៍ : តាមរយៈបេសកកម្មនិងការ សិក្សារួម ជាជាង បេសកកម្មនិងការសិក្សារបស់អ្នកផ្តល់ជំនួយតែមួយ) ដើម្បីកាត់បន្ថយបន្ទុកលើរាជរដ្ឋាភិបាល និង ៣) ផ្លាស់ប្តូរគ្នាយ៉ាងទូលាយនូវការងារវិភាគនិងព័ត៌មានស្តីពីលំហូជំនួយដែលបានធ្វើផែនការនិងដែលជាក់ស្តែង ។ ជាការសំខាន់ ត្រូវកត់សំគាល់ថា ការរៀបចំសុខដុមនីយកម្មសហគមន៍ផ្តល់ជំនួយ គួរតែធ្វើឡើង ទោះបីជាគេអាច ឬ មិនអាចរៀបចំតំរូវ កម្មវិធីនិងប្រព័ន្ធរបស់គេឱ្យត្រូវជាមួយនឹងកម្មវិធីនិងប្រព័ន្ធរបស់រាជរដ្ឋាភិបាល ក៏ដោយ ។ សហគមន៍ផ្តល់ជំនួយអាចចាត់វិធានការនៅក្នុងចំណោមពួកខ្លួន ដើម្បីធ្វើសុខដុមនីយកម្ម សូម្បីតែនៅពេលដែលសហគមន៍ផ្តល់ជំនួយ មិនអាចរៀបចំតំរូវគោលនយោបាយ ឬ ប្រព័ន្ធរបស់ខ្លួន អោយត្រូវជាមួយនឹងគោល នយោបាយ ឬ ប្រព័ន្ធរបស់រាជរដ្ឋាភិបាល ដោយសារសហគមន៍នេះ យល់ថា គោលនយោបាយទាំងនោះ មាន ទិសដៅមិនសមស្រប ឬថា ប្រព័ន្ធទាំងនោះ មិនមានលក្ខណៈពេញលេញ ដែលអាចធានាអោយមានការប្រើប្រាស់

ធនធានជំនួយ ប្រកបដោយប្រសិទ្ធិភាព និង មានការទទួលខុសត្រូវខ្ពស់ ឬក៏ ដោយសារបទបញ្ហាផ្ទៃក្នុងរបស់ សហគមន៍នេះ ហាមឃាត់ការប្រើប្រាស់ប្រព័ន្ធរបស់រាជរដ្ឋាភិបាល ។

**ប្រអប់ ៦.២ សមាសភាគនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដែលត្រូវបានកែលំអ**

១. ភាពម្ចាស់ការៈ
រដ្ឋាភិបាល និង សង្គម

២. ការរៀបចំឱ្យស៊ីសង្វាក់គ្នា ៖
អ្នកផ្ដល់ជំនួយ - រដ្ឋាភិបាល

៣. សុខុដុមនីយកម្មសហគមន៍
ផ្ដល់ជំនួយ




*ប្រភព : យកតាមលំនាំOECD-DAC ២០០៤*

១០. ជំពូកនេះ ពិនិត្យមើលដោយសង្ខេបលើបញ្ហាទាំងនេះ ។ ជំពូកនេះអះអាងថា ការបោះជំហានទៅកាន់វិធី សាស្ត្រជាដៃគូចំពោះកិច្ចអភិវឌ្ឍន៍កម្ពុជាទាមទារអោយមានកំណែទំរង់នៃអ្នកផ្ដល់កំចីនិងអ្នកផ្ដល់ជំនួយ (និងគោលនយោបាយមិនមែន ODA របស់រដ្ឋាភិបាលអ្នកផ្ដល់ជំនួយ) ក៏ដូចជាកំណែទំរង់នៃរាជរដ្ឋាភិបាលកម្ពុជាផងដែរ ។ គោលបំណងរយៈពេលវែងគឺដើម្បីអោយក្លាយជាការពិតនូវគោលការណ៏នៃការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក ពោលគឺ ដៃគូអភិវឌ្ឍន៍កម្ពុជា និង រាជរដ្ឋាភិបាលចាំបាច់ត្រូវឯកភាពគ្នា និង ធ្វើតាមវិធានមួយចំនួន ដែលកំណត់ តួនាទីនិងកាតព្វកិច្ចរបស់គេចំពោះគ្នាទៅវិញទៅមក និង ចំពោះពលរដ្ឋកម្ពុជា ។ អ្នកផ្ដល់ជំនួយ ត្រូវគោរពតាម គោលការណ៏ទូទៅនេះឱ្យបានខ្ជាប់ខ្ជួន និង កំណែទំរង់ជាក់លាក់ នៅក្នុងក៏រិតពិភពលោក មានជាអាទិ៍នៅឯកិច្ចប្រជុំកំពូលប្រចាំសហស្សវត្សរ៍[១] សន្និសីទទីក្រុង Monterrey ស្ដីពីហិរញ្ញប្បទានដើម្បីកិច្ចអភិវឌ្ឍន៍ និង កិច្ចព្រមព្រៀង OECD-DAC ទីក្រុងរ៉ូម ស្ដីពីការធ្វើសុខុដុមនីយកម្ម ។ បញ្ហាប្រឈម គឺការសំរេចអោយបាននូវការសន្យាទាំងនេះនៅកម្ពុជា ។

១១. ទោះជាយ៉ាងណាក៏ដោយ ប្រការទាំងនេះ មិនគួរប្រកាន់យកដើម្បីធ្វើឱ្យទន់ខ្សោយដល់សារដ៏សំខាន់បំផុត ដែលមាននៅក្នុងរបាយការណ៏នេះ (និង ដែលមានបង្ហាញច្បាស់នៅក្នុងយុទ្ធសាស្ត្រចតុកោណ

របស់រាជរដ្ឋាភិបាល) ពោលគឺ កម្ពុជា នឹងមិនអាចគេចវេះពីភាពក្រីក្រនិងភាពខ្សត់ខ្សោយបានឡើយ ប្រសិនបើកម្ពុជា មិនសំរេចបាននូវ អភិបាលកិច្ចល្អ ។ អ្នកផ្តល់ជំនួយអាចសំរេចសមិទ្ធផលច្រើន សូម្បីនៅក្នុងស្ថានភាពបច្ចុប្បន្នក្តី ប្រសិនបើគេ អនុម័តយកវិធីសាស្ត្រ ដែលត្រូវបានសំរបសំរួលនិងធ្វើសុខុដុមនីយកម្ម។ ប៉ុន្តែការសំរេចបាននូវសក្តានុពលជំនួយ ពេញលេញតំរូវអោយអ្នកផ្តល់ជំនួយអាចធ្វើអន្តរកម្មជាមួយរាជរដ្ឋាភិបាល និង តម្រង់កម្មវិធីជំនួយរបស់ខ្លួនតាម រាជរដ្ឋាភិបាលមួយ ដែលកំពុងកាន់តែបង្ហាញថាមានតម្លាភាព ទទួលខុសត្រូវ និង សំរបសំរួលផ្ទៃក្នុង នៅក្នុងការ សំរេចអោយបាននូវចក្ខុវិស័យមួយដើម្បីកាត់បន្ថយភាពក្រីក្រ ។ ប្រសិនបើគ្មានកំណែទំរង់ធំដុំលើស្ថាប័ន និង ប្រព័ន្ធ រាជរដ្ឋាភិបាលទេនោះ សូម្បីជំនួយដែលសំរបសំរួលបានល្អក៏ដោយ ក៏នឹងសំរេចបានផលតិចតួចណាស់ ។ ក្នុងកាលទេសៈបែបនេះ សហគមន៍ផ្តល់ជំនួយ នឹងត្រូវបង្ខំចិត្តធ្វើការពិចារណាឡើងវិញលើយុត្តិកម្មនៃការបន្តជួយ ឧបត្ថម្ភដល់ប្រទេសកម្ពុជាជាជាង ជួយប្រទេសជាតិដទៃទៀតដែលក្រីក្រដូចគ្នា ។

១២. ជំពូកនេះចាប់ផ្តើមដោយការពិនិត្យជារួមអំពីប្រការដែលថា តើជំនួយដែលគ្រប់គ្រងមិនបានល្អបានរួម ចំណែកដល់បញ្ហាអភិបាលកិច្ចរបស់កម្ពុជាដូចម្តេច ។ បន្ទាប់មក ជំពូកនេះនឹងសង្ខេបកិច្ចអភិវឌ្ឍន៍ជាវិជ្ជមានថ្មីៗ ដែលបានកើតឡើង និង ដាក់ចេញនូវរបៀបវារៈបច្ចុប្បន្នសំរាប់រយៈពេលឆាប់ៗខាងមុខ និងរយៈពេលមធ្យម ។ ប្រធានបទទូលាយត្រូវបានកំណត់សំរាប់ប្រការដែលថាតើ ODA អាចក្លាយជាផ្នែកមួយនៃដំណោះស្រាយ មិនមែនជាផ្នែកមួយនៃបញ្ហាឡើយ ទាក់ទិននឹងបញ្ហានៃគ្រឿងលើកទឹកចិត្តអភិវឌ្ឍន៍ស្ថាប័ន និង អភិបាលកិច្ច។

## ក. ជំនួយអភិវឌ្ឍន៍ និង បញ្ហាអភិបាលកិច្ចរបស់កម្ពុជា

១៣. ដោយសារភូមិសាស្ត្រនយោបាយសង្គ្រាមត្រជាក់ ប្រទេសកម្ពុជាត្រូវបានដាក់នៅក្រៅប្រព័ន្ធជំនួយអន្តរជាតិ ក្នុងរយៈពេលជិតមួយទសវត្សរ៍ឆ្នាំ ៨០ ។ ដោយមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងឆ្នាំ ១៩៩១ ទំហំនៃជំនួយអន្តរជាតិចំពោះកម្ពុជា និង ចំនួននៃតួអង្គដែលទាក់ទិនក្នុងការផ្តល់ជំនួយ បានកើនឡើងយ៉ាងច្រើន ។ ជាក់ស្តែង ការគ្រប់គ្រងនិងប្រសិទ្ធិភាពជំនួយមានវិបត្តិដោយសារយន្តការដែលបានបង្ហាញថាមានប្រសិទ្ធិភាពក្នុងការសំរបសំរួលគំរោងមួយចំនួនតូច ដែលទទួលមូលនិធិជំនួយនៅក្នុងវិស័យមួយក្នុងអំឡុងពេលនៃការដាក់អោយនៅឯកោ និង ការងើបឡើងវិញក្នុង

ទសវត្សរ៍ឆ្នាំ ៨០ បានបង្ហាញថា មិនគ្រប់គ្រាន់ទេ សំរាប់ការកើនឡើងច្រើននៃចំនួនតួអង្គ និង ភាពខុសគ្នាច្រើន និង មហិច្ឆិតានៃការធ្វើអន្តរាគមន៍នៅក្នុងដំណាក់ កាលធ្វើឱ្យមានភាពប្រក្រតីឡើងវិញនៅពាក់កណ្តាលនិងចុងទសវត្សរ៍ឆ្នាំ ១៩៩០ ។ តារាង ៦.១ បង្ហាញជូននូវ ការយល់ដឹងពីទំហំនៃបញ្ហា ពោលគឺថ្វីបើចំណូលក្នុងស្រុកកំពុងចាប់ផ្តើមកើនឡើងក្តី ក៏កម្ពុជានៅតែពឹងផ្អែកយ៉ាង ច្រើនលើជំនួយ ។

**តារាង ៦.១ សូចនាករជ្រើសរើសនៃការពឹងផ្អែកលើជំនួយនៅប្រទេសកម្ពុជា**

| សូចនាករ | ឆ្នាំ | តម្លៃ |
|---|---|---|
| ចំនួនអ្នកផ្តល់ជំនួយ | ២០០៣ | ៣១ |
| ចំនួនសកម្មភាពដែលជួយឧបត្ថម្ភដោយអ្នកផ្តល់ជំនួយ | ២០០៣ | ៤១០ |
| ODA គិតជាភាគរយនៃចំណូលជាតិសរុប | ២០០២ | ១២.៧% |
| ODA គិតជាភាគរយនៃការនាំចូល | ២០០២ | ១៦.៧% |
| លំហូជំនួយបរទេសដែលបានរាយការណ៍ | ១៩៩៦-២០០១ | $២.៦៧២ លាន |
| ... ប្រៀបធៀបទៅនឹងចំណាយសរុបដែលបានធ្វើឡើងដោយរតនាគារជាតិ | ១៩៩៦-២០០១ | $២.១២២ លាន |
| ភាគរយនៃចំណាយសាធារណៈសរុបដែលត្រូវបានរ៉ាប់រងដោយ ODA នៅក្នុងវិស័យ: | | |
| សុខាភិបាល | ២០០១ | ៦៩.៩% |
| កសិកម្ម | ២០០១ | ៦៧.៤% |
| ដឹកជញ្ជូន | ២០០១ | ៦៨.១% |
| អភិវឌ្ឍន៍ជនបទ | ២០០១ | ៨៨.៨% |

*ប្រភព: ធនាគារពិភពលោក ២០០៣ ទំព័រ ១៩-២២, ធនាគារពិភពលោក ២០០៤*

១៤. ទំនាក់ទំនងរវាងសមត្ថភាពរដ្ឋ អភិបាលកិច្ច និង ជំនួយនៅក្រោមស្ថានភាពទាំងនេះគឺមានលក្ខណៈស្មុគ្រស្មាញនិងធំធេង ។ សហគមន៍ផ្តល់ជំនួយ មានទំនោរពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើអង្គភាពអនុវត្តន៍គំរោង (PIUs) ដោយសារគេមានជំនឿថា ស្ថាប័នរដ្ឋមានភាពទន់ខ្សោយ ហើយ អំពើពុករលួយមានការរីករាលដាល ដែលតំរូវអោយគេធ្វើការគ្រប់គ្រងជំនួយរបស់គេអោយបានជិតដល់បំផុត ឬ ដោយសារទាំងនោះ គឺជាអ្វីដែលច្បាប់របស់ ប្រទេសផ្តល់ជំនួយ ឬ បទបញ្ជាផ្ទៃក្នុងរបស់ស្ថាប័នផ្តល់ជំនួយ បានកំណត់ ។ ទោះបីជាមិនទទួលបានជោគជ័យ ជានិច្ចកាលក៏ដោយ ក៏អ្នកផ្តល់ជំនួយ បានគ្រោងថា នឹងញែក

សកម្មភាពគំរោងទាំងនេះអោយដាច់ចេញពីកំហុសឆ្គង របស់រាជរដ្ឋាភិបាល ដោយពឹងផ្អែកទៅលើអង្គភាពអនុវត្តន៍គំរោង និង ជំនួយបច្ចេកទេស ដែលត្រូវបានចាត់ទុកថា មានសារៈសំខាន់ចាំបាច់ក្នុងការជំរុញអោយជំនួយមានប្រសិទ្ធិភាព ដោយប្រឈមមុខនឹងសមត្ថភាពទន់ខ្សោយ និង ជាមធ្យោបាយមួយសំរាប់កសាងសមត្ថភាពនេះ ។ អង្គភាពអនុវត្តន៍គំរោងទាំងនេះ ពិតជា សំរេចបានគោលដៅ ប្រសិទ្ធិភាពដែលបានកំណត់នៅក្នុងគំរោងនីមួយៗ ដោយមួយផ្នែកធំបានផ្តល់ប្រាក់បៀវត្សរ៍ខ្ពស់សំរាប់ជ្រើសរើស រក្សាទុក និង លើកទឹកចិត្ត ដល់បុគ្គលិកដែលមានសមត្ថភាពខ្ពស់ ។ ទោះជាយ៉ាងណាក៏ដោយ មានការទទួល ស្គាល់កាន់តែច្រើនឡើងថា មានឧបសគ្គធ្ងន់ធ្ងរចំពោះអ្វីដែលត្រូវសំរេចអោយបាន តាមរយៈគំរូនៃការផ្តល់ជំនួយនេះ (មើលប្រអប់ ៦.២) ។ តាមការអនុវត្តន៍ជាក់ស្តែង យុទ្ធវិធីនេះ ធ្វើអោយខូចខាតដល់មូលដ្ឋានគ្រឹះសំរាប់ការប្រើប្រាស់ធនធានដែលមាន ប្រកបដោយប្រសិទ្ធិភាពនិងមានការទទួលខុសត្រូវខ្ពស់ (ធនធានក្នុងស្រុក និង ODA) និង សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តន៍មុខងារសំខាន់ៗទាំងឡាយ ។

**ប្រអប់ ៦.៣ សមត្ថភាពនិងអភិបាលកិច្ចៈ ការលំបាកនៃគំរោង**

ចំពោះរូបភាពល្អបំផុត ការរីកដុះដាលនៃអង្គភាពអនុវត្តន៍គំរោង បានបង្កើតអោយមាន "កោះឧត្តមភាពនៅក្នុងសមុទ្របរាជ័យរបស់រាជរដ្ឋាភិបាល" គឺថា កំណើនលទ្ធផលក្នុងរយៈពេលខ្លីត្រូវសំរេចបាន ដោយមានឥទ្ធិពលតិចតួចលើបញ្ហាដែល មានផលប៉ះពាល់លើការអនុវត្តន៍រដ្ឋបាលសាធារណៈ និង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ចំពោះរូបភាពអន់បំផុត ការរីកដុះដាលនៃគំរោងគ្រប់គ្រងដោយសហគមន៍ផ្តល់ជំនួយតែឯង មានផលប៉ះពាល់ដល់ប្រសិទ្ធិភាពរដ្ឋ គឺថា ការបង្កើតចក្ខុវិស័យ យុទ្ធសាស្ត្រ និង ប្រព័ន្ធរបស់រាជរដ្ឋាភិបាលត្រូវរាំងស្ទះ ឬ ត្រូវបានកាត់បន្ថយ ដោយសារក្រសួង ត្រូវចំណាយពេលវេលា ទាំងអស់របស់ខ្លួនដើម្បីស្វែងរកមូលនិធិសំរាប់គំរោង ដែលនាំអោយមានទិសដៅដែលគ្មានការសំរបសំរួល (និង មានលក្ខណៈ ផ្ទុយគ្នា) ហើយបុគ្គលិកដែលមានសមត្ថភាពខ្ពស់ព្យួរការងារស្នូលរបស់ក្រសួងរួចរត់ចូលទៅក្នុងអង្គភាពអនុវត្តន៍គំរោង ។ លើសពីនេះទៀត សមិទ្ធិផលដែលសំរេចបានក្នុងកាលៈទេសៈបែបនេះ មិនមាននិរន្តរភាពទេ ពីព្រោះថា វាទំនងជានឹងដួលរលំ នៅពេលណាដែលសហគមន៍ផ្តល់ជំនួយបញ្ឈប់ជំនួយរបស់គេ ។

១៩. ការបារម្ភណ៍ជាពិសេសនៃរាជរដ្ឋាភិបាលគឺការពឹងផ្អែកដ៏លើសលុបលើជំនួយបច្ចេកទេសរបស់អ្នកផ្តល់ ជំនួយ ដែលភាគច្រើនមានប្រភពមកពីបរទេស ។ ចំនួនទីប្រឹក្សាជំនួយបច្ចេកទេសបរទេស (ប៉ាន់ស្មានក្នុងរង្វង់ចំនួន ៨០០) ហើយទំហំនៃការចំណាយលើជំនួយបច្ចេកទេស (ក្នុងរង្វង់ ១៦២ លានដុល្លារក្នុងឆ្នាំ

២០០១ - ប្រហាក់ប្រហែល នឹង ២១ ភាគរយនៃចំណាយក្នុងស្រុក និង ចំណាយដែលបានទទួលហិរញ្ញប្បទានពីបរទេស ឬលើសចំនួនប្រាក់បៀវត្សរ៍សរុបរបស់រាជរដ្ឋាភិបាល) គឺមានលក្ខណៈខ្ពស់ពន់ពេកណាស់ ។ ជាការពិតណាស់ ជំនួយបច្ចេកទេស ពិតជាមានតួនាទីសំខាន់មួយ ដែលប្រសិនបើត្រូវបានគ្រប់គ្រងបានត្រឹមត្រូវ ពិតជាអាចរួម ចំណែកដល់កិច្ចអភិវឌ្ឍសមត្ថភាពរយៈពេលវែង ។ ប៉ុន្តែ ទន្ទឹមនឹងនេះដែរ ការពឹងផ្អែកលើទីប្រឹក្សាក្នុងការគ្រប់ គ្រងគំរោង ឬ ដំណើរការកំណែទំរង់ អាចធ្វើអោយប៉ះពាល់ដល់ភាពជាម្ចាស់លើប្រទេសជាតិ និង ធ្វើអោយរាំងស្ទះដល់ កិច្ចអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន ជាពិសេស នៅពេលដែលទីប្រឹក្សាទាំងនេះ ត្រូវបានធ្វើសមាហរណកម្ម ដោយមិនមានការពិនិត្យជិតដល់ទៅក្នុងដំណើរការទូទៅរបស់ក្រសួង ។ (Godfrey et al 2003; Mysliwiec 2004)

១៦. ក្នុងករិតម៉ាក្រូ ការដឹកនាំរបស់រាជរដ្ឋាភិបាលលើរបៀបវារៈកំណែទំរង់ជំនួយពឹងផ្អែកយ៉ាងសំខាន់លើការ មានយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដ៏ពេញលេញនិងច្បាស់លាស់មួយ ។ បើគ្មានយុទ្ធសាស្ត្ររួមរយៈពេលមធ្យមនេះទេ គេ អាចឃើញមានតែការរីកចំរើនស្តួចស្តើងប៉ុណ្ណោះក្នុងការតម្រង់ជួរការគាំទ្ររបស់អ្នកផ្តល់ជំនួយចំពោះអាទិភាព រាជរដ្ឋាភិបាល ។ យុទ្ធសាស្ត្ររួមនេះមិនទាន់ត្រូវបានអភិវឌ្ឍពេញលេញនិងបញ្ជ្រាបនៅកម្ពុជានៅឡើយ ។ ប្រការនេះមិនគួរអោយភ្ញាក់ផ្អើលទេ បើគិតពីសមត្ថភាពស្ថាប័នដែលនៅមានករិត ។ ក្រៅពីកិច្ចខិតខំប្រឹងប្រែងរៀបចំអោយមានយុទ្ធសាស្ត្រនេះ មានកិច្ចខិតខំប្រឹងប្រែងមួយចំនួនទៀតស្ថិតនៅក្រោមការឧបត្ថមរបស់សហគមន៍ផ្តល់ជំនួយ ដែលត្រូវបានអនុវត្តស្របពេលជាគ្នា ឬ ជាបន្តបន្ទាប់ រហូតដល់ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើទី ២ (SEDPII) ដែលទទួលបានជំនួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី និង យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) ទទួលបានជំនួយឧបត្ថម្ភពីធនាគារពិភពលោក ដែលត្រូវបានចាត់ទុកថាជា ឯកសារយុទ្ធសាស្ត្រជាតិកាត់ បន្ថយភាពក្រីក្ររបស់កម្ពុជា ។ ទោះបីជាឯកសារទាំងនេះមានចំណុចដូចគ្នាភាគច្រើនក្តី ក៏វាខុសគ្នាត្រង់ចំណុចសំខាន់ៗខ្លះ ជាពិសេសចំពោះក្របខ័ណ្ឌតាមដាននិងវាយតម្លៃការអនុវត្តន៍គោលនយោបាយ និង លទ្ធផលក្នុងរយៈពេលមធ្យម ។ ស្ថានភាពនៃការតាមដានការរីកចំរើនត្រូវបានធ្វើអោយមានភាពស្មុគ្រស្មាញបន្ថែមទៀត ដោយការផលិតចេញ (ដោយមានការជួយឧបត្ថម្ភពី UNDP) នូវរបាយការណ៍គោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សរ៍កម្ពុជា ដែលដាក់ចេញនូវបន្ទាត់មូលដ្ឋាននិងសូចនាករគោលដៅផ្លូវការទីបី ដែលស្របគ្នាលើចំណុចខ្លះៗតែប៉ុណ្ណោះ ។

## ខ. កិច្ចប្រឹងប្រែងដើម្បីធ្វើកំណែទំរង់ជំនួយក្នុងឆ្នាំ ២០០៤

១៧. នៅចុងឆ្នាំ ២០០៤ គេឃើញមានមូលដ្ឋានសំខាន់ៗសំរាប់សុទិដ្ឋិនិយមចំពោះទំនាក់ទំនងរាជរដ្ឋាភិបាលអ្នកផ្តល់ជំនួយ ។ ការរីកចំរើនជាវិជ្ជមានមួយចំនួន ដែលភាគច្រើនកើតឡើងក្នុងអំឡុងពេលដប់ពីរខែចុងក្រោយ បានកែលំអយ៉ាងច្រើននូវលទ្ធភាពបោះជំហានទៅកាន់ការប្រើធនធានជំនួយអោយបានកាន់តែមានផលច្រើន ។ ប្រការទាំងអស់នេះអាចត្រូវបានចាត់ទុកថាជាការឆ្លើយតបទៅនឹងរបៀបវារៈពិភពលោកទូទៅសំរាប់គំរូកែលំអជំនួយ ដែលដឹកនាំដោយរដ្ឋាភិបាលនៅក្នុងក៏រិតប្រទេស (ដែលត្រូវបានចែងយ៉ាងច្បាស់លាស់នៅក្នុង*សេចក្តីណែនាំស្តីពី ការធ្វើសុខដុមនីយកម្មអ្នកជំនួយ* របស់ OECD-DAC) និងទៅនឹងការតិទៀនជាក់លាក់របស់រាជរដ្ឋាភិបាល កម្ពុជាលើការផ្តល់ជំនួយដែលគ្មានការសំរបសំរួលគ្នាជូនដល់កម្ពុជា (ដែលបានបង្ហាញនៅក្នុងការសិក្សានិងសេចក្តី ថ្លែងការមួយចំនួនរបស់រាជរដ្ឋាភិបាលចាប់តាំងពីចុងទសវត្សរ៍ ១៩៩០[២])។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជា បានចាប់ផ្តើមផ្សាភ្ជាប់ទៅនឹងការពិភាក្សាពិភពលោក ហើយបច្ចុប្បន្ននេះ គឺជាហត្ថលេខីមួយនៃ សេចក្តីថ្លែងការណ៍ក្រុងរ៉ូមស្តីពីសុខដុមនីយកម្ម[៣] ។

១៨. ចលនាឆ្ពោះទៅកាន់ ODA ដែលមានលក្ខណៈកាន់តែស៊ីសង្វាក់គ្នានោះ ជាដំបូង បានចាប់ផ្តើមល្បឿន យ៉ាងលឿននៅតាមវិស័យ ។ សព្វថ្ងៃនេះ របៀបវារកំណែទំរង់ជំនួយ គឺមានការរីកចំរើនខ្លាំងបំផុតនៅក្នុងវិស័យ អប់រំ និង សុខាភិបាល ដែលក្នុងនោះ ភាពជាដៃគូពហុអ្នកផ្តល់ជំនួយ បានវិវឌ្ឍជាបណ្តើរៗឆ្ពោះទៅជួយទ្រទ្រង់ ដល់ការរៀបចំយុទ្ធសាស្រ្តតាមវិស័យ (វិធីសាស្រ្តទូទាំងវិស័យ [SWAp] នៅក្នុងវិស័យអប់រំ និង ការគ្រប់គ្រង តាមវិស័យ [SWIM] នៅក្នុងវិស័យសុខាភិបាល) ដែលរៀបចំតំរូវ ODA អោយត្រូវនឹងយុទ្ធសាស្រ្ត របស់ក្រសួង និង កាត់បន្ថយចំណាយប្រតិបត្តិការចំពោះរាជរដ្ឋាភិបាល[៤] ។ ភាពជាដៃគូនៃពហុអ្នកផ្តល់ជំនួយ ក៏បានធ្វើអោយរលូនផង ដែរនូវទំនាក់ទំនងអ្នកផ្តល់ជំនួយ-រដ្ឋាភិបាល និង ជួយកាត់បន្ថយគំលាតនិងការត្រួតគ្នាទាក់ទិននឹងការធ្វើវិមជ្ឈការ និង អភិបាលកិច្ចមូលដ្ឋាន (សិលា និងភាពជាដៃគូដើម្បីរាជរដ្ឋាភិបាលនៅតាមមូលដ្ឋាន) និង ពេលថ្មីៗ បំផុតនេះ នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដោយមានកិច្ចព្រមព្រៀងស្តីពីការជួយឧបត្ថម្ភពហុអ្នកផ្តល់ ជំនួយចំពោះដំណើរការ

កំណែទំរង់ដែលមានបីដំណាក់កាលមួយ ដែលរួមមានកំណែទំរង់ប្រាក់បៀវត្សរ៍ នៅក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ។

១៩. ក្នុងកិច្ចប្រឹងប្រែងដាក់ចេញនូវរចនាសម្ព័ន្ធរួមជាមូលដ្ឋានមួយលើការផ្តួចផ្តើមគំនិតរៀបចំតំរូវ/សុខុដុមនីយកម្មនៅក្រោមថ្នាក់ជាតិ និង លើកកំពស់ការរៀបចំនៅក្នុងវិស័យដែលមិនសូវជឿនលឿនអោយបានដល់កំរិតស្តង់ដារដែលគេឃើញនៅក្នុងវិស័យសុខាភិបាលនិងអប់រំ រាជរដ្ឋាភិបាលបានកំណត់ថា អង្គភាពសំរបសំរួល រាជរដ្ឋាភិបាល-អ្នកផ្តល់ជំនួយដែលមានស្រាប់នៅតាមវិស័យនិងតាមប្រធានបទ គួរតែកែសំរួលរចនាសម្ព័ន្ធអោយស្របទៅតាមបន្ទាត់ស្តង់ដារ គឺ ក្រុមការងារបច្ចេកទេស ។ នៅក្នុងកិច្ចប្រជុំត្រៀមឆ្ពោះកាន់កិច្ចប្រជុំក្រុមពិគ្រោះ ដែលធ្វើឡើងនៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៤ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសអំពីការចាប់ផ្តើម ការងាររបស់ក្រុមការងារបច្ចេកទេសថ្មីចំនួន ១៧ និង ដាក់ចេញនូវគោលការណ៍ជាមូលដ្ឋានសំរាប់ធ្វើកំណែទំរង់ រចនាសម្ព័ន្ធក្រុមការងារចាស់ :

២០. **ទី ១ :** រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍របស់ខ្លួន ទទួលស្គាល់តំរូវការឱ្យមានការពិនិត្យមើលឡើងវិញ និងរៀបចំរចនាសម្ព័ន្ធក្រុមការងារទាំងនេះឡើងវិញឱ្យក្លាយទៅជាក្រុមការងារបច្ចេកទេសរួមដែលជាយន្តការ មួយនៅតាមវិស័យ/តាមសាខា ។

២១. **ទី ២ :** ដើម្បីពង្រឹងភាពជាម្ចាស់ និង ភាពជាអ្នកដឹកនាំ ដល់រាជរដ្ឋាភិបាល ក្រុមការងារបច្ចេកទេសរួម ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួង ឬ ស្ថាប័នមួយដែលមានការទទួលខុសត្រូវ ដោយមានការចូលរួមពី តំណាងមួយចំនួនមកពីក្រសួង និង ដៃគូអភិវឌ្ឍន៍ផ្សេងទៀត ជាសមាជិក ។ កិច្ចសហការខាងសហគមន៍ផ្តល់ ជំនួយ នឹងទទួលបានការសំរបសំរួលពីអ្នកសំរបសំរួលឈានមុខរបស់ម្ចាស់ជំនួយ ។

២២. **ទី ៣ :** ក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវតែមានក្របខ័ណ្ឌការងាររួម ដែលកំណត់ច្បាស់លាស់នូវ តួនាទី និង ការទទួលខុសត្រូវ ។

២៣. ទោះបីជាមានសមិទ្ធិផលជាច្រើន អាចសំរេចបាន តាមរយៈគំនិតផ្តួចផ្តើមនៅតាមផ្នែកក៏ដោយក៏នៅមានតំរូវការអោយមានក្របខ័ណ្ឌរួមនៅថ្នាក់ជាតិសំរាប់គ្រប់គ្រងជំនួយដែរ ។ ក្នុងឆ្នាំកន្លងទៅនេះទាំងរាជរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយ បានបញ្ជាក់ក្នុងកំរិតខ្ពស់បំផុតថា ស្ថានភាពនៃយុទ្ធសាស្ត្រ

ជាតិជាច្រើន នឹងត្រូវដោះស្រាយ ដោយមានការរៀបចំអោយមានយុទ្ធសាស្ត្រសំរាប់ប្រាំឆ្នាំខាងមុខ ២០០៦-២០១០ ។ នេះ គឺជាការរីកចំរើនជាវិជ្ជមាន បំផុតមួយ ។ យុទ្ធសាស្ត្រថ្មីនេះ នឹងត្រូវរៀបចំអោយហើយមុនដំណាច់ឆ្នាំ ២០០៥ ហើយនឹងធ្វើអោយមានការឯកភាពគ្នានូវយុទ្ធវិធីទាំងឡាយ ដែលត្រូវបានរៀបចំឡើងកាលពីពេលមុន នៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើទី ២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និង គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ សម្តេចនាយករដ្ឋមន្ត្រី បានបញ្ជាក់យ៉ាងច្បាស់លាស់ និង ជាច្រើនដងថា ការរៀបចំយុទ្ធសាស្ត្រជាតិអោយមានឯកលក្ខណ៍ គឺជាគោលបំណង របស់រាជរដ្ឋាភិបាល ។ ចំណែកឯអ្នកផ្តល់ជំនួយទាំងបីដែលទាក់ទិននឹងឯកសារយុទ្ធសាស្ត្រ ដោយឡែកពីគ្នា ក្នុងពេលកន្លងមក (ពោលគឺ ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និង អង្គការសហប្រជាជាតិ) បានថ្លែងជាសាធារណៈថា ខ្លួននឹងអនុវត្តតាមយុទ្ធវិធីឯកភាពគ្នាមួយ ។ ផែនការប្រាំឆ្នាំថ្មី នឹងចែងអំពីគោលនយោបាយ ច្បាស់លាស់ និង ការវិនិយោគ ដែលជាតំរូវការចាំបាច់សំរាប់សំរេចចក្ខុវិស័យរបស់កម្ពុជា ដូចមានចែងនៅក្នុង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

២៤. គេក៏ឃើញមាននិន្នាការជាវិជ្ជមានឆ្ពោះទៅរកចក្ខុវិស័យជាយុទ្ធសាស្ត្រ ដែលមានទំនាក់ទំនងល្អប្រសើរ និង មានភាពស៊ីសង្វាក់គ្នា នៅក្នុងចំណោមសហគមន៍ផ្តល់ជំនួយ ។ គេសង្កេតឃើញមាននិន្នាការនេះនៅក្នុងចលនា ជាក់ស្តែងមួយចំនួនដែលមានលក្ខណៈជំរុញលើកទឹកចិត្ត ឆ្ពោះទៅរកសុខដុមនីយកម្ម ។ គំនិតផ្តួចផ្តើមទាំងនេះ រួមមាន ការងារវិភាគរួម[៥] ដំណើរការរៀបចំយុទ្ធសាស្ត្ររួមប្រចាំប្រទេសដែលតំរូវអោយមានការចូលរួមពីសំណាក់ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស (DFID) ធនាគារពិភពលោក និង ថ្មីៗនេះ គឺ អង្គការសហប្រជាជាតិ ព្រមទាំងការធ្វើសមាហរណកម្មខួបនៃការវិភាគនិងការធ្វើផែនការរបស់ ទីភ្នាក់ងារសហប្រជាជាតិជុំវិញដំណើរការ CCA-UNDAF (ដែលត្រូវរៀបចំអោយត្រូវនឹងយុទ្ធសាស្ត្រជាតិកាត់ បន្ថយភាពក្រីក្រ) ។ ការវិភាគរួមនៅក្នុងការវាយតំលៃទំនុកចិត្តរួមនិងការពិនិត្យមើលចំណាយសាធារណៈ (IFAPER) ដែលត្រូវបានធ្វើឡើងដោយធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់នូវមូលដ្ឋាន នៃការរៀបចំយុទ្ធវិធីភាពជាដៃគូសំរាប់ធ្វើកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានម្ចាស់ជំនួយ ទ្វេនិងពហុភាគីចំនួន ១០ ដែលត្រូវរៀបចំតំរូវជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសរបស់ខ្លួន អោយត្រូវនឹងកំណែទំរង់ជា ជំហានៗមួយចំនួន ដែលត្រូវបានរៀបចំឡើង ដើម្បីជំរុញអោយរបៀបរបបគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល

កម្ពុជា ឈានដល់ស្តង់ដារអន្តរជាតិនៅមុនដំណាច់ឆ្នាំ ២០១៥ (សូមមើលជំពូកទី ៣) ។ នៅកិរិតសុខដុម-និយកម្មប្រព័ន្ធនិងនីតិវិធី រាជរដ្ឋាភិបាល ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី បានសហការគ្នារៀបចំ ឯកសារនីតិវិធីប្រតិបត្តិការស្តង់ដារ និង ឯកសារស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុគំរោងរួម[៦] ។

*<u>តារាង ៦.២ សេចក្តីសង្ខេបផែនការសកម្មភាពសំរាប់ឆ្នាំ ២០០៤-២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីសុខដុមនីយកម្ម និង ការរៀបចំភាពស៊ីសង្វាក់</u>*

ផ្នែក ក : ភាពជាម្ចាស់ និង ភាពជាអ្នកដឹកនាំ

១. រាជរដ្ឋាភិបាលកម្ពុជា ដឹកនាំ ដំណើរការ និង រៀបចំក្របខ័ណ្ឌជាតិអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រតែមួយគត់សំរាប់ខួបផែនការ លើកក្រោយ (ឆ្នាំ ២០០៦-២០១០) :
   - ក) រាជរដ្ឋាភិបាលកម្ពុជា រៀបចំ និង អនុម័តផែនការជាតិអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រ (ឆ្នាំ ២០០៦-២០១០) ។
   - ខ) រាជរដ្ឋាភិបាលកម្ពុជា ប្រើប្រាស់ក្របខ័ណ្ឌជាតិអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រតែមួយគត់សំរាប់ការធ្វើផែនការដែលមានទំនាក់ទំនងនឹងការបែងចែកធនធាន រួមទាំង **ODA** ផង ។

២. រាជរដ្ឋាភិបាលកម្ពុជា អនុវត្តតួនាទីជាអ្នកដឹកនាំសំរបសំរួលជំនួយអភិវឌ្ឍន៍ :
   - ក) ផែនការរបស់កម្ពុជាស្តីពីសុខដុមនីយកម្ម និង ការរៀបចំភាពស៊ីសង្វាក់សំរាប់ឆ្នាំ ២០០៤-២០០៨ ដែលបានបញ្ជាក់ច្បាស់លាស់អំពីអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងសុខដុមនីយកម្ម និង ការរៀបចំភាពស៊ី សង្វាក់ ត្រូវបានរៀបចំឡើង និង ទទួលបានឯកភាពពីសំណាក់ដៃគូអភិវឌ្ឍន៍ ។
   - ខ) រាជរដ្ឋាភិបាលកម្ពុជា មានអង្គភាពសំរបសំរួល **ODA** មួយ ។
   - គ) គោលនយោបាយគ្រប់គ្រង ODA របស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានរៀបចំ និង ទទួលបានការឯកភាពពី សហគមន៍ផ្តល់ជំនួយ ។
   - ឃ) ផែនការ និង ការពិនិត្យតាមដានរួម លើការអនុវត្តន៍អាទិភាពអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា តំរូវឱ្យសហគមន៍ផ្តល់ជំនួយ និង ភាគីពាក់ព័ន្ធ ដូចបានរៀបរាប់នៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រ និង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។
   - ង) រាជរដ្ឋាភិបាលកម្ពុជា មានពត៌មានដែលខ្លួនត្រូវការសំរាប់ដឹកនាំ និង សំរបសំរួលជំនួយអភិវឌ្ឍន៍ ។

៣. កម្ពុជា ជាប្រទេសមួយនៅក្នុងចំណោមប្រទេសសាកល្បងទាំង ១៤ ដែលមានតួនាទីសកម្មក្នុងការអនុវត្តន៍សេចក្តីប្រកាស ទីក្រុងរ៉ូមស្តីពីសុខដុមនីយកម្ម និង ការរៀបចំភាពស៊ីសង្វាក់ (ឆ្នាំ ២០០៣) :
   - ក) រាជរដ្ឋាភិបាលកម្ពុជា ផ្តល់នូវរបាយការណ៍វឌ្ឍនភាពជាទៀងទាត់ស្តីពីការអនុវត្តន៍ផែនការសុខដុមនីយ-កម្ម និង ការរៀបចំភាពស៊ីសង្វាក់ របស់កម្ពុជា ។

## ផ្នែក ខ : ការពង្រឹងសមត្ថភាព

១. ការពង្រឹងសមត្ថភាពដល់រាជរដ្ឋាភិបាលកម្ពុជា
ដើម្បីអនុវត្តមុខងារសំរបសំរួលនិងគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធិភាព

ក) ពង្រឹងសមត្ថភាពដល់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្ថាប័នសំរបសំរួល និង ក្រសួងតាមវិស័យនីមួយៗ ដើម្បី អនុវត្តមុខងារសំរបសំរួលនិងគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធិភាព ។

ខ) កិច្ចព្រមព្រៀងស្តីពីគោលការណ៍ និង របៀបរបបអនុវត្តន៍ជំនួយឧបត្ថម្ភរបស់សហគមន៍ផ្តល់ជំនួយ ដើម្បី ផ្តល់ប្រាក់ឧបត្ថម្ភ និង ប្រាក់បៀវត្សរ៍បន្ថែម ដល់និយោជិតរាជរដ្ឋាភិបាល ។

## ផ្នែក គ : ការរៀបចំភាពស៊ីសង្វាក់

១. រាជរដ្ឋាភិបាលកម្ពុជា និង សហគមន៍ផ្តល់ជំនួយ អនុម័តប្រើប្រាស់ផែនការអភិវឌ្ឍន៍ជាយុទ្ធសាស្ត្ររួមរបស់រាជរដ្ឋាភិបាល កម្ពុជា ជាក្របខ័ណ្ឌរួមសំរាប់ការធ្វើផែនការ ODA ។

ក) សកម្មភាពរបស់សហគមន៍ផ្តល់ជំនួយ ត្រូវបានរៀបចំឱ្យស៊ីសង្វាក់គ្នាជាមួយនឹងយុទ្ធសាស្ត្រ និង គោលនយោ-បាយរបស់រាជរដ្ឋាភិបាល និង ស្របទៅតាមក្របខ័ណ្ឌសំរាប់វិស័យឯកជន និងការចូលរួមរបស់សង្គមស៊ីវិល ។

២. របៀបរបបអនុវត្តន៍របស់សហគមន៍ផ្តល់ជំនួយ ត្រូវបានធ្វើសុខដុមនីយកម្មជាមួយនឹងសមាសធាតុរួមនៃខូបកម្ម-វិធី/គំរោង:

ក) រាជរដ្ឋាភិបាល
ដាក់ចេញនូវគោលការណ៍ណែនាំប្រតិបត្តិថ្នាក់ជាតិសំរាប់សកម្មភាពសហប្រតិបត្តិការលើ កិច្ចអភិវឌ្ឍន៍ដែលគ្រប់ដណ្តប់លើគ្រប់សមាសភាពទាំងអស់នៃខូបកម្មវិធី/គំរោង ។

ខ) ជំនួយអភិវឌ្ឍន៍ ត្រូវបានចែកជូនកាន់តែច្រើនឡើង ដោយអនុលោមទៅតាមអាទិភាពរបស់រាជរដ្ឋា-ភិបាល សង្គមស៊ីវិល និង វិស័យឯកជន ។

៣. សហគមន៍ជំនួយ ប្រើប្រាស់ ប្រព័ន្ធ នីតិវិធី និង របៀបរបបអនុវត្តន៍ របស់រាជរដ្ឋាភិបាល កាន់តែច្រើនឡើង តាមការចាំបាច់ :

ក) ដៃគូអភិវឌ្ឍន៍ ព្យាយាមកាត់បន្ថយសមាមាត្រ ODA ដែលមិនឆ្លងកាត់ថវិកាជាតិ ហើយ រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាធ្វើសមាហរណកម្ម ODA ចូលក្នុងថវិកាជាតិ ។

ខ) ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ត្រូវបានពង្រឹង និង ពង្រីក ។

គ) ការបែងចែក និង ការប្រើបាស់ធនធាន ODA គឺមានតម្លាភាព និង មានការទទួលខុសត្រូវ ។

២៥. ដំណើរការគាំទ្រទៅវិញទៅមកទាំងអស់នេះ ត្រូវបានប្រមូលដាក់បញ្ចូលគ្នា ក្នុងរយៈពេល ៦ ខែចុងក្រោយនេះ ។ អូស្ត្រាលី ជប៉ុន ប្រព័ន្ធសហប្រជាជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោក បានជួយ ឧបត្ថម្ភគាំទ្រដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើការគ្រប់គ្រងសិក្ខាសាលាថ្នាក់ជាតិនិងថ្នាក់តំបន់ ដែលត្រូវរៀបចំ ឡើងជាបន្តបន្ទាប់ ក្រោមកិច្ចសហការរវាង រាជរដ្ឋាភិបាល និង សហគមន៍ផ្តល់ជំនួយ ដើម្បីវាយតំលៃស្ថានភាព បច្ចុប្បន្ននៃការអនុវត្តន៍សុខដុមនីយកម្ម (ដោយប្រើប្រាស់កំរងសំណួរទាក់ទងនឹង **OECD-DAC** ធ្វើជាមូលដ្ឋានសំរាប់ការវាយតំលៃ) និង រៀបចំឯកសារកំណត់តួនាទីនិងការទទួលខុសត្រូវ សំរាប់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងសហគមន៍ផ្តល់ជំនួយ ។ លទ្ធផលនៃកិច្ចប្រជុំចុងក្រោយ ដែលរៀបចំធ្វើឡើងនៅឯក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នាថ្ងៃទី ២៦ និងទី ២៧ ខែតុលា គឺការរៀបចំផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម និង ការរៀបចំភាព ស៊ីសង្វាក់របស់ រាជរដ្ឋាភិបាលកម្ពុជា (មានសង្ខេបជូនក្នុងតារាង ៦.២) (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០០៤) ។ ការអនុម័តជា ផ្លូវការលើឯកសារនេះ នឹងត្រូវធ្វើឡើង មុនកិច្ចប្រជុំក្រុមពិគ្រោះយោបល់ ដែលនឹងប្រព្រឹត្តទៅនៅ ដើមខែ ធ្នូ ឆ្នាំ ២០០៤ ។ នេះគឺជាសញ្ញាមួយនៅក្នុងឆ្នាំនេះ ដែលបង្ហាញអោយឃើញថា របៀបវារៈសុខដុមនីយកម្ម និងការរៀបចំភាពស៊ីសង្វាក់ ត្រូវបានទទួលស្គាល់ដោយថ្នាក់ដឹកនាំនយោបាយនៅកម្ពុជា[៧] ។

## គ. ចលនាឆ្ពោះទៅរកការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក : របៀបវារៈនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ ២០០៥

### *ការប្តេជ្ញាចិត្តជាប្រចាំចំពោះយុទ្ធសាស្ត្ររយៈពេលខ្លីរបស់រាជរដ្ឋាភិបាលកម្ពុជាដែលផ្តោតលើភាពក្រីក្រ*

២៦. ប្រការសំខាន់បំផុតគឺថា ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំតែមួយគត់ដែលផ្តោតលើភាពក្រីក្រ (២០០៦-២០១០) ត្រូវបានដើរតាមនៅក្នុងការអនុវត្តន៍ ជាក់ស្តែង ។ ដូចបាន លើកឡើងខាងលើ វិធីសាស្ត្រ "យុទ្ធសាស្ត្រមួយ" ត្រូវបានអនុម័តនៅក្នុងកំរិតខ្ពស់បំផុត ដោយទាំងរាជរដ្ឋាភិបាល និងទាំងអ្នកផ្តល់ជំនួយ ។ ប៉ុន្តែក្នុងកំរិតប្រតិបត្តិការ ក្បើរដំណើលនៃកម្មវិធីអ្នកផ្តល់ជំនួយជាកលាក់ស្របគ្នា នៃការជួយទ្រទ្រង់ដល់ការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ គឺថានៅក្រសួងផែនការនៅមានការបែងចែកពលកម្មដែល បែងចែកភារៈកិច្ចដោយឡែកនិងដាច់ពីគ្នាសំរាប់គំរោងផែនអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច យុទ្ធសាស្ត្រជាតិកាត់ បន្ថយភាពក្រីក្រ និង គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

ថ្នាក់ដឹកនាំនយោបាយជាន់ខ្ពស់ និង សហគមន៍ ផ្តល់ជំនួយ ចាំបាច់ត្រូវធ្វើការជាមួយក្រសួងផែនការដើម្បី ដោះស្រាយស្ថានភាពនេះ និង ដើម្បីបង្កើតមូលដ្ឋាន ចាំបាច់សំរាប់ជំរុញភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និង ដើម្បីគ្រប់គ្រងរួមគ្នាលើធនធានរួមរបស់អ្នកផ្តល់ជំនួយ នៅក្រោមយុទ្ធសាស្ត្រឯកភាពជាតិមួយដែលផ្តេត លើភាពក្រីក្រ ។ គេឃើញមានលេចឡើងនូវការយល់ស្របគ្នា មួយ ដែលថា អ្វីដែលចាំបាច់នោះ គឺទំរង់ ខ្លះនៃ "SWAp សំរាប់ការធ្វើផែនការ" ទោះបីជាទំរង់នេះមិនទាន់ត្រូវ បានបង្កើតឡើងក្តី[៥៨] ។ ក្នុងការចាប់ ផ្តើមរៀបចំថវិកា (ការវិនិយោគ និង ចំនួននៃការវិនិយោគ) អោយស៊ីសង្វាក់ជា មួយនឹងផែនការ និង ការ រៀបចំការគ្រប់គ្រងចំណាយសាធារណៈជាក់ស្តែង អោយស៊ីសង្វាក់ជាមួយនឹងថវិកា ប្រការសំខាន់ គឺ ត្រូវ កំណត់តួនាទី និង ទំនាក់ទំនងនៅក្នុងចំណោម ក្រសួងពាក់ព័ន្ធ ក្រសួងផែនការក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ព្រមទាំងកំណត់ពីទំនាក់ទំនងរវាងផែនការ និងការបង្វែរទិសដៅលំហូរវិនិយោគឆ្ពោះទៅរក សកម្មភាព នៅជនបទនិងសកម្មភាពជួយដល់ប្រជាពលរដ្ឋក្រីក្រ ជាពិសេស តាមរយៈ កម្មវិធីវិនិយោគសាធារណៈ ។

### *ការដឹកនាំរបស់រាជរដ្ឋាភិបាលលើការប្រើជំនួយបច្ចេកទេស និង ជំនួយមានចំណង*

២៧. ទំនិញនិងសេវាកម្មដែលត្រូវបានធ្វើលទ្ធកម្មដោយប្រើ ODA ត្រូវពឹងផ្អែកលើលក្ខណៈវិនិច្ឆ័យ អភិវឌ្ឍន៍ ដ៏តឹងរ៉ឹង ដោយសង្កត់ធ្ងន់លើការទទួលផលប្រយោជន៍ជាអតិបរិមា ពីប្រាក់ដែលបានចំណាយដើម្បី ឆ្លើយតបទៅ នឹងតំរូវការដែលបានកំណត់ ។ អ្នកផ្តល់ជំនួយកំពុងកាន់តែដកថយពីជំនួយមានចំណង ពោលគឺ រាជរដ្ឋាភិបាលនិង សហគមន៍អ្នកផ្តល់ជំនួយរួមគ្នាចាំបាច់ត្រូវរក្សាសម្ពាធលើចំណុចនេះ (រាជរដ្ឋាភិបាល កម្ពុជា ឆ្នាំ ២០០៤) ។

២៨. លើសពីនេះទៀត សហគមន៍ផ្តល់ជំនួយ ចាំបាច់ត្រូវសហការជាមួយនឹងរាជរដ្ឋាភិបាល ដើម្បីបង្កើត ឡើងនូវគោលការណ៍មួយចំនួន ដែលដឹកនាំវិធីសាស្ត្ររួមក្នុងការកសាងសម្ថភាព និង ការប្រើប្រាស់ជំនួយ បច្ចេកទេស ។ គេចាំបាច់ត្រូវមានការប្តេជ្ញាចិត្ត ដែលត្រូវបានបង្ខំឱ្យអនុវត្តដោយសម្ពាធរបស់សមភាគី និង ស្ថាប័នជាដៃគូ រាជរដ្ឋាភិបាល ដែលថា គោលបំណងចំបងនៃជំនួយបច្ចេកទេសគឺជាការផ្ទេរជំនាញរយៈពេល វែង (ជាជាង ការបំពេញចន្លោះប្រហោងជំនាញ) ។ ជាការចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ទៅ លើការអភិវឌ្ឍន៍សមត្ថភាព ស្ថាប័នផង និង សមត្ថភាពបុគ្គលផង ។ ក្នុងរយៈពេលខ្លីចំពោះមុខ អ្នកផ្តល់ ជំនួយចាំបាច់ត្រូវផ្តល់ការឯកភាពលើ ក្របខ័ណ្ឌការងារជំនួយបច្ចេកទេស ជាមួយរាជរដ្ឋាភិបាល និង ដោយ

ពិគ្រោះយោបល់ជាមួយអ្នកផ្ដល់ជំនួយ ដទៃទៀតនៅក្នុងវិស័យនេះ អនុម័តប្រើប្រាស់យុទ្ធវិធីអភិវឌ្ឍន៍ស្ថាប័ន ដែលយកចិត្តទុកដាក់ទៅលើទស្សនាទាននិង បំណងប្រាថ្នារបស់កម្ពុជា ជាជាង "គំរូអនុវត្តន៍ ឬបទពិសោធន៍ល្អ" ក្នុងបរិបទអន្តរជាតិ ព្រមទាំងរៀបចំ យុទ្ធសាស្ត្រសំរាប់ដោះស្រាយការិតទំនុកចិត្តដ៏លើសលុបទៅលើទីប្រឹក្សាបរទេស ជាបន្ទាន់ ។ ក្នុងរយៈពេលពី មធ្យមទៅវែងយុទ្ធសាស្ត្រនេះ នឹងវិវត្តទៅជាកម្មវិធីមួយដែលមានពេលវេលាកំណត់ច្បាស់លាស់សំរាប់កាត់បន្ថយ ទីប្រឹក្សាបរទេសជាជំហានៗ រហូតដល់អស់ ហើយដាក់បញ្ចូលទីប្រឹក្សាកម្ពុជាដែលមានសមត្ថភាពសមស្របជា ជំនួសវិញ ។ ការអនុវត្តន៍កិច្ចការនេះ ចាំបាច់ត្រូវមានយុទ្ធវិធីសមស្របសំរាប់កាត់បន្ថយប្រាក់បៀវត្សរ៍បន្ថែម ពិសេសនិងផលប្រយោជន៍នានា ដែលសហគមន៍ផ្តល់ជំនួយ ប្រើប្រាស់សំរាប់ឧបត្ថម្ភមន្ត្រីរាជការធ្វើការក្នុងកម្មវិធី ដែលស្ថិតក្រោមការឧបត្ថម្ភរបស់សហគមន៍ផ្តល់ជំនួយ ។ ថវិកា ដែលបានពីការកាត់បន្ថយប្រាក់ឧបត្ថម្ភមន្ត្រី រាជការក្នុងកម្មវិធីរបស់ម្ចាស់ជំនួយនេះ និង បានពីការកាត់បន្ថយទីប្រឹក្សាបរទេស អាចយកមកឧបត្ថម្ភមន្ត្រី រាជការក្នុងក្រុមអាទិភាព តាមរយៈប្រព័ន្ធទូទាត់មួយដែលមានតម្លាភាព ដោយសារក្រុមនេះ ត្រូវបានចាត់ទុកថា មានសារៈសំខាន់ក្នុងការធានាអោយមានការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋក្រីក្រ ប្រកបដោយប្រសិទ្ធិភាព ។ កម្មវិធីនេះ ត្រូវរៀបចំឡើង នៅតាមក្រសួងនីមួយៗ ហើយ ត្រូវមានទំនាក់ទំនងជាមួយ នឹងអនុវត្តន៍កម្មវិធី កំណែទំរង់រួមមួយសំរាប់ក្រសួងពាក់ព័ន្ធ (រួមទាំងការគ្រប់គ្រងល្អលើការងាររបស់ មន្ត្រីរាជការដែលមានប្រាក់ បៀវត្សរ៍ខ្ពស់ទាំងនោះផងដែរ) ។ ជំនួយគាំទ្រប្រភេទនេះ ត្រូវអនុវត្តរហូតដល់ពេលដែលរាជរដ្ឋាភិបាលមាន លទ្ធភាពរកបានចំណូលក្នុងចំនួនមួយដែលអាចធានាអោយមន្ត្រីរាជការ ទាំងអស់មានបៀវត្សរ៍គ្រប់គ្រាន់សំរាប់ទ្រទ្រង់ ជីវភាពរស់នៅរបស់ខ្លួន (ពី ១០-១៥ឆ្នាំខាងមុខ) និង អាស្រ័យទៅលើការប្តេជ្ញាចិត្តសំរាប់រយៈពេលវែងរបស់ រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តន៍កំណែទំរង់ស្ថាប័ននេះ។

## *ការបត់បែនតាមកាលទេសៈរបស់សហគមន៍ផ្តល់ជំនួយ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល និងតំរូវការ បន្ទាន់របស់កម្ពុជា*

២៩. នៅក្នុងជំពូកទី ១ មានការកត់សំគាល់ថា កំណើនសេដ្ឋកិច្ច ទំនងជាមានការធ្លាក់ចុះវិញច្រើនក្នុងចន្លោះ ឆ្នាំ ២០០៤-២០០៥ ហើយ ទំនងជាអាចឡើងដល់ចំណុចដៅ ៦-៦,៥ ភាគរយ ដូចមានចែងក្នុងយុទ្ធសាស្ត្រជាតិកាត់ បន្ថយភាពក្រីក្រវិញ នៅក្រោយឆ្នាំ ២០០៩ ។ ក្នុងដំណាក់កាលអន្តរកាលនេះ

ជាការចាំបាច់ សហគមន៍ផ្តល់ជំនួយ ត្រូវជួយទប់ស្កាត់ការធ្លាក់ចុះដំបូងនៃអត្រាកំណើនសេដ្ឋកិច្ចនេះ ហើយបន្ទាប់មក ត្រូវស្តារកំណើននេះឡើងវិញអោយបានឆាប់ និង អោយបានច្រើនតាមដែលអាចធ្វើបាន ។ ក្នុងអំឡុងឆ្នាំ ១៩៩៩-២០០៥ ការហូរចូលនូវជំនួយដែលមាន ជាមធ្យម ១២%នៃផលិតផលសរុបក្នុងស្រុក បានជួយដល់ការវិនិយោគក្នុងស្រុក និង ជំរុញដល់សកម្មភាពសាងសង់ (មូលនិធិរូបិយវត្ថុអន្តរជាតិ ឆ្នាំ ២០០៤) ។ ប្រហែលពាក់កណ្តាលនៃជំនួយដែលហូរចូលមកនេះ គឺជា ជំនួយ ឧបត្ថម្ភ តាមរូបភាពគំរោង ដែលស្ថិតក្រោមការឧបត្ថម្ភរបស់ម្ចាស់ជំនួយ និង ជំនួយបច្ចេកទេស ។ ជំនួយទាំងអស់ នេះ ស្ថិតនៅក្រៅខ្ទង់ថវិកា ។ ជំនួយដែលទទួលបាននេះ ត្រូវបានប្រើប្រាស់សំរាប់ វិស័យសុខាភិបាលនិងអប់រំ (២៤%) កសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (២៣%) និង ពង្រឹងស្ថាប័នសេដ្ឋកិច្ចនិងសង្គមកិច្ច (១៥%) ។ វិស័យកសិកម្ម និង រុក្ខាប្រមាញ់ ទទួលបានតែ ៨%នៃជំនួយទាំងអស់នេះប៉ុណ្ណោះ ។

៣០. ឥឡូវនេះ ដល់ពេលវេលាពិនិត្យវាយតំលៃលើការបែងចែកជំនួយបរទេសនេះ ដោយផ្តោតជាសំខាន់ទៅ លើការរក្សាស្ថិរភាពនិងបង្កើនអត្រាកំណើនសេដ្ឋកិច្ច និង ការធានាឱ្យកំណើននេះមានទំនាក់ទំនងរឹងមាំជាមួយនឹង ការកាត់បន្ថយភាពក្រីក្រ ។ ក្នុងរយះពេលកន្លងមក ដោយសារសមត្ថភាពរដ្ឋបាលមានភាពទន់ខ្សោយ ODA មួយផ្នែកធំ ត្រូវបានបញ្ជូន តាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេស (ដែលមាន ៥០% នៃជំនួយដែលទទួលបាន ទាំងអស់ក្នុងអំឡុងឆ្នាំ ១៩៩៩-២០០៣) ។ ទោះជាយ៉ាងណាក៏ដោយ ឥឡូវនេះ ជាពេលវេលាល្អដែលត្រូវធ្វើការ បែងចែក ODA ជាថ្មីឡើងវិញ ដើម្បីដោះស្រាយបញ្ហាភាពក្រីក្រដោយផ្ទាល់ និង ជំរុញអោយមានកំណើនសេដ្ឋកិច្ច រយះពេលវែង ។ តំរូវការចំបងអោយមានការបង្កើនចំណូលនៅជនបទ ជំរុញអោយមានការស្វែងយល់អោយបានកាន់តែ ប្រសើរលើឧបសគ្គដែលរាំងដល់កំណើនសេដ្ឋកិច្ចជនបទ និង កិច្ចអភិវឌ្ឍន៍ ជាពិសេស នៅក្នុងវិស័យកសិកម្ម ដែលមានអត្រាកំណើនទាប ហើយសក្តានុពលភាពរបស់វិស័យនេះ មិនទាន់បានយកទៅប្រើប្រាស់នៅឡើយ ។ តំរូវការបន្ទាន់ជាជំហានទី ១ គឺ យុទ្ធសាស្ត្រកសិកម្ម សំរាប់កំណត់អំពីឧបសគ្គដែលរាំងដល់កំណើនកសិកម្ម និង សំរាប់ជំរុញអោយមានការព្រមព្រៀងគ្នាជាទូទៅលើគោលនយោបាយចាំបាច់ និង ការវិនិយោគ ដែលជាតំរូវការសំរាប់ជំរុញកំណើនកសិកម្ម ។

## ឃ. ពង្រឹងក្រុមការងារបច្ចេកទេស

៣១. ក៏រិតតាមផ្នែកគឺជានិងនឹងស្ថិតនៅជាកំរិតដ៏សំខាន់មួយក្នុងការកែលំអការពិភាក្សារវាងរាជរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយ និង ប្រសិទ្ធិភាពជំនួយ ។ ដូច្នេះ ក្រុមការងារបច្ចេកទេសដែលត្រូវបានរៀបចំឡើងវិញគឺមានតួនាទី ដ៏សំខាន់ ។ ប៉ុន្តែ ការធ្វើឱ្យក្រុមការងារបច្ចេកទេសទាំងនេះដំណើរការបានល្អទាមទារអោយមានការយកចិត្តទុកដាក់ រួមគ្នាលើបញ្ហាមួយចំនួនដូចខាងក្រោម:

- *ធានាឱ្យបាននូវការចូលរួមក្នុងកំរិតសមស្រប ទាំងពីខាងរាជរដ្ឋាភិបាលនិងទាំងពីខាងអ្នកផ្តល់ជំនួយ។* លើកលែងតែករណីតិចតួចប៉ុណ្ណោះ កាធ្វើឱ្យក្រុមការងារបច្ចេកទេសដំណើរការបានជាយន្តការមួយ សំរាប់ការពិភាក្សាជាបន្តបន្ទាប់ជាប្រចាំ ទាមទារអោយអ្នកចូលរួមក្នុងក្រុមការងារបច្ចេកទេសគួរគឺជា បុគ្គលិកកំរិតបច្ចេកទេសជាន់ខ្ពស់ មិនមែនជាកំរិតនយោបាយឡើយ (រដ្ឋមន្ត្រី ឬ ឯកអគ្គរដ្ឋទូត / ប្រធានបេសកកម្ម) ។ អ្នកផ្តល់ជំនួយនិងអង្គការក្រៅរដ្ឋាភិបាលគួរខិតខំបញ្ជូនប្រតិភូបន្ថែមទៀត ទៅចូលរួមប្រជុំ ហើយគេគួរខិតខំធានាអោយបានថាជនដដែលចូលរួមប្រជុំក្នុងពេលនីមួយៗ ។ ប្រការ នេះគឺមានលក្ខណៈងាយស្រួលក្នុងការនិយាយជាងក្នុងការធ្វើជាក់ស្តែង ដោយសារការិយាល័យរបស់ អ្នកផ្តល់ជំនួយមានទំហំតូច និងដោយសារធនធានមានកំរិតរបស់រាជរដ្ឋាភិបាល ក៏ដូចជារបស់អង្គការ ក្រៅរដ្ឋាភិបាល សំរាប់ការងារបែបនេះ ។ ប្រការនេះបង្ហាញថា គេអាចមានការដោះដូររវាង ប្រសិទ្ធិភាពរបស់ក្រុម និង ចំនួនច្រើនដែលមាននាពេលបច្ចុប្បន្ននេះ ។

- *សមាជិកភាពដែលបង្កើតតួនាទីរបស់តួអង្គជាតិក្រៅរដ្ឋាភិបាលដែលបង្កើនការចូលរួមរបស់អង្គការ សង្គមស៊ីវិល និង* សមាគមវិស័យឯកជន ក្នុងការពិភាក្សានិងដំណើរការរបស់ រាជរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយ ។ ការជ្រើសរើសដំណាងស្របច្បាប់ពីក្នុងចំណោមក្រុមដ៏ធំ និងភាគច្រើនខុសៗគ្នានៃតួអង្គក្រៅរដ្ឋាភិបាលទាមទារឱ្យមានការពិចារណានិងពេលវេលាច្រើន។

- *ក្របខ័ណ្ឌការងារច្បាស់លាស់និងដែលមានលក្ខណៈស្តង់ដារ និង គោលការណ៍ភាពជាដៃគូ* ដើម្បីបង្កើតរចនាសម្ព័ន្ធការងាររបស់ក្រុមការងារបច្ចេកទេស ។ ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM TWG) បានបង្កើតឡើងនូវគោលការណ៍ដ៏ល្អប្រសើរនៃភាពជាដៃគូ ដែលអាចធ្វើជាគំរូសំរាប់ក្រុមការងារបច្ចេកទេសដទៃទៀត ។ កិច្ចព្រមព្រៀង

បង្កើតទាំងនេះ និង វិន័យរបស់សមាជិកទាំងអស់ គួរធានាអោយបានថាគោលដៅរបស់ក្រុមគឺផ្តោតលើការកំណត់បញ្ហាតាម វិស័យ និង វិធីកែលំអគោលនយោបាយតាមវិស័យ ការធ្វើផែនការ ការធ្វើថវិការ និង ការតាមដាន និងវាយតម្លៃ, និង មិនជាប់គាំងលើត្រឹមតែការចែករំលែកព័ត៌មាន និង ការពណ៌នាគំរោងនីមួយៗ ប៉ុណ្ណោះឡើយ ។

- *ការបង្កើត និង រក្សាគោលបំណងសំរាប់ក្រុមការងារបច្ចេកទេស ។* វិធីមួយដើម្បីអនុវត្តចំណុចនេះ គឺការផ្តល់ជូនដល់ក្រុមការងារបច្ចេកទេស នូវការទទួលខុសត្រូវផ្លូវការលើសមាសភាគនៅក្នុងវដ្តធ្វើ ផែនការនិងធ្វើថវិការប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយៈ ឧទាហរណ៍ ដោយតំរូវអោយក្រុម ការងារបច្ចេកទេសនីមួយៗរៀបចំការពិនិត្យប្រចាំឆ្នាំ លើវឌ្ឍនៈភាពតាមវិស័យ ជាធនធានបញ្ចូល មួយចំពោះការពិនិត្យការអនុវត្តដែលដឹកនាំដោយក្រសួងផែនការ និង/ឬ របាយការណ៍របស់រាជ រដ្ឋាភិបាលសំរាប់កិច្ចប្រជុំពិគ្រោះយោបល់ ។

៣២. ក្រុមការងារបច្ចេកទេសចំណុចរួមដ៏សមស្របនៃកំណែទំរង់ដទៃទៀតជាច្រើន ដែលបានលើកឡើងនៅ ក្នុងផ្នែកនេះៈ បានន័យថា វិធានការទាំងនេះ ដែលរួមមានការវាយតម្លៃរួមគ្នា គោលការណ៍សំរាប់ការធ្វើ សុខុដុមនីយកម្មនិងការតម្រង់ជួរជំនួយបច្ចេកទេស និងវិធីសាស្ត្រកសាងសមត្ថភាព ការតាមដានសូចនាករ អនុវត្តន៍ទាំងរបស់រាជរដ្ឋាភិបាលនិងទាំងរបស់អ្នកផ្តល់ជំនួយ និង ភាពជាដៃគូពហុអ្នកផ្តល់ជំនួយឬដៃគូនាំមុខ/ស្ងៀមស្ងាត់ - គឺទំនងជានឹងចាប់ដុះឬសមុនគេនៅកំរិតតាមវិស័យ តាមរយៈវេទិកានៃក្រុមការងារបច្ចេកទេស ពាក់ព័ន្ធ ។ ប្រសិនបើក្រុមការងារបច្ចេកទេស ត្រូវប្រើប្រាស់សក្តានុពលភាពនេះ ប្រការសំខាន់ គឺរាជរដ្ឋាភិបាល ត្រូវទទួលស្គាល់សារៈសំខាន់របស់ក្រុម ហើយ ត្រូវមានភាពជាម្ចាស់លើក្រុមនេះ ។ កត្តានេះ តំរូវអោយមានការខិតខំ ប្រឹងប្រែងទាំងពី ខាងរាជរដ្ឋាភិបាល (ដែលត្រូវការពារការដឹកនាំជាវិជ្ជមាននៅក្នុងការពិភាក្សាវែកញែកលើ គោលនយោបាយតាមវិស័យ តាមរយៈក្រុមការងារបច្ចេកទេស) និង ខាងសហគមន៍ផ្តល់ជំនួយ (ដែលត្រូវរៀន សូត្រអនុវត្តវិន័យ និង ផ្តល់ឱកាសអោយរាជរដ្ឋាភិបាលអភិវឌ្ឍសមត្ថភាពដឹកនាំ) ។

*កាត់បន្ថយចំណាយប្រតិបត្តិការតាមរយៈភាពជាដៃគូរវាងអ្នកផ្តល់ជំនួយនិងអ្នកផ្តល់ជំនួយ*

៣៣. គេឃើញមានកំណែទំរង់សំខាន់ៗមួយចំនួនដែលអ្នកផ្តល់ជំនួយអាចធ្វើបាន ដើម្បីកែលំអប្រសិទ្ធិ-ភាព នៃកម្មវិធីជំនួយរបស់ខ្លួនខ្លួនឯង ដោយមិនចាំបាច់រង់ចាំដល់មានការដឹកនាំកំរិតខ្ពស់របស់រាជរដ្ឋាភិបាល ឬ ចាំដល់មានអ្នកផ្តល់ជំនួយចំនួនច្រើនឯកភាពគ្នាលើវិធីសាស្រ្តតាមវិស័យទាំងមូលនោះឡើយ ។ អ្នកផ្តល់ជំនួយដែលបង្កើត ការយល់ដឹងរួមគ្នា និង មូលដ្ឋានទំនុកចិត្តគ្នារវាងគ្នានិងគ្នា គួរកាន់តែខិតខំឈានទៅកាន់ភាពជាដៃគូអ្នកផ្តល់ ជំនួយនាំមុខ/ស្ងៀមស្ងាត់ ពោលគឺ អ្នកផ្តល់ជំនួយ **ក** ផ្តល់ជូនអ្នកផ្តល់ជំនួយ **ខ** នូវការទទួលខុសត្រូវសំរាប់គ្រប់ គ្រងការជួយឧបត្ថម្ភរបស់អ្នកផ្តល់ជំនួយ **ក** ចំពោះវិស័យឬគំរោងមួយ ដោយផ្តល់មូលនិធិនិងដោយគ្រាន់តែសុំអោយមានការរាយការណ៍ជាមូលដ្ឋានទៀងទាត់ខ្លះៗ និង ការពិនិត្យរួមលើសកម្មភាពនិងលទ្ធផល ដែលផ្អែកលើអ្វីដែល បានព្រមព្រៀងគ្នាពីពេលមុនតែប៉ុណ្ណោះ ។ ការព្រមព្រៀងគ្នាបែបនេះមានសក្តានុពលក្នុងការកាត់បន្ថយចំណាយ ប្រតិបត្តិការទាំងសំរាប់រាជរដ្ឋាភិបាល និងទាំងសំរាប់អ្នកផ្តល់ជំនួយពាក់ព័ន្ធ និង កាត់បន្ថយយ៉ាងច្រើននូវការមិន ឯកភាពគ្នានៃសម្លេងរបស់អ្នកផ្តល់ជំនួយ ដែលរាជរដ្ឋាភិបាលត្រូវតែស្តាប់ ។

## ខ. ពិនិត្យតាមដានប្រសិទ្ធិភាពជំនួយ និង ការអនុវត្តរបស់សហគមន៍ផ្តល់ជំនួយ

### *ពិនិត្យតាមដាន និង វាយតំលៃជំនួយ ឱ្យកាន់តែមានប្រសិទ្ធិភាព និង ទៅតាមចេតនាយមួយដែលជួយពង្រឹងសមត្ថភាព*

៣៤. ដោយមានករណីលើកលែងដ៏តិចតួច អ្នកផ្តល់ជំនួយជាទូទៅពុំបានចំណាយពេលវេលាឬធនធានគ្រប់គ្រាន់ លើការវាយតម្លៃដ៏ហ្មត់ចត់លើជំនួយដែលខ្លួនផ្តល់ជូនដល់កម្ពុជា ។ គេឃើញមានភាពចាំបាច់នឹងធានាអោយបានថា ការវាយតម្លៃ ក្រោយពេលបានដាក់ចេញ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ និង ត្រូវបានចែកផ្សាយយ៉ាងសកម្ម ជូនដល់រាជរដ្ឋាភិបាល សង្គមស៊ីវិល និង ដៃគូអភិវឌ្ឍន៍ដទៃទៀត (ជាពិសេសដៃគូអភិវឌ្ឍន៍ទាំងឡាយដែលធ្វើប្រតិបត្តិការនៅក្នុងវិស័យឬតំបន់ភូមិសាស្រ្តដូចគ្នា) ហើយសំខាន់បំផុតនោះ គឺថាអនុសាសន៍នៃការវាយតម្លៃ ទាំងនោះនាំអោយមានសកម្មភាពជាក់ស្តែងដោយអ្នកផ្តល់ជំនួយ ។

៣៥. ជាបឋម វាគឺជាសារៈសំខាន់ដែលថា ការវាយតម្លៃទាំងនោះត្រូវបានគេយល់ថាគឺជាល័ក្ខខ័ណ្ឌមួយសំរាប់ ទីភ្នាក់ងារអភិវឌ្ឍន៍ (ដែលចាំបាច់ត្រូវបង្ហាញជូនដល់អ្នកបង់ពន្ធ ឬ ក្រុមប្រឹក្សាភិបាលរបស់ខ្លួន

ថាធនធាន ODA ត្រូវបានប្រើប្រាស់ក្នុងលក្ខណៈសមស្របនិងមានប្រសិទ្ធិភាព) ។ ប៉ុន្តែ ការវាយតម្លៃទាំងនេះក៏គួរត្រូវបានប្រកាន់ យកជាមធ្យោបាយមួយសំរាប់បណ្តុះគោលការណ៍នៃការទទួលខុសត្រូវ (ឡើងទៅលើចំពោះអ្នកដឹកនាំនយោបាយ និង ចុះមកក្រោម ចំពោះប្រជាពលរដ្ឋ) និង បណ្តុះការធ្វើសេចក្តីសំរេចចិត្តដែលផ្អែកលើភស្តុតាងនៅក្នុងចរន្តនៃគោលនយោបាយជាតិ ការធ្វើផែនការ និង ប្រព័ន្ធថវិការ ។ នៅទីណាដែលអាចធ្វើបាន អ្នកផ្តល់ជំនួយ/អ្នក អោយប្រាក់កំចីគួរខិតខំធ្វើរូបមន្តវាយតម្លៃរបស់ខ្លួនជាលំហាត់រួម (រាជរដ្ឋាភិបាល និង ដៃគូ) ដែលគួរបង្កើនកាលានុវត្តភាពសំរាប់សម ភាគីរាជរដ្ឋាភិបាលបានរៀនសូត្រពីគោលការណ៍និងជំនាញខាងវាយតម្លៃ និង ធ្វើអោយកាន់តែស៊ីជំរៅនូវភាពជាម្ចាស់ជាតិនៃរបកគំហើញនិងអនុសាសន៍នៃការវាយតម្លៃ ។

៣៦. ប៉ុន្តែ ការវាយតម្លៃបែបនេះគឺជាការទាមទារបន្ថែមលើពេលវេលានិងធនធានដ៏មានកំរិតរបស់សមភាគី រាជរដ្ឋាភិបាល ។ ប្រការនេះគឺមានលក្ខណៈពិតប្រាកដជាពិសេសប្រសិនបើពុំមានការកាត់បន្ថយសមស្របលើចំនួន នៃការវាយតម្លៃជាឧបតោភាគី ដែលនឹងក្លាយជាករណីមួយ ប្រសិនបើអ្នកផ្តល់ជំនួយម្នាក់ៗ ឬ ស្ថាប័នផ្តល់ជំនួយនីមួយៗ នៅតែទាមទារអោយមានការវាយតំលៃ ដោយផ្តោតទៅលើគំរោងទ្វេភាគីនោះ ។ គេអាចប្រកាន់យក សកម្មភាពមួយចំនួនដើម្បីជួយសរុះសំរួលភាពចាំបាច់នៃការវាយតម្លៃដ៏ហ្មត់ចត់ ជាមួយនឹងភាពចាំបាច់ក្នុងការកាត់ បន្ថយចំណាយប្រតិបត្តិការចំពោះរាជរដ្ឋាភិបាល ។ ការវាយតម្លៃចំនួនតិចប៉ុន្តែមានអត្ថន័យជាងជាអត្ថប្រយោជន៍ មួយបន្ថែមទៀតនៃការបោះជំហានឆ្ពោះទៅកាន់ការប្រមូលផ្តុំធនធាន ODA ផ្តោតទៅលើគំរោងធំៗនិងរយៈវែង ចំនួនតិច និង គំរោងពហុអ្នកផ្តល់ជំនួយច្រើនថែមទៀត ។

៣៧. សហគមន៍ផ្តល់ជំនួយ ក៏គួរតែប្រើប្រាស់សកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ និង ក្រុមហ៊ុនទីប្រឹក្សា នៅកម្ពុជា អោយធ្វើការងារពិនិត្យតាមដាននិងវាយតំលៃជំនួយនេះ ។ សហគមន៍នេះ អាចផ្តល់ប្រូបគល់សិទ្ធិអោយអ្នកស្រាវជ្រាវកម្ពុជា ធ្វើការវាយតំលៃដោយឯករាជ្យលើ គំរោង កម្មវិធី និង គំរូនានាដែលស្ថិតនៅក្រោមជំនួយ **ODA** ។ ការធ្វើដូច្នេះ នឹងជួយពង្រឹង និង ពង្រីកសមត្ថភាពដល់ក្រុមនៅខាងក្រៅរាជរដ្ឋាភិបាល ដើម្បីជំរុញអោយ រាជរដ្ឋាភិបាល និង សហគមន៍ផ្តល់ជំនួយ ទទួលខុសត្រូវចំពោះការគ្រប់គ្រងជំនួយ[៥] ។

## *តាមដានការអនុវត្តន៍របស់សហគមន៍ផ្តល់ជំនួយ និង ការវឌ្ឍនភាពលើសុខដុមនីយកម្ម និង ការរៀបចំ ភាពស៊ីសង្វាក់*

៣៨. សហគមន៍អ្នកផ្តល់ជំនួយធ្វើការទាមទារស្របច្បាប់លើរាជរដ្ឋាភិបាល ដើម្បីកំណត់អោយបានថា ធនធាន ជំនួយដែលខ្លួនបានផ្តល់ គឺត្រូវបានប្រើប្រាស់ក្នុងលក្ខណៈមួយដែលមានតម្លាភាពនិងការទទួលខុសត្រូវ ដើម្បីផលប្រយោជន៍របស់ប្រជាពលរដ្ឋកម្ពុជា និង បានបង្កើតវង្វាស់ដើម្បីតាមដានវឌ្ឍនៈភាពក្នុងការងារនេះរវាងកិច្ចប្រជុំ ពិគ្រោះយោបល់ទាំងឡាយ ។ ក្នុងន័យដូចគ្នានេះដែរ រាជរដ្ឋាភិបាលក៏មានសិទ្ធិសុំអោយអ្នកផ្តល់ជំនួយទទួលខុសត្រូវ លើការគ្រប់គ្រងជំនួយរបស់ខ្លួនផងដែរ ។ ចំណុចនេះអាចចាប់ផ្តើមជាមួយនឹងការរាយការណ៍ប្រកបដោយតម្លាភាព និង ការពិនិត្យប្រចាំឆ្នាំនូវពត៌មានទាក់ទិននឹងការគ្រប់គ្រង ODA ដោយផ្ទៀងផ្ទាត់ជាមួយនឹងសូចនាករ មួយចំនួនដែលកាន់តែមានលក្ខណៈលំអិតដោយផ្អែកលើព័ត៌មានដែលបានរាយការណ៍ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ ប្រអប់ ៦.៤ ផ្តល់នូវបញ្ជីជាបឋមមួយនៃសូចនាករណាដែលអាចត្រូវបានបញ្ចូលក្នុងការវាស់វែងនិងការ ពិនិត្យរបស់សមភាគីលើការអនុវត្តរបស់អ្នកផ្តល់ជំនួយ ។

៣៩. ក្នុងការរាយការណ៍ពីការអនុវត្តន៍របស់ អ្នកផ្តល់ជំនួយ ក៏ដូចជានៅក្នុងទិដ្ឋភាពដទៃទាំង អស់ទៀតនៃសកម្មភាពរបស់អ្នកផ្តល់ជំនួយ គេឃើញមានភាពចាំបាច់បន្ទាន់មួយក្នុងការបកប្រែភ្លាមៗនូវឯកសាររបស់អ្នកផ្តល់ជំនួយទៅជាភាសាខ្មែរ និង ចែកចាយឯកសារទាំងនេះយ៉ាងសកម្មជូន ដល់សាធារណៈជនទូទៅ អង្គការសង្គម ស៊ីវិល និង អង្គការក្រៅរដ្ឋាភិបាល និង វិស័យឯកជនដទៃទៀត ។ ភាពជាដៃគូអ្នកផ្តល់ជំនួយ ដែលល្អបំផុត គឺ មានលក្ខណៈជាវិស័យទាំងមូលតាមរយៈ ក្រុមការងារបច្ចេកទេស ប៉ុន្តែក្នុងអវត្តមាននៃចំណុចនេះ តាមរយៈចង្កោមភាពជាដៃគូពហុអ្នកផ្តល់ជំនួយ ផ្តល់នូវវិធីដ៏សមរម្យមួយដើម្បីស្រូបយកការកើនឡើងនៃចំណាយបកប្រែ និងព័ត៌មានសាធារណៈ ដែលចាំបាច់សំរាប់យុទ្ធវិធីមួយដែលកាន់តែមានតម្លាភាពនិងការទទួលខុសត្រូវ ក្នុងការរៀបចំអនុវត្ត និង គ្រប់គ្រងសកម្មភាព ដែលទទួលហិរញ្ញប្បទានជំនួយ ។

*ប្រអប់ ៦.៣ សូចនាករសំរាប់វាស់ស្ទង់ការអនុវត្តន៍របស់សហគមន៍ផ្តល់ជំនួយ : បញ្ជីដំបូង*

សូចនាករនៃការរៀបចំភាពស៊ីសង្វាក់

- ភាគរយនៃថវិកាសំរាប់កម្មវិធីប្រចាំប្រទេស
- ភាគរយនៃកម្មវិធីប្រចាំប្រទេសចំណាយជាភាគរយនៃជំនួយបច្ចេកទេស
- រាជរដ្ឋាភិបាលចូលរួមក្នុងការរៀបចំក្របខ័ណ្ឌការងារសំរាប់ TA
- ការប្រើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- កម្មវិធីប្រចាំប្រទេសគាំទ្រយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ភាគរយនៃកម្មវិធីប្រចាំប្រទេសដែលត្រូវបានផ្តល់ជូនក្នុងក្របខ័ណ្ឌ SWAps

សូចនាករនៃការការពង្រឹង / ការប្រមូលផ្តុំ

- ទំហំគំរោងជាមធ្យម / អនុបាតនៃគំរោងចំពោះ ODA សរុប
- អនុបាតនៃចំនួនគំរោង: ចំនួនវិស័យដែលក្នុងនោះអ្នក ផ្តល់ជំនួយធ្វើការ
- អនុបាតនៃថវិការកម្មវិធីប្រចាំប្រទេសសរុប: ចំនួនវិស័យ ដែលក្នុងនោះអ្នកផ្តល់ជំនួយធ្វើការ

សូចនាករនៃសុខដុមនីយកម្ម និង ការបន្ថយចំណាយ ប្រតិបត្តិការ

- ចំនួនបេសកកម្មក្នុងមួយឆ្នាំ
- ភាគរយនៃបេសកកម្មដែលធ្វើរួមគ្នា
- ភាគរយនៃការវិភាគនិងវាយតម្លៃដែលធ្វើរួមគ្នា
- រយៈពេលមធ្យមនៃគំរោង (ឆ្នាំ)
- ការចូលរួមនៅក្នុងគំរោងពហុអ្នកផ្តល់ជំនួយ (គិតជាភាគ រយនៃគំរោងក្នុងកម្មវិធីប្រចាំប្រទេស)
- ការប្រើជំនួយមានចំណង (មាន/គ្មាន)

សូចនាករនៃតម្លាភាពនិងការដែលអាចព្យាករណ៍បាន

- កម្មវិធីប្រចាំប្រទេសដែលបានផ្សព្វផ្សាយជាសាធារណៈ
- ការសន្យា: អនុបាតនៃការចេញប្រាក់
- ការផ្តល់ការព្យាករណ៍ជាកញ្ចប់ពហុឆ្នាំ (ចង្អុលបង្ហាញ / ប្រាកដប្រជា)
- ការផ្លាស់ប្តូរ / កែប្រែជាអន្តរឆ្នាំ

## ច. សហគមន៍ផ្ដល់ជំនួយ និង អភិបាលកិច្ច

៤០. ប្រសិនបើអ្នកផ្ដល់ជំនួយគាំទ្រការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអភិបាលកិច្ចល្អ អ្នកផ្ដល់ជំនួយត្រូវ ចំណាយការយកចិត្តទុកដាក់និងធនធានច្រើនចំពោះការគាំទ្រកំណែទំរង់នៃទិទ្ធភាពស្នូលខ្លះនៃអភិបាលកិច្ច ។ ប្រការទាំងនេះ រួមមានការពង្រឹងសមត្ថភាពជំនឿទុកចិត្តរូបិយវត្ថុរបស់រាជរដ្ឋាភិបាល (ដែលរួមមានការតំរង់ជួរ នីតិវិធីរបស់អ្នកផ្ដល់ជំនួយ នៅជុំវិញការគ្រប់គ្រងនិងដំណើរការជំនឿទុកចិត្តរូបិយវត្ថុដែលត្រូវបានកែលំអមួយចំនួនដែលមានរាជរដ្ឋាភិបាលធ្វើជាម្ចាស់) ការបង្កើននិងនៅពេលណាចាំបាច់បន្ថយសម្ពាធប្រាក់បៀវត្សរ៍ ការផ្ដើមអនុវត្តប្រព័ន្ធធនធានមនុស្សដែលតែងតាំងតួនាទីលើមូលដ្ឋាននៃគុណវិបត្តិ និង ការផ្ដល់រង្វាន់លើមូលដ្ឋាននៃការអនុវត្តការងារ ការដាក់អោយអនុវត្តនូវប្រព័ន្ធតាមដាននិងវាយតម្លៃប្រកបដោយប្រសិទ្ធិភាព ដើម្បីធ្វើអោយគោល នយោបាយនិងផែនការត្រូវបានធ្វើឡើងដោយមានការវិភាគនិងភស្តុតាង ។ ចុងក្រោយបង្អស់ គឺ ការផ្សាភ្ជាប់ គោលនយោបាយនិងផែនការទៅនឹងដំណើរការចំណាយប្រចាំឆ្នាំនិងរយៈពេលមធ្យម ដែលអនុញ្ញាតអោយធនធាន ត្រូវបានបែងចែកលើមូលដ្ឋាននៃគោលដៅ ជាជាងការធ្វើថវិកាអោយគេ ។

៤១. អ្នកផ្ដល់ជំនួយក៏អាចធ្វើការងារជាច្រើនទៀតផងដែរដើម្បីជួយពង្រឹង "ខាងតំរូវការ" នៃកំណែទំរង់ អភិបាលកិច្ច ដោយអោយមានការចូលរួមពីសង្គមស៊ីវិលនិងវិស័យឯកជនកាន់តែមានលក្ខណៈជាប្រព័ន្ធនិងកាន់តែច្រើន នៅក្នុងការធ្វើគំរោងអនុវត្តន៍ និង វាយតម្លៃជំនួយអភិវឌ្ឍន៍ និងដោយប្រើចំណុចនេះដើម្បីពង្រីកបន្តិច ម្ដងៗនូវឱកាសសំរាប់អោយក្រុមទាំងនេះបានចូលរួមក្នុងដំណើរការគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ បទពិសោធន៍នៅក្នុងប្រទេសដទៃដែលនៅទីនោះអ្នកផ្ដល់ជំនួយត្រូវបានតិទៀនចំពោះការគ្មានសកម្មភាពកន្លងមក ទៅលើអំពើពុករលួយនិងអភិបាលកិច្ចមិនល្អ ស្នើអោយមានការផ្លាស់ប្ដូរផ្ទៃក្នុងជាមូលដ្ឋានខ្លះដែលអ្នកផ្ដល់ជំនួយអាចអនុវត្តបាន - ការបង្ហាញព័ត៌មាន ការពង្រឹងការគ្រប់គ្រងនិងត្រួតពិនិត្យ ការចូលរួមរបស់សហគមន៍និងអង្គការ សង្គមស៊ីវិលនៅក្នុងការរៀបចំនិងការត្រួតពិនិត្យគំរោងជាបទដ្ឋាន និង ការអនុវត្តបទដ្ឋានបានល្អនៅពេលណាដែល ការបំពារបំពានត្រូវបានរកឃើញ ។ វិធានការទាំងនេះ អាចកាត់បន្ថយយ៉ាងច្រើននូវកាលានុវត្តភាពនៃការប្រើ ប្រាស់មិនសមស្របនៃ ODA ហើយ ដោយធ្វើដូច្នេះ ចូលរួមចំណែកដល់ការបំភ្លឺនូវការញែកអោយដាច់រវាងធនធាន សាធារណៈ និង

ធនធានឯកជន ។ ការជួយឧបត្ថម្ភចំពោះកម្មវិធីដែលនាំមុខដោយសហគមន៍ ដែលនៅក្នុងនោះ សហគមន៍បានបង្ហាញសមត្ថភាពតាមដាននិងគ្រប់គ្រងមូលនិធិអ្នកផ្តល់ជំនួយជារឿយៗ អាចជាធនធាន សំរាប់ អ្នកផ្តល់ជំនួយនៅពេលណាដែលរដ្ឋាភិបាលខកខានមិនបានធ្វើសកម្មភាពដើម្បីត្រួតពិនិត្យអំពើពុក រលួយនៅក្នុង កម្មវិធីដែលគ្រប់គ្រងដោយរដ្ឋាភិបាល ។

## ឆ. របៀបដែលដៃគូអភិវឌ្ឍន៍របស់កម្ពុជាអាចគាំទ្រដល់ការជំរុញអោយមាន អភិបាលកិច្ចល្អ នៅកម្ពុជា

៤២. ទ្វេគ្រោះសំរាប់ដៃគូអភិវឌ្ឍន៍អន្តរជាតិ គឺថាតើត្រូវកំណត់អាទិភាពលើតំរូវការ (ឧទាហរណ៍ ការ រាប់ចំនួនភាពក្រីក្រ) ឬ ការអនុវត្តន៍ (ការបង្ហាញសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការប្រើជំនួយយ៉ាងមាន ប្រសិទ្ធិភាព ដើម្បីធ្វើអោយមានឥទ្ធិពល) នៅពេលបែងចែកជំនួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ។ គេ កាន់តែឃើញមានភស្តុតាង ដែលថាប្រសិទ្ធិភាពជំនួយពឹងផ្អែកយ៉ាងច្រើនលើការមានបរិដ្ឋានស្ថាប័ននិង គោលនយោបាយរឹងមាំ ។ នៅពេលណា ដែលខ្វះបរិដ្ឋានបែបនេះ អ្នកផ្តល់ជំនួយកាន់តែរារែកក្នុងការសន្យា ផ្តល់ជំនួយឧបត្ថម្ភ (grant) ឬ កំចីធំដុំ ។

៤៣. អ្នកផ្តល់ជំនួយមួយចំនួន ដូចជា ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្សារ ភ្ជាប់កញ្ចប់ធន ធានរួមរបស់កម្មវិធីប្រចាំប្រទេស ជាមួយនឹងការអនុវត្តន៍របស់ប្រទេស ដោយស្វ័យប្រវត្តិ និង ឧបតោភាគី ។ ឧទាហរណ៍ : ធនាគារពិភពលោក ប្រើប្រាស់លទ្ធផលវាយតំលៃគោលនយោបាយ ប្រចាំប្រទេសនិងស្ថាប័នប្រចាំឆ្នាំ (CPIA) ដើម្បីដាក់ពិន្ទុអោយប្រទេសនីមួយៗ ដោយផ្អែកលើលក្ខណៈ វិនិច្ឆ័យមួយចំនួនធំ ។ សូចនាករអភិបាលកិច្ច ក្នុងផ្នែកតូចៗ ឥឡូវនេះ មានតំលៃណាស់នៅក្នុងពិន្ទុ CPIA រួម ។ ចំពោះករណីរបស់កម្ពុជា ពិន្ទុសំរាប់សូចនាករ ៣ នៅក្នុងចំណោមសូចនាករអភិបាលកិច្ចទាំង ៥ នៅតែមានទំហំធំដូចពីមុន ឬ ធ្លាក់ចុះក្នុងអំឡុងឆ្នាំ ១៩៩៩-២០០៣ ដោយមានការកើនឡើងបន្តិចតែនៅ ក្នុងសូចនាករ ២ ប៉ុណ្ណោះ (សូមមើលរូប ៦.២) ។ បើប្រៀបធៀប ជាមួយនឹងប្រទេសទទួល IDA នៅឆ្នាំ ២០០៣ កម្ពុជា មានពិន្ទុស្មើគ្នា លើផ្នែកគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និង មាន ពិន្ទុជិតស្មើលើផ្នែកសមធមិរចនា សម្ព័ន្ធនិងសង្គមកិច្ច ប៉ុន្តែមានពិន្ទុក្រោមពិន្ទុមធ្យមរបស់ប្រទេស IDA លើ លក្ខណៈវិនិច្ឆ័យអភិបាលកិច្ច

ទាំង ៥ (សូមមើលរូប ៦.៣) ។ ជាលទ្ធផល ការបែងចែក IDA រួមរបស់ធនាគារ ពិភពលោកសំរាប់ជំនួយអោយកម្ពុជា ត្រូវបានកាត់បន្ថយ ។ ធនាគារអភិវឌ្ឍន៍អាស៊ី ប្រើប្រាស់របៀបកំណត់អត្រានៃការអនុវត្តប្រហាក់ប្រហែលគ្នានេះ ដើម្បីបែងចែកមូលនិធិក៏រិតប្រទេស ហើយដូចគ្នានេះដែរ កាត់បន្ថយការបែងចែកតាមរយៈច្រកប្រទេសកម្ពុជារបស់ខ្លួន ។ ផលប៉ះពាល់ដែលបានកើតមាន គឺថា ដោយសារអភិបាលកិច្ច មានសារៈសំខាន់ចំពោះធនាគារទាំងពីរនោះ ការកែលំអអភិបាលកិច្ច ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ អាចធ្វើឱ្យ ជំនួយកើនឡើងច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ។

**រូប ៦.២ ការវាយតំលៃគោលនយោបាយប្រចាំប្រទេស និង ស្ថាប័ន (CPIA) - ពិន្ទុនៅឆ្នាំ ១៩៩៩ និង ២០០៣**



**រូប ៦.៣ កម្ពុជាប្រៀបធៀបនឹងប្រទេសដទៃទៀតដែលទទួលមូនិធិ IDA ធនាគារពិភពលោក នៅក្នុងឆ្នាំ ២០០៣**




## សេចក្តីយោង

[១] គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី ៨ ជំរុញឱ្យប្រទេសនានា បង្កើតដៃគូអភិវឌ្ឍន៍នៅក្នុងពិភពលោក ។ អង្គការសហប្រជាជាតិឆ្នាំ ២០០០ ។

[២] ឧទាហរណ៍ សូមមើលរបាយការណ៍វឌ្ឍនៈភាពប្រចាំឆ្នាំ (APR) ស្តីពីការអនុវត្តន៍យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រកម្ពុជា ដែល ទាមទារឱ្យមានការដាក់បញ្ចូលមូលនិធិទាំងឡាយដែលបច្ចុប្បន្នត្រូវបានបែងចែកសំរាប់ការផ្តល់ប្រាក់បៀវត្សរ៍បន្ថែម ដែលផ្អែកលើគំរោង នៅក្នុងកញ្ចប់រួមមួយដើម្បីជួយឧបត្ថម្ភដល់កំណែទំរង់ប្រាក់បៀវត្សរ៍ ។

[៣] ប្រទេសកម្ពុជាបានចូលរួមក្នុងក្រុមការងារ OECD-DAC ស្តីពីការអនុវត្តន៍របស់អ្នកផ្តល់ជំនួយ និងត្រូវបានជ្រើសរើសជាប្រទេសសាកល្បងមួយសំរាប់ការងារ OECD-DAC ស្តីពីសុខដុមនីយកម្ម ។

[៤] ទាក់ទិននឹងវិធីសាស្ត្រតាមវិស័យនៅក្នុងវិស័យអប់រំនិងសុខាភិបាល សូមមើលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ២០០៤ ជំពូក ៦ និង ៧, ឯកឧត្តម ឈៀង យ៉ាណារ៉ា ២០០៤ខ ។

[៥] ឧទាហរណ៍ : ការវាយតំលៃទំនុកចិត្តរួមនិងការពិនិត្យមើលចំណាយសាធារណៈ (IFAPER) (ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍ អាស៊ី ឆ្នាំ ២០០៤) និង ការប៉ាន់ប្រមាណបញ្ហាយេនឌ័រនៅកម្ពុជា (UNIFEM, WB, ADB, UNDP, DFID និង ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ឆ្នាំ ២០០៤) ។

[៦] ឯកឧត្តម ឈាង យ៉ាណារ៉ា ឆ្នាំ ២០០៤ ។

[៧] ឧទាហរណ៍ : សូមកត់សំគាល់ថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រើប្រាស់កិច្ចប្រជុំត្រៀមឆ្ពោះទៅកិច្ចប្រជុំក្រុមពិគ្រោះយោបល់ ដែលត្រូវបានរៀបចំដោយរាជរដ្ឋាភិបាល និង សហគមន៍ផ្តល់ជំនួយ នៅដើមខែ តុលា ដើម្បីអនុម័តដំណើរការ និង ដាក់ចេញសេចក្តីណែនាំ សំរាប់ដឹកនាំការបញ្ចប់ដំណើរការនេះ ។

[៨] ទិដ្ឋភាពមួយចំពោះភាពទន់ខ្សោយដែលបំប៉ោងឡើងដោយអ្នកផ្តល់ជំនួយនៅក្នុងការធ្វើផែនការនិងការធ្វើគោលនយោបាយ គឺ ពហុភាព និងភាពមានកំរិតនៃក្របខ័ណ្ឌជាតិសំរាប់ការតាមដាននិងការវាយតម្លៃការផ្លាស់ប្តូរ ។ ថ្វីបើគេឃើញមានកិច្ចប្រឹងប្រែងមួយចំនួន ដើម្បីបង្កើតឡើងនូវប្រព័ន្ធរួមមួយសំរាប់ប្រមូល ថ្មៃ វិភាគ និង ប្រើប្រាស់ទិន្នន័យសង្គម-សេដ្ឋកិច្ចក្តី ក៏ស្ថានភាពបច្ចុប្បន្នមានលក្ខណៈ ច្របូកច្របល់ ដោយកង្វះភាពច្បាស់លាស់អំពីតួនាទីសំរាប់អង្គភាពបច្ចេកទេសតាមដាននិង វិភាគភាពក្រីក្រ (PMATU), CamInfo, ប្រព័ន្ធតាមដាននិងវាយតម្លៃតាមវិស័យ និង ក្របខ័ណ្ឌសូចនាករនៃផែនការ អភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចទី ២ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាព ក្រីក្រ និង គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

[៩] ប្រសិនបើមានការសង្ស័យអំពីសមត្ថភាពរបស់សហគមន៍ការស្រាវជ្រាវនិងផ្តល់ប្រឹក្សានៅកម្ពុជា ក្នុងការធ្វើការងារស្មុគ្រស្មាញខាងបច្ចេកទេស ឬ ទំហំនៃការងារវាយតម្លៃដែលចាំបាច់ (គឺជាការបារម្ភណ៍ត្រឹមត្រូវ) ស្ថាប័នវាយតម្លៃ នេះអាចត្រូវបានរៀបចំឡើង ដោយមានការចុះកិច្ចសន្យារយៈពេលវែងដែលផ្អែកលើការងារដែលមានជាមួយនឹងវិទ្យាស្ថានស្រាវជ្រាវ គោលនយោបាយ ឬ ស្ថាប័នពិគ្រោះ ការងារសមស្របនៅទីកន្លែងដទៃនៅក្នុងតំបន់ឬពិភពលោក ដោយផ្តល់នូវកាលានុវត្តភាពសំរាប់ការផ្ទេរជំនាញនិងការកសាងសមត្ថភាព ស្ថាប័នរយៈពេលវែង ។

# ក្រឡេកមើលប្រទេសកម្ពុជាមួយគ្រួស

| ភាពក្រីក្រ និង សង្គម<br>ឆ្នាំ ២០០៣ | កម្ពុជា | អាស៊ីខាងកើត<br>និងប៉ាស៊ីហ្វិក | ចំណូលទាប |
|---|---|---|---|
| ប្រជាពលរដ្ឋពាក់កណ្ដាលឆ្នាំ ( *លាននាក់* ) | 13.4 | 1,855 | 2,310 |
| GNI ក្នុងប្រជាពលរដ្ឋម្នាក់ៗ *វិធីសាស្ត្រ* Atlas, ដុល្លារអាមេរិក | 300 | 1,080 | 450 |
| GNI (វិធីសាស្ត្រ Atlas ពាន់ដុល្លារអាមេរិក) | 4.1 | 2,011 | 1,038 |
| **កំណើនជាមធ្យមប្រចាំឆ្នាំ 1997-03** | | | |
| ប្រជាពលរដ្ឋ (%) | 2.4 | 1.0 | 1.9 |
| កំលាំងពលកម្ម (%) | 2.5 | 1.1 | 2.3 |
| **តួលេខប៉ាន់ស្មានថ្មីៗបំផុត ( ឆ្នាំចុងក្រោយដែលមាន 1997-03 )** | | | |
| ភាពក្រីក្រ( *% ប្រជាពលរដ្ឋរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ថ្នាក់ជាតិ*) | 36 | .. | .. |
| ប្រជាពលរដ្ឋនៅទីប្រជុំជន ( *% នៃប្រជាពលរដ្ឋសរុប*) | 19 | 40 | 30 |
| អាយុរំពឹងរស់រានមានជីវិត ( *ឆ្នាំ* ) | 56 | 69 | 58 |
| អត្រាស្លាប់របស់ទារក( *ក្នុង១.០០០នាក់ដែលមាន អាយុរស់នៅក្រោយកើត* ) | 84 | 32 | 82 |
| កង្វះអាហារូបត្ថម្ភចំពោះទារក ( *% នៃទារក < ៥ឆ្នាំ*) | 45 | 15 | 44 |
| លទ្ធភាពបានទទួលប្រភពទឹកស្អាត ( % នៃប្រជាពលរដ្ឋ) | 30 | 76 | 75 |
| អក្ខរភាព ( % នៃប្រជាពលរដ្ឋអាយុ ១៥+ ) | 30 | 10 | 39 |
| អត្រាចុះឈ្មោះចូលរៀនដុលកំរិតបឋមសិក្សា<br>( % ចំនួនសិស្សដល់អាយុចូលរៀន) | 118 | 111 | 92 |
| ប្រុស | 123 | 112 | 99 |
| ស្រី | 112 | 106 | 85 |




| **អនុបាតសេដ្ឋកិច្ចសំខាន់ៗ និង និន្នាការរយៈពេលវែង** | | | | |
|---|---|---|---|---|
| GDP ( ពាន់លានដុល្លារអាមេរិក) | **1983** | **1993** | **2002** | **2003** |
| វិនិយោគក្នុងស្រុកដុលធៀបនឹង GDP | .. | 2.5 | 4.0 | 4.2 |
| ការនាំចេញទំនិញ និង សេវាកម្មធៀបនឹង GDP | .. | 11.2 | 22.2 | 22.2 |
| សញ្ច័យក្នុងស្រុកដុល/GDP | .. | 16.4 | 59.2 | 62.0 |
| សញ្ច័យដុលរបស់ជាតិ/GDP | .. | -5.1 | 14.0 | 13.0 |
| ជញ្ជីងពាណិជ្ជកម្មចរន្ត/GDP | .. | 0.5 | 21.0 | 20.2 |
| ការបង់ការប្រាក់/GDP | .. | -4.2 | -1.4 | -3.0 |
| បំណុលសរុប/GDP | .. | 0.0 | 0.4 | 0.4 |
| អត្រាការប្រាក់សរុប/បរិមាណនាំចេញ | .. | 73.4 | .. | .. |
| តំលៃបច្ចុប្បន្ននៃបំណុល/GDP | .. | 9.9 | .. | .. |
| តំលៃបច្ចុប្បន្ននៃបំណុល/បរិមាណនាំចេញ | .. | .. | .. | .. |
| | | .. | .. | .. |




| | 1983-93 | 1993-03 | 2002 | 2003 | 2003-07 |
|---|---|---|---|---|---|
| *( កំណើនជាមធ្យមប្រចាំឆ្នាំ)* | | | | | |
| GDP | .. | 6.5 | 5.5 | 5.2 | .. |
| GDP ក្នុងប្រជាពលរដ្ឋម្នាក់ៗ | .. | 3.4 | 3.6 | 3.3 | .. |
| បរិមាណនាំចេញនៃទំនិញ និង សេវាកម្មផ្សេងៗ | .. | 20.7 | 21.0 | 10.0 | .. |

**រចនាសម្ព័ន្ធនៃសេដ្ឋកិច្ច**

| | 1983 | 1993 | 2002 | 2003 |
|---|---|---|---|---|
| *(% នៃ GDP)* | | | | |
| កសិកម្ម | .. | 46.1 | 33.4 | 33.0 |
| ឧស្សាហកម្ម | .. | 12.5 | 26.3 | 28.4 |
| កម្មន្តសាល | .. | 8.4 | 19.0 | 21.2 |
| សេវា | .. | 38.7 | 34.2 | 34.4 |
| ការប្រើប្រាស់របស់ឯកជន | .. | 100.5 | 80.1 | 77.5 |
| ការប្រើប្រាស់របស់រដ្ឋាភិបាលទូទៅ | .. | 4.6 | 5.8 | 6.5 |
| បរិមាណនាំចូលទំនិញ និង សេវា | .. | 32.8 | 67.4 | 71.3 |
| | **1983-93** | **1993-03** | **2002** | **2003** |
| *(កំណើនជាមធ្យមប្រចាំឆ្នាំ)* | | | | |
| កសិកម្ម | .. | 3.1 | -2.7 | 9.2 |
| ឧស្សាហកម្ម | .. | 14.7 | 17.7 | 8.1 |
| កម្មន្តសាល | .. | 17.4 | 15.1 | 12.0 |
| សេវា | 54.2 | 5.7 | 4.5 | 2.8 |
| ការប្រើប្រាស់របស់ឯកជន | .. | 4.4 | 2.7 | 2.5 |
| ការប្រើប្រាស់របស់រដ្ឋាភិបាលទូទៅ | .. | 8.0 | 7.8 | 13.2 |
| វិនិយោគក្នុងស្រុកដុល | .. | 12.7 | 10.5 | 19.5 |
| បរិមាណនាំចូលទំនិញ និង សេវា | .. | 14.9 | 16.9 | 11.0 |







កំណត់សំគាល់ : ទិន្នន័យឆ្នាំ២០០៣ គឺជាតួលេខប៉ាន់ស្មានបណ្តោះអាសន្ន

* គំនូសរាងដូចពេជ្រនៃ បង្ហាញនូវសូចនាករសំខាន់ៗចំនួន ៤នៅក្នុងប្រទេស (តួលេខដិត) ប្រៀបធៀបជាមួយមធ្យមភាគនៃក្រុមប្រាក់ចំណូលរបស់ខ្លួន ។ ប្រសិនបើខ្វះទិន្នន័យនោះ គំនូសរាងដូចពេជ្រនឹងពុំមានលក្ខណៈពេញលេញ ។

## ថ្លៃនិងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល

| | 1983 | 1993 | 2002 | 2003 |
|---|---|---|---|---|
| *ថ្លៃក្នុងស្រុក* | | | | |
| *(បំរែបំរួលជា%)* | | | | |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ | .. | .. | 3.7 | 0.5 |
| អត្រាបរិវត្តដំណោះ GDP | .. | .. | 2.1 | 2.3 |
| *ហិរញ្ញវត្ថុរដ្ឋាភិបាល* | | | | |
| *(% នៃGDP* | | | | |
| *គិតទាំងអំណោយបច្ចុប្បន្ន)* | .. | 4.6 | 11.1 | 10.3 |
| ចំណូលបច្ចុប្បន្ន | .. | -1.0 | 1.1 | -0.1 |
| សមតុល្យថវិកាបច្ចុប្បន្ន | .. | -4.5 | -6.8 | -7.0 |
| អតិរេក/ឱនភាពសរុប | | | | |

| ពាណិជ្ជកម្ម | 1983 | 1993 | 2002 | 2003 |
|---|---|---|---|---|
| *(គិតជាលានដុល្លារអាមេរិក)* | | | | |
| នាំចេញសរុប (Fob) | .. | 284 | 1,750 | 2003 |
| កៅស៊ូ | .. | .. | 38 | 36 |
| ឈើ និង ឈើអារ | .. | .. | 30 | 45 |
| ទំនិញកម្មន្តសាល | .. | .. | 1490 | 1780 |
| បរិមាណនាំចូលសរុប (Cif) | .. | 422 | 2,314 | 2601 |
| ស្បៀងអាហារ | | .. | 75 | 80 |
| ឥន្ធនៈ និង ថាមពល | .. | .. | 353 | 429 |
| ទំនិញមូលធន | .. | .. | 22 | 25 |
| សន្ទស្សន៍ថ្លៃនាំចេញ | | .. | .. | .. |
| (ឆ្នាំ1995=100) | .. | .. | .. | .. |
| សន្ទស្សន៍ថ្លៃនាំចូល | .. | .. | .. | .. |
| (ឆ្នាំ1995=100) | | | | |






## ជញ្ជីងពាណិជ្ជកម្ម

| (គិតជាលានដុល្លារអាមេរិក) | 1983 | 1993 | 2002 | 2003 |
|---|---|---|---|---|
| បរិមាណនាំចេញទំនិញ និង សេវា | .. | 348 | 2,354 | 2,572 |
| បរិមាណទំនិញនាំចូល និង សេវា | .. | 592 | 2,687 | 2,990 |
| តុល្យការធនធាន | .. | -244 | -333 | -417 |
| ចំណូលសុទ្ធ | .. | -16 | -169 | -183 |
| ប្រាក់បង្វែរបច្ចុប្បន្នសុទ្ធ | .. | 156 | 447 | 475 |
| តុល្យការគណនីចរន្ត | .. | -104 | -55 | -125 |
| យថាប្រភេទហិរញ្ញប្បទាន (សុទ្ធ) | .. | .. | 125 | .. |
| បំរែបំរួលនៃប្រាក់បំរុងសុទ្ធ | .. | .. | -70 | .. |
| *អនុស្សរណៈ:* | | | | |
| ប្រាក់បំរុងរួមមានមាស *(គិតជាលានដុល្លារអាមេរិក)* | .. | .. | 661 | 737 |
| *អត្រាប័ណ្ណ* (DEC ក្នុងស្រុក/ដុល្លារអាមេរិក) | .. | 2,689.0 | 3,917.0 | 3,985.0 |




## បំណុលបរទេស និង លំហូរធនធាន

| (គិតជាលានដុល្លារអាមេរិក) | 1983 | 1993 | 2002 | 2003 |
|---|---|---|---|---|
| បំណុលនៅជំពាក់ និង បានបើកផ្តល់សរុប | 9 | 1,820 | .. | .. |
| IBRD | 0 | 0 | 0 | 0 |
| IDA | 0 | 0 | 306 | 369 |
| សេវាការប្រាក់សរុប | 0 | 34 | .. | .. |
| IBRD | 0 | 0 | .. | .. |
| IDA | 0 | 0 | .. | .. |
| សមាសភាពនៃលំហូរធនធានសុទ្ធ | | | | |
| ជំនួយជាផ្លូវការ | 25 | 176 | .. | .. |
| ឥណទាយកផ្លូវការ | 0 | 5 | .. | .. |
| ឥណទាយកឯកជន | 0 | 0 | .. | .. |
| វិនិយោគផ្ទាល់ពីបរទេស | 0 | 70 | 139 | 77 |
| ផលប័ត្រភាគហ៊ុនម្ចាស់ទ្រព្យ | 0 | 0 | .. | .. |
| កម្មវិធីរបស់ធនាគារពិភពលោក | | | | |
| ការសន្យា | 0 | 63 | 70 | 70 |
| ការបើកផ្តល់ | 0 | 0 | 43 | .. |
| ការសងប្រាក់លើប្រាក់ដើម | 0 | 0 | .. | .. |
| លំហូរសុទ្ធ | 0 | 0 | .. | .. |
| ការបង់ការប្រាក់ | 0 | 0 | 2 | .. |
| ការបង្វែរប្រាក់សុទ្ធ | 0 | 0 | .. | .. |




សេដ្ឋកិច្ចអភិវឌ្ឍន៍

11/1/04

## តារាងទី ១: ចំនួនប្រជាជន

| ឆ្នាំ | ប្រជាជន (គិតជាលាននាក់) | បុរស (គិតជាលាននាក់) | ស្ត្រី (គិតជាលាននាក់) |
|---|---|---|---|
| 1962 | 5.70 | 2.90 | 2.80 |
| 1982 | 6.90 | 3.10 | 3.80 |
| 1993 | 9.30 | 4.30 | 5.00 |
| 1994 | 9.87 | 4.71 | 5.16 |
| 1995 | 10.20 | 4.85* | 5.35 |
| 1996 | 10.34 | 5.00 | 5.34 |
| 1997 | 10.37 | 5.00 | 5.40 |
| 1998 | 11.44 | 5.50 | 5.94 |
| 1999 | 12.50 | 6.04 | 6.46 |
| 2000 | 12.82 | 6.21 | 6.62 |
| 2001 | 13.15 | 6.37 | 6.77 |
| 2002 | 13.47 | 6.54 | 6.93 |
| 2003 | 13.80 | 6.71 | 7.09 |
| 2004 | 14.11 | .. | .. |
| 2005 | 14.45 | .. | .. |
| 2010 | 16.25 | .. | .. |
| 2015 | 18.09 | .. | .. |
| 2020 | 19.92 | .. | .. |

* តួលេខប៉ាន់ស្មាន

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៣

## តារាងទី ២: ចំនួនប្រជាជនប៉ាន់ស្មានឆ្នាំ ២០០១ គិតតាមអាយុ និងភេទ នៅកម្ពុជា នៅទីប្រជុំជន និងនៅតំបន់ជនបទ ផ្អែកលើ GPCC ឆ្នាំ ១៩៩៨

| ក្រុមអាយុ | សរុប | | | ទីប្រជុំជន | | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | | ប្រុស | ស្រី | ទាំងពីរភេទ |
| 0 - 4 . . . | 1,025,677 | 993,031 | 2,018,708 | 145,979 | 140,766 | 286,745 | | 879,698 | 852,265 | 1,731,963 |
| 5 - 9 . . . | 938,705 | 909,096 | 1,847,801 | 128,866 | 124,118 | 252,984 | | 809,839 | 784,978 | 1,594,817 |
| 10 - 14. | 896,965 | 858,147 | 1,755,112 | 129,020 | 123,954 | 252,975 | * | 767,945 | 734,193 | 1,502,138 |
| 15 - 19. | 784,015 | 766,854 | 1,550,869 | 126,635 | 127,722 | 254,357 | | 657,380 | 639,132 | 1,296,512 |
| 20 - 24. | 536,449 | 564,352 | 1,100,801 | 97,084 | 101,858 | 198,942 | | 439,365 | 462,494 | 901,859 |
| 25 - 29. | 391,176 | 429,415 | 820,591 | 76,527 | 76,052 | 152,580 | * | 314,649 | 353,363 | 668,011 |
| 30 - 34. | 406,886 | 446,920 | 853,806 | 79,003 | 77,633 | 156,636 | | 327,883 | 369,287 | 697,170 |
| 35 - 39. | 354,160 | 399,555 | 753,715 | 68,756 | 68,341 | 137,097 | | 285,404 | 331,214 | 616,619 |
| 40 - 44. | 272,009 | 342,151 | 614,160 | 53,750 | 59,674 | 113,424 | | 218,259 | 282,477 | 500,736 |
| 45 - 49. | 189,470 | 274,724 | 464,194 | 38,163 | 47,992 | 86,155 | | 151,307 | 226,732 | 378,039 |
| 50 - 54. | 155,444 | 214,700 | 370,144 | 28,590 | 35,534 | 64,123 | * | 126,854 | 179,166 | 306,021 |
| 55 - 59. | 120,680 | 164,453 | 285,133 | 19,726 | 25,430 | 45,156 | | 100,954 | 139,023 | 239,977 |
| 60 - 64. | 96,417 | 131,521 | 227,938 | 14,059 | 19,187 | 33,245 | * | 82,358 | 112,335 | 194,693 |
| 65 - 69. | 74,676 | 103,644 | 178,320 | 9,898 | 14,942 | 24,840 | | 64,778 | 88,702 | 153,481 |
| 70 - 74. | 53,317 | 74,990 | 128,307 | 6,611 | 10,770 | 17,380 | * | 46,707 | 64,220 | 110,927 |
| 75 + | 52,066 | 77,807 | 129,873 | 6,739 | 11,758 | 18,497 | | 45,327 | 66,049 | 111,376 |
| សរុប | 6,348,112 | 6,751,360 | 13,099,472 | 1,029,405 | 1,065,730 | 2,095,135 | | 5,318,707 | 5,685,630 | 11,004,338 |

* ផលបូករវាងចំនួនប្រុសនិងស្រីមិនស្មើនឹងតួលេខសរុបនៃភេទទាំងពីរឡើយ ដោយសារការកំណត់តួលេខមូល នៃកម្មវិធីគណនាប្រជាជនប្រើប្រាស់សំរាប់ការព្យាករណ៍

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៣

## តារាងទី ៣. តួលេខប៉ាន់ស្មាននៃចំនួនប្រជាជនប្រចាំឆ្នាំ (គិតជាពាន់នាក់) ចាប់ពីឆ្នាំ ២០០១ ដល់ ២០១០ ផ្អែកលើការព្យាករណ៍ចំនួនប្រជាជន នៅប្រទេសកម្ពុជា និងនៅតាមបណ្តាខេត្ត

| លេខកូដ | តំបន់ | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|
| | សរុបនៅកម្ពុជា | 13099 | 13433 | 13770 | 14111 | 14454 | 14798 | 15159 | 15521 | 15882 | 16245 |
| 1 | បន្ទាយមានជ័យ | 703 | 725 | 748 | 771 | 794 | 817 | 841 | 866 | 890 | 915 |
| 2 | បាត់ដំបង | 950 | 971 | 993 | 1015 | 1037 | 1059 | 1083 | 1107 | 1132 | 1156 |
| 3 | កំពង់ចាម | 1800 | 1838 | 1876 | 1914 | 1952 | 1990 | 2030 | 2069 | 2108 | 2146 |
| 4 | កំពង់ឆ្នាំង | 477 | 489 | 502 | 514 | 527 | 540 | 554 | 568 | 582 | 596 |
| 5 | កំពង់ស្ពឺ | 681 | 699 | 717 | 735 | 753 | 771 | 791 | 811 | 830 | 851 |
| 6 | កំពង់ធំ | 643 | 658 | 673 | 688 | 703 | 718 | 735 | 751 | 767 | 784 |
| 7 | កំពត | 589 | 600 | 611 | 622 | 633 | 644 | 656 | 668 | 679 | 691 |
| 8 | កណ្តាល | 1205 | 1231 | 1257 | 1283 | 1309 | 1336 | 1363 | 1391 | 1418 | 1445 |
| 9 | កោះកុង | 165 | 173 | 182 | 191 | 201 | 210 | 220 | 229 | 239 | 249 |
| 10 | ក្រចេះ | 302 | 311 | 319 | 328 | 337 | 346 | 355 | 365 | 373 | 383 |
| 11 | មណ្ឌលគិរី | 39 | 40 | 42 | 43 | 45 | 46 | 48 | 50 | 51 | 53 |
| 12 | ភ្នំពេញ | 1185 | 1234 | 1283 | 1335 | 1387 | 1442 | 1493 | 1546 | 1600 | 1656 |
| 13 | ព្រះវិហារ | 141 | 146 | 150 | 156 | 161 | 166 | 171 | 177 | 182 | 188 |
| 14 | ព្រៃវែង | 1043 | 1060 | 1077 | 1094 | 1110 | 1127 | 1144 | 1160 | 1176 | 1192 |
| 15 | ពោធិសាត់ | 418 | 428 | 439 | 449 | 459 | 470 | 481 | 493 | 505 | 517 |
| 16 | រតនៈគិរី | 112 | 116 | 120 | 124 | 128 | 132 | 137 | 142 | 146 | 151 |
| 17 | សៀមរាប | 799 | 821 | 843 | 866 | 888 | 911 | 935 | 960 | 984 | 1009 |
| 18 | ក្រុងព្រះសីហនុ | 188 | 196 | 204 | 213 | 222 | 231 | 240 | 249 | 259 | 268 |
| 19 | ស្ទឹងត្រែង | 95 | 98 | 102 | 105 | 109 | 112 | 116 | 119 | 123 | 127 |
| 20 | ស្វាយរៀង | 531 | 541 | 551 | 561 | 570 | 580 | 591 | 601 | 611 | 620 |
| 21 | តាកែវ | 880 | 896 | 912 | 929 | 945 | 962 | 979 | 996 | 1013 | 1030 |
| 22 | ឧត្តរមានជ័យ | 91 | 94 | 98 | 101 | 104 | 107 | 111 | 115 | 118 | 122 |
| 23 | ក្រុងកែប | 35 | 36 | 38 | 40 | 42 | 43 | 45 | 47 | 49 | 51 |
| 24 | ក្រុងប៉ៃលិន | 29 | 30 | 32 | 33 | 35 | 36 | 38 | 40 | 41 | 43 |

កំណត់សំគាល់: ការប៉ាន់ស្មានចំនួនប្រជាជនសំរាប់ឆ្នាំនីមួយៗ ផ្អែកលើសូហ្វវែរឈ្មោះ "PEOPLE" ។ មានករណីមួយចំនួន តួលេខសរុបមិនឆ្លើយគ្នានឹងតួលេខនីមួយៗ បូកបញ្ចូលគ្នាឡើយ ។

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ (NIS) សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៣

## តារាងទី ៤. និយោជន៏សរុបតាមផ្នែកនៅក្នុងវិស័យសំខាន់ៗ ចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០២

(ពាន់នាក់)

| ផ្នែក | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 |
|---|---|---|---|---|---|---|---|---|---|---|
| | *គិតតាមបែបសមមូល* | | | | | | | | | *គិតតាមបែបសមមូល* |
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **3192.4** | **2958.8** | **4013.5** | **3482.5** | **3491.9** | **3771.0** | **4213.6** | **3889.0** | **4384.3** | **4479.8** |
| *កសិកម្ម គិតជា% នៃនិយោជន៏សរុប* | *81.0%* | *75.0%* | *81.4%* | *78.1%* | *78.8%* | *76.8%* | *76.3%* | *73.7%* | *70.2%* | *70.0%* |
| កសិកម្ម និង រុក្ខាប្រមាញ់ | 3132.8 | 2903.7 | 3964.2 | 3388.8 | 3412.8 | 3968.1 | 4109.0 | 3741.8 | 4123.2 | 4255.8 |
| ជលផល | 59.5 | 55.2 | 49.3 | 93.7 | 79.1 | 72.8 | 104.7 | 147.3 | 261.1 | 224.0 |
| **ឧស្សាហកម្ម** | **118.2** | **177.3** | **141.6** | **211.1** | **210.1** | **216.3** | **352.5** | **444.2** | **656.2** | **672.0** |
| *ឧស្សាហកម្ម គិតជា% នៃនិយោជន៏សរុប* | *3.0%* | *4.5%* | *2.9%* | *4.7%* | *4.7%* | *4.4%* | *6.4%* | *8.4%* | *10.5%* | *10.5%* |
| អាជីវកម្មយករ៉ែ និងយកថ្ម | 5.3 | 7.9 | 5.6 | 1.0 | 8.0 | 6.4 | 5.5 | 3.3 | 13.5 | 10.8 |
| កម្មន្តសាល | 89.3 | 134.0 | 108.5 | 168.8 | 144.4 | 159.0 | 258.9 | 367.3 | 544.8 | 556.4 |
| ទឹក ភ្លើង ទូរស័ព្ទ | 2.6 | 3.9 | 0.9 | 3.3 | 3.8 | 3.3 | 5.5 | 3.8 | 3.8 | 4.7 |
| សំណង់ | 21.0 | 31.5 | 26.7 | 38.0 | 53.9 | 47.7 | 82.6 | 69.8 | 94.1 | 100.1 |
| **សេវាកម្ម** | **630.6** | **807.7** | **776.6** | **762.6** | **727.6** | **921.9** | **952.9** | **941.9** | **1202.9** | **1247.9** |
| *សេវាកម្ម គិតជា% នៃនិយោជន៏សរុប* | *16.0%* | *20.5%* | *15.7%* | *17.1%* | *16.4%* | *18.8%* | *17.3%* | *17.9%* | *19.3%* | *19.5%* |
| ពាណិជ្ជកម្ម | 301.5 | 386.1 | 350.2 | 394.3 | 349.2 | 341.4 | 402.1 | 436.3 | 644.3 | 629.0 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 6.2 | 7.9 | 11.2 | 7.0 | 5.8 | 15.3 | 27.5 | 18.8 | 10.4 | 32.4 |
| ដឹកជញ្ជូន និង គមនាគមន៍ | 62.6 | 122.1 | 64.1 | 66.1 | 81.5 | 118.0 | 121.2 | 119.6 | 169.3 | 174.7 |
| អន្តរការិយកម្មហិរញ្ញវត្ថុ | 3.1 | 3.9 | 4.9 | 3.7 | 10.8 | 1.4 | 5.5 | 8.2 | 6.1 | 7.5 |
| អចលនទ្រព្យ និង ការជួល | 9.2 | 11.8 | 13.9 | 9.2 | 6.0 | 3.0 | 11.0 | 8.4 | 5.7 | 8.7 |
| រដ្ឋបាលសាធារណៈ | 149.6 | 149.7 | 169.8 | 143.3 | 138.2 | 222.0 | 187.3 | 147.0 | 149.4 | 143.5 |
| អប់រំ | 49.2 | 63.0 | 86.3 | 61.8 | 55.6 | 81.7 | 88.1 | 87.4 | 88.4 | 102.3 |
| សុខាភិបាល និង សង្គមកិច្ច | 15.4 | 19.7 | 21.9 | 15.5 | 18.1 | 26.2 | 27.5 | 30.2 | 24.8 | 36.2 |
| សេវាកម្មសង្គមដទៃទៀត | 21.5 | 27.6 | 33.3 | 15.8 | 20.1 | 68.3 | 38.6 | 40.1 | 35.2 | 44.9 |
| សេវាកម្មឯទៀត | 12.3 | 15.8 | 20.8 | 45.8 | 42.4 | 45.3 | 44.1 | 45.9 | 69.2 | 68.6 |
| **និយោជន៏សរុប** | **3941.2** | **3943.8** | **4931.8** | **4456.2** | **4429.7** | **4909.2** | **5519.0** | **5275.2** | **6243.3** | **6399.7** |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ (NIS) សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៣

## តារាងទី ៥. ចំនួនប្រជាជនដែលមានអាយុលើសពី ១០ ឆ្នាំ នៅក្នុងកំលាំងពលកម្ម មានការងារធ្វើ និងគ្មានការងារធ្វើ និងមិនស្ថិតនៅក្នុងកំលាំងពលកម្ម គិតតាមភេទ និងតាមក្រុម នៅកម្ពុជា: ខែ វិច្ឆិកា ឆ្នាំ ២០០១

| ក្រុមអាយុ | ចំនួនប្រជាជន | នៅក្នុងកំលាំងពលកម្ម | | មានការងារធ្វើ | | គ្មានការងារធ្វើ | | មិនស្ថិតក្នុងកំលាំងពលកម្ម | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | អត្រា | ចំនួន | អត្រា | ចំនួន | អត្រា | ចំនួន | អត្រា |
| **សរុប ទូទាំងកម្ពុជា** | **8,488,907** | **6,206,649** | **73.1** | **6,175,827** | **99.5** | **30,822** | **0.5** | **2,282,258** | **26.9** |
| 10-14 | 1,583,880 | 430,192 | 27.2 | 423,956 | 98.6 | 6,237 | 1.4 | 1,153,688 | 72.8 |
| 15 - 19 | 1,484,663 | 1,023,607 | 68.9 | 1,013,935 | 99.1 | 9,673 | 0.9 | 461,056 | 31.1 |
| 20 - 24 | 1,119,060 | 998,947 | 89.3 | 991,668 | 99.3 | 7,279 | 0.7 | 120,113 | 10.7 |
| 25 - 29 | 658,774 | 615,611 | 93.4 | 613,514 | 99.7 | 2,097 | 0.3 | 43,163 | 6.6 |
| 30 - 34 | 661,190 | 622,455 | 94.1 | 620,470 | 99.7 | 1,985 | 0.3 | 38,735 | 5.9 |
| 35 - 39 | 643,634 | 609,223 | 94.7 | 607,992 | 99.8 | 1,231 | 0.2 | 34,411 | 5.3 |
| 40 - 44 | 568,690 | 536,955 | 94.4 | 536,955 | 100 | 0 | 0 | 31,735 | 5.6 |
| 45 - 49 | 476,182 | 447,233 | 93.9 | 446,425 | 99.8 | 808 | 0.2 | 28,949 | 6.1 |
| 50 - 54 | 399,452 | 366,970 | 91.9 | 366,482 | 99.9 | 488 | 0.1 | 32,482 | 8.1 |
| 55 - 59 | 274,220 | 238,200 | 86.9 | 237,176 | 99.6 | 1,024 | 0.4 | 36,020 | 13.1 |
| 60 - 64 | 226,473 | 164,754 | 72.7 | 164,754 | 100 | 0 | 0 | 61,719 | 27.3 |
| ចាប់ពី 65 ឡើង | 392,688 | 152,501 | 38.8 | 152,501 | 100 | 0 | 0 | 240,187 | 61.2 |
| **បុរស** | **4,057,152** | **3,000,152** | **73.9** | **2,985,843** | **99.5** | **14,309** | **0.5** | **1,057,000** | **26.1** |
| 10-14 | 821,707 | 230,256 | 28 | 227,559 | 98.8 | 2,697 | 1.2 | 591,451 | 72.0 |
| 15 - 19 | 730,633 | 468,313 | 64.1 | 462,588 | 98.8 | 5,725 | 1.2 | 262,320 | 35.9 |
| 20 - 24 | 547,042 | 487,618 | 89.1 | 484,200 | 99.3 | 3,419 | 0.7 | 59,424 | 10.9 |
| 25 - 29 | 327,067 | 316,439 | 96.8 | 314,873 | 99.5 | 1,566 | 0.5 | 10,628 | 3.2 |
| 30 - 34 | 309,308 | 303,267 | 98 | 302,472 | 99.7 | 796 | 0.3 | 6,041 | 2.0 |
| 35 - 39 | 298,412 | 294,297 | 98.6 | 294,262 | 100 | 35 | 0 | 4,115 | 1.4 |
| 40 - 44 | 251,870 | 248,845 | 98.8 | 248,845 | 100 | 0 | 0 | 3,025 | 1.2 |
| 45 - 49 | 189,743 | 186,275 | 98.2 | 186,202 | 100 | 73 | 0 | 3,468 | 1.8 |
| 50 - 54 | 173,304 | 169,182 | 97.6 | 169,182 | 100 | 0 | 0 | 4,122 | 2.4 |
| 55 - 59 | 126,368 | 118,459 | 93.7 | 118,459 | 100 | 0 | 0 | 7,909 | 6.3 |
| 60 - 64 | 101,676 | 83,658 | 82.3 | 83,658 | 100 | 0 | 0 | 18,018 | 17.7 |
| ចាប់ពី 65 ឡើង | 180,022 | 93,543 | 52 | 93,543 | 100 | 0 | 0 | 86,479 | 48.0 |
| **ស្ត្រី** | **4,431,755** | **3,206,497** | **72.4** | **3,189,985** | **99.5** | **16,513** | **0.5** | **1,225,258** | **27.6** |
| 10-14 | 762,173 | 199,937 | 26.2 | 196,397 | 98.2 | 3,540 | 1.8 | 562,236 | 73.8 |
| 15 - 19 | 754,030 | 555,294 | 73.6 | 551,346 | 99.3 | 3,948 | 0.7 | 198,736 | 26.4 |
| 20 - 24 | 572,018 | 511,328 | 89.4 | 507,468 | 99.2 | 3,860 | 0.8 | 60,690 | 10.6 |
| 25 - 29 | 331,708 | 299,172 | 90.2 | 298,641 | 99.8 | 531 | 0.2 | 32,536 | 9.8 |
| 30 - 34 | 351,882 | 319,188 | 90.7 | 317,999 | 99.6 | 1,189 | 0.4 | 32,694 | 9.3 |
| 35 - 39 | 345,222 | 314,926 | 91.2 | 313,729 | 99.6 | 1,197 | 0.4 | 30,296 | 8.8 |
| 40 - 44 | 316,820 | 288,110 | 90.9 | 288,110 | 100 | 0 | 0 | 28,710 | 9.1 |
| 45 - 49 | 286,440 | 260,958 | 91.1 | 260,222 | 99.7 | 736 | 0.3 | 25,482 | 8.9 |
| 50 - 54 | 226,148 | 197,789 | 87.5 | 197,301 | 99.8 | 488 | 0.2 | 28,359 | 12.5 |
| 55 - 59 | 147,852 | 119,741 | 81 | 118,717 | 99.1 | 1,024 | 0.9 | 28,111 | 19.0 |
| 60 - 64 | 124,797 | 81,096 | 65 | 81,096 | 100 | 0 | 0 | 43,701 | 35.0 |
| ចាប់ពី 65 ឡើង | 212,666 | 58,958 | 27.7 | 58,958 | 100 | 0 | 0 | 153,708 | 72.3 |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ (NIS) សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៣

## តារាងទី ៦. ផលិតផលក្នុងស្រុកសរុប GDP -គិតលើមូលដ្ឋានថ្លៃបច្ចុប្បន្ន) និង GDP ក្នុងពលរដ្ឋម្នាក់ៗ

(ពាន់លានរៀល)

| | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002p/ |
|---|---|---|---|---|---|---|---|---|---|---|
| GDP គីតជាពាន់លានរៀល | 6666 | 6986 | 8294 | 9024 | 9927 | 11609 | 13131 | 13810 | 14544 | 15667 |
| អត្រាកំណើនជាភាគរយ (%) | | 4.8% | 18.7% | 8.8% | 10.0% | 16.9% | 13.1% | 5.2% | 5.3% | 7.7% |
| GDP ក្នុងម្នាក់ៗគិតជាពាន់លានរៀល | 704 | 702 | 792 | 818 | 853 | 953 | 1050 | 1077 | 1106 | 1163 |
| អត្រាកំណើនជាភាគរយ (%) | | -0.3% | 12.9% | 3.2% | 4.3% | 11.7% | 10.2% | 2.5% | 2.7% | 5.1% |
| GDP គិតជាលានដុល្លារអាមេរិក | 2427 | 2718 | 3362 | 3418 | 3319 | 3076 | 3443 | 3579 | 3706 | 3996 |
| អត្រាកំណើនជាភាគរយ (%) | | 12.0% | 23.7% | 1.7% | -2.9% | -7.3% | 11.9% | 3.9% | 3.6% | 7.8% |
| GDP ក្នុងម្នាក់ៗគិតជាដុល្លារអាមេរិក | 256 | 273 | 321 | 310 | 285 | 252 | 275 | 279 | 282 | 297 |
| អត្រាកំណើនជាភាគរយ (%) | | 6.6% | 17.6% | -3.5% | -8.0% | -11.5% | 9.1% | 1.3% | 1.0% | 5.2% |
| ចំណាយប្រើប្រាស់ចុងក្រោយ របស់គ្រួសារ (HFCE) | 6713 | 6571 | 7916 | 8725 | 8952 | 10776 | 11582 | 11838 | 12038 | 12497 |
| HFCE ក្នុងម្នាក់ៗគិតជាពាន់រៀល | 709 | 660 | 756 | 791 | 769 | 884 | 926 | 923 | 916 | 927 |
| HFCE ប្រចាំខែក្នុងម្នាក់ៗគិតជារៀល | 59049 | 55011 | 63001 | 65895 | 64088 | 73689 | 77192 | 76919 | 76295 | 77297 |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ-គណនីជាតិនៃកម្ពុជាពីឆ្នាំ ១៩៩៣-២០០២ (ខែ កក្កដា ឆ្នាំ ២០០៣)

# តារាងទី ៧. ផលិតផលក្នុងស្រុកសរុប (លើមូលដ្ឋានថ្លៃថេរឆ្នាំ ២០០០) និង GDP ក្នុងពលរដ្ឋម្នាក់ៗ

(គិតជាពាន់លានរៀល)

| | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002p/ |
|---|---|---|---|---|---|---|---|---|---|---|
| GDP គិតជាពាន់លានរៀល | 8594 | 9371 | 10017 | 10514 | 11231 | 11647 | 12903 | 13810 | 14593 | 15392 |
| អត្រាកំណើនជាភាគរយ (%) | | 9.0% | 6.9% | 5.0% | 6.8% | 3.7% | 10.8% | 7.0% | 5.7% | 5.5% |
| GDP ក្នុងម្នាក់ៗគិតជាពាន់លានរៀល | 907 | 941 | 957 | 953 | 965 | 956 | 1032 | 1077 | 1110 | 1142 |
| អត្រាកំណើនជាភាគរយ (%) | | 3.8% | 1.6% | -0.4% | 1.3% | -0.9% | 8.0% | 4.3% | 3.1% | 2.9% |
| GDP គិតជាលានដុល្លារអាមេរិក | 3128 | 3646 | 4060 | 3983 | 3755 | 3086 | 3383 | 3579 | 3719 | 3926 |
| អត្រាកំណើនជាភាគរយ (%) | | 16.6% | 11.4% | -1.9% | -5.7% | -17.8% | 9.6% | 5.8% | 3.9% | 5.6% |
| GDP ក្នុងម្នាក់ៗគិតជាដុល្លារអាមេរិក | 330 | 366 | 388 | 361 | 323 | 253 | 271 | 279 | 283 | 291 |
| អត្រាកំណើនជាភាគរយ (%) | | 10.9% | 5.9% | -6.9% | -10.6% | -21.5% | 6.8% | 3.1% | 1.4% | 3.0% |
| ចំណាយប្រើប្រាស់ចុងក្រោយ របស់គ្រួសារ (HFCE) | 8087 | 8476 | 9328 | 9993 | 9927 | 10797 | 11490 | 11838 | 11868 | 12090 |
| HFCE ក្នុងម្នាក់ៗគិតជាពាន់រៀល | 854 | 851 | 891 | 906 | 853 | 886 | 919 | 923 | 903 | 897 |
| HFCE ប្រចាំខែក្នុងម្នាក់ៗគិតជារៀល | 71131 | 70956 | 74244 | 75466 | 71072 | 73834 | 76581 | 76919 | 75224 | 74778 |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ-គណនីជាតិនៃកម្ពុជាពីឆ្នាំ ១៩៩៣-២០០២ (ខែ កក្កដា ឆ្នាំ ២០០៣)

## តារាងទី ៨. GDP តាមប្រភពវិស័យ និងតាមផ្នែកសេដ្ឋកិច្ច លើមូលដ្ឋានថ្លៃបច្ចុប្បន្ន

(ពាន់លានរៀល)

| | | | | | | ពាន់លានរៀល | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1993r/ | 1994r/ | 1995r/ | 1996r/ | 1997r/ | 1998r/ | 1999r/ | 2000r/ | 2001r/ | 2002p/ |
| **កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** | **3,070** | **3,231** | **4,017** | **4,068** | **4,475** | **5,248** | **5,560** | **5,191** | **5,162** | **5,231** |
| កសិផល | 1,169 | 1,313 | 1,994 | 1,941 | 2,052 | 2,456 | 2,585 | 2,429 | 2,385 | 2,250 |
| បសុសត្វ និងសត្វស្លាប | 483 | 443 | 489 | 551 | 561 | 677 | 824 | 737 | 799 | 840 |
| ជលផល | 1,133 | 953 | 1,034 | 1,176 | 1,229 | 1,492 | 1,610 | 1,561 | 1,564 | 1,801 |
| រុក្ខាប្រមាញ់ និងការកាប់ឈើ | 285 | 522 | 500 | 400 | 633 | 623 | 541 | 464 | 414 | 340 |
| **ឧស្សាហកម្ម** | **835** | **970** | **1,193** | **1,356** | **1,629** | **1,996** | **2,371** | **3,047** | **3,519** | **4,115** |
| ការធ្វើអាជីវកម្មរ៉ែ | 13 | 16 | 19 | 20 | 21 | 19 | 27 | 34 | 40 | 47 |
| កម្មន្តសាល | 561 | 624 | 758 | 909 | 1,156 | 1,535 | 1,737 | 2,239 | 2,556 | 2,970 |
| ស្បៀងអាហារ ភេសជ្ជៈ និងថ្នាំជក់ | 280 | 265 | 337 | 347 | 364 | 433 | 467 | 433 | 442 | 450 |
| វាយនភណ្ឌ សំលៀកបំពាក់ និងស្បែកជើង | 71 | 80 | 123 | 198 | 378 | 588 | 792 | 1,296 | 1,622 | 1,959 |
| ឈើ ក្រដាស និងការបោះពុម្ព | 58 | 115 | 105 | 133 | 156 | 228 | 129 | 110 | 83 | 101 |
| កម្មន្តសាលផ្នែកកៅស៊ូ | 24 | 23 | 31 | 43 | 49 | 47 | 56 | 69 | 62 | 74 |
| កម្មន្តសាលដទៃទៀត | 128 | 142 | 163 | 189 | 209 | 239 | 293 | 330 | 347 | 385 |
| អគ្គិសនី ឧស្ម័ន និង ទឹក | 24 | 31 | 40 | 40 | 41 | 47 | 43 | 43 | 57 | 76 |
| សំណង់ | 237 | 299 | 376 | 387 | 412 | 396 | 565 | 732 | 867 | 1,023 |
| **សេវាកម្ម** | **2,580** | **2,467** | **2,761** | **3,180** | **3,409** | **3,895** | **4,448** | **4,856** | **5,059** | **5,358** |
| ពាណិជ្ជកម្ម | 966 | 892 | 968 | 1,104 | 1,187 | 1,313 | 1,419 | 1,432 | 1,446 | 1,484 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 155 | 194 | 239 | 250 | 283 | 320 | 396 | 473 | 575 | 657 |
| ដឹកជញ្ជូន និងគមនាគមន៍ | 376 | 400 | 449 | 533 | 570 | 638 | 779 | 878 | 947 | 960 |
| ហិរញ្ញវត្ថុ | 24 | 28 | 77 | 87 | 98 | 100 | 129 | 175 | 128 | 85 |
| រដ្ឋបាលសាធារណៈ | 142 | 229 | 234 | 296 | 305 | 333 | 389 | 377 | 359 | 390 |
| អចលនទ្រព្យ និងអាជីវកម្ម | 623 | 452 | 483 | 537 | 601 | 733 | 764 | 826 | 853 | 880 |
| សេវាកម្មដទៃទៀត | 295 | 274 | 312 | 374 | 366 | 458 | 573 | 696 | 751 | 903 |
| **ពន្ធលើផលិតផលដកឧបត្ថម្ភកធន** | **195** | **334** | **395** | **484** | **537** | **594** | **865** | **870** | **921** | **1,040** |
| ដក ឧបត្ថម្ភកធន | 2 | 4 | 12 | 15 | 6 | 14 | 12 | 31 | 32 | 51 |
| ដក បន្ទុកសេវាហិរញ្ញវត្ថុ | 15 | 17 | 73 | 63 | 123 | 124 | 114 | 154 | 118 | 78 |
| **ផលិតផលក្នុងស្រុកសរុប (GDP)** | **6,665** | **6,985** | **8,293** | **9,024** | **9,927** | **11,609** | **13,130** | **13,809** | **14,543** | **15,665** |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ (ណីស) សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៣

*r/ - តួលេខបាន់ស្មានក្រោយពេលកែសំរួល*

*p/ - តួលេខបាន់ស្មានជំហានដំបូង*

## តារាងទី ៨ក: GDP គិតតាមប្រភពវិស័យ និងតាមផ្នែកសេដ្ឋកិច្ច លើមូលដ្ឋានថ្លៃបច្ចុប្បន្ន

## ( គិតជាភាគរយនៃ GDP )

| | គិតជាភាគរយនៃ GDP | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1993 r/ | 1994 r/ | 1995 r/ | 1996 r/ | 1997 r/ | 1998 r/ | 1999 r/ | 2000 r/ | 2001 r/ | 2002 p/ |
| **កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** | **46.1%** | **46.3%** | **48.4%** | **45.1%** | **45.1%** | **45.2%** | **42.3%** | **37.6%** | **35.5%** | **33.4%** |
| កសិផល | 17.5% | 18.8% | 24.0% | 21.5% | 20.7% | 21.2% | 19.7% | 17.6% | 16.4% | 14.4% |
| បសុសត្វ និងសត្វស្លាប | 7.2% | 6.3% | 5.9% | 6.1% | 5.7% | 5.8% | 6.3% | 5.3% | 5.5% | 5.4% |
| ជលផល | 17.0% | 13.6% | 12.5% | 13.0% | 12.4% | 12.9% | 12.3% | 11.3% | 10.8% | 11.5% |
| រុក្ខាប្រមាញ់ និងការកាប់ឈើ | 4.3% | 7.5% | 6.0% | 4.4% | 6.4% | 5.4% | 4.1% | 3.4% | 2.8% | 2.2% |
| **ឧស្សាហកម្ម** | **12.5%** | **13.9%** | **14.4%** | **15.0%** | **16.4%** | **17.2%** | **18.1%** | **22.1%** | **24.2%** | **26.3%** |
| ការធ្វើអាជីវកម្មរ៉ែ | 0.2% | 0.2% | 0.2% | 0.2% | 0.2% | 0.2% | 0.2% | 0.2% | 0.3% | 0.3% |
| កម្មន្តសាល | 8.4% | 8.9% | 9.1% | 10.1% | 11.6% | 13.2% | 13.2% | 16.2% | 17.6% | 19.0% |
| ស្បៀងអាហារ ភេសជ្ជៈនិងថ្នាំជក់ | 4.2% | 3.8% | 4.1% | 3.8% | 3.7% | 3.7% | 3.6% | 3.1% | 3.0% | 2.9% |
| វាយនភណ្ឌ សំលៀកបំពាក់និងស្បែកជើង | 1.1% | 1.1% | 1.5% | 2.2% | 3.8% | 5.1% | 6.0% | 9.4% | 11.2% | 12.5% |
| ឈើ ក្រដាស និងការបោះពុម្ព | 0.9% | 1.6% | 1.3% | 1.5% | 1.6% | 2.0% | 1.0% | 0.8% | 0.6% | 0.6% |
| កម្មន្តសាលផ្នែកកៅស៊ូ | 0.4% | 0.3% | 0.4% | 0.5% | 0.5% | 0.4% | 0.4% | 0.5% | 0.4% | 0.5% |
| កម្មន្តសាលដទៃទៀត | 1.9% | 2.0% | 2.0% | 2.1% | 2.1% | 2.1% | 2.2% | 2.4% | 2.4% | 2.5% |
| អគ្គិសនី ឧស្ម័ន និង ទឹក | 0.4% | 0.4% | 0.5% | 0.4% | 0.4% | 0.4% | 0.3% | 0.3% | 0.4% | 0.5% |
| សំណង់ | 3.6% | 4.3% | 4.5% | 4.3% | 4.1% | 3.4% | 4.3% | 5.3% | 6.0% | 6.5% |
| **សេវាកម្ម** | **38.7%** | **35.3%** | **33.3%** | **35.2%** | **34.3%** | **33.5%** | **33.9%** | **35.2%** | **34.8%** | **34.2%** |
| ពាណិជ្ជកម្ម | 14.5% | 12.8% | 11.7% | 12.2% | 12.0% | 11.3% | 10.8% | 10.4% | 9.9% | 9.5% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 2.3% | 2.8% | 2.9% | 2.8% | 2.9% | 2.8% | 3.0% | 3.4% | 4.0% | 4.2% |
| ដឹកជញ្ជូន និងគមនាគមន៍ | 5.6% | 5.7% | 5.4% | 5.9% | 5.7% | 5.5% | 5.9% | 6.4% | 6.5% | 6.1% |
| ហិរញ្ញវត្ថុ | 0.4% | 0.4% | 0.9% | 1.0% | 1.0% | 0.9% | 1.0% | 1.3% | 0.9% | 0.5% |
| រដ្ឋបាលសាធារណៈ | 2.1% | 3.3% | 2.8% | 3.3% | 3.1% | 2.9% | 3.0% | 2.7% | 2.5% | 2.5% |
| អចលនទ្រព្យ និងអាជីវកម្ម | 9.3% | 6.5% | 5.8% | 6.0% | 6.1% | 6.3% | 5.8% | 6.0% | 5.9% | 5.6% |
| សេវាកម្មដទៃទៀត | 4.4% | 3.9% | 3.8% | 4.1% | 3.7% | 3.9% | 4.4% | 5.0% | 5.2% | 5.8% |
| **ពន្ធលើផលិតផលដកឧបត្ថម្ភកធន** | **2.9%** | **4.8%** | **4.8%** | **5.4%** | **5.4%** | **5.1%** | **6.6%** | **6.3%** | **6.3%** | **6.6%** |
| ដក ឧបត្ថម្ភកធន | 0.0% | 0.1% | 0.1% | 0.2% | 0.1% | 0.1% | 0.1% | 0.2% | 0.2% | 0.3% |
| ដក បន្ទុកសេវាហិរញ្ញវត្ថុ | 0.2% | 0.2% | 0.9% | 0.7% | 1.2% | 1.1% | 0.9% | 1.1% | 0.8% | 0.5% |
| **ផលិតផលក្នុងស្រុកសរុប (GDP)** | **100%** | **100%** | **100%** | **100%** | **100%** | **100%** | **100%** | **100%** | **100%** | **100%** |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ (NIS) សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៣

*r/ - តួលេខប៉ាន់ស្មានក្រោយពេលកែសំរួល*

*p/ - តួលេខប៉ាន់ស្មានជំហានដំបូង*

## តារាងទី ៩: GDP គិតតាមប្រភពផលិត និងគិតតាមផ្នែកសេដ្ឋកិច្ច តាមថ្លៃថេរឆ្នាំ ២០០០

(គិតជាពាន់លានរៀល)

| | ពាន់លានរៀល | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1993r/ | 1994r/ | 1995r/ | 1996r/ | 1997r/ | 1998r/ | 1999r/ | 2000r/ | 2001r/ | 2002p/ |
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **3,903** | **4,339** | **4,484** | **4,527** | **4,814** | **5,094** | **5,269** | **5,191** | **5,307** | **5,162** |
| កសិផល | 1,627 | 1,670 | 1,859 | 1,917 | 1,888 | 2,049 | 2,358 | 2,429 | 2,442 | 2,300 |
| បសុសត្វ និងសត្វស្លាប | 731 | 709 | 767 | 779 | 774 | 823 | 813 | 737 | 822 | 832 |
| ជលផល | 1,158 | 1,205 | 1,305 | 1,365 | 1,442 | 1,498 | 1,474 | 1,561 | 1,666 | 1,689 |
| រុក្ខាប្រមាញ់ និងការកាប់ឈើ | 387 | 756 | 554 | 467 | 711 | 724 | 624 | 464 | 377 | 342 |
| **ឧស្សាហកម្ម** | **1,102** | **1,292** | **1,592** | **1,675** | **2,003** | **1,954** | **2,332** | **3,047** | **3,441** | **4,051** |
| ការធ្វើអាជីវកម្មរ៉ែ | 18 | 23 | 28 | 24 | 24 | 21 | 27 | 34 | 38 | 45 |
| កម្មន្តសាល | 685 | 779 | 969 | 1,103 | 1,443 | 1,474 | 1,729 | 2,239 | 2,557 | 2,944 |
| ស្បៀងអាហារ ភេសជ្ជៈ និងថ្នាំជក់ | 344 | 335 | 395 | 394 | 403 | 438 | 458 | 433 | 453 | 444 |
| វាយនភណ្ឌ សំលៀកបំពាក់ និងស្បែកជើង | 63 | 79 | 141 | 239 | 453 | 589 | 793 | 1,296 | 1,590 | 1,925 |
| ឈើ ក្រដាស និងការបោះពុម្ព | 96 | 168 | 218 | 230 | 333 | 149 | 125 | 110 | 75 | 85 |
| កម្មន្តសាលផ្នែកកៅស៊ូ | 23 | 21 | 25 | 30 | 31 | 55 | 63 | 69 | 70 | 69 |
| កម្មន្តសាលដទៃទៀត | 160 | 177 | 189 | 210 | 223 | 244 | 290 | 330 | 369 | 421 |
| អគ្គិសនី ឧស្ម័ន និង ទឹក | 26 | 28 | 38 | 38 | 39 | 40 | 42 | 43 | 44 | 46 |
| សំណង់ | 374 | 462 | 558 | 511 | 498 | 420 | 535 | 732 | 802 | 1,017 |
| **សេវាកម្ម** | **3,337** | **3,270** | **3,545** | **3,821** | **3,952** | **4,143** | **4,595** | **4,856** | **5,060** | **5,287** |
| ពាណិជ្ជកម្ម | 1,354 | 1,198 | 1,258 | 1,286 | 1,403 | 1,436 | 1,463 | 1,432 | 1,445 | 1,458 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 202 | 239 | 340 | 342 | 353 | 349 | 413 | 473 | 558 | 622 |
| ដឹកជញ្ជូន និងគមនាគមន៍ | 542 | 604 | 647 | 722 | 675 | 685 | 842 | 878 | 965 | 972 |
| ហិរញ្ញវត្ថុ | 40 | 49 | 118 | 125 | 130 | 117 | 141 | 175 | 161 | 151 |
| រដ្ឋបាលសាធារណៈ | 168 | 287 | 269 | 333 | 347 | 384 | 380 | 377 | 367 | 374 |
| អចលនទ្រព្យ និងអាជីវកម្ម | 731 | 567 | 589 | 627 | 669 | 737 | 796 | 826 | 852 | 879 |
| សេវាកម្មដទៃទៀត | 301 | 327 | 325 | 387 | 376 | 436 | 561 | 696 | 712 | 831 |
| **ពន្ធលើផលិតផលដកឧបត្ថម្ភកធន** | **277** | **500** | **509** | **582** | **613** | **598** | **833** | **870** | **932** | **1,031** |
| ដក ឧបត្ថម្ភកធន | 2 | 5 | 11 | 20 | 8 | 15 | 11 | 31 | 33 | 52 |
| ដក បន្ទុកធនាគារ | 25 | 30 | 114 | 91 | 151 | 142 | 126 | 154 | 147 | 139 |
| **ផលិតផលក្នុងស្រុកសរុប (GDP)** | **8,593** | **9,371** | **10,017** | **10,514** | **11,231** | **11,647** | **12,902** | **13,809** | **14,592** | **15,392** |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ (NIS) សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៣

*r/ - តួលេខបាន់ស្មានក្រោយពេលកែសំរួល*

*p/ - តួលេខបាន់ស្មានជំហានដំបូង*

## តារាងទី ៩ក: GDP គិតតាមប្រភពផលិត និងគិតតាមផ្នែកសេដ្ឋកិច្ច តាមថ្លៃថេរឆ្នាំ ២០០០
(គិតជាភាគរយ)

| | គិតជាភាគរយនៃ GDP | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1993r/ | 1994r/ | 1995r/ | 1996r/ | 1997r/ | 1998r/ | 1999r/ | 2000r/ | 2001r/ | 2002p/ |
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **45.4%** | **46.3%** | **44.8%** | **43.1%** | **42.9%** | **43.7%** | **40.8%** | **37.6%** | **36.4%** | **33.5%** |
| កសិផល | 18.9% | 17.8% | 18.6% | 18.2% | 16.8% | 17.6% | 18.3% | 17.6% | 16.7% | 14.9% |
| បសុសត្វ និងសត្វស្លាប | 8.5% | 7.6% | 7.7% | 7.4% | 6.9% | 7.1% | 6.3% | 5.3% | 5.6% | 5.4% |
| ជលផល | 13.5% | 12.9% | 13.0% | 13.0% | 12.8% | 12.9% | 11.4% | 11.3% | 11.4% | 11.0% |
| រុក្ខាប្រមាញ់ និងការកាប់ឈើ | 4.5% | 8.1% | 5.5% | 4.4% | 6.3% | 6.2% | 4.8% | 3.4% | 2.6% | 2.2% |
| **ឧស្សាហកម្ម** | **12.8%** | **13.8%** | **15.9%** | **15.9%** | **17.8%** | **16.8%** | **18.1%** | **22.1%** | **23.6%** | **26.3%** |
| ការធ្វើអាជីវកម្មរ៉ែ | 0.2% | 0.2% | 0.3% | 0.2% | 0.2% | 0.2% | 0.2% | 0.2% | 0.3% | 0.3% |
| កម្មន្តសាល | 8.0% | 8.3% | 9.7% | 10.5% | 12.8% | 12.7% | 13.4% | 16.2% | 17.5% | 19.1% |
| ស្បៀងអាហារ ភេសជ្ជៈ និងថ្នាំជក់ | 4.0% | 3.6% | 3.9% | 3.7% | 3.6% | 3.8% | 3.5% | 3.1% | 3.1% | 2.9% |
| វាយនភណ្ឌ សំលៀកបំពាក់ និងស្បែកជើង | 0.7% | 0.8% | 1.4% | 2.3% | 4.0% | 5.1% | 6.1% | 9.4% | 10.9% | 12.5% |
| ឈើ ក្រដាស និងការបោះពុម្ព | 1.1% | 1.8% | 2.2% | 2.2% | 3.0% | 1.3% | 1.0% | 0.8% | 0.5% | 0.6% |
| កម្មន្តសាលផ្នែកកៅស៊ូ | 0.3% | 0.2% | 0.2% | 0.3% | 0.3% | 0.5% | 0.5% | 0.5% | 0.5% | 0.4% |
| កម្មន្តសាលដទៃទៀត | 1.9% | 1.9% | 1.9% | 2.0% | 2.0% | 2.1% | 2.2% | 2.4% | 2.5% | 2.7% |
| អគ្គិសនី ឧស្ម័ន និង ទឹក | 0.3% | 0.3% | 0.4% | 0.4% | 0.3% | 0.3% | 0.3% | 0.3% | 0.3% | 0.3% |
| សំណង់ | 4.4% | 4.9% | 5.6% | 4.9% | 4.4% | 3.6% | 4.1% | 5.3% | 5.5% | 6.6% |
| **សេវាកម្ម** | **38.8%** | **34.9%** | **35.4%** | **36.3%** | **35.2%** | **35.6%** | **35.6%** | **35.2%** | **34.7%** | **34.3%** |
| ពាណិជ្ជកម្ម | 15.8% | 12.8% | 12.6% | 12.2% | 12.5% | 12.3% | 11.3% | 10.4% | 9.9% | 9.5% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 2.4% | 2.5% | 3.4% | 3.3% | 3.1% | 3.0% | 3.2% | 3.4% | 3.8% | 4.0% |
| ដឹកជញ្ជូន និងគមនាគមន៍ | 6.3% | 6.4% | 6.5% | 6.9% | 6.0% | 5.9% | 6.5% | 6.4% | 6.6% | 6.3% |
| ហិរញ្ញវត្ថុ | 0.5% | 0.5% | 1.2% | 1.2% | 1.2% | 1.0% | 1.1% | 1.3% | 1.1% | 1.0% |
| រដ្ឋបាលសាធារណៈ | 1.9% | 3.1% | 2.7% | 3.2% | 3.1% | 3.3% | 2.9% | 2.7% | 2.5% | 2.4% |
| អចលនទ្រព្យ និងអាជីវកម្ម | 8.5% | 6.0% | 5.9% | 6.0% | 6.0% | 6.3% | 6.2% | 6.0% | 5.8% | 5.7% |
| សេវាកម្មដទៃទៀត | 3.5% | 3.5% | 3.2% | 3.7% | 3.3% | 3.7% | 4.3% | 5.0% | 4.9% | 5.4% |
| **ពន្ធលើផលិតផលដកឧបត្ថម្ភកធន** | **3.2%** | **5.3%** | **5.1%** | **5.5%** | **5.5%** | **5.1%** | **6.5%** | **6.3%** | **6.4%** | **6.7%** |
| ដក ឧបត្ថម្ភកធន | 0.0% | 0.1% | 0.1% | 0.2% | 0.1% | 0.1% | 0.1% | 0.2% | 0.2% | 0.3% |
| ដក បន្ទុកធនាគារ | 0.3% | 0.3% | 1.1% | 0.9% | 1.3% | 1.2% | 1.0% | 1.1% | 1.0% | 0.9% |
| **ផលិតផលក្នុងស្រុកសរុប (GDP)** | **100%** | **100%** | **100%** | **100%** | **100%** | **100%** | **100%** | **100%** | **100%** | **100%** |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ (NIS) សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៣

*r/ - តួលេខបាន់ស្មានក្រោយពេលកែសំរួល*

*p/ - តួលេខបាន់ស្មានជាបានដំបូង*

# តារាងទី ១០: GDP គិតតាមប្រភពផលិត និងគិតតាមផ្នែកសេដ្ឋកិច្ច តាមថ្លៃថេរឆ្នាំ ២០០០

| | អត្រាកំណើនប្រចាំឆ្នាំ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | 1994 r/ | 1995 r/ | 1996 r/ | 1997 r/ | 1998 r/ | 1999 r/ | 2000 r/ | 2001 r/ | 2002 p/ |
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **11.2%** | **3.3%** | **1.0%** | **6.3%** | **5.8%** | **3.4%** | **-1.5%** | **2.2%** | **-2.7%** |
| កសិផល | 2.6% | 11.3% | 3.1% | -1.5% | 8.6% | 15.1% | 3.0% | 0.5% | -5.8% |
| បសុសត្វ និងសត្វស្លាប | -3.1% | 8.2% | 1.5% | -0.6% | 6.3% | -1.2% | -9.4% | 11.6% | 1.2% |
| ជលផល | 4.1% | 8.2% | 4.6% | 5.6% | 3.9% | -1.6% | 5.9% | 6.8% | 1.3% |
| រុក្ខាប្រមាញ់ និងការកាប់ឈើ | 95.7% | -26.7% | -15.7% | 52.3% | 1.8% | -13.8% | -25.6% | -18.9% | -9.3% |
| **ឧស្សាហកម្ម** | **17.2%** | **23.3%** | **5.2%** | **19.5%** | **-2.4%** | **19.3%** | **30.7%** | **12.9%** | **17.7%** |
| ការធ្វើអាជីវកម្មរ៉ែ | 29.4% | 20.0% | -13.7% | -1.8% | -13.7% | 32.8% | 24.8% | 13.4% | 18.7% |
| កម្មន្តសាល | 13.8% | 24.4% | 13.8% | 30.8% | 2.1% | 17.3% | 29.5% | 14.2% | 15.1% |
| ស្បៀងអាហារ ភេសជ្ជៈ និងថ្នាំជក់ | -2.6% | 18.2% | -0.4% | 2.3% | 8.6% | 4.7% | -5.4% | 4.5% | -2.0% |
| វាយនភណ្ឌ សំលៀកបំពាក់ និងស្បែកជើង | 25.8% | 77.4% | 69.6% | 89.9% | 30.0% | 34.6% | 63.4% | 22.7% | 21.0% |
| ឈើ ក្រដាស និងការបោះពុម្ព | 75.5% | 30.0% | 5.3% | 45.1% | -55.4% | -16.1% | -11.9% | -31.9% | 13.3% |
| កម្មន្តសាលផ្នែកកៅស៊ូ | -8.5% | 19.5% | 21.4% | 3.7% | 76.4% | 14.8% | 10.0% | 0.8% | -0.7% |
| កម្មន្តសាលដទៃទៀត | 10.5% | 7.1% | 10.9% | 6.0% | 9.5% | 18.9% | 14.0% | 11.7% | 14.0% |
| អគ្គិសនី ឧស្ម័ន និង ទឹក | 8.6% | 36.2% | 0.8% | 1.3% | 3.7% | 3.8% | 4.0% | 2.5% | 2.5% |
| សំណង់ | 23.4% | 20.8% | -8.5% | -2.5% | -15.7% | 27.4% | 36.8% | 9.6% | 26.8% |
| **សេវាកម្ម** | **-2.0%** | **8.4%** | **7.8%** | **3.4%** | **4.8%** | **10.9%** | **5.7%** | **4.2%** | **4.5%** |
| ពាណិជ្ជកម្ម | -11.5% | 5.0% | 2.2% | 9.1% | 2.4% | 1.8% | -2.1% | 0.9% | 0.8% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 18.1% | 42.5% | 0.6% | 3.3% | -1.3% | 18.5% | 14.4% | 18.1% | 11.4% |
| ដឹកជញ្ជូន និងគមនាគមន៍ | 11.4% | 7.1% | 11.6% | -6.6% | 1.5% | 23.0% | 4.2% | 9.9% | 0.8% |
| ហិរញ្ញវត្ថុ | 21.5% | 138.9% | 6.7% | 3.6% | -9.5% | 19.7% | 24.4% | -8.2% | -5.7% |
| រដ្ឋបាលសាធារណៈ | 71.3% | -6.4% | 23.9% | 4.2% | 10.8% | -1.2% | -0.8% | -2.4% | 1.6% |
| អចលនទ្រព្យ និងអាជីវកម្ម | -22.5% | 3.9% | 6.5% | 6.7% | 10.1% | 8.0% | 3.8% | 3.1% | 3.2% |
| សេវាកម្មដទៃទៀត | 8.8% | -0.5% | 18.8% | -2.9% | 16.1% | 28.8% | 24.0% | 2.3% | 16.8% |
| **ពន្ធលើផលិតផលដកឧបត្ថម្ភកធន** | **80.8%** | **1.8%** | **14.3%** | **5.3%** | **-2.4%** | **39.2%** | **4.5%** | **7.1%** | **10.6%** |
| ដក ឧបត្ថម្ភកធន | 104.7% | 128.1% | 90.6% | -61.6% | 93.6% | -24.6% | 171.6% | 5.5% | 57.1% |
| ដក បន្ទុកធនាគារ | **21.5%** | **269.1%** | **-19.8%** | **65.6%** | **-6.4%** | **-11.3%** | **23.1%** | **-4.7%** | **-5.3%** |
| **ផលិតផលក្នុងស្រុកសរុប (GDP)** | **9.0%** | **6.9%** | **5.0%** | **6.8%** | **3.7%** | **10.8%** | **7.0%** | **5.7%** | **5.5%** |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ (NIS) សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៣

*r/ - តួលេខបាន់ស្មានក្រោយពេលកែសំរួល*

*p/ - តួលេខបាន់ស្មានជំហានដំបូង*

## តារាងទី ១១: សន្ទស្សន៍ថ្លៃធៀបនឹង GDP ឆ្នាំ 1994-2002
## បំរែបំរួលប្រចាំឆ្នាំ គិតជាភាគរយ

| | បំរែបំរួលប្រចាំឆ្នាំ គិតជាភាគរយ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | 1994r/ | 1995r/ | 1996r/ | 1997r/ | 1998r/ | 1999r/ | 2000r/ | 2001r/ | 2002p/ |
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **-5.4%** | **20.3%** | **0.3%** | **3.4%** | **10.9%** | **2.4%** | **-5.2%** | **-2.7%** | **4.2%** |
| កសិផល | 9.5% | 36.5% | -5.6% | 7.4% | 10.3% | -8.6% | -8.8% | -2.3% | 0.2% |
| បសុសត្វ និងសត្វស្លាប | -5.4% | 1.8% | 11.2% | 2.3% | 13.5% | 23.2% | -1.3% | -2.8% | 3.9% |
| ជលផល | -19.2% | 0.2% | 8.6% | -1.0% | 16.8% | 9.6% | -8.4% | -6.2% | 13.7% |
| រុក្ខាប្រមាញ់ និងការកាប់ឈើ | -6.5% | 30.7% | -5.1% | 3.9% | -3.2% | 0.8% | 15.2% | 9.9% | -9.5% |
| **ឧស្សាហកម្ម** | **-0.9%** | **-0.2%** | **8.0%** | **0.5%** | **25.6%** | **-0.4%** | **-1.7%** | **2.3%** | **-0.7%** |
| ការធ្វើអាជីវកម្មរ៉ែ | -5.8% | 1.4% | 16.7% | 7.0% | 9.1% | 3.7% | 0.9% | 4.2% | -1.0% |
| កម្មន្តសាល | -2.2% | -2.2% | 5.4% | -2.9% | 30.0% | -3.5% | -0.5% | 0.0% | 0.9% |
| ស្បៀងអាហារ ភេសជ្ជៈ និងថ្នាំជក់ | -2.8% | 7.7% | 3.6% | 2.4% | 9.6% | 3.1% | -1.9% | -2.3% | 3.8% |
| វាយនភណ្ឌ សំលៀកបំពាក់ និងស្បែកជើង | -10.2% | -13.3% | -5.3% | 0.7% | 19.4% | 0.2% | 0.1% | 2.0% | -0.2% |
| ឈើ ក្រដាស និងការបោះពុម្ព | 12.9% | -30.2% | 20.2% | -18.9% | 228.2% | -32.8% | -3.2% | 10.8% | 7.9% |
| កម្មន្តសាលផ្នែកកៅស៊ូ | 3.3% | 17.9% | 11.2% | 11.0% | -46.1% | 4.7% | 12.8% | -11.5% | 20.3% |
| កម្មន្តសាលដទៃទៀត | 0.0% | 7.0% | 5.1% | 4.2% | 4.5% | 3.1% | -1.1% | -6.0% | -2.6% |
| អគ្គិសនី ឧស្ម័ន និង ទឹក | 17.9% | -6.0% | 0.7% | 0.0% | 10.4% | -10.0% | -4.2% | 27.8% | 30.3% |
| សំណង់ | 2.2% | 4.1% | 12.4% | 9.3% | 14.0% | 11.9% | -5.3% | 8.1% | -7.0% |
| **សេវាកម្ម** | **-2.4%** | **3.2%** | **6.9%** | **3.7%** | **9.0%** | **3.0%** | **3.3%** | **0.0%** | **1.3%** |
| ពាណិជ្ជកម្ម | 4.3% | 3.4% | 11.6% | -1.4% | 8.0% | 6.1% | 3.1% | 0.1% | 1.7% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 6.1% | -13.7% | 4.0% | 9.8% | 14.6% | 4.2% | 4.5% | 3.0% | 2.4% |
| ដឹកជញ្ជូន និងគមនាគមន៍ | -4.5% | 4.7% | 6.3% | 14.5% | 10.3% | -0.8% | 8.1% | -1.8% | 0.5% |
| ហិរញ្ញវត្ថុ | -5.2% | 17.0% | 6.0% | 9.1% | 13.3% | 7.7% | 8.6% | -20.0% | -30.0% |
| រដ្ឋបាលសាធារណៈ | -6.2% | 9.2% | 2.3% | -1.1% | -1.4% | 18.0% | -2.3% | -2.2% | 7.0% |
| អចលនទ្រព្យ និងអាជីវកម្ម | -6.4% | 3.1% | 4.4% | 4.7% | 10.8% | -3.5% | 4.2% | 0.1% | 0.1% |
| សេវាកម្មដទៃទៀត | -14.7% | 14.3% | 1.0% | 0.9% | 7.9% | -2.9% | -2.1% | 5.6% | 2.9% |
| **ពន្ធលើផលិតផលដកឧបត្ថម្ភកធន** | **-4.9%** | **16.1%** | **7.0%** | **5.5%** | **13.4%** | **4.6%** | **-3.8%** | **-1.3%** | **2.2%** |
| ដក ឧបត្ថម្ភកធន | -5.2% | 17.0% | -33.8% | 9.1% | 16.4% | 11.2% | -3.5% | -3.5% | 2.3% |
| ដក បន្ទុកធនាគារ | -5.2% | 14.8% | 8.0% | 17.6% | 8.0% | 3.5% | 10.0% | -20.0% | -30.0% |
| **ផលិតផលក្នុងស្រុកសរុប (GDP)** | **-3.9%** | **11.1%** | **3.7%** | **3.0%** | **12.8%** | **2.1%** | **-1.7%** | **-0.3%** | **2.1%** |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ (NIS) សៀវភៅស្ថិតិប្រចាំឆ្នាំ ២០០៣

*r/ - តួលេខបាន់ស្មានក្រោយពេលកែសំរួល*

*p/ - តួលេខបាន់ស្មានដំបូង*

## តារាងទី ១២. កម្ពុជា: ស្ថានភាពរូបិយវត្ថុ ពីឆ្នាំ ១៩៩៧ — ២០០៣

| ខែ ធ្នូ | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 |
|---|---|---|---|---|---|---|---|
| | | | | **ពាន់លានរៀល - ចុងគ្រា** | | | |
| ទ្រព្យសកម្មបរទេស(សុទ្ធ) | 1,172 | 1,728 | 2,019 | 2,588 | 3,081 | 3,737 | 4,033 |
| ទ្រព្យសកម្មបរទេស | 1,597 | 2,203 | 2,508 | 3,047 | 3,587 | 4,279 | 4,749 |
| ទ្រព្យអកម្មបរទេស | 425 | 475 | 489 | 459 | 507 | 542 | 716 |
| ធនាគារជាតិ (សុទ្ធ) | 808 | 1,425 | 1,649 | 2,102 | 2,429 | 3,220 | 3,505 |
| ទ្រព្យសកម្ម | 1,033 | 1,675 | 1,924 | 2,389 | 2,740 | 3,598 | 3,907 |
| ទ្រព្យអកម្ម | 225 | 251 | 275 | 286 | 311 | 379 | 402 |
| ប្រាក់បញ្ញើនៅធនាគារ (សុទ្ធ) | 363 | 304 | 370 | 486 | 651 | 517 | 528 |
| ទ្រព្យសកម្ម | 564 | 528 | 585 | 659 | 847 | 681 | 842 |
| ទ្រព្យអកម្ម | 200 | 224 | 214 | 173 | 196 | 164 | 314 |
| ទ្រព្យសកម្មក្នុងស្រុក (សុទ្ធ) | -109 | -498 | -576 | -758 | -877 | -849 | -741 |
| ឥណទានផ្តល់អោយផ្នែកសេដ្ឋកិច្ច (សុទ្ធ) | 697 | 839 | 876 | 904 | 868 | 942 | 1,202 |
| រដ្ឋាភិបាល (សុទ្ធ) | 54 | 179 | 103 | 3 | -75 | -119 | -128 |
| ធនាគារជាតិ | 58 | 182 | 107 | 4 | -75 | -78 | -37 |
| ប្រាក់បញ្ញើនៅធនាគារ | -4 | -4 | -4 | 0 | 0 | -41 | -91 |
| សហគ្រាសសាធារណ: | 6 | 6 | 10 | 3 | 7 | 2 | 14 |
| សហគ្រាសឯកជន | 637 | 655 | 763 | 898 | 936 | 1,059 | 1,330 |
| យថាប្រភេទឯទៀត (សុទ្ធ) | -805 | -1,337 | -1,453 | -1,662 | -1,744 | -1,791 | -1,943 |
| មូលធន និងធនបំរុង | -875 | -1,387 | -1,451 | -1,541 | -1,959 | -1,943 | -2,069 |
| ផ្សេងៗ | 70 | 50 | -2 | -121 | 314 | 248 | 235 |
| រូបិយវត្ថុទូទៅ | 1,063 | 1,230 | 1,443 | 1,831 | 2,204 | 2,888 | 3,292 |
| រូបិយវត្ថុក្នុងន័យចង្អៀត | 385 | 543 | 532 | 540 | 610 | 813 | 935 |
| រូបិយវត្ថុក្នុងចរាចរ | 356 | 509 | 490 | 495 | 578 | 766 | 904 |
| ប្រាក់បញ្ញើចរន្ត | 29 | 34 | 42 | 45 | 32 | 47 | 31 |
| រូបិយវត្ថុផ្សេងៗ | 678 | 687 | 911 | 1,291 | 1,594 | 2,075 | 2,357 |
| ប្រាក់បញ្ញើមានកាលកំណត់ | 13 | 20 | 32 | 46 | 56 | 74 | 77 |
| ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស | 665 | 667 | 879 | 1,245 | 1,539 | 2,001 | 2,281 |
| | | | | (បំរែបំរួលជាភាគរយនៃសន្និធិរូបិយវត្ថុទូទៅ) | | | |
| *យថាប្រភេទអនុស្សរណ:* | | | | | | | |
| ទ្រព្យសកម្មបរទេស (សុទ្ធ) | 32.2 | 52.4 | 23.6 | 39.5 | 26.9 | 29.8 | 10.2 |
| ទ្រព្យសកម្មបរទេស | 40.4 | 57.1 | 24.8 | 37.4 | 29.5 | 31.4 | 16.3 |
| ទ្រព្យអកម្មបរទេស | 85.0 | 4.7 | 1.2 | -2.1 | 2.6 | 1.6 | 6.0 |
| ទ្រព្យសកម្មក្នុងស្រុក (សុទ្ធ) | -15.6 | -36.6 | -6.3 | -12.6 | -6.5 | 1.3 | 3.7 |
| ឥណទានក្នុងស្រុក (សុទ្ធ) | 14.2 | 13.4 | 3.0 | 2.0 | -2.0 | 3.4 | 9.0 |
| ឥណទានផ្តល់អោយរដ្ឋាភិបាល (សុទ្ធ) | -8.1 | 11.7 | -6.1 | -6.9 | -4.3 | -2.0 | -0.3 |
| ផ្សេងៗ | 22.3 | 1.7 | 9.2 | 8.9 | 2.3 | 5.4 | 9.8 |
| យថាប្រភេទឯទៀត (សុទ្ធ) | -29.7 | -50.1 | -9.4 | -14.5 | 0.1 | -6.7 | -6.1 |
| រូបិយវត្ថុទូទៅ | 16.6 | 15.7 | 17.3 | 26.9 | 20.4 | 31.1 | 14.0 |
| រូបិយវត្ថុ | 6.1 | 14.9 | -0.9 | 0.5 | 3.8 | 9.2 | 4.2 |
| រូបិយវត្ថុផ្សេងៗ | 10.5 | 0.8 | 18.2 | 26.4 | 16.6 | 21.8 | 9.8 |
| ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (ជាលានដុល្លារអាមេរិក) | 193 | 176 | 233 | 319 | 395 | 509 | 573 |
| GDP នាមនាម (ពាន់លានរៀល) | 9,927 | 11,609 | 13,131 | 13,810 | 14,544 | 15,667 | 16,748 |
| អនុបាតបំរែបំរួល 1/ | 10.6 | 10.5 | 9.7 | 7.8 | 7.2 | 6.2 | 5.6 |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារអាមេរិក - នៅចុងគ្រា) | 3,452 | 3,780 | 3,770 | 3,905 | 3,895 | 3,930 | 3,980 |

*ប្រភព: ធនាគារជាតិនៃកម្ពុជា ( NBC )*

1/អនុបាតនៃ GDP នាមនាម ធៀបនឹងសន្និធិរូបិយវត្ថុទូទៅ

# តារាងទី ១៤: សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) (កក្កដា - ធ្នូ ឆ្នាំ 2000=100) 1/ | អត្រាអតិផរណា 2/ គិតជា % | អត្រាប្តូរប្រាក់ទីផ្សារ 3/ | អត្រាប្តូរប្រាក់ផ្លូវការ 4/ | អត្រាប្តូរប្រាក់ផ្លូវការ /អត្រាប្តូរបាក់ទីផ្សារ (%) |
|---|---|---|---|---|---|
| 1999 | | | | | |
| មិនា | 140.7 | 8.0 | 3,824 | 3,795 | -0.8 |
| មិថុនា | 144.2 | 4.9 | 3,823 | 3,805 | -0.5 |
| កញ្ញា | 144.0 | 0.7 | 3,917 | 3,900 | -0.4 |
| ធ្នូ | 142.6 | -0.5 | 3,795 | 3,775 | -0.5 |
| 2000 | | | | | |
| មិនា | 140.9 | 0.2 | 3,826 | 3,820 | -0.2 |
| មិថុនា | 139.4 | -3.3 | 3,879 | 3,865 | -0.4 |
| កញ្ញា | 144.3 | 0.2 | 3,910 | 3,880 | -0.8 |
| ធ្នូ | 141.5 | -0.8 | 3,919 | 3,910 | -0.2 |
| 2001 (កក្កដា - ធ្នូ 2000=100) | | | | | |
| មិនា | 100.0 | 0.0 | 3,924 | 3,915 | -0.2 |
| មិថុនា | 99.7 | -0.3 | 3,926 | 3,920 | -0.2 |
| កញ្ញា | 101.3 | 1.3 | 3,960 | 3,945 | -0.4 |
| ធ្នូ | 100.7 | 0.7 | 3,905 | 3,900 | -0.1 |
| 2002 | | | | | |
| មិនា | 102.8 | 2.9 | 3,904 | 3,900 | -0.1 |
| មិថុនា | 102.9 | 3.2 | 3,924 | 3,920 | -0.1 |
| កញ្ញា | 104.5 | 3.2 | 3,970 | 3,950 | -0.5 |
| ធ្នូ | 104.4 | 3.7 | 3,942 | 3,935 | -0.2 |
| 2003 | | | | | |
| មិនា | 105.0 | 2.1 | 3,953 | 3,945 | -0.2 |
| មិថុនា | 104.6 | 1.7 | 3,990 | 3,990 | 0.0 |
| កញ្ញា | 105.1 | 0.5 | 4,002 | 4,005 | 0.1 |
| ធ្នូ | 104.9 | 0.5 | 3,984 | 3,980 | -0.1 |

**តារាងទី ១៥: កម្ពុជា - ជំនួយបរទេសជាផ្លូវការចំពោះថវិកា ឆ្នាំ 1997-2003**

(ពាន់លានរៀល)

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 |
|---|---|---|---|---|---|---|---|
| **ហិរញ្ញប្បទានផ្លូវការសរុបពីបរទេស** | 445.8 | 505.4 | 515.4 | 707.6 | 889.3 | 1,060.6 | 901.9 |
| **ទ្រទ្រង់ថវិកា** | **95.9** | **1.5** | **4.4** | **113.2** | **54.2** | **178.2** | **139.1** |
| អំណោយ | 46.2 | 1.5 | 4.4 | 23.8 | 36.2 | 91.5 | 52.2 |
| ឥណទាន | 49.7 | 0.0 | 0.0 | 89.4 | 18.0 | 86.7 | 86.9 |
| ធនាគារពិភពលោក | 7.2 | 0.0 | 0.0 | 36.9 | 18.0 | 8.9 | 64.5 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 42.5 | 0.0 | 0.0 | 52.5 | 0.0 | 77.8 | 22.4 |
| **ជំនួយគំរោង** | **350.8** | **503.9** | **511.0** | **594.4** | **839.4** | **890.3** | **822.1** |
| អំណោយ | 244.6 | 340.7 | 337.4 | 360.0 | 463.2 | 360.0 | 360.0 |
| ឥណទាន | 97.0 | 168.9 | 166.8 | 232.5 | 355.1 | 501.1 | 494.8 |
| ធនាគារពិភពលោក | 66.4 | 56.3 | 69.8 | 97.8 | 139.3 | 160.8 | 178.6 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 30.6 | 112.6 | 96.6 | 134.7 | 191.3 | 245.1 | 236.4 |
| ក្រៅពីនេះ | .. | .. | .. | .. | 24.5 | 95.2 | 79.8 |
| រង់ចាំការសំរេច | 9.2 | -5.7 | 6.8 | 1.9 | 21.1 | 29.2 | -32.7 |
| **វិលស់** | **-0.9** | **0.0** | **0.0** | **0.0** | **-4.3** | **-8.0** | **-59.3** |

ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមូលនិធិរូបិយវត្ថុអន្តរជាតិ

ប្រសិនបើលោក លោកស្រីចង់បានព័ត៌មានបន្ថែម លោកអ្នកអាចមកមើលបាននៅមជ្ឈមណ្ឌលព័ត៌មាន

ដែលមានអាសយដ្ឋានលេខ ១១៣ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ពីម៉ោង ៩ព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់

និងពីម៉ោង ២ រសៀល ដល់ម៉ោង ៥ ល្ងាច

ទូរស័ព្ទលេខ ( ៨៥៥ - ២៣ ) ២១៣ ៥៣៨

វិអាចមើលតាមប្រព័ន្ធវេបសាយជាភាសាខ្មែរ : www.worldbank.org/kh

ឬ ជាភាសាអង់គ្លេស : www.worldbank.org/kh

**ធនាគារពិភពលោកការិយាល័យប្រចាំនៅកម្ពុជា**

១១៣ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : ( ៨៥៥ – ២៣ ) ២១៣ ៥៣៨

ទូរសារ : ( ៨៥៥ – ២៣ ) ២១០ ៣៧៣

**វេបសាយ** : ជាភាសាខ្មែរ www.worldbank.org.kh

ជាភាសាអង់គ្លេស www.worldbank.org/kh